# មគ្គបដិបត្តិ

## អានាបានស្សតិកម្មដ្ឋាន

### វិសុទ្ធិមគ្គ មហាដីកា

### បាលី-ប្រែ

### ភាគ ២

រួបរួមដោយ

ភិក្ខុ ហាណេក សួស ប៊ុនថន

ផ្សាយចេញពី

ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា

សម្រាប់ធម្មទាន

ព.ស.២៥៦៩ គ.ស.២០២៥

# មគ្គបដិបត្តិ

## អានាបានស្សតិកម្មដ្ឋាន

### វិសុទ្ធិមគ្គ មហាដីកា

បាលី-ប្រែ

### ភាគ ២

រួបរួមដោយ

ភិក្ខុ ហានវោ សួស ប៊ុនថន

ផ្សាយចេញពី

ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា

សម្រាប់ធម្មទាន

ព.ស.២៥៦៩ គ.ស.២០២៥

ឈ្មោះសៀវភៅ **មគ្គបដិបត្តិអានាបានស្សតិ ភាគ ២**

ត្រួតពិនិត្យដោយ ព្រះសាសនមុនី មហាកម្មដ្ឋានាចរិយ

**ហ៊ឹម ប៊ុនធឿន ធម្មត្ថេរោ**

រៀបរៀងដោយ ភិក្ខុ ឋានវរោ **ស្ងួស ប៊ុនថន**

រចនាក្របដោយ មហាឧបាសក **ធឿន ពិសិដ្ឋ**

ឧបត្ថម្ភដោយ អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍

**សុខ អ៊ឹម** ព្រមទាំងបុត្រ **ត្ធូ ឆៃគៀង** និងភរិយា ព្រមទាំងចៅ

បោះពុម្ពលើកទី១ ចំនួន ១,០០០ក្បាល

បោះពុម្ពដោយ ...

ថ្ងៃបោះពុម្ព ថ្ងៃអាទិត្យ ១៥កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ត្រូវនឹងថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៥

ទីកន្លែងធ្វើ ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា

ភូមិភ្នំ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល

ការផ្សាយរបស់ ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា

# ទស្សនកថា

ខ្ញុំព្រះករុណា អាត្មាភាព បានពិនិត្យនូវរាល់ខ្លឹមសារព្រះធម៌សៀវភៅ **មគ្គបដិបត្តិ អាណាបានស្សតិកម្មដ្ឋាន**នេះ ដោយយកចិត្តទុកដាក់បំផុតទៅលើអត្ថន័យ និងពាក្យពេចន៍នៃព្រះធម៌ ដែលបានដកស្រង់ចេញពី **ព្រះ-ត្រៃបិដក អដ្ឋកថា** និង **គម្ពីរវិសុទ្ធិមគ្គ** បានឃើញថា សៀវភៅនេះពិតជាមានសារៈប្រយោជន៍ច្រើនណាស់ សម្រាប់ពុទ្ធសាសនិកជន អ្នកសិក្សាប្រតិបត្តិ និងស្រាវជ្រាវ ស្វែងយល់ព្រះធម៌ របស់ព្រះសម្មាសម្ពុទ្ធ ឱ្យកាន់តែស៊ីជម្រៅទៅលើអត្ថ និងព្យញ្ជនៈ និងរបៀបកិច្ចចម្រើនប្រតិបត្តិ ឱ្យកាន់តែយល់ដាក់ច្បាស់ត្រឹមត្រូវល្អ ងាយស្រួលយកទៅអនុវត្តប្រតិបត្តិ ឆាប់បានសម្រេចគុណធម៌ពិតប្រាកដ ។

អានាបានស្សតិ ជាគោលបដិបត្តិដ៏ឧត្តម ល្អិតផូរផង់មួយចំណែកក្នុងសតិប្បដ្ឋាន ដែលជាផ្លូវមូលតែមួយនាំសត្វឱ្យស្អាតបរិសុទ្ធ រួចចាកសេចក្តីទុក្ខទាំងពួងបាន ។

ខ្ញុំព្រះករុណា អាត្មាភាព ពិតជាមានបីតិសោមនស្សរីករាយដ៏ក្រៃលែងចំពោះការខិតខំប្រឹងប្រែង ចងក្រង រៀបចំ សៀវភៅដ៏មានតម្លៃនេះឡើង គឺជាការបំពេញបន្ថែម នូវបញ្ញាញាណមួយកម្រិតទៀត ដើម្បីជំនួយដល់សតិបញ្ញាដល់ពុទ្ធបរិស័ទទូទៅគ្រប់រូប ឱ្យបានស្គាល់តម្លៃនៃសច្ចធម៌ដ៏បរិសុទ្ធ របស់ព្រះសម្មាសម្ពុទ្ធ ដែលបានត្រាស់ដឹង ពិតជាមានប្រយោជន៍សេចក្តីសុខ សេចក្តីចម្រើន ដល់ទេវតា និងមនុស្សទាំងឡាយពិតមែន ។

សូមឱ្យធម្មទាន ដែលមានរសព្រះធម៌ដ៏ត្រជាក់ក្សេមចាកទុក្ខ ដែលកើតឡើងពីការចម្រើន ព្រះអានាបានស្សតិកម្មដ្ឋាននេះ បានផ្សព្វផ្សាយជ្រាបក្នុងដួងចិត្តសព្វសត្វគ្រប់គ្នាទាំងអស់កុំបីអាក់ខានឡើយ ។

សូមឱ្យព្រះពុទ្ធសាសនា ផ្សាយទូទៅពេញសកលលោក ។ សូមឱ្យលោកទាំងមូល បានទទួលសុខសន្តិភាព និងការរីកចម្រើន អស់កាលជាយូរអង្វែងតរៀងទៅ ។

ថ្ងៃចន្ទ ២កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ពុទ្ធមណ្ឌល ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៥



**ព្រះសាសនមុនី ហ៊ឹម ប៊ុនធឿន ធម្មត្ថេរោ**

# អារម្ភកថា

មុនិន្ទវទនម្ពោជ	កព្ភសម្ភវសុន្ទរី
សរណំ បាណិនំ វាណី	មយ្ហំ បីណយតំ មនំ ។

*សូមព្រះសទ្ធម្មដ៏ល្អស្អាត កើតក្នុងត្របកនៃផ្កាឈូក គឺអំពីព្រះឱសរបស់ព្រះមុនិន្ទ សូមជាទីពឹងរបស់សព្វសត្វទាំងឡាយ សូមញ៉ាំងចិត្តរបស់ខ្ញុំព្រះអង្គឲ្យរីករាយ សាធុ សាធុ សាធុ ។*

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

*វីកិរិយានមស្ការ ថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។*

*ខ្ញុំសូមរំលឹកនឹកដល់គុណព្រះអង្គគ្រូ លោកគ្រូគ្រប់ព្រះអង្គ និងគ្រប់ៗរូប គុណព្រះមហាថេរៈ គុណព្រះថេរៈ គុណឪពុក គុណម្តាយ គុណញាតិមិត្ត និងសព្វសត្វទាំងអស់ក្នុងសេចក្តីល្អ ។ ដោយអំណាចនៃការធ្វើបទនមស្ការ និងការរំលឹកនឹកគុណនេះ សូមអន្តរាយទាំងឡាយទាំងពួងកុំមកបៀតបៀន និងរារាំងឡើយ សូមឱ្យការធ្វើសៀវភៅនេះសូមបានសម្រេច និងមានសេចក្តីសុខគ្រប់យ៉ាងជារៀងរហូតតទៅ សាធុ សាធុ សាធុ ។*

*សៀវភៅដែលព្រះគុណម្ចាស់ និងញាតិញោមកំពុងតែកាន់ក្នុងព្រះហស្ត និងក្នុងដៃនេះ ជាការរួបរួមឡើង ដោយអាស្រ័យបានសិក្សាជាមួយព្រះ-អាចារ្យ* **បញ្ញាធរោ មហាណាម៉ុន** *និងគ្រូអាចារ្យ* **សុភី ថុមថន** *ក្នុងថ្ងៃទី ១រោច ខែចេត្រ ឆ្នាំកុរ ព.ស. ២៥៦២, ត្រូវនឹងថ្ងៃទី២០ ខែមេសា គ.ស. ២០១៩ មកដល់ថ្ងៃទី ១រោច ខែជេស្ឋ ឆ្នាំខាល ព.ស. ២៥៦៦, ត្រូវនឹងថ្ងៃទី ១៥ ខែមិថុនា គ.ស. ២០២២ ។ ហើយនៅថ្ងៃទី១១រោច ខែជេស្ឋ ឆ្នាំខាល ព.ស. ២៥៦៦ ត្រូវនឹង*

ថ្ងៃទី២៥ ខែមិថុនា គ.ស. ២០២២ ដែលរូបអាត្មាភាពបានសេចក្តីអនុគ្រោះអំពីព្រះអង្គគ្រូសាសនមុនី មហាកម្មដ្ឋានាចរិយ **ហ៊ឹម ប៊ុនធឿន ធម្មត្ថេរោ** បានមករស់នៅក្នុងពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបានសិក្សានូវកម្មដ្ឋានបន្តទៀតក្នុងសម្នាក់របស់ព្រះអង្គគ្រូ រហូតមកដល់សព្វថ្ងៃនេះ ។ ក្នុងឱកាសគង់នៅពុទ្ធមណ្ឌលវិបស្សនាធុរៈនេះឯង ដែលខ្ញុំបានសិក្សាបន្តទៀត និងបានធ្វើសៀវភៅនេះឡើង ព្រោះថា កាលគង់នៅក្នុងសម្នាក់របស់ព្រះអាចារ្យ **បញ្ញាធរោ មហាណាប៊ុន** នាប្រទេសថៃនោះ ឯកសារទាំងអស់នោះនៅជាសំណៅសរសេរដៃនៅឡើយ ទើបមកដល់ពុទ្ធមណ្ឌលវិបស្សនាធុរៈ ទើបបានចម្លងចូលក្នុងកុំព្យូទ័រ ។ ហើយក្នុងការរួបរួមនេះ ខ្ញុំព្រះករុណាអាត្មាភាពប្រារព្ធក្នុងបុព្វហេតុបីយ៉ាងគឺ ៖

១. ខ្ញុំព្រះករុណាអាត្មាភាព មើលឃើញថា សៀវភៅដែលបរិយាយលម្អិតអំពីកិច្ចបដិបត្តិ ពុំសូវមានច្រើន ពិសេសសំដៅវិធីសាស្ត្រនៃការចម្រើនកម្មដ្ឋានឱ្យបានត្រឹមត្រូវទៅតាមពុទ្ធឱវាទរបស់ព្រះសម្មាសម្ពុទ្ធ ។

២. ខ្ញុំព្រះករុណាអាត្មាភាព មើលឃើញថា ការបដិបត្តិសមាធិ ចាប់ផ្តើមមានការចាប់អារម្មណ៍ច្រើនឡើងៗអំពីសម្នាក់ពុទ្ធបរិស័ទ និងត្រូវការរបៀបបដិបត្តិឱ្យត្រឹមត្រូវមួយតាមក្បួនច្បាប់គម្ពីរ និងចៀសវាងការបដិបត្តិខុស ។

៣. ខ្ញុំព្រះករុណាអាត្មាភាព មើលឃើញថា ឯកសារជាភាសាបរទេស មានភាសាថៃ ភូមា ជាដើម គេបានស្រាវជ្រាវ និងចងក្រងទុកមានច្រើន ដើម្បីសម្រួលដល់ការយល់ត្រូវក្នុងផ្លូវបដិបត្តិ តែជាភាសាខ្មែរមិនទាន់សម្បូរទេ ។

ដោយហេតុយ៉ាងនេះ អាត្មាភាពចាប់ផ្តើមចំណាយពេលវេលាដើម្បីរួបរួមឯកសារនេះទុកទៅតាមគម្ពីរ ព្រះត្រៃបិដក អដ្ឋកថា និងមហាដីកា ព្រមទាំងបកប្រែពីភាសាបរទេសមកបន្ថែមទៀត ដើម្បីសង្ខាយសេចក្តីឱ្យកាន់តែច្បាស់លាស់ ក្នុងកិច្ចបដិបត្តិសមាធិនេះ ។

*គោលបំណងក្នុងការរៀបរៀងសៀវភៅនេះ គឺដើម្បីរក្សានូវ* ***សម្មា-បដិបទា*** *ក្នុងការអប់រំចម្រើននូវសមាធិភាវនា ។ ម្យ៉ាងវិញទៀត ដើម្បីផ្ដល់កម្លាំងចិត្តដល់ព្រះយោគាវចរគ្រប់រូប ជាអ្នកត្រេកអរក្នុងវិវេកធម៌ មានព្រៃស្ងាត់ ទៀបគល់ឈើ និងផ្ទះស្ងាត់ជាដើម ។ ម្យ៉ាងវិញទៀតដើម្បីថែរក្សា នូវត្រៃសិក្ខា ពោលគឺ* ***សីល សមាធិ*** *និង****បញ្ញា*** *ដូចមានក្នុងគម្ពីរវិសុទ្ធិមគ្គបានសម្ដែងទុកមកថា* ***លម្អបទដើម*** *ព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសសម្ដែងដោយ* ***សីល***, ***លម្អបទកណ្ដាល*** *ទ្រង់ប្រកាសសម្ដែងដោយ* ***សមាធិ***, *និង****លម្អបទចុង*** *ទ្រង់ប្រកាសសម្ដែងដោយ* ***បញ្ញា*** *។ ចំណុចសំខាន់នៃសៀវភៅ អានាបានស្សតិកម្មដ្ឋាន នេះ មានការបំភ្លឺជុំវិញ នៃការអប់រំអានាបានស្សតិ ដើម្បីចៀសវាងការបដិបត្តិ ចូលទៅកាន់ មិច្ឆាសមាធិ ដែលជាសត្រូវដល់ សម្មាសមាធិ ហើយក្នុងសៀវភៅនេះ មានគោលអាងពីភាសាបាលី ចេញពីព្រះត្រៃបិដក អដ្ឋកថា និងមហាដីកាគម្ពីរវិសុទ្ធិមគ្គ ទៀតផង ។*

*ខ្ញុំព្រះករុណាអាត្មាភាព សូមបូជាសៀវភៅមួយភាគនេះដល់ព្រះពុទ្ធ-សាសនា ហើយសង្ឃឹមថា សៀវភៅនេះនឹងបានជាប្រទីប ក្នុងការធ្វេះបញ្ចាំងនូវ****សម្មាបដិបទា*** *ដល់ព្រះយោគាវចរគ្រប់ៗរូប ដែលជាអ្នកត្រេកអរក្នុងត្រៃសិក្ខា និងបានជាប្រយោជន៍ដល់មហាជនជាច្រើនគ្នាផងដែរ ។ ដោយអំណាចនៃសេចក្ដីព្យាយាមរបស់អាត្មាភាព សូមឱ្យយើងខ្ញុំទាំងឡាយ និងសព្វសត្វទាំងអស់ បាននូវ សេចក្ដីចម្រើន បានជាប្រយោជន៍ បាននូវសេចក្ដីសុខ ជារៀងរហូត ក្នុងកាលជាបច្ចុប្បន្ននេះ និងបានជាបច្ច័យក្នុងការរួចផុតចាកទុក្ខ ពោលគឺបានដល់****ព្រះនិព្វាន****ឆាប់ៗ នៅឯខាងមុខនេះផង សាធុ សាធុ សាធុ ។*

រតនត្តយតេជេន កម្ពោជរដ្ឋវាសិនោ
វុឌ្ឍី វិរូឡ្ហីបប្បោន្តុ សន្តិភាវញ្ច ជាញ្ញថា ។

*ដោយតេជៈនៃព្រះរតនៈត្រៃ សូមឱ្យប្រជាជនទាំងឡាយអ្នករស់នៅក្នុងកម្ពុជរដ្ឋដល់នូវការលូតលាស់រីកចម្រើន និងសន្តិភាព កុំបីឃ្លាងឃ្លាតទៅជា*

បការៈដទៃទៀយ ។

ពុទ្ធមណ្ឌលវិបស្សនាធុរៈនៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១២រោច ខែជេស្ឋ ឆ្នាំម្សាញ់ ព.ស.២៥៦៩

ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០២៥ ។

**ភិក្ខុ ឋានវរោ សួស ប៊ុនថន**

# វាចារអ្នករៀបរៀង

ការរៀបរៀងឡើងនូវសៀវភៅ "**អានាបានស្សតិកម្មដ្ឋាន**" នេះ ខ្ញុំព្រះករុណា បានរៀបរៀងទៅតាមព្រះបាលី នៃព្រះត្រៃបិដក ហើយរួមជាមួយអដ្ឋកថា និងមហាដីកា ដែលមានសេចក្តីប្រែជា ខេមរភាសា និងរៀបរៀងទៅតាមលំដាប់នៃមាតិកានីមួយៗ យ៉ាងផ្ចិតផ្ចង់បំផុត មិនឱ្យឃ្លៀងឃ្លាតពីច្បាប់ដើមឡើយ ដើម្បីបានជាប្រយោជន៍ដល់កុលបុត្រជាអ្នកជ្រះថ្លា ក្នុងព្រះរតនៈត្រ័យ និងជាពិសេសដើម្បីជាប្រយោជន៍ ដល់ការសិក្សារបស់ព្រះយោគាវចរគ្រប់ៗរូប ងាយស្រួលក្នុងការសិក្សារៀនសូត្រ និងបដិបត្តិឱ្យបានត្រឹមត្រូវទៅតាមព្រះធម៌ព្រះវិន័យរបស់ព្រះសម្មាសម្ពុទ្ធនៃយើង ។ សៀវភៅនេះបានលម្អិតច្បាស់លាស់អំពីកម្មដ្ឋាននិងពន្យល់អត្ថសេចក្តីច្បាស់លាស់ទៅតាមព្រះពុទ្ធដីកា ។

ដើម្បីងាយយល់ក្នុងការអាន យោគីបដិបត្តិគប្បីយល់អំពីលំដាប់នៃការរួបរួមនេះ ដោយផ្តើមអំពីពុទ្ធដីកាជាគោល បន្ទាប់មកគម្ពីរវិសុទ្ធិមគ្គសង្ខាយ-សេចក្តីលើអត្ថនីមួយៗនៃព្រះពុទ្ធដីកា ហើយមហាដីកាវិសុទ្ធិមគ្គអធិប្បាយបញ្ជាក់បន្ថែមទៀតលើសេចក្តីនៃវិសុទ្ធិមគ្គ។ បន្ទាប់មកវិសុទ្ធិមគ្គពន្យល់អំពីរបៀបនៃការបដិបត្តិកម្មដ្ឋានទៅតាមពុទ្ធដីកានោះ ហើយមហាដីកាពន្យល់បន្ថែមលើវិធីអធិប្បាយរបស់វិសុទ្ធិមគ្គ។

សៀវភៅដែលឈ្មោះថា **មគ្គបដិបត្តិអានាបានស្សតិកម្មដ្ឋាន**នេះ មកពីពាក្យថា **មគ្គ** ប្រែថា ផ្លូវ **បដិបត្តិ** ប្រែថា ប្រព្រឹត្តិតាម **អាន** ប្រែថា ខ្យល់ដង្ហើមចូល **អបាន** ប្រែថា ខ្យល់ដង្ហើមចេញ **សតិ** ប្រែថា កំណត់ដឹង **កម្មដ្ឋាន** ប្រែថា ហេតុជាទីតម្កល់នៃបរិកម្ម ដូច្នេះ បានសេចក្តីថា ការប្រាប់ផ្លូវនៃកម្មដ្ឋានមួយ ដែលមានការកំណត់ដឹងនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញមកជាអារម្មណ៍ ។ សៀវភៅមួយនេះកើតឡើងមកពីការរួបរួម**គម្ពីរវិសុទ្ធិមគ្គ និងបរមត្ថមញ្ជុសា វិសុទ្ធិមគ្គមហាដីកា** ដើម្បីទុកឱ្យសេចក្តីរបស់អានាបានស្សតិបានជាប់តសេចក្តីគ្នាងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ និងយកទៅបដិបត្តិតាម ។ ព្រះពុទ្ធឃោសាចារ្យ ជាព្រះអាចារ្យដ៏ឈ្លាសវាងវៃ ក្នុង

ព្រះពុទ្ធវចនៈ បានលើកយកសេចក្ដីក្នុងការបដិបត្តិទាំងនោះ មកទុកក្នុងគម្ពីរវិសុទ្ធមគ្គ ដែលជាគម្ពីរមួយដ៏សំខាន់ក្នុងការប្រព្រឹត្តបដិបត្តិកម្មដ្ឋាន ។ រួចហើយព្រះថេរៈព្រះនាមថា ធម្មបាលថេរៈ លោកបានអធិប្បាយសេចក្ដីនោះយ៉ាងស៊ីជម្រៅបន្ថែមទៀតដែលគម្ពីរនោះឈ្មោះថា **បរមត្ថមញ្ជុសា វិសុទ្ធិមគ្គមហាដីកា** ការរួបរួមមកមានប្រមាណប៉ុណ្ណោះ ជាការអធិប្បាយផ្នែកសមថៈដែលនៅក្នុងចតុក្កទី ១ ប៉ុណ្ណោះ គោលដៅនៅក្នុងសៀវភៅនេះ គឺសំដៅយកផ្នែកសមថៈជាគោល ហើយសៀវភៅសមថៈនេះ ខ្ញុំអធិប្បាយបានយ៉ាងត្រឹមត្រូវទៅតាមលំដាប់ចាប់តាំងទី១ ពាក្យថានិមិត្ត, ទី២ ពាក្យថាបរិកម្មនិមិត្ត, ទី៣ ពាក្យថាឧគ្គហនិមិត្ត និងទី៤ ពាក្យថាបដិភាគនិមិត្ត ចំណែកវិធីពិនិត្យអង្គឈាន ផ្ទើវសីនិងការចូលកាន់ឈានទៅតាមលំដាប់នោះនឹងមានការអធិប្បាយនៅសៀវភៅភាគ ៣ បន្តបន្ទាប់ទៀត ។

សៀវភៅនេះ មានការអធិប្បាយតាមលេខឃ្លៀបទាំងវិសុទ្ធិមគ្គ និងមហា-ដីកាទៅតាមលំដាប់ ជាលេខឃ្លៀបរបស់ឆដ្ឋសង្គាយនាលើកទី ៦ ដើម្បីងាយស្រួលដល់អ្នកសិក្សាចង់ដឹងនូវអត្ថសេចក្ដីនីមួយៗឱ្យបានជាក់ច្បាស់ និងទៅតាមលំដាប់នីមួយៗ ក្នុងការងាយស្រួលដល់អ្នកសិក្សា ។ ហើយមូលហេតុដែលខ្ញុំរៀបឱ្យមានជាភាសាបាលី ប្រែៗ បែបនេះ ព្រោះថា កាលបើរៀបឱ្យមានតែភាសាប្រែតែយ៉ាងនោះ ប្រាកដណាស់ថានឹងមានអ្នកអាននឹងចង់បាននូវភាសាបាលីមកមើលផង ហើយម្យ៉ាងទៀតភាសាប្រែសុទ្ធនោះ លោកអ្នកប្រាជ្ញលោកបានប្រែរួចមកហើយ ដូច្នេះក្នុងការតម្រូវសម្រាប់អ្នកសិក្សាស្រាវជ្រាវផងនឹងឱ្យកាន់តែស៊ីជម្រៅផង ទើបតម្រូវឱ្យមានទាំងភាសាបាលី ប្រែ សម្រាប់បំពេញចំណេះដឹងបន្ថែមទៀត ពិសេសការយល់កាន់តែច្បាស់ប្រាកដផង ។

ភិក្ខុ ហានវរោ សួស ប៊ុនថន

# **បដិការគុណកថា**

១. ព្រះសាសនមុនី មហាកម្មដ្ឋានាចរិយ **ហ៊ឹម ម៉ុនធឿន ធម្មត្ថេរោ** ព្រះអង្គគ្រូជាអ្នកបង្ហាត់បង្រៀននូវកម្មដ្ឋាន ជួយត្រួតពិនិត្យសៀវភៅ និងជាអ្នកចង្អុលបង្ហាញប្រាប់នូវអត្ថសេចក្ដី

២. ព្រះអាចារ្យ **បញ្ញាធរោ មហាណាម៉ុន** ជាអ្នកបង្ហាត់បង្រៀននូវកម្មដ្ឋាន និងប្រាប់ពន្យល់នូវអត្ថសេចក្ដី ។

៣. គ្រូអាចារ្យ **សុតី ថុមថង** ជាអ្នកបង្រៀននូវកម្មដ្ឋានប្រាប់ពន្យល់នូវអត្ថសេចក្ដីដោយភាសាបាលីប្រែ

៤. ព្រះមហា វជិរធម្មោ **វ៉ាត សាធុឌ្ឍ** ជួយពិនិត្យកែអក្ខរាវិរុទ្ធ

៥. ព្រះភិក្ខុ បញ្ញាបទីបោ **ឡេង ធី** ជួយពិនិត្យកែអក្ខរាវិរុទ្ធ

៦. ព្រះមុនីចរិយាវង្ស **ហ៊ុនខេមរា** ប្រធានក្នុងការដឹកនាំប្រែសៀវភៅ និងពិនិត្យកែសម្រួលទូទៅ

៧. ព្រះទេពវិចិត្រ **ប៉ាច សុផុន** ចាត់ចែកក្នុងការបោះពុម្ពសៀវភៅ

៨. ព្រះមហា រតនសុភោ **សូ រុន** ជួយពិនិត្យកែអក្ខរាវិរុទ្ធ

៩. ព្រះភិក្ខុ សារានន្ទោ **ឡាំ សុផាត** ជួយពិនិត្យកែអក្ខរាវិរុទ្ធ

៦. សាមណេរ សុវណ្ណជោតោ **ហាម ស៊ុយ** ជួយពិនិត្យកែអក្ខរាវិរុទ្ធ និងកែសម្រួលសៀវភៅ

៧. ឧបាសក **ធឿន ពិសិដ្ឋ** រចនាក្រប និងកែសម្រួលសៀវភៅ

៨. មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក **រ័ត្ន ភារនីនាដ្យ** ជួយពិនិត្យកែអក្ខរាវិរុទ្ធ ។

# ឧទ្ទិសកថា

*ដោយអំណាចវីរិយភាព ដែលខ្ញុំព្រះករុណាអាត្មាភាព និងក្រុមការងារ គណៈកម្មការពុទ្ធមណ្ឌលវិបស្សនាធុរៈទាំងអស់ ដែលបានប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការរៀបចំបោះពុម្ពសៀវភៅ* **មគ្គបដិបត្តិអានាបានស្សតិ** *ដែលជាក្បួនច្បាប់របស់ព្រះពុទ្ធសាសនាថេរវាទ ។*

*សៀវភៅនេះមានគុណតម្លៃយ៉ាងក្រៃលែងណាស់ មិនអាចកាត់ថ្លៃបាន ហើយបានរៀបចំបោះពុម្ពទុកដាក់សម្រាប់ជាធម្មទាន ។ ដោយសទ្ធាទឹកចិត្តជ្រះថ្លាប្រកបដោយ មហាកុសល ដ៏ថ្លៃថ្លាប្រសើរខ្ពង់ខ្ពស់ទាំងអស់នេះ! ខ្ញុំព្រះករុណា សូមថ្វាយប្រគេន នូវមហាកុសលនេះឧទ្ទិសជូនចំពោះ* **សម្តេចព្រះមហាសង្ឃរាជ សម្តេចព្រះសង្ឃនាយក សម្តេចព្រះមន្ត្រីសង្ឃ** *គ្រប់ឋានានុក្រម ជាពិសេស* **សម្តេចមហាសង្ឃរាជ ជោតញ្ញាណោ ជួន ណាត** *និងក្រុមជំនុំបកប្រែគម្ពីរព្រះត្រៃបិដកគ្រប់អង្គ/នាក់ និងប្រគេនចំពោះព្រះគ្រូឧបជ្ឈាយាចារ្យ កម្មដ្ឋានគ្រប់ៗព្រះអង្គ មានព្រះអង្គគ្រូ* **ព្រះធម្មវិបស្សនា កេតុធម្មោ សំ ប៊ុនធឿន** *ជាដើម ។*

*ជាពិសេសជូនចំពោះ ញោមប្រុស ឧបាសក* **ឡៅ ផុន** *និង ញោមស្រី ឧបាសិកា* **រស់ ស្រឿន** *ព្រមទាំងពពួកញាតិ និងអ្នកមានគុណូបការៈទាំងអស់ក្នុងសង្សារវដ្ត ។*

*សូមអនុមោទនា ផលានិសង្សនៃធម្មទាននេះ ហើយទទួលបានបរមសុខក្នុងសុគតិភព ជាភិយ្យោភាពតរៀងទៅ កុំបីឃ្លៀងឃ្លាតឡើយ ។*

*សូមអនុមោទនា សាធុ សាធុ សាធុ!*

*ថ្ងៃពុធ ១១រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*

*ពុទ្ធមណ្ឌល ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥*

**ភិក្ខុ ឋានវរោ សួស ប៊ុនថន**

# ឧបត្ថម្ភកថា

**គណៈកម្មការបោះពុម្ព និងផ្សព្វផ្សាយ**
**ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា**
**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ**

អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ មហាសទ្ធម្មជោតិកធជ **សុខ អ៊ីម** ព្រមទាំងបុត្រ **តូ នៃគៀង** និងភរិយាព្រមទាំងចៅ ដែលមានឧបការៈគុណដ៏ធំធេងចំពោះព្រះពុទ្ធសាសនា ដែលបានចំណាយទ្រព្យធនជានផ្ទាល់ខ្លួន ដើម្បីជួយឧបត្ថម្ភបោះពុម្ពសៀវភៅ "**មគ្គបដិបត្តិអានាបានស្សតិកម្មដ្ឋាន ភាគ ២**" លើកទី១ ចំនួន១,០០០ ក្បាល សម្រាប់ទុកជាធម្មទាន ។

សូមឱ្យអគ្គមហាឧបាសិកា មហាសទ្ធម្មជោតិកធជៈ ព្រមទាំងបុត្រ និងចៅ បានសម្រេចនូវសម្បត្តិជាន់ខ្ពស់គឺ លោកិយសម្បត្តិ និងលោកុត្តរសម្បត្តិ កុំបីឃ្លាងឃ្លាតឡើយ ។

ព.ស.២៥៦៩ គ.ស.២០២៥

# មាតិកាធម៌


ទស្សនកថា......................................................................................III

អារម្ភកថា ......................................................................................V

វាចាអ្នករួបរួម..................................................................................IX

បដិការគុណកថា...............................................................................XI

ឧទ្ទិសកថា .....................................................................................XII

ឧបត្ថម្ភកថា....................................................................................XIII

មាតិកាធម៌ .....................................................................................XIV

**អានាបានស្សតិកថា** ....................................................................... ១

កថាពោលអំពីអានាបានស្សតិ (វិសុទ្ធិមគ្គ) ........................................ ១

បតុក្កៈទី ១ៈ ពួកកាយ ..................................................................... ៣

បតុក្កៈទី ២ ពួកវេទនា ..................................................................... ៤

បតុក្កៈទី ៣ ពួកចិត្ត.......................................................................... ៥

បតុក្កៈទី ៤ ពួកធម្មា ........................................................................ ៦

អានាបានស្សតិកថាវណ្ណនា ........................................................... ៩

ការពណ៌នាអានាបានស្សតិកថា (មហាដីកាវិសុទ្ធិមគ្គ ) ................... ៩

កថំ ភាវិតោ ច ......................................................................... ១២

**អធិប្បាយពាក្យសួរក្នុងព្រះបាលី** ( **វិសុទ្ធិមគ្គ** ) ............................. ១២

ពាក្យថាអានាបានស្សតិសមាធិ មានអត្ថន័យពីរយ៉ាង................ ១៣

អធិប្បាយពាក្យ សន្តោ ចេវ បណីតោ ច....................................... ១៤

អធិប្បាយពាក្យ អសេចនកោ ........................................ ១៥
កបំ ភាវិតោ ច (មហាដីកាវិសុទ្ធិមគ្គ) ..................................១៧
ពាក្យថា ឥធ ភិក្ខវេ ភិក្ខុ (វិសុទ្ធិមគ្គ)................................... ៣១
ទីកន្លែងបដិបត្តិដែលសមគួរ ............................................ ៣២
ព្រះសាស្តាបង្ហាញនូវទីកន្លែង ........................................... ៣៦
ពាក្យថា ឥធ ភិក្ខវេ ភិក្ខុ (មហាដីកាវិសុទ្ធិមគ្គ)............................ ៣៨
អធិប្បាយ លក្ខណៈព្រៃ (វិសុទ្ធិមគ្គ) ..................................... ៤៣
ការតម្កល់នូវកាយ........................................................... ៤៤
ការតម្កល់នូវសតិ ........................................................... ៤៦
ទីសេនាសនៈ ៧ យ៉ាង (មហាដីកាវិសុទ្ធិមគ្គ)..............................៤៧
សោ សតោវ អស្សសតិ សតោ បស្សសតិ (វិសុទ្ធិមគ្គ) ................... ៥២
អធិប្បាយពាក្យថា អស្សាសបស្សាស........................................ ៥៤
ខ្យល់ដង្ហើមរបស់មនុស្ស...................................................... ៥៦
អានាបានស្សតិជាកាយានុបស្សនាសតិប្បដ្ឋាន...........................៥៧
**ចតុក្កៈទី ១ លំដាប់ទី ១ និងទី ២** ........................................ ៥៨
ការកំណត់ដឹងនូវខ្យល់ដង្ហើម ៩ យ៉ាង (វិសុទ្ធិមគ្គ) ...................... ៥៨
សោ សតោវ អស្សសតិ សតោ បស្សសតិ (មហាដីកាវិសុទ្ធិមគ្គ) .... ៦៣
អាការៈ ៩ យ៉ាង..................................................................៧១
វិធីចម្រើនអាការៈ ៩ យ៉ាង .....................................................៧៤
ឆន្ទៈ រមែងកើតឡើង...........................................................៧៥

ពេលពន្លឺបដិភាគនិមិត្តកើតឡើង ........................................ ៧៦
**ចតុក្កៈទី ១ លំដាប់ទី ៣** ........................................ ៨២
សព្វកាយប្បដិសំវេទី (វិសុទ្ធិមគ្គ) ........................................ ៨២
ត្រូវព្យាយាមឱ្យបញ្ញាកើតឡើង ........................................ ៨៨
សព្វកាយប្បដិសំវេទី (មហាដីកាវិសុទ្ធិមគ្គ) ........................................ ៩២
**ចតុក្កៈទី ១ លំដាប់ទី ៤** ........................................ ៩៩
បស្សម្ភយំ កាយសង្ខារំ (វិសុទ្ធិមគ្គ) ........................................ ៩៩
ការបង្អោនចិត្តទៅរកកម្មដ្ឋានមាន ៤ ចំណុច ........................................ ១០២
លំដាប់នៃឈាន តាមន័យសមថ (វិសុទ្ធិមគ្គ) ........................................ ១០៤
តាមន័យ វិបស្សនា ........................................ ១០៦
ការឧបមា ........................................ ១១១
ការឧបមេយ្យ ........................................ ១១៣
លំដាប់នៃឈាន តាមន័យសមថ (មហាដីកាវិសុទ្ធិមគ្គ) ........................................ ១១៥
បស្សម្ភយំ កាយសង្ខារំ ........................................ ១២៣
ការឧបមា ........................................ ១២៨
វិធីហ្វឹកហាត់ (វិសុទ្ធិមគ្គ) ........................................ ១៣២
រៀនតាមតំណ ៥ យ៉ាង ........................................ ១៣៣
វិធីហ្វឹកហាត់ (មហាដីកាវិសុទ្ធិមគ្គ) ........................................ ១៣៥
**វិធីមនសិការ ៨ យ៉ាង** (**វិសុទ្ធិមគ្គ**) ........................................ ១៣៩
កុលបុត្រអាទិកម្មិកបដិបត្តិកម្មដ្ឋានគួររាប់ ........................................ ១៤០

ការពប់ដោយយឺតៗ តាមអ្នកវាល់ស្រូវ.................................... ១២១
ការពប់រហ័ស តាមអ្នកចិញ្ចឹមគោ............................................ ១២៣
វិធីមនសិការ ៨ យ៉ាង (មហាដីកាវិសុទ្ធិមគ្គ) .............................១២៧
ការពប់រហ័ស......................................................................... ១៥២
ការពប់ដោយមានអនុពន្ធនា (វិសុទ្ធិមគ្គ)................................. ១៥៤
អធិប្បាយពាក្យ អនុពន្ធនា (មហាដីកាវិសុទ្ធិមគ្គ)....................... ១៥៨
ប្រៀបដូចជាមនុស្សខ្វិនយោលទោង (វិសុទ្ធិមគ្គ) ....................... ១៦៦
មនុស្សខ្វិនយោលទោង (មហាដីកាវិសុទ្ធិមគ្គ) ...........................១៦៧
ប្រៀបដូចជាមនុស្សយាមទ្វារ (វិសុទ្ធិមគ្គ) ................................ ១៦៩
ឧបមា មនុស្សយាមទ្វារក្រុង (មហាដីកាវិសុទ្ធិមគ្គ)....................១៧០
ឧបមា ដោយរណារដៃ (វិសុទ្ធិមគ្គ)............................................ ១៧០
ការឧបមា ..............................................................................១៧២
ការឧបមេយ្យ...........................................................................១៧២
ឧបមា ដោយរណារដៃ (មហាដីកាវិសុទ្ធិមគ្គ) ............................១៧៦
**ការកើតឡើងនៃបរិកម្មនិមិត្ត ( វិសុទ្ធិមគ្គ )** ..................................... ១៨៦
ការកើតឡើងនៃបរិកម្មនិមិត្ត (មហាដីកាវិសុទ្ធិមគ្គ).................. ១៨៩
មកដល់ខ្យល់ល្អិតសុខុម (វិសុទ្ធិមគ្គ) ........................................ ១៩៣
ឧបាយ កំណត់ដឹងខ្យល់ឡើងវិញ ........................................... ១៩៤
ខ្យល់ល្អិតសុខុម (មហាដីកាវិសុទ្ធិមគ្គ)........................................ ១៩៦
ឧបមា ឧបមេយ្យ (វិសុទ្ធិមគ្គ) ....................................................២០០

ការឧបមា ........................................................................ ២០២

ការឧបមេយ្យ...................................................................... ២០៣

ឧបមា ឧបមេយ្យ (មហាដីកាវិសុទ្ធិមគ្គ) .................................. ២០៤

**ឧគ្គហនិមិត្ត និងបដិភាគនិមិត្ត មាន ១៧ (វិសុទ្ធិមគ្គ)**................. ២០៦

ការវិនិច្ឆ័យរបស់ព្រះអដ្ឋកថា ..............................................២០៧

ឧគ្គហនិមិត្ត និង បដិភាគនិមិត្ត (មហាដីកាវិសុទ្ធិមគ្គ) ............... ២១១

ការទូន្មានរបស់លោកអាចារ្យ (វិសុទ្ធិមគ្គ) ................................ ២១៥

ការទូន្មានរបស់លោកអាចារ្យ (មហាដីកាវិសុទ្ធិមគ្គ).................. ២១៨

**ការកំណត់នាម និងរូប (វិសុទ្ធិមគ្គ)**............................................. ២២៤

ការកំណត់នាម និងរូប (មហាដីកាវិសុទ្ធិមគ្គ) .......................... ២២៧

វេទនានុបស្សនា ចតុក្កៈទី ២ (វិសុទ្ធិមគ្គ) .................................. ២៣២

វេទនានុបស្សនា ចតុក្កៈទី ២ (មហាដីកាវិសុទ្ធិមគ្គ).................. ២៣៨

ចិត្តានុបស្សនា ចតុក្កៈទី ៣ (វិសុទ្ធិមគ្គ).................................... ២៥៣

ចិត្តានុបស្សនា ចតុក្កៈទី ៣ (មហាដីកាវិសុទ្ធិមគ្គ).......................២៥៧

ធម្មានុបស្សនា ចតុក្កៈទី ៤ (វិសុទ្ធិមគ្គ)........................................ ២៦៦

ធម្មានុបស្សនា ចតុក្កៈទី ៤ (មហាដីកាវិសុទ្ធិមគ្គ).......................២៧១

**អានិសង្សរបស់អានាបានស្សតិ (វិសុទ្ធិមគ្គ)**.................................. ២៨០

អានិសង្សរបស់អានាបានស្សតិ (មហាដីកាវិសុទ្ធិមគ្គ)............... ២៨២

ចរិមក(មានទីបំផុត) ៣ យ៉ាង (វិសុទ្ធិមគ្គ)................................. ២៨៤

ចរិមក (មហាដីកាវិសុទ្ធិមគ្គ) ................................................ ២៨៩

ធម៌បដិបក្ខគ្នា........................................................................ ២៩៣
ពាក្យថានិមិត្ត មាន ២ ប្រភេទ ................................................ ២៩៣
ពាក្យថា និមិត្ត.......................................................................... ២៩៣
**បរិកម្មនិមិត្តមាន ៤ លំដាប់**........................................................ ២៩៤
លំដាប់ទី ១ ................................................................................ ២៩៤
លំដាប់ទី ២ ................................................................................ ២៩៤
លំដាប់ទី ៣ ................................................................................ ២៩៥
លំដាប់ទី ៤ ................................................................................ ២៩៥
**ឧគ្គហនិមិត្ត និងបដិភាគនិមិត្តមាន១៧ ប្រភេទ**............................ ២៩៦
សមាធិមាន ៣ ប្រភេទ.................................................................. ២៩៧
សង្ខេបមាន ៤ ចំណុច ................................................................. ២៩៧
ចំណុចសំខាន់របស់សមាធិមាន ៣ យ៉ាង................................ ២៩៩
ឯកសារយោង ............................................................................ ៣០០

# អានាបានស្សតិកថា

## កថាពោលអំពីអានាបានស្សតិ

( **វិសុទ្ធិមគ្គ** )

[២១៤] ឥទានិ យំ តំ ភគវតា"អយម្បិ ខោ, ភិក្ខវេ, អានាបានស្សតិសមាធិ ភាវិតោ ពហុលីកតោ សន្តោ ចេវ បណីតោ ច អសេចនកោ ច សុខោ ច វិហារោ, ឧប្បន្នុប្បន្នេ ច បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតី"តិ **ឯវំ បសំសិត្វា។**

*ក្នុងកាលឥឡូវនេះ អានាបានស្សតិសមាធិកម្មដ្ឋានឯណា* ***ដែល ព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរហើយ យ៉ាងនេះថា*** *"ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិនេះឯង ដែលព្រះយោគីភិក្ខុបានចម្រើនហើយ បានធ្វើឱ្យច្រើនហើយ ជាធម៌ល្អិតផង ជាធម៌ដ៏ឧត្តមផង ជាធម៌ដែលមិនប្រឡូកប្រឡំដោយ (តណ្ហា និងឧបាទាន) ផង ធម៌ជាគ្រឿងនៅ នាំមកនូវសេចក្ដីសុខផង តែងញុំាងធម៌ទាំងឡាយ ដែលជាអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ឱ្យអន្តរធានបាត់ទៅ ឱ្យស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរ" យ៉ាងដូច្នេះ។*

**"កថំ ភាវិតោ ច, ភិក្ខវេ, អានាបានស្សតិសមាធិ កថំ ពហុលីកតោ សន្តោ ចេវ បណីតោ ច អសេចនកោ ច សុខោ ច វិហារោ, ឧប្បន្នុប្បន្នេ ច បាបកេ អកុសលេ ធម្មេ ឋានសោ អន្តរធាបេតិ វូបសមេតិ?[១] ។**

*"ម្នាលភិក្ខុទាំងឡាយ ចុះអានាបានស្សតិសមាធិ ដែលបុគ្គលបានចម្រើនហើយ យ៉ាងដូចម្ដេច? បានធ្វើឱ្យច្រើនហើយ យ៉ាងដូចម្ដេច? ទើបជាធម៌ដែលល្អិតផង ជាធម៌ដ៏ឧត្តមផង ជាធម៌ដែលមិនប្រឡូកប្រឡំដោយ (តណ្ហា និង*

*១ ចាប់ផ្ដើមពីទំព័រ១២ទៅ នឹងមានការខែសេចក្ដីបន្ថែមនូវបទបាលីនីមួយៗដូចជា កថំ ភាវិតោ ជាដើម ។*

*ឧបាទាន)ផង ធម៌ជាគ្រឿងនៅ នាំមកនូវសេចក្តីសុខ (ជាសុខវិហារធម៌) ផង, តែងញ៉ាំងធម៌ទាំងឡាយ ដែលជាអកុសលធម៌ដ៏លាមក ដែលបានកើតឡើងហើយ ឱ្យអន្តរធានបាត់ទៅ ឱ្យស្ងប់រម្ងាប់ទៅ ដោយហេតុដ៏សមគួរផង ។*

**ឥធ,ភិក្ខវេ, ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ។**[២]

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់គល់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី រួចហើយអង្គុយពែនភ្នែន ។*

**ឧជុំ កាយំ បណិធាយ ។**

*តាំងកាយឱ្យត្រង់ ។*

**បរិមុខំ សតឹ ឧបដ្ឋបេត្វា ។**

*ហើយតម្កល់សតិស្មារតី ឱ្យមានមុខឆ្ពោះទៅរកព្រះកម្មដ្ឋាន (គឺតម្កល់សតិ នៅត្រង់ចុងច្រមុះ ឬក៏ផ្ទៃបបូរមាត់ខាងលើ) ។*

**សោ សតោវ អស្សសតិ, សតោ បស្សសតិ ។**

*ព្រះយោគាវចរភិក្ខុនោះ ជាអ្នកមានសតិស្មារតីតម្កល់ (នៅត្រង់ចុងច្រមុះ ឬក៏ផ្ទៃបបូរមាត់ខាងលើ) ខណៈដកដង្ហើមចូល កំណត់ដឹងថាចូល, ជាអ្នកមានសតិស្មារតីតម្កល់ (នៅត្រង់ចុងច្រមុះ ឬក៏ផ្ទៃបបូរមាត់ខាងលើ) ខណៈដកដង្ហើមចេញ កំណត់ដឹងថាចេញ ។*

---

២ *ចាប់ផ្តើមពីទំព័រ៣១ទៅ នឹងមានការខែសេចក្តីបន្ថែមនូវបទបាលីនីមួយៗដូចជា ឥធ ភិក្ខវេ ភិក្ខុ ជាដើម ។*

## ចតុក្កៈទី ១: ពួកកាយ[៣]

១. ទីឃំ វា អស្សសន្តោ "ទីឃំ អស្សសាមី"តិ បជានាតិ ។

*ព្រះយោគាវចរភិក្ខុរូបនោះ កាលដកដង្ហើមចូលវែង ក៏កំណត់ដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចូលវែង" ។*

ទីឃំ វា បស្សសន្តោ "ទីឃំ បស្សសាមី"តិ បជានា"តិ ។

*កាលដកដង្ហើមចេញវែង ក៏កំណត់ដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចេញវែង" ។*

២. រស្សំ វា អស្សសន្តោ "រស្សំ អស្សសាមី"តិ បជានាតិ។

*កាលដកដង្ហើមចូលខ្លី ក៏កំណត់ដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចូលខ្លី" ។*

រស្សំ វា បស្សសន្តោ "រស្សំ បស្សសាមី"តិ បជានាតិ។

*កាលដកដង្ហើមចេញខ្លី ក៏កំណត់ដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចេញខ្លី" ។*

៣. "សព្វកាយប្បដិសំវេទី អស្សសិស្សាមី"តិ សិក្ខតិ។

*ភិក្ខុរមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងឱ្យជាក់ច្បាស់នូវកាយ គឺខ្យល់ដង្ហើមចូលទាំងអស់ ជាចំណែកៗដោយល្អ (គឺខាងដើម កណ្តាល និងខាងចុងរបស់ខ្យល់) ក្នុងខណៈដកដង្ហើមចូល" ។*

---

*៣ ការចម្រើនព្រះអានាបានស្សតិ ដោយបរិបូណ៌ មានដូចជាចតុក្កៈនេះ មានតែនៅក្នុងសាសនាព្រះសម្មាសម្ពុទ្ធតែមួយគត់ ក្នុងអានាបានស្សតិសូត្រ នៃមជ្ឈិមនិកាយ ព្រះសូត្រទី១១៨ ព្រះដ៏មានព្រះភាគបានសម្តែងការចម្រើនព្រះអានាបានស្សតិ ជា១៦ប្រការ ហើយ១៦ប្រការនេះ ក៏ចែកទៅជាចតុក្កៈ៤ ចតុក្កៈនីមួយៗ មាន៤ប្រការ ដែលបានបែងចែកជា ចតុក្កៈទី១ ទី២ ទី៣ ទី៤ ហើយចតុក្កៈ៤នេះ យើងអាចប្រៀបធៀបទៅសតិប្បដ្ឋាន៤ដែរ ។*
*ចតុក្កៈទី១ កាយានុបស្សនា ចតុក្កៈទី ២ វេទនានុបស្សនា ចតុក្កៈទី៣ ចិត្តានុបស្សនា ចតុក្កៈទី ៤ ធម្មានុបស្សនា ។*

**"សព្វកាយប្បដិសំវេទី បស្សសិស្សាមី"តិ សិក្ខតិ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងឱ្យជាក់ច្បាស់នូវកាយ គឺខ្យល់ដង្ហើមចេញទាំងអស់ ជាចំណែកៗដោយល្អ (គឺខាងដើម កណ្ដាល និងខាងចុងរបស់ខ្យល់) ក្នុងខណៈដកដង្ហើមចេញ" ។*

**៤. "បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមី"តិ សិក្ខតិ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកធ្វើកាយសង្ខារគឺខ្យល់ដង្ហើមដែលគ្រោតគ្រាតៗ ឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចូល ។*

**"បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមី"តិ សិក្ខតិ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកធ្វើកាយសង្ខារគឺខ្យល់ដង្ហើមដែលគ្រោតគ្រាតៗ ឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចេញ" ។*

## ចតុក្កៈទី ២ ពួកវេទនា

**៥. "បីតិប្បដិសំវេទី អស្សសិស្សាមី"តិ សិក្ខតិ ។**

*ភិក្ខុរមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងចែកឱ្យជាក់ច្បាស់ដោយល្អនូវបីតិ ក្នុងខណៈដកដង្ហើមចូល" ។*

**"បីតិប្បដិសំវេទី បស្សសិស្សាមី"តិ សិក្ខតិ ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងចែកឱ្យជាក់ច្បាស់ដោយល្អនូវបីតិ ក្នុងខណៈដកដង្ហើមចេញ" ។*

**៦. "សុខប្បដិសំវេទី អស្សសិស្សាមី"តិ សិក្ខតិ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងចែកឱ្យជាក់ច្បាស់ដោយល្អនូវសុខ ក្នុងខណៈដកដង្ហើមចូល" ។*

**"សុខប្បដិសំវេទី បស្សសិស្សាមី"តិ សិក្ខតិ ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងចែកឱ្យជាក់ច្បាស់ដោយល្អនូវសុខ ក្នុងខណៈដកដង្ហើមចេញ" ។*

**៧. "ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមី"តិ សិក្ខតិ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងចែកឱ្យជាក់ច្បាស់ដោយល្អនូវចិត្តសង្ខារ (គឺវេទនាខន្ធ និងសញ្ញាខន្ធ) ក្នុងខណៈដកដង្ហើមចូល"។*

**"ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមី"តិ សិក្ខតិ ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងចែកឱ្យជាក់ច្បាស់ដោយល្អ នូវចិត្តសង្ខារ (គឺវេទនាខន្ធ និងសញ្ញាខន្ធ) ក្នុងខណៈដកដង្ហើមចេញ" ។*

**៨. "បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមី"តិ សិក្ខតិ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នករម្ងាប់នូវចិត្តសង្ខារ (គឺខ្យល់ដង្ហើមដែលគ្រោតគ្រាតៗ) ក្នុងខណៈដកដង្ហើមចូល" ។*

**"បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមី"តិ សិក្ខតិ ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នករម្ងាប់នូវចិត្តសង្ខារ (គឺខ្យល់ដង្ហើមដែលគ្រោតគ្រាតៗ) ក្នុងខណៈដកដង្ហើមចេញ" ។*

## ចតុក្កៈទី ៣ ពួកចិត្ត

**៩. "ចិត្តប្បដិសំវេទី អស្សសិស្សាមី"តិ សិក្ខតិ។**

*ភិក្ខុរមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងចែកឱ្យជាក់ច្បាស់ដោយល្អនូវចិត្ត ក្នុងខណៈដកដង្ហើមចូល" ។*

**"ចិត្តប្បដិសំវេទី បស្សសិស្សាមី"តិ សិក្ខតិ ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងចែកឱ្យជាក់ច្បាស់ដោយល្អនូវចិត្ត ក្នុងខណៈដកដង្ហើមចេញ" ។*

១០. "អភិប្បមោទយំ ចិត្តំ អស្សសិស្សាមី"តិ សិក្ខតិ។

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកញុំាងចិត្តឱ្យរីករាយ ក្នុងខណៈដកដង្ហើមចូល" ។*

"អភិប្បមោទយំ ចិត្តំ បស្សសិស្សាមី"តិ សិក្ខតិ ។

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកញុំាងចិត្តឱ្យរីករាយ ក្នុងខណៈដកដង្ហើមចេញ" ។*

១១. "សមាទហំ ចិត្តំ អស្សសិស្សាមី"តិ សិក្ខតិ។

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកញុំាងចិត្តឱ្យតាំងនៅក្នុងអារម្មណ៍ដ៏ស្មើៗ ក្នុងខណៈដកដង្ហើមចូល" ។*

"សមាទហំ ចិត្តំ បស្សសិស្សាមី"តិ សិក្ខតិ ។

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកញុំាងចិត្តឱ្យតាំងនៅក្នុងអារម្មណ៍ដ៏ស្មើៗ ក្នុងខណៈដកដង្ហើមចេញ" ។*

១២. "វិមោចយំ ចិត្តំ អស្សសិស្សាមី"តិ សិក្ខតិ។

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកញុំាងចិត្តឱ្យរួចផុតស្រឡះ (ចាកពីនីវរណធម៌ជាដើម) ក្នុងខណៈដកដង្ហើមចូល" ។*

"វិមោចយំ ចិត្តំ បស្សសិស្សាមី"តិ សិក្ខតិ ។

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកញុំាងចិត្តឱ្យរួចផុតស្រឡះ (ចាកពីនីវរណធម៌ជាដើម) ក្នុងខណៈដកដង្ហើមចេញ" ។*

## ចតុក្កៈទី ៤ ពួកធម្មា

១៣. "អនិច្ចានុបស្សី អស្សសិស្សាមី"តិ សិក្ខតិ។

*ភិក្ខុរមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកពិចារណាឃើញរឿយៗ (នូវ*

*បញ្ចក្ខន្ធ) ថា មិនទៀង ក្នុងខណៈដកដង្ហើមចូល" ។*

**"អនិច្ចានុបស្សី បស្សសិស្សាមី"តិ សិក្ខតិ ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកពិចារណាឃើញរឿយៗ (នូវបញ្ចក្ខន្ធ)ថា មិនទៀង ក្នុងខណៈដកដង្ហើមចេញ" ។*

**១៤. "វិរាគានុបស្សី អស្សសិស្សាមី"តិ សិក្ខតិ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកពិចារណាឃើញរឿយៗ នូវធម៌ជាគ្រឿងធ្វើចិត្តឱ្យប្រាសចាកនូវតម្រេក ក្នុងខណៈដកដង្ហើមចូល" ។*

**"វិរាគានុបស្សី បស្សសិស្សាមី"តិ សិក្ខតិ ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកពិចារណាឃើញរឿយៗ នូវធម៌ជាគ្រឿងធ្វើចិត្តឱ្យប្រាសចាកនូវតម្រេក ក្នុងខណៈដកដង្ហើមចេញ" ។*

**១៥. "និរោធានុបស្សី អស្សសិស្សាមី"តិ សិក្ខតិ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកពិចារណាឃើញរឿយៗ នូវធម៌សម្រាប់រំលត់នូវកងទុក្ខ ក្នុងខណៈដកដង្ហើមចូល" ។*

**"និរោធានុបស្សី បស្សសិស្សាមី"តិ សិក្ខតិ ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកពិចារណាឃើញរឿយៗ នូវធម៌សម្រាប់រំលត់នូវកងទុក្ខ ក្នុងខណៈដកដង្ហើមចេញ" ។*

**១៦. "បដិនិស្សគ្គានុបស្សី អស្សសិស្សាមី"តិ សិក្ខតិ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកពិចារណាឃើញរឿយៗ នូវធម៌ជាគ្រឿងសម្រាប់លះនូវកិលេសចេញ (ព្រមទាំងខន្ធ និងអភិសង្ខារខន្ធ បានដល់វិបស្សនាមគ្គ) ក្នុងខណៈដកដង្ហើមចូល" ។*

**"បដិនិស្សគ្គានុបស្សី បស្សសិស្សាមី"តិ សិក្ខតី"តិ –**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកពិចារណាឃើញរឿយៗ នូវធម៌ជាគ្រឿងសម្រាប់លះនូវកិលេសចេញ (ព្រមទាំងខន្ធ និងអភិសង្ខារខន្ធ បានដល់វិបស្សនាមគ្គ) ក្នុងខណៈដកដង្ហើមចេញ" ដូច្នេះឯង ។*[៤]

**ឯវំ សោឡសវត្ថុកំ អានាបានស្សតិកម្មដ្ឋានំ និទ្ទិដ្ឋំ ។**

*អានាបានស្សតិកម្មដ្ឋាន**មានវត្ថុ១៦** (**ឬ១៦ចំណុច**) ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សរសើរទុកមកហើយ យ៉ាងនេះឯង ។*

**តស្ស ភាវនានយោ អនុប្បត្តោ ។**

*និទ្ទេស នៃការចម្រើននូវអានាបានស្សតិកម្មដ្ឋាននោះ មកដល់ហើយទៅតាមលំដាប់ ។*

**សោ បន យស្មា ចាឡិវណ្ណនានុសារេនេវ វុច្ចមានោ សព្វាការប-រិបូរោ ហោតិ ។**

*ប៉ុន្តែ ព្រោះហេតុដែលនិទ្ទេសនៃការចម្រើននូវអានាបានស្សតិកម្មដ្ឋានដែលនឹងពោលទៅដល់នោះ និងមាន**បរិបូរណ៍ដោយអាការៈទាំងពួង** ទៅតាមព្រះបាលីប៉ុណ្ណោះ ។*

**តស្មា អយមេត្ថ ចាឡិវណ្ណនាបុព្វង្គមោ និទ្ទេសោ។**

*ព្រោះហេតុនោះ តទៅនេះ**ជានិទ្ទេស**ដែលមានពាក្យពណ៌នារបស់ព្រះត្រៃបិដកជាខាងដើមនៅក្នុងអានាបានស្សតិកម្មដ្ឋាននេះ ។*

---

*៤ ចាប់ពីឃ្នាបទី២១៥ ដល់វត្ថុទី១៦ចុងក្រោយ នៃចតុក្កៈទី៤ ជាព្រះពុទ្ធដីកា*

# អានាបានស្សតិកថាវណ្ណនា

# ការពណ៌នាអានាបានស្សតិកថា

**( មហាដីកាវិសុទ្ធិមគ្គ )**

[២១៤] យំ តំ ឯវំ បសំសិត្វា អានាបានស្សតិកម្មដ្ឋានំ និទ្ទិដ្ឋន្តិ សម្ពន្ធោ

*សេចក្តីថា អានាបានស្សតិកម្មដ្ឋាន ដែលព្រះមានព្រះភាគទ្រង់ត្រាស់សរសើរហើយ សម្តែងអធិប្បាយយ៉ាងនេះ ។*

តត្ថ យស្មា "**កថំ ភាវិតោ**"តិអាទិកាយ បុច្ឆាបាឡិយា អត្ថេ វិភាវិតេ ថោមនាបាឡិយាបិ អត្ថោ វិភាវិតោយេវ ហោតិ ភេទាភាវតោ, តស្មា តំ លង្ឃិត្វា "**កថំ ភាវិតោ ច**"តិអាទិនា អារភតិ។

*ក្នុងពាក្យទាំងឡាយនោះ កាលនឹងបើកផ្សារបង្ហាញនូវអត្ថសេចក្តីនៃព្រះបាលី ដែលជាសំណួរ មានពាក្យថា "**កថំ ភាវិតោ**" ជាដើមហើយ គឺបានបើកផ្សារនូវព្រះបាលី អត្ថសេចក្តីនៃព្រះបាលីដែលជាពាក្យសរសើរសុទ្ធសាធ ព្រោះមិនមានសេចក្តីផ្សេងគ្នាទេ, ព្រោះដូច្នោះ លោកអាចារ្យ ទើបកន្លងនូវអត្ថនៃព្រះបាលី ដែលជាពាក្យសរសើរនោះចេញ ហើយផ្តើមនូវពាក្យថា "**កថំ ភាវិតោ ច**" ដូច្នេះ ជាដើម ។*

តត្ថ ហិ ឥតោ បសំសាភាគេ "អយម្បិ ខោ"តិ វចនញ្ច វិសេសោ។

*ក្នុងបណ្តាពាក្យទាំងឡាយនោះ សេចក្តីត្រង់កម្មដ្ឋានដែលទ្រង់ត្រាស់សរសើរហើយ និងពាក្យថា "**អយម្បិ ខោ**" ចាត់ជាការផ្សេងគ្នាអំពីកម្មដ្ឋាននេះ ។*

តេសុ បសំសាភាវំ ទស្សេតុំ "**ឯវំ បសំសិត្វា**"តិ វុត្តំ។

*ក្នុងបណ្តាសេចក្តីដែលផ្សេងគ្នានោះ លោកអាចារ្យមានបំណងនឹងសម្តែងនូវអត្ថរបស់កម្មដ្ឋាន ដែលព្រះអង្គទ្រង់ត្រាស់សរសើរ ទើបពោលពាក្យ*

*ថា "ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរហើយ ទុកយ៉ាងនេះ" ដូច្នេះ ។*

**បសំសា ច តត្ថ អភិរុចិជននេន ឧស្សាហជននត្ថា ។**

*ពាក្យដែលព្រះអង្គទ្រង់ត្រាស់សរសើរ ជាការធ្វើឱ្យព្រះយោគាវចរយកចិត្តទុកដាក់ កើតទៅជាប្រយោជន៍ ព្រោះធ្វើឱ្យគាប់ចិត្តកាន់តែខ្លាំងឡើងក្នុងអានាបានស្សតិកម្មដ្ឋាននោះ ។*

**តញ្ហិ សុត្វា ភិក្ខូ "ភគវា ឥមំ សមាធឹ អនេកេហិ អាការេហិ បសំសតិ, សន្តោ ចាយំ សមាធិ បណីតោ ច អសេចនកោ ច សុខោ ច វិហារោ ចាបកេ ច ហនសោ អន្តរធាបេតី"តិ សញ្ជាតាភិរុចយោ ឧស្សាហជាតា សក្កច្ចំ អនុយុញ្ជិតព្វំ បដិបជ្ជិតព្វំ មញ្ញន្តិ។**

*ពិតហើយ ភិក្ខុទាំងឡាយបានស្តាប់ហើយ នូវព្រះតម្រាស់សរសើរនោះហើយ ជាអ្នកមានសេចក្តីពេញចិត្តជាខ្លាំង ដោយគិតថា "ព្រះមានព្រះភាគទ្រង់ត្រាស់សរសើរនូវសមាធិនេះ ដោយអនេកបរិយាយ, ក្នុងន័យថា សមាធិនេះស្ងប់ផង សមាធិនេះប្រណីតផង រៀបរយផង ជាសុខវិហារធម៌ផង ញ៉ាំងធម៌ដែលឃើតយូរទាំងឡាយឱ្យអន្តរធានបាត់ទៅដោយឆាប់រហ័សផង" ដូច្នេះ ជាអ្នកមានសេចក្តីព្យាយាមកើតឡើង នឹងសំគាល់បានថា ជាកម្មដ្ឋានដែលគប្បីប្រកបរឿយៗ និងគប្បីបដិបត្តិដោយសេចក្តីគោរពកោតក្រែងយ៉ាងក្រៃលែង ។*

**"អយម្បិ ខោ"តិ បទស្ស យេ ឥមេ មយា និព្វានមហាសរស្ស ឱតរណតិត្ថភូតា កសិណជ្ឈានអសុភជ្ឈានាទយោ ទេសិតា, ន កេវលំ តេ ឯវ, អយម្បិ ខោតិ ភគវា អត្តនោ បច្ចក្ខភូតំ សមាធឹ ទេសនានុភាវេន តេសម្បិ ភិក្ខូនំ អាសន្នំ, បច្ចក្ខញ្ច ករោន្តោ សម្បិណ្ឌនវសេន ឯវមាហាតិ សម្ពន្ធមុខេន អត្ថោ វេទិតព្វោ។**

*សម្រាប់បទថា "**អយម្បិ ខោ**" បណ្ឌិតគប្បីជ្រាបនូវសេចក្តី តាមបែបនេះថា ព្រះមានព្រះភាគ កាលទ្រង់ចម្រើននូវសមាធិ ជាធម្មជាតិដែលព្រះអង្គ*

*ឃើញប្រចក្សច្បាស់ហើយ ឱ្យបិតនៅក្នុងទីជិត ឃើញបានប្រចក្សច្បាស់ដល់ភិក្ខុទាំងឡាយនោះ ដោយអានុភាពនៃព្រះធម្មទេសនា ទើបទ្រង់ត្រាស់សម្ដែងទុកដោយអំណាចការរួបរួម (ដោយ* **បិ សទ្ទ**) *យ៉ាងនេះថា សមាធិទាំងឡាយ មានកសិណឈាន និងអសុភឈាន ជាដើម វាជាកំពង់សម្រាប់ចុះទៅកាន់ស្រះទឹកដ៏ធំ គឺព្រះនិព្វាន ដែលព្រះតថាគតបានសំដែងទុករួចមកហើយយ៉ាងណា, ព្រះតថាគត មិនបានសំដែងទុកចំពោះសមាធិទាំងនោះតែម្យ៉ាងប៉ុណ្ណោះទេ, អានាបានស្សតិសមាធិនេះ តថាគតបានសម្ដែងទុករួចមកហើយផងដែរ ។*

"**សោឡសវត្ថុកា**"ន្តិ ចតូសុ អនុបស្សនាសុ ចតុន្នំ ចតុក្កានំ វសេន សោឡសដ្ឋានំ។

*ពាក្យថា "**មានវត្ថុ ១៦**" គឺមាន ១៦ ចំណុច ដែលជាប់ទាក់ទងទៅនឹងមួយចតុក្កៗ មាន (៤ ក្រុម) ហើយមាន ៤ ចតុក្ក ក្នុងបណ្ដាអនុបស្សនា ៤ (គឺមានកាយានុបស្សនា ១ ចតុក្ក, ក្នុងវេទនានុបស្សនា ១ ចតុក្ក, ក្នុងចិត្តានុបស្សនា ១ ចតុក្ក និងក្នុងធម្មានុបស្សនា ១ ចតុក្ក) ។*

"**សព្វាការបរិបូរោ**"តិ កម្មដ្ឋានចាឡិយា បទត្ថោ បិណ្ឌត្ថោ ឧបមា ចោទនា បរិហារោ បយោជនន្តិ ឯវមាទីហិ សព្វេហិ អាការេហិ បរិបុណ្ណោ។

*ពាក្យថា "**បរិបូរណ៍ដោយអាការៈទាំងពួង**" គឺបរិបូរណ៍ដោយអាការៈទាំងពួង យ៉ាងនេះគឺ អត្ថនៃបទព្រះបាលីកម្មដ្ឋាន អត្ថនៃពាក្យរួបរួម ជាការឧបមា ជាសំនួរ និងជាចម្លើយដែលមានប្រយោជន៍ ដូច្នេះជាដើម ។*

"**និទ្ទេសោ**"តិ កម្មដ្ឋានស្ស និស្សេសតោ វិត្ថារោ។

*ពាក្យថា "**និទ្ទេស**" បានដល់ ជាពាក្យអធិប្បាយស្រាយបំភ្លឺនូវសេចក្ដីនៃកម្មដ្ឋាន ដោយមិនឱ្យនៅសេសសល់ ។*

## កថំ ភាវិតោ ច

## អធិប្បាយពាក្យសួរក្នុងព្រះបាលី

(**វិសុទ្ធិមគ្គ**)

[២១៦] កថំ ភាវិតោ ច, ភិក្ខវេ, អានាបានស្សតិ សមាធីតិ ឯត្ថ តាវ "**កថ**"ន្តិ អានាបានស្សតិសមាធិភាវនំ នានប្បការតោ វិត្ថារេតុកម្យតា-បុច្ឆា។

*បណ្ឌិតគប្បីជ្រាបនូវនិទ្ទេសនៃព្រះបាលីបុច្ឆា ថា "***កថំ ភាវិតោ ច, ភិក្ខវេ អានាបានស្សតិសមាធិ***" ប្រែថា ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលព្រះយោគាវចរភិក្ខុចម្រើនហើយ* ***តើដោយបការៈដូចម្តេច?*** *ជាដើមសិន, ពាក្យថា "***កថំ*** *ប្រែថា* ***តើដោយបការៈដូចម្តេច?****" ជាព្រះបុច្ឆាដែលព្រះអង្គទ្រង់ប្រាថ្នានឹងត្រាស់សម្តែងនូវវិធីចម្រើនអានាបានស្សតិសមាធិធ្វើសេចក្តីឱ្យពិស្តារដោយប្រការផ្សេងៗ ។*

"**ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធី**"តិ នានប្បការតោ វិត្ថារេតុកម្យតាយបុដ្ឋធម្មនិទស្សនំ។

*ពាក្យថា "***ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ***"(អានាបានស្សតិសមាធិនេះ ដែលព្រះយោគាវចរភិក្ខុចម្រើនឱ្យកើតឡើង) ជាពាក្យ ដែលទ្រង់បង្ហាញដល់ធម៌ដែលព្រះអង្គបានត្រាស់សួរទុកមកហើយ ព្រោះទ្រង់មានព្រះបំណងនឹងត្រាស់សម្តែងនូវសេចក្តីនោះឱ្យពិស្តារដោយប្រការផ្សេងៗ ។*

"**កថំ ពហុលីកតោ។...បេ...។** រូបសមេតី"តិ ឯត្ថាបិ ឯសេវ នយោ។

*សូម្បីក្នុងពាក្យបុច្ឆាថា "* **កថំ ពហុលីកតោ។...បេ...។ រូបសមេតិ**" *ប្រែថា ធ្វើឱ្យច្រើនហើយ ។...ល...។ ឱ្យអន្តរធានបាត់ទៅ ឱ្យស្ងប់រម្ងាប់ទៅដោយហេតុដ៏សមគួរ តើដោយប្រការដូចម្តេច? ក៏មានន័យសេចក្តីដូចគ្នា ។*

តត្ថ "**ភាវិតោ**"តិ ឧប្បាទិតោ វឌ្ឍិតោ វា។

*ក្នុងបទទាំងឡាយនោះ បទថា "**ភាវិតោ**" ប្រែថា ដែលព្រះយោគាវចរភិក្ខុធ្វើឱ្យកើតឡើង ឬ ចម្រើនឱ្យកើតឡើង ។*

## ពាក្យថាអានាបានស្សតិសមាធិ មានអត្ថន័យពីរយ៉ាង

"**អានាបានស្សតិសមាធី**"តិ អានាបានបរិគ្គាហិកាយ សតិយា សទ្ធឹ សម្បយុត្តោ សមាធិ ។

*ន័យទី ១ បទថា "**អានាបានស្សតិសមាធិ**" ប្រែថា សមាធិដែលប្រកបរួមជាមួយសតិ ដែលកំណត់ដឹងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ (មកជាអារម្មណ៍) ។*

*( សមាធិដែលប្រកបរួមជាមួយសតិ ដែលកំណត់ដឹងនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដោយបាលីថា =* **អានាបានស្សតិយា សម្បយុត្តោ សមាធិ អានាបានស្សតិសមាធិ** *) (មជ្ឈេលោបតតិយាតប្បុរិសសមាស) ។*

អានាបានស្សតិយំ វា សមាធិ អានាបានស្សតិសមាធិ។

*ន័យទី ២ ប្រែថា សមាធិដែលកើតឡើង ព្រោះសតិដែលកំណត់ដឹងនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឈ្មោះថា អានាបានស្សតិសមាធិ ។ ( សមាធិដែលកើតឡើង ព្រោះសតិដែលកំណត់ដឹងនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដោយបាលីថា =* **អានាបានស្សតិយំ សមាធិ អានាបានស្សតិសមាធិ** *) (សត្តមីតប្បុរិសសមាស) ។*

"**ពហុលីកតោ**"តិ បុនប្បុនំ កតោ។

*បទថា "**ពហុលីកតោ**" ប្រែថា* **ធ្វើឱ្យច្រើនហើយ** *គឺធ្វើឱ្យរឿយៗ ។*

## អធិប្បាយពាក្យ សន្តោ ចេវ បណីតោ ច

**"សន្តោ ចេវ បណីតោ ចា"**តិ សន្តោ ចេវ បណីតោ ចេវ។ ឧភយត្ថ ឯវ-សទ្ទេន និយមោ វេទិតព្វោ។

*ទាំង ២ បទថា* **"សន្តោ ចេវ បណីតោ ច"** *នោះ គប្បីអធិប្បាយថា* **សន្តោ ចេវ** *ប្រែថា ស្ងប់ផង,* **បណីតោ ចេវ** *ប្រែថា ប្រណីតផង ។ បណ្ឌិតគប្បីជ្រាបថា មានការប្រើ ឯវ សព្ទ ជាការកំណត់ទុកក្នុងបទបាលីទាំង ២ បទ ។*

**កឹ វុត្តំ ហោតិ? អយញ្ហិ យថា អសុភកម្មដ្ឋានំ កេវលំ បដិវេធវសេន សន្តញ្ច បណីតញ្ច, ឱឡារិការម្មណត្តា បន បដិក្កូលារម្មណត្តា ច អារម្មណវសេន នេវ សន្តំ ន បណីតំ, ន ឯវំ កេនចិ បរិយាយេន អសន្តោ វា អបណីតោ វា, អថ ខោ អារម្មណសន្តតាយបិ សន្តោ វូបសន្តោ និព្វុតោ, បដិវេធសង្ខាតអង្គសន្តតាយបិ។**

*សួរថា តើពាក្យនោះសំដៅ ដូចម្តេច? ដែលព្រះមានព្រះភាគទ្រង់ត្រាស់ហើយ? ឆ្លើយថា ព្រះអង្គទ្រង់ត្រាស់ថា "មែនពិត អសុភកម្មដ្ឋាន ជាធម្មជាតិដែលស្ងប់ និងប្រណីត ដោយអំណាចការចាក់ធ្លុះ (គឺការបានឈាន) តែម្យ៉ាង, ព្រោះតែមានអារម្មណ៍គ្រោតគ្រាត និងមានអារម្មណ៍គួរខ្ពើមរអើម ទើបមិនជាធម្មជាតិដែលគួរឱ្យស្ងប់ និងប្រណីតបានទេ ដោយអំណាចនៃអារម្មណ៍, ចំណែកអានាបានស្សតិសមាធិនេះ មិនមែនជាធម៌មិនស្ងប់ មិនមែនជាធម៌មិនប្រណីត ដោយបរិយាយឯណានីមួយនោះទេ, តាមសេចក្តីពិត គឺ អានាបានស្សតិសមាធិនេះ ជាធម្មជាតិដែលស្ងប់ផង ស្ងប់រម្ងាប់ផង ជាធម៌រំលត់ផង ព្រោះមានអារម្មណ៍ស្ងប់, និងស្ងប់ដោយអង្គឈាន ដែលហៅថា ជាការចាក់ធ្លុះ ។*

**អារម្មណាបណីតតាយបិ បណីតោ អតិត្តិការោ, អង្គបណីតតាយបីតិ។**

*ធម្មជាតិដែលប្រណីត គឺធ្វើឱ្យមិនធុញទ្រាន់ ព្រោះតែប្រណីតទាំង*

*អារម្មណ៍ និងប្រណីតទាំងអង្គឈាន ដូច្នោះឯង ។*

**តេន វុត្តំ "សន្តោ ចេវ បណីតោ ចា"តិ។**

*ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា "សន្តោ ចេវ បណីតោ ចេវ" (អានាបានស្សតិសមាធិ) ជាធម៌ស្ងប់ផង និងប្រណីតផង" ។*

## អធិប្បាយពាក្យ អសេចនកោ

**អសេចនកោ ច សុខោ ច វិហារោតិ ឯត្ថ បន នាស្ស សេចនន្តិ អសេចនកោ, អនាសិត្តកោ អព្ពោកិណ្ណោ បាដិយេក្កោ អាវេ-ណិកោ។**

*ចំណែកក្នុងពាក្យថា "**អសេចនកោ ច សុខោ ច វិហារោ** (ជាធម៌មិនប្រឡូកប្រឡំ ដោយការបរិកម្ម ជាដើម) ជាធម៌ដែលជាគ្រឿងនៅនាំមកនូវសេចក្តីសុខផងនេះ" អធិប្បាយថា ឈ្មោះថា **អសេចនក** មិនប្រឡូកប្រឡំ ព្រោះអត្ថថា មិនមាន **សេចនក** វត្ថុដែលលាយផ្សំ, គឺមិនចាំបាច់មកប្របូកប្របល់លាយគ្នា បានដល់ មិនបានមកផ្សំចូលគ្នា ជាការញែកចេញពីគ្នាដោយឡែក ។*

**នត្ថិ ឯត្ថ បរិកម្មេន វា ឧបចារេន វា សន្តតា។**

*សេចក្តីស្ងប់ល្អិត ក្នុងអានាបានស្សតិសមាធិនេះ មិនមានដោយការបរិកម្ម ឬ ដោយឧបចារនោះទេ ។*

**អាទិសមន្នាហារតោ បកុតិ អត្តនោ សភាវេនេវ សន្តោ ច បណីតោ ចាតិ អត្ថោ។**

*សេចក្តីថា អានាបានស្សតិសមាធិនេះ ជាធម៌ស្ងប់ផង ជាធម៌ប្រណីតផង ដោយសភាវៈរបស់ខ្លួនឯងតែម្យ៉ាង គឺចាប់តាំងពីការផ្តើមប្រមូលចិត្តចម្រើនកម្មដ្ឋានជាដំបូងមក ។*

កេចិ បន អសេចនកោតិ អជាសិត្តកោ ឱជវន្តោ សភាវេនេវ មធុរោតិ វទន្តិ។

*ចំណែកឯលោកអាចារ្យពួកខ្លះ បានពោលថា៖ បទថា "**អសេចនកោ**" សេចក្តីថា មិនត្រូវបានគ្រុបសង្កត់ (ដោយកិលេស) គឺមានឱជារសឆ្ងាញ់ ដូចទឹកឃ្មុំ ទៅតាមសភាវៈធម៌ហ្នឹងឯង ។*

**ឯវំ អយំ អសេចនកោ ច,** អប្បិតប្បិតក្ខណេ កាយិក-ចេតសិកសុខបដិលាភាយ សំវត្តនតោ **សុខោ ច វិហារោ**តិ វេទិតព្វោ។

*បណ្ឌិតគប្បីជ្រាបថា អានាបានស្សតិសមាធិនេះ **ជាធម៌មិនមានការប្រឡូកប្រឡំ**ហ្នឹងឯង, ទើបជាធម៌សម្រាប់នៅនាំមកនូវសេចក្តីសុខផង ព្រោះប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវសេចក្តីសុខតាមផ្លូវកាយ និងសេចក្តីសុខតាមផ្លូវចិត្ត ក្នុងខណៈដែលដល់នូវអប្បនាឈាន ។*

"**ឧប្បន្នុប្បន្នេ**"តិ អវិក្ខម្ភិតេ អវិក្ខម្ភិតេ។ "**ចាបកេ**"តិ លាមកេ។

*បទថា "**ឧប្បន្នុប្បន្នេ** ប្រែថា **ដែលកើតឡើងហើយៗ**" មានន័យថា ដែលគ្រុបសង្កត់មិនបាន គ្រុបសង្កត់មិនបានហើយ ។ បទថា "**ចាបកេ** ប្រែថា **អាក្រក់** (លាមក)" ។*

"**អកុសលេ ធម្មេ**"តិ អកោសល្លសម្ភូតេ ធម្មេ។

*បទថា "**អកុសលេ ធម្មេ** ប្រែថា **ធម៌ដែលកើតចាកពីភាពល្ងង់ខ្លៅ** (**អវិជ្ជា**) គឺ សភាវៈធម៌ដែលកើតពីការមិនឆ្លាត ។*

"**ឋានសោ អន្តរធាបេតី**"តិ ខណេនេវ អន្តរធាបេតិ វិក្ខម្ភេតិ។

*បទថា "**ឋានសោ អន្តរធាបេតិ** ប្រែថា **ឱ្យអន្តរធានបាត់ទៅដោយឆាប់រហ័ស**" មានន័យថា ឱ្យវិនាសទៅក្នុងខណៈនោះ គឺរមែងគ្រុបសង្កត់បានភ្លាម ។*

**"វូបសមេតី"តិ សុដ្ឋុ ឧបសមេតិ។**

*បទថា "**វូបសមេតិ** ប្រែថា ឱ្យស្ងប់រម្ងាប់ទៅដោយមិនសេលសល់" គឺការចូលទៅស្ងប់រម្ងាប់ ស្ងប់បានដោយល្អ ។*

**និព្វេធភាគិយត្តា វា អនុបុព្វេន អរិយមគ្គវុឌ្ឍិប្បត្តោ សមុច្ឆិន្ទតិ, បដិប្បស្សម្ភេតីតិ វុត្តំ ហោតិ។**

*អ្នកដល់នូវការចម្រើននូវអរិយមគ្គ ទៅតាមលំដាប់ ព្រោះធម៌ជា **និព្វេធភាគិយសមាធិ** (ជាសមាធិដែលមានចំណែកក្នុងការត្រាស់ដឹងនូវព្រះធម៌ ត្រាស់ដឹងនូវអរិយសច្ចៈ) ហើយរមែងលះបង់បានដោយការដាច់ស្រឡះ, បានសេចក្ដីថា ធ្វើឱ្យស្ងប់រម្ងាប់ទៅបាន ។*

**អយំ បនេត្ថ សង្ខេបត្ថោ។ ភិក្ខវេ, កេន បការេន កេនាការេន កេន វិធិនា ភាវិតោ អានាបានស្សតិសមាធិ កេន បការេន ពហុលីកតោ សន្តោ ចេវ។...បេ...។ វូបសមេតីតិ។**

*ចំណែកសេចក្ដីសង្ខេបក្នុងព្រះត្រៃបិដក ដែលជាសំណួរនោះ នឹងមានដូចតទៅនេះ ។ **ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលព្រះយោគាវចរភិក្ខុចម្រើនហើយ ដោយបការៈដូចម្ដេច ? គឺដោយអាការៈដូចម្ដេច ? ដោយវិធីដូចម្ដេច ? ធ្វើឱ្យច្រើនហើយ ដោយបការៈដូចម្ដេច ? ទើបជាធម៌ដែលស្ងប់ផង ។...ល...។ ឱ្យស្ងប់រម្ងាប់ទៅផង** ដូច្នោះ ។*

## កថំ ភាវិតោ ច

### (មហាដីកាវិសុទ្ធិមគ្គ)

[២១៦] "**កថ**"ន្តិ ឥទំ បុច្ឆាការវិភាវនបទំ។ បុច្ឆា ចេត្ថ កថេតុកម្យតាវសេន អញ្ញាសំ អសម្ភវតោ ។

*ពាក្យថា "**កថំ** ប្រែថា ដោយបការៈដូចម្ដេច ?" នេះ ជាបទបាលីដែល*

*បើកបង្ហាញនូវអាការៈដែលសួរ ។ ពាក្យសួរ នៅក្នុងព្រះបាលីនេះ ប្រព្រឹត្តទៅដែលជាប់ទាក់ទងទៅនឹង* **កថេតុកម្យតាបុច្ឆា** *(គឺសួរដើម្បីនឹងឆ្លើយដោយខ្លួនឯង) ព្រោះមិនមានការសាកសួរអំពីអ្នកដទៃ ។*

**សា ច ឧបរិ ទេសនំ អារុឡ្ហានំ សព្វេសំ បការវិសេសានំ អាមសនវសេនាតិ ឥមមត្ថំ ទស្សេន្តោ "កថន្តិ។... បេ...។ កម្យតាបុច្ឆា"តិ អាហ។**

*លោកអាចារ្យ កាលនឹងសម្តែងនូវសេចក្តីនេះ គឺពាក្យសួរនោះ ប្រព្រឹត្តទៅដោយអំណាចនៃការលើកយកនូវសេចក្តី ដោយអាការៈទាំងពួង ដែលផ្សេងៗគ្នាគ្រប់ៗប្រការដែលឡើងកាន់ព្រះធម្មទេសនាដ៏កំពូល ទើបពោលថា* **"កថន្តិ។..បេ...។ កម្យតាបុច្ឆា"** *ដូច្នេះ ។*

**"កថំ ពហុលីកតោ"តិ ឯត្ថាបិ "អានាបានស្សតិសមាធី"តិ បទំ អានេត្វា សម្ពន្ធិតព្វំ។**

*សូម្បីក្នុងពាក្យថា* **"កថំ ពហុលីកតោ** *ប្រែថា* **ធ្វើឱ្យច្រើនហើយ ដោយបការៈដូចម្តេច ?** *នេះ ក៏គប្បីនាំមកនូវបទថា* **"អានាបានស្សតិសមាធិ"** *ចូលមកភ្ជាប់ជាមួយផង (ទៅជា* **កថំ ពហុលីកតោ អានាបានស្សតិសមាធិ** *)។*

**តត្ថ "កថ"ន្តិ អានាបានស្សតិសមាធិពហុលីការំ នានប្បការតោ វិត្ថារេតុកម្យតាបុច្ឆា។**

*ក្នុងបទទាំងឡាយនោះ បទថា* **"កថំ"** *ជាពាក្យសួរ ជាព្រះបំណង របស់ព្រះអង្គនឹងអធិប្បាយឱ្យសេចក្តីពិស្តារនូវការចម្រើនអានាបានស្សតិសមាធិដោយបការៈផ្សេងៗ ។*

**"ពហុលីកតោ អានាបានស្សតិសមាធី"តិ តថាបុដ្ឋធម្មនិទស្សនន្តិ ឥមមត្ថំ "ឯសេវ នយោ"តិ ឥមិនា អតិទិសតិ។**

*បទថា* **"ឯសេវ នយោ"** *ប្រែថា* **មានន័យនេះឯង** *ត្រង់នេះ ទ្រង់ចង្អុលបង្ហាញ សេចក្តីនេះឱ្យឃើញថា ពាក្យថា* **"ពហុលីកតោ អានាបាន-**

**ស្សតិសមាធិ**” *ជាការសម្តែងធម៌ដែលបានត្រាស់សួរទុកមកហើយ យ៉ាងនោះ។*

តថា សន្តភាវាទយោបិ តស្ស យេហិ ភាវនាពហុលីការេហិ សិទ្ធា, តគ្គហណេនេវ គហិតា ហោន្តីតិ ទស្សេតុំ “**កថំ ពហុលីកតោ។... បេ...។ វូបសមេតីតិ ឯត្ថាបិ ឯសេវ នយោ**”តិ វុត្តំ។

*សេចក្តីនោះយ៉ាងណា លោកអាចារ្យក៏ប្រាថ្នានឹងសម្តែងថា សូម្បីជាធម្មជាតិដែលស្ងប់ជាដើម របស់អានាបានស្សតិសមាធិនោះ គប្បីកាន់យកបានព្រោះការធ្វើឱ្យកើតឡើង និងការធ្វើឱ្យច្រើននោះ ជាហេតុធ្វើឱ្យបានសម្រេចនោះឯង ទើបពោលថា “សូម្បីក្នុងពាក្យថា “***កថំ ពហុលីកតោ។...បេ...។ វូបសមេតិ*** *ដូច្នេះ នេះ ក៏មានន័យសេចក្តីដូច្នោះឯង”។*

“បុន ច បរំ, ឧទាយិ, អក្ខាតា មយា សាវកានំ បដិបទា, យថាបដិបន្នា មេ សាវកា ចត្តារោ សតិបដ្ឋានេ ភាវេន្តី”តិអាទីសុ[៩]ឧប្បាទន-វឌ្ឍនដ្ឋេន ភាវនា វុច្ចតីតិ តទុភយវសេន អត្ថំ ទស្សេន្តោ “**ភាវិតោតិ ឧប្បាទិតោ វឌ្ឍិតោ វា**”តិ អាហ។

*លោកអាចារ្យ កាលនឹងសម្តែងនូវសេចក្តី “**របស់ពាក្យថា ភាវិតោ**” ដែលមានសេចក្តី ២ ន័យនោះ ដែលហៅថា **ភាវនា** ដោយមានសេចក្តីថា ធ្វើឱ្យកើតឡើង និងធ្វើឱ្យច្រើន ដូចក្នុងប្រយោគថា “ម្នាលឧទាយី សេចក្តីដទៃនៅមានទៀត បដិបទាសម្រាប់ សាវ័កទាំងឡាយ តថាគតបានពោលទុក ក្នុងប្រការដែលសាវ័កអ្នកបដិបត្តិទាំងឡាយរបស់តថាគត គប្បីចម្រើនសតិប្បដ្ឋានទាំង ៤ ឱ្យកើតឡើង (ឬឱ្យច្រើន)” ជាដើម ដូច្នោះទើបពោលថា “**បទថា ភាវិតោ ប្រែថា ធ្វើឱ្យកើតឡើង និងធ្វើឱ្យច្រើន**” ដូច្នេះ ។*

តត្ថ ភាវំ វិជ្ជមានតំ ឥតោ គតោតិ **ភាវិតោ**, ឧប្បាទិតោ បដិលទ្ធ-

---

៩ (ម. និ. ២.២៤៧)

មត្តោតិ អត្ថោ។

*ក្នុងបទទាំងឡាយនោះ អានាបានស្សតិសមាធិ ឈ្មោះថា* **ភាវិតោ** *ព្រោះអត្ថថា ដល់ហើយ គឺដល់នូវសភាវៈ ជាសភាវៈកំពុងមាន, បានដល់ ធ្វើឱ្យកើតឡើង មានន័យថា ជាសមាធិដែលបានមក ។*

**ឧប្បន្នោ** បន លទ្ធាសេវនោ, **ភាវិតោ** បគុណភាវំ អាបាទិតោ, វឌ្ឍិតោតិ អត្ថោ។

*ចំណែកសមាធិ **ដែលកើតឡើងហើយ** បានការអាស្រ័យនៅ, ក៏ឈ្មោះថា* **ភាវិតោ** *គឺធ្វើឱ្យដល់ការស្ទាត់ជំនាញបានល្អហើយ,មានន័យថា ចម្រើនហើយ ។*

"**អានាបានបរិគ្គាហិកាយា**"តិ ទីឃរស្សាទិវិសេសេហិ សទ្ធឹ អស្សាសបស្សាសេ បរិច្ឆិជ្ជគាហិកាយ, តេ អារព្ភ បវត្តាយ, សតិយំ បច្ចយភូតាយន្តិ អត្ថោ។

*ពាក្យថា (ដែលសម្បយុត្តជាមួយ) "**សតិ ដែលកំណត់កាន់យកនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ**" មានន័យថា (ដែលសម្បយុត្តជាមួយ) សតិដែលជាបច្ច័យ កំណត់កាន់យកនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ, គឺប្រព្រឹត្តទៅ ប្រារព្ធនូវខ្យល់ទាំងនោះ ព្រមទាំងភាពប្លែកគ្នា ដែលមានសភាពវែង និងសភាពខ្លី ជាដើម ។*

បុរិមស្មិញ្ហិ អត្ថេ សមាធិស្ស សតិយា សហជាតាទិបច្ចយភាវោ វុត្តោ សម្បយុត្តវចនតោ, ទុតិយស្មឹ បន ឧបនិស្សយភាវោបិ។

*ក្នុងអត្ថខាងដើម (ដែលពោលថា អានាបានស្សតិសមាធិ បានដល់សមាធិដែលសម្បយុត្តជាមួយសតិ កំណត់កាន់យកនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ) គឺលោកពោលដល់សភាវៈធម៌ ដែលសតិជាបច្ច័យ ដោយសហជាតបច្ច័យ ជាដើម ដល់សមាធិ ដោយមានពាក្យថា សម្បយុត្ត, ចំណែកក្នុងអត្ថទី ២ (ដែលថា សមាធិក្នុងអានាបានស្សតិ ឈ្មោះថា អានាបានស្សតិ*

*សមាធិ) លោកពោលសូម្បីតែសភាវៈធម៌ដែលសតិជាបច្ច័យ ដោយឧបនិស្សយ-បច្ច័យដល់សមាធិ ។*

*(ន័យទី ១ ពោលថា សតិជា សហជាតបច្ច័យ (បច្ច័យដែលកើតរួមគ្នា) ជាដើមដល់សមាធិ ព្រោះពោលដល់ការប្រកបរួមគ្នា, ន័យទី ២ ពោលថា សតិជា ឧបនិស្សយបច្ច័យ (បច្ច័យដែលអាស្រ័យដ៏មានកម្លាំង) ដល់សមាធិទៀតផង ព្រោះសតិដែលកើតរួមជាមួយឧបចារឈាន ជាបច្ច័យដល់អប្បនាសមាធិ) ។*

**ឧបចារជ្ឈានសហគតា ហិ សតិ អប្បនាសមាធិស្ស ឧបនិស្សយោ ហោតីតិ។**

*ពិតហើយ សតិដែលសហគតដោយឧបចារជ្ឈាន រមែងជាឧបនិស្សយបច្ច័យដល់អប្បនាសមាធិ ។*

**"ពហុលីកតោ"តិ ពហុលំ បវត្តិតោ, តេន អាវជ្ជនាទិវសីភាវប្បត្តិ-មាហ។**

*បទថា* "**ពហុលីកតោ**" *ប្រែថា* ***ធ្វើឱ្យច្រើន*** *គឺធ្វើឱ្យប្រព្រឹត្តទៅដោយច្រើនៗ, ដោយបទថា ពហុលីកតោ នោះ ទ្រង់ត្រាស់សម្ដែងសំដៅដល់ការសម្រេចនូវវសីមាន* **អាវជ្ជនវសី** *ជំនាញក្នុងការនឹករលឹកដល់ពន្លឺបដិភាគនិមិត្ត ឱ្យកើតឡើង ជាដើម ។*

**យោ ហិ វសីភាវំ អាបាទិតោ, សោ ឥច្ឆិតិច្ឆិតក្ខណេ សមាបជ្ជិ-តព្វតោ បុនប្បុនំ បវត្តីយតិ។**

*ពិតមែនហើយ សមាធិណាដែលព្រះយោគាវចរភិក្ខុ បានធ្វើឱ្យជំនាញទៅជាវសីបានសម្រេចរួចហើយ, សមាធិនោះ បានឈ្មោះថា ត្រូវបានព្រះយោគាវចរភិក្ខុ ធ្វើឱ្យស្ទាត់ជំនាញបានប្រព្រឹត្តទៅរឿយៗហើយ ព្រោះព្រះយោគាវចរភិក្ខុគប្បីចូលកាន់សមាបត្តិបាន គ្រប់ៗខណៈដែលប្រាថ្នាត្រូវការចង់ចូល ។*

**តេន វុត្តំ "បុនប្បុនំ កាតោ"តិ។**

*ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា "**ធ្វើឱ្យរឿយៗ**" ដូច្នេះ ។*

**យថា "ឥធេវ, ភិក្ខវេ, សមណោ"តិ [៦] "វិវិច្ចេវ កាមេហី"តិ[៧]ច ឯវមាទីសុ បឋមបទេ វុត្តោ ឯវ-សទ្ទោ ទុតិយាទីសុបិ វុត្តោ ឯវ ហោតិ, ឯវមិធាបីតិ អាហ "ឧភយត្ថ ឯវសទ្ទេន និយមោ វេទិតព្វោ"តិ។**

*ឯវ សព្ទ ដែលត្រាស់សម្ដែងទុកក្នុងបទខាងដើម ក្នុងប្រយោគមានយ៉ាងនេះថា "សមណៈទី ១ មាននៅក្នុងធម្មវិន័យនេះ តែប៉ុណ្ណោះ" និងថា "ស្ងាត់ចាកកាមទាំងឡាយហើយ" ដូច្នេះជាដើម ឈ្មោះថា ព្រះអង្គបានត្រាស់សម្ដែងទុកក្នុងបទទី ២ ជាដើមផងដែរ យ៉ាងណា, សូម្បី **ឯវ** សព្ទ ដែលបានត្រាស់សម្ដែងទុកក្នុងវគ្គដំបូងថា **សន្តោ ចេវ** ប្រែថា ស្ងប់ផង នេះឈ្មោះថា ទ្រង់បានត្រាស់សម្ដែងទុកក្នុងបទទី ២ ផងដែរ បទថា **បណីតោ ចេវ** ប្រែថា ប្រណីតផង យ៉ាងនោះឯង ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា "**គប្បីឃើញថា មានការប្រើ ឯវ សព្ទ ជាការកំណត់ទុកយ៉ាងច្បាស់លាស់ក្នុងបទទាំង ២**" ដូច្នេះ ។*

**ឧភយបទនិយមេន លទ្ធគុណំ ទស្សេតុំ "អយញ្ហី"តិអាទិ វុត្តំ។**

*ទ្រង់មានបំណងសម្ដែងនូវគុណដែលបានប្រើ **ឯវ** សព្ទ កំណត់ទុកយ៉ាងច្បាស់ក្នុងបទទាំង ២ ទើបទ្រង់សម្ដែងថា "**អយញ្ហិ**" ជាដើម ។*

**"អសុភកម្មដ្ឋាន"ន្តិ អសុភារម្មណឈានមាហ។**

*ព្រះអង្គសម្ដែងដល់ឈាន ដែលមានអសុភនិមិត្ត ធ្វើជាអារម្មណ៍ "**អសុភកម្មដ្ឋាន**" ។*

**តំ ហិ អសុភេសុ យោគកម្មភាវតោ, យោគិនោ សុខវិសេសានំ**

---

*៦ (ម. និ. ១.១៣៩; អ. និ. ៤.២៤១) ។*

*៧ (ទី. និ. ១.២២៦; សំ. និ. ២.១៥២; អ. និ. ៤.១២៣) ។*

ការណការតោ ច "អសុភកម្មដ្ឋាន"ន្តិ វុច្ចតិ។

*ពិតមែនហើយ ឈានដែលមាន អសុភនិមិត្តមកជាអារម្មណ៍លោកហៅថា "**អសុភកម្មដ្ឋាន**" ព្រោះកើតមកអំពីការបំពេញសេចក្តីព្យាយាមពិចារណាក្នុងសាកសពអសុភទាំងឡាយ និងព្រោះជាហេតុនៃសេចក្តីសុខដ៏ពិសេសរបស់ព្រះយោគាវចរភិក្ខុ ។*

"**កេវល**"ន្តិ ឥមិនា អារម្មណំ និវត្តេតិ។ "**បដិវេធវសេន**"តិ ឈានបដិវេធវសេន។

*ពាក្យថា "**កេវលំ** ប្រែថា **តែម្យ៉ាង**" នេះ លោកហាមនូវអារម្មណ៍ (ដទៃ) ។ ពាក្យថា "**ដែលទាក់ទងទៅនឹងការចាក់ធ្លុះធម៌**" គឺទាក់ទងនឹងបដិវេធធម៌បានដល់ឈាន ។*

ឈានញ្ហិ ភាវនាវិសេសេន ឥជ្ឈន្តំ អត្តនោ វិសយំ បដិវិជ្ឈន្តមេវ បវត្តតិ, យថាសភាវតោ បដិវិជ្ឈីយតិ ចាតិ "បដិវេធោ"តិ វុច្ចតិ។

*ពិតមែនហើយ ឈានដែលសម្រេចដោយអំណាចការភាវនាដ៏ពិសេស រមែងប្រព្រឹត្តទៅ ដើម្បីការចាក់ធ្លុះនូវអារម្មណ៍របស់ខ្លួនឯងនោះ, ហើយព្រះយោគាវចរភិក្ខុ រមែងចាក់ធ្លុះ ដោយសភាវៈតាមសេចក្តីពិត ព្រោះហេតុនោះទើបហៅថា "**បដិវេធ**" ។*

"**ឱឡារិការម្មណត្តា**"តិ ពីភច្ឆារម្មណត្តា។"**បដិក្កូលារម្មណត្តា**"តិ ជិគុច្ឆិតព្វារម្មណត្តា។ "**បរិយាយេន**"តិ ការណេន, លេសន្តរេន វា។

*ពាក្យថា "**ព្រោះមានអារម្មណ៍គ្រោតគ្រាត**" គឺ ព្រោះមានអារម្មណ៍ដែលគួរឱ្យខ្ពើមរអើម ។ ពាក្យថា "**ព្រោះមានអារម្មណ៍ជាបដិកូល**" គឺ ព្រោះមានអារម្មណ៍គួររង្កៀស ។ ពាក្យថា "**ដោយបរិយាយ**" គឺ ដោយហេតុ, ឬ ដោយចំណុចដទៃ ។*

"**អារម្មណសន្តតាយា**"តិ អនុក្កមេន វិចេតព្វតំ បត្តំ អារម្មណស្ស

**បរមសុខុមតំ សង្ខាយាហ។**

*ពាក្យថា "**ព្រោះមានអារម្មណ៍ស្ងប់**" លោកពោលសំដៅយកសភាវៈ ដែលមានអារម្មណ៍ដ៏ល្អិតសុខុមយ៉ាងក្រៃលែងទៅតាមលំដាប់ ដល់នូវសភាវៈដែលគួរសង្កេតពិនិត្យ ។*

**សន្តេ ហិ សន្និសិន្នេ អារម្មណេ បវត្តមានោ ធម្មោ សយម្បិ សន្និសិន្នោវ ហោតិ ។**

*វីធម៌ ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលកំពុងអង្គុយស្ងប់ គឺស្ងប់រម្ងាប់ហើយ ក៏រមែងនៅនឹងថ្កល់ដោយខ្លួនឯងតែម្យ៉ាង ។*

**តេនាហ "*សន្តោ វូបសន្តោ និព្វុតោ*"តិ, និព្វុតសព្វបរិឡាហោតិ អត្ថោ ។**

*ព្រោះហេតុនោះ ទើបលោកពោលថា "**ជាធម្មជាតិដែលស្ងប់ គឺចូលទៅស្ងប់រម្ងាប់ រលត់បាត់ (មានសភាពត្រជាក់)**" ដូច្នេះ, មានន័យថា រលត់បាត់នូវសភាពក្តៅក្រហាយទាំងឡាយទាំងពួងបាន ។*

**អារម្មណសន្តតាយ តទារម្មណធម្មានំ សន្តតា លោកុត្តរធម្មារម្មណាហិ បច្ចវេក្ខណាហិ ទីបេតព្វា។**

*សភាវៈដែលស្ងប់នៃធម៌ទាំងឡាយ ដែលមានខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនោះមកជាអារម្មណ៍ ព្រោះការដែលមានអារម្មណ៍ស្ងប់ប្រណីតបណ្ឌិតគប្បីសម្តែងដោយ បច្ចវេក្ខណញាណ ដែលមានលោកុត្តរធម៌ជាអារម្មណ៍ (គឺ បច្ចវេក្ខណញាណ ឈ្មោះថា ស្ងប់រម្ងាប់ ព្រោះមានលោកុត្តរធម៌ដែលស្ងប់ប្រណីត មកជាអារម្មណ៍យ៉ាងណា, ធម៌ គឺអានាបានស្សតិសមាធិ ឈ្មោះថា ស្ងប់រម្ងាប់ ព្រោះមានខ្យល់ដង្ហើមដែលស្ងប់ប្រណីត គឺល្អិតសុខុមយ៉ាងក្រៃលែងមកជាអារម្មណ៍ ក៏យ៉ាងនោះដែរ) ។*

**ជាស្ស សន្តបណីតភាវាវហំ កិញ្ចិ សេចនដ្ឋិ អសេចនកោ។**

*ឈ្មោះថា* **អសេចនកោ** *ប្រែថា មិនច្រឡូកច្រឡំ (ដោយការបរិកម្ម ជាដើម) ព្រោះអត្ថថា មិនមានអ្វីៗ មកលាយផ្សំច្របល់ចូលជាមួយ ដែលជាហេតុនាំឱ្យមានសភាវៈធម៌ស្ងប់រម្ងាប់ និងប្រណីត ។*

អសេចនកត្តា **អជាសិត្តកោ**។ អជាសិត្តកត្តា ឯវ **អញ្ញោតិណ្ណោ** អសម្មិស្សោ បរិកម្មាទិនា។ តតោ ឯវ **ចាជិយេក្កោ** វិសុំយេវកោ។

*ព្រោះមិនមានវត្ថុមកច្របូកច្របល់ ទើបឈ្មោះថា* **មិនមានច្រឡូកច្រឡំ** *។ ព្រោះមិនបានច្រឡូកច្រឡំនោះឯង ទើបឈ្មោះថា* **មិនបានផ្សំចូលគ្នា** *គឺមិនច្របូកច្របល់ ដោយការបរិកម្ម ជាដើម ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា* **ជាការញែកចេញពីគ្នា** *គឺជាចំណែកផ្សេងពីគ្នា ។*

**អាវេណិកោ** អសាធារណោ។ សព្វមេតំ សរសតោ ឯវ សន្តភាវំ ឧស្សេតុំ វុត្តំ។

*ឈ្មោះថា* **ជាចំណែកមួយផ្សេង** *គឺមិនជាសាធារណៈ ។ ពាក្យទាំងអស់នេះលោកពោលទុក ដើម្បីសម្តែងសភាវៈដែលស្ងប់ ដោយសភាវៈរបស់ខ្លួននោះឯង ។*

**បរិកម្មំ** វា សន្តភាវនិមិត្តំ, **បរិកម្មន្តិ** ច កសិណការណាទិ និមិត្តុប្បាទបរិយោសានំ, តាទិសំ ឥធ នត្ថីតិ អធិប្បាយោ។

*ន័យម្យ៉ាងទៀត ហេតុនៃសេចក្តីស្ងប់ ឈ្មោះថា* **បរិកម្ម**, *មានសេចក្តីថា ចាប់ផ្តើមតាំងតែចម្រើនពួកកសិណ រហូតមកដល់កើតនូវពន្លឺបដិភាគនិមិត្ត ជាទីបំផុត ឈ្មោះថា* **បរិកម្ម**, *អធិប្បាយថា ក្នុងអានាបានស្សតិសមាធិនេះ មិនមានការបរិកម្មបែបដូច្នេះទេ ។*

តថា ហិ កម្មដ្ឋានំ និរស្សាទត្តា អសន្តមប្បណីតំ សិយា។ **ឧបចារេន** វា នត្ថិ ឯត្ថ សន្តតាតិ យោជនា។

*ព្រោះថា ក្នុងពេលនោះកម្មដ្ឋាននឹងមិនស្ងប់ មិនប្រណីត ព្រោះមិនមាន*

*សេចក្តីត្រេកអរ ។ សេចក្តីថា ក្នុងអានាបានស្សតិសមាធិនេះ សភាវៈដែលស្ងប់* ***ដោយសារឧបចារ*** *គឺមិនមាន ។*

**យថា ឧបចារក្ខណេ នីវរណាវិគមេន, អង្គចាតុកាវេន ច បរេសំ សន្តតា ហោតិ, ន ឯវមិមស្ស។ អយំ បន អាទិសមន្នា។...បេ...។ បណីតោ ចាតិ យោជនា ។**

*សមាធិដទៃស្ងប់ទៅបាន ក៏ព្រោះការប្រាសទៅនៃនីវរណធម៌ និងការប្រាកដនៃអង្គឈានក្នុងខណៈនៃឧបចារ យ៉ាងណា, អានាបានស្សតិសមាធិនេះនឹងមិនមានសេចក្តីដូច្នោះឡើយ ។ បានសេចក្តីថា ប៉ុន្តែសមាធិនេះ ស្ងប់ និងប្រណីតទៅតាមសភាវៈធម៌របស់សមាធិៗ ប៉ុណ្ណោះ ចាប់តាំងតែការចាប់ផ្តើមប្រមូល (នូវអារម្មណ៍កម្មដ្ឋាន គឺសតិដឹងខ្យល់ចូល ចេញ) មកពីខាងដើម ។*

**"កេចី"តិ ឧត្តរវិហារវាសិកេ សន្ធាយាហ។ "អជាសិត្តកោ"តិ ឧបសេចនេន ន អាសិត្តកោ ។ តេនាហ "ឱជវន្តោ"តិ, ឱជវន្តសទិសោតិ អត្ថោ។**

*ពាក្យថា "**អាចារ្យពួកខ្លះ**" លោកអាចារ្យសំដៅយកអាចារ្យដែលអាស្រ័យនៅក្នុង ឧត្តរវិហារ (ក្នុងប្រទេសស្រីលង្កា) ។ ពាក្យថា "**មិនច្របូកច្របល់**" (លោកអាចារ្យពួកខ្លះពោលថា) បានដល់ មិនច្រឡូកច្រឡំដោយការលាយផ្សំចូលទៅ ។ ព្រោះហេតុនោះ លោកទើបពោលថា "**មានឱជា**" ដូច្នេះ, សេចក្តីថា ប្រៀបដូចរបស់ដែលមានឱជា ។*

**"មធុរោ"តិ ឥដ្ឋោ, ចេតសិកសុខបដិលាភសំវត្តនំ តិកចតុក្កជ្ឈាន វសេន, ឧបេក្ខាយ វា សន្តភាវេន សុខគតិកត្តា សព្វសម្បិ វសេន វេទិតព្វំ ។**

*ពាក្យថា "**ផ្អែមឆ្ងាញ់**" គឺគួរប្រាថ្នា, ឈ្មោះថា ការប្រព្រឹត្តទៅព្រមដើម្បីបាននូវសេចក្តីសុខតាមផ្លូវចិត្ត បណ្ឌិតគប្បីជ្រាបបាន ដែលជាប់ទាក់ទងទៅនឹង*

*ឈាន ៣ យ៉ាង, ឈាន ៤ យ៉ាង ឬជាប់ទាក់ទងទៅនឹងឈានទាំងអស់ (គឺរួមទាំងឈានទី ៥ ផងដែរ) ព្រោះឧបេក្ខាក៏មានគតិជាសុខ ព្រោះជាធម្មជាតិដែលស្ងប់ ។*

**ឈានសមុដ្ឋានបណីតរូបផុដ្ឋសរីរតាវសេន បន កាយិកសុខ-បដិលាភសំវត្តនំ ឧដ្ឋព្វំ, តញ្ច ខោ ឈានតោ វុដ្ឋិតកាលេ។**

*ចំណែកការប្រព្រឹត្តទៅព្រម ដើម្បីបានមកនូវសេចក្តីសុខតាមផ្លូវកាយ គប្បីឃើញបានដោយអាស្រ័យរាងកាយដែលត្រូវបានរូបដែលប្រណីតគឺមានឈានជាសមុដ្ឋានបានពាល់ត្រូវហើយ, តែសេចក្តីនោះនឹងកើតមានបានក្នុងពេលដែលចេញចាកនូវឈាននោះឯង។*

**ឥមស្មឹ បក្ខេ "អប្បិតប្បិតក្ខណេ"តិ ឥទំ ហេតុម្හិ ភុម្មវចនំ ឧដ្ឋព្វំ។ "អវិក្ខម្භិតេ"តិ ឈានេន សកសន្តានតោ អនីហដេ អប្បហីនេ។**

*ក្នុងចំណែកនេះ បទថា* **"អប្បិតប្បិតក្ខណេ"** *នេះ គប្បីជ្រាបថា ជាសត្តមីវិភត្តិ ក្នុងអត្ថថា ហេតុ ប្រែថា* ***"ព្រោះគ្រប់ៗខណៈដែលដល់អប្បនា"*** *។ ពាក្យថា* ***"ដែលគ្របសង្កត់មិនទាន់បាន"*** *គឺមិនទាន់កម្ចាត់ចេញពីសន្តានរបស់ខ្លួននៅឡើយ ដែលនៅមិនទាន់បានកម្ចាត់បង់ ដោយឈាន ។*

**"អកោសល្លសម្ភូតេ"តិ អកោសល្លំ វុច្ចតិ អវិជ្ជា, តតោ សម្ភូតេ។ អវិជ្ជាបុព្វង្គមា ហិ សព្វេ បាបធម្មា។ "ខណេនេវា"តិ អត្តនោ បវត្តិក្ខណេនេវ។**

*ពាក្យថា* ***"ដែលកើត តែមិនឆ្លាត"*** *មានន័យថា លោកហៅ អវិជ្ជា ថា មិនឆ្លាត, បានដល់ការកើតឡើងអំពីអវិជ្ជានេះឯង ។ តាមសេចក្តីពិត បាបធម៌ទាំងឡាយ គឺមានអវិជ្ជា ជាអ្នកនាំមុខ (ជាប្រធានអ្នកនាំមុខ) ។ ពាក្យថា* ***"ដោយខណៈមួយ"*** *គឺដោយខណៈដែលខ្លួន (បានដល់អានាបានស្សតិសមាធិ) ប្រព្រឹត្តទៅនុ៎ះឯង។*

**"អន្តរធាបេតី"តិ ឯត្ថ អន្តរធាបនំ វិនាសនំ, តំ បន ឈានកត្តុកស្ស ឥធាធិប្បេតត្តា បរិយុដ្ឋានប្បហានំ ហោតីតិ អាហ "វិក្ខម្ភេតី"តិ។**

*ក្នុងពាក្យថា "**ឱ្យអន្តរធានបាត់ទៅ**" នេះ ឈ្មោះថា ជាការធ្វើឱ្យអន្តរធានបានដល់ ការធ្វើឱ្យវិនាស, ការធ្វើឱ្យអន្តរធាននោះ ជាការលះបរិយុដ្ឋាន ព្រោះក្នុងទីនេះបំណងយក ការធ្វើឱ្យអន្តរធានដែលជាទីតាំងអាស្រ័យនៃឈាន ព្រោះហេតុនោះ លោកទើបពោលថា "**គឺគ្របសង្កត់បាន**" ដូច្នេះ ។*

**"វូបសមេតី"តិ វិសេសេន ឧបសមេតិ។ វិសេសេន ឧបសមនម្បនសម្មទេវ ឧបសមនំ ហោតីតិ អាហ "សុដ្ឋុ ឧបសមេតី"តិ។**

*ពាក្យថា "**វូបសមេតិ** ប្រែថា **ឱ្យស្ងប់**" បានដល់ ចូលទៅស្ងប់រម្ងាប់ដោយពិសេស ។ ឯការចូលទៅស្ងប់ ដោយពិសេស គឺការចូលទៅស្ងប់រម្ងាប់នុ៎ះឯង ព្រោះហេតុនោះ លោកអាចារ្យ ពោលថា "**ចូលទៅស្ងប់រម្ងាប់បានដោយល្អ**" ដូច្នេះ ។*

**ននុ ច អញ្ញោបិ សមាធិ អត្តនោ បវត្តិក្ខណេនេវ បដិបក្ខធម្មេ អន្តរធាបេតិ វូបសមេតិ, អថ កស្មា អយមេវ សមាធិ ឯវំ វិសេសេត្វា វុត្តោតិ? បុព្វភាគតោ បដ្ឋាយ នានាវិតក្កវូបសមសព្ភាវតោ។**

*សួរថា សូម្បីតែសមាធិដទៃៗ រមែងធ្វើធម៌ដែលជាបដិបក្ខទាំងឡាយ ឱ្យអន្តរធានបាត់ទៅ ឱ្យរម្ងាប់ទៅបានក្នុងខណៈដែលខ្លួនប្រព្រឹត្តទៅ មិនមែនទេឬ?, បើដូច្នោះ ព្រោះហេតុអ្វី ទើបព្រះអង្គត្រាស់សម្ដែងចំពោះតែសមាធិនេះឱ្យទៅជាពិសេសយ៉ាងនេះ ? ឆ្លើយថា កាលដែលព្រះអង្គត្រាស់សម្ដែងយកសមាធិនេះ ជាលក្ខណៈពិសេសយ៉ាងនេះ ក៏ព្រោះមានការរម្ងាប់ វិតក្កៈផ្សេងៗ តាំងតែចាប់ផ្ដើមចម្រើនមកពីខាងដើម ។*

**វុត្តញ្ហេតំ – "អានាបានស្សតិ ភាវេតព្វា វិតក្កុបច្ឆេទាយា"តិ**[៨] ។

---

*៨ (អ. និ. ៩.១; ឧទា. ៣១) ។*

*ត្រង់ចំណុចនេះ ស្របទៅតាមព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងទុកមកថា "គប្បីចម្រើនអានាបានស្សតិសមាធិ ដើម្បីកាត់នូវវិតក្ក" ដូច្នេះ ។*

**អបិច តិក្ខបញ្ញស្ស ញាណុត្តរស្សេតំ កម្មដ្ឋានំ, ញាណុត្តរស្ស ច កិលេសប្បហានំ ឥតរេហិ សាតិសយំ, យថា សទ្ធាធិមុត្តេហិ ទិដ្ឋិប្បត្តស្ស។**

*ម្យ៉ាងទៀត អានាបានស្សតិសមាធិកម្មដ្ឋាននេះ ចាត់ជាកម្មដ្ឋានសម្រាប់អ្នកមានបញ្ញាខ្លាំងក្លាក្រៃលែងដោយបញ្ញាញាណប្រសើរជាងការលះកិលេសរបស់បុគ្គលក្រៅពីនេះ, ដូចជាការលះកិលេសរបស់ព្រះអរិយបុគ្គលដែលជាទិដ្ឋិប្បត្តៈ ប្រសើរជាងការលះកិលេសរបស់ព្រះអរិយបុគ្គល ដែលជាសទ្ធាវិមុត្ត យ៉ាងនោះដែរ ។*

**តស្មា ឥមំ វិសេសំ សន្ធាយ "ឋានសោ អន្តរធាបេតិ វូបសមេតី"តិ វុត្តំ។**

*ព្រោះហេតុនោះ ព្រះអង្គទ្រង់សំដៅយកសេចក្តីជាពិសេសនៅត្រង់ចំណុចនេះ ទើបទ្រង់ត្រាស់សម្តែងទុកយ៉ាងនេះថា "**ឱ្យអន្តរធានបាត់ទៅ ឱ្យស្ងប់រម្ងាប់ទៅ ដោយឆាប់រហ័ស**" ដូច្នេះ ។*

**អថ វា និមិត្តចាតុភាវេ សតិ ខណោយេវ អង្គចាតុភាវសញ្ញាវតោ អយមេវសមាធិ "ឋានសោ អន្តរធាបេតិ វូបសមេតី"តិ វុត្តោ។**

*ន័យម្យ៉ាងទៀត កាលប្រាកដនៃនិមិត្ត សមាធិនេះប៉ុណ្ណោះដែលអាចពោលបានថា "ធ្វើ (អកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយៗ)ឱ្យអន្តរធានបាត់ទៅ ឱ្យស្ងប់រម្ងាប់ទៅ ដោយឆាប់រហ័ស" ដូច្នេះ ដោយការប្រាកដនៃអង្គឈានក្នុងខណៈនោះឯង។*

**យថា តំ មហាតោ អកាលមេឃស្ស ឧដ្ឋិតស្ស ធារានិបាតេ ខណោយេវ បថវិយំ រជោជល្លស្ស វូបសមោ។**

*ប្រៀបដូច កាលដែលភ្លៀងធំធ្លាក់មកខុសរដូវកាល មហាមេឃគ្រហឹម ហើយគ្រាប់ភ្លៀងក៏ធ្លាក់ចុះមកលើផែនដី លំអងធូលីក៏ស្ងប់រម្ងាប់នៅក្នុង ខណៈនុ៎ះឯង ដូច្នោះ ។*

**តេនាហ – "សេយ្យថាបិ, ភិក្ខវេ, មហាអកាលមេឃោ ឧដ្ឋិតោ" តិ អាទិ**(៩)**។**

*ព្រោះហេតុនោះ ទើបព្រះអង្គត្រាស់សម្ដែងទុកមកថា "ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជា ភ្លៀងធំដែលធ្លាក់ចុះខុសរដូវកាល" ដូច្នោះជាដើម ។*

**សាសនិកស្ស ឈានភាវនា យេភុយ្យេន និព្វេធភាគិយាវ ហោតីតិ អាហ "និព្វេធភាគិយត្តា" តិ។**

*ការចម្រើនឈានរបស់ព្រះយោគាវចរភិក្ខុ ក្នុងព្រះពុទ្ធសាសនានេះ ដោយច្រើនជា* **និព្វេធភាគិយ** *ប្រែថា មានចំណែកក្នុងការទម្លុះនូវសច្ចធម៌ ព្រោះហេតុនោះ លោកអាចារ្យពោលថា "**ព្រោះភាពជានិព្វេធភាគិយ**" ដូច្នេះ ។*

**ពុទ្ធានំ បន ឯកំសេន និព្វេធភាគិយាវ ហោតិ។ ឥមមេវ ហិ កម្មដ្ឋានំ ភាវេត្វា សព្វេបិ សម្មាសម្ពុទ្ធា សម្មាសម្ពោធឹ អធិគច្ឆន្តិ។**

*ចំណែក ការចម្រើននូវឈានរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយជា* **និព្វេធភាគិយសមាធិ** *តែម្យ៉ាងប៉ុណ្ណោះ ។ ពិតហើយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយ ទ្រង់ចម្រើនកម្មដ្ឋាននេះហើយ ទើបទ្រង់សម្រេចបានជាព្រះសម្មាសម្ពោធិញ្ញាណ ។*

**អរិយមគ្គស្ស ចាតកាភូតោ អយំ សមាធិ អនុក្កមេន វឌ្ឍិត្វា អរិយមគ្គភាវំ ឧបគតោ វិយ ហោតីតិ អាហ "អនុបុព្វេន អរិយមគ្គវុឌ្ឍិប្បត្តោ" តិ។**

*សមាធិនេះ ជាបាទនៃព្រះអរិយមគ្គ ចម្រើនទៅតាមលំដាប់ហើយ ក៏*

---

*៩ (សំ. និ. ៥.៩៨៥; បារា. ១៦៥) ។*

*រមែងចូលដល់ភាពជាព្រះអរិយមគ្គ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា "**ដល់នូវការចម្រើនជាព្រះអរិយមគ្គ ទៅតាមលំដាប់**" ដូច្នេះ ។*

អយំ បនត្ថោ វិរាគនិរោធបដិនិស្សគ្គានុបស្សនានំ វសេន សម្មា វេទិតព្វោ។

*សេចក្តីនេះប្រកបបានដោយល្អនឹងដោយជាប់ទាក់ទងទៅនឹង* **វិរាគានុបស្សនា និរោធានុបស្សនា** *និងបដិនិស្សគ្គានុបស្សនា ។*

ហេដ្ឋា បបញ្ចវសេន វុត្តមត្ថំ សុខគ្គហណត្ថំ សង្ខិបិត្វា ឧស្សេន្តោ "**អយំ បនេត្ថ សង្ខេបត្ថោ**"តិ អាហ, បិណ្ឌត្ថោតិ វុត្តំ ហោតិ។

*លោកអាចារ្យ កាលនឹងសម្តែងដោយសង្ខេប ដើម្បីឱ្យយល់បានងាយនូវខ្លឹមសារ ដែលបានពោលទុកមកហើយ ដោយសេចក្តីពិស្តារនៅក្នុងបទខាងក្រោយ ទើបលោកពោលថា "**ចំណែកសេចក្តីសង្ខេបក្នុងព្រះបាលី ដែលជាសំនួរនេះ មានដូចតទៅនេះ**" ដូច្នេះ, សេចក្តីថា គឺសេចក្តីរួបរួម ។*

## ពាក្យថា ឥធ ភិក្ខវេ ភិក្ខុ

**(វិសុទ្ធិមគ្គ)**

[២១៧] ឥទានិ តមត្ថំ វិត្ថារេន្តោ "ឥធ, ភិក្ខវេ"តិអាទិមាហ។ តត្ថ **ឥធ ភិក្ខវេ ភិក្ខូតិ** ភិក្ខវេ, ឥមស្មិំ សាសនេ ភិក្ខុ។

*ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់អធិប្បាយ នូវសេចក្តីនោះឱ្យពិស្តារទើបទ្រង់ត្រាស់សម្តែងថា "**ឥធ ភិក្ខវេ**" ទុកដូច្នេះ ជាដើម ។ ក្នុងបណ្តាពាក្យទាំងឡាយនោះ ពាក្យថា* **ឥធ ភិក្ខវេ ភិក្ខុ** *ស្មើនឹងពាក្យថា* **ភិក្ខវេ ឥមស្មិំ សាសនេ ភិក្ខុ** *ប្រែថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងព្រះធម្មវិន័យនេះ ។*

អយញ្ហិ ឯត្ថ ឥធ-សទ្ទោ សព្វប្បការអានាបានស្សតិសមាធិនិព្វ-ត្តកស្ស បុគ្គលស្ស សន្និស្សយភូតសាសនបរិទីបនោ អញ្ញសាសនស្ស តថាភាវបដិសេធនោ ច។

*ក៏ **ឥធ** សព្ទ ដែលប្រែថា **ក្នុងព្រះសាសនានេះ** ក្នុងពាក្យថា **ឥធ ភិក្ខវេ ភិក្ខុ** នេះ ក្នុងព្រះបាលីនោះជាសព្ទសម្តែងដល់ព្រះពុទ្ធសាសនា ដែលជាទីអាស្រ័យរបស់បុគ្គលអ្នកចម្រើនអានាបានស្សតិសមាធិមានប្រការទាំងពួងឱ្យកើតឡើង និងជាការបដិសេធនូវសេចក្តីយ៉ាងនោះនៃសាសនាដទៃទៀត ។*

វុត្តញ្ហេតំ – ឥធេវ, ភិក្ខវេ, សមណោ។...បេ...។ សុញ្ញា បរប្បវាទា សមណេភិ អញ្ញេហី"តិ[១០]។ តេន វុត្តំ "ឥមស្មឹ សាសនេ ភិក្ខូ"តិ។

*សេចក្តីនេះសមដូចនឹងព្រះអង្គទ្រង់បានត្រាស់សម្តែងទុកមកថា "ម្នាលភិក្ខុទាំងឡាយ សមណៈ ទី១, ទី២, ទី៣, និងទី៤ មាននៅក្នុងព្រះពុទ្ធសាសនានេះប៉ុណ្ណោះ ។...ល...។ លទ្ធិរបស់សាសនាដទៃ (គឺទិដ្ឋិ ៦២) សោះសូន្យចាកសមណៈអ្នកដឹងច្បាស់ (នូវអរិយសច្ច)" ដូច្នេះ ។ ព្រោះហេតុនោះ ខ្ញុំម្ចាស់ទើបពោលថា "**ឥមស្មឹ សាសនេ ភិក្ខុ** ប្រែថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងព្រះពុទ្ធ-សាសនានេះ" ដូច្នេះ ជាដើម ។*

## ទីកន្លែងបដិបត្តិដែលសមគួរ

"អរញ្ញគតោ វា ។...បេ...។ សុញ្ញាគារគតោ វា"តិ ឥទមស្ស អានាបានស្សតិសមាធិភាវនានុរូបសេនាសនបរិគ្គហបរិទីបនំ។

*ពាក្យថា* **"អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា"** *ប្រែថា* ***"ទៅកាន់ព្រៃក្តី ទៅកាន់គល់ឈើក្តី ឬនៅក្នុងផ្ទះស្ងាត់ក្តី"*** *នេះជាព្រះតម្រាស់ដែលសំដែងដល់ការកំណត់កាន់យកនូវទីសេនាសនៈដែលសមគួរសម្រាប់ការចម្រើនអានាបានស្សតិសមាធិ របស់ព្រះយោគាវចរភិក្ខុនោះ ។*

---

១០ (ម. និ. ១.១៣៩) ។

ឥមស្ស ហិ ភិក្ខុនោ ទីឃរត្តំ រូបាទីសុ អារម្មណេសុ អនុវិសដំ ចិត្តំ អានាបានស្សតិសមាធិអារម្មណំ អភិរុហិតុំ ន ឥច្ឆតិ, កូដគោណ-យុត្តរថោ វិយ ឧប្បថមេវ ធាវតិ។

*ព្រោះថា ចិត្តដែលត្រាច់ទៅកាន់ក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើមអស់កាលជាយូរមកហើយរបស់ភិក្ខុរូបនេះ រមែងមិនប្រាថ្នាដើម្បីនឹងឡើងកាន់អារម្មណ៍នៃអានាបានស្សតិសមាធិ, រមែងផ្ទាប់លេងនៅតែខាងក្រៅផ្លូវដូចរទេះដែលទឹមដោយគោកៀច (គឺគោខូច) ក៏ដូច្នោះដែរ ។*

តស្មា សេយ្យថាបិ នាម គោបោ កូដធេនុយា សព្វំ ខីរំ បិវិត្វា វឌ្ឍិតំ កូដវច្ឆំ ទមេតុកាមោ ធេនុតោ អបនេត្វា ឯកមន្តេ មហន្តំ ថម្ភំ និខណិត្វា តត្ថ យោត្តេន ពន្ធេយ្យ, អថស្ស សោ វច្ឆោ ឥតោ ចិតោ ច វិប្ផន្ទិត្វា បលាយិតុំ អសក្កោន្តោ តមេវ ថម្ភំ ឧបនិសីទេយ្យ វា ឧបនិបជ្ជេយ្យ វា, ឯវមេវ ឥមិនាបិ ភិក្ខុនា ទីឃរត្តំ រូបារម្មណាទិរសបាន-វឌ្ឍិតំ ទុដ្ឋចិត្តំ ទមេតុកាមេន រូបាទិអារម្មណតោ អបនេត្វា អរញ្ញំ វា ។...បេ...។ សុញ្ញាគារំ វា បវិសេត្វា តត្ថ អស្សាសបស្សាសថម្ភេ សតិយោត្តេន ពន្ធិតព្វំ។

*ព្រោះដូច្នោះ ទើបមានការឧបមាថា នាយគោបាលកាលប្រាថ្នាដើម្បីបង្ហាត់នូវកូនគោកៀចនោះ ដែលធំធាត់ដោយផឹកទឹកដោះស្រស់ទាំងអស់ នៃមេគោរបស់ខ្លួន ទើបបំបែកកូនគោចេញអំពីមេគោ ដោយការដាំនូវបង្គោលដ៏ធំក្នុងទីដ៏សមគួរមួយ ហើយយកខ្សែចងនៅត្រង់បង្គោលនោះ, កាលបើមានប្រការដូច្នោះ កូនគោរបស់នាយគោបាលនោះ ក៏មិនអាចដើម្បីនឹងរើបម្រាសទៅខាងនេះផង ទៅខាងនោះផង ដើម្បីរត់គេចចេញទៅបានឡើយ គប្បីឈរជ្រប់ឬ ដេកជ្រប់នៅត្រង់បង្គោលធំនោះនុ៎ះឯង មានការឧបមាយ៉ាងណាមិញ, សូម្បីព្រះយោគាវចរភិក្ខុរូបនេះឯង កាលប្រាថ្នាដើម្បីនឹងទូន្មាននូវចិត្តដ៏កាច ដែលចម្រើនដោយការផឹកនូវរសនៃអារម្មណ៍ ដែលមានរូបារម្មណ៍ជាដើម អស់កាល*

*នៃពេលដ៏យូរមកហើយ ក៏គប្បីនាំចេញអំពីអារម្មណ៍ មានរូបារម្មណ៍ជាដើម ហើយចូលទៅកាន់ព្រៃក្តី ទៅកាន់គល់ឈើក្តី ឬ ទៅកាន់ផ្ទះស្ងាត់ក្តី* ***គប្បីប្រើ ខ្សែ គឺសតិ ចងទុកនៅត្រង់បង្គោលដ៏ធំ គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ។***

**ឯវមស្ស តំ ចិត្តំ ឥតោ ចិតោ ច វិប្ផន្ទិត្វាបិ បុព្វេ អាចិណ្ណារម្មណំ អលភមានំ សតិយោត្តំ ឆិន្ទិត្វា បលាយិតុំ អសក្កោន្តំ តមេវារម្មណំ ឧបចារប្បនាវសេន ឧបនិសីទតិ ចេវ ឧបនិបជ្ជតិ ច។**

*ដោយប្រការយ៉ាងនេះ ចិត្តរបស់ព្រះយោគាវចរភិក្ខុនោះ សូម្បីនឹងរើបម្រាសចេញទៅខាងនោះ ខាងនេះ កាលមិនបាននូវអារម្មណ៍ដែលធ្លាប់ស្និទ្ធស្នាលក្នុងកាលកន្លងមក ក៏មិនអាចនឹងកាត់ខ្សែ គឺសតិ ដើម្បីគេចចេញទៅបានឡើយ ក៏រមែងនៅស្ងៀម នឹងដេកចុះក្បែរអារម្មណ៍នោះ ទ្រុះឯង ដោយអំណាចនៃឧបចារសមាធិ និងអប្បនាសមាធិ យ៉ាងនេះ ទ្រុះឯង ។*

**តេនាហុ បោរាណា –**

*ព្រោះហេតុនោះ លោកបោរាណាចារ្យទាំងឡាយ ទើបលោកពោលថា៖*

**"យថា ថម្ភេ និពន្ធេយ្យ, វច្ឆំ ទមំ នរោ ឥធ;**

**ពន្ធេយ្យេវំ សកំ ចិត្តំ, សតិយារម្មណេ ទឡ្ហ"ន្តិ(១១)។**

*"បុគ្គលណាក្នុងលោកនេះ កាលនឹងបង្ហាត់កូនគោ គប្បីចងទុកត្រង់បង្គោល ឧបមាយ៉ាងណាមិញ, ព្រះយោគាវចរភិក្ខុគប្បីប្រើសតិ ចងចិត្តរបស់ខ្លួនឱ្យតាំងនៅជាមួយអារម្មណ៍ មានឧបមេយ្យ ក៏យ៉ាងនោះដូចគ្នា" ដូច្នេះ ។*

**ឯវមស្សេតំ សេនាសនំ ភាវនានុរូបំ ហោតិ។**

*ឈ្មោះថាព្រៃ ជាដើមនេះ ទើបចាត់ជាទីសេនាសនៈដែលសមគួរដល់ការភាវនារបស់ភិក្ខុនោះ ដូចកាលដែលបានពោលមកហើយ ។*

---

១១ (បារា. អដ្ឋ. ២.១៦៥; ទី. និ. អដ្ឋ. ៣.៣៧៤; ម. និ. អដ្ឋ. ១.១០៧) ។

តេន វុត្តំ "ឥទមស្ស អានាបានស្សតិសមាធិភាវនានុរូបសេនាសនបរិគ្គហាបរិទីបនំ"ន្តិ។

*ព្រោះហេតុនោះ ខ្ញុំម្ចាស់ទើបពោលថា "ត្រង់ចំណុចថា* **អរញ្ញគតោ វា ។...បេ...។ សុញ្ញាគារគតោ វា** *នេះ ជាពាក្យដែលសំដែងដល់ការកំណត់យកនូវទីសេនាសនៈ ដែលសមគួរដល់ការចម្រើនអានាបានស្សតិសមាធិ របស់ព្រះយោគាវចរភិក្ខុរូបនោះ" ទុកដូច្នេះ ។*

អថ វា យស្មា ឥទំ កម្មដ្ឋានប្បភេទេ មុទ្ធភូតំ សព្វញ្ញុពុទ្ធបច្ចេកពុទ្ធពុទ្ធសាវកានំ វិសេសាធិគមទិដ្ឋធម្មសុខវិហារបទដ្ឋានំ អានាបានស្សតិកម្មដ្ឋានំ ឥត្ថិបុរិសហត្ថិអស្សាទិសទ្ទសមាកុលំ គាមន្តំ អបរិច្ចជិត្វា ន សុករំ ភាវេតុំ, សទ្ទកណ្ដកត្តា ឈានស្ស។

*ន័យម្យ៉ាងទៀត ព្រោះការដែលព្រះយោគាវចរភិក្ខុ មិនលះនូវអ្នកស្រុកដែលអ៊ូអរអ៊ឹកធឹក ព្មដោយសំឡេងស្ត្រី សំឡេងបុរស សំឡេងសត្វដំរី សេះជាដើម ហើយមិនចម្រើននូវអានាបានស្សតិសមាធិកម្មដ្ឋាននេះ ដែលជាកំពូលក្នុងប្រភេទនៃកម្មដ្ឋាន គឺជាបទដ្ឋាននៃការបានសម្រេចនូវគុណវិសេស និងជាទិដ្ឋធម្មសុខវិហារ (ការនៅជាសុខក្នុងអត្តភាពនេះ) របស់ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និងសាវ័ករបស់ព្រះពុទ្ធជាម្ចាស់ទាំងពួង មិនមែនជាកិច្ចដែលបុគ្គល នឹងធ្វើបានដោយងាយ, ព្រោះឈានមានសំឡេងជាសត្រូវ ។*

អគាមកេ បន អរញ្ញេ សុករំ យោគាវចរេន ឥទំ កម្មដ្ឋានំ បរិគ្គហេត្វា អានាបានចតុត្ថជ្ឈានំ និព្វត្តេត្វា តទេវ បាទកំ កត្វា សង្ខារេ សម្មសិត្វា អគ្គផលំ អរហត្តំ សម្បាបុណិតុំ។

*ចំណែក ក្នុងព្រៃដែលមិនមានផ្ទះ ការដែលព្រះយោគាវចរភិក្ខុនឹងកំណត់កាន់យកនូវកម្មដ្ឋាននេះ ហើយចម្រើនឈានទាំង ៤ ក្នុងអានាបានស្សតិសមាធិ ឱ្យកើតឡើង ហើយចម្រើនឈាននោះ នោះឯង ឱ្យទៅជាបាទក្នុង*

*ការពិចារណានូវសង្ខាររហូតបានសម្រេចផលដ៏ប្រសើរ គឺព្រះអរហត្ត ជាកិច្ចដែលបុគ្គលធ្វើបានយ៉ាងងាយ ។*

តស្មាស្ស អនុរូបសេនាសនំ ទស្សេន្តោ ភគវា "អរញ្ញគតោ វា"តិ អាទិមាហ។

*ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ កាលនឹងសំដែងនូវទីសេនាសនៈដែលសមគួរ ដល់យោគីភិក្ខុនោះ ទើបព្រះអង្គត្រាស់សំដែងទុកថា "**អរញ្ញគតោ វា** **ទៅកាន់ព្រៃក្តី**" ដូច្នេះជាដើម ។*

## ព្រះសាស្តាបង្ហាញនូវទីកន្លែង

វត្ថុវិជ្ជាចរិយោ វិយ ហិ ភគវា, សោ យថា វត្ថុវិជ្ជាចរិយោ នគរភូមឹ បស្សិត្វា សុដ្ឋុ ឧបបរិក្ខិត្វា "ឯត្ថ នគរំ មាបេថា"តិ ឧបទិសតិ, សោត្ថិនា ច នគរេ និដ្ឋិតេ រាជកុលតោ មហាសក្ការំ លភតិ, ឯវមេវ យោគាវចរស្ស អនុរូបសេនាសនំ ឧបបរិក្ខិត្វា "ឯត្ថ កម្មដ្ឋានំ អនុយុញ្ជិតព្វ"ន្តិ ឧបទិសតិ, តតោ តត្ថ កម្មដ្ឋានំ អនុយុត្តេន យោគិនា កមេន អរហត្តេ បត្តេ "សម្មាសម្ពុទ្ធោ វត សោ ភគវា"តិ មហន្តំ សក្ការំ លភតិ។

*មែនពិត ព្រះដ៏មានព្រះភាគទ្រង់ជាលោកអាចារ្យ ជាអ្នកមានវិជ្ជាមើលនូវភូមិសាស្ត្រ, ឧបមាដូចជា លោកអាចារ្យជាអ្នកមានវិជ្ជាមើលនូវភូមិសាស្ត្រ កាលបានជួបនូវភូមិសាស្ត្រសម្រាប់កសាងព្រះនគរហើយ ក៏ត្រួតពិនិត្យមើលបានយ៉ាងល្អ ក៏ចង្អុលបង្ហាញប្រាប់ថា "ចូរកសាងព្រះនគរត្រង់ទីនេះចុះ" ដូច្នេះ, កាលព្រះនគរបានកសាងសម្រេចដោយសិរីសួស្តីហើយ ក៏រមែងបានទទួលនូវសក្ការៈដ៏ច្រើនអំពីរាជត្រកូល ឧបមេយ្យក៏យ៉ាងនោះដូចគ្នា, ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ក៏ត្រួតពិនិត្យមើលនូវទីសេនាសនៈ ដែលសមគួរដល់ព្រះយោគាវចររួចហើយ ទ្រង់ក៏ចង្អុលបង្ហាញណែនាំថា "គប្បីបំពេញកម្មដ្ឋានក្នុងទីនេះចុះ" ដូច្នេះ, តអំពីនេះទៅ កាលព្រះយោគាវចរប្រកបកម្មដ្ឋានក្នុង*

*ទីសេនាសនៈ ដែលទ្រង់បានចង្អុលបង្ហាញប្រាប់ទុកមកនោះ បន្ទាប់ពីបានសម្រេចនូវព្រះអរហត្តទៅតាមលំដាប់រួចហើយ ព្រះអង្គក៏បានទទួលនូវសក្ការៈដ៏ធំ (គឺការសរសើរនូវព្រះគុណ)ថា "ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះសម្មាសម្ពុទ្ធ ហ្ន៎" ដូច្នេះ ។*

**អយំ បន ភិក្ខុ ទីបិសទិសោតិ វុច្ចតិ។**

*ម្យ៉ាងទៀត ព្រះយោគាវចរភិក្ខុរូបនេះ លោកហៅថា ប្រៀបដូចជាសត្វសីហៈ ។*

**យថា ហិ មហាទីបិរាជា អរញ្ញេ តិណគហនំ វា វនគហនំ វា បព្វតគហនំ វា និស្សាយ និលីយិត្វា វនមហឹសគោកណ្ណសូករាទយោ មិគេគណ្ហាតិ, ឯវមេវ អយំ អរញ្ញាទីសុ កម្មដ្ឋានំ អនុយុញ្ជន្តោ ភិក្ខុ យថាក្កមេន សោតាបត្តិសកទាគាមិអនាគាមិអរហត្តមគ្គេ ចេវ អរិយផលញ្ច គណ្ហាតីតិ វេទិតព្វោ ។**

*គប្បីជ្រាបនូវសេចក្តីអធិប្បាយថា ប្រៀបដូចជាស្តេចរាជសីហ៍មួយដ៏ធំ ដែលអាស្រ័យនៅក្នុងគុម្ពស្មៅក្រាស់ ឬ ក្នុងព្រៃល្បោះ ឬក៏ ក្នុងព្រៃស្រោង ឬថា លាក់ខ្លួនតាមញកភ្នំ ចូលទៅក្នុងព្រៃរួចពួនសម្ងំ ទើបចាប់សត្វព្រៃទាំងឡាយ ដែលមានក្របីព្រៃ គោព្រៃ ក្តាន់ព្រៃ ជ្រូកព្រៃបានជាដើម យ៉ាងណាមិញ, ព្រះយោគាវចរភិក្ខុ ជាអ្នកប្រកបកម្មដ្ឋាននៅក្នុងទីសេនាសនៈ ដែលមានព្រៃជាដើមនេះ ក៏រមែងចាប់យកបាននូវព្រះសោតាបត្តិមគ្គ ព្រះសកទាគាមិមគ្គ ព្រះអនាគាមិមគ្គ ព្រះអរហត្តមគ្គ និងព្រះអរិយផលបាន ទៅតាមលំដាប់ ក៏យ៉ាងនោះដូចគ្នា ។*

**តេនាហុ ពោរាណា –**

*ព្រោះហេតុនោះ លោកបោរាណាចារ្យទាំងឡាយ ទើបពោលទុកថាៈ*

**"យថាបិ ទីបិកោ នាម, និលីយិត្វា គណ្ហតី មិគេ;**

តថេវាយំ ពុទ្ធបុត្តោ, យុត្តយោគោ វិបស្សកោ;
អរញ្ញំ បវិសិត្វាន, គណ្ហាតិ ផលមុត្តម”ន្តិ។[១២]

*“ឧបមាដូចជា សត្វរាជសីហ៍លាក់ខ្លួន ទើបចាប់សត្វព្រៃទាំងឡាយបាន រីការឧបមេយ្យក៏មានន័យដូចគ្នា ព្រះយោគាវចរភិក្ខុជាកូនរបស់ព្រះសម្មាសម្ពុទ្ធអង្គនេះ ចូលទៅក្នុងព្រៃប្រកបសេចក្តីព្យាយាមហើយ ចម្រើនវិបស្សនា ទើបចាប់យកនូវផលដ៏ខ្ពង់ខ្ពស់បំផុត (ឧត្តមផល) បាន ដូច្នោះឯង ។*

**តេនស្ស បរក្កមជវយោគ្គភូមឹ អរញ្ញសេនាសនំ ទស្សេន្តោ ភគវា “អរញ្ញគតោ វា”តិអាទិមាហ។**

*ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ កាលព្រះអង្គសំដែងនូវទីសេនាសនៈព្រៃ គឺជាភូមិសាស្រ្តមួយដ៏សមគួរ នៃការព្យាយាមរបស់ព្រះយោគាវចរភិក្ខុរូបនោះ ទើបព្រះអង្គត្រាស់សំដែងថា “អរញ្ញគតោ វា” ដូច្នេះជាដើម ។*

## ពាក្យថា ឥធ ភិក្ខវេ ភិក្ខុ

### (មហាដីកាវិសុទ្ធិមគ្គ)

[២១៧] “**តមត្ថ**”ន្តិ តំ “កថំ ភាវិតោ”តិអាទិនា បុច្ឆាវសេន សង្ខេប-តោ វុត្តមត្ថំ។ “ឥធ តថាគតោ លោកេ ឧប្បជ្ជតី”តិអាទីសុ[១៣] ឥធសទ្ទោ លោកំ ឧបាទាយ វុត្តោ, “ឥធេវ តិដ្ឋមានស្ស”តិអាទីសុ[១៤] ឱកាសំ, “ឥធាហំ, ភិក្ខវេ, ភុត្តាវី អស្សំ បវារិតោ”តិអាទីសុ[១៥] បទបូរណមត្តំ,

---

*១២ (បារា. អដ្ឋ. ២.១៦៥; ទី. និ. អដ្ឋ. ២.៣៧៤; ម. និ. អដ្ឋ. ១.១០៧) ។*

*១៣ (ទី. និ. ១.១៩០; ម. និ. ១.២៩១; អ. និ. ៣.៦១) ។*

*១៤ (ទី. និ. ២.៣៦៩) ។*

*១៥ (ម. និ. ១.៣០) ។*

"ឥធ ភិក្ខុ ធម្មំ បរិយាបុណាតី"តិអាទីសុ[១៦]បន សាសនំ, "ឥធ, ភិក្ខវេ, ភិក្ខូ"តិ ឥធាបិ សាសនមេវាតិ ឥមស្មិំ អត្ថេ "ភិក្ខវេ, ឥមស្មិំ សាសនេ ភិក្ខូ"តិ វត្វា តមត្ថំ ចាកដំ កត្វា ឥមស្មិំ "អយម្បិ"តិអាទិ វុត្តំ។

*លោកអាចារ្យកាលនឹងសំដែងនូវពាក្យថា* **ឥធ** *សព្ទក្នុងប្រយោគថា "ព្រះតថាគត រមែងកើតឡើងក្នុងលោកនេះ" ជាដើម ទ្រង់ត្រាស់សំដៅយកនូវលោក,* **ឥធ** *សព្ទក្នុងប្រយោគថា "អ្នកចូរឈរនៅត្រង់ទីនោះឯង" ជាដើម ទ្រង់ត្រាស់សំដៅយកនូវទីឱកាស (ទីកន្លែង),* **ឥធ** *សព្ទក្នុងប្រយោគថា "ម្នាលភិក្ខុទាំងឡាយ តថាគតឆាន់ចង្ហាន់រួចរាល់ហាមកត្តហើយ" ជាដើម ទ្រង់ត្រាស់សំដៅយកការធ្វើបទឱ្យពេញ, ចំណែក* **ឥធ** *សព្ទក្នុងប្រយោគថា "ភិក្ខុនៅក្នុងព្រះសាសនានេះ រមែងរៀននូវព្រះធម៌" ជាដើម ទ្រង់ត្រាស់សំដៅយកព្រះសាសនា,* **ឥធ** *សព្ទសូម្បីក្នុងប្រយោគថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងព្រះសាសនានេះ" នេះទ្រង់ត្រាស់សំដៅយកព្រះសាសនា នុ៎ះឯង ដូច្នេះ ទើបទ្រង់ត្រាស់សំដែងថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងព្រះសាសនានេះ" ទ្រង់ប្រាថ្នាសំដែងនូវសេចក្តីនោះ ធ្វើឱ្យជាក់ច្បាស់ប្រាកដ ទើបទ្រង់ត្រាស់សំដែងថា "***អយំហិ***" *ដូច្នេះ ជាដើម ។*

តត្ថ "**សព្វប្បការអានាបានស្សតិសមាធិនិព្វត្តកស្ស**"តិ សព្វប្បការគ្គហណំ សោឡស បការេ សន្ធាយ។

*ក្នុងពាក្យទាំងនោះ ពាក្យថា របស់បុគ្គល* "***អ្នកចម្រើនអានាបានស្សតិសមាធិ ឱ្យកើតឡើង បានដោយប្រការទាំងពួង***" *សព្ទថា ប្រការទាំងពួង លោកពោលសំដៅយកទាំង ១៦ ប្រការ (របស់អានាបានស្សតិកម្មដ្ឋាន) ។*

តេ ហិ ឥមស្មិំយេវ សាសនេ។ ពាហិរកា ហិ ជានន្តា អាទិតោ ចតុប្បការមេវ ជានន្តិ។

---

*១៦ (អ. និ. ៥.៧៣) ។*

*ក៏ប្រការទាំង ១៦ នោះ មាននៅក្នុងព្រះពុទ្ធសាសនានេះ ប៉ុណ្ណោះ។ ពិតមែន បុគ្គលក្រៅសាសនា កាលនឹងដឹង រមែងដឹងបានចំពោះតែ ៤ ប្រការខាងដើមតែប៉ុណ្ណោះ ។*

តេនាហ "**អញ្ញសាសនស្ស តថាការបដិសេធនោ**"តិ, យថាវុត្តស្ស បុគ្គលស្ស និស្សយការបដិសេធនោតិ អត្ថោ។

*ព្រោះហេតុនោះ លោកទើបពោលថា "**បដិសេធនូវសេចក្តីយ៉ាងនោះ នៃសាសនាដទៃ**" ដូច្នេះ សេចក្តីថា បដិសេធនូវសេចក្តីដែលអាស្រ័យបុគ្គលដែលបានពោលមកហើយ ។*

ឯតេន "**ឥធ ភិក្ខវេ**"តិ ឥទំ អន្តោគធេវសទ្ទន្តិ ទស្សេតិ។ សន្តិ ហិ ឯកបទានិបិ សាវធារណានិ យថា "វាយុភក្ខោ"តិ។

*ដោយពាក្យនេះ លោកសម្តែងថា ពាក្យថា "**ឥធ ភិក្ខវេ**" នេះ ជាពាក្យដែលមាន **ឯវ** សព្ទ មករួបរួមនៅក្នុងពាក្យ (គឺស្មើជាមួយពាក្យថា **ឥធេវ ភិក្ខវេ**) នុ៎ះឯង។ ពិតហើយ ពាក្យនិយាយសូម្បីមានមួយបទ តែជាពាក្យ **អវធារណ** (ជាពាក្យកំណត់ឱ្យប្រែថា ប៉ុណ្ណោះ, នុ៎ះឯងតែម្យ៉ាង ។ ល ។) ដែលមានដូចជាពាក្យថា "**វាយុភក្ខោ** ប្រែថា មានខ្យល់ប៉ុណ្ណោះ ជាអាហារ" ។*

តេនេវាហ "**ឥធេវ, ភិក្ខវេ, សមណោ**"តិអាទិ។ បរិបុណ្ណសមណករណធម្មោ ហិ សោ, យោ សព្ពប្បការអានាបានស្សតិសមាធិនិព្ពត្តកោ ។

*ព្រោះហេតុនោះ លោកទើបពោលថា "**ឥធេវ ភិក្ខវេ សមណោ**" ដូច្នេះជាដើម ។ ក៏បុគ្គលអ្នកចម្រើនអានាបានស្សតិសមាធិ ឱ្យកើតឡើងបានដោយប្រការទាំងពួង ឈ្មោះថា ជាអ្នកមានធម៌ដែលសាងភាពជាសមណៈឱ្យពេញបរិបូរណ៍ ។*

"**បរប្បវាទា**"តិ បរេសំ អញ្ញតិត្ថិយានំ នានប្បការា វាទា តិត្ថាយតនានិ ។

*ពាក្យថា “**លទ្ធិរបស់សាសនាដទៃ**” បានដល់ វាទៈ មានប្រការផ្សេងៗ នៃពួកតិរ្ថិយដទៃ ដែលជាសាសនារបស់ពួកអន្យតិរ្ថិយ ។*

**អរញ្ញាទិកស្ស ភាវនានុរូបសេនាសនតំ ទស្សេតុំ “ឥមស្ស ហី”តិ អាទិ វុត្តំ។**

*លោកអាចារ្យប្រាថ្នានឹងសម្តែងដល់ស្ថានទី ដែលមានព្រៃជាដើម នុ៎ះឯងជាទីសេនាសនៈដ៏សមគួរ ដែលគួរដល់ការចម្រើនភាវនា ទើបពោលថា “**ឥមស្ស ហិ**” ដូច្នេះជាដើម។*

**ទុទ្ទមោ ទមថំ អនុបគតោ គោណោ កូដគោណោ។ យថា ថនេហិ សព្វសោ ខីរំ ន បគ្ឃរតិ, ឯវំ ទោហបដិពន្ធិនី កូដធេនុ។**

*គោដែលគេបង្វឹកបានដោយលំបាក គឺការហ្វឹកហាត់មិនបានសម្រេច ហៅថា **គោកៀច** (ឬ គោខូច គោកាច)។ មេគោ ដែលចងដោះក្នុងពេលដែលគេរឹត ដោយប្រការដែលអាចឱ្យទឹកដោះហូរចេញចាកដោះឱ្យអស់ តែមិនបាន (បែបនេះ) ហៅថា **មេគោកៀច** ។*

**រូបសទ្ទាទិកោ បដិច្ច ឧប្បជ្ជនកោ អស្សាទោ រូបារម្មណាទិរសោ។**

*សេចក្តីត្រេកអរដែលអាស្រ័យអារម្មណ៍ មានរូប ឬសម្លេងជាដើម កើតឡើង ឈ្មោះថា រសនៃអារម្មណ៍ មានរូបជាដើម ។*

“**បុព្វេ អាចិណ្ណារម្មណា**”ន្តិ បព្វជ្ជតោ បុព្វេ, អនាទិមតិ វា សំសារេ បរិចិតារម្មណំ។

*ពាក្យថា “**អារម្មណ៍ដែលធ្លាប់សេពក្នុងគ្រាមុន**” បានដល់ អារម្មណ៍ដែលធ្លាប់សេពក្នុងកាលមិនទាន់បព្វជ្ជា, ឬ ក្នុងសង្សារវដ្តដែលមិនមានខាងដើម និងទីបំផុតឡើយ ។*

“**និពន្ធេយ្យា**”តិ ពន្ធេយ្យ។ “**សតិយា**”តិ សម្មទេវ កម្មដ្ឋានសល្លក្ខ-ណសម្បវត្តាយ សតិយា។ “**អារម្មណេ**”តិ កម្មដ្ឋានារម្មណេ។ “**ទឡ្ហ**”ន្តិ

ចិរំ, យថា  សតោការិស្ស ឧបចារប្បនាភេទោ សមាធិ ឥជ្ឈតិ, តថា ថាមគតំ កត្វាតិ  អត្ថោ។

បទថា "**និពន្ធេយ្យ** ប្រែថា គប្បីចង" ។ បទថា "**សតិយា**" បានដល់ សតិ ដែលប្រព្រឹត្តទៅជាប់ទាក់ទងនឹងការកំណត់កម្មដ្ឋានដោយត្រឹមត្រូវ នុ៎ះឯង ។ បទថា "**អារម្មណេ**" បានដល់ អារម្មណ៍ គឺកម្មដ្ឋាន ។ បទថា "**ទឡ្ហំ** ប្រែថា **មាំទាំ**" មានន័យថា ធ្វើឱ្យមានកម្លាំងទៅតាមលំដាប់របស់សមាធិ ដែលមានប្រភេទជា ឧបចារ និងអប្បនា ដែលបានសម្រេចដល់ភិក្ខុអ្នកចម្រើននូវសតិនោះ ។

"វិសេសាធិគមទិដ្ឋធម្មសុខវិហារបទដ្ឋាន"ន្តិ  សព្វេសំ  ពុទ្ធានំ, ឯកច្ចានំ  បច្ចេកពុទ្ធានំ, ពុទ្ធសាវកានញ្ច វិសេសាធិគមស្ស ចេវ អញ្ញកម្មដ្ឋានេន  អធិគតវិសេសានំ ទិដ្ឋធម្មសុខវិហារស្ស ច បទដ្ឋានភូតំ។

ពាក្យថា "**ជាបទដ្ឋាននៃការបានសម្រេចគុណវិសេស និងទិដ្ឋធម្មសុខវិហារ**" គឺជា **បទដ្ឋាន** (ជាហេតុជិត) នៃការបានសម្រេចនូវគុណវិសេសរបស់ព្រះពុទ្ធជាម្ចាស់គ្រប់ៗ ព្រះអង្គ, របស់ព្រះបច្ចេកពុទ្ធជាម្ចាស់ និងព្រះសាវ័ករបស់ព្រះពុទ្ធជាម្ចាស់រូបខ្លះ និងជា **ទិដ្ឋធម្មសុខវិហារ** (ការនៅជាសុខក្នុងអត្តភាពនេះ) របស់អ្នកបានសម្រេចនូវគុណវិសេសដោយកម្មដ្ឋានដទៃ ។

**វត្ថុវិជ្ជាចរិយោ វិយ ភគវា** យោគីនំ អនុរូបនិវាសដ្ឋានុបទិសនតោ។

**ព្រះដ៏មានព្រះភាគ** ឈ្មោះថា **ទ្រង់ប្រៀបដូចជាគ្រូអាចារ្យ** ដែលមានវិជ្ជាមើលនូវភូមិសាស្ត្រ ព្រោះទ្រង់បានណែនាំបង្ហាញនូវស្ថានទី ដែលសមគួរដល់ព្រះយោគាវចរ ។

**ភិក្ខុ ទីបិសទិសោ** អរញ្ញេ ឯកកោ វិហរិត្វា បដិបក្ខនិម្មថនេន ឥច្ឆិតត្ថសាធនតោ។ "**ផលមុត្តម**"ន្តិ  សាមញ្ញផលមាហ។ "**បរក្កមជវយោគ្គភូមិ**"ន្តិ ភាវនុស្សាហជវស្ស យោគ្គករណភូមិភូតំ។

**ភិក្ខុ** ឈ្មោះថា **ដូចជាស្តេចសីហៈ** ព្រោះញុំាងប្រយោជន៍ដែលខ្លួនប្រាថ្នាឱ្យបានសម្រេច ដោយការនៅក្នុងព្រៃតែម្នាក់ឯង និងបានញុំាញីធម៌ដែលជា

*បដិបក្ខ ។ ដោយបទថា "**ផលមុត្តមំ** ប្រែថា **ផលដែលខ្ពស់បំផុត**" លោកពោលសំដៅដល់ សាមញ្ញផល ។ ពាក្យថា "**ភូមិប្រទេសដែលសមគួរដល់ការប្រកបនូវសេចក្តីព្យាយាម**" គឺជាភូមិប្រទេសដែលមានសភាពសមគួរដល់ការញ៉ាំងនូវឧស្សាហៈ ឱ្យកើតឡើងក្នុងភាវនា ។*

## អធិប្បាយ លក្ខណៈព្រៃ

**(វិសុទ្ធិមគ្គ)**

[២១៨] តត្ថ "**អរញ្ញគតោ**"តិ "អរញ្ញន្តិ និក្ខមិត្វា ពហិ ឥន្ទខីលា សព្វមេតំ អរញ្ញ"ន្តិ(១៧)ច, "អារញ្ញកំ នាម សេនាសនំ បញ្ចធនុសតិកំ បច្ឆិម"ន្តិ(១៨)ច ឯវំ វុត្តលក្ខណេសុ អរញ្ញេសុ យំកិញ្ចិ បវិវេកសុខំ អរញ្ញំ គតោ។

*បណ្តាបទទាំងនោះ បទថា "**អរញ្ញគតោ** ប្រែថា **ទៅកាន់ព្រៃ**" បានដល់ទៅកាន់ព្រៃដែលមានសភាពស្ងប់ស្ងាត់ និងមានសេចក្តីសុខតែម្យ៉ាង (គឺសម្បូរដោយសេចក្តីសុខ) ក្នុងបណ្តាព្រៃទាំងឡាយ ដែលមានលក្ខណៈទៅតាមលោកបានពោលទុកយ៉ាងនេះថា "ឈ្មោះថា ព្រៃ មានសេចក្តីថា នៅខាងក្រៅស្ថានទីបង្គោលធរណីទ្វារ ចាត់ជាព្រៃទាំងអស់ ឈ្មោះថា ព្រៃ" ដូច្នេះក្តី, "ឈ្មោះថាទីសេនាសនៈព្រៃ បានដល់ ស្ថានទីដែលមានរយៈចម្ងាយ ៥០០ ធ្នូរង្វង់ ហើយនេះជាការកំណត់យកយ៉ាងជិតបំផុត" ដូច្នេះ ។*

"រុក្ខមូលគតោ"តិ រុក្ខសមីបំ គតោ។ "សុញ្ញាគារគតោ"តិ សុញ្ញំ វិវិត្តោកាសំ គតោ ។

*១៧ (វិភ. ៥២៩) ។*
*១៨ (បារា. ៦៥៤) ។*

*បទថា "រុក្ខមូលគតោ ប្រែថា ទៅកាន់គល់ឈើ" គឺទៅកាន់ស្ថានទី ដែលនៅជិតដើមឈើ" ។ បទថា* **"សុញ្ញាគារគតោ** *ប្រែថា* ***ទៅកាន់ផ្ទះស្ងាត់"*** *គឺទៅកាន់ស្ថានទី ដែលទំនេរ បានដល់ ឱកាសស្ថានទីដែលស្ងាត់ ។*

**ឯត្ថ ច បវេត្វា អរញ្ញញ្ច រុក្ខមូលញ្ច អវសេសសត្តវិធសេនាសន-គតោបិ សុញ្ញាគារគតោតិ វត្តុំ វដ្ដតិ។**

*ក៏ក្នុងបណ្តាទីសេនាសនៈទាំងនោះ សូម្បីទៅកាន់ទីសេនាសនៈ ៧ យ៉ាងដ៏សេសទៀត (គឺ ១ ភ្នំ, ២ ញកភ្នំ, ៣ គុហាភ្នំ, ៤ ព្រៃស្មសាន, ៥ ព្រៃស្រោង, ៦ ទីវាល, ៧ គំនរចំបើង) លើកលែងតែព្រៃ និងទៀបគល់ឈើ (ដែលមាននៅក្នុងព្រះបាលីនេះ) ក៏សមគួរហៅថា* **សុញ្ញាគារគតោ** *បានផងដែរ ។*

## ការតម្កល់នូវកាយ

**ឯវមស្ស ឧតុត្តយានុកូលំ ធាតុចរិយានុកូលញ្ច អានាបានស្ស-តិភាវនានុរូបំ សេនាសនំ ឧបទិសិត្វា អលីនានុទ្ធច្ចបក្ខិកំ សន្តំ ឥរិយាបថំ ឧបទិសន្តោ "និសីទតី"តិ អាហ។**

*ព្រះដ៏មានព្រះភាគ កាលទ្រង់ត្រាស់សម្តែងបង្ហាញណែនាំ នូវទីសេនាសនៈដែលសមគួរដល់អានាបានស្សតិភាវនា ស្របទៅតាមរដូវកាលទាំង ៣ និងស្របទៅតាមធាតុ និងចរិតរបស់ភិក្ខុអង្គនោះៗ យ៉ាងនេះហើយ កាលនឹងទ្រង់ត្រាស់សម្តែងណែនាំនូវឥរិយាបថដែលស្ងប់ស្ងាត់ មិនប្រព្រឹត្តទៅនាំឱ្យរួញរា និងរាយមាយ ទើបទ្រង់ត្រាស់សម្តែងថា* **"និសីទតិ** *ប្រែថា* ***ការអង្គុយ"*** *។*

**អថស្ស និសជ្ជាយ ទឡ្ហភាវំ អស្សាសបស្សាសានំ បវត្តនសុខតំ អារម្មណបរិគ្គហូបាយញ្ច ទស្សេន្តោ "បល្លង្កំ អាភុជិត្វា"តិអាទិមាហ។**

*លំដាប់តមកទៀត កាលនឹងទ្រង់សម្តែងនូវការអង្គុយដែលធ្វើឱ្យតាំងមាំ*

*ហើយប្រព្រឹត្តទៅដោយងាយស្រួលនៃការដកខ្យល់ដង្ហើមចូល និងការដកខ្យល់ដង្ហើមចេញ ហើយជាឧបាយក្នុងការកំណត់កាន់យកនូវអារម្មណ៍កម្មដ្ឋាន ទើបទ្រង់ត្រាស់សម្ដែងថា "***បល្លង្កំ អាភុជិត្វា*** *ប្រែថា ពែនជើង ឬអង្គុយពែនភ្នែន" ដូច្នេះជាដើម ។*

តត្ថ "**បល្លង្ក**"ន្តិ សមន្តតោ ឩរុពទ្ធាសនំ។ "**អាភុជិត្វា**"តិ ពន្ធិត្វា។

*បណ្ដាបទទាំងឡាយនោះ បទថា "***បល្លង្កំ*** *បានដល់* ***ការអង្គុយបត់ជើងចូលមកខាងក្នុង*** *" គឺការចូលមកដោយជុំវិញ ។ បទថា "***អាភុជិត្វា*** *ប្រែថា* ***បត់ជើងទាំងពីរចូលមកខាងក្នុងហើយ*** *" គឺការពត់ជើងចូលមក ។*

"**ឧជុំ កាយំ បណិធាយា**"តិ ឧបរិមសរីរំ ឧជុកំ ឋបេត្វា។ អដ្ឋារសបិដ្ឋិកណ្ដកេ កោដិយា កោដឹបដិបាទេត្វា។

*សេចក្ដីថា "***ឧជុំ កាយំ បណិធាយ*** *ប្រែថា* ***តាំងកាយឱ្យត្រង់*** *គឺការតាំងនូវសរីរៈរាងកាយផ្នែកខាងលើធ្វើឱ្យត្រង់ ។ បានដល់ ការធ្វើឆ្អឹងកងរបស់ខ្នងទាំង ១៨ កងឱ្យជិតស្និទ្ធគ្នា (គឺឱ្យត្រង់បានល្អ) ។*

ឯវញ្ហិ និសីទន្តស្ស ចម្មមំសន្ហារូនិ ន បណាមន្តិ។

*ព្រោះថា កាលព្រះយោគាវចរអង្គុយបែបនេះ ស្បែក សាច់ និងសរសៃរមែងមិនរួញអង្កុញចូលគ្នា ។*

អថស្ស យា តេសំ បណាមនប្បច្ចយា ខណេ ខណេ វេទនា ឧប្បជ្ជេយ្យុំ, តា ន ឧប្បជ្ជន្តិ ។

*កាលបើដូច្នោះ ទុក្ខវេទនា ដែលនឹងកើតឡើងដល់ព្រះយោគាវចរ ជាខណៈ ជា ខណៈ ព្រោះតែការតឹងនៃស្បែកជាដើម ទាំងឡាយនោះដែលជាហេតុបច្ច័យនឹងមិនកើតឡើងឡើយ ។*

តាសុ អនុប្បជ្ជមានាសុ ចិត្តំ ឯកគ្គំ ហោតិ, កម្មដ្ឋានំ ន បរិបតតិ,

វុត្តំ ជាតំ ឧបកច្ចតិ។

*កាលដែលទុក្ខវេទនាទាំងឡាយនោះ មិនបានកើតឡើងទេ ចិត្ត ជាធម្មជាតិដែលមានអារម្មណ៍តែមួយ, កម្មដ្ឋានក៏មិនធ្លាក់ចុះ, ហើយចូលដល់សភាពចម្រើនរុងរឿងល្អឡើងៗ ។*

## ការតម្កល់នូវសតិ

**"បរិមុខំ សតឹ ឧបដ្ឋបេត្វា"** តិ កម្មដ្ឋានាភិមុខំ សតឹ ឋបយិត្វា។

*សេចក្តីថា* "**បរិមុខំ សតឹ ឧបដ្ឋបេត្វា**" *ប្រែថា* ***តាំងសតិស្មារតី ឱ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន*** *គឺតម្កល់សតិ កំណត់ឱ្យមានមុខចេញទៅរកកម្មដ្ឋាន ។*

*(គឺតម្កល់សតិ នៅត្រង់ចុងច្រមុះ ឬក៏ផ្ទៃបបូរមាត់ខាងលើ រួចហើយកំណត់ដឹងនូវខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ) ។*

អថ វា "**បរី**"តិ បរិគ្គហដ្ឋោ។ "**មុខ**"ន្តិ និយ្យានដ្ឋោ។ "**សតី**"តិ ឧបដ្ឋានដ្ឋោ។

*ពាក្យថា* "**បរិ**" *មានអត្ថថា កំណត់កាន់យក ។ ពាក្យថា* "**មុខំ**" *មានអត្ថថា ចេញទៅ ។ ពាក្យថា* "**សតិ**" *មានអត្ថថា ចូលទៅកំណត់ដឹង ។*

តេន វុច្ចតិ "បរិមុខំ សតិ"ន្តិ ឯវំ **បដិសម្ភិទាយំ**[១៩]វុត្តនយេនបេត្ថ អត្ថោ ទដ្ឋព្វោ។

*ន័យម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងពាក្យនេះ ទៅតាមន័យសេចក្តីដែលព្រះសារីបុត្តថេរបានពោលទុកក្នុង* **គម្ពីរបដិសម្ភិទាមគ្គ** *យ៉ាងនេះថា សព្ទថា* "**បរិ**" *មានអត្ថថា* **កំណត់**, *ពាក្យថា* "**មុខំ**" *មានអត្ថថា* **ធម៌ជាគ្រឿងនាំចេញ**, "**សតិ**" *មានអត្ថថា* **ប្រុងប្រយ័ត្ន**, *ព្រោះហេតុនោះ ទើបលោកពោលថា* "បរិមុខំ សតិ" *ដូច្នេះ ។*

តត្រាយំ សង្ខេបោ, "បរិគ្គហិតនិយ្យានំ សតឹ កត្វា"តិ។

---

*១៩ (បដិ. ម. ១.១៦៤) ។*

*ក្នុងពាក្យទាំងឡាយនោះ មានសេចក្ដីសង្ខេបថា "ធ្វើសតិឱ្យមានអាការៈចាកចេញ (ពីធម៌ដែលជាបដិបក្ខ) គឺការកំណត់កាន់យក" ដូច្នេះ ។*

## ទីសេនាសនៈ ៧ យ៉ាង

### (មហាដីកាវិសុទ្ធិមគ្គ)

[២១៨] "ឯវំ វុត្តលក្ខណេសូ"តិ អភិធម្មបរិយាយេន(២០), សុត្តន្តបរិយាយេន ច វុត្តលក្ខណេសុ។

*ពាក្យថា "**ដែលមានលក្ខណៈដូចលោកបានពោលទុកមក យ៉ាងនេះ**" គឺមានលក្ខណៈដូចលោកបានពោលទុកមក **ដោយបរិយាយព្រះអភិធម្ម** និង **ដោយបរិយាយនៃព្រះសូត្រ** ។*

**"រុក្ខសមីប"ន្តិ** "យាវតា មជ្ឈន្ហិកេ កាលេ សមន្តា ឆាយា ផរតិ, និវាតេ បណ្ណានិ បតន្តិ, ឯត្តាវតា រុក្ខមូលន្តិ វុច្ចតី"តិ ឯវំ វុត្តំ រុក្ខស្ស សមីបដ្ឋានំ។

*ពាក្យថា "**ស្ថានទីជិតដើមឈើ**" បានដល់ ស្ថានទីដែលនៅជិតដើមឈើ លោកពោលទុកយ៉ាងនេះថា "ជាស្ថានទី ត្រឹមទីដែលម្លប់ឈើផ្សាយទៅដោយជុំវិញ ក្នុងពេលថ្ងៃដែលត្រង់, ហើយស្លឹកឈើធ្លាក់ចុះក្នុងពេលមិនមានខ្យល់ ឈ្មោះថា រុក្ខមូល ដើមឈើ" ដូច្នេះ ។*

**"អវសេសសត្តវិធសេនាសន"ន្តិ** "បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជ"ន្តិ ឯវំ វុត្តំ។

*ពាក្យថា "**ទីសេនាសនៈ ៧ យ៉ាងដទៃទៀត**" បានដល់ សេនាសនៈ ៧ យ៉ាង តាមដែលលោកបានពោលទុក យ៉ាងនេះថា "១ ភ្នំ, ២ ញកភ្នំ, ៣ គុហាភ្នំ,*

២០ (វិភ. ៤៣០) ។

*៤ ព្រៃស្មសាន, ៥ ព្រៃស្រោង, ៦ ទីវាល, ៧ គំនរចំបើង" ដូច្នេះ ។*

**"ឧតុត្តយានុកូលំ ជាតុចរិយានុកូល"ន្តិ កិម្ហាទិឧតុត្តយស្ស, សេម្ហាទិជាតុត្តយស្ស, មោហាទិចរិយត្តយស្ស ច អនុកូលំ។**

*ពាក្យថា "**ស្របទៅតាមរដូវកាលទាំង ៣ និងស្របទៅតាមជាតុទាំង៣ និងចរិតទាំង ៣ដែរ**" គឺស្របដល់រដូវកាលទាំង ៣ ដែលមានគិម្ហរដូវ រដូវក្តៅ (១ រោច ខែផល្គុន ដល់ ១៥កើត ខែអាសាឍ), វស្សានរដូវ រដូវភ្លៀង (១ រោច ខែអាសាឍ ដល់ ១៥កើត ខែកត្តិក), និងហេមន្តរដូវ រដូវរងា (១ រោច ខែកត្តិក ដល់ ១៥កើត ខែផល្គុន), ចំពោះជាតុមាន ៣ គឺមានជាតុស្លេស្ម, ជាតុប្រមាត់និង ជាតុខ្យល់, និងចំពោះចរិតមាន ៣ ដែរ គឺមានមោហៈចរិត, ទោសៈចរិត និង រាគៈចរិត ។*

**តថា ហិ គិម្ហកាលេ ច អរញ្ញំ អនុកូលំ, ហេមន្តេ រុក្ខមូលំ, វស្សកាលេ សុញ្ញាគារំ, សេម្ហជាតុកស្ស សេម្ហបកតិកស្ស អរញ្ញំ, បិត្តជាតុកស្ស រុក្ខមូលំ, វាតជាតុកស្ស សុញ្ញាគារំ អនុកូលំ, មោហចរិតស្ស អរញ្ញំ, ទោសចរិតស្ស រុក្ខមូលំ, រាគចរិតស្ស សុញ្ញាគារំ អនុកូលំ ។**

*មែនពិត ទី១. ព្រៃ ចាត់ជាទីសេនាសនៈដែលសមគួរក្នុងរដូវក្តៅ, ហើយ ទៀបគល់ឈើ ចាត់ជាទីសេនាសនៈដែលសមគួរក្នុងរដូវរងា, និង*សុញ្ញាគារ *ផ្ទះស្ងាត់ ចាត់ជាទីសេនាសនៈដែលសមគួរក្នុងរដូវភ្លៀង,*

*ទី២. ព្រៃ ចាត់ជាទីសេនាសនៈដែលសមគួរ សម្រាប់បុគ្គលដែលមានជាតុ ស្លេស្ម គឺមានស្លេស្មជាប្រក្រតី, ហើយទៀបគល់ឈើ ចាត់ជាទីសេនាសនៈ ដែល សមគួរសម្រាប់បុគ្គលដែលមានជាតុប្រមាត់, និង*សុញ្ញាគារ *ផ្ទះស្ងាត់ ចាត់ជា ទីសេនាសនៈ ដែលសមគួរសម្រាប់បុគ្គលដែលមានជាតុខ្យល់,*

*ទី៣.ព្រៃ ចាត់ជាទីសេនាសនៈ ដែលសមគួរសម្រាប់បុគ្គលមោហៈចរិត,*

*ហើយទៀបគល់ឈើ ចាត់ជាទីសេនាសនៈ ដែលសមគួរសម្រាប់បុគ្គលទោសៈចរិត, និង**សុញ្ញាគារ** ផ្ទះស្ងាត់ ចាត់ជាទីសេនាសនៈ ដែលសមគួរសម្រាប់បុគ្គលរាគៈចរិត ។*

**"អលីនានុទ្ធច្ចបក្ខិកា"ន្តិ** អសង្កោចាវិក្ខេបបក្ខិកំ។

*ពាក្យថា "**ជាបក្ខពួកនៃការមិនរួញរា និងការមិនរាយមាយ**" គឺជាបក្ខពួកនៃការមិនរាថយ និងការមិនរវើរវាយ (នៃចិត្ត) ។*

**សយនញ្ហិ កោសជ្ជបក្ខិកំ, ឋានចង្កមនានិ ឧទ្ធច្ចបក្ខិកានិ, ន ឯវំ និសជ្ជា។**

*ពិតហើយ ការដេកជាបក្ខពួកនៃការខ្ជិលច្រអូស, ការឈរ និងការចង្ក្រមជាបក្ខពួកនៃការរាយមាយ, ការអង្គុយចុះ មិនមែនជាយ៉ាងដូច្នោះឡើយ ។*

តតោ ឯវស្ស សន្តតា។ **និសជ្ជាយ ឧឡារាវំ** បល្លង្កាភុជនេន, **អស្សាសបស្សាសានំ បវត្តនសុខតំ** ឧបរិមកាយស្ស ឧជុកដ្ឋបនេន, **អារម្មណបរិគ្គហូបាយំ** បរិមុខំ សតិយា ឋបនេន **ឧស្សេដ្ឋោ**។

*ព្រោះហេតុដូច្នោះឯង ការអង្គុយនេះ ទើបមានភាពស្ងប់ ។ ឈ្មោះថា **ព្រះអង្គទ្រង់សម្ដែងភាវៈដែលតាំងមាំនៃការអង្គុយ** គឺការអង្គុយពែនភ្នែន, ឈ្មោះថា **ព្រះអង្គទ្រង់សម្ដែង** ក្នុងការស្រួលដកដង្ហើមចូល និងដកដង្ហើមចេញឱ្យប្រព្រឹត្តទៅបាននូវសេចក្ដីសុខ គឺការតាំងកាយកំណាត់ផ្នែកខាងលើឱ្យត្រង់, ឈ្មោះថា **ព្រះអង្គទ្រង់សម្ដែងជាឧបាយក្នុងការកំណត់កាន់យកនូវអារម្មណ៍** គឺការតាំងសតិ ឱ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។*

**"ឩរុពទ្ធាសន"ន្តិ** ឩរូនមធោពន្ធនវសេន និសជ្ជា។

*ពាក្យថា "**ការអង្គុយពត់ជើង**" គឺការអង្គុយបត់ជើងចូល (តម្រួតលើគ្នា ឬដាក់ខ្វែងជើងជាបល្ល័ង្កពេជ្រ និងការអង្គុយតម្រៀបជើងគ្នាក៏បាន) ។*

ហេដ្ឋិមកាយស្ស អនុជុកំ បបជ្ជំ និសជ្ជាវចនេនេវ ពោធិតន្តិ, "**ឧជុំ កាយ**"ន្តិ ឯត្ថ **កាយសទ្ទោ** ឧបរិមកាយវិសយោតិ អាហ "**ឧបរិមសរីរំ ឧជុកំ ឋបេត្វា**"តិ។

*ការតាំងកាយផ្នែកខាងកណ្ដាលមិនបានត្រង់ គប្បីជ្រាបបានដោយពាក្យពោលដល់ការអង្គុយនោះឯង, ពាក្យថា "**ឧជុំ កាយំ**" នេះ សព្ទថា **កាយ** មានព្រំដែនត្រឹមតែកាយផ្នែកខាងលើ ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា "**គឺ តាំងសរីរៈផ្នែកខាងលើឱ្យត្រង់**" ដូច្នេះ ។*

តំ បន ឧជុកដ្ឋបនំ សរូបតោ, បយោជនតោ ច ទស្សេតុំ "**អដ្ឋារស**"តិអាទិ វុត្តំ។

*ម្យ៉ាងទៀត ជាការសម្ដែងដល់ការតាំងឱ្យត្រង់នោះ តាមសភាវៈដែលមានប្រាកដ, និងជាប្រយោជន៍ ទើបលោកពោលថា "បានដល់ **ឆ្អឹងខ្នង ១៨ កងឱ្យត្រង់**" ដូច្នេះជាដើម ។*

"**ន បណមន្តី**"តិ ន ឱនមន្តិ។ "**ន បរិបតតី**"តិ ន វិគច្ឆតិ វីថឹ ន វិលង្ឃតិ, តតោ ឯវ បុព្វេនាបរំ វិសេសុប្បត្តិយា **វុឌ្ឍឹ ផាតឹ ឧបគច្ឆតិ**។

*ពាក្យថា "**នឹងមិនតឹង**" គឺមិនឱនចុះ ។ ពាក្យថា "**នឹងមិនធ្លាក់ទៅ**" គឺនឹងមិនវិនាសទៅ បានដល់ មិនចេញខុសពីផ្លូវ, ព្រោះហេតុនុ៎ះឯង ទើបចូលដល់* ***ភាពចម្រើន និងសេចក្ដីរុងរឿងបាន*** *ព្រោះជាហេតុ ឧប្បត្តិក្នុងការកើតឡើងនៃគុណវិសេសតទៅ ។*

ឥធ **បរិសទ្ទោ អភិ-សទ្ទេន** សមានត្ថោតិ អាហ "**កម្មដ្ឋានាភិមុខ**"ន្តិ, ពហិទ្ធា បុថុត្តារម្មណតោ និវារេត្វា កម្មដ្ឋានំយេវ បុរក្ខិត្វាតិ អត្ថោ។

*ពាក្យថា **បរិ** ក្នុងពាក្យថា **បរិមុខំ** នេះ មានអត្ថសេចក្ដី ដូចគ្នានឹងពាក្យថា **អភិ** ព្រោះហេតុនោះ លោកទើបពោលថា "**កម្មដ្ឋានាភិមុខំ** ប្រែថា (សតិ)*

*បែរមុខត្រង់ **ឆ្ពោះទៅរកកម្មដ្ឋាន**” ដូច្នេះ, សេចក្តីថា ហាមចេញចាកពីអារម្មណ៍របស់កម្មដ្ឋាន ហើយទៅរកអារម្មណ៍ខាងក្រៅ ត្រូវនៅចម្រើនកម្មដ្ឋានតែម្យ៉ាង ។*

**បរីតិ បរិគ្គហដ្ឋោ** “បរិណាយិកា”តិអាទីសុ[២១]វិយ។

*ពាក្យថា “**បរិ** មានអត្ថថា **កំណត់កាន់យក**” ដូចគ្នា ក្នុងពាក្យថា “**បរិណាយិកា**” ជាដើម។*

**និយ្យានដ្ឋោ** បដិបក្ខតោ និក្ខមនដ្ឋោ។ តស្មា **បរិគ្គហិតនិយ្យានន្តិ** សព្វថា គហិតាសម្មោសំ បរិច្ចត្តសម្មោសំ សតឹ កត្វា, បរមំ សតិនេបក្កំ ឧបដ្ឋបេត្វាតិ អត្ថោ។

*ឈ្មោះថា “**មានអត្ថថា ចេញទៅ**” បានដល់ មានអត្ថថា ចេញអំពីធម៌ដែលជាបដិបក្ខ ។ ព្រោះហេតុនោះ ពាក្យថា “**ឱ្យមានការនាំចេញទៅ ដែលកំណត់កាន់យកបានល្អហើយ**” ទើបមានសេចក្តីថា ធ្វើសតិឱ្យមានការកាន់យកដែលមិនឱ្យភ្លេចភ្លាំង គឺឱ្យលះនូវភាពភ្លេចភ្លាំងចេញ ដោយប្រការទាំងពួង, បានដល់ ចូលទៅតាំងទុកនូវសតិដែលឆ្លាតវាងវៃយ៉ាងក្រៃលែង ។*

---

២១ (ធ. ស. ១៦)

# សោ សតោវ អស្សសតិ សតោ បស្សសតិ

## (វិសុទ្ធិមគ្គ)

*ខ្យល់ដង្ហើមចូល ចេញត្រូវមានសតិកំណត់ដឹង*

[២១៩] **"សោ សតោវ អស្សសតិ សតោ បស្សសតី"**តិ សោ ភិក្ខុ ឯវំ និសីទិត្វា ឯវញ្ច សតឹ ឧបដ្ឋបេត្វា តំ សតឹ អវិជហន្តោ សតោ ឯវ អស្សសតិ សតោ បស្សសតិ, សតោការី ហោតីតិ វុត្តំ ហោតិ។

*ពាក្យថា* **"សោ សតោវ អស្សសតិ"** *មានសេចក្ដីថា ភិក្ខុនោះ អង្គុយរួចហើយយ៉ាងនេះ និងញុំាងសតិឱ្យតាំងមាំផង កាលមិនលះនូវសតិនោះ ឈ្មោះថា ជាអ្នកមានសតិនុ៎ះឯង ដកដង្ហើមចូលក៏មានសតិ និងដកដង្ហើមចេញក៏មានសតិ, ឈ្មោះថា ជា* **សតោការី** *ប្រែថា អ្នកមានសតិជាប្រក្រតី ។*

**ឥទានិ យេហាការេហិ សតោការី ហោតិ, តេ ទស្សេតុំ "ទីឃំ វា អស្សសន្តោ"តិអាទិមាហ ។**

*ភិក្ខុនឹងជាអ្នក* **សតោការី** *បានដោយអាការៈ ប៉ុន្មានយ៉ាង, ពេលនេះ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងនូវអាការៈទាំងនោះ ទើបព្រះអង្គត្រាស់សម្ដែងថា "***ទីឃំ វា អស្សសន្តោ** *ប្រែថា កាលដកដង្ហើមចូលវែង" ដូច្នេះ ជាដើម ។*

**វុត្តញ្ហេតំ បដិសម្ភិទាយំ "សោ សតោវ អស្សសតិ សតោ បស្សសតី"តិ ឯតស្សេវ វិភង្គេ –**

*ត្រង់ចំណុចនេះ ព្រះសារីបុត្តថេរៈ ក៏បានសម្ដែងទុកនៅក្នុង***គម្ពីរបដិសម្ភិទាមគ្គ***ថា* "សោ សតោវ អស្សសតិ សតោ បស្សសតិ" *យ៉ាងនេះនុ៎ះឯងថា ៖*

**"ពាត្តឹសាយ អាការេហិ សតោ ការី ហោតិ។**

*"ព្រះយោគីភិក្ខុ ជាអ្នកចម្រើននូវសតិ ដោយអាការៈ ៣២ ប្រការគឺ ៖*

១. ទីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ, សតិ ឧបដ្ឋិតា ហោតិ។

*កាលភិក្ខុដឹងច្បាស់នូវអារម្មណ៍មានតែមួយ គឺការមិនរាយមាយនៃចិត្ត ដោយអំណាចនៃខ្យល់ដង្ហើមចូលវែង, សតិ ជាធម្មជាតិដែលបានចូលទៅតម្កល់ទុក ។*

តាយ សតិយា តេន ញាណេន សតោ ការី ហោតិ។

*ព្រះយោគាវចរភិក្ខុនោះ ឈ្មោះថា ជាអ្នកចម្រើននូវសតិ ដោយសតិនោះ ដោយញាណនោះ។*

២. ទីឃំ បស្សាសវសេន ។...បេ...។

*កាលភិក្ខុដឹងច្បាស់នូវអារម្មណ៍មានតែមួយ គឺការមិនរាយមាយនៃចិត្ត ដោយអំណាចនៃខ្យល់ដង្ហើមចេញវែង ។...ល...។*

៣១. បដិនិស្សគ្គានុបស្សី អស្សាសវសេន។

*កាលភិក្ខុដឹងច្បាស់នូវអារម្មណ៍មានតែមួយ គឺការមិនរាយមាយនៃចិត្ត ដោយអំណាចដកដង្ហើមចូល ជាអ្នកពិចារណាឃើញរឿយៗ នូវធម៌ជាគ្រឿងរលាស់ចេញ ។*

៣២.បដិនិស្សគ្គានុបស្សី បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ, សតិ ឧបដ្ឋិតា ហោតិ ។

*កាលភិក្ខុដឹងច្បាស់នូវអារម្មណ៍មានតែមួយ គឺការមិនរាយមាយនៃចិត្ត ដោយអំណាចដកដង្ហើមចេញ ជាអ្នកពិចារណាឃើញរឿយៗ នូវធម៌ជាគ្រឿងរលាស់ចេញ, សតិ ជាធម្មជាតិដែលបានចូលទៅតម្កល់ទុក ។*

តាយ សតិយា តេន ញាណេន សតោ ការី ហោតី"តិ[២២] ។

---

២២ (បដិ. ម. ១.១៦៥) ។

*ព្រះយោគីភិក្ខុនោះ ឈ្មោះថា ជាអ្នកចម្រើននូវសតិ ដោយសតិនោះ ដោយញាណនោះ” ដូច្នេះ ។*

## អធិប្បាយពាក្យថា អស្សាសបស្សាស

តត្ថ “**ទីឃំ វា អស្សសន្តោ**”តិ ទីឃំ វា អស្សាសំ បវត្តយន្តោ។

*បណ្តាបទទាំងឡាយនោះ ទាំងពីរបទថា “**ទីឃំ វា អស្សសន្តោ** ប្រែថា **កាលដកដង្ហើមចូលវែង**” បានដល់ ការចម្រើននូវខ្យល់ដង្ហើមចូលវែង ឱ្យប្រព្រឹត្តទៅ ។*

“**អស្សាសោ**”តិ ពហិ និក្ខមនវាតោ។

*លោកបានពោលទុកនៅក្នុង**អដ្ឋកថាព្រះវិន័យ**ថា ខ្យល់ដង្ហើមដែលចេញទៅខាងក្រៅ ឈ្មោះថា “**អស្សាស** ប្រែថា **ខ្យល់ដង្ហើមចេញ**” ។*

“**បស្សាសោ**”តិ អន្តោ បវិសនវាតោតិ **វិនយដ្ឋកថាយំ** វុត្តំ។

*ខ្យល់ដែលចូលទៅខាងក្នុង ឈ្មោះថា “**បស្សាស** ប្រែថា **ខ្យល់ដង្ហើមចូល**” ។*

**សុត្តន្តដ្ឋកថាសុ** បន ឧប្បដិបាដិយា អាគតំ។

*ប៉ុន្តែ **នៅក្នុងអដ្ឋកថាព្រះសូត្រទាំងឡាយ** ដែលមានមកហើយ គឺមានន័យសេចក្តីផ្ទុយពីគ្នា ជាមួយនឹងអដ្ឋកថាព្រះវិន័យ ។*

តត្ថ សព្វេសម្បិ គព្ភសេយ្យកានំ មាតុកុច្ឆិតោ និក្ខមនកាលេ បឋមំ អព្ភន្តរវាតោ ពហិ និក្ខមតិ។

*ក្នុងសេចក្តីរបស់ខ្យល់ទាំង ២ យ៉ាងនោះ គឺនៅពេលដែលគព្ភសេយ្យកសត្វ សូម្បីគ្រប់ប្រភេទទាំងអស់ នៅពេលចេញចាកពីផ្ទៃមាតា (គឺទារកប្រសូតចេញពីផ្ទៃម្តាយ) ខ្យល់ដង្ហើមនៅខាងក្នុងផ្ទៃពោះរបស់ទារកនោះ រមែង*

*ចេញទៅខាងក្រៅមុនគេ (គឺដកដង្ហើមចេញមុន) ។*

**បច្ឆា ពាហិរវាតោ សុខុមរជំ គហេត្វា អព្ភន្តរំ បវិសន្តោ តាលុំ អាហច្ច និព្វាយតិ។**

*បន្ទាប់មកទៀត ខ្យល់ដែលនៅខាងក្រៅ ក៏បាននាំធូលីដ៏ល្អិតសុខុម ចូលទៅខាងក្នុង ដែលល្មមដល់ពិតានមាត់ (របស់ទារកនោះ) ហើយក៏រលត់បាត់ទៅ ។*

**ឯវំ តាវ អស្សាសបស្សាសា វេទិតព្វា។**

*បណ្ឌិតទាំងឡាយ គប្បីជ្រាបនូវសេចក្តីរបស់ខ្យល់* **អស្សាស** *និង* **បស្សាស** *យ៉ាងនេះសិនចុះ (នេះសេចក្តីរបស់ព្រះវិន័យ) ។*

**យា បន តេសំ ទីឃរស្សតា, សា អទ្ធានវសេន វេទិតព្វា។**

*ចំណែកសេចក្តីរបស់ខ្យល់វែង និងខ្យល់ខ្លីនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងពីរនោះ តើយ៉ាងណាវិញ ?, គឺភាពវែង និងភាពខ្លីនោះ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃ* **អទ្ធាន** *ប្រែថា ជាពេលវេលា ឬ ជាឱកាស ឬថា ជាការប្រើរយៈពេល ។*

**យថា ហិ ឱកាសទ្ធានំ ផរិត្វា ឋិតំ ឧទកំ វា វាលិកា វា "ទីឃមុទកំ ទីឃា វាលិកា, រស្សមុទកំ រស្សា វាលិកា"តិ វុច្ចតិ, ឯវំ ចុណ្ណវិចុណ្ណាបិ អស្សាសបស្សាសា ហត្ថិសរីរេ ច អហិសរីរេ ច តេសំ អត្តភាវសង្ខាតំ ទីឃំ អទ្ធានំ សណិកំ បូរេត្វា សណិកមេវ និក្ខមន្តិ។ តស្មា "ទីឃា"តិ វុច្ចន្តិ។**

*ប្រៀបដូចជា ខ្សែទឹក (លាតត្រដាង) ឬ ធ្នេរខ្សាច់ ដែលលាតត្រដាងផ្សាយទៅ រហូត***ឱកាសអទ្ធាន** *គឺជាពេលវេលា ឬ ជាឱកាស ឬថា ជារយៈពេលដែល (វែង ឬ ខ្លី) ដែលឋិតនៅ (ឬ តាំងនៅក្នុងទីនោះ) លោកហៅថា "ខ្សែទឹកវែង ឬ ធ្នេរខ្សាច់វែង, ខ្សែទឹកខ្លី ឬធ្នេរខ្សាច់ខ្លី", យ៉ាងណាមិញ*

*ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ សូម្បីដែលល្អិតសុខុមយ៉ាងក្រៃលែង ញ៉ាំងអទ្ធាន (គឺរយៈពេល) ដែលវែង ក្នុងរាងកាយនៃសត្វដំរី និងក្នុងរាងកាយនៃសត្វពស់ ពោលគឺអត្តភាពនៃសត្វដំរី និងសត្វពស់ទាំងពីរនោះ ឱ្យពេញជាសន្សឹមៗ ហើយចេញទៅខាងក្រៅក៏សន្សឹមៗ ដែរ ។ ព្រោះហេតុនោះទើបលោកពោលថា ខ្យល់ដកដង្ហើម (នៃសត្វដំរី និងសត្វពស់) "វែង" ។*

**សុនខសសាទីនំ អត្តភាវសង្ខាតំ រស្សំ អទ្ធានំ សីឃំ បូរេត្វា សីឃមេវ និក្ខមន្តិ, តស្មា "រស្សា"តិ វុច្ចន្តិ។**

*ខ្យល់នោះ រមែងញ៉ាំង អទ្ធាន (គឺរយៈពេល) ដែលខ្លី ពោលគឺអត្តភាពនៃសត្វទាំងឡាយ មានសត្វឆ្កែ និងសត្វទន្សាយជាដើម ឱ្យពេញបានយ៉ាងឆាប់រហ័ស ហើយចេញមកវិញក៏ឆាប់រហ័សផងដែរ, ព្រោះហេតុនោះ ទើបលោកពោលថា ខ្យល់ដកដង្ហើម (នៃសត្វឆ្កែ និងសត្វទន្សាយ) "ខ្លី" ។*

## ខ្យល់ដង្ហើមរបស់មនុស្ស

**មនុស្សេសុ បន កេចិ ហត្ថិអហិអាទយោ វិយ កាលទ្ធានវសេន ទីឃំ អស្សសន្តិ ច បស្សសន្តិ ច។**

*ចំណោកក្នុងមនុស្សពួកខ្លះ ខ្យល់ដកដង្ហើមចូលក៏វែង និងខ្យល់ដកដង្ហើមចេញក៏វែង ដោយអំណាចនៃអទ្ធាន គឺប្រើរយៈពេលយូរ ដូចគ្នានឹងសត្វដំរី និងសត្វពស់ជាដើម ។*

**កេចិ សុនខសសាទយោ វិយ រស្សំ, តស្មា តេសំ កាលវសេន ទីឃមទ្ធានំ និក្ខមន្តា ច បវិសន្តា ច តេ "ទីឃា" ឥត្តរមទ្ធានំ និក្ខមន្តា ច បវិសន្តា ច "រស្សា"តិ វេទិតព្វា។**

*មនុស្សពួកខ្លះ ខ្យល់ដកដង្ហើមចូលក៏ខ្លី និងខ្យល់ដកដង្ហើមចេញក៏ខ្លី ដោយអំណាចនៃអទ្ធាន គឺរយៈពេល ដូចគ្នានឹងសត្វឆ្កែ និងសត្វទន្សាយជាដើម, ព្រោះហេតុនោះ ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ នៃ*

*មនុស្សទាំងឡាយនុ៎ះ កាលចូលក្តី កាលចេញក្តី អស់រយៈពេលវែង ក៏គប្បីជ្រាប ថា "វែង", កាលចូលក្តី កាលចេញក្តី អស់រយៈពេលខ្លី ក៏គប្បីជ្រាបថា "ខ្លី" ដោយអំណាចនៃការប្រើពេលវេលា ក៏យ៉ាងនោះដែរ ។*

## អានាបានស្សតិជាកាយានុបស្សនាសតិប្បដ្ឋាន

**តត្រាយំ ភិក្ខុ នវហាការេហិ ទីឃំ អស្សសន្តោ បស្សសន្តោ ច "ទីឃំ អស្សសាមិ, បស្សសាមី"តិ បជានាតិ។**

*ក្នុងកិរិយាដកដង្ហើមចូល និងដកដង្ហើមចេញ ដែលវែង និងខ្លីនោះព្រះយោគាវចរភិក្ខុនេះ កាលដកដង្ហើមចូលវែង និងដកដង្ហើមចេញវែង ដោយអាការៈ ៩ យ៉ាង រមែងដឹងច្បាស់ថា "អាត្មាអញ ដកដង្ហើមចូលវែង, ដកដង្ហើមចេញវែង" ដូច្នេះ ។*

**ឯវំ បជានតោ ចស្ស "ឯកេនាការេន កាយានុបស្សនាសតិប្បដ្ឋានភាវនា សម្បជ្ជតីតិ វេទិតព្វំ។**

*កាលបើព្រះយោគីភិក្ខុអង្គនោះ ដឹងច្បាស់យ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា "រមែងបានសម្រេចនូវកាយានុបស្សនាសតិប្បដ្ឋានភាវនា ដោយអាការៈមួយ" ។*

**យថាហ បដិសម្ភិទាយំ**[២៣]**–**

*ដូចគ្នានឹងព្រះសារីបុត្តថេរបានសម្តែងទុកនៅក្នុង***គម្ពីរបដិសម្ភិទាមគ្គ***ថា*

**កថំ ទីឃំ អស្សសន្តោ "ទីឃំ អស្សសាមី"តិ បជានាតិ។ ទីឃំ បស្សសន្តោ "ទីឃំ បស្សសាមី"តិ បជានាតិ។**

*សួរថា កាលភិក្ខុដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា "អាត្មាអញដកដង្ហើមចូលវែង"។ កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា "អាត្មាអញដកដង្ហើមចេញវែង" តើដូចម្តេច ?*

---

២៣ (បដិ.ម. បិ. ៧០ [៩៨]) ។

# ចតុក្កៈទី ១ លំដាប់ទី ១ និងទី ២

## ការកំណត់ដឹងនូវខ្យល់ដង្ហើម ៩ យ៉ាង[២៤]

**(វិសុទ្ធិមគ្គ)**

**១. ទីឃំ អស្សាសំ អទ្ធានសង្ខាតេ អស្សសតិ។**

*ឆ្លើយថា ព្រះយោគាវចរភិក្ខុនោះ រមែងដកចូល នូវខ្យល់ដង្ហើមចូល ក្នុងចំណែកនៃការប្រើពេលវេលាកំណត់ដឹងថាវែង (គឺយូរ) ។*

**២. ទីឃំ បស្សាសំ អទ្ធានសង្ខាតេ បស្សសតិ។**

*ព្រះយោគីភិក្ខុនោះ រមែងដកចេញ នូវខ្យល់ដង្ហើមចេញ ក្នុងចំណែកនៃការប្រើពេលវេលាកំណត់ដឹងថាវែង (គឺយូរ) ។*

**៣.ទីឃំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតិបិ បស្សសតិបិ។**

*ព្រះយោគីភិក្ខុនោះ រមែងដកចូលក្តី ដកចេញក្តី នូវខ្យល់ដង្ហើមចូល ឬខ្យល់ដង្ហើមចេញ ក្នុងចំណែកនៃការប្រើពេលវេលាកំណត់ដឹងថាវែង (គឺយូរ) (នេះហៅថា ដកដង្ហើមចូលវែង និងដកដង្ហើមចេញវែង) ។*

**ទីឃំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតោបិ បស្សសតោបិ ឆន្ទោ ឧប្បជ្ជតិ។**

*កាលភិក្ខុ រមែងដកចូលក្តី ដកចេញក្តី នូវខ្យល់ដង្ហើមចូលខ្លះ នូវខ្យល់ដង្ហើមចេញខ្លះ ក្នុងចំណែកនៃការប្រើពេលវេលាកំណត់ដឹងថាវែង (គឺយូរច្រើន ៗ ដង), វីឆន្ទៈ (គឺចំណង់ក្នុងអ្វីមួយ) រមែងកើតឡើង ដល់ភិក្ខុនោះ ។*

**៤. ឆន្ទវសេន តតោ សុខុមតរំ ទីឃំ អស្សាសំ អទ្ធានសង្ខាតេ**

---

២៤ ការកំណត់ដឹងខ្យល់ទាំង៩យ៉ាង ក្នុងចតុក្កៈទី១ នៅត្រង់លំដាប់ទី១ និងទី២ សម្តែងដោយព្រះសារីបុត្ត ក្នុងគម្ពីរបដិសម្ភិទាមគ្គ បិដក ៧០ [៩៨] ។

អស្សសតិ។

*កាលព្រះយោគាវចរភិក្ខុ រមែងដកចូល នូវខ្យល់ដង្ហើមចូលវែង ដែលល្អិតសុខុមជាងនោះ ក្នុងចំណែកនៃការប្រើពេលវេលាកំណត់ដឹងថាវែង (គឺយូរ) ដោយអំណាចនៃឆន្ទៈ។*

៥.ឆន្ទវសេន តតោ សុខុមតរំ ទីឃំ បស្សាសំ។...បេ...។

*កាលព្រះយោគាវចរភិក្ខុ រមែងដកចេញ នូវខ្យល់ដង្ហើមចេញវែង ដែលល្អិតសុខុមជាងនោះ ក្នុងចំណែកនៃការប្រើពេលវេលាកំណត់ដឹងថាវែង (គឺយូរ) ដោយអំណាចនៃឆន្ទៈ។*

៦.ទីឃំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតិបិ បស្សសតិបិ។

*ព្រះយោគាវចរភិក្ខុនោះ រមែងដកចូលក្តី ដកចេញក្តី នូវខ្យល់ដង្ហើមចូលវែង ឬខ្យល់ដង្ហើមចេញវែង ដែលល្អិតសុខុមជាងនោះ ក្នុងចំណែកនៃការប្រើពេលវេលាកំណត់ដឹងថាវែង (គឺយូរ) ដោយអំណាចនៃឆន្ទៈ។*

ឆន្ទវសេន តតោ សុខុមតរំ ទីឃំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតោបិ បស្សសតោបិ, ចាមោជ្ជំ ឧប្បជ្ជតិ។

*កាលភិក្ខុដកចូលក្តី ដកចេញក្តី នូវខ្យល់ដង្ហើមចូលវែង ឬខ្យល់ដង្ហើមចេញវែង ដែលល្អិតសុខុមជាងនោះ ក្នុងការប្រើពេលវេលាកំណត់ដឹងថាវែង (គឺយូរ) ដោយអំណាចនៃ ឆន្ទៈ (ច្រើនៗដង), រី បាមោជ្ជៈ (សេចក្តីរីករាយ) រមែងកើតឡើង ដល់ភិក្ខុនោះ។*

៧.ចាមោជ្ជវសេន តតោ សុខុមតរំ ទីឃំ អស្សាសំ អទ្ធានសង្ខាតេ អស្សសតិ។

*ព្រះយោគីភិក្ខុ រមែងដកចូល នូវខ្យល់ដង្ហើមចូលវែង ដែលល្អិតសុខុម*

*ជាងនោះ ក្នុងចំណែកនៃការប្រើពេលវេលាកំណត់ដឹងថាវែង (គឺយូរ) ដោយអំណាចនៃបាមោជ្ជៈ ។*

**៨.ចាមោជ្ជវសេន តតោ សុខុមតរំ ទីឃំ បស្សាសំ។...បេ...។**

*ព្រះយោគីភិក្ខុ រមែងដកចេញ នូវខ្យល់ដង្ហើមចេញវែង ដែលល្អិតសុខុមជាងនោះ ក្នុងចំណែកនៃការប្រើពេលវេលាកំណត់ដឹងថាវែង (គឺយូរ) ដោយអំណាចនៃបាមោជ្ជៈ ។*

**៩.ទីឃំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតិបិ បស្សសតិបិ។**

*ព្រះយោគីភិក្ខុនោះ រមែងដកចូលក្តី ដកចេញក្តី នូវខ្យល់ដង្ហើមចូលវែង ឬខ្យល់ដង្ហើមចេញវែង ដែលល្អិតសុខុមជាងនោះ ក្នុងចំណែកនៃការប្រើពេលវេលាកំណត់ដឹងថាវែង (គឺយូរ) ដោយអំណាចនៃបាមោជ្ជៈ ។*

**ចាមោជ្ជវសេន តតោ សុខុមតរំ ទីឃំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតោបិ បស្សសតោបិ ទីឃំ អស្សាសបស្សាសា ចិត្តំ វិវដ្តតិ, ឧបេក្ខា សណ្ឋាតិ។**

*កាលភិក្ខុ រមែងដកចូលក្តី ដកចេញក្តី នូវខ្យល់ដង្ហើមចូលវែង ឬខ្យល់ដង្ហើមចេញវែង ដែលល្អិតសុខុមជាងនោះ ក្នុងចំណែកនៃការប្រើពេលវេលាកំណត់ដឹងថាវែង (គឺយូរ) ដោយអំណាចនៃបាមោជ្ជៈ សេចក្តីរីករាយ (ច្រើនៗផង) ចិត្ត រមែងងាកចេញ អំពីខ្យល់ដង្ហើមចូលវែង ខ្យល់ដង្ហើមចេញវែង, រីសភាវៈធម៌ឧបេក្ខា រមែងតាំងនៅស៊ប់ ។*

**ឥមេហិ នវហិ អាការេហិ ទីឃំ អស្សាសបស្សាសា កាយោ ។**

*ខ្យល់ដកដង្ហើមចូលវែង និងខ្យល់ដកដង្ហើមចេញវែង ដោយអាការៈ៩ យ៉ាងនេះ ឈ្មោះថា* **កាយ** *។*

**ឧបដ្ឋានំ សតិ ។**

*សភាវៈដែលចូលទៅកាន់អារម្មណ៍(គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ) ហើយបានតាំងនៅ ឈ្មោះថា* ***សតិ*** *។*

**អនុបស្សនា ញាណំ។**

*ការពិចារណាឃើញរឿយៗ ឈ្មោះថា ញាណ ។*

**កាយោ ឧបដ្ឋានំ, នោ សតិ។ សតិ ឧបដ្ឋានញ្ចេវ សតិ ច។**

*កាយ (គឺខ្យល់ដង្ហើម) ជាទីតាំងសម្រាប់សតិចូលទៅតម្កល់ទុក, មិនមែនឈ្មោះថា សតិទេ ។ សតិជាសភាវៈចូលទៅតម្កល់ទុកផង និងឈ្មោះថា សតិផង។*

**តាយ សតិយា តេន ញាណេន តំ កាយំ អនុបស្សតិ។**

*ព្រះយោគាវចរភិក្ខុ រមែងពិចារណាឃើញរឿយៗនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ។*

**តេន វុច្ចតិ កាយេ កាយានុបស្សនាសតិបដ្ឋានភាវនា”តិ ។**

*ព្រោះហេតុនោះ លោកទើបពោលថា“សតិប្បដ្ឋានភាវនា គឺការពិចារណាឃើញរឿយៗនូវកាយ (គឺខ្យល់ដង្ហើមចូល និងចេញ នៅត្រង់ចុងច្រមុះ) ត្រង់កាយ” ។*

**ឯស នយោ រស្សបទេបិ។**

*សូម្បីនៅក្នុងបទដែលកំណត់ទុក ដោយខ្យល់ដង្ហើមចូលខ្លី និងខ្យល់ដង្ហើមចេញខ្លី ក៏មានន័យសេចក្ដីដូចគ្នាទាំងអស់ផងដែរ ។*

**អយំ បន វិសេសោ, យថា ឯត្ថ “ទីឃំ អស្សាសំ អទ្ធានសង្ខាតេ”តិ វុត្តំ, ឯវមិធ “រស្សំ អស្សាសំ ឥត្តរសង្ខាតេ អស្សសតី”តិ អាគតំ។**

*ចំណែកសេចក្តីតទៅនេះ ជាចំណុចដែលមានសេចក្តីប្លែកគ្នា, គឺតាមន័យក្នុងព្រះត្រៃបិដកដែលមានមកហើយនោះ ដោយមានការកំណត់វែង ព្រោះខ្យល់ដកដង្ហើមវែង លោកសម្តែងទុកថា "ព្រះយោគីភិក្ខុ រមែងដកដង្ហើមចូលវែង ក្នុងចំណែកនៃការប្រើពេលវេលាវែង គឺយូរ" ជាដើម យ៉ាងណាមិញ, ក្នុងបទដែលកំណត់ទុកដោយខ្យល់ដង្ហើមចូលខ្លី និងខ្យល់ដង្ហើមចេញខ្លីនេះ ក៏មានមកហើយថា "ព្រះយោគីភិក្ខុ រមែងដកដង្ហើមចូលខ្លី ក្នុងចំណែកនៃការប្រើពេលវេលាគិតថាខ្លី គឺបន្តិចបន្តួច" ជាដើម ក៏យ៉ាងនោះ ដូចគ្នា ។*

**តស្មា រស្សវសេន យាវ "តេន វុច្ចតិ កាយេ កាយានុបស្សនាសតិ-ប្បដ្ឋានភាវនា"តិ, តាវ យោជេតព្វំ។**

*ព្រោះហេតុនោះ បណ្ឌិតទាំងឡាយគប្បីជ្រាបនូវការប្រកបសេចក្តីជាមួយពាក្យថា រស្ស ប្រែថា ខ្លី ឱ្យប្រព្រឹត្តទៅរហូតដល់មានពាក្យថា "ព្រោះហេតុនោះទើបលោកហៅថា* **កាយេ កាយានុបស្សនាសតិប្បដ្ឋានភាវនា"** *ដូច្នេះផងចុះ ។*

**ឯវំ អយំ អទ្ធានវសេន ឥត្តរវសេន ច ឥមេហាការេហិ អស្សាសបស្សាសេ បជានន្តោ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ។...បេ...។ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតីតិ វេទិតព្វោ។ ឯវំ បជានតោ ចស្ស –**

*ព្រះយោគាវចរភិក្ខុនេះ កាលដឹងច្បាស់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដោយអាការៈទាំងនេះ ដែលអាស្រ័យជាមួយ ការប្រើពេលវេលាវែង គឺយូរ និងអាស្រ័យជាមួយការប្រើពេលវេលាខ្លី គឺរហ័ស យ៉ាងនេះហើយគប្បីជ្រាបថា ដែលឈ្មោះថា កាលដកដង្ហើមចូលវែង រមែងដឹងច្បាស់ថាអាត្មាអញដកដង្ហើមចូលវែង ។...ល...។ កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថាអាត្មាអញដកដង្ហើមចេញខ្លី ។ កាលភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះ*

ទីឃោ រស្សោ ច អស្សាសោ, បស្សាសោបិ ច តាទិសោ;
ចត្តារោ វណ្ណា វត្តន្តិ, នាសិកគ្គេវ ភិក្ខុនោតិ(២៥)។

*អាការៈ ៤ យ៉ាង គឺខ្យល់ដង្ហើមចូលវែង និងខ្យល់ដង្ហើមចូលខ្លី សូម្បីខ្យល់ដង្ហើមចេញ ក៏មានន័យសេចក្តីដូចគ្នាផងដែរ (គឺខ្យល់ដង្ហើមចេញវែង និងចេញខ្លី) រមែងប្រព្រឹត្តទៅ នៅត្រង់ចុងច្រមុះរបស់ភិក្ខុនោះ ទុំះឯង ។*

## សោ សតោវ អស្សសតិ សតោ បស្សសតិ

### (មហាដីកាវិសុទ្ធិមគ្គ)

[២១៩] "**សតោវា**"តិ សតិយា សមន្នាគតោ ឯវ សរន្តោ ឯវ "**អស្សសតិ**"តិ នាស្ស កាចិ សតិវិរហិតា អស្សាសប្បវត្តិ ហោតីតិ អត្ថោ។

*ពាក្យថា "**ជាអ្នកមានសតិកំណត់ដឹងនោះ**" គឺជាអ្នកប្រកបព្រមដោយសតិទុំះឯង មានការកំណត់ដឹងនូវការដកដង្ហើមចូល មានន័យថា សម្រាប់ភិក្ខុរូបនេះការប្រព្រឹត្តទៅនៃខ្យល់ដង្ហើមចូល ដែលប្រាសចាកសតិ តែបន្តិចបន្តួចនោះ គឺមិនមានឡើយ ។*

"**សតោ បស្សសតី**"តិ ឯត្ថាបិ សតោវ បស្សសតីតិ ឯវ-សទ្ទោ អានេត្វា វត្តព្វោ ។

*សូម្បីក្នុងបទថា "**សតោ បស្សសតិ**" នេះ គប្បីនាំយកនូវ **ឯវ**-សព្ទ (ដែលប្រែថា ទុំះឯង) យកមកពោលទុកក្នុង **សតោ បស្សសតិ** ដែលប្រែថា ជាអ្នកមានសតិកំណត់ដឹងបាន ទុំះឯង ដកដង្ហើមចេញ) ។*

"**សតោការី**"តិ សតោ ឯវ ហុត្វា, សតិយា ឯវ វា កាតព្វស្ស កត្តា, ការណសីលោ វា។

*ពាក្យថា "**សតោការី**" គឺជាអ្នកបានកំណត់ដឹង ទុំះឯង, បានដល់ ធ្វើកិច្ច*

---

២៥ (បាក. អដ្ឋ. ២.១៦៥) ។

*ដែលគប្បីធ្វើ ដោយសតិ, ឬ ជាអ្នកមានប្រក្រតីធ្វើនូវសតិ (ជាអ្នកចម្រើននូវសតិ ជាអ្នកមានសតិដែលកំណត់ដឹង) ។*

**យទិ "សតោវ អស្សសតិ សតោ បស្សសតី"តិ ឯតស្ស វិភង្គេ[២៦] វុត្តំ, អថ កស្មា "អស្សសតិ បស្សសតិ"ច្ចេវ អវត្វា "សតោការី"តិ វុត្តំ? ឯករសំ ទេសនំ កាតុកាមតាយ ។**

*សួរថា ប្រសិនជាពាក្យអធិប្បាយដែលព្រះអង្គសម្ដែងទុក* **ក្នុងវិភង្គ** *នៃព្រះត្រៃបិដកនេះថា "***សតោវ អស្សសតិ សតោ បស្សសតិ***", ជាយ៉ាងនោះ តើព្រោះហេតុអ្វី? ទើបព្រះអង្គមិនសម្ដែងថា "***អស្សសតិ** *ប្រែថា ដកដង្ហើមចូល* **បស្សសតិ** *ប្រែថា ដកដង្ហើមចេញ" នុ៎ះឯង បែរជាមកសម្ដែងថា "***សតោការី***" ដូច្នេះទៅវិញ ?*

*ឆ្លើយថា ព្រះអង្គមិនសម្ដែងថា "***សតោវ អស្សសតិ សតោ បស្សសតិ***" ប៉ុន្តែ មកសម្ដែងថា "***សតោការី***" ទុកដូច្នេះ ព្រោះថា សេចក្ដីដែលព្រះអង្គត្រូវការនឹងធ្វើព្រះធម្មទេសនាឱ្យមានឱជារសនៃព្រះធម៌តែមួយ ។*

**បឋមចតុក្កេ បទទ្វយមេវ ហិ វត្តមានកាលវសេន អាគតំ, ឥតរានិ អនាគតកាលវសេន។**

*ពិតហើយ ២ បទខាងដើម ក្នុងបឋមចតុក្កៈប៉ុណ្ណោះ ដែលមកហើយដោយអំណាចជាបច្ចុប្បន្នកាល, បទក្រៅអំពីនេះទៅ ដែលមកហើយដោយអំណាចជាអនាគតកាល ។*

**តស្មា ឯករសំ ទេសនំ កាតុកាមតាយ សព្វត្ថ[២៧] "សតោការិ"ច្ចេវ វុត្តំ។**

*ព្រោះហេតុនោះ សេចក្ដីត្រូវការនឹងធ្វើព្រះធម្មទេសនាឱ្យមានឱជារស*

---

២៦ (ម. និ. ៣.១៤៨; សំ. និ. ៥.៩៨៦; បារា. ១៦៥) ។
២៧ (បដិ. ម. ១.១៦៥ អាទយោ) ។

*តែមួយ ទើបព្រះអង្គសម្ដែងទុកក្នុងបទ **ទាំងពួង** ថា "**សតោការី**" តែប៉ុណ្ណោះ ។*

"**ទីឃំ អស្សាសវសេនា**"តិ ទីឃអស្សាសវសេន វិកត្តិអលោបំ-កត្វា និទ្ទេសោ។

*សេចក្ដីថា "**ទីឃំ អស្សាសវសេន**" ជាពាក្យសម្ដែងខែអធិប្បាយ ដែលមិនបានលុបនូវវិកត្តិទេ ដោយអំណាចនៃខ្យល់ដង្ហើមចូលវែង ។*

"**ទីឃ**"ន្តិ វា ភគវតា វុត្តអស្សាសវសេន។ "**ចិត្តស្ស ឯកគ្គតំ អវិក្ខេប**"ន្តិ វិក្ខេបស្ស បដិបក្ខភាវតោ "**អវិក្ខេបោ**"តិ លទ្ធនាមចិត្តស្ស ឯកគ្គភាវំ បជានតោ។

*ន័យម្យ៉ាងទៀត ប្រែថា ដោយអំណាចនៃខ្យល់ដង្ហើមចូល ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងហៅថា "**វែង**" ។ ពាក្យថា "**ភាពមានអារម្មណ៍តែមួយ គឺការមិនរាយមាយនៃចិត្ត**" សេចក្ដីថា កាលភិក្ខុដឹងច្បាស់នូវសភាពមានអារម្មណ៍តែមួយ (**ឯកគ្គតាភាវ**) នៃចិត្តដែលបានឈ្មោះថា "**អវិក្ខេប** ប្រែថា **ការមិនរាយមាយ**" ព្រោះជាបដិបក្ខ ដល់ **វិក្ខេប** ប្រែថា **ការរាយមាយ** ។*

"**សតិ ឧបដ្ឋិតា ហោតី**"តិ អារម្មណំ ឧបគន្ត្វា ឋិតា ហោតិ។

*ពាក្យថា "**សតិ ជាធម្មជាតិដែលចូលទៅតម្កល់ទុក**" គឺសតិ ជាធម្មជាតិដែលចូលទៅកាន់អារម្មណ៍ ហើយក៏តាំងនៅ ។*

"**តាយ សតិយា តេន ញាណេនា**"តិ យថាវុត្តាយ សតិយា, យថាវុត្តេន ច ញាណេន ។

*ពាក្យថា "**ដោយសតិនោះ ដោយញាណនោះ**" គឺដោយសតិ ទៅតាមសេចក្ដីដែលបានពោលទុកមកហើយ, និងដោយញាណនោះ គឺដោយញាណទៅតាមសេចក្ដីដែលបានពោលទុកមកហើយដែរ ។*

ឥទំ វុត្តំ ហោតិ –

*សេចក្តីនេះ មានពាក្យអធិប្បាយថា ៖*

**ឌីឃំ អស្សាសំ អារម្មណាកូតំ អវិក្ខិត្តចិត្តស្ស, អសម្មោហតោ វា បជានន្តស្ស តត្ថ សតិ ឧបដ្ឋិតា ឃវ ហោតិ, តំ សម្បជានន្តស្ស អារម្មណា-ការណវសេន, អសម្មោហវសេន វា សម្បជញ្ញំ, តេនឌីនសតិសម្បជ-ញ្ញេន តំសមង្គី យោគាវចពេ សតោការី ជាម ហោតីតិ។**

*កាលភិក្ខុ មានចិត្តមិនរាយមាយ ឬថា មិនវង្វេង ដឹងច្បាស់នូវខ្យល់ដង្ហើមចូលវែង ដែលជាអារម្មណ៍របស់សតិ ក៏ឈ្មោះថា ជាធម្មជាតិដែលចូលទៅតាំងនៅក្នុងអារម្មណ៍នោះហើយ តែម្យ៉ាង, កាលដឹងច្បាស់បានយ៉ាងល្អ នូវខ្យល់ដង្ហើមចូលវែងនោះ ដោយអំណាចធ្វើជាអារម្មណ៍ក្តី, ដោយអំណាចមិនវង្វេងក្តី (គឺមិនភ្លេចភ្លាំង) សម្បជញ្ញៈ ក៏ឈ្មោះថា ជាធម្មជាតិដែលចូលទៅតាំងនៅក្នុងអារម្មណ៍នោះហើយ តែម្យ៉ាង, ព្រះយោគាវចរ អ្នកដល់ព្រមដោយសតិសម្បជញ្ញៈនោះ ឈ្មោះថា ជាសតោការី ក៏ព្រោះសតិសម្បជញ្ញៈ ជាប់នៅជាមួយខ្យល់ដង្ហើមចូលវែងនុ៎ះឯង ។*

**"បដិនិស្សគ្គានុបស្សី អស្សាសវសេជា"តិ បដិនិស្សគ្គានុបស្សី ហុត្វា អស្សសនស្ស វសេន។**

*ទាំង ២ បទថា "***បដិនិស្សគ្គានុបស្សី អស្សាសវសេជា*** ប្រែថា ដោយអំណាចជាអ្នកពិចារណាឃើញរឿយៗ នូវការសញ្ជរទៅនៃខ្យល់ដង្ហើមចូល" ។*

"បដិនិស្សគ្គានុបស្សីអស្សាសវសេជា"តិ វា ចាហោ។

*ព្រះបាលីមានជា* "បដិនិស្សគ្គានុបស្សីអស្សាសវសេន" *ដូចនេះក៏មានដែរ ។*

តស្ស បដិនិស្សគ្គានុបស្សិនោ អស្សាសា បដិនិស្សគ្គានុបស្សី អស្សាសា, តេសំ វសេនាតិ អត្ថោ។

*សេចក្ដីថា ខ្យល់ដង្ហើមចូលរបស់ព្រះយោគាវចរនោះ ដែលពិចារណាឃើញរឿយៗ នូវការសញ្ចរទៅ ឈ្មោះថា បដិនិស្សគ្គានុបស្សីអស្សាសា, បានដល់ ដោយអំណាចនៃ បដិនិស្សគ្គានុបស្សីអស្សាសា នោះ ។*

**វិនយនយេន អន្តោ ឧដ្ឋិតសសនំ អស្សាសោ, ពហិ ឧដ្ឋិតសសនំ បស្សាសោ ។**

*តាមសេចក្ដីនៃព្រះវិន័យ ខ្យល់ដែលតាំងឡើងខាងក្នុង ឈ្មោះថា* **អស្សាស** *ប្រែថា* **ខ្យល់ចេញ**, *ខ្យល់ដែលតាំងឡើងខាងក្រៅ ឈ្មោះថា* **បស្សាស** *ប្រែថា* **ខ្យល់ចូល** ។

**សុត្តន្តនយេន បន ពហិ ឧដ្ឋហិត្វាបិ អន្តោ សសនតោ អស្សាសោ, អន្តោ ឧដ្ឋហិត្វាបិ ពហិ សសនតោ បស្សាសោ។**

*ប៉ុន្តែតាមសេចក្ដីនៃព្រះសូត្រវិញ គឺខ្យល់តាំងឡើងខាងក្រៅ ឈ្មោះថា* **អស្សាស** *ប្រែថា* **ខ្យល់ចូល** *ព្រោះមានការស្រូបខ្យល់ចូលទៅខាងក្នុង, សូម្បីខ្យល់តាំងឡើងខាងក្នុង ក៏ឈ្មោះថា* **បស្សាស** *ប្រែថា* **ខ្យល់ចេញ** *ព្រោះមានការបញ្ចេញទៅខាងក្រៅ ។*

**អយមេវ ច នយោ –**

*ក៏តាមន័យសេចក្ដីនៃព្រះសូត្រនេះឯង ដែលសមស្របជាមួយព្រះបាលីនេះដែលមានមកហើយថា ៖*

**១."អស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ អជ្ឈត្តំ វិក្ខេបគតេន ចិត្តេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ចា"តិ។**

*"កាលព្រះយោគាវចរភិក្ខុ ញុំាងសតិឱ្យតាមជាប់ខ្យល់ដង្ហើមចូលខាងដើម(ចុងច្រមុះ) កណ្ដាល(បេះដូង) និងខាងចុង(គឺត្រង់ផ្ចិត) សូម្បីកាយ និងចិត្តរមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្តដែល*

*បង្អោនទៅរកយមាយ ក្នុងខ្យល់ដង្ហើមខាងក្នុង" ។*

២. "បស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ ពហិទ្ធាវិក្ខេបគតេន ចិត្តេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ចា"តិ(២៨)ឥមាយ **ចាឡិយា** សមេតិ។

*កាលព្រះយោគាវចរភិក្ខុ ញុំាងសតិឱ្យជាប់តាមខ្យល់ដង្ហើមចេញ ខាងដើម(ត្រង់ផ្ចិត) កណ្ដាល(បេះដូង) និងខាងចុង(ត្រង់ចុងច្រមុះ) សូម្បីកាយ និងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្តដែល បង្អោនទៅរកយមាយ ក្នុងខ្យល់ដង្ហើមខាងក្រៅ" ដូច្នេះ ។*

**"បឋមំ អព្ភន្តរវាតោ ពហិ និក្ខមតិ**, តស្មា បវត្តិក្កមេន អស្សាសោ បឋមំ វុត្តោតិ វេទន្តិ។

*ព្រះអដ្ឋកថាចារ្យ លោកពោលថា **ខ្យល់ខាងក្នុង រមែងចេញទៅខាងក្រៅ** មុន, ព្រោះហេតុនោះ តាមលំដាប់ដែលប្រព្រឹត្តទៅ ទើបព្រះអង្គត្រាស់ សម្ដែង នូវខ្យល់ អស្សាស មុនដូច្នេះ ។*

**"តាលុំ អាហច្ច និព្វាយតី"**តិ តាលុំ អាហច្ច និរុជ្ឈតិ។ តេន កិរ សម្បតិជាតោ ពាលទារកោ ខិបិតំ ករោតិ។

*ពាក្យថា **"ចំណុចពិតានមាត់ រួចហើយក៏រលត់បាត់ទៅ"** គឺត្រង់ចំណុច ពិតានមាត់ ហើយក៏រលត់បាត់ទៅ ។ គប្បីជ្រាបតាមពាក្យរបស់លោកពោលទុក មកថា ទារកតូច (កូនង៉ែត) ដែលទើបនឹងកើត រមែងស្ទះនូវខ្យល់ដង្ហើម ។*

**"ឯវំ តាវា"**តិអាទិ យថាវុត្តស្ស អត្ថស្ស និគមនំ។

*ពាក្យថា **"ឯវំ តាវ"** ជាដើម ជាពាក្យពោលសំដៅដល់សេចក្ដី តាមដែល បានពោលមកហើយ ។*

កេចិ "ឯវំ តាវាតិ អនេន បវត្តិក្កមេន អស្សាសោ ពហិនិក្ខមន-

២៨ (បដិ. ម. បិដក ៧០ [៧៦] ។

វាតោតិ គហេតព្វន្តិ អធិប្បាយោ”តិ វទន្តិ។

*លោកអាចារ្យពួកខ្លះបានពោលថា “ដោយពាក្យថា* **ឯវំ តាវ** *នេះ មានសេចក្តីអធិប្បាយថា បណ្ឌិតគប្បីជ្រាប ហើយកាន់យកថា ខ្យល់* **អស្សាស** *បានដល់ ខ្យល់ដែលចេញទៅខាងក្រៅ ដែលប្រព្រឹត្តទៅ ទៅតាមលំដាប់” ដូច្នេះ ។*

“**អទ្ធានវសេនា**”តិ កាលទ្ធានវសេន។ អយំ ហិ **អទ្ធាន**-សទ្ទោ កាលស្ស, ទេសស្ស ច វាចកោ។

*ពាក្យថា “***ដោយអំណាចនៃ អទ្ធាន***” បានដល់ ដោយអំណាចនៃ* **អទ្ធាន** *គឺជាការប្រើពេលវេលា ។ ក៏សព្ទថា* **អទ្ធាន** *នេះ បានប្រាប់ដល់កាលពេលវេលា និង* **ទេស** *ប្រែថា ទីកន្លែង ។*

តត្ថ ទេសទ្ធានំ ឧទាហរណភាវេន ទស្សេត្វា កាលទ្ធានវសេន អស្សាសបស្សាសានំ ទីឃរស្សតំ វិភាវេតុំ “**យថា ហី**”តិអាទិ វុត្តំ។

*ក្នុង* **អទ្ធាន** *ទាំង ២ យ៉ាងនោះ លោកអាចារ្យប្រាថ្នានឹងសម្តែងដល់* **អទ្ធាន** *គឺ* **ទេស** *ដែលមានសេចក្តីជាឧទាហរណ៍ ហើយបើកបង្ហាញនូវសេចក្តីនៃភាពវែង និងភាពខ្លី របស់ខ្យល់អស្សាស និងបស្សាសទុក ព្រោះអំណាចនៃ* **អទ្ធាន** *គឺការប្រើពេលវេលា ទើបពោលថា “***យថា ហិ***” ដូច្នេះ ជាដើម ។*

តត្ថ “**ឱកាសទ្ធាន**”ន្តិ ឱកាសភូតំ អទ្ធានំ។ “**ផរិត្វា**”តិ ព្យាបេត្វា។

*បណ្តាបទទាំងនោះ បទថា “***ឱកាសទ្ធាន***” ប្រែថា អទ្ធាន ជាឱកាស ឬជាទីតាំង ។ បទថា “***ផរិត្វា*** *ប្រែថា* ***ផ្សាយទៅ***” ។*

**ចុណ្ណវិចុណ្ណាបិ** អនេកកលាបភាវេន។ “**ទីឃំ អទ្ធាន**”ន្តិ ទីឃំ បទេសំ។

*ឈ្មោះថា “***សូម្បីល្អិតសែនល្អិត***” ក៏ព្រោះមានច្រើនក្រុម ។ ពាក្យថា “***អទ្ធាន*** *ប្រែថា* ***ដែលវែង***” *គឺជាទីកន្លែងដែលវែង ។*

**"តស្មា"តិ សណិកំ បវត្តិយា ទីឃសន្តានតាយ "ទីឃា"តិ វុច្ចន្តិ។**

*ពាក្យថា "**ព្រោះហេតុនោះ**" មានសេចក្ដីថា ព្រោះជាប់បន្តគ្នាវែងយូរ ដែលប្រព្រឹត្តទៅយ៉ាងយឺតៗ ទើបហៅថា "វែង" ដូច្នេះ ។*

**ឯត្ថ ច ហត្ថិអាទិសរីរេ, សុនខាទិសរីរេ ច អស្សាសបស្សាសានំ ទេសទ្ធានវសិ ឥដ្ឋេន កាលទ្ធានវសេនេវ ទីឃរស្សតា វុត្តាតិ វេទិតព្វា។**

*ក្នុងសេចក្ដីនេះ បណ្ឌិតគប្បីជ្រាបថា លោកពោលថាវែង និងខ្លី នៃខ្យល់* **អស្សាស** *និង* **បស្សាស** *នៅក្នុងរាងកាយរបស់សត្វដំរី ជាដើម, និងនៅក្នុងរាងកាយរបស់សត្វសុនខ (សត្វឆ្កែ) ជាដើមនេះ ដោយអំណាចនៃ* **អទ្ធាន** *គឺជារយៈការប្រើពេលវេលា ដែលពិសេសដោយ* **អទ្ធាន** *គឺជាទីតាំងនុ៎ះឯង ។*

**"សណិកំ បូរេត្វា សណិកមេវ និក្ខមន្តិ", "សីឃំ បូរេត្វា សីឃមេវនិក្ខមន្តី"តិ ច វចនតោ។**

*ព្រោះមានពាក្យថា "ឱ្យពេញបានដោយយឺតៗ នឹងចេញមកវិញក៏យឺតៗ ដូចគ្នាដែរ", នឹងថា "ឱ្យពេញបានយ៉ាងលឿន និងចេញមកខាងក្រៅវិញ ក៏លឿនដូចគ្នា" ដូច្នេះ ។*

**"មនុស្សេសុ"តិ សមានប្បមាណេសុបិ មនុស្សសរីរេសុ។ "ទីឃំ អស្សសន្តី"តិ ទីឃំ អស្សាសប្បពន្ធំ បវត្តេន្តីតិ អត្ថោ។**

*ពាក្យថា "**ក្នុងពួកមនុស្ស**" គឺក្នុងរាងកាយរបស់មនុស្សទាំងឡាយ សូម្បីមានខ្នាតស្មើគ្នា (គឺប៉ុនគ្នា) ។ ពាក្យថា "**ដកដង្ហើមចូលវែង**" មានន័យថា ជាប់បន្តគ្នានៃខ្យល់ដង្ហើមចូលវែង ឱ្យប្រព្រឹត្តទៅ ។*

**"បស្សសន្តី"តិ ឯត្ថាបិ ឯសេវ នយោ។ សុនខសសាទយោ វិយ រស្សំ អស្សសន្តិ ច បស្សសន្តិ ចាតិ យោជនា។ ឥធំ បន ទីឃំ, រស្សញ្ច អស្សសនំ, បស្សសនញ្ច តេសំ សត្តានំ សរីរសភាវោតិ ទដ្ឋព្វំ។**

*សូម្បីក្នុងពាក្យថា "**ដកដង្ហើមចេញវែង**" នេះ ក៏មានន័យដូចគ្នា ។ សេចក្តីថា (គឺពួកខ្លះ) ដកដង្ហើមចូល និងដកដង្ហើមចេញខ្លី ដូចគ្នា នឹងសត្វទាំងឡាយដែលមានសុនខ ឬសត្វទន្សាយ ជាដើម ។ បណ្ឌិតទាំងឡាយ គប្បីឃើញថា ការដកដង្ហើមចូល និងការដកដង្ហើមចេញវែង, និងខ្លីនេះ ជាសភាពនៃសរីរៈរាងកាយរបស់សត្វទាំងនោះ ។*

"**តេស**"ន្តិ សត្តានំ។ "**តេ**"តិ អស្សាសបស្សាសា។ "**ឥត្តរមទ្ធាន**"ន្តិ អប្បកំ កាលំ។

*បទថា "**តេសំ យោគ សត្តានំ**" ប្រែថា របស់សត្វទាំងនោះ ។ បទថា "**តេ**" យោគ អស្សាសបស្សាស ប្រែថា ខ្យល់អស្សាស និងបស្សាសទាំងនោះ ។ ពាក្យថា "**អស់អទ្ធានបន្តិចបន្តួច**" គឺអស់កាលពេលវេលាតែបន្តិច ។*

## អាការៈ ៩ យ៉ាង

"**នវហាការេហី**"តិ ការេនមនុយុញ្ជន្តស្ស បុព្វេនាបរំ អលទ្ធវិសេសស្ស កោវលំ អទ្ធានវសេន អាចិតោ វុត្តា តយោ អាការា, តេ ច ខោ ឯកច្ចោ អស្សាសំ សុដ្ឋុ សល្លក្ខេតិ, ឯកច្ចោ បស្សាសំ, ឯកច្ចោ តទុភយន្តិ ឥមេសំ តិណ្ណំ បុគ្គលានំ វសេន។

*ពាក្យថា "**ដោយអាការៈ៩ យ៉ាង**" បានដល់ អាការៈ ៩ យ៉ាង ទាំងនេះគឺៈ មាន ៣ អាការៈដែលលោកបានពោលទុកនៅខាងដើម ដោយអំណាចការប្រើពេលវេលាតែម្យ៉ាង របស់ព្រះយោគាវចរភិក្ខុអ្នកបំពេញភាវនា ជាពេលដែលមិនទាន់បាននូវគុណវិសេសជាប់តៗគ្នាទៅតាមលំដាប់, ហើយ ៣ អាការៈទាំងនេះឯង លោកពោលទុកដែលជាប់ទាក់ទងជាមួយបុគ្គល ៣ ជំពូកទាំងនេះ គឺៈ*

*ទី ១ អ្នកកំណត់កាន់យកនូវខ្យល់ដង្ហើមចូលបានល្អ,*

*ទី ២ អ្នកកំណត់កាន់យកនូវខ្យល់ដង្ហើមចេញបានល្អ,*

*ទី ៣ អ្នកកំណត់កាន់យកនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញបានល្អ ។*

**កេចិ បន "អស្សសតិបិ បស្សសតិបីតិ ឯកជ្ឈំ វចនំ ភាវនាយ និរន្តរំ បវត្តិទស្សនត្ថ"ន្តិ វទន្តិ។**

*ប៉ុន្តែ លោកអាចារ្យពួកខ្លះបានពោលថា "ពាក្យដែលលោកពោលរួមគ្នាទុកថា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដូច្នេះ លោកពោលទុក ដើម្បីសម្តែងនូវការប្រព្រឹត្តទៅជាប់តៗគ្នា ដោយមិនដាច់រយៈនៃការភាវនា" ដូច្នេះ ។*

**ឆន្ទវសេន បុព្វេ វិយ តយោ, តថា បាមោជ្ជវសេនាតិ ឥមេហិ នវហាការេហិ។**

*អាការៈ ៣ យ៉ាងទៀតមានដូចគ្នាទៅនឹងអាការៈខាងដើម ហើយបន្ថែមដោយអំណាចនៃឆន្ទៈ, និង អាការៈ ៣ យ៉ាងទៀតនោះ មានដូចគ្នានឹងខាងដើមដែរ ហើយបន្ថែមដោយអំណាចនៃបាមោជ្ជៈ ដូច្នេះ ។*

**កាមំ ចេត្ថ ឯកស្ស បុគ្គលស្ស តយោ ឯវ អាការា លព្ភន្តិ, តន្តិវសេន បន សព្វេសំ ចាឡិអារុឡ្ហត្តា, តេសំ វសេន បរិកម្មស្ស កាតព្វត្តា ច "តត្រាយំ ភិក្ខុ នវហាការេហី"តិ វុត្តំ។**

*ម្យ៉ាងទៀត ក្នុងបណ្តាអាការៈទាំង ៩ យ៉ាងនេះ សម្រាប់បុគ្គលម្នាក់ រមែងចម្រើនបានតែ ៣ អាការៈតែប៉ុណ្ណោះ, ប៉ុន្តែ ដែលលោកពោលទុក (នៅក្នុងគម្ពីរវិសុទ្ធិមគ្គនោះ)ថា "**ព្រះយោគីភិក្ខុនេះ កាលដកដង្ហើមចូលវែង និងដកដង្ហើមចេញវែង ដោយអាការៈ ៩ យ៉ាង**" ដូច្នេះ ក៏ព្រោះ អាការៈទាំងពួង ឡើងកាន់ព្រះត្រៃបិដកដោយអំណាចជាក្បួនច្បាប់, និងព្រោះព្រះយោគាវចរ គប្បីចម្រើនបរិកម្មបាននោះ ដោយអំណាចនៃអាការៈទាំងនោះ ។*

**"ឯវំ បជានតោ"តិ ឯវំ យថាវុត្តេហិ អាការេហិ អស្សាសបស្សាសេ បជានតោ, តត្ថ មនសិការំ បវត្តេន្តស្ស។**

*ពាក្យថា កាលភិក្ខុនេះ "**ដឹងច្បាស់យ៉ាងនេះ**" មានន័យថា កាលភិក្ខុដឹង*

*ច្បាស់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ គឺធ្វើមនសិការឱ្យប្រព្រឹត្តិទៅក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនោះ ទៅតាមអាការៈដែលលោកបានពោលមកហើយ យ៉ាងនេះ ។*

**"ឯកេនាការេនា"**តិ ឥមេសំ អស្សាសាទីសុ ចតូសុ អាការេសុ ឯកេន អាការេន, នវសុ តីសុ វា ឯកេន។

*ពាក្យថា* ***"ដោយអាការៈ ១"*** *គឺដោយអាការៈ ១ ក្នុងបណ្ដាអាការៈទាំង ៤ យ៉ាង ដែលមានខ្យល់ដង្ហើមចូលវែង ជាដើម, ជាអាការៈ ១ ក្នុងបណ្ដាអាការៈ ៩ យ៉ាង ឬ ៣ យ៉ាង ។*

តថា ហិ វក្ខតិ –

*មែនពិត ទើបលោកពោលថា ៖*

"ទីឃោ រស្សោ ច អស្សាសោ, បស្សាសោបិ ច តាទិសោ;
ចត្តារោ វណ្ណា វត្តន្តិ, នាសិកគ្គេវ ភិក្ខុនោ"តិ។

*"អាការៈ ៤ យ៉ាង គឺខ្យល់ដង្ហើមចូលវែង១, ខ្យល់ដង្ហើមចូលខ្លី១, និងសូម្បីខ្យល់ដង្ហើមចេញ ក៏មានន័យសេចក្ដីដូចគ្នា, រមែងប្រព្រឹត្តទៅ នៅត្រង់ចុងច្រមុះរបស់ព្រះយោគីភិក្ខុនោះ" ដូច្នេះ ។*

អយំ ភាវនា អស្សាសបស្សាសកាយានុបស្សនាតិ កត្វា វុត្តំ **"កាយានុបស្សនាសតិបដ្ឋានភាវនា សម្បជ្ជតី"**តិ។

*លោកអាចារ្យបានធ្វើទុកក្នុងចិត្តថា ការភាវនានេះ ជាការពិចារណាឃើញរឿយៗនូវកាយ គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដូច្នេះឯង ហើយទើបពោលថា "សម្រេចនូវ* **កាយានុបស្សនាសតិប្បដ្ឋានភាវនា"** *ដូច្នេះ ។*

## វិធីចម្រើនអាការៈ ៩ យ៉ាង

ឥទានិ ចាឡីសសេនេវ តេ នវ អាការេ, ការនាវិធិញ្ច ទស្សេតុំ "**យថាហ**"តិអាទិ អារទ្ធំ។ តត្ថ "**កថំ បជានាតី**"តិ បជាននវិធី កថេតុ-កម្យតាយ បុច្ឆតិ។

*ឥឡូវនេះ លោកប្រាថ្នានឹងសម្ដែងនូវអាការៈទាំង ៩ យ៉ាងទាំងនោះ, និង វិធីការនាទៅតាមន័យនៃព្រះបាលីទុំះឯង ទើបបានផ្ដើមនូវពាក្យថា "**យថាហ**" ដូច្នេះ ជាដើម ។ ក្នុងបណ្ដាពាក្យទាំងនោះ មានពាក្យថា "**តើដូចម្ដេច? រមែងដឹងច្បាស់**" ថាដកដង្ហើមចេញវែង ដូច្នេះ លោកសួរ ដើម្បីជាឱកាសបានពោលប្រាប់នូវវិធីនោះឱ្យបានដឹងកាន់តែជាក់ច្បាស់ ។*

"**ទីឃំ អស្សាស**"ន្តិ វុត្តលក្ខណំ ទីឃំ អស្សាសំ។ "**អទ្ធានសង្ខាតេ**"តិ "អទ្ធាន"ន្តិ សង្ខំ គតេ ទីឃេ កាលេ, ទីឃំ ខណន្តិ អត្ថោ។

*២ បទថា "**ទីឃំ អស្សាសំ**" បានដល់ ខ្យល់ដង្ហើមចូលវែង ដែលមានលក្ខណៈ ដូចបានពោលមកហើយ ។ ពាក្យថា "**អទ្ធានសង្ខាតេ** ប្រែថា ក្នុងកាលដែលរាប់ថាវែង" គឺក្នុងកាលដែលវែង ដល់ការកំណត់រាប់បានថា "ជា **អទ្ធាន**",* មានន័យថា *អស់ខណៈពេលដែលវែង ។*

កោដ្ឋាសបរិយាយោ វា សង្ខាត-សទ្ទោ "ថេយ្យសង្ខាត"ន្តិ-អាទីសុ[២៩] វិយ, តស្មា អទ្ធានសង្ខាតេតិ អទ្ធានកោដ្ឋាសេ, ទេសភា-គេតិ អត្ថោ។

*ន័យម្យ៉ាងទៀត សព្ទថាសង្ខាត ជាពាក្យប្រើជំនួសពាក្យថា* **កោដ្ឋាស** *ដែលប្រែថា ចំណែក ដូចក្នុងពាក្យថា "**ថេយ្យសង្ខាតំ**" ប្រែថា ចំណែកនៃការលួច ជាដើម, ព្រោះហេតុនោះ ពាក្យថា* **អទ្ធានសង្ខាតេ** *ទើបមានសេចក្ដីថា* **អទ្ធានកោដ្ឋាសេ** *គឺក្នុងចំណែកដែលជាទីកន្លែង ។*

---

២៩ (បារា. ៩១) ។

## ឆន្ទៈ រមែងកើតឡើង

**"ឆន្ទោ ឧប្បជ្ជតី"**តិ ភាវនាយ បុព្វេនាបរំ វិសេសំ អាវហន្តិយា លទ្ធស្សាទត្តា តត្ថ សាតិសយោ កត្តុកាមតាលក្ខណោ កុសលច្ឆន្ទោ ឧប្បជ្ជតិ។

*ពាក្យថា **"ឆន្ទៈ រមែងកើតឡើង"** មានន័យថា ព្រោះបានទទួលភាពរីករាយត្រេកអរក្នុងការភាវនា ដែលនាំមកនូវគុណវិសេសជាប់តៗគ្នាទៅតាមលំដាប់ រីកុសលធម៌ឆន្ទៈយ៉ាងប្រសើរ ដែលមានសេចក្តីប្រាថ្នាក្នុងការបំពេញភាវនានោះជាលក្ខណៈ រមែងកើតឡើង ។*

**"ឆន្ទវសេនា"**តិ តថាបវត្តឆន្ទស្ស វសេន សវិសេសំ ភាវនមនុយុញ្ជន្តស្ស កម្មដ្ឋានំ វុឌ្ឍិ ជាតី តមេន្តស្ស។

*ពាក្យថា **"ដោយអំណាចនៃឆន្ទៈ"** គឺដោយអំណាចនៃឆន្ទៈ ដែលប្រព្រឹត្តទៅយ៉ាងនោះ ដែលញ៉ាំងកម្មដ្ឋានរបស់ព្រះយោគាវចរ អ្នកចម្រើនភាវនាឱ្យប្រព្រឹត្តទៅជាមួយគុណវិសេស ឱ្យដល់នូវសេចក្តីចម្រើនឡើងៗ ។*

**"តតោ សុខុមតរ"**ន្តិ យថាវុត្តឆន្ទប្បវត្តិយា បុរិមតោ សុខុមតរំ។

*ពាក្យថា **"ដែលល្អិតសុខុមជាងនោះ"** គឺដែលល្អិតសុខុមជាងខ្យល់មុនៗទៅទៀត ព្រោះការប្រព្រឹត្តទៅនៃឆន្ទៈ ដូចដែលបានពោលមកហើយ ។*

ភាវនាពលេន ហិ បដិប្បស្សទ្ធទរថបរិឡាហតាយ កាយស្ស អស្សាសបស្សាសា សុខុមតរា ហុត្វា បវត្តន្តិ។

*ពិតហើយ ព្រោះការរម្ងាប់នូវភាពរសាប់រសល់ និងភាពក្តៅក្រហាយនៃកាយ បានហើយ ដោយកម្លាំងនៃភាវនា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទើបប្រព្រឹត្តទៅតាមធម្មជាតិដែលល្អិតសុខុមក្រៃលែង ។*

**"បាមោជ្ជំ ឧប្បជ្ជតី"**តិ អស្សាសបស្សាសានំ សុខុមតរភាវេន

អារម្មណស្ស សន្តតរតាយ, កម្មដ្ឋានស្ស ច វីថិបដិបន្នតាយ ភាវនាចិត្ត សហគតោ បមោជ្ជោ ខុទ្ទិកាទិភេទា តរុណាបីតិ ឧប្បជ្ជតិ។

*ពាក្យថា "**បាមោជ្ជៈ រមែងកើតឡើង**" មានន័យថា ព្រោះថាកម្មដ្ឋានបានប្រព្រឹត្តទៅតាមវិថីចិត្តរួចហើយ ព្រោះការដែលមានអារម្មណ៍ស្ងប់ប្រណីតក្រៃលែងទៅៗ តាមសភាពល្អិតសុខុមនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ បាមោជ្ជៈដែលមានសហគត (ទៅជាមួយ) ដោយការភាវនាចិត្ត (គឺតរុណាបីតិ) បីតិមានសភាពបន្តិចបន្តួច ដែលមានប្រភេទជា ខុទ្ទកាបីតិ ជាដើម រមែងកើតឡើង ។*

"**ចិត្តំ វិវដ្ដតី**"តិ អនុក្កមេន អស្សាសបស្សាសានំ អតិវិយ សុខុមតរភាវប្បត្តិយា អនុបដ្ឋហនេ វិចេតញ្ញាការប្បត្តេហិ ចិត្តំ វិនិវដ្ដតីតិ កេចិ។

*ពាក្យថា "ចិត្ត រមែងងាកចេញ" លោកអាចារ្យពួកខ្លះពោលថា ក្នុងការដែលខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ (នៅពេល) ដែលមិនប្រាកដ ព្រោះដល់នូវភាពល្អិតសុខុមក្រៃលែង (ជាងមុនៗ) មកតាមលំដាប់រួចហើយ ចិត្ត រមែងងាកចេញអំពីខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះ ក៏ដល់នូវអាការៈស្វែងរកនូវខ្យល់ដង្ហើម ដូច្នេះ ។*

## ពេលពន្លឺបដិភាគនិមិត្តកើតឡើង

ភាវនាពលេន បន សុខុមតរភាវប្បត្តេសុ អស្សាសបស្សាសេសុ តត្ថ បដិភាគនិមិត្តេ ឧប្បន្នេ បកតិអស្សាសបស្សាសតោ ចិត្តំ និវត្តតិ។

*កាលពន្លឺបដិភាគនិមិត្តកើតឡើងហើយ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលដល់នូវភាពល្អិតសុខុមដ៏ក្រៃលែងដោយកម្លាំងរបស់ភាវនានោះ ចិត្តរមែងងាកចេញអំពីខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ( តោងយកនូវពន្លឺបដិភាគនិមិត្ត) ទៅតាមលំដាប់ជាធម្មតារបស់វា ។*

"**ឧបេក្ខា សណ្ឋាតី**"តិ តស្មឹ បដិភាគនិមិត្តេ ឧបចារប្បនាភេទេ សមាធិម្ហិ ឧប្បន្នេ បុន ឈាននិព្វត្តនត្थំ ព្យាបារាភាវតោ អជ្ឈុបេក្ខនំ ហោតីតិ។

*ពាក្យថា "**ឧបេក្ខា រមែងតាំងឡើង**" មានន័យថា កាលសមាធិដែលមានប្រភេទជាឧបចារ និងអប្បនា កើតឡើងហើយ ក្នុងពន្លឺបដិភាគនិមិត្តនោះ មានភាពព្រងើយកន្តើយ រមែងកើតឡើង ព្រោះតែមិនមានការព្យាយាមដើម្បីធ្វើឈានឱ្យកើតឡើងទៀត ។*

សា បនាយំ ឧបេក្ខា តត្រមជ្ឈត្តុបេក្ខាតិ វេទិតព្វា។

*ក៏ឧបេក្ខានេះ គប្បីជ្រាបថា បានដល់ តត្រមជ្ឈត្ត ឧបេក្ខា (ជាឧបេក្ខារបស់អង្គឈាន) ប្រែថា ឧបេក្ខា គឺសភាពជាកណ្តាលៗ តម្កល់ជាធម្មតាៗ ក្នុងសភាពនៃពន្លឺបដិភាគនិមិត្តនោះ ។*

"**ឥមេហិ នវហិ អាការេហី**"តិ ឥមេហិ យថាវុត្តេហិ នវហិ បការេហិ បវត្តា។

*ពាក្យថា "**ដោយអាការៈ ៩ យ៉ាងនេះ**" គឺ ដែលប្រព្រឹត្តិទៅដោយអាការៈ ៩ យ៉ាង តាមដែលបានពោលមកហើយទាំងនេះ ។*

"**ទីឃំ អស្សាសបស្សាសា កាយោ**"តិ ទីឃាការា អស្សាសបស្សាសា ចុណ្ណវិចុណ្ណាបិ សមូហដ្ឋេន កាយោ។

*ពាក្យថា "**ខ្យល់ដង្ហើមចូលវែង និងខ្យល់ដង្ហើមចេញវែង ចាត់ជាកាយ**" មានន័យថា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលមានអាការៈវែង សូម្បីល្អិតសុខុម សែនល្អិតក្រៃលែងនោះ ក៏ចាត់ទុកថាជាកាយ ដោយមានន័យថា ចាត់ទុកជាក្រុមៗ ផងដែរ ។*

អស្សាសបស្សាសេ និស្សាយ ឧប្បន្ននិមិត្តម្បេត្ថ អស្សាសបស្សាសសាមញ្ញមេវ វុត្តំ។

*សូម្បីនិមិត្ត (របស់អានាបានស្សតិ គឺប្រភេទជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត ដែលនៅមិនទាន់មានកម្លាំងនៅឡើយ) ដែលអាស្រ័យនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ទើបកើតឡើងក្នុងទីនេះ លោកក៏ពោលទុកមានសេចក្ដីស្មើដូចគ្នា ជាមួយខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ នុ៎ះឯង ។*

"**ឧបដ្ឋានំ សតី**"តិ អារម្មណំ ឧបគន្ត្វា តិដ្ឋតីតិ សតិ ឧបដ្ឋានំ ណាម។

*ពាក្យថា "**ឧបដ្ឋាន ចាត់ជាសតិ**" គឺ សតិ ឈ្មោះថា **ឧបដ្ឋាន** ព្រោះអត្ថថា ចូលទៅកាន់អារម្មណ៍នោះ ហើយតាំងនៅ ។*

"**អនុបស្សនា ញាណ**"ន្តិ សមថវសេន និមិត្តស្ស អនុបស្សនា, វិបស្សនាវសេន អស្សាសបស្សាសេ, តន្និស្សយញ្ច កាយំ "រូប"ន្តិ, ចិត្តំ តំសម្បយុត្តធម្មេ ច "អរូប"ន្តិ វវត្ថបេត្វា ណាមរូបស្ស អនុបស្សនា ច ញាណំ, តត្ថ យថាភូតាវពោធោ។

*ពាក្យថា "**អនុបស្សនា ចាត់ជាញាណ**" មានន័យថា ការពិចារណាឃើញរឿយៗ នូវនិមិត្ត ដោយអំណាចនៃសមថៈ, និងការពិចារណាឃើញរឿយៗ នូវនាមរូប ដោយកំណត់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ, និងកាយដែលជាទីអាស្រ័យនៃខ្យល់ដង្ហើមទាំងនោះ ឈ្មោះថា "ជារូប", កំណត់ចិត្ត និងធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយចិត្តនោះ ឈ្មោះថា "ជានាម" ដោយអំណាចនៃវិបស្សនា ឈ្មោះថា ជាញាណ, បានដល់ ការដឹងទៅតាមសេចក្ដីពិត ក្នុងធម៌ទាំងនោះ ។*

"**កាយោ ឧបដ្ឋាន**"ន្តិ សោ កាយោ អារម្មណាករណវសេន ឧបគន្ត្វា សតិ ឯត្ថ តិដ្ឋតីតិ ឧបដ្ឋានំ ណាម។

*ពាក្យថា "**កាយ ឈ្មោះថា ឧបដ្ឋាន**" មានន័យថា រីកាយនោះ ឈ្មោះថា ឧបដ្ឋាន ព្រោះអត្ថថា ជាកន្លែងរបស់សតិ ដែលចូលទៅហើយតាំងនៅ ដោយអំណាចធ្វើឱ្យទៅជាអារម្មណ៍ ។*

**ឯត្ថ ច "កាយោ ឧបដ្ឋាន"ន្តិ ឥមិនា ឥតរកាយស្សាបិ សង្គហោ ហោតិ យថាវុត្តសម្មសនចារស្សាបិ ឥធ ឥច្ឆិតត្តា។**

*ក្នុងសេចក្តីនេះ ពាក្យថា "**កាយ ឈ្មោះថា ឧបដ្ឋាន**" នេះ មានការសង្គ្រោះយកនូវកាយក្រៅអំពីនេះផងដែរ (គឺមិនមែនសំដៅយកចំពោះតែខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ប៉ុណ្ណោះទេ) ព្រោះក្នុងទីនេះ សូម្បីការពិចារណាទៅតាមសេចក្តី ដែលបានពោលមកហើយ លោកក៏សំដៅយកដែរ ។*

**"នោ សតី"**តិ សោ កាយោ សតិ នាម ន ហោតិ។

*ពាក្យថា "**មិនមែន ឈ្មោះថា សតិ ទេ**" គឺ កាយនោះ មិនមែន ឈ្មោះថាជា **សតិ** ទេ ។*

**"សតិ ឧបដ្ឋានញ្ចេវ សតិ ច"** សរណដ្ឋេន, ឧបតិដ្ឋនដ្ឋេន ច។

*ពាក្យថា "**សតិ ឈ្មោះថា ជាឧបដ្ឋាន ផង ឈ្មោះថា ជាសតិ ផង**" ក៏ព្រោះជាសភាវៈដែលកំណត់ដឹង (នូវខ្យល់ដង្ហើម), និងព្រោះជាសភាវៈដែលចូលទៅតម្កល់ទុក ។*

**"តាយ សតិយា"**តិ យថាវុត្តាយ សតិយា។

*ពាក្យថា "**ដោយសតិនោះ**" គឺ ដោយសតិ តាមដែលបានពោលមកហើយ ។*

**"តេន ញាណេនា"**តិ យថាវុត្តេនេវ ញាណេន។

*ពាក្យថា "**ដោយញាណនោះ**" គឺដោយញាណ តាមដែលបានពោលមកហើយ ដូចគ្នា ។*

**"តំ កាយ"**ន្តិ តំ អស្សាសបស្សាសកាយញ្ចេវ តន្និស្សយ-រូបកាយញ្ច។

*ពាក្យថា "**កាយនោះ**" គឺនូវកាយ បានដល់ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនោះ ទុំះឯង និងរូបកាយ ដែលជាទីអាស្រ័យនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនោះ ។*

**"អនុបស្សតី"តិ ឈានសម្បយុត្តញាណេន ចេវ វិបស្សនាញាណេន ច អនុ អនុបស្សតិ។**

*ពាក្យថា "**រមែងពិចារណាឃើញរឿយៗ**" គឺរមែងពិចារណាឃើញរឿយៗដោយញាណដែលសម្បយុត្តជាមួយញាណ និងដោយវិបស្សនាញាណនោះ ប៉ុណ្ណោះ ។*

**"តេន វុច្ចតិ កាយេ កាយានុបស្សនាសតិប្បដ្ឋានភាវនា"តិ តេន អនុបស្សនេន "យថាវុត្តេ កាយេ អយំ កាយានុបស្សនាសតិបដ្ឋានភាវនា"តិ វុច្ចតិ។**

*ពាក្យថា "**ព្រោះហេតុនោះ លោកពោលថា កាយានុបស្សនាសតិប្បដ្ឋានភាវនា**" មានន័យថា ព្រោះមានការពិចារណាឃើញរឿយៗនោះ ទើបហៅភាវនានេះថា "ការចម្រើនសតិប្បដ្ឋានដែលសម្បយុត្តជាមួយ ការពិចារណាឃើញរឿយៗ នូវកាយ ក្នុងកាយតាមដែលបានពោលមកហើយ" ដូច្នេះ ។*

**ឥទំ វុត្តំ ហោតិ –**

*ត្រង់ចំណុចនេះ មានពាក្យអធិប្បាយថា ៖*

**យា អយំ យថាវុត្តេ អស្សាសបស្សាសកាយេ, តស្ស និស្សយភូតេ ករជកាយេ ច កាយស្សេវ អនុបស្សនា អនុគតភូតាយ មរីចិយា ឧទកានុបស្សនា វិយ ន អនិច្ចាទិសភាវេ កាយេ និច្ចាទិភាវានុបស្សនា, អថ ខោ យថារហំ អនិច្ចទុក្ខានត្តាសុភភាវស្សេវានុបស្សនា។**

*ការពិចារណាឃើញរឿយៗ នូវកាយនោះ ក្នុងកាយ គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ តាមដែលបានពោលមកហើយ, និងក្នុងករជកាយ ដែល*

*ជាទីអាស្រ័យនៃខ្យល់ដង្ហើមចូលនោះ សេចក្តីនេះយ៉ាងណា គឺមិនមែនជាការពិចារណាឃើញរឿយៗ នូវសភាវៈថាជារបស់ទៀង ជាដើម ក្នុងកាយដែលមានសភាវៈមិនទៀងជាដើម ប្រៀបដូចជា ការឃើញនូវទឹកក្នុងថ្ងៃបណ្តើរកូន ដែលជាស្ថានទីមិនមានទឹក ក៏យ៉ាងនោះដូចគ្នា, តែថា ជាការពិចារណាឃើញរឿយៗ នូវសភាវៈជារបស់មិនទៀង ជាទុក្ខ ជាអនត្តា និងមិនស្អាតតាមសមគួរ តែប៉ុណ្ណោះ ។*

អថ វា កាយេ "អហ"ន្តិ វា "មម"ន្តិ វា "ឥត្ថី"តិ វា "បុរិសោ"តិ វា គហេតព្វស្ស កស្សចិ អភាវតោ តាទិសំ អននុបស្សិត្វា កាយមត្តស្សេវ អនុបស្សនា **កាយានុបស្សនា**, តាយ កាយានុបស្សនាយ សម្បយុត្តា សតិយេវ ឧបដ្ឋានំ **សតិប្បដ្ឋានំ**, តស្ស ភាវនា វឌ្ឍនា "**កាយានុបស្សនា-សតិប្បដ្ឋានភាវនា**"តិ។

*ន័យម្យ៉ាងទៀត ព្រោះធម្មជាតិណាៗ ដែលគប្បីប្រកាន់ថា "ជាយើង" ក្តី ថា "ជារបស់យើង" ក្តី ថា "ជាស្រី" ក្តី ថា "ជាប្រុស" ក្តី មិនមាននៅក្នុងកាយ ការពិចារណាឃើញរឿយៗ នូវធម្មជាតិបែបដូច្នោះ តែបែមកពិចារណាឃើញរឿយៗ នូវធម្មជាតិនោះថា គ្រាន់តែជាកាយតែប៉ុណ្ណោះ (បែបនេះ) ឈ្មោះថា* **កាយានុបស្សនា**, *សតិ ដែលសម្បយុត្តជាមួយកាយានុបស្សនានោះ នុ៎ះឯងជា* **ឧបដ្ឋាន** *ទើបឈ្មោះថា* **សតិប្បដ្ឋាន**, *ភាវនា គឺការចម្រើននូវសតិប្បដ្ឋាននោះ ឈ្មោះថា "***កាយានុបស្សនាសតិបដ្ឋានភាវនា***" ដូច្នេះឯង ។*

"**ឯស នយោ**"តិ "នវហិ អាការេហី"តិអាទិនា វុត្តវិធឹ វស្សបទេ អតិទិសតិ។

*ពាក្យថា "***ក៏មានន័យនេះ***" លោកសំដៅយកវិធីដែលបានពោលមកហើយ ដែលមានពាក្យថា "***នវហិ អាការេហិ***" ជាដើម ទុកក្នុងវស្សបទ (បទដែលកំណត់ដោយ ខ្យល់ដង្ហើមខ្លី) ។*

"**ឯត្ថា**"តិ ឯតស្មឹ យថាឧស្សិតេ "កាចំ ឌីឃំ អស្សសន្តោ"តិអាទិ ណា(៣០) អាគតេ ចាឡិនយេ។

*បទថា "**ឯត្ថ**" ប្រែថា ក្នុងន័យព្រះត្រៃបិដក ដែលមានមកហើយ ដែល ជាប់ទាក់ទងជាមួយបទថា "**កំណត់ទុកដោយខ្យល់ដង្ហើមវែងនេះ**" គឺក្នុងន័យ ព្រះត្រៃបិដកដែលមានមកហើយ ដោយបទថា "**កាចំ ឌីឃំ អស្សសន្តោ**" ជាដើម តាមដែលព្រះសារីបុត្តថេរៈ បានសម្ដែងទុកមកហើយ ។*

"**ឥជា**"តិ ឥមស្មឹ រស្សបទវសេន អាគតេ ចាឡិនយេ។

*បទថា "**ឥជ**" ប្រែថា ក្នុងន័យព្រះត្រៃបិដក ដែលមានមកហើយ ដោយអំណាចនៃបទដែលកំណត់ទុកដោយខ្យល់ដង្ហើមខ្លី នេះ ។*

"**អយ**"ន្តិ យោគាវចរោ។ "**អទ្ធានវសេជា**"តិ ឌីឃកាលវសេន។

*បទថា "**អយំ**" បានដល់ **យោគាវចរោ** ប្រែថា ព្រះយោគាវចរ ។ បទថា "**អទ្ធានវសេន**" ប្រែថា ដែលជាប់ទាក់ទងជាមួយកាលពេលវេលា ដែលវែង គឺ ប្រើពេលយូរ ។*

"**ឥត្តរវសេជា**"តិ បរិត្តកាលវសេន។ "**ឥមេហិ អាកាវេហី**"តិ ឥមេហិ នវហិ អាកាវេហិ ។

*បទថា "**ឥត្តរវសេន**" ប្រែថា ដែលជាប់ទាក់ទងជាមួយកាលពេលវេលា តែបន្តិចបន្តួច ។ ពាក្យថា "**ដោយអាការៈទាំងនេះ**" គឺដោយអាការៈទាំង ៩ យ៉ាងនេះ ។*

"**តាជិសោ**"តិ ឌីឃោ, រស្សោ ច។

*ពាក្យថា (និងសូម្បីខ្យល់ដង្ហើមចេញ) "**ក៏មានសភាពដូចគ្នា**" គឺដែលវែង ១ និងដែលខ្លី ១ ។*

---

*៣០ (ម. និ. ៣.១៤៨; សំ. និ. ៥.៩៨៦; បារា. ១៦៥)*

"**ចត្តារោ វណ្ណា**"តិ ចត្តារោ អាការា, តេ ច ទីឃាទយោ ឯវ។

*ពាក្យថា "**ចត្តារោ វណ្ណា** ប្រែថា អាការៈ ៤ យ៉ាង", ក៏អាការៈ ៤ យ៉ាង ទាំងនោះ បានដល់ អាការៈដែលវែង ជាដើម នុ៎ះឯង ។*

"**ជាសិកាគ្គេ វ ភិក្ខុនោ**"តិ គាថាពន្ធសុខត្ថំ រស្សំ កត្វា វុត្តំ "**ជាសិកាគ្គេ វា**"តិ, **វា**- សទ្ទោ អនិយមត្ថោ, តេន ឧត្តរោដ្ឋំ សង្គណ្ហាតិ។

*ទាំង ២ បទថា "**ជាសិកាគ្គេ វ ភិក្ខុនោ**" មានន័យថា លោកពោលដើម្បីធ្វើឱ្យទៅជារស្សបទ (ឱ្យទៅជាសម្លេងខ្លី) ថា "**ជាសិកាគ្គេវ**" (ឱ្យមកជំនួសនឹងពាក្យថា **ជាសិកាគ្គេ វា**) ដើម្បីឱ្យស្រួលក្នុងការប្រព័ន្ធជាគាថា, ពាក្យថា "**វា**" សព្ទ មានអត្ថថា មិនកំណត់ទេ, ដោយ **វា** សព្ទនេះ លោកសង្គ្រោះយកនូវបរិវេណនៃផ្ទៃបបូរមាត់ខាងលើផងដែរ ។*

# ចតុក្កៈទី ១ លំដាប់ទី ៣

## សព្វកាយប្បដិសំវេទី

(វិសុទ្ធិមគ្គ)

[២២០] "**សព្វកាយប្បដិសំវេទី អស្សសិស្សាមិ ។...បេ...។ បស្សសិស្សាមីតិ សិក្ខតី**"តិ សកលស្ស អស្សាសកាយស្ស អាទិ-មជ្ឈបរិយោសានំ វិទិតំ ករោន្តោ ចាកដំ ករោន្តោ អស្សសិស្សាមីតិ សិក្ខតិ។

*ពាក្យថា* "**សព្វកាយប្បដិសំវេទី អស្សសិស្សាមិ។...បេ...។ បស្សសិស្សាមីតិ សិក្ខតិ** *ប្រែថា ព្រះយោគីភិក្ខុ រមែងសិក្សាថា* "***អាត្មាអញ នឹងជាអ្នកកំណត់ដឹងឱ្យជាក់ច្បាស់នូវកាយ គឺខ្យល់ដង្ហើមទាំងអស់ ជាចំណែកៗ ដោយល្អក្នុងខណៈដកដង្ហើមចូល។...ល...។ ក្នុងខណៈដកដង្ហើមចេញ***"*ដូច្នេះ មានសេចក្តីថា រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកចម្រើន គឺការកំណត់ដឹងជាចំណែកៗនូវខាងដើមខ្យល់ កណ្តាលខ្យល់ និងខាងចុងខ្យល់ នៃកងខ្យល់ដង្ហើមចូលទាំងអស់ឱ្យជាក់ច្បាស់ ឱ្យប្រាកដច្បាស់" ដូច្នេះ ។*

សកលស្ស បស្សាសកាយស្ស អាទិមជ្ឈបរិយោសានំ វិទិតំ ករោន្តោ ចាកដំ ករោន្តោ បស្សសិស្សាមីតិ សិក្ខតិ។

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកចម្រើន គឺការកំណត់ដឹងជាចំណែកៗនូវខាងដើមខ្យល់ កណ្តាលខ្យល់ និងខាងចុងខ្យល់ នៃកងខ្យល់ដង្ហើមចេញទាំងអស់ឱ្យជាក់ច្បាស់ ឱ្យប្រាកដច្បាស់" ដូច្នេះ ។*

ឯវំ វិទិតំ ករោន្តោ ចាកដំ ករោន្តោ ញាណសម្បយុត្តចិត្តេន អស្សសតិ ចេវ បស្សសតិ ច ។

*ព្រះយោគាវចរ កាលចម្រើនឱ្យជាក់ច្បាស់ គឺការចម្រើនឱ្យប្រាកដច្បាស់*

*យ៉ាងនេះ ឈ្មោះថា រមែងដកដង្ហើមចូល និងដកដង្ហើមចេញ ដោយចិត្តដែលសម្បយុត្តជាមួយបញ្ញា ។*

តស្មា "អស្សសិស្សាមិ បស្សសិស្សាមី"តិ សិក្ខតីតិ វុច្ចតិ។

*ព្រោះហេតុនោះ ទើបព្រះអង្គត្រាស់ហៅ ភិក្ខុនេះថា រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងឱ្យជាក់ច្បាស់ នូវកាយ គឺខ្យល់ដង្ហើមទាំងអស់ជាចំណែកៗ ដោយល្អ ក្នុងខណៈដកដង្ហើមចូល និងខណៈដកដង្ហើមចេញ" ដូច្នេះ ។*

១. ឯកស្ស ហិ ភិក្ខុនោ ចុណ្ណវិចុណ្ណវិសដេ អស្សាសកាយេ បស្សាសកាយេ វា អាទិ ចាកដោ ហោតិ, ន មជ្ឈបរិយោសានំ។

*មែនពិត សម្រាប់ភិក្ខុរូបខ្លះ បានដឹងនូវចំណែក**ខាងដើមខ្យល់** ក្នុងខ្យល់ដង្ហើមចូល ឬចំណែករបស់ខ្យល់ ក្នុងខ្យល់ដង្ហើមចេញ ដែលបានពាល់ត្រូវហើយ បានប្រាកដច្បាស់ហើយដោយល្អិតសុខុមក្រៃលែង, ប៉ុន្តែ ចំណែកខាងកណ្តាលរបស់ខ្យល់ និងខាងចុងរបស់ខ្យល់ មិនបានប្រាកដច្បាស់ទេ ។*

សោ អាទិមេវ បរិគ្គហេតុំ សក្កោតិ, មជ្ឈបរិយោសានេ កិលមតិ។

*ភិក្ខុរូបនោះ គប្បីកំណត់កាន់យកចំពោះតែ **ខាងដើមរបស់ខ្យល់** តែប៉ុណ្ណោះបានហើយ, (ព្រោះថា) រមែងលំបាកក្នុងការកំណត់កាន់យកនៅត្រង់ខាងកណ្តាលខ្យល់ និងខាងចុងរបស់ខ្យល់ ។*

២. ឯកស្ស មជ្ឈំ ចាកដំ ហោតិ, ន អាទិបរិយោសានំ។

*សម្រាប់ភិក្ខុរូបខ្លះ បានដឹងនូវចំណែក**ខាងកណ្តាលខ្យល់** រមែងប្រាកដច្បាស់, ចំណែកឯ ខាងដើមខ្យល់ និងខាងចុងរបស់ខ្យល់ រមែងមិនប្រាកដច្បាស់ទេ ។(ព្រះយោគីភិក្ខុរូបនោះ គប្បីកំណត់កាន់យកចំពោះតែ **ខាងកណ្តាលខ្យល់** តែប៉ុណ្ណោះបានហើយ, កុំទៅកាន់យកខាងដើមខ្យល់ និងខាងចុងរបស់ខ្យល់ឡើយ ដែលនាំឱ្យលំបាកក្នុងការកំណត់កាន់យកនូវខ្យល់នោះ) ។*

**៣. ឯកស្ស បរិយោសានំ ចាកដំ ហោតិ, ន អាទិមជ្ឈំ ។**

*សម្រាប់ភិក្ខុរូបខ្លះបានដឹងនូវចំណែក* ***ខាងចុងខ្យល់*** *រមែងប្រាកដច្បាស់, ប៉ុន្តែ ខាងដើមខ្យល់ និងខាងកណ្តាលរបស់ខ្យល់ រមែងមិនប្រាកដឡើយ ។*

**សោ បរិយោសានំយេវ បរិគ្គហេតុំ សក្កោតិ, អាទិមជ្ឈេ កិលមតិ។**

*ភិក្ខុរូបនោះ គប្បីកំណត់កាន់យកចំពោះតែ* ***ខាងចុងខ្យល់*** *តែប៉ុណ្ណោះបានហើយ, កុំកាន់យកខាងដើមខ្យល់ និងខាងកណ្តាលខ្យល់ ព្រោះថា នាំឱ្យលំបាកក្នុងការកំណត់កាន់យកនូវខ្យល់នោះ ។*

**៤. ឯកស្ស សព្វម្បិ ចាកដំ ហោតិ, សោ សព្វម្បិ បរិគ្គហេតុំ សក្កោតិ, ន កត្ថចិ កិលមតិ, តាទិសេន ភវិតព្វន្តិ ទស្សេន្តោ អាហ "សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ ។...បេ...។ បស្សសិស្សាមីតិ សិក្ខតី"តិ។**

*សម្រាប់ភិក្ខុរូបខ្លះ កំណត់ដឹងបានយ៉ាងច្បាស់ប្រាកដសូម្បីខ្យល់ដង្ហើមទាំងអស់ ត្រង់កន្លែងណាក៏ដោយ (គឺខាងដើម កណ្តាល និងខាងចុង) រមែងមិនលំបាកឡើយ, ភិក្ខុរូបនោះ អាចដើម្បីកំណត់កាន់យកនូវខ្យល់ដង្ហើមនោះសូម្បីទាំងអស់ចុះ, ព្រះយោគាវចរគប្បីធ្វើឱ្យដូចក្នុងបុគ្គលទី ១ នោះ ទើបព្រះដ៏មានព្រះភាគទ្រង់សម្តែងថា រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងឱ្យជាក់ច្បាស់ នូវកាយ គឺខ្យល់ដង្ហើមទាំងអស់ ជាចំណែកៗ ដោយល្អក្នុងខណៈដកដង្ហើមចូល ។...ល...។ ក្នុងខណៈដកដង្ហើមចេញ" ដូច្នេះជាដើម ។*

**តត្ថ "សិក្ខតី"តិ ឯវំ ឃដតិ វាយមតិ។**

*បណ្តាបទទាំងនោះ បទថា "**សិក្ខតិ** ប្រែថា **រមែងខំប្រឹងប្រែង រមែងព្យាយាម**" យ៉ាងនេះ។*

**យោ វា តថាភូតស្ស សំវរោ, អយមេត្ថ អធិសីលសិក្ខា។**

*ន័យម្យ៉ាងទៀត គប្បីជ្រាបនូវសេចក្តីក្នុងបទនេះ យ៉ាងនេះថា សេចក្តីសង្រួមរបស់ភិក្ខុរូបនេះយ៉ាងណា, សេចក្តីសង្រួមនេះចាត់ជា***អធិសីលសិក្ខា***នៅក្នុងទីនេះ ។*

**យោ តថាភូតស្ស សមាធិ, អយំ អធិចិត្តសិក្ខា។**

*សមាធិរបស់ព្រះយោគីភិក្ខុ អ្នកបដិបត្តិនោះបែបណា, សមាធិនេះចាត់ជា* ***អធិចិត្តសិក្ខា*** *។*

**យា តថាភូតស្ស បញ្ញា, អយំ អធិបញ្ញាសិក្ខាតិ ឥមា តិស្សោ សិក្ខាយោ តស្មឹ អារម្មណេ តាយ សតិយា តេន មនសិការេន សិក្ខតិ អាសេវតិ ភាវេតិ ពហុលីករោតីតិ ឯវមេត្ថ អត្ថោ ទដ្ឋព្វោ។**

*សេចក្តីក្នុងពាក្យនេះ ព្រះយោគាវចរគប្បីយល់ឃើញយ៉ាងនេះថា ៖*

*បញ្ញារបស់ភិក្ខុរូបនេះ យ៉ាងណា, បញ្ញានេះចាត់ជា* ***អធិបញ្ញាសិក្ខា*** *ភិក្ខុរមែងសិក្សា គឺ រមែងសេពគប់ រមែងចម្រើន រមែងធ្វើឱ្យច្រើនឡើង នូវសិក្ខាទាំង ៣ យ៉ាងនេះ ដោយសតិនោះ ដោយមនសិការនោះ ក្នុងអារម្មណ៍នោះ ដោយប្រការយ៉ាងនេះ ដូច្នេះ ។*

**តត្ថ យស្មា បុរិមនយេ កេវលំ អស្សសិតព្វំ បស្សសិតព្វមេវ, ន ច អញ្ញំ កិញ្ចិ កាតព្វំ ។**

*ក្នុងន័យខាងដើមនោះ (គឺក្នុងចតុក្កៈទី ១ ត្រង់លំដាប់ទី ១ ជាអ្នកដកដង្ហើមចូល, ចេញវែង និងទី ២ ជាអ្នកដកដង្ហើមចូលខ្លី, ចេញខ្លី) ព្រោះហេតុដែលក្នុងលំដាប់ខាងដើមនេះ ព្រះយោគាវចរ គប្បីដកដង្ហើមចូល និងដកដង្ហើមចេញ តែម្យ៉ាងប៉ុណ្ណោះបានហើយ, មិនគប្បីធ្វើកិច្ចអ្វីៗដទៃផ្សេងទេ ។*

## ត្រូវព្យាយាមឱ្យបញ្ញាកើតឡើង

**តតោ បដ្ឋាយ បន ញាណុប្បាទនាទីសុ យោគោ ករណីយោ ។**

*ប៉ុន្តែ បន្ទាប់ពីលំដាប់ទី៣ នេះទៅ (ក្នុងចតុក្កទី១ដដែល) គប្បីធ្វើសេចក្តីព្យាយាមក្នុងកិច្ច ដែលមានការធ្វើបញ្ញាឱ្យកើតឡើងជាដើម ។*

**តស្មា តត្ថ អស្សសាមីតិ បជានាតិ បស្សសាមីតិ បជានាតិច្ចេវ វត្តមានកាលវសេន បាឡឹ វត្វា តតោ បដ្ឋាយ កត្តព្វស្ស ញាណុប្បាទនាទិនោ អាការស្ស ទស្សនត្ថំ "សព្វកាយប្បដិសំវេទី អស្សសិស្សាមី"តិអាទិនា នយេន អនាគតវចនវសេន បាឡិ អារោបិតាតិ វេទិតព្វា ។**

*ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្តែងនូវព្រះបាលីដោយអំណាចជាបច្ចុប្បន្នកាលថា* **អស្សសាមីតិ បជានាតិ** *រមែងដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចូល (វែង និងខ្លី)"* , **បស្សសាមីតិ បជានាតិ** *រមែងដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចេញ (វែង និងខ្លី)" ដូច្នេះ ទុកក្នុងលំដាប់ទី១ និងលំដាប់ទី២ខាងដើមនោះ ហើយទើបទ្រង់ត្រាស់សម្តែងនូវព្រះធម្មទេសនាបាលីបន្ថែមទៀតដោយអំណាចជាពាក្យវិភត្តិដែលសម្តែងជាអនាគតកាល ក្នុងលំដាប់ទី៣ ថា* **"សព្វកាយប្បដិសំវេទី អស្សសិស្សាមី"តិអាទិ** *(រមែងសិក្សាថា) "អាត្មាអញ នឹងជាអ្នកកំណត់ដឹងឱ្យជាក់ច្បាស់នូវកាយ គឺខ្យល់ដង្ហើមទាំងអស់ ជាចំណែកៗ ដោយល្អក្នុងខណៈដកដង្ហើមចូល" ដូច្នេះ ជាដើម, ដើម្បីព្រះអង្គនឹងសម្តែងនូវអាការៈដែលមាន ការធ្វើបញ្ញាឱ្យកើតឡើងជាដើម ដែលសមគួរក្នុងការចម្រើនតាំងតែពីលំដាប់ទី៣ នេះតទៅ ។*

**បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ។...បេ...។ បស្សសិស្សាមីតិ សិក្ខតីតិ ឱឡារិកំ កាយសង្ខារំ បស្សម្ភេន្តោ បដិប្បស្សម្ភេន្តោ និរោធេន្តោ វូបសមេន្តោ អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតិ។**

*ពាក្យថា រមែងសិក្សាថា "**អាត្មាអញ នឹងជាអ្នកធ្វើកាយសង្ខារ** គឺខ្យល់ដង្ហើមដែលគ្រោតគ្រាតៗឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចូល ។...ល...។ ក្នុងខណៈដកដង្ហើមចេញ" មានន័យសេចក្ដីថា រមែងសិក្សាថា "**អាត្មាអញ នឹងជាអ្នកធ្វើកាយសង្ខារ** ដែលគ្រោតគ្រាត (គឺខ្យល់ដង្ហើមដែលគ្រោតគ្រាត) ឱ្យរលត់បាត់ ឱ្យស្ងប់រម្ងាប់ ឱ្យរលត់ ឱ្យរលត់ស្ងប់ ក្នុងខណៈដកដង្ហើមចូល និងក្នុងខណៈដកដង្ហើមចេញ" ដូច្នេះ ។*

**តត្រ ឯវំ ឱឡារិកសុខុមតា ច បស្សទ្ធិ ច វេទិតព្វា។**

*ក្នុងពាក្យនោះ គប្បីជ្រាបនូវសភាវៈដែលគ្រោតគ្រាតជាមួយនឹងភាពល្អិតសុខុម និងសេចក្ដីរលត់ស្ងប់ យ៉ាងនេះ ។*

**ឥមស្ស ហិ ភិក្ខុនោ បុព្វេ អបរិគ្គហិតកាលេ កាយោ ច ចិត្តញ្ច សទរថា ហោន្តិ ឱឡារិកា។**

(**តាមន័យសមថៈ**) *មែនពិត កាយ និងចិត្តរបស់ភិក្ខុរូបនោះ ក្នុងកាលមុន គឺក្នុងពេល ដែលមិនទាន់បានកំណត់ដឹង (នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនេះ) ចិត្តជាធម្មជាតិដែលមានសភាពរសាប់រសល់ (ដល់កាយ និងចិត្ត) ទើបឈ្មោះថា មានសភាពគ្រោតគ្រាត ។*

**កាយចិត្តានំ ឱឡារិកត្តេ អវូបសន្តេ អស្សាសបស្សាសាបិ ឱឡារិកា ហោន្តិ, ពលវតរា ហុត្វា បវត្តន្តិ, នាសិកា នប្បហោតិ, មុខេន អស្សសន្តោបិ បស្សសន្តោបិ តិដ្ឋតិ ។**

*កាលកាយ និងចិត្តមានសភាពជាធម្មជាតិ ដែលគ្រោតគ្រាតមិនស្ងប់ហើយ សូម្បីខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ក៏ជារបស់ដែលគ្រោតគ្រាតផងដែរ, ហើយប្រព្រឹត្តទៅយ៉ាងមានកម្លាំងក្រៃលែង, ធ្វើឱ្យច្រមុះមិនគ្រប់គ្រាន់ក្នុងការដកដង្ហើម, គឺត្រូវឈរដកដង្ហើមចូលផង និងដកដង្ហើមចេញផងទៅតាមមាត់បន្ថែមទៀត ។*

យទា បនស្ស កាយោបិ ចិត្តម្បិ បរិគ្គហិតា ហោន្តិ, តទា តេ សន្តា ហោន្តិ វូបសន្តា ។

*ចំណែកក្នុងពេលណា ទាំងកាយ ទាំងចិត្តរបស់ភិក្ខុនោះ គឺត្រូវបានកំណត់យកអារម្មណ៍កម្មដ្ឋានហើយ, ក្នុងពេលនោះ ទាំងកាយផង និងទាំងចិត្តផង ជាធម្មជាតិដែលស្ងប់រម្ងាប់ គឺបានចូលទៅស្ងប់រម្ងាប់យ៉ាងពិសេសហើយ ។*

តេសុ វូបសន្តេសុ អស្សាសបស្សាសា សុខុមា ហុត្វា បវត្តន្តិ, "អត្ថិ នុ ខោ នត្ថី"តិ វិចេតព្វតាការប្បត្តា ហោន្តិ។

*កាលកាយ និងចិត្តនោះ បានស្ងប់រម្ងាប់ហើយ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ រមែងប្រព្រឹត្តទៅយ៉ាងល្អិតសុខុម, រហូតដល់អាការៈ ដែលនឹងកំណត់រកថា "តើមាន ឬក៏ មិនមានទេហ្ន៎" ដូច្នេះ ។*

សេយ្យថាបិ បុរិសស្ស ធាវិត្វា, បព្វតា វា ឱរោហិត្វា, មហាភារំ វា សីសតោ ឱរោបេត្វា ឋិតស្ស ឱឡារិកា អស្សាសបស្សាសា ហោន្តិ, នាសិកា នប្បហោតិ, មុខេន អស្សសន្តោបិ បស្សសន្តោបិ តិដ្ឋតិ។

*ឧបមាដូចជា កាលបុរសម្នាក់បានរត់ចុះមកអំពីភ្នំ, ឬបុរសម្នាក់បានទម្លាក់ភារៈដ៏ធ្ងន់ចេញអំពីក្បាល ហើយក៏បានឈរដកដង្ហើមចូលផង និងដកដង្ហើមចេញផង (ខ្យល់នោះ) រមែងជាខ្យល់ដែលគ្រោតគ្រាត, ធ្វើឱ្យច្រមុះដកដង្ហើមមិនទាន់, ក៏ត្រូវឈរដើម្បីដកដង្ហើមចូលផង និងដកដង្ហើមចេញផងតាមមាត់បន្ថែមទៀត ។*

យទា បនេស តំ បរិស្សមំ វិនោទេត្វា ន្ហត្វា ច បិវិត្វា ច អល្លសាដកំ ហទយេ កត្វា សីតាយ ឆាយាយ និបន្នោ ហោតិ, អថស្ស តេ អស្សាសបស្សាសា សុខុមា ហោន្តិ "អត្ថិ នុ ខោ នត្ថី"តិ វិចេតព្វតាការប្បត្តា, ឯវមេវ ឥមស្ស ភិក្ខុនោ បុព្វេ អបរិគ្គហិតកាលេ កាយោ ច។...បេ...។ វិចេតព្វតាការប្បត្តា ហោន្តិ។

*ប៉ុន្តែ ក្នុងពេលណាបុរសនោះបានបន្ថយនូវភាពនឿយហត់នោះ ដោយការងូតទឹក និងផឹកទឹករួចហើយ បានយកក្រណាត់សើមមកគ្របដណ្តប់នៅលើដើមទ្រូង ហើយដេកសម្រាកនៅក្រោមម្លប់ដើមឈើដ៏ត្រជាក់, ក្នុងពេលនោះខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ របស់បុរសនោះ រមែងជាខ្យល់ល្អិតសុខុម ដល់នូវអាការៈដែលនឹងគិតថា "តើមាន ឬក៏ មិនមានទេហ្ន៎" ដូច្នេះ យ៉ាងណាមិញ, កាយ និងចិត្តក្នុងកាលមុន គឺក្នុងពេលដែលមិនទាន់បានកំណត់ (អានាបានស្សតិកម្មដ្ឋាន) របស់ភិក្ខុរូបនេះ ។...ល...។ ដល់នូវអាការៈដែលនឹងគិតថា "តើមាន ឬក៏ មិនមានទេហ្ន៎" ក៏យ៉ាងនោះដូចគ្នា ។*

**តំ កិស្ស ហេតុ?**

*សួរថា តើសេចក្តីនោះ ព្រោះហេតុអ្វី?*

**តថា ហិស្ស បុព្វេ អបរិគ្គហិតកាលេ "ឱឡារិកោឡារិកេ កាយសង្ខារេ បស្សម្ភេមី"តិ អាភោគសមន្នាហារមនសិការបច្ចវេក្ខណា នត្ថិ, បរិគ្គហិតកាលេ បន អត្ថិ ។**

*ឆ្លើយថា "ព្រោះតាមសេចក្តីពិត ក្នុងកាលមុន គឺក្នុងពេលដែលមិនទាន់បានកំណត់ (នូវកម្មដ្ឋាននេះ) នៅឡើយ ភិក្ខុនោះ រមែងមិនមានក្នុងការរំពឹងគិត ដល់ការប្រមូលនូវចិត្ត ការធ្វើទុកក្នុងចិត្ត និងការពិចារណាថា "អាត្មាអញ នឹងធ្វើនូវកាយសង្ខារ គឺខ្យល់ដង្ហើមដែលគ្រោតគ្រាតៗ ឱ្យរលត់បាត់" ដូច្នេះ, ប៉ុន្តែថា ក្នុងពេលដែលបានកំណត់ទុក (នូវកម្មដ្ឋាននេះទុកក្នុងចិត្តរួចហើយ), ទើបមានសភាពស្ងប់រម្ងាប់ (ទៅរឿយៗ) ។*

**តេនស្ស អបរិគ្គហិតកាលតោ បរិគ្គហិតកាលេ កាយសង្ខារោ សុខុមោ ហោតិ ។**

*ព្រោះហេតុនោះ កាយសង្ខារគឺខ្យល់ដង្ហើមរបស់ភិក្ខុនោះ ក្នុងពេលដែលបានកំណត់ (នូវកម្មដ្ឋាន) រួចហើយ រមែងល្អិតសុខុមជាងពេលដែលមិនទាន់*

*បានកំណត់ ។*

តេនាហុ បោរាណា –

*ព្រោះហេតុនោះ បានជាបោរាណាចារ្យទាំងឡាយ លោកពោលថា៖*

"សារទ្ធេ កាយេ ចិត្តេ ច, អធិមត្តំ បវត្តតិ;

អសារទ្ធម្ហិ កាយម្ហិ, សុខុមំ សម្បវត្តតី"តិ(៣១)។

*"កាលបើកាយ និងចិត្ត ក្រវល់ក្រវាយហើយ រីកាយសង្ខារគឺខ្យល់ដង្ហើមទាំងឡាយ ក៏រមែងប្រព្រឹត្តទៅដោយសភាពគ្រោតគ្រាតផងដែរ, កាលបើកាយនិងចិត្ត មិនក្រវល់ក្រវាយទេ រីកាយសង្ខារគឺខ្យល់ដង្ហើមទាំងឡាយ រមែងប្រព្រឹត្តទៅ ដែលមានសភាពល្អិតសុខុមៗក្រៃលែង" ដូច្នេះ ។*

## សព្វកាយប្បដិសំវេទី

**(មហាដីកាវិសុទ្ធិមគ្គ)**

[២២០] "**សព្វកាយប្បដិសំវេទី**"តិ សព្វស្ស កាយស្ស បដិ បដិ បច្ចេកំ សម្មទេវ វេទនសីលោ ជាននសីលោ, តស្ស វា បដិ បដិ សម្មទេវ វេទោ ឯតស្ស អត្ថិ, តំ វា បដិ បដិ សម្មទេវ វេទមានោតិ អត្ថោ។

*បទថា "**សព្វកាយប្បដិសំវេទី**" មានវិគ្រោះថា ជាអ្នកមានប្រក្រតីដឹង គឺជាអ្នកកំណត់ដឹងឱ្យជាក់ច្បាស់ នូវកាយគឺខ្យល់ដង្ហើមទាំងអស់ ជាចំណែកៗ ដោយល្អ តែម្យ៉ាងៗ, មានន័យថា ជាអ្នកកំណត់ដឹង ជាចំណែកៗ ដោយល្អ នូវខ្យល់ដង្ហើមទាំងអស់នោះ, ឬការដឹងដោយល្អនូវខ្យល់ដង្ហើមទាំងអស់នោះ ជាចំណែកៗ ។*

តត្ថ តត្ថ សព្វគ្គហណេន អស្សាសាទិកាយស្ស អនវសេសប-

---

*៣១ (បាវ. អដ្ឋ. ២.១៦៥) ។*

វិយាធានេ សិទ្ធេបិ អនេកាកលាបសមុទាយភាវតោ តស្ស សព្វស្សបិ ភាគាធំ សំវេទនទស្សនត្ថំ បដិ-សទ្ទគ្គហណំ។

*ក្នុងបណ្ដាបទទាំងនោះ លោកអាចារ្យ កាលនឹងសម្ដែងនូវសេចក្ដីនេះ ក្នុងបទថា* **សព្វកាយប្បដិសំវេទី** *(**សព្វ** ប្រែថា **ទាំងអស់** , **កាយ** ប្រែថា **ខ្យល់ដង្ហើម** , **បដិ** ប្រែថា **ចំណែក** ,**សំ** ប្រែថា **ដោយល្អ** , **វេទី** ប្រែថា **ការដឹង, ដឹងឱ្យជាក់ច្បាស់**)នោះ សូម្បីកាលកាន់យកនូវកាយ ដែលមិនមានការលើកលែងនូវកាយ មានខ្យល់ដង្ហើមចូល ជាដើម សម្រេចហើយដោយសព្ទថា **សព្វ** ប្រែថា **ទាំងអស់** ក៏ទ្រង់នៅមានការកាន់យកនូវសព្ទថា **បដិ** ប្រែថា **ចំណែក** ដើម្បីសម្ដែងការដឹងនូវកាយ គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនោះ សូម្បីគ្រប់ៗ ចំណែក ព្រោះមានការរួបរួមគ្នាជាច្រើនចំណែក ។*

តត្ថ សក្កច្ចការីភាវទស្សនត្ថំ សំ-សទ្ទគ្គហណន្តិ ឥមមត្ថំ ទស្សេន្តោ "**សកលស្ស**"តិអាទិមាហ ។

*ការកាន់យក សព្ទថា **សំ** ប្រែថា **ដោយល្អ** គឺសម្ដែងនូវភាពជាអ្នកចម្រើនការនោយ៉ាងគោរពក្នុងសេចក្ដីដឹងនោះ ដូច្នោះទើបពោលថា "**សកលស្ស**" ដូច្នេះ ជាដើម ។*

តត្ថ យថា សមានេបិ អស្សាសបស្សាសេសុ យោគិនោ បដិបត្តិវិ-ធានេ បច្ចេកំ សក្កច្ចំយេវ បដិបជ្ជិតព្វន្តិ ទស្សេតុំ វិសុំ ទេសនា កតា, ឯវំ តមេវត្ថំ ទីបេតុំ សតិបិ អត្ថស្ស សមានតាយ "សកលស្ស"តិអាទិនា បទទ្វយស្ស វិសុំ វិសុំ អត្ថវណ្ណនា កតាតិ វេទិតព្វំ ។

*បណ្ដាពាក្យទាំងឡាយនោះ លោកអាចារ្យធ្វើព្រះធម្មទេសនាទុកញែកចេញផ្សេងៗពីគ្នា (ជាចំណែក) ក៏ដើម្បីសម្ដែងថា ក្នុងវិធីបដិបត្តិនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ សូម្បីដែលមានហើយដល់ព្រះយោគីព្រះយោគាវចរភិក្ខុនោះ គប្បីបដិបត្តិក្នុងវិធីនីមួយៗ ដោយសេចក្ដីគោរពផងចុះ*

*ដូច្នេះ, សូម្បីនឹងមានសេចក្ដីនោះៗ ដូចគ្នា (ក៏ដោយ) ក៏គប្បីជ្រាបថា លោកធ្វើការពណ៌នានូវអត្ថនៃបទទាំង ២ ញែកចេញផ្សេងពីគ្នា ដោយបទថា "**សកលស្ស**" ជាដើម ដើម្បីសម្ដែងនូវសេចក្ដីដូចដែលបានពោលមកហើយនោះ នុ៎ះឯង ។*

**"ចាកដំ ករោន្តោ"**តិ វិភូតំ ករោន្តោ, សព្វសោ វិភាវេន្តោតិ អត្ថោ ។

*ពាក្យថា "**ធ្វើឱ្យប្រាកដជាក់ច្បាស់**" គឺធ្វើឱ្យជាក់ច្បាស់ មានន័យថា ធ្វើឱ្យជាក់លាក់ ដោយប្រការទាំងពួង ។*

ចាកជីករណំ វិភាវនំ តត្ថ អសម្មុយ្ហនំ ញាណេនេវ នេសំ បវត្តនេន ហោតីតិ ឧស្សេន្តោ "**ឯវំ វិទិតំ ករោន្តោ**"តិអាទិមាហ ។

*លោកអាចារ្យ កាលនឹងសម្ដែងថា ធ្វើឱ្យប្រាកដជាក់ច្បាស់ គឺធ្វើឱ្យមិនប្រែប្រួល ជាការមិនវង្វេងក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ទាំងនោះរមែងមាន បានដោយការធ្វើខ្យល់ដង្ហើមទាំងនោះឱ្យប្រព្រឹត្តទៅប្រកបដោយបញ្ញា តែប៉ុណ្ណោះ ដូច្នេះ ទើបពោលថា "**អាត្មាអញ នឹងធ្វើឱ្យដឹងជាក់ច្បាស់យ៉ាងនេះ**" ដូច្នេះជាដើម ។*

តត្ថ "**តស្មា**"តិ យស្មា ញាណសម្បយុត្តចិត្តេនេវ អស្សាសបស្សាសេ បវត្តេតិ, ន វិប្បយុត្តចិត្តេន, តស្មា ឯវំភូតោ សព្វកាយបដិសំវេទី អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតីតិ វុច្ចតិ ពុទ្ធាទីហីតិ យោជនា ។

*ក្នុងពាក្យទាំងនោះ ពាក្យថា "**ព្រោះហេតុនោះ**" មានសេចក្ដីថា ព្រោះហេតុដែលព្រះយោគាវចរភិក្ខុ ជាអ្នកចម្រើននូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឱ្យប្រព្រឹត្តទៅដោយចិត្តដែលសម្បយុត្តជាមួយបញ្ញា នុ៎ះឯង, មិនបានធ្វើ ឱ្យប្រព្រឹត្តទៅដោយចិត្តដែលវិប្បយុត្តប្រាសចាកបញ្ញាទេ, ព្រោះដូច្នោះ បណ្ឌិតទាំងឡាយ ដែលមានព្រះសម្មាសម្ពុទ្ធជាដើម ទើបទ្រង់ត្រាស់ហៅ*

*ភិក្ខុនោះយ៉ាងនេះថា រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងឱ្យជាក់ច្បាស់នូវកាយ គឺខ្យល់ដង្ហើមទាំងអស់ ជាចំណែកៗ ដោយល្អ ក្នុងខណៈដកដង្ហើមចូល និងក្នុងខណៈដកដង្ហើមចេញ" ដូច្នេះ ។*

"**ចុណ្ណវិចុណ្ណវិសដេ**"តិ អនេកកលាបតាយ ចុណ្ណវិចុណ្ណភាវេន វិសដេ ។

*ពាក្យថា "(**ខ្យល់ដង្ហើមទាំងអស់) ដែលផ្សាយទៅល្អិតសុខុមក្រៃលែង**" គឺដែលផ្សាយទៅ ដោយសភាវៈជាធម្មជាតិដែលល្អិតសុខុម ព្រោះភាពជាក្រុមៗច្រើនក្រុមក្រៃលែង ។*

"**អាទិ ថាមជោ ហោ**"តិ សតិយា, ញាណស្ស ច វសេន តថា បុញ្ញាភិសង្ខារស្ស បវត្តត្តា ។

*ឈ្មោះថា "**ខាងដើមខ្យល់ប្រាកដជាក់ច្បាស់**" ព្រោះបុញ្ញាភិសង្ខារប្រព្រឹត្តទៅយ៉ាងនោះ ដោយអំណាចនៃសតិ និងញាណ ។*

"**តាទិសេន ភវិតព្វ**"ន្តិ ចតុត្ថបុគ្គលសទិសេន ភវិតព្វំ, បគេវ សតី, ញាណញ្ច បច្ចុបដ្ឋបេត្វា តីសុបិ ឋានេសុ ញាណសម្បយុត្តមេវ ចិត្តំ បវត្តេតព្វន្តិ អធិប្បាយោ ។

*ទាំង ២ បទថា "**តាទិសេន ភវិតព្វំ**" គឺគប្បីឱ្យដូចបុគ្គលទី ៤, អធិប្បាយថា គប្បីចម្រើននូវសតិ និងបញ្ញាឱ្យកើតឡើងប្រាកដជាមុនសិន ហើយធ្វើចិត្តដែលសម្បយុត្តជាមួយបញ្ញានោះ ឱ្យប្រព្រឹត្តទៅក្នុងឋានៈទាំង ៣ (គឺ ១ ខ្យល់ខាងដើម, ២ ខ្យល់កណ្ដាល, ៣ ខ្យល់ខាងចុង) ។*

"**ឯវ**"ន្តិ វុត្តប្បការេន សព្វកាយបដិសំវេទនវសេនេវ ។

*ពាក្យថា "**ឯវំ ប្រែថា យ៉ាងនេះ**" បានដល់ តាមប្រការដូចបានពោលមកហើយ គឺដោយអំណាចការកំណត់ខ្យល់ដង្ហើមទាំងអស់ឱ្យជាក់ច្បាស់ នុ៎ះឯងៗ*

"**ឃដតី**"តិ ឧស្សហតិ។ "**វាយមតី**"តិ វាយាមំ ករោតិ, មនសិការំ បវត្តេតីតិ អត្ថោ ។

*ពាក្យថា "**រមែងខំប្រឹងប្រែង**" គឺ រមែងឧស្សាហ៍ ។ ពាក្យថា "**រមែងព្យាយាម**" គឺ រមែងសង្វាតមិនខ្ជិលច្រអូស, មានន័យថា រមែងធ្វើមនសិការឱ្យប្រព្រឹត្តទៅ ។*

"**តថាភូតស្ស**"តិ អាជាចាជស្សតី ភាវេន្តស្ស។ "**សំវរោ**"តិ សតិ, វីរិយម្បិ វា។

*ពាក្យថា របស់ភិក្ខុ "**ជាអ្នកយ៉ាងនោះ**" គឺ របស់ភិក្ខុអ្នកចម្រើននូវអានាបានស្សតិ ។ ពាក្យថា "**សេចក្តីសង្រួម**" បានដល់ សតិ ឬ សូម្បីតែវីរិយៈ ។*

"**តាយ សតិយា**"តិ យា អាជាចាជេ អារព្ភ បវត្តា សតិ, តាយ។

*ពាក្យថា "**ដោយសតិនោះ**" គឺ ដោយសតិដែលបានប្រព្រឹត្តទៅប្រារព្ធនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ។*

"**តេន មនសិការេជា**"តិ យោ សោ តត្ថ សតិបុព្វង្គមោ ភាវនាមនសិការោ, តេន សទ្ធិន្តិ អធិប្បាយោ។

*ពាក្យថា "**ដោយមនសិការនោះ**" គឺ ដោយការធ្វើទុកក្នុងចិត្តនូវការភាវនាដែលមានសតិជាប្រធានក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនោះ ។*

**អាសេវតីតិ** "តិស្សោ សិក្ខាយោ"តិ វុត្តេ អធិកុសលធម្មេ អាសេវតិ។

*ពាក្យថា "**រមែងសេពគប់**" គឺ រមែងសេពគប់នូវអធិកុសលធម៌ទាំងឡាយដែលហៅថា "សិក្ខា ៣" ។*

តជាសេវជញ្ញោត្ត សិក្ខន្តិ អធិប្បេតំ។

*ការសេពគប់នូវអធិកុសលធម៌នោះ លោកប្រាថ្នាហើយថា ជាការសិក្សា*

*ក្នុងទីនេះ ។*

**"បុរិមនយេ"**តិ បុរិមស្មឹ ការណនយេ, បឋមវត្ថុទ្វយេតិ អធិប្បាយោ។

*ពាក្យថា **"ក្នុងន័យខាងដើម"** (គឺក្នុងចតុក្កទី ១ ត្រង់លំដាប់ទី ១ ជាអ្នកដកដង្ហើមចូល, ចេញវែង និងទី ២ ជាអ្នកដកដង្ហើមចូលខ្លី, ចេញខ្លី) ក្នុងន័យការការនាខាងដើមនេះ, អធិប្បាយថា ក្នុងលំដាប់ទាំង ២ យ៉ាងខាងដើមនោះ ។*

តត្ថាបិ កាមំ ញាណុប្បាទនំ លព្ភតេវ អស្សាសបស្សាសានំ យាថាវតោ ទីឃរស្សភាវាវពោធសព្ភាវតោ, តថាបិ តំ ន ទុក្ករំ យថាបវត្តានំ តេសំ គហណមត្តភាវតោតិ តត្ថ វត្តមានកាលប្បយោគោ កតោ ឥធំ បន ទុក្ករំ បុរិសស្ស ខុរធារាយំ គមនសទិសំ, តស្មា សាតិសយេនេត្ថ បុព្វាភិសង្ខារេន ភវិតព្វន្តិ ទីបេតុំ អនាគតកាលប្បយោគោ កតោតិ ឥមមត្ថំ ទស្សេតុំ **"តត្ថ យស្មា"**តិអាទិ វុត្តំ ។

*លោកអាចារ្យ ប្រាថ្នាសម្ដែងនូវសេចក្ដីនេះថា សូម្បីក្នុងន័យខាងដើមនោះ ដែលព្រះអង្គសម្ដែងនូវវិភត្តិជាបច្ចុប្បន្នកាលថា* **អស្សសាមិ** *ដកដង្ហើមចូល និង* **បស្សសាមិ** *ដកដង្ហើមចេញ រមែងធ្វើនូវបញ្ញាញាណឱ្យកើតឡើងបានដូចគ្នា ព្រោះមានការដឹងនូវសភាវៈរបស់ខ្យល់ដែលវែង និងខ្លី នៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ទៅតាមសេចក្ដីយ៉ាងពិតប្រាកដ, សូម្បីដូច្នោះ ការធ្វើបញ្ញាញាណឱ្យកើតឡើងនោះ មិនមែនជាកិច្ចដែលធ្វើបានដោយលំបាកនោះទេ ព្រោះមានត្រឹមតែការកំណត់យកនូវខ្យល់ដង្ហើមនោះដែលប្រព្រឹត្តទៅប៉ុណ្ណោះឯង ព្រោះហេតុនោះ ក្នុងលំដាប់ទី១ និងលំដាប់ទី២ ព្រះដ៏មានព្រះភាគ ទើបធ្វើការប្រកបពាក្យពោលទុកជាបច្ចុប្បន្នកាល (គឺមានពាក្យថា* **អស្សសាមិ** *ប្រែថា រមែងដកដង្ហើមចូល,* **បស្សសាមិ** *ប្រែថា រមែងដកដង្ហើមចេញ) ទ្រង់ប្រាថ្នាសម្ដែងថា ជាការធ្វើបញ្ញាញាណឱ្យកើតឡើងបានហើយ, ចំណែកក្នុងលំដាប់ទី៣ នេះ ជាកិច្ចដែលធ្វើបានដោយលំបាក ដូចជាការដើរ*

*លើមុខកាំបិតរបស់បុរស, ព្រោះដូច្នោះ ទើបជាអ្នកត្រូវមានបុញ្ញាភិសង្ខារ ក្នុងរឿងនេះ ទើបព្រះអង្គទ្រង់សម្ដែងជាពាក្យអនាគតកាលថា "**អស្សសិស្សាមិ**" នឹងដកដង្ហើមចូល, "**បស្សសិស្សាមិ**" នឹងដកដង្ហើមចេញ ដូច្នេះ ហើយសម្ដែងថា "**ក្នុងចតុក្កៈខាងដើមនោះ ព្រោះហេតុណា**" ដូច្នេះ ជាដើម ។*

**តត្ថ ញាណុប្បាទនាទីសុ** **អាទិ**-**សទ្ទេន កាយសង្ខារបស្សម្ភន-បីតិប្បដិសំវេទនាទីនំ សង្គណ្ហាតិ។**

*ក្នុងពាក្យទាំងនោះ ពាក្យថា ក្នុងកិច្ចមាន**ការធ្វើបញ្ញាញាណឱ្យកើតឡើងជាដើម** ដោយ **អាទិ** សព្ទ ប្រែថា **ជាដើម** លោករួបរួមយកការធ្វើកាយសង្ខារឱ្យរលត់បាត់ (ដែលជាលំដាប់ទី ៤ ផងដែរ) និងការធ្វើបីតិឱ្យដឹងជាក់ច្បាស់ (ដែលជាលំដាប់ទី ៥ ក្នុងចតុក្កទី២ នោះតទៅផងដែរ ) ទុកយ៉ាងនេះ ជាដើម ។*

**កេចិ បនេត្ថ "សំវរសមាទានានំ សង្គហោ"តិ វទន្តិ ។**

*តែថា ក្នុងពាក្យថា ក្នុងកិច្ចមានធ្វើបញ្ញាញាណឱ្យកើតឡើងជាដើមនេះ លោកអាចារ្យពួកខ្លះ ពោលថា "មានការរួមយកនូវសេចក្ដីសង្រួម និងការសមាទានផងដែរ" ដូច្នេះ ។*

# ចតុក្កៈទី ១ លំដាប់ទី ៤

## បស្សម្ភយំ កាយសង្ខារំ

### (វិសុទ្ធិមគ្គ)

**“កាយសង្ខារ”ន្តិ** អស្សាសបស្សាសំ។

*ពាក្យថា **“កាយសង្ខារ”** បានដល់ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ។*

**សោ ហិ ចិត្តសមុដ្ឋានោបិ សមានោ ករជកាយប្បដិពទ្ធវុត្តិតាយ តេន សង្ខរីយតីតិ កាយសង្ខារោតិ វុច្ចតិ។**

*កាយសង្ខារនោះ សូម្បីថា ជារបស់ដែលមានចិត្តជាសមុដ្ឋាន លោកក៏ហៅថា កាយសង្ខារ ព្រោះអត្ថថា ត្រូវកាយនោះតាក់តែង ព្រោះមានការប្រព្រឹត្តទៅជាប់ដោយ* **ករជកាយ** *។*

**យោ បន “កាយសង្ខារោ វចីសង្ខារោ”តិ[៣២] ឯវមាគតោ កាយសង្ខារោ ចេតនាលក្ខណោ សតិបិ ទ្វារន្តរុប្បត្តិយំ យេភុយ្យវុត្តិយា, តព្ពហុលវុត្តិយា ច កាយទ្វារេន លក្ខិតោ, សោ ឥធ នាធិប្បេតោ។**

*ចំណែកកាយសង្ខារណា ដែលមកហើយយ៉ាងនេះថា **“កាយសង្ខារោ វចីសង្ខារោ”** ដូច្នេះ ដែលមានលក្ខណៈជាចេតនា សូម្បីមានការកើតឡើងតាមផ្លូវទ្វារដទៃទៀត លោកក៏កំណត់ទុក ដោយកាយទ្វារ (ទើបឈ្មោះថាកាយសង្ខារ) ព្រោះមានការប្រព្រឹត្តទៅដោយច្រើន (តាមផ្លូវកាយនោះ) និងព្រោះប្រព្រឹត្តទៅដោយច្រើនតាមផ្លូវកាយទ្វារនោះ, កាយសង្ខារដែលមានលក្ខណៈជាចេតនានោះ លោកមិនបានប្រាថ្នាយកមកក្នុងទីនេះទេ ។*

**“បស្សម្ភេន្តោ”តិអាទីសុ បដិប្បស្សម្ភេន្តោ បដិប្បស្សម្ភេន្តោ** បជំ បុរិមស្ស បុរិមស្ស

---

៣២ (ម. និ. ១.១០២) ។

អត្ថវចនំ, តស្មា បស្សម្ភនំ ឯាម វូបសមនំ, តញ្ច តថាបយោគេ អសតិ ឧប្បជ្ជនារហស្ស ឱឡារិកស្ស កាយសង្ខារស្ស បយោគសម្បត្តិយា អនុប្បាទនន្តិ ឧដ្ឋព្វំ។

*ក្នុងពាក្យថា "**បស្សម្ភេន្តោ** ប្រែថា **ឱ្យរលត់បាត់** ជាដើម មានន័យថា បទខាងក្រោយៗ (មានបទថា **បដិសម្ភេន្តោ** ប្រែថា **ឱ្យស្ងប់រម្ងាប់** ជាដើម) ជាពាក្យអធិប្បាយអត្ថ សេចក្តីរបស់បទខាងដើមៗនោះ, ព្រោះហេតុនោះ គប្បីឃើញថា ឈ្មោះថា ការធ្វើឱ្យរលត់បាត់ បានដល់ ការស្ងប់រម្ងាប់, និងការធ្វើឱ្យរលត់ស្ងប់នោះ បានដល់ ការធ្វើកាយសង្ខារគឺខ្យល់ដង្ហើមដែលគ្រោតគ្រាតៗ ដែលគួរកើតឡើងបានក្នុងកាលមិនមានការព្យាយាមបែបនោះ មិនឱ្យកើតឡើង ដោយការដល់ព្រមនៃការព្យាយាម ។*

"**តត្រា**"តិ "ឱឡារិកំ កាយសង្ខារំ បស្សម្ភេន្តោ"តិ ឯត្ថ។

*ពាក្យថា "**នោះ**" គឺក្នុងពាក្យថា "អាត្មាអញ នឹងជាអ្នកធ្វើកាយសង្ខារគឺខ្យល់ដង្ហើមដែលគ្រោតគ្រាតឱ្យរលត់បាត់ក្នុងខណៈដកដង្ហើមចូល, ចេញ" ដូច្នេះ ។*

"**អបរិគ្គហិតកាលេ**"តិ កម្មដ្ឋានស្ស អឯារទ្ធកាលេ, តតោ ឯវ កាយចិត្តានម្បិ អបរិគ្គហិតកាលេ។

*ពាក្យថា "**ក្នុងពេលដែលមិនបានកំណត់**" គឺក្នុងពេលដែលមិនបានប្រារព្ធនូវកម្មដ្ឋាន, ព្រោះហេតុនោះ ទុំះឯងទើបជាពេលដែលមិនបានកំណត់នូវកាយ និងចិត្តផង ។*

"និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយា"តិ ហិ ឥមិនា កាយបរិគ្គហោ, "បរិមុខំ សតឹ ឧបដ្ឋបេត្វា"តិ ឥមិនា ចិត្តបរិគ្គហោ វុត្តោ ។

*មែនពិត ដោយពាក្យថា "អង្គុយពែនភ្នែន តាំងកាយឱ្យត្រង់" នេះ ព្រះអង្គ*

*ទ្រង់ត្រាស់សំដៅដល់ការកំណត់នូវកាយ, ចំណែកពាក្យថា "តាំងសតិ កំណត់ឱ្យមានមុខឆ្ពោះទៅ (រកកម្មដ្ឋាន)"នេះ ព្រះអង្គត្រាស់សំដៅដល់ការកំណត់នូវចិត្ត ។*

តេនេវាហ "**កាយោបិ ចិត្តម្បិ បរិគ្គហិតា ហោន្តី**"តិ។

*ព្រោះហេតុនុ៎ះឯង លោកអាចារ្យទើបពោលថា "**ទាំងកាយ ទាំងចិត្ត ត្រូវបានកំណត់ទុករួចហើយ**" ដូច្នេះ ។*

"**កាយោ**"តិ ករជកាយោ។

*ពាក្យថា "**កាយ**" បានដល់ ករជកាយ ។*

"**សទរថា**"តិ សបរិឡាហា, សា ច នេសំ សទរថតា គរុកាវេន វិយ ឱឡារិកតាយ អវិជាភាវិជីតិ អាហ "**ឱឡារិកា**"តិ។

*ពាក្យថា "**មានសភាពក្រវល់ក្រវាយ**" គឺមានភាពក្តៅពោលពល, មានសភាពរសាប់រសល់នៃរាងកាយ និងចិត្តទាំងនោះ នោះមានប្រក្រតីមិនប្រាសចាកនូវរបស់ដែលគ្រោតគ្រាត ដូចគ្នាជាមួយនឹងមានប្រក្រតីមិនលះនូវរបស់ដែលធ្ងន់ ព្រោះហេតុនោះ លោកទើបពោលថា "**ទើបឈ្មោះថាគ្រោតគ្រាត**" ដូច្នេះ ។*

"**ពលវតរា**"តិ សពលា ថូលា។ "**សន្តា ហោន្តី**"តិ ចិត្តំ តាវ ពហិទ្ធា វិក្ខេចាភាវេន ឯកគ្គំ ហុត្វា កម្មដ្ឋានំ បរិគ្គហេត្វា បវត្តមានំ សន្តំ ហោតិ វូបសន្តំ, តតោ ឯវ តំសមុដ្ឋានា រូបធម្មា លហុមុទុកម្មញ្ញ-ភាវប្បត្តា, តទនុគុណតាយ សេសំ តិសន្តតិរូបន្តិ ឯវំ ចិត្តេ, កាយេ ច វូបសន្តេ បវត្តមានេ តន្និស្សិតា អស្សាសបស្សាសា សន្តសភាវា អនុក្កមេន សុខុមតរសុខុមតមា ហុត្វា បវត្តន្តិ ។

*ពាក្យថា "**មានកម្លាំងដ៏ក្រៃលែង**" គឺមានកម្លាំងច្រើន ។ ពាក្យថា "**ជាធម្មជាតិដែលស្ងប់**" មានន័យថា ខាងដើមឡើយចិត្តជាធម្មជាតិមានអារម្មណ៍*

*តែមួយ ព្រោះមិនមានការរាយមាយទៅខាងក្រៅ នៅពេលបានកំណត់កាន់យកនូវកម្មដ្ឋានឱ្យប្រព្រឹត្តទៅ ក៏ក្លាយទៅជាធម្មជាតិដែលស្ងប់ ហើយស្ងប់ដោយពិសេសទៀតផង, ព្រោះហេតុនុ៎ះឯង ក៏នៅសល់តែរូបធម៌ទាំងឡាយដែលមានចិត្តនោះ ជាសមុដ្ឋាន ដល់ព្រមជាសភាពស្រាលទន់ និងគួរដល់ការងារ, ដោយសមគួរដល់ចិត្តនោះ ជាសន្តតិរូប ៣ ដែលនៅសល់, កាលចិត្ត និងកាយប្រព្រឹត្តទៅស្ងប់ល្អពិសេស យ៉ាងនេះ ដោយប្រការដូច្នេះ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលអាស្រ័យចិត្ត និងកាយនោះ ក៏រមែងប្រព្រឹត្តទៅ ជាធម្មជាតិដែលមានសភាវៈស្ងប់ប្រណីតល្អិតយ៉ាងសុខុម និងល្អិតយ៉ាងក្រៃលែងបំផុត ទៅតាមលំដាប់របស់សភាវៈធម៌នោះៗ ។*

តេន វុត្តំ "**យទា បនស្ស កាយោបី**"តិអាទិ។

*ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា "**ចំណែក ក្នុងពេលណាសូម្បីទាំងកាយ**" ដូច្នេះ ជាដើម ។*

## ការបង្អោនចិត្តទៅរកកម្មដ្ឋានមាន ៤ ចំណុច

១. អាកុដ្ឋនំ **អាភោគោ**, "បស្សម្ភេមី"តិ បឋមាវជ្ជនា។

*ការរំពឹងគិតដល់ ឈ្មោះថា **អាភោគ**, បានដល់ ការនឹកនូវគ្រាដំបូងថា "**អាត្មាអញនឹងធ្វើឱ្យរលត់បាត់**" ដូច្នេះ ។*

២. សម្មា អនុ អនុ អាហរណំ **សមន្នាហារោ**, តស្មឹយេវ អត្ថេ អបរាបរំ បវត្តអាវជ្ជនា។

*ការបង្អោនចិត្តមករឿយៗ ដោយល្អ ឈ្មោះថា **សមន្នាហារ** ប្រែថា **ការប្រមូលនូវចិត្ត**, បានដល់ ការនឹកឱ្យប្រព្រឹត្តទៅជាប់តៗគ្នាក្នុងសភាវៈនោះនុ៎ះឯង ។*

៣. តស្សេវ អត្ថស្ស មនសិ ករណំ ចិត្តេ ឋបនំ **មនសិការោ**។

*ការធ្វើនូវសភាវៈនោះៗ ទុះឯង ទុកក្នុងចិត្ត គឺការតាំងទុកក្នុងចិត្ត ឈ្មោះថា* **មនសិការ** *ប្រែថា ការធ្វើទុកក្នុងចិត្ត ។*

៤. **វីមំសា បច្ចវេក្ខណា។**

*ការត្រិះរិះ ឈ្មោះថា* **បច្ចវេក្ខណា** *ប្រែថា* **ការពិចារណា** *។*

**"សារទ្ធេ"តិ សទរថេ សបរិឡាហេ។ "អធិមត្ត"ន្តិ ពលវំ ឱឡារិកំ។**

*(ក្នុងគាថា) បទថា "***សារទ្ធ** *ប្រែថា* **មានសភាពក្រវល់ក្រវាយ** *" គឺមានភាពក្តៅពោលពល ។ បទថា "***អធិមត្ត** *ប្រែថា* **មានប្រមាណក្រៃលែង** *" គឺមានកម្លាំងជារបស់គ្រោតគ្រាត ។*

**លិង្គវិបល្លាសេន វុត្តំ។ កាយសង្ខារោតិ ហិ អធិប្បេតោ។**

*លោកពោលទុកជា លិង្គវិបល្លាស គឺតាមពិតជា* **អធិមត្តោ** *។ ព្រោះថា លោកប្រាថ្នាថា* **កាយសង្ខារោ** *(តាមពិតជា បុំលិង្គ) ។*

"អធិមត្តំ ហុត្វា បវត្តតី"តិ កិរិយាវិសេសនំ វា ឯតំ។ **"សុខុម"ន្តិ** ឯត្ថាបិ ឯសេវ នយោ។

*ន័យម្យ៉ាងទៀត ពាក្យថា "***អធិមត្តំ** *" នេះ ជាកិរិយាវិសេសនៈ ជាយ៉ាងនេះថា "***អធិមត្តំ ហុត្វា បវត្តតិ** *" ប្រែថា ប្រព្រឹត្តទៅប្រមាណក្រៃលែង ។ សូម្បីក្នុងបទថា "***សុខុមំ** *" នេះ ក៏មានន័យសេចក្តីដូចគ្នា ។*

**"កាយម្ហី"តិ ឯត្ថ "ចិត្តេ ចា"តិ អានេត្វា សម្ពន្ធិតព្វំ។**

*ក្នុងបទថា "***កាយម្ហិ** *" នេះ គប្បីនាំបទថា "***ចិត្តេ ច** *" មកភ្ជាប់ទុកជាមួយផង ។*

# លំដាប់នៃឈាន តាមន័យសមថ

(វិសុទ្ធិមគ្គ)

[២២១]

**១. បរិគ្គហេបិ ឱឡារិកោ, បឋមជ្ឈានុបចារេ សុខុមោ។**

*កាយសង្ខារ គឺខ្យល់ដង្ហើមសូម្បីក្នុងដំណាក់កាលនៃការកំណត់ ក៏រាប់ថានៅគ្រោតគ្រាត, ក្នុងឧបចារនៃបឋមជ្ឈាន ទើបចាត់ថាល្អិតសុខុម ។*

**២. តស្មិម្បិ ឱឡារិកោ, បឋមជ្ឈានេ សុខុមោ។**

*ខ្យល់ដង្ហើមសូម្បីក្នុងឧបចាររបស់បឋមជ្ឈាននោះ ក៏នៅចាត់ទុកថាគ្រោតគ្រាត, ក្នុងបឋមជ្ឈាន ទើបចាត់ទុកថាល្អិតសុខុម ។*

**៣. បឋមជ្ឈានេ ច ទុតិយជ្ឈានុបចារេ ច ឱឡារិកោ, ទុតិយជ្ឈានេ សុខុមោ ។**

*ខ្យល់ដង្ហើមក្នុងបឋមជ្ឈាន និងក្នុងឧបចារនៃទុតិយជ្ឈាន ចាត់ទុកថានៅតែគ្រោតគ្រាត, ក្នុងទុតិយជ្ឈានទើបចាត់ទុកថាល្អិតសុខុម ។*

**៤. ទុតិយជ្ឈានេ ច តតិយជ្ឈានុបចារេ ច ឱឡារិកោ, តតិយជ្ឈានេ សុខុមោ ។**

*ខ្យល់ដង្ហើមក្នុងទុតិយជ្ឈាននិងក្នុងឧបចារនៃតតិយជ្ឈានចាត់ទុកថានៅគ្រោតគ្រាត, ក្នុងតតិយជ្ឈានទើបចាត់ទុកថាល្អិតសុខុម ។*

**៥.តតិយជ្ឈានេ ច ចតុត្ថជ្ឈានុបចារេ ច ឱឡារិកោ, ចតុត្ថជ្ឈានេ អតិសុខុមោ អប្បវត្តិមេវ ចាបុណាតីតិ។**

*ខ្យល់ដង្ហើមក្នុងតតិយជ្ឈាន និងក្នុងឧបចារនៃចតុត្ថជ្ឈានចាត់ទុកថានៅគ្រោតគ្រាត, ក្នុងចតុត្ថជ្ឈានទើបល្អិតសុខុមក្រៃលែង រហូតដល់នូវការមិន*

*ប្រព្រឹត្តទៅតែម្តង ។*

**ឥទំ តាវ ទីឃភាណកសំយុត្តភាណកានំ** មតំ។

*ពាក្យដែលពោលមកនេះ ជាមតិរបស់ **ព្រះអាចារ្យអ្នកតែងគម្ពីរទីឃនិកាយ និងព្រះអាចារ្យអ្នកតែងគម្ពីរសំយុត្តនិកាយ** ។*

**មជ្ឈិមភាណកា** បន បឋមជ្ឈានេ ឱឡារិកោ, ទុតិយជ្ឈានុបចារេ សុខុមោតិ ឯវំ ហេដ្ឋិមហេដ្ឋិមជ្ឈានតោ ឧបរូបរិជ្ឈានុបចារេបិ សុខុមតរមិច្ឆន្តិ ។

*ចំណែក **ព្រះអាចារ្យអ្នកតែងគម្ពីរមជ្ឈិមនិកាយ** មានបំណងយល់ថា កាយសង្ខារគឺខ្យល់ដង្ហើម សូម្បីក្នុងឧបចារនៃឈានលំដាប់ខ្ពស់ៗឡើងទៅ ចាត់ទុកថា ល្អិតសុខុមជាងឈាន ក្នុងលំដាប់ជាន់ខាងក្រោមៗ យ៉ាងនេះ កាយសង្ខារគឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ក្នុងបឋមជ្ឈាន ចាត់ថានៅគ្រោតគ្រាត, ក្នុងឧបចារនៃទុតិយជ្ឈាន ចាត់ថាល្អិតសុខុមជាង ដូច្នេះ ជាដើម ។*

សព្វេសញ្ញេវ បន មតេន អបរិគ្គហិតកាលេ បវត្តកាយសង្ខារោ បរិគ្គហិតកាលេ បដិប្បស្សម្ភតិ។

*ប៉ុន្តែ បើតាមមតិរបស់លោកអាចារ្យទាំងអស់អង្គនោះ បានសេចក្តីថា កាយសង្ខារគឺខ្យល់ដង្ហើម ដែលប្រព្រឹត្តទៅ ក្នុងកាលដែលមិនទាន់បានកំណត់ (នូវកម្មដ្ឋាន គឺមិនទាន់បានស្ងប់ទេ) ហើយរមែងស្ងប់រម្ងាប់ ក្នុងកាលដែលបានកំណត់ (នូវកម្មដ្ឋានរួចហើយ)។*

បរិគ្គហិតកាលេ បវត្តកាយសង្ខារោ បឋមជ្ឈានុបចារេ។...បេ..។ ចតុត្ថជ្ឈានុបចារេ បវត្តកាយសង្ខារោ ចតុត្ថជ្ឈានេ បដិប្បស្សម្ភតិ ។

*កាយសង្ខារគឺខ្យល់ដង្ហើម ដែលប្រព្រឹត្តទៅក្នុងកាលដែលបានកំណត់ (នូវកម្មដ្ឋាន) រមែងស្ងប់រម្ងាប់ ក្នុងឧបចារ នៃបឋមជ្ឈាន ។..ល...។ កាយសង្ខារដែលប្រព្រឹត្តទៅក្នុងឧបចារនៃចតុត្ថជ្ឈាន រមែងរលត់បាត់ទៅក្នុង ចតុតជ្ឈាន*

*ដូច្នេះ ។*

**អយំ តាវ សមថេ នយោ។**

*នេះជាន័យ* **ក្នុងសមថ** *បានពោលទុកមកហើយ ។*

## តាមន័យ វិបស្សនា

**១. វិបស្សនាយំ** បន អបរិគ្គហេ បវត្តោ កាយសង្ខារោ ឱឡារិកោ, មហាភូតបរិគ្គហេ សុខុមោ។

*(ន័យក្នុងវិបស្សនា) ចំណែក* **ក្នុងផ្លូវវិបស្សនាវិញ** *កាយសង្ខារ ដែលប្រព្រឹត្តទៅក្នុងពេលដែលមិនទាន់បានកំណត់នូវកម្មដ្ឋានមហាភូតរូបចាត់ទុកថានៅគ្រោតគ្រាត, ដែលប្រព្រឹត្តទៅក្នុងពេលបានកំណត់នូវមហាភូតរូប (គឺធាតុទាំង ៤) ទើបចាត់ទុកថាល្អិតសុខុម ។*

២. សោបិ ឱឡារិកោ, ឧបាទារូបបរិគ្គហេ សុខុមោ។

*សូម្បីកាយសង្ខារដែលប្រព្រឹត្តទៅក្នុងពេលកំណត់នូវមហាភូតរូបនោះ ក៏ចាត់ទុកថានៅតែគ្រោតគ្រាត, ដែលប្រព្រឹត្តទៅក្នុងពេលបានកំណត់នូវឧបាទាយរូប(គឺរូប ២៤) ទើបចាត់ទុកថាល្អិតសុខុម ។*

៣. សោបិ ឱឡារិកោ, សកលរូបបរិគ្គហេ សុខុមោ។

*សូម្បីកាយសង្ខារដែលប្រព្រឹត្តទៅក្នុងពេលកំណត់នូវឧបាទាយរូបនោះ ក៏ចាត់ថានៅតែគ្រោតគ្រាត, ដែលប្រព្រឹត្តទៅក្នុងពេលបានកំណត់នូវរូបទាំងអស់(គឺរូប២៨) ទើបចាត់ទុកថាល្អិតសុខុម ។*

៤. សោបិ ឱឡារិកោ, អរូបបរិគ្គហេ សុខុមោ។

*សូម្បីកាយសង្ខារដែលប្រព្រឹត្តទៅក្នុងពេលកំណត់នូវរូបទាំងអស់នោះ ក៏ចាត់ទុកថានៅតែគ្រោតគ្រាត, ដែលប្រព្រឹត្តទៅក្នុងពេលបានកំណត់នូវនាម*

ទើបចាត់ទុកថាល្អិតសុខុម ។

៥. សោបិ ឱឡារិកោ, រូបារូបបរិគ្គហេ សុខុមោ។

សូម្បីកាយសង្ខារ ដែលប្រព្រឹត្តទៅក្នុងពេលកំណត់នូវនាមនោះ ក៏ចាត់ទុកថានៅតែគ្រោតគ្រាត, ដែលប្រព្រឹត្តទៅក្នុងពេលបានកំណត់នូវរូបផង នាមផង ទើបចាត់ទុកថាល្អិតសុខុម ។

៦. សោបិ ឱឡារិកោ, បច្ចយបរិគ្គហេ សុខុមោ។

សូម្បីកាយសង្ខារដែលប្រព្រឹត្តទៅក្នុងពេលកំណត់នូវរូបផង នាមផង នោះ ក៏ចាត់ទុកថានៅតែគ្រោតគ្រាត, ដែលប្រព្រឹត្តទៅក្នុងពេលបានកំណត់នូវហេតុបច្ច័យ ទើបចាត់ទុកថាល្អិតសុខុម ។

៧. សោបិ ឱឡារិកោ, សប្បច្ចយនាមរូបបរិគ្គហេ សុខុមោ។

សូម្បីកាយសង្ខារដែលប្រព្រឹត្តទៅក្នុងពេលកំណត់នូវហេតុបច្ច័យនោះ ក៏ចាត់ទុកថានៅតែគ្រោតគ្រាត, ដែលប្រព្រឹត្តទៅក្នុងពេលបានឃើញនូវនាម និងរូបព្រមទាំងហេតុបច្ច័យទៀត ទើបចាត់ទុកថាល្អិតសុខុម ។

៨.សោបិ ឱឡារិកោ, លក្ខណារម្មណិកវិបស្សនាយ សុខុមោ។

សូម្បីកាយសង្ខារ ដែលប្រព្រឹត្តទៅក្នុងពេលបានឃើញនូវនាម និងរូបព្រមទាំងហេតុបច្ច័យនោះ ក៏ចាត់ទុកថានៅតែគ្រោតគ្រាត, ដែលប្រព្រឹត្តទៅក្នុងវិបស្សនា ដែលមានលក្ខណៈ (ជាត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តា) មកជាអារម្មណ៍ ទើបចាត់ទុកថាល្អិតសុខុម ។

៩. សោបិ ទុព្វលវិបស្សនាយ ឱឡារិកោ, ពលវវិបស្សនាយ សុខុមោ។

សូម្បីកាយសង្ខារដែលប្រព្រឹត្តទៅក្នុងវិបស្សនាដែលមានកម្លាំង

ទន់ខ្សោយនោះ ក៏ចាត់ទុកថានៅតែគ្រោតគ្រាត, ដែលប្រព្រឹត្តទៅក្នុងវិបស្សនាដែលមានកម្លាំងខ្លាំង ទើបចាត់ទុកថាល្អិតសុខុម ។

**តត្ថ បុព្វេ វុត្តនយេនេវ បុរិមស្ស បុរិមស្ស បច្ឆិមេន បច្ឆិមេន បដិប្បស្សទ្ធិ វេទិតព្វា ។**

ក្នុងកាយសង្ខារទាំងនោះ គប្បីជ្រាបនូវសេចក្តីរលត់បាត់ នៃកាយសង្ខារក្នុងកាលខាងដើមៗ និងដោយកាយសង្ខារក្នុងកាលជាខាងក្រោយៗ គឺតាមន័យសេចក្តីដែលខ្ញុំម្ចាស់បានពោលសម្តែងទុកមកហើយ ក្នុងន័យសេចក្តីដំបូងៗនុ៎ះឯង ។

**ឯវមេត្ថ ឱឡារិកសុខុមតា ច បស្សទ្ធិ ច វេទិតព្វា ។**

គប្បីជ្រាបនូវសភាវៈដែលគ្រោតគ្រាត ជាមួយល្អិតសុខុម ព្រមទាំងសេចក្តីរលត់បាត់ក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនេះ តាមប្រការដែលបានពោលមកហើយនេះផងចុះ ។

**បដិសម្ភិទាយំ[៣៣]បនស្ស សទ្ធឹ ចោទនាសោធនាហិ ឯវមត្ថោ វុត្តោ**

ចំណែកនៅក្នុងគម្ពីរបដិសម្ភិទាមគ្គ ព្រះសារីបុត្តថេរៈបានសម្តែងនូវអត្ថសេចក្តីរបស់បទទាំងនោះព្រមទាំងជាពាក្យសួរ និងការឆ្លើយតបនូវសេចក្តីទាំងនោះថា ៖

**"កថំ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមិ។...បេ...។ បស្សសិស្សាមីតិ សិក្ខតិ?**

ព្រះយោគីភិក្ខុ រមែងសិក្សាថា "អាត្មាអញ នឹងធ្វើកាយសង្ខារគឺខ្យល់ដង្ហើមដែលគ្រោតគ្រាតៗឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចូល ។

រមែងសិក្សាថា "អាត្មាអញ នឹងធ្វើកាយសង្ខារ គឺខ្យល់ដង្ហើមដែល

៣៣ (បដិ. ម. ១.១៧១)

*គ្រោតគ្រាតៗឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចេញ" តើដូចម្តេច?*

**កតមេ កាយសង្ខារា?**

*ពាក្យថា កាយសង្ខារ តើដូចម្តេច?*

**ទីឃំ អស្សាសបស្សាសា កាយិកា ឯតេ ធម្មា កាយបដិពទ្ធា កាយសង្ខារា ។**

*ពួកខ្យល់ដង្ហើមចូលវែង និងខ្យល់ដង្ហើមចេញវែង ដែលប្រព្រឹត្តទៅមាននៅក្នុងកាយ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថា **កាយសង្ខារ** (កាយសង្ខារនេះគឺជាខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនេះឯង)* ។

**តេ កាយសង្ខារេ បស្សម្ភេន្តោ និរោធេន្តោ វូបសមេន្តោ សិក្ខតិ។...បេ...។ យថារូបេហិ កាយសង្ខារេហិ កាយស្ស អានមនា, វិនមនា, សន្នមនា, បណាមនា, ឥញ្ជនា, ផន្ទនា, ចលនា, កម្បនា បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ, បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។**

*ព្រះយោគីភិក្ខុ រមែងសិក្សាថា "អាត្មាអញ នឹងធ្វើកាយសង្ខារគឺខ្យល់ដង្ហើមចេញចូលដែលគ្រោតគ្រាតៗទាំងនោះ ឱ្យរលត់បាត់ ឱ្យបាត់ស្ងាត់ ឱ្យចូលទៅស្ងប់រម្ងាប់ ឈ្មោះថា រមែងសិក្សា ។...ល...។ ការឱនទៃកាយ, ការផ្អៀកកាយ, ការទម្រេតកាយ, ការឈមកាយ, ការរញ្ជួយកាយ, ការអន្ទះសាកាយ,ការកម្រើកកាយ, ការញាប់ញ័រកាយ រមែងមាន ព្រោះកាយសង្ខារទាំងឡាយណា, ព្រះយោគាវចរភិក្ខុ រមែងសិក្សាថា "អាត្មាអញនឹងធ្វើកាយសង្ខារទាំងឡាយនោះ ឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចូល", សិក្សាថា "អាត្មាអញនឹងធ្វើកាយសង្ខារទាំងឡាយនោះ ឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចេញ* ។

**យថារូបេហិ កាយសង្ខារេហិ កាយស្ស ន អានមនា, ន វិនមនា,ន សន្នមនា, ន បណាមនា, អនិញ្ជនា, អផន្ទនា, អចលនា,**

**អកម្បនា សន្តំ សុខុមំ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតិ ។**

*ការមិនឱននៃកាយ, ការមិនងាកកាយ, ការមិនទម្រេតកាយ, ការមិនឈមកាយ, ការមិនរញ្ជួយកាយ, ការមិនអន្ទះសាកាយ,ការមិនកម្រើកកាយ,ការមិនញាប់ញ័រនៃកាយ រមែងមាន ព្រោះកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា, ព្រះយោគាវចរភិក្ខុ រមែងសិក្សាថា "អាត្មាអញ នឹងធ្វើកាយសង្ខារគឺខ្យល់ដង្ហើម ដែលល្អិតសុខុមមានសភាពយ៉ាងនោះ ឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចូល ក្នុងខណៈដកដង្ហើមចេញ ។*

**ឥតិ កិរ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ។**

*សួរថា ប្រសិនបើជាយ៉ាងនេះ ក៏ឈ្មោះថា រមែងសិក្សាថា "អាត្មាអញ នឹងធ្វើកាយសង្ខារឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចូល ។*

**បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ។**

*រមែងសិក្សាថា "អាត្មាអញ នឹងធ្វើកាយសង្ខារឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចេញ" ដោយប្រការដូច្នេះ ។*

**ឯវំ សន្តេ វាតូបលទ្ធិយា ច បភាវនា ន ហោតិ។**

*កាលបើយ៉ាងនេះ ការធ្វើ* **វាតុបលទ្ធិ** *(ការដឹងនូវខ្យល់) ឱ្យកើត ក៏មិនទាន់មាន ។*

**អស្សាសបស្សាសានញ្ច បភាវនា ន ហោតិ។**

*ការធ្វើខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឱ្យកើត ក៏មិនទាន់មាន ។*

**អានាបានស្សតិយា ច បភាវនា ន ហោតិ, អានាបានស្សតិសមាធិស្ស ច បភាវនា ន ហោតិ, ន ច នំ តំ សមាបត្តឹ បណ្ឌិតា សមាបជ្ជន្តិបិ វុដ្ឋហន្តិបិ ។**

*ការធ្វើអានាបានស្សតិ ឱ្យកើត ក៏មិនទាន់មាន, ទាំងការធ្វើអានាបាន-ស្សតិសមាធិឱ្យកើត ក៏មិនទាន់មាន, និងបណ្ឌិតទាំងឡាយ មិនចូលកាន់សមាបត្តិនោះផង ទាំងមិនចេញចាកពីសមាបត្តិនោះផង ក៏មិនបាន ។*

**ឥតិ កិរ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមិ បស្សសិ-ស្សាមីតិ សិក្ខតិ។**

*ឆ្លើយថា ប្រសិនបើព្រះយោគាវចរភិក្ខុ រមែងសិក្សាថា "អាត្មាអញ នឹងធ្វើកាយសង្ខារគឺខ្យល់ដង្ហើមឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចូល, អាត្មាអញ នឹងធ្វើកាយសង្ខារគឺខ្យល់ដង្ហើមឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចេញដូច្នេះមែន ។*

**ឯវំ សន្តេ វាតុបលទ្ធិយា ច បភាវនា ហោតិ, អស្សាសបស្សាសា-នញ្ច បភាវនា ហោតិ, អានាបានស្សតិយា ច បភាវនា ហោតិ, អានាបា-នស្សតិសមាធិស្ស ច បភាវនា ហោតិ, តញ្ច នំ សមាបត្តឹ បណ្ឌិតា សមាបជ្ជន្តិបិ វុដ្ឋហន្តិបិ ។**

*កាលបើយ៉ាងនេះ ការធ្វើ**វាតុបលទ្ធិ** (ការដឹងនូវខ្យល់) ឱ្យកើត ក៏មាន, ការធ្វើខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឱ្យកើត ក៏មាន, ការធ្វើអានាបានស្សតិឱ្យកើត ក៏មាន, ទាំងការធ្វើអានាបានស្សតិសមាធិឱ្យកើត ក៏មាន, ទើបបណ្ឌិតទាំងឡាយ លោកចូលកាន់សមាបត្តិនោះផង ទាំងចេញចាកពីសមាបត្តិនោះផង ក៏មាន ។*

## ការឧបមា[៣៤]

**យថា កថំ វិយ?**

*មានការឧបមា ដូចម្ដេចមិញថា ?*

*៣៤ ឧបមានិងឧបមេយ្យ ជាការពន្យល់អំពីលំដាប់នៃខ្យល់គ្រោតគ្រាតដល់ខ្យល់ល្អិតទៅតាមលំដាប់សមថៈ និងវិបស្សនា ។*

"សេយ្យថាបិ កំសេ អាកោដិតេ បឋមំ ឱឡារិកា សទ្ទា បវត្តន្តិ។

*តើដំណើរនោះ ប្រៀបដូចនឹងអ្វី ? គឺប្រៀបដូចជា កាលគេគាំងសំរឹទ្ធិ ដែលគេគោះវាយ បានឮសំឡេងគ្រោតគ្រាត (គឺឮខ្លាំង) រមែងប្រព្រឹត្តទៅជាលើកដំបូង (ដោយសំឡេងគ្រោតគ្រាតនោះៗ) ។*

**ឱឡារិកានំ សទ្ទានំ និមិត្តំ សុគហិតត្តា សុមនសិកាតត្តា សូបធារិតត្តា, និរុទ្ធេបិ ឱឡារិកេ សទ្ទេ, អថ បច្ឆា សុខុមកា សទ្ទា បវត្តន្តិ ។**

*ព្រោះបុគ្គលបានកាន់យកដោយល្អ ព្រោះធ្វើទុកក្នុងចិត្តបានដោយល្អ ព្រោះចាំទុកបានដោយល្អ នូវនិមិត្តនៃសំឡេង ដ៏គ្រោតគ្រាត (គឺសំឡេងឮខ្លាំងនោះៗ), កាលបើសំឡេងគ្រោតគ្រាត រលត់បាត់ទៅហើយ (ចិត្ត ក៏រមែងប្រព្រឹត្តទៅបាន ព្រោះមាននិមិត្តនៃសំឡេងគ្រោតគ្រាតនោះមកជាអារម្មណ៍), បន្ទាប់មក សំឡេងដ៏ល្អិតសុខុម (គឺសំឡេងឮតិចៗ) រមែងប្រព្រឹត្តទៅជាខាងក្រោយ ។*

**សុខុមកានំ សទ្ទានំ និមិត្តំ សុគ្គហិតត្តា សុមនសិកាតត្តា សូបធារិតត្តា, និរុទ្ធេបិ សុខុមកេ សទ្ទេ, អថ បច្ឆា សុខុមសទ្ទនិមិត្តារម្មណតាបិ ចិត្តំ បវត្តតិ ។**

*ព្រោះបុគ្គលបានកាន់យកដោយល្អ ព្រោះធ្វើទុកក្នុងចិត្តបានដោយល្អ ព្រោះចាំទុកបានដោយល្អនូវនិមិត្តនៃសំឡេងដ៏ល្អិតសុខុម (គឺសំឡេងឮតិចៗ) នោះ, កាលបើសំឡេងដ៏ល្អិតសុខុមនោះ រលត់បាត់ទៅហើយ, បន្ទាប់មក ចិត្ត រមែងប្រព្រឹត្តទៅ ជាខាងក្រោយ ព្រោះចិត្តមាននិមិត្តនៃសំឡេងដ៏ល្អិតសុខុមនោះ មកជាអារម្មណ៍ ។*

## ការឧបមេយ្យ

**ឯវមេវ បឋមំ ឱឡារិកា អស្សាសបស្សាសា បវត្តន្តិ។**

*យ៉ាងណាមិញ ដូចគ្នាជាមួយខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏គ្រោតគ្រាត រមែងប្រព្រឹត្តទៅជាលើកដំបូង (ដូចគ្នា) ។*

**ឱឡារិកានំ អស្សាសបស្សាសានំ និមិត្តំ សុគ្គហិតត្តា សុមនសិកាតត្តា សូបធារិតត្តា, និរុទ្ធេបិ ឱឡារិកេ អស្សាសបស្សាសេ, អថ បច្ឆា សុខុមកា អស្សាសបស្សាសា បវត្តន្តិ។**

*ព្រោះយោគីភិក្ខុ បានកាន់យកដោយល្អ ព្រោះធ្វើទុកក្នុងចិត្តបានដោយល្អ ព្រោះចាំទុកបានដោយល្អ នូវនិមិត្តនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏គ្រោតគ្រាតនោះ, កាលបើខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏គ្រោតគ្រាត រលត់បាត់ទៅហើយ (ចិត្ត ក៏មិនដល់នូវការរាយមាយ ព្រោះសភាវៈចិត្តដែលមាននិមិត្តនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ មកធ្វើជាអារម្មណ៍), បន្ទាប់មក ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏ល្អិតសុខុមនោះ រមែងប្រព្រឹត្តទៅជាខាងក្រោយៗទៀត ។*

**សុខុមកានំ អស្សាសបស្សាសានំ និមិត្តំ សុគ្គហិតត្តា សុមនសិកាតត្តា សូបធារិតត្តា, និរុទ្ធេបិ សុខុមកេ អស្សាសបស្សាសេ, អថ បច្ឆា សុខុមអស្សាសបស្សាសនិមិត្តារម្មណតាបិ ចិត្តំ ន វិក្ខេបំ គច្ឆតិ។**

*ព្រោះយោគីភិក្ខុ បានកាន់យកដោយល្អ ព្រោះធ្វើទុកក្នុងចិត្តបានដោយល្អ ព្រោះចាំទុកបានដោយល្អ នូវនិមិត្តនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏ល្អិតសុខុមនោះ, កាលបើខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏ល្អិតសុខុម រលត់បាត់ទៅហើយ, បន្ទាប់មក ចិត្ត ក៏មិនដល់នូវការរាយមាយជាខាងក្រោយឡើយ ព្រោះចិត្តបានកាន់យកនូវនិមិត្តនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏ល្អិតសុខុមនោះៗ មកធ្វើជាអារម្មណ៍ ។*

**"ឯវំ សន្តេ វាតូបលទ្ធិយា ច បភាវនា ហោតិ, អស្សាសបស្សាសានញ្ច បភាវនា ហោតិ, អានាបានស្សតិយា ច បភាវនា ហោតិ, អានាបានស្សតិសមាធិស្ស ច បភាវនា ហោតិ, តញ្ច នំ សមាបត្តឹ បណ្ឌិតា សមាបជ្ជន្តិបិ វុដ្ឋហន្តិបិ ។**

*"កាលបើយ៉ាងនេះ* **វាតូបលទ្ធិ** *ការប្រាកដនៃការបានដឹងនូវខ្យល់ ក៏កើតមាន, ការប្រាកដនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ក៏កើតមាន, ការប្រាកដនៃអានាបានស្សតិ ក៏កើតមាន, ទាំងការប្រាកដនៃអានាបានស្សតិសមាធិ ក៏កើតមាន, ទើបបណ្ឌិតទាំងឡាយ លោករមែងចូលកាន់សមាបត្តិនោះផង ទាំងចេញចាកពីសមាបត្តិនោះផង ក៏កើតមាន ។*

**បស្សម្ភយំ កាយសង្ខារំ អស្សាសបស្សាសា កាយោ ។**

*ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ របស់ព្រះយោគាវចរភិក្ខុ កាលរលត់បាត់នូវកាយសង្ខារ ឈ្មោះថា* **កាយ** *។*

**ឧបដ្ឋានំ សតិ ។**

*សភាវៈដែលចូលទៅកាន់អារម្មណ៍ហើយបានតាំងនៅ ឈ្មោះថា* **សតិ** *។*

**អនុបស្សនា ញាណំ ។**

*ការតាមពិចារណាឃើញរឿយៗ ឈ្មោះថា* **ញាណ** *។*

**កាយោ ឧបដ្ឋានំ, នោ សតិ ។**

*កាយ (គឺខ្យល់ដង្ហើម) ជាទីតាំងសម្រាប់សតិចូលទៅតម្កល់ទុក, មិនមែនឈ្មោះថា សតិទេ ។*

**សតិ ឧបដ្ឋានញ្ចេវ សតិ ច ។**

*សតិ ជាសភាវៈដែលចូលទៅតម្កល់ទុកផង និងឈ្មោះថា សតិផង ។*

**តាយ សតិយា តេន ញាណេន តំ កាយំ អនុបស្សតិ។**

*ព្រះយោគាវចរភិក្ខុ រមែងពិចារណាឃើញរឿយៗ នូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ។*

**តេន វុច្ចតិ កាយេ កាយានុបស្សនា សតិប្បដ្ឋានភាវនា´´តិ។**

*ព្រោះហេតុនោះ លោកពោលថា* **កាយេកាយានុបស្សនាសតិប្បដ្ឋានភាវនា** *(ប្រែថា ការចម្រើនភាវនាដែលមានសតិចូលទៅតម្កល់ទុកនៅត្រង់ចុងច្រមុះ ហើយកំណត់ដឹងនូវខ្យល់ដង្ហើមចូល. និងខ្យល់ដង្ហើមចេញរឿយៗ)´´ ដូច្នេះ ។*

**អយំ តាវេត្ថ កាយានុបស្សនាវសេន វុត្តស្ស បឋមចតុក្កស្ស អនុបុព្វបទវណ្ណនា។**

*នេះជាពាក្យពណ៌នាទៅតាមលំដាប់បទនៃចតុក្កទី ១ ដែលព្រះអង្គទ្រង់ត្រាស់សម្តែងទុកដោយអំណាចនៃកាយានុបស្សនា ក្នុងអានាបានស្សតិនេះ ជាលំដាប់ខាងដើម (លំដាប់ដំបូងគេ) ។*

## លំដាប់នៃឈាន តាមន័យសមថ

### (មហាដីកាវិសុទ្ធិមគ្គ)

[២២១] **បឋមជ្ឈានតោ វុដ្ឋាយ ករិយមានំ ទុតិយជ្ឈានស្ស នានាវជ្ជនំ បរិកម្មំ បឋមជ្ឈានំ វិយ ទូរសមុស្សារិតបដិបក្ខន្តិ កត្វា តំសមុដ្ឋានោ កាយសង្ខារោ បឋមជ្ឈានេ ច ទុតិយជ្ឈានូបចារេ ច ឱឡារិកោតិ សទិសោ វុត្តោ។**

*លោកអាចារ្យ បានអធិប្បាយ ថា* **បរិកម្ម** *ដែលមាន***អាវជ្ជន** *ផ្សេងៗគ្នានៃទុតិយជ្ឈាន (ដែលជា ឧបចារនៃទុតិយជ្ឈាន ន័យក្នុងទីនេះ) ដែលព្រះយោគាវចរភិក្ខុចេញចាកពីបឋមជ្ឈាន ហើយធ្វើការដកធម៌ដែលជាបដិបក្ខទុកក្នុងទីឆ្ងាយបានដោយល្អ ដូចបឋមជ្ឈាន ដូច្នេះហើយ ទើបពោលដល់*

*កាយសង្ខារ ដែលមានបឋមជ្ឈាន និងឧបចារនៃទុតិយជ្ឈាននោះជាសមុដ្ឋានថា ជាកាយសង្ខារដែលមានដូចគ្នា យ៉ាងនេះថា ក្នុងបឋមជ្ឈាន និងក្នុងឧបចារនៃ ទុតិយជ្ឈានចាត់ថានៅគ្រោតគ្រាត ដូច្នេះ ។*

**ឯស នយោ សេសូបចារទ្វយេបិ។**

*សូម្បីក្នុងឧបចារទាំង ២ ដ៏សេសទៀត ក៏មានន័យសេចក្តីបែបនេះ ។*

**អថ វា ទុតិយជ្ឈានាទីនំ អធិគមាយ បដិបជ្ជតោ ទុក្ខាបដិបទាទិ-វសេន កិលមតោ យោគិនោ កាយកិលមថចិត្តុបឃាតាទិវសេន, វិតក្កាទិសង្ខោភេន ច សបរិឡាហាយ ចិត្តប្បវត្តិយា ទុតិយជ្ឈានាទិ ឧបចារេសុ កាយសង្ខារស្ស ឱឡារិកតា វេទិតព្វា។**

*ន័យម្យ៉ាងទៀត កាលព្រះយោគាវចរភិក្ខុបដិបត្តិដើម្បីសម្រេចបាននូវ ទុតិយជ្ឈាន ជាដើមក៏មានការលំបាក នេះជាប់ទាក់ទងជាមួយទុក្ខាបដិបទា ជាដើម គប្បីជ្រាបនូវសេចក្តីជាកាយសង្ខារនៅក្នុងឧបចារ នៃឈានទាំងឡាយ ដែលមានទុតិយជ្ឈានជាដើម ជាសភាពដែលគ្រោតគ្រាត ព្រោះអាស្រ័យ មានការលំបាកនៃកាយ (ជានាមកាយ) និងការរួញរានៃចិត្ត និងព្រោះការប្រព្រឹត្ត ទៅរបស់ចិត្តដែលមានសភាពក្តៅក្រហាយ ដោយអង្គឈានដែលហៅថា វិតក្ក ជាដើម ។*

**"អតិសុខុមោ"តិ អញ្ញត្ថ លព្ភមានោ កាយសង្ខារោ ចតុត្ថជ្ឈានេ អតិក្កន្តសុខុមោ ។**

*ពាក្យថា "**ល្អិតសុខុមក្រៃលែង**" មានសេចក្តីថា កាយសង្ខារ ដែលមាននៅ ក្នុងឈានដទៃទៀតក្នុងចតុត្ថជ្ឈាន ឈ្មោះថា ល្អិតសុខុមយ៉ាងក្រៃលែងដ៏ លើសលប់ ។*

**សុខុមភាវោបិស្ស តត្ថ នត្ថិ, កុតោ ឱឡារិកតា អប្បវត្តនតោ។**

*សូម្បីសភាវៈដែលកាយសង្ខារនេះក្នុងចតុត្ថជ្ឈាននោះ ល្អិតសុខុម រមែង*

*មិនមាន, ចុះសភាវៈដែលត្រោតត្រាត នឹងមានមកអំពីទីណា ព្រោះរកការប្រព្រឹត្តទៅ មិនមាន ។*

**តេនាហ "អប្បវត្តិមេវ ចាបុណាតី"តិ។**

*ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា "**រហូតដល់នូវការមិនប្រព្រឹត្តទៅតែម្តង**" ដូច្នេះ ។*

**លាភិស្ស សតោ អនុបុព្វសមាបត្តិសមាបជ្ជនវេលំ, ឯកាសនេនេវ វា សព្វេសំ ឈានានំ បដិលាភំ សន្ធាយ មជ្ឈិមភាណកា ហេដ្ឋិមហេដ្ឋិមជ្ឈានតោ ឧបរូបរិឈានូបចារេបិ សុខុមតរំ ឥច្ឆន្តិ។**

*លោកអាចារ្យ **អ្នកតែងគម្ពីរមជ្ឈិមនិកាយ** ឈ្មោះថា ត្រូវការកាយសង្ខារសូម្បីក្នុងឧបចារៈរបស់ឈានក្នុងលំដាប់ខ្ពស់ៗឡើងទៅថា ល្អិតជាងឈានក្នុងលំដាប់ទាបៗ ដោយសំដៅយកវេលាដែលព្រះយោគាវចរជាអ្នកឈានលាភីចូលសមាបត្តិទៅតាមលំដាប់, ឬសំដៅយកការបានឈានទាំងពួង ដោយអាសនៈតែមួយប៉ុណ្ណោះ (គឺដោយការអង្គុយតែមួយភ្លែនប៉ុណ្ណោះ) ។*

**តត្ថ ហិ សោបចារានំ ឈានានំ ឧបរូបរិ វិសេសវន្តតា, សន្តតា ច សម្ភវេយ្យ, ឯកាវជ្ជនូបចារំ វា សន្ធាយ ឯវំ វុត្តំ។**

*ពិតហើយ ឈានទាំងឡាយ ព្រមទាំងឧបចារៈ នឹងគប្បីមាននូវសេចក្តីពិសេសទៅតាមលំដាប់ខ្ពស់ឡើងទៅៗ និងមានសេចក្តីស្ងប់នៅក្នុងវេលានោះ, ន័យម្យ៉ាងទៀត លោកបានពោលទុកយ៉ាងនេះ ដោយសំដៅយកឧបចារៈដែលមានអាវជ្ជនៈជាមួយគ្នា (គឺឧបចារៈដែលនៅក្នុងវិថីចិត្តជាមួយឈាន) ។*

**ឯវញ្ហិ ហេដ្ឋា វុត្តវាទេន ឥមស្ស វាទស្ស អវិរោធោ សិទ្ធោ ភិន្នវិសយត្តា។**

*ពិតហើយ វាទៈនេះ (ជាវាទៈរបស់លោកអាចារ្យ អ្នកតែងគម្ពីរមជ្ឈិមនិកាយ) និងមានការសមស្របនូវសេចក្តីមិនខុសគ្នាជាមួយវាទៈ ដែល*

*បានពោលហើយក្នុងបទខាងដើម (គឺវាទៈរបស់លោកអាចារ្យអ្នកតែងគម្ពីរទីឃនិកាយ និងវាទៈរបស់លោកអាចារ្យអ្នកតែងគម្ពីរសំយុត្តនិកាយ) ព្រោះមានវិស័យផ្សេងៗគ្នា តាមប្រការដែលបានពោលមកហើយនេះ ។*

"**សព្វេសញ្ញេវា**"តិ ឧភយេសម្បិ។ យស្មា តេ សព្វេបិ វុត្តមានេន វិធិនា បស្សទ្ធិមិច្ឆន្តិយេវ ។

*ពាក្យថា របស់លោកអាចារ្យ "**គ្រប់ផ្នែកទាំងអស់អង្គនោះ**" គឺរបស់លោកអាចារ្យទាំង ២ ផ្នែក ។ ព្រោះហេតុដែលលោកអាចារ្យទាំងឡាយនោះ សូម្បីគ្រប់ៗអង្គ ក៏ប្រាថ្នានូវសេចក្តីស្ងប់ (របស់កាយសង្ខារ) ដោយវិធីដែលកំពុងពោលឱ្យទៅដល់នុ៎ះឯង ។*

"**អបរិគ្គហិតកាលេ បវត្តកាយសង្ខារោ បរិគ្គហិតកាលេ បដិប្បស្សម្ភតី**"តិ ឥធំ សទិសសន្តានតាយ វុត្តំ។

*លោកបានពោលពាក្យថា "**កាយសង្ខារដែលប្រព្រឹត្តទៅក្នុងវេលាដែលមិនទាន់បានកំណត់ រមែងរលត់បាត់ទៅនោះ ក្នុងវេលាដែលបានកំណត់ហើយ**" ដូច្នេះនេះ ព្រោះមានការជាប់បន្តគ្នាដោយសភាពស្មើៗគ្នា ។*

ន ហិ តេ ឯវ ឱឡារិកា អស្សាសាទយោ សុខុមា ហោន្តិ។ បស្សម្ភនាការោ បន នេសំ ហេដ្ឋា វុត្តោយេវ។

*ពិតហើយ ខ្យល់ដង្ហើមចូល ជាដើមដែលគ្រោតគ្រាតទាំងឡាយនោះ មិនក្លាយមកជាខ្យល់ល្អិតសុខុម នុ៎ះទេ ។ ប៉ុន្តែ អាការៈដែលរលត់បាត់ទៅនៃខ្យល់ដង្ហើមទាំងនោះ លោកអាចារ្យ ក៏បានពោលទុកនៅបទខាងដើមមកហើយ ។*

"**មហាភូតបរិគ្គហេ សុខុមោ**"តិ ចតុធាតុមុខេន វិបស្សនាភិនិវេសំ សន្ធាយ វុត្តំ ។

*ពាក្យថា ដែលប្រព្រឹត្តទៅ "**ក្នុងវេលាដែលបានកំណត់នូវមហាភូតរូបថាល្អិតសុខុម**" លោកពោលសំដៅការចាប់អារម្មណ៍របស់វិបស្សនា តាម*

*ធាតុទាំង ៤ យ៉ាង ជាសំខាន់ ។*

**សកលរូបបរិគ្គហេ សុខុមោ** ភាវនាយ ឧបរូបរិ បណីតភាវតោ។

*ឈ្មោះថា ដែលប្រព្រឹត្តទៅ **ក្នុងវេលាកំណត់នូវរូបទាំងអស់ ចាត់ថាល្អិតសុខុម** ព្រោះការភាវនាមានភាពប្រណីតក្រៃលែងឡើងទៅៗ ។*

តេនេវាហ "**រូបារូបបរិគ្គហេ សុខុមោ**"តិ។

*ព្រោះហេតុនុ៎ះឯង លោកទើបពោលថា "ដែលប្រព្រឹត្តទៅក្នុងវេលា **កំណត់ទាំងរូប ទាំងនាម ចាត់ថាល្អិតសុខុម**" ដូច្នេះ ។*

"**លក្ខណារម្មណិកវិបស្សនា**"តិ កលាបសម្មសនមាហ ។

*ពាក្យថា **វិបស្សនាដែលមានលក្ខណៈ (ជាត្រៃលក្ខណ៍) មកជាអារម្មណ៍** លោកសំដៅដល់ការពិចារណា (នូវរូប) កលាប ។*

និព្វិទានុបស្សនតោ បដ្ឋាយ **ពលវវិបស្សនា**។ តតោ ឱរំ **ទុព្វលវិបស្សនា** ។

*ឈ្មោះថា **វិបស្សនាដែលមានកម្លាំងខ្លាំង** គឺការកំណត់រាប់យកតាំងតែ **និព្វិទានុបស្សនាញាណ**ឡើងទៅ ។ ទាបជាង **និព្វិទានុបស្សនាញាណ**នោះ ឈ្មោះថា **វិបស្សនាដែលមានកម្លាំងខ្សោយ** ។*

"**បុព្វេ វុត្តនយេនា**"តិ "អបរិគ្គហិតកាលេ"តិអាទិនា សមថនយេ វុត្តេន នយេន ។ "អបរិគ្គហេ បវត្តោ កាយសង្ខារោ មហាភូតបរិគ្គហេ បដិប្បស្សម្ភតី"តិអាទិនា វិបស្សនានយេបិ បដិប្បស្សទ្ធិ យោជេតព្វាតិ វុត្តំ ហោតិ ។

*ពាក្យថា តាមន័យដែលខ្ញុំម្ចាស់ បានពោលមកហើយក្នុងន័យជាដំបូង គឺតាមន័យ ដែលលោកអាចារ្យបានពោលទុកក្នុងន័យសមថៈ ដោយពាក្យថា "**អបរិគ្គហិតកាលេ**" ជាដើម ។ មានពាក្យអធិប្បាយថា គប្បីប្រកបនូវសភាវៈ*

*រលត់បាត់ សូម្បីក្នុងន័យវិបស្សនា ដោយពាក្យថា "កាយសង្ខារ ដែលប្រព្រឹត្តិទៅ ក្នុងវេលាដែលមិនទាន់បានកំណត់ រមែងរលត់បាត់ទៅ ក្នុងវេលាដែលបាន កំណត់នូវមហាភូតរូប" ដូច្នេះ ជាដើមផងចុះ ។*

**"អស្សា"តិ ឥមស្ស "បស្សម្ភយំ កាយសង្ខារ"ន្តិ បទស្ស។**

*ពាក្យថា "**នៃបទនេះ**" គឺនៃបទថា "**បស្សម្ភយំ កាយសង្ខារំ**" នេះ ។*

**"ចោទនាសោធនាហិ"តិ អនុយោគបរិហារេហិ។**

*ពាក្យថា "**ព្រមទាំងពាក្យសួរ និងពាក្យឆ្លើយ**" គឺព្រមទាំងពាក្យជាសំនួរ និងពាក្យជាចម្លើយ ។*

**"ឯវ"ន្តិ ឥទានិ វុច្ចមានាការេន។**

*ពាក្យថា "**យ៉ាងនេះ**" គឺដោយអាការៈដែលនឹងពោលដល់ក្នុងកាលជាឥឡូវនេះ ។*

**"កថ"ន្តិ យំ ឥទំ "បស្សម្ភយំ។...បេ...។ សិក្ខតី"តិ**(៣៩) **វុត្តំ, តំ កថំ កេន បការេន កាយសង្ខារស្ស បស្សម្ភនំ, យោគិនោ ច សិក្ខនំ ហោតីតិ កថេតុកម្យតាយ បុច្ឆិត្វា កាយសង្ខារេ សរូបតោ, ឱឡារិក-សុខុមតោ, វូបសមតោ, អនុយោគបរិហារតោ ច ទស្សេតុំ "កតមេ កាយសង្ខារា"តិអាទិ អារទ្ធំ ។**

*ពាក្យថា "**តើដូចម្តេច ?**" គឺពាក្យដែលពោលថា ព្រះយោគីភិក្ខុ រមែងសិក្សាថា "អាត្មាអញនឹងចម្រើនឱ្យរលត់បាត់នូវកាយសង្ខារ ។...ល...។" បែបនេះយ៉ាងណា, ពាក្យនោះ តើដូចម្តេច ? ព្រះសារីបុត្តថេរៈ កាលសួរ ដោយអាការៈជាអ្នកប្រាថ្នាដើម្បីនឹងឆ្លើយតប ដោយព្រះអង្គឯងថា ការរលត់បាត់ នៃកាយសង្ខារ និងការសិក្សារបស់ព្រះយោគាវចរភិក្ខុ នឹងកើតមានបានដោយប្រការអ្វី ? ដូច្នេះហើយ ក៏ប្រាថ្នានឹងសម្តែងនូវកាយសង្ខារទាំងឡាយ ទៅតាម*

៣៩ (បដិ. ម. ១.១៧១) ។

*សភាវៈដែលមាន, ដែលជាកាយសង្ខារគ្រោតគ្រាត និងល្អិតសុខុម, ដោយអាការៈដែលរលត់បាត់ និងដោយពាក្យសួរ ព្រមទាំងពាក្យឆ្លើយតប ទើបបានផ្ដើមនូវពាក្យថា "**កាយសង្ខារ តើដូចម្ដេច?**" ដូច្នេះ ជាដើម ។*

តត្ថ "**កាយិកា**"តិ រូបកាយេ ភវា។ "**កាយបដិពទ្ធា**"តិ កាយសន្និស្សិតា។

*បណ្ដាពាក្យទាំងនោះ ត្រង់ពាក្យថា "**មានក្នុងកាយ**" គឺមានក្នុងរូបកាយ ។ ពាក្យថា "**ជាប់ដោយកាយ**" គឺអាងអាស្រ័យនូវកាយ ។*

កាយេ សតិ ហោន្តិ, អសតិ ន ហោន្តិ, តតោ ឯវ តេ អកាយសមុដ្ឋានាបិ កាយេន សង្ខរីយន្តីតិ **កាយសង្ខារា**។

*អធិប្បាយថា កាលកាយមាន ទើបបានមាន, កាលកាយមិនមាន ក៏មិនមានដូចគ្នា, ព្រោះហេតុនុ៎ះឯង ទើបហៅខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះថា **ជាកាយសង្ខារ** ព្រោះអត្ថថា សូម្បីមិនមានកាយជាសមុដ្ឋាន ប៉ុន្តែត្រូវបានកាយ (គឺរូបកាយ) តាក់តែងឡើង ។*

"**បស្សម្ភយំ**"តិ ឱឡារិកោឡារិកំ បស្សម្ភេន្តោ។

*ពាក្យថា "**ធ្វើឱ្យរលត់បាត់**" គឺធ្វើកាយសង្ខារ (ខ្យល់ដង្ហើមចូល ចេញ) ដែលគ្រោតគ្រាតៗ ឱ្យរលត់បាត់ ។*

សេសបទទ្វយំ តស្សេវ វេវចនំ។

*ទាំង២ បទ ដ៏សេសទៀត (គឺឱ្យស្ងប់រលត់, ឱ្យចូលទៅស្ងប់រម្ងាប់) វាជាពាក្យវេវចនៈរបស់ពាក្យថា ឱ្យរលត់បាត់ នុ៎ះឯង ។*

ឱឡារិកញ្ហិ កាយសង្ខារំ អរូបសន្តសភាវំ សន្និសីទាបេន្តោ "**បស្សម្ភេន្តោ**"តិ វុច្ចតិ, អនុប្បាទនិរោធំ ចាបេន្តោ "**និរោធេន្តោ**"តិ, សុដ្ឋុ សន្តសភាវំ នយន្តោ "**វូបសមេន្តោ**"តិ។

*មែនពិត កាលធ្វើកាយសង្ខារ (គឺខ្យល់ដង្ហើមចូល ចេញ) ដែលគ្រោតគ្រាត ដែលមានសភាវៈមិនស្ងប់ ឱ្យទៅជាស្ងប់នៅនឹងធឹងបាន លោកហៅថា "**ឱ្យរលត់បាត់**", កាលធ្វើឱ្យដល់សភាវៈរលត់ គឺការមិនកើតឡើងទៀត លោកហៅថា "**ឱ្យស្ងប់រលត់**", កាលនាំទៅកាន់សភាវៈដែលស្ងប់ដោយល្អ លោកហៅថា "**ធ្វើឱ្យចូលទៅស្ងប់រម្ងាប់**" ដូច្នេះ ។*

"**យថារូបេហី**"តិ យាទិសេហិ ។ "**កាយសង្ខារេហី**"តិ ឱឡារិកេហិ កាយសង្ខារេហិ ។ "**អានមនា**"តិ អភិមុខភាវេន កាយស្ស នមនា ។

*ពាក្យថា "**យ៉ាងណា**" គឺបែបណា ។ ពាក្យថា "**ព្រោះកាយសង្ខារ**" គឺព្រោះកាយសង្ខារដែលគ្រោតគ្រាត ។ បទថា "**អានមនា** ប្រែថា **ការឱនកាយ**" គឺការនាំកាយទៅខាងមុខ ។*

"**វិនមនា**"តិ វិសុំ វិសុំ បស្សតោ នមនា។ "**សន្នមនា**"តិ សព្វតោ, សុដ្ឋុ វា នមនា ។

*បទថា "**វិនមនា** ប្រែថា **ការផ្អៀកកាយ**" គឺការនាំកាយទៅមួយខាង ។ បទថា "**សន្នមនា** ប្រែថា **ការទ្រេតកាយ**" គឺការនាំកាយទៅគ្រប់ទិស, ឬការនាំកាយទៅដោយល្អ ។*

"**បណមនា**"តិ បច្ឆតោ នមនា។

*បទថា "**បណមនា** ប្រែថា **ទម្រេតកាយ**" គឺការបង្អោនកាយទៅខាងក្រោយ ។*

"**ឥញ្ជនា**"ទីនិ អានមនាទីនំ វេវចនានិ, អធិមត្តានិ វា អភិមុខំ ចលនាទីនិ អានមនាទយោ, មន្ទានិ ឥញ្ជនាទយោ។

*បទថា "**ឥញ្ជនា** ប្រែថា **ការរញ្ជួយកាយ**" ជាដើម វាជាពាក្យវេវចនៈរបស់ពាក្យថា **អានមនា** ជាដើម, ន័យម្យ៉ាងទៀត ការកម្រើកកាយ ជាដើម ទៅខាងមុខច្រើនៗជង ឈ្មោះថា **អានមនា** ជាដើម, ការកម្រើកកាយជាដើម តែ*

*បន្តិចបន្តួច ឈ្មោះថា ឥញ្ជនា ជាដើម ។*

"**បស្សម្ភយំ កាយសង្ខារ**"ន្តិ តថារូបំ អាឯមជាឪធំ ការណោកូតំ ឱឡារិកំ កាយសង្ខារំ បស្សម្ភេន្តោ ។

*ពាក្យថា "**អាត្មាអញ នឹងធ្វើកាយសង្ខារ** (បែបនោះ) **ឱ្យរលត់បាត់** មានន័យថា យើងនឹងធ្វើកាយសង្ខារបែបនោះ គឺកាយសង្ខារដែលគ្រោតគ្រាត ដែលជាហេតុនៃការបង្អោនកាយ ជាដើម ឱ្យរលត់បាត់ ។*

តស្មឹ ហិ បស្សម្ភិតេ អាឯមជាឧយោបិ បស្សម្ភិតា ឯវ ហោន្តិ។

*មែនពិត កាលកាយសង្ខារនោះរលត់បាត់ទៅហើយសូម្បីការបង្អោនកាយ ជាដើម ក៏រលត់បាត់ទៅដូចគ្នា ។*

"**សន្តំ សុខុម**"ន្តិ យថារូបេហិ កាយសង្ខារេហិ កាយស្ស អបរិប្ផន្ទនហេតូហិ អាឯមជាឧយោ ន ហោន្តិ, តថារូបំ ឧរថាភាវតោ សន្តំ, អនោឡារិកតាយ សុខុមំ។

*ពាក្យថា "**ដែលស្ងប់ ដែលល្អិតសុខុម**" មានន័យថា ការឱនកាយជាដើម រមែងមិនមាន ព្រោះកាយសង្ខារ ដែលជាហេតុនៃការមិនអន្ទះសាទូវកាយ យ៉ាងណា, កាយសង្ខារ យ៉ាងនោះ ឈ្មោះថា ស្ងប់ ព្រោះមិនមានភាពក្តៅក្រហាយ, ឈ្មោះថា ល្អិតសុខុម ព្រោះសភាវៈដែលមិនមានគ្រោតគ្រាត ។*

## បស្សម្ភយំ កាយសង្ខារំ

"**បស្សម្ភយំ កាយសង្ខារ**"ន្តិ សាមញ្ញតោ ឯកំ កត្វា វុត្តំ។

*លោកពោលធ្វើឱ្យជាបទតែមួយ ព្រោះស្មើគ្នា (ដោយភាពជាកាយសង្ខារ) ថា* **បស្សម្ភយំ កាយសង្ខារំ** ។

អថ វា បុព្វេ ឱឡារិកោឡារិកំ កាយសង្ខារំ បដិប្បស្សម្ភេន្តោ អនុក្កមេន កាយស្ស អបរិប្ផន្ទនហេតុភូតេ សុខុមសុខុមតរេ

ឧប្បាទេត្វា តេបិ បដិប្បស្សម្ភេត្វា បរមសុខុមតាយ កោដិប្បត្តំ យំ កាយសង្ខារំ បដិប្បស្សម្ភេតិ, តំ សន្ធាយ វុត្តំ "**សន្តំ សុខុមំ បស្សម្ភយំ កាយសង្ខារ**"ន្តិ។

*ន័យម្យ៉ាងទៀត ព្រះយោគាវចរភិក្ខុ ជាអ្នកធ្វើកាយសង្ខារដែលគ្រោតគ្រាតៗ ឱ្យរលត់បាត់ទៅក្នុងគ្រាដំបូងៗនោះ បន្ទាប់មកធ្វើកាយសង្ខារដែលល្អិតសុខុមជាងនោះឱ្យប្រព្រឹត្តិទៅតាមលំដាប់ បែបនេះវាជាហេតុនៃការមិនអន្ទះសាដល់កាយ ឱ្យកើតឡើងបាន, ធ្វើកាយសង្ខារ សូម្បីបែបនោះឱ្យរលត់បាត់ទៅហើយបានធ្វើកាយសង្ខារឱ្យបានដល់កំពូល ព្រោះវាជាកាយសង្ខារដែលល្អិតសុខុមយ៉ាងក្រៃលែង យ៉ាងណា, ការឱ្យរលត់បាត់ទៅ ទៅតាមលំដាប់ និងពាក្យថា "**អាត្មាអញ នឹងធ្វើកាយសង្ខារ ដែលស្ងប់រម្ងាប់ ដែលល្អិតសុខុម ឱ្យរលត់បាត់**" ដូច្នេះនេះ គឺលោកពោលសំដៅយកនូវកាយសង្ខារ ដែលបានទៅដល់ត្រង់ចំណុចកំពូលហើយ នុ៎ះឯង ។*

"**ឥតី**"តិអាទិ ចោទកាវចនំ។ តត្ថ "**ឥតី**"តិ បការត្ថេ និបាតោ។

*ពាក្យថា "**ឥតិ**" ជាដើម ជាពាក្យសួរ ។ បណ្ដាពាក្យទាំងនោះ ពាក្យថា "**ឥតិ**" ជានិបាត ក្នុងអត្ថថា បការៈ ។*

"**កិរា**"តិ អរុចិសូចនេ, ឯវំ ចេតិ អត្ថោ។

*ពាក្យថា "**កិរ**" ក្នុងសេចក្ដីថា* **អរុចិសូចន** *ប្រែថា ការប្រាប់នូវសេចក្ដីមិនពេញចិត្ត គឺមិនស្របតាម, វាមានសេចក្ដីស្មើគ្នានឹងពាក្យថា* **ឯវំ ចេ** *ដែលប្រែថា ប្រសិនបើដូច្នេះ ។*

អយញ្ហេត្ថ អធិប្បាយោ –

*ក្នុងសេចក្ដីថា* **ឥតិ កិរ** *នេះ មានពាក្យអធិប្បាយដូចតទៅនេះថា ៖*

វុត្តប្បការេន យទិ អតិសុខុមម្បិ កាយសង្ខារំ បស្សម្ភេតីតិ ។

*ប្រសិនបើថា ការធ្វើកាយសង្ខារសូម្បីល្អិតសុខុមយ៉ាងក្រៃលែង ឱ្យរលត់បាត់ទៅ តាមប្រការដែលបានពោលមកហើយនោះ ដូច្នេះ ។*

**"ឯវំ សន្តេ"**តិ ឯវំ សតិ តយា វុត្តាការេ លព្ភមានេ ។

*ពាក្យថា "**ឯវំ សន្តេ** ប្រែថា កាលបើយ៉ាងនេះ" គឺកាលអាការៈដែលលោកបានពោលដល់ ។*

**"វាតូបលទ្ធិយា"**តិ វាតស្ស ឧបលទ្ធិយា ។

*បទថា "**វាតូបលទ្ធិយា** ប្រែថា ការដឹងនូវខ្យល់" ។*

**ច**-សទ្ទោ សមុច្ចយត្ថោ, អស្សាសាទិវាតារម្មណស្ស ចិត្តស្ស បភាវនា ឧប្បាទនា បវត្តនា ន ហោតិ, តេ ច តេន បស្សម្ភេតព្វាតិ អធិប្បាយោ ។

**ច**- *សព្ទ មានអត្ថថា រួបរួម, ការធ្វើចិត្ត ដែលមានខ្យល់ដង្ហើមចូលជាដើមមកជាអារម្មណ៍ ឱ្យកើតឡើង ហើយឱ្យប្រព្រឹត្តទៅ (បែបនេះ) រមែងមិនមាន, បានសេចក្ដីថា ព្រោះខ្យល់ដង្ហើមទាំងឡាយនោះ ត្រូវបានព្រះយោគាវចរនោះធ្វើឱ្យរលត់បាត់ទៅហើយ ។*

**"អស្សាសបស្សាសានញ្ច ភាវនា"**តិ ឱឡារិកេ អស្សាសបស្សាសេ ភាវនាយ បដិប្បស្សម្ភេត្វា សុខុមានំ តេសំ បភាវនា ច ន ហោតិ, ឧភយេសំ តេសំ តេន បដិប្បស្សម្ភេតព្វតោ ។

*ពាក្យថា "**ការធ្វើខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឱ្យកើតឡើង**" (ក៏មិនទាន់មាន) មានន័យថា ការធ្វើខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលគ្រោតគ្រាត ឱ្យរលត់បាត់ទៅ ដោយការចម្រើនភាវនា ហើយធ្វើខ្យល់ដង្ហើមទាំងនោះដែលល្អិតសុខុម ឱ្យកើតឡើង គឺមិនមានឡើយ, ព្រោះខ្យល់ទាំង ២ យ៉ាងនោះ ត្រូវបានព្រះយោគាវចរនោះ ធ្វើឱ្យរលត់បាត់ទៅហើយ ។*

**"អាណាចានស្សតិយា"**តិ អាណាចាជារម្មណាយ សតិយា ច បវត្តនំ ន ហោតិ, អាណាចាជានំ អភាវតោ ។

*ពាក្យថា "(ការធ្វើ) **អានាបានស្សតិ** (ឱ្យកើតឡើង ក៏មិនបាន)" គឺការធ្វើសតិ ដែលមានខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឱ្យមកជាអារម្មណ៍ ឱ្យប្រព្រឹត្តទៅ ក៏មិនបាន, ព្រោះមិនមានខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ។*

**តតោ ឯវ តំសម្បយុត្តស្ស អាណាចានស្សតិសមាធិស្ស ច បភាវជា ឧប្បាទនាបិ ន ហោតិ ។**

*ព្រោះហេតុនុ៎ះឯង **ការចម្រើនអានាបានស្សតិសមាធិ** ដែលសម្បយុត្តជាមួយអានាបានស្សតិនោះ **ឱ្យកើតឡើង** គឺជាការធ្វើឱ្យកើតឡើង រមែងមិនមានឡើយ ។*

**ន ហិ កាជាចិ អារម្មណេន វិនា សារម្មណាជម្មា សម្ភវន្តិ ។**

*ព្រោះថា ធម៌ដែលមានអារម្មណ៍ទើបកើតឡើង នឹងមិនកើតឡើងដោយការវៀរចាកនូវអារម្មណ៍នោះទេ ។*

**"ន ច នំ តន្តិ ឯត្ថ ន"ន្តិ និចាតមត្តំ ។**

*ក្នុងពាក្យថា "**ន ច នំ តំ**" នេះ ត្រង់បទថា **នំ** គ្រាន់តែជានិបាត ។*

**តំ វុត្តវិធានំ សមាបត្តឹ បណ្ឌិតា បញ្ញវន្តោ ន ចេវ សមាបជ្ជន្តិបិ តតោ ន វុដ្ឋហន្តិបីតិ យោជនា ។**

*សេចក្តីថា បណ្ឌិតអ្នកមានបញ្ញា កាលទាំងចូលនូវសមាបត្តិដែលមានវិធីដូចបានពោលមកហើយនោះ ក៏មិនបាន ទាំងការចេញចាកពីសមាបត្តិនោះ ក៏មិនបាន ដូច្នេះ ។*

**ឯវំ ចោទកោ សព្វេន សព្វំ អភាវូបនយនំ បស្សម្ភនន្តិ អធិប្បាយេន ចោទេតិ ។**

*តាមប្រការបានពោលមកនេះ ព្រះអាចារ្យ ដែលជាអ្នកសួរ រមែងសួរ ដោយមានន័យថា ការចម្រើនឱ្យរលត់បាត់ ជាការនាំចូលទៅកាន់នូវការមិន មាន ហើយអស់ដោយប្រការទាំងពួង ។*

បុន "**ឥតិ កិរា**"តិអាទិ យថាវុត្តាយ ចោទនាយ វិស្សជ្ជនា ។

*សេចក្តីថា "**ឥតិ កិរ**" ជាដើម ពាក្យមួយទៀតជាពាក្យឆ្លើយនូវពាក្យសួរ តាមដែលបានពោលមកហើយ ។*

តត្ថ "**កិរា**"តិ "យទី"តិ ឯតស្ស អត្ថេ និបាតោ ។ ឥតិ កិរ សិក្ខតិ, មយា វុត្តាកាវេន យទិ សិក្ខតីតិ អត្ថោ។

*ក្នុងពាក្យនោះ សព្ទថា "**កិរ**" ជានិបាត ក្នុងសេចក្តីថា "យទិ ប្រែថា ប្រសិនបើថា" នេះ ។ មានន័យថា **ឥតិ កិរ សិក្ខតិ** គឺប្រសិនបើថាព្រះ យោគាវចរភិក្ខុ រមែងសិក្សា ទៅតាមអាការៈដែលខ្ញុំម្ចាស់បានពោលទុកមក ហើយ ។*

"**ឯវំ សន្តេ**"តិ ឯវំ បស្សម្ភនេ សតិ ។

*ពាក្យថា "**កាលជាយ៉ាងនេះ**" គឺកាលមានការចម្រើនឱ្យរលត់បាត់ យ៉ាងនេះ ។*

"**បភាវនា ហោតី**"តិ យទិបិ ឱឡារិកា កាយសង្ខារា បដិប្បស្សម្ភន្តិ, សុខុមា បន អត្ថេវាតិ អនុក្កមេន បរមសុខុមភាវប្បត្តស្ស វសេន និមិត្តុប្បត្តិយា អានាបានស្សតិយា, អានាបានស្សតិសមាធិស្ស ច បភាវនា ឥជ្ឈតេវាតិ អធិប្បាយោ ។

*ពាក្យថា "**ការធ្វើ ឬការចម្រើន** (នូវអានាបានស្សតិសមាធិ) **ឱ្យកើតឡើង បាន**" អធិប្បាយថា កាយសង្ខារដែលគ្រោតគ្រាត រមែងរលត់បាត់ទៅ យ៉ាង ពិតប្រាកដ, ប៉ុន្តែថា កាយសង្ខារដែលល្អិតសុខុម នៅមាននៅឡើយ ព្រោះ ដូច្នោះ ការចម្រើននូវអានាបានស្សតិសមាធិ ឱ្យកើតឡើង រមែងសម្រេចទៅបាន*

*យ៉ាងពិតប្រាកដ ព្រោះមានខ្យល់ដង្ហើមល្អិតនោះជានិមិត្ត កើតឡើងដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលមានសភាពល្អិតសុខុមក្រៃលែង ទៅតាមលំដាប់ ។*

**"យថា កថំ វិយា"តិ យថាវុត្តវិធានំ តំ កថំ វិយ ទដ្ឋព្វំ, អត្ថិ កិញ្ចិ តទត្ថសម្បដិចាតនេ ឧបម្មន្តិ អធិប្បាយោ ។**

*ពាក្យថា "**មានការឧបមា ប្រៀបបានដូចទៅនឹងអ្វី ?**" មានន័យថា វិធីតាមដែលបានពោលមកហើយនោះ មានការឧបមា ប្រៀបដូចនឹងអ្វី ? ទើបគប្បីឃើញបាន, អធិប្បាយថា តើការឧបមាប្រភេទណាមួយ ដើម្បីអាចទទួលយកនូវខ្លឹមសារនោះបាន មានដែរឬទេ ? ។*

**ឥទានិ ឧបម្មំ ទស្សេន្តោ "សេយ្យថាបី"តិអាទិ វុត្តំ ។**

*ឥឡូវនេះ ព្រះសារីបុត្តថេរៈប្រាថ្នាសម្តែងនូវ ឧបមាមួយ ទើបលោកពោលថា "សេយ្យថាបិ" ដែលមានសេចក្តីដូច្នេះ ជាដើម ។*

## ការឧបមា

**តត្ថ "សេយ្យថាបី"តិ ឧបម្មត្ថេ និបាតោ ។**

*ក្នុងបណ្តាពាក្យទាំងឡាយនោះ ពាក្យថា "**ប្រៀបដូចនឹងអ្វី ?**" ជាពាក្យនិបាត ក្នុងសេចក្តីថា ជាការឧបមា ។*

**"កំសេ"តិ កំសភាជនេ ។**

*បទថា "**កំសេ**" បានដល់ ជួងសំរឹទ្ធ ។*

**"និមិត្ត"ន្តិ និមិត្តស្ស, តេសំ សទ្ទានំ បវត្តាការស្សាតិ អត្ថោ ។**

*បទថា "**និមិត្តំ**" កែមកជា **និមិត្តស្ស**, មានន័យថា បានកែអាការៈឱ្យប្រព្រឹត្តទៅនៃសំឡេងទាំងនោះ ។*

សាមិអត្ថេ ហិ ឥទំ ឧបយោគវចនំ ។

*បទថា* **និមិត្តំ** *នេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។*

"**សុគ្គហិតត្តា**"តិ សុដ្ឋុ គហិតត្តា ។

*បទថា* "**សុគ្គហិតត្តា**" *ប្រែថា ព្រោះ (និមិត្តនៃសំឡេងដែលគ្រោតគ្រាត) ព្រះយោគាវចរភិក្ខុបានកាន់យកដោយល្អហើយ ។*

"**សុមនសិកតត្តា**"តិ សុដ្ឋុ ចិត្តេ ឋបិតត្តា ។

*ពាក្យថា* "**ព្រោះធ្វើទុកក្នុងចិត្តបានល្អហើយ**" *គឺ ព្រោះតាំងទុកក្នុងចិត្តបានល្អហើយ ។*

"**សូបធារិតត្តា**"តិ សម្មទេវ ឧបធារិតត្តា សល្លក្ខិតត្តា ។

*ពាក្យថា* "**ព្រោះចងចាំទុកបានល្អហើយ**" *បានដល់ ព្រោះចងចាំទុកបាន គឺ ព្រោះកំណត់ទុកបានដោយប្រពៃហើយ នុ៎ះឯង ។*

"**សុខុមកា សទ្ទា**"តិ អណុវោ អាហ, យេ អប្បកា ។

*លោកពោលដល់សំឡេងថ្នមៗថា* "**សុខុមកា សទ្ទា**" *ប្រែថា* ***ជាសំឡេងល្អិតសុខុម, ដែលបានដល់សំឡេងស្រាលៗ ឬតិចៗ នោះឯង ។***

អប្បត្ថោ ហិ អយំ ក-សទ្ទោ ។

*ព្រោះ* **ក**-*សព្ទ (ក្នុងពាក្យថា* **សុខុមកា**) *នេះ មានអត្ថថា បន្តិចបន្តួច គឺ ស្រាលៗ តិចៗ ។*

"**សុខុមសទ្ទនិមិត្តារម្មណតាបី**"តិ សុខុមោ សទ្ទោវ និមិត្តំ សុខុមសទ្ទនិមិត្តំ, តទារម្មណតាយបិ ។

*ពាក្យថា* "***សូម្បីសភាវៈដែលមាននិមិត្តនៃសំឡេង ដែលល្អិតសុខុម មកជាអារម្មណ៍***" *មានន័យថា សំឡេងដែលល្អិតសុខុមនោះឯងវាជានិមិត្ត ទើប*

*ឈ្មោះថា សុខុមសទ្ទនិមិត្តំ, បានដល់ ព្រោះសភាវៈដែលមាននិមិត្ត គឺសំឡេងដែលល្អិតសុខុមនោះ មកជាអារម្មណ៍ ។*

**កឹ វុត្តំ ហោតិ? តាមំ តបាសុខុមាបិ សទ្ទា និរុទ្ធា, សទ្ទនិមិត្តស្ស បន សុគ្គហិតត្តា សុខុមតរសទ្ទនិមិត្តារម្មណភាវេនាបិ ចិត្តំ បវត្តតិ ។**

*តើមានការអធិប្បាយដូចម្តេច? អធិប្បាយថា ក្នុងវេលានោះ សំឡេងដែលល្អិតសុខុម បានរលត់បាត់ទៅហើយក៏ពិត, ព្រោះតែនិមិត្តនៃសំឡេង ដែលបុគ្គលបានកាន់យកដោយល្អហើយ ចិត្តក៏ប្រព្រឹត្តទៅបាន ដោយសភាវៈដែលមាននិមិត្តនៃសំឡេងដែលល្អិតសុខុមជាងនោះ មកជាអារម្មណ៍ ។*

**អាទិតោ បដ្ឋាយ ហិ តស្ស តស្ស និរុទ្ធស្ស សទ្ទស្ស និមិត្តំ អវិក្ខិត្តេន ចិត្តេន ឧបជាវេន្តស្ស អនុក្កមេន បរិយោសានេ អតិសុខុមសទ្ទនិមិត្តម្បិ អារម្មណំ កត្វា ចិត្តំ បវត្តតេវ ។**

*មែនពិត កាលបុគ្គលមានចិត្តមិនរាយមាយ បានចងចាំនៃនិមិត្តគឺសំឡេងដែលរលត់បាត់ទៅហើយនោះ មកតាំងតែពីដើម ចិត្តក៏នៅប្រព្រឹត្តទៅ បានធ្វើនៃនិមិត្តគឺសំឡេងដែលកាន់តែល្អិតសុខុមក្រៃលែងជាងនោះ ឱ្យមកជាអារម្មណ៍ រហូតទៅដល់ទីបំផុត ទៅតាមលំដាប់ ។*

**ចិត្តំ ន វិក្ខេបំ គច្ឆតិ តស្មឹ យថាឧបដ្ឋិតេ និមិត្តេ សមាធានសព្ភាវតោ ។**

*ឈ្មោះថា ចិត្ត ក៏មិនដល់នូវភាពរាយមាយ ព្រោះមានការតាំងមាំក្នុងនិមិត្ត គឺសំឡេងតាមដែលប្រាកដមកហើយនោះ ។*

**ឯវំ "សន្តេ"តិអាទិ វុត្តស្សេវត្ថស្ស និគមនវសេន វុត្តំ ។**

*ពាក្យថា "**កាលបើយ៉ាងនេះ**" ជាដើម លោកពោលទុក ដោយជាប់ទាក់ទងជាមួយពាក្យបញ្ចប់នូវសេចក្តី ដែលបានពោលហើយ នុ៎ះឯង ។*

តត្ថ យស្ស សុត្តបទស្ស សង្ខី ចោទនាសោធនាហិ អត្ថោ វុត្តោ, តំ ឧទ្ធរិត្វា កាយានុបស្សនាសតិបដ្ឋានាទិ វិភាគតោ ទស្សេតុំ "**បស្សម្ភយ**"ន្តិអាទិ វុត្តំ។

*បណ្ដាពាក្យទាំងនោះ លោកពោលនូវអត្ថសេចក្ដីព្រមទាំងជាពាក្យសំណួរ និងពាក្យចម្លើយនៃបទព្រះសូត្រណាទុក, ដើម្បីនឹងលើកព្រះសូត្រនោះឡើងមកសម្ដែងនូវ* **កាយានុបស្សនាសតិប្បដ្ឋាន** *ដោយចំណែក ទើបពោលថា "កាយសង្ខារដែលព្រះយោគីភិក្ខុ **បានចម្រើនឱ្យរលត់បាត់ទៅ**" ដូច្នេះជាដើម ។*

តំ សព្ពំ វុត្តនយត្តា ឧត្តានមេវ ។

*ពាក្យដ៏ទៃទាំងអស់នោះ ងាយយល់សេចក្ដីហើយ ព្រោះមានន័យសេចក្ដីទៅតាមលំដាប់ ដែលបានពោលមកហើយ នុ៎ះឯង ។*

# វិធីហ្វឹកហាត់

(វិសុទ្ធិមគ្គ)

[២២២] យស្មា បនេត្ថ ឥទមេវ ចតុក្កំ អាទិកម្មិកស្ស កម្មដ្ឋានវសេន វុត្តំ ។

*ព្រោះហេតុដែលក្នុងចតុក្កៈទាំង ៤ នេះ ចតុក្កៈខាងដើមនេះប៉ុណ្ណោះ ដែលព្រះអង្គបានត្រាស់សម្ដែងទុក ដោយជាប់ទាក់ទងជាកម្មដ្ឋានរបស់ព្រះយោគាវចរ ដែលជាអាទិកម្មិកបុគ្គល (គឺបុគ្គលអ្នកបដិបត្តិដំបូងៗ) ។*

ឥតរានិ បន តីណិ ចតុក្កានិ ឯត្ថ បត្តជ្ឈានស្ស វេទនាចិត្តធម្មានុបស្សនាវសេន វុត្តានិ ។

*ចំណែក ៣ ចតុក្កៈក្រៅពីនេះ ព្រះអង្គត្រាស់សម្ដែងទុក ដោយជាប់ទាក់ទងជាមួយ វេទនានុបស្សនា ចិត្តានុបស្សនា និងធម្មានុបស្សនារបស់ព្រះយោគាវចរ អ្នកបានសម្រេចនូវឈានរួចហើយ ដែលមាននៅក្នុងចតុក្កៈដំបូង (គឺចតុក្កៈទី ១) នេះឯង ។*

តស្មា ឥទំ កម្មដ្ឋានំ ភាវេត្វា អានាបានចតុត្ថជ្ឈានបទដ្ឋានាយ វិបស្សនាយ សហ បដិសម្ភិទាហិ អរហត្តំ បាបុណិតុកាមេន អាទិកម្មិកេន កុលបុត្តេន បុព្វេ វុត្តនយេនេវ សីលបរិសោធនាទីនិ សព្វកិច្ចានិ កត្វា វុត្តប្បការស្ស អាចរិយស្ស សន្តិកេ បញ្ចសន្ធិកំ កម្មដ្ឋានំ ឧគ្គហេតព្វំ ។

*ព្រោះហេតុនោះ កុលបុត្រជាអាទិកម្មិកៈ ដែលប្រាថ្នានឹងចម្រើននូវកម្មដ្ឋាននេះ ហើយបានសម្រេចនូវព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ដោយវិបស្សនាដែលមានចតុត្ថជ្ឈានក្នុងអានាបានស្សតិជាបទដ្ឋាន គប្បីចម្រើននូវកិច្ចទាំងពួង ដែលមានការជម្រះនូវសីលឱ្យបរិសុទ្ធិជាដើម តាមន័យដែលបានពោលមកហើយនៅខាងដើមនុ៎ះឯង ហើយរៀនយកនូវកម្មដ្ឋាន ដែលមាន*

*សន្ធិ ៥ យ៉ាងក្នុងសំណាក់របស់លោកអាចារ្យ តាមដែលបានពោលមកហើយនុ៎ះ ចុះ ។*

## រៀនតាមតំណា ៥ យ៉ាង

តត្រិមេ បញ្ច សន្ធយោ ឧគ្គហោ, បរិបុច្ឆា, ឧបដ្ឋានំ, អប្បនា, លក្ខណន្តិ ។

*ក្នុងពាក្យថា កម្មដ្ឋានដែលមានសន្ធិ ៥ យ៉ាងនោះ បានដល់សន្ធិ ៥ ប្រភេទគឺ ៖*

១. **ឧគ្គហ** *ការរៀនយក*

២. **បរិបុច្ឆនា** *ការសាកសួរ*

៣. **ឧបដ្ឋាន** *ការប្រាកដរបស់កម្មដ្ឋាន*

៤. **អប្បនា** *ការតាំងមាំរបស់កម្មដ្ឋាន*

៥. **លក្ខណា** *ការកំណត់ ។*

តត្ថ **ឧគ្គហោ** នាម កម្មដ្ឋានស្ស ឧគ្គណ្ហនំ ។

*ក្នុងសន្ធិ ៥ យ៉ាងនោះ ដែលឈ្មោះថា* **ឧគ្គហ** *បានដល់ ការរៀនយកនូវកម្មដ្ឋាន ។*

**បរិបុច្ឆា** នាម កម្មដ្ឋានស្ស បរិបុច្ឆនា ។

*ឈ្មោះថា* **បរិបុច្ឆនា** *បានដល់ ការសាកសួរនូវកម្មដ្ឋាន ។*

**ឧបដ្ឋានំ** នាម កម្មដ្ឋានស្ស ឧបដ្ឋានំ ។

*ឈ្មោះថា* **ឧបដ្ឋាន** *បានដល់ ការប្រាកដនៃកម្មដ្ឋាន ។*

**អប្បនា** នាម កម្មដ្ឋានស្ស អប្បនា ។

*ឈ្មោះថា អប្បនា បានដល់ ការតាំងមាំនៃកម្មដ្ឋាន ។*

**លក្ខណំ នាម កម្មដ្ឋានស្ស លក្ខណំ ។**

*ឈ្មោះថា លក្ខណា បានដល់ ការកំណត់យកនូវកម្មដ្ឋាន ។*

**"ឯវំលក្ខណមិទំ កម្មដ្ឋាន"ន្តិ កម្មដ្ឋានសភាវូបធារណន្តិ វុត្តំ ហោតិ ។**

*មានសេចក្ដីអធិប្បាយទុកថា ការទ្រទ្រង់ចាំទុកនូវសភាវៈនៃកម្មដ្ឋានថា "កម្មដ្ឋាននេះ មានលក្ខណៈ យ៉ាងនេះៗ" ដូច្នេះ ។*

**ឯវំ បញ្ចសន្ធិកំ កម្មដ្ឋានំ ឧគ្គណ្ហន្តោ អត្តនាបិ ន កិលមតិ, អាចរិយម្បិ ន វិហេសេតិ ។**

*ព្រះយោគាវចរ កាលរៀនយកនូវកម្មដ្ឋានដែលមានសន្ធិ ៥ យ៉ាងនេះ រមែងមិនលំបាកសូម្បីតែខ្លួនឯងផង, និងសូម្បីតែលោកអាចារ្យ ក៏មិនលំបាកក្នុងការបង្រៀនផង ។*

**តស្មា ថោកំ ឧទ្ទិសាបេត្វា ពហុកាលំ សជ្ឈាយិត្វា ឯវំ បញ្ចសន្ធិកំ កម្មដ្ឋានំ ឧគ្គហេត្វា អាចរិយស្ស សន្តិកេ វា អញ្ញត្រ វា បុព្វេ វុត្តប្បការេ សេនាសនេ វសន្តេន ឧបច្ឆិន្នខុទ្ទកបលិពោធេន កតភត្តកិច្ចេន ភត្តសម្មទំ បដិវិនោទេត្វា សុខនិសិន្នេន រតនត្តយគុណានុស្សរណេន ចិត្តំ សម្បហំសេត្វា អាចរិយុគ្គហតោ ឯកបទម្បិ អសម្មុយ្ហន្តេន ឥទំ អានាបានស្សតិកម្មដ្ឋានំ មនសិកាតព្វំ ។**

*ព្រោះហេតុនោះ អានាបានស្សតិកម្មដ្ឋាននេះ ព្រះយោគាវចរគួរឱ្យគ្រូបាអាចារ្យចង្អុលបង្ហាញ (បង្រៀនប្រៀនប្រដៅ) តែបន្តិចបន្តួច ហើយប្រើពេលស្វាធ្យាយឱ្យច្រើន រៀនយកកម្មដ្ឋានដែលមានសន្ធិ ៥ យ៉ាង នេះហើយក៏នៅក្នុងសំណាក់របស់លោកអាចារ្យ ឬក្នុងទីដទៃ ដែលជាទីសេនាសនៈដូចបានពោលមកហើយ នៅក្នុងន័យខាងដើម រួចហើយត្រូវកាត់បលិពោធតិចតួចចេញ និង*

*ធ្វើកត្តកិច្ចឱ្យរួចជាស្រេចហើយ បន្ទាប់ការស្រវឹងក្នុងអាហារ អង្គុយឱ្យសប្បាយ ញ៉ាំងចិត្តឱ្យត្រេកអរ (ក្នុងកម្មដ្ឋាន) ដោយការរលឹករឿយៗ នូវគុណរបស់ព្រះរតនត្រ័យ ដោយមិនភ្លេចសូម្បីតែមួយបទ ដែលបានរៀនមកពីគ្រូបាអាចារ្យ ហើយគប្បីមនសិការទៅរឿយៗចុះ ។*

តត្រាយំ មនសិការវិធិ ។

*តទៅនេះ ជាវិធីមនសិការក្នុងអានាបានស្សតិកម្មដ្ឋាននេះ ។*

## វិធីហ្វឹកហាត់

**(មហាដីកាវិសុទ្ធិមគ្គ)**

[២២២] "**អាទិកម្មិកស្ស កម្មដ្ឋានវសេនា**"តិ សមថកម្មដ្ឋានំ សន្ធាយ វុត្តំ។

*ពាក្យថា "**ដោយជាប់ទាក់ទងជាមួយកម្មដ្ឋានរបស់ព្រះយោគាវចរជាអាទិកម្មិក**" គឺលោកពោលសំដៅយកសមថកម្មដ្ឋាន ។*

វិបស្សនំ កម្មដ្ឋានំ បន ឥតរចតុក្កេសុបិ លព្ភតេវ ។

*ចំណែកក្នុងវិបស្សនាកម្មដ្ឋាន រមែងមាន សូម្បីក្នុងចតុក្កៈក្រៅពីនេះ (គឺមាននៅក្នុងចតុក្កៈទី ២ ជាដើម) ។*

"**ឯត្ថា**"តិ បឋមចតុក្កេ ។

*បទថា "**ឯត្ថ**" យោគ បឋមចតុក្កេ ប្រែថា ក្នុងចតុក្កៈខាងដើមនេះ ។*

"**បញ្ចសន្ធិកា**"ន្តិ បញ្ចបព្វំ, បញ្ចភាគន្តិ អត្ថោ ។

*ពាក្យថា "**ដែលមានសន្ធិ ៥ យ៉ាង**" គឺ មាន ៥ ចំណុច បានសេចក្ដីថា មាន ៥ ចំណែក ។*

"**កម្មដ្ឋានស្ស ឧគ្គណ្ហន**"ន្តិ កម្មដ្ឋានគន្ថស្ស ឧគ្គណ្ហនំ ។

*ពាក្យថា "**ការរៀនយកនូវកម្មដ្ឋាន**" គឺការរៀនតាមក្បួនតម្រាដែលបាន ពោលអំពីកម្មដ្ឋានមានបិដក អដ្ឋកថា មហាដីកា ជាដើម ។*

**តជត្ថបរិបុច្ឆា កម្មដ្ឋានស្ស បរិបុច្ឆនា ។**

*ការសាកសួរនូវសេចក្តីក្នុងក្បួនតម្រា ដែលបានពោលអំពីកម្មដ្ឋាននោះ ឈ្មោះថា **ការសាកសួរនូវកម្មដ្ឋាន** (គឺសួរក្នុងសម្នាក់របស់លោកអាចារ្យ) ។*

**អថ វា គន្ថតោ, អត្ថតោ ច កម្មដ្ឋានស្ស ឧគ្គណ្ហនំ ឧគ្គហោ ។**

*ន័យម្យ៉ាងទៀត ការរៀនយកនូវកម្មដ្ឋានតាមក្បួនតម្រា និងតាមសភាវៈ ឈ្មោះថា **ឧគ្គហ** ។*

**តត្ថ សំសយបរិបុច្ឆនា បរិបុច្ឆា ។**

*ការសាកសួរ ព្រោះភាពសង្ស័យក្នុងកម្មដ្ឋាននោះៗ ឈ្មោះថា **បរិបុច្ឆា** ។*

**"កម្មដ្ឋានស្ស ឧបដ្ឋាន"ន្តិ និមិត្តុបដ្ឋានំ, ឯវំ ភាវេមនុយុញ្ជន្តស្ស "ឯវមិទំ និមិត្តំ ឧបដ្ឋាតី"តិ ឧបធារណំ, តថា កម្មដ្ឋានប្បនា "ឯវំ ឈានមប្បេតី"តិ ។**

*ពាក្យថា "**ការប្រាកដនៃកម្មដ្ឋាន**" បានដល់ ការប្រាកដនៃនិមិត្ត(គឺបរិកម្មនិមិត្ត,ឧគ្គហនិមិត្ត,ពន្ទឹបដិភាគនិមិត្ត), គឺការចងចាំទុកថា កាលអាត្មាអញ ចម្រើនភាវនាទៅយ៉ាងនេះ "និមិត្ត ក៏ប្រាកដក្នុងកម្មដ្ឋានយ៉ាងនេះ" ដូច្នេះ, ដែល ឈ្មោះថា **អប្បនានៃកម្មដ្ឋាន** គឺយ៉ាងនោះ ដូចគ្នា បានដល់ ការចងចាំទុកថា កាលអាត្មាអញ បានចម្រើនភាវនាទៅយ៉ាងនេះ ថា "ឈាន រមែងដល់ នូវអប្បនា បានយ៉ាងនេះ" ។*

**"កម្មដ្ឋានស្ស លក្ខណ"ន្តិ គណនានុពន្ធនាផុសនានំ វសេន ភាវនំ ឧស្សុក្កាបេត្វា បបញ្ចាយ សម្បត្តិ, តតោ បរម្បិ វា សលក្ខណា-និវសេន មត្ថកប្បត្តីតិ កម្មដ្ឋានសភាវស្ស សលក្ខណំ ។**

*ពាក្យថា "**ការកំណត់នូវកម្មដ្ឋាន**" បានដល់ ការកំណត់ទុកដោយល្អ នូវសភាវៈនៃកម្មដ្ឋានថា ព្រោះតែចម្រើនភាវនាឱ្យចម្រើនទៅមុខ ដោយអំណាចនៃ*

១. **គណនា** *ការកំណត់រាប់នូវខ្យល់ដង្ហើមចូល ចេញ ។*

២. **អនុពន្ធនា** *សតិនៅជាមួយខ្យល់ដង្ហើមចូល ចេញ ។*

៣. **ផុសនា** *ទីកន្លែងដែលពាល់ត្រូវនូវខ្យល់ដង្ហើមចូល ចេញ ។*

៤. **ឋបនា** *ការតាំងមាំរបស់សមាធិ គឺជា* **អប្បនា**, *ឬសូម្បីឱ្យក្រៃលែងជាងនោះ គឺមានការទៅដល់ចំណុចកំពូល ដែលជាប់ទាក់ទងជាមួយ* **សល្លក្ខណា** *ប្រែថា វិបស្សនាដែលកំណត់យកជាត្រៃលក្ខណ៍ ជាដើម ដូច្នេះ ។*

តេនាហ "**កម្មដ្ឋានសភាវូបធារណន្តិ វុត្តំ ហោតី**"តិ ។

*ព្រោះហេតុនោះ លោកទើបពោលថា "**អធិប្បាយថា ការចងចាំនូវ សភាវៈនៃកម្មដ្ឋាន**" ដូច្នេះ ។*

**អត្តនាបិ ន កិលមតិ ឱធិសោ កម្មដ្ឋានស្ស ឧគ្គណ្ហនតោ ។**

*ឈ្មោះថា **រមែងមិនលំបាក សូម្បីតែខ្លួនឯងផង** ព្រោះរៀនយកនូវកម្មដ្ឋានទុកដោយហ្មត់ចត់ ។*

**តតោ ឯវ អាចរិយម្បិ ន វិហេសេតិ ធម្មាធិករណម្បិ ភាវនាយ មត្ថកំ ចាបនតោ ។**

*ព្រោះហេតុនុ៎ះឯង ទើបឈ្មោះថា **រមែងមិនធ្វើឱ្យសូម្បីតែលោកអាចារ្យលំបាកផង** ឬថាបានធ្វើការត្រៀមទុកនូវព្រះធម៌ ឱ្យដល់កំពូលនៃការភាវនា ។*

"**តស្មា**"តិ តំ និមិត្តំ អត្តនោ អកិលមនអាចរិយាវិហេសនហេតុ ។

*ពាក្យថា "**ព្រោះហេតុនោះៗ**" គឺព្រោះហេតុនោះ បានដល់ ព្រោះហេតុដែលមិនធ្វើខ្លួនឱ្យលំបាក និងមិនធ្វើឱ្យលោកអាចារ្យក្តៅក្រហាយផង ។*

"**ថោកា**"ន្តិ ថោកំ ថោកំ ។

*បទថា "***ថោកំ***" កែមកជា* **ថោកំ ថោកំ** *ប្រែថា បន្តិចបន្តួច ។*

**ឧគ្គហេតព្វតោ ឧគ្គហោ, សព្វោបិ កម្មដ្ឋានវិធិ, ន បុព្វេ វុត្ត ឧគ្គហមត្តំ ។**

*វិធីនៃកម្មដ្ឋានសូម្បីទាំងអស់ ឈ្មោះថា* **ឧគ្គហ** (*ក្នុងបទថា* **អាចរិយុគ្គ-ហោ**) *ព្រោះត្រូវតែរៀន, មិនមែនគ្រាន់តែជា* **ឧគ្គហ** (*ប្រែថា ការរៀន*) *ដែលបានពោលទុកក្នុងសន្ធិខាងដើម ប៉ុណ្ណោះទេ ។*

**អាចរិយតោ ឧគ្គហោ អាចរិយុគ្គហោ, តតោ។ "ឯកបទម្បី"តិ ឯកកោដ្ឋាសម្បិ ។**

*វិធីដែលរៀនពីលោកលោកអាចារ្យ ឈ្មោះថា* **អាចរិយុគ្គហោ**, *បានដល់រៀនមកពីលោកគ្រូអាចារ្យនោះ ។ ពាក្យថា "***សូម្បីតែមួយបទ***" គឺសូម្បីតែមួយចំណែក ។*

# វិធីមនសិការ ៨ យ៉ាង[៣៦]

## (វិសុទ្ធិមគ្គ)

[២២៣] គណនា អនុពន្ធនា, ផុសនា ឋបនា សល្លក្ខណា;
វិវដ្ដនា ចារិសុទ្ធិ, តេសញ្ច បដិបស្សនាតិ ។

១. **គណនា** *ការកំណត់រាប់នូវខ្យល់ដង្ហើមចូល ចេញ ។*

២. **អនុពន្ធនា** *គឺសតិនៅជាមួយខ្យល់ដង្ហើមចូល ចេញ ។*

៣. **ផុសនា** *ទីកន្លែងដែលពាល់ត្រូវនូវខ្យល់ដង្ហើម ។*

៤. **ឋបនា** *ការតាំងមាំរបស់សមាធិ ។*

៥. **សល្លក្ខណា** *ការកំណត់*

៦. **វិវដ្ដនា** *ការបញ្ឈប់ (នូវការអន្ទោលទៅមកៗ)*

៧. **ចារិសុទ្ធិ** *ភាពបរិសុទ្ធិ*

៨. **តេសញ្ច បដិបស្សនា** *ការត្រឡប់មកមើលនូវវិវដ្ដនា និង បារិសុទ្ធិ ឡើងវិញ ។*

**តត្ថ "គណនា"តិ គណនាយេវ ។**

*ក្នុងវិធីមនសិការទាំងនោះ បទថា* "**គណនា**" *ការកំណត់រាប់នូវខ្យល់ដង្ហើមចូល ចេញ ។*

**"អនុពន្ធនា"តិ អនុវហនា ។**

*បទថា* "**អនុពន្ធនា**" *កែទៅជា អនុវហនា សតិនៅជាមួយខ្យល់ដង្ហើម ។*

**"ផុសនា"តិ ផុដ្ឋដ្ឋានំ ។**

---

*៣៦ នេះគឺជាវិធីធ្វើទុកក្នុងចិត្ត៨ ប្រការ ដើម្បីធ្វើឱ្យសតិតាំងមាំជាមួយដង្ហើមចូលដង្ហើមចេញ*

*បទថា* "**ផុសនា**" *ទីកន្លែងដែលពាល់ត្រូវនូវខ្យល់ដង្ហើមចូល ចេញ ។*

"**ឋបនា**"តិ អប្បនា ។

*បទថា* "**ឋបនា**" *បានដល់* អប្បនា *ការតាំងមាំរបស់សមាធិ ។*

"**សល្លក្ខណា**"តិ វិបស្សនា ។

*បទថា* "**សល្លក្ខណា**" *បានដល់* វិបស្សនា *។*

"**វិវដ្ដនា**"តិ មគ្គោ ។

*បទថា* "**វិវដ្ដនា**" *បានដល់* មគ្គ *។*

"**បារិសុទ្ធី**"តិ ផលំ ។

*បទថា* "**បារិសុទ្ធិ**" *បានដល់* ផល *។*

"**តេសញ្ច បដិបស្សនា**"តិ បច្ចវេក្ខណា ។

*បទថា* "**តេសញ្ច បដិបស្សនា**" *បានដល់* បច្ចវេក្ខណៈ *(ការពិចារណាមគ្គ និងផល) ។*

## កុលបុត្រអាទិកម្មិកបដិបត្តិកម្មដ្ឋានគួររាប់

តត្ថ ឥមិនា អាទិកម្មិកេន កុលបុត្តេន បឋមំ គណនាយ ឥទំ កម្មដ្ឋានំ មនសិកាតព្វំ ។

*ក្នុងវិធីមនសិការទាំង ៨ យ៉ាងនោះ កុលបុត្រដែលជាអាទិកម្មិកនេះ គប្បីមនសិការនូវកម្មដ្ឋាននេះ ជាដំបូងដោយការរាប់សិន ។*

គណេន្តេន ច បញ្ចន្នំ ហេដ្ឋា ន ឋបេតព្វំ។

*ការរាប់ មិនគួរឈប់រាប់ក្រោម ៥ ន៉ុះទេ ។*

ទសន្នំ ឧបរិ ន នេតព្វំ។

*និងមិនគួររាប់ឱ្យលើសជាង ១០ នោះទេ ។*

អន្តរា ខណ្ឌំ ន ទស្សេតព្វំ។

*មិនគួរធ្វើឱ្យខាតតាមលំដាប់ (នៃការរាប់ទេ) ។*

បញ្ចន្នំ ហេដ្ឋា ឋបេន្តស្ស ហិ សម្ពាធេ ឱកាសេ ចិត្តុប្បាទោ វិប្ផន្ទតិ សម្ពាធេវជេ សន្និរុទ្ធគោគណោ វិយ ។

*ព្រោះថា កាលឈប់រាប់ក្រោម ៥ ចិត្តក៏កើតឡើងនូវភាពរសាប់រសល់ក្នុងឱកាសដែលចង្អៀត ប្រៀបដូចហ្វូងគោ ដែលត្រូវបានឃាំងទុកក្នុងក្រោលគោដែលតូចចង្អៀតដូច្នោះ ។*

ទសន្នម្បិ ឧបរិ នេន្តស្ស គណននិស្សិតកោ ចិត្តុប្បាទោ ហោតិ ។

*សូម្បីកាលរាប់ទៅលើស ១០ ចិត្តក៏ជាប់រវល់នៅជាមួយនៃការរាប់ នោះតែប៉ុណ្ណោះ ។*

អន្តរា ខណ្ឌំ ទស្សេន្តស្ស "សិខាប្បត្តំ នុ ខោ មេ កម្មដ្ឋានំ, នោ"តិ ចិត្តំ វិកម្បតិ ។

*កាលធ្វើឱ្យខាតតាមលំដាប់ (នៃការរាប់) ចិត្ត រមែងកង្វល់ថា "កម្មដ្ឋានរបស់អាត្មាអញ នឹងដល់ទីបំផុត ឬទេហ្ន៎ (គឺចិត្តបានរាយមាយបែបនេះ)" ដូច្នេះ ។*

តស្មា ឯតេ ទោសេ វជ្ជេត្វា គណេតព្វំ ។

*ព្រោះហេតុនោះ គប្បីរាប់ដោយការវៀរចាកនូវទោសទាំងនេះចេញ ។*

## ការរាប់ដោយយឺតៗ តាមអ្នកវាល់ស្រូវ

គណេន្តេន ច បឋមំ ទន្ធគណនាយ ធញ្ញមាបកគណនាយ គណេតព្វំ ។

*ម្យ៉ាងទៀត ព្រះយោគាវចរ កាលនឹងរាប់ មុនដំបូងត្រូវរាប់តាមវិធីរាប់យឺតៗ* ***គឺរាប់តាមវិធីអ្នកវាល់ស្រូវជាមុនសិន ។***

**ធញ្ញមាបកោ ហិ ធាញ្ញំ បូរេត្វា "ឯក"ន្តិ វត្វា ឱកិរតិ ។**

*មែនពិត អ្នកវាល់ស្រូវ កាលកើបពេញនាឡិហើយ ក៏ពោលថា " មួយ " ហើយក៏ចាក់ចេញទៅ (គឺទាំងការកើប និងការចាក់ចេញរាប់ថា "១")។*

**បុន បូរេន្តោ កិញ្ចិ កចវរំ ទិស្វា តំ ឆឌ្ឌេន្តោ "ឯកំ ឯក"ន្តិ វទតិ ។**

*រួចហើយក៏កើបឱ្យពេញនាលម្តងទៀត កាលឃើញកម្ទេចកម្ទីអ្វីៗ បានចូលក្នុងនាឡិ ក៏យកបោះចោលទៅ ហើយបានពោលថា "មួយ, មួយ" (បានសេចក្តីថា ទាំងការកើបស្រូវចូលក្នុងនាឡិ និងទាំងការចាក់ស្រូវចេញពីនាឡិ ក៏នៅតែរាប់ថា "មួយដដែល) ដូច្នេះ ។*

**ឯស នយោ "ទ្វេ ទ្វេ"តិអាទីសុ ។**

*ក្នុងការពោលថា "ពីរ,ពីរ" ជាដើម ក៏មានន័យសេចក្តីដូចគ្នា ។*

**ឯវមេវ ឥមិនាបិ អស្សាសបស្សាសេសុ យោ ឧបដ្ឋាតិ, តំ គហេត្វា "ឯកំ ឯក"ន្តិ អាទឹ កត្វា យាវ "ទស ទសា"តិ បវត្តមានំ បវត្តមានំ ឧបលក្ខេត្វាវ គណេតព្វំ ។**

*ក្នុងបណ្តាខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ខ្យល់ប្រភេទណាមួយដែលបានប្រាកដច្បាស់ដល់ព្រះយោគាវចរ, សូម្បីព្រះយោគាវចរ ដែលជាអាទិកម្មិកបុគ្គលរូបនេះ ក៏គប្បីកំណត់កាន់យកនូវខ្យល់ដង្ហើមដែលកំពុងប្រព្រឹត្តទៅប្រភេទនោះ នុ៎ះឯង ហើយចាប់ផ្តើមរាប់តាំងតែខាងដើមមកថា "មួយ, មួយ" រហូតដល់ថា "ដប់, ដប់" ដូច្នេះ យ៉ាងនេះចុះ ។*

**តស្ស ឯវំ គណយតោ និក្ខមន្តា ច បវិសន្តា ច អស្សាសបស្សាសា បាកដា ហោន្តិ ។**

*កាលព្រះយោគាវចររូបនោះ រាប់ទៅៗ យ៉ាងនេះ ខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ ដែលបានចូល និងចេញ រមែងជាខ្យល់ធម្មជាតិ ហើយ បានដឹងប្រាកដច្បាស់ ។*

## ការរាប់រហ័ស តាមអ្នកចិញ្ចឹមគោ

អថានេន តំ ធញ្ញមាបកគណនំ បហាយ សីឃគណនាយ គោបាលកគណនាយ គណេតព្វំ ។

*លំដាប់នោះ ព្រះយោគាវចរគប្បីលះបង់នូវការរាប់យឺតៗ គឺការរាប់ តាមវិធីអ្នកវាល់ស្រូវនោះចេញ ហើយមករាប់តាមវិធីរហ័សវិញ **គឺរាប់តាម វិធីអ្នកចិញ្ចឹមគោ** ។*

ឆេកោ ហិ គោបាលកោ សក្ខរាយោ ឧច្ឆង្គេន គហេត្វា រជ្ជុទណ្ឌហត្ថោ បាតោវ វជំ គន្ត្វា គាវោ បិដ្ឋិយំ បហរិត្វា បលិឃត្ថម្ភមត្ថកេ និសិន្នោ ទ្វារប្បត្តំ ទ្វារប្បត្តំយេវ គាវី "ឯកា ទ្វេ"តិ សក្ខរំ ខិបិត្វា គណេតិ ។

*មែនពិត អ្នកចិញ្ចឹមគោដែលឆ្លាតបានប្រើថ្មក់កន្សែងដែលមានដុំក្រួស ហើយមានខ្សែ និងឈើច្រត់ (ឬរំពាត់) ក្នុងដៃបានដើរទៅកាន់ក្រោលគោ តាំងតែពីព្រឹកព្រលឹម (ហើយបានបើកក្រោលគោ) ដេញគោច្រើនក្បាលទៅ ខាងក្រៅ ហើយក៏អង្គុយនៅលើក្បាលសសរ ដែចាប់ដុំក្រួសទុកជាតំណាងគោ តែមួយក្បាលៗ ដែលបានមកដល់មាត់ទ្វារក្រោល តែប៉ុណ្ណោះ រាប់ទៅរឿយៗ ថា "មួយ ពីរ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន ដប់" ដូច្នេះ ។*

តិយាមរត្តឹ សម្ពាធេ ឱកាសេ ទុក្ខំ វុត្ថគោគណោ និក្ខមន្តោ និក្ខមន្តោ អញ្ញមញ្ញំ ឧបនិឃំសន្តោ វេគេន វេគេន បុញ្ជបុញ្ជោ ហុត្វា និក្ខមតិ ។

*ហ្វូងគោ ដែលនៅជាមួយគ្នារហូតមកអស់ពេល ៣ យាមនៃរាត្រីមកហើយ ក៏លំបាកព្រោះជាទីដែលចង្អៀត កាលដែលចេញមកខាងក្រៅក៏ប្រជ្រៀតគ្នាចេញជាហ្វូងៗ ចេញយ៉ាងរហ័សរហួន ។*

**សោ វេគេន វេគេន "តីណិ ចត្តារិ បញ្ច ឆសា"តិ គណេតិយេវ, ឯវមិមស្សាបិ បុរិមនយេន គណយតោ អស្សាសបស្សាសា ធាតុជា ហុត្វា សីឃំ សីឃំ បុនប្បុនំ សញ្ចរន្តិ ។**

*អ្នកចិញ្ចឹមគោ ពេលនោះរមែងរាប់ទៅរឿយៗយ៉ាងរហ័សរហួនថា "មួយ, ពីរ, បី, បួន, ប្រាំ, ប្រាំមួយ, ប្រាំពីរ, ប្រាំបី, ប្រាំបួន, ដប់" ដូច្នេះ ទុំះឯងយ៉ាងណាមិញ, សូម្បីកាលព្រះយោគាវចររូបនេះ ក៏រាប់ទៅតាមន័យសេចក្ដីដូចខាងដើម ហើយខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ជាខ្យល់ធម្មជាតិដែលប្រាកដច្បាស់ ត្រាច់ចរទៅមកយ៉ាងរហ័សរហួន ទៅរឿយៗ បែបនេះ ។*

**តតោនេន "បុនប្បុនំ សញ្ចរន្តី"តិ ញត្វា អន្តោ ច ពហិ ច អគ្គហេត្វា ទ្វារប្បត្តំ ទ្វារប្បត្តំយេវ គហេត្វា "ឯកោ ទ្វេ តីណិ ចត្តារិ បញ្ច ។**

*បន្ទាប់អំពីនោះមក អ្នកចម្រើនធម៌បានជ្រាបថា "ខ្យល់ត្រាច់ចរទៅមករឿយៗ" (ត្រាច់ចរនៅទីនេះ គឺសតិតម្កល់នៅត្រង់ចុងច្រមុះ ហើយដឹងខ្យល់ទៅមកៗ) ដូច្នេះហើយ (ពេលនោះ) កុំចាប់យកខ្យល់ដង្ហើមដែលនៅខាងក្នុង (ដែលមានត្រង់បេះដូង និងផ្ចិត) និងកុំចាប់យកខាងក្រៅ (ដែលមានត្រង់ផ្ចិត និងបេះដូង)ឡើយ ប៉ុន្តែ គប្បីចាប់យកនូវខ្យល់ដង្ហើមនៅត្រង់ចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើ ដែលខ្យល់ដង្ហើមមកដល់ហើយៗ តែប៉ុណ្ណោះ ហើយក៏រាប់ទៅយ៉ាងរហ័សរហួនថា ៖*

*"១, ២, ៣, ៤, ៥ ។*

**ឯកោ ទ្វេ តីណិ ចត្តារិ បញ្ច ឆ**

*១, ២, ៣, ៤, ៥, ៦ ។*

**ឯកោ ទ្វេ តីណិ ចត្តារិ បញ្ច ឆ សត្ត។...បេ...។ អដ្ឋ, នវ, ទសា″តិ សីឃំ សីឃំ គណេតព្វមេវ។**

*១, ២, ៣, ៤, ៥, ៦, ៧ ។*

*១, ២, ៣, ៤, ៥, ៦, ៧, ៨ ។*

*១, ២, ៣, ៤, ៥, ៦, ៧, ៨, ៩ ។*

*១, ២, ៣, ៤, ៥, ៦, ៧, ៨, ៩, ១០″ ដូច្នេះ យ៉ាងនេះចុះ ។*

**គណនាបដិពទ្ធេ ហិ កម្មដ្ឋានេ គណនាពលេនេវ ចិត្តំ ឯកគ្គំ ហោតិ, អរិត្តុបត្ថម្ភនវសេន ចណ្ឌសោតេ នាវាដ្ឋបនមិវ ។**

*មែនពិត កម្មដ្ឋានដែលជាប់ទាក់ទងជាមួយការរាប់នេះ ដោយសារកម្លាំងរបស់ការរាប់នេះឯង ដែលធ្វើឱ្យចិត្ត មានអារម្មណ៍តែមួយ , ប្រៀបដូចជាការបញ្ឈប់នូវទូក ក្នុងក្រសែទឹកហូរ ដែលអាចឈប់បាន ដោយអំណាចការចាក់ទប់ទុករបស់ថ្នោល ដូច្នោះដែរ ។*

**តស្សេវំ សីឃំ សីឃំ គណយតោ កម្មដ្ឋានំ និរន្តរំ បវត្តំ វិយ ហុត្វា ឧបដ្ឋាតិ។**

*កាលព្រះយោគាវចររូបនោះ រាប់ទៅដោយរហ័សរហួនយ៉ាងនេះ កម្មដ្ឋាន រមែងប្រាកដច្បាស់ ហាក់បីដូចជាប្រព្រឹត្តទៅមិនមានចន្លោះ ដូច្នោះ ។*

**អថ "និរន្តរំ បវត្តតី″តិ ញត្វា អន្តោ ច ពហិ ច វាតំ អបរិគ្គហេត្វា បុរិមនយេនេវ វេគេន វេគេន គណេតព្វំ ។**

*លំដាប់នោះ ព្រះយោគាវចរក៏បានជ្រាបដឹងច្បាស់ថា "វាប្រព្រឹត្តិទៅមិនដាច់ចន្លោះយ៉ាងនេះហើយ″ ពេលនោះកុំទៅកំណត់ចាប់យកខ្យល់ដង្ហើមដែលនៅខាងក្នុង (ដែលមានត្រង់បេះដូង និងផ្ចិត) និងខាងក្រៅ (ដែលមានត្រង់ផ្ចិត និងបេះដូង)ឡើយ គប្បីរាប់ដោយរហ័សរហួន ទៅតាមន័យសេចក្ដីដូចបាន*

*ពោលមកហើយពីខាងដើមនោះ តែប៉ុណ្ណោះ ។*

**អន្តោ បវិសនវាតេន ហិ សទ្ធឹ ចិត្តំ បវេសយតោ អព្ភន្តរំ វាតព្ភាហតំ មេទបូរិតំ វិយ ហោតិ ។**

*ព្រោះថា កាលអ្នកបដិបត្តិបង្អោនចិត្តទៅព្រមជាមួយខ្យល់ដង្ហើមដែលចូលទៅខាងក្នុង គឺខាងក្នុងរាងកាយ (ដែលមានត្រង់បេះដូង និងផ្ចិត) វាហាក់បីដូចជាត្រូវខ្យល់កំពុងវាយត្រូវ ឬដូចជាពេញទៅដោយខ្លាញ់ខាប់ (នៅខាងក្នុងពោះ ធ្វើឱ្យអន្តរាយដល់សមាធិ) ។*

**ពហិ និក្ខមនវាតេន សទ្ធឹ ចិត្តំ នីហរតោ ពហិទ្ធា បុថុត្តារម្មណោ ចិត្តំ វិក្ខិបតិ ។**

*ហើយកាលបើនាំចិត្តទៅខាងក្រៅ ព្រមជាមួយខ្យល់ដង្ហើមដែលចេញទៅខាងក្រៅ (ដែលមានត្រង់ផ្ចិត និងបេះដូង) ចិត្ត រមែងរាយមាយទៅក្នុងអារម្មណ៍ដែលមានសភាវៈច្រើនប្រការនៅខាងក្រៅ (ធ្វើឱ្យអន្តរាយដល់សមាធិ)។*

**ផុដ្ឋផុដ្ឋោកាសេ បន សតឹ ឋបេត្វា ភាវេន្តស្សេវ ភាវនា សម្បជ្ជតិ ។**

*ប៉ុន្តែថា កាលតម្កល់សតិទុកនៅត្រង់ទីកន្លែងដែលខ្យល់ដង្ហើមពាល់ត្រូវហើយៗ (នៅត្រង់ចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើ) ច្រើនដងៗ ទុំះឯង រីការចម្រើនភាវនា រមែងបានសម្រេច ។*

**តេន វុត្តំ "អន្តោ ច ពហិ ច វាតំ អបរិគ្គហេត្វា បុរិមនយេនេវ វេគេន វេគេន គណេតព្វ"ន្តិ ។**

*ព្រោះហេតុនោះ ខ្ញុំម្ចាស់ទើបពោលថា "កុំទៅកំណត់កាន់យកខ្យល់ដែលទៅខាងក្នុង និងទៅខាងក្រៅ គប្បីរាប់កាន់យកទៅដោយរហ័សរហួន តាមន័យសេចក្តីដែលបានពោលហើយនៅខាងដើមនោះ តែប៉ុណ្ណោះ" ។*

**កីវចិរំ បនេតំ គណេតព្វន្តិ? យាវ វិនា គណនាយ អស្សាសប-**

ស្សាសារម្មណោ សតិ សណ្ឋិដ្ឋតិ ។

*សួរថា តើត្រូវការរាប់ខ្យល់ដង្ហើមនេះ យូរដល់ពេលណា ?*

*ឆ្លើយថា គឺយូររហូតដល់សតិអាចតាំងមាំ នៅជាមួយអារម្មណ៍នោះគឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញបានល្អ (ដោយមិនមានភាពរាយមាយ ឬក៏នៅមានតិចបំផុត) ទើបវៀរចាកការរាប់បាន ។*

ពហិវិសដវិតក្កវិច្ឆេទំ កត្វា អស្សាសបស្សាសារម្មណេ សតិសណ្ឋាបនត្ថំយេវ ហិ គណនាតិ ។

*មែនពិត ការរាប់នេះវាជាប្រយោជន៍ធ្វើការកាត់នូវវិតក្កៈ ដែលរាយមាយទៅក្នុងរឿងខាងក្រៅ ហើយតាំងសតិមាំនៅក្នុងអារម្មណ៍ គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ តែប៉ុណ្ណោះ ដូច្នេះឯង ។*

## វិធីមនសិការ ៨ យ៉ាង

### (មហាដីកាវិសុទ្ធិមគ្គ)

[២២៣] "**អនុពន្ធនា**"តិ អស្សាសបស្សាសានំ អនុគមនវសេន សតិយា និរន្តរំ អនុបវត្តនា ។

*បទថា "**អនុពន្ធនា** ប្រែថា សតិនៅជាមួយខ្យល់ដង្ហើមចូល ចេញ" គឺញុំាងសតិឱ្យប្រព្រឹត្តទៅរឿយៗ មិនឱ្យដាច់ចន្លោះ ដោយអំណាចសតិនៅជាមួយខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ។*

"**ផុសនា**"តិ អស្សាសបស្សាសេ គណេន្តស្ស គណនំ បដិសំហរិត្វា តេ សតិយា អនុពន្ធន្តស្ស យថា អប្បនា ហោតិ, តថា ចិត្តំ ឋបេន្តស្ស ច ជាសិកគ្គាទិដ្ឋានស្ស ផេសំ ផុសនា ។

*បទថា "**ផុសនា**" បានដល់ **ទីកន្លែងដែលពាល់ត្រូវនូវខ្យល់ដង្ហើមទាំងនោះ** ជាមួយបរិវេណត្រង់ចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើរបស់*

*ព្រះយោគាវចរ ដែលកំពុងកំណត់រាប់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដល់ពេលឈប់រាប់ ក៏ញ៉ាំងសតិកំណត់ដឹងនូវខ្យល់ទាំងនោះ (ត្រង់ចុងច្រមុះ ឬ ផ្ទៃបបូរមាត់ខាងលើ) និងតាំងចិត្តទុកក្នុងពេលដែលអប្បនាដែលកើតឡើង (នៅពេលបន្ទាប់ទៀត) ។*

**យស្មា បន គណនាវសេន វិយ ផុសនាវសេន វិសុំ មនសិការោ នត្ថិ, ផុដ្ឋផុដ្ឋដ្ឋានេយេវ គណនាតិ កាតព្វន្តិ ទស្សេតុំ ឥធ ផុសនាគហណន្តិ ទីបេន្តោ "ផុសនាតិ ផុដ្ឋដ្ឋាន"ន្តិ អាហ ។**

*ព្រោះហេតុថា ការមនសិការដែលជាប់ទាក់ទងជាមួយទីកន្លែង ដែលខ្យល់ដង្ហើមពាល់ត្រូវ វាជាផ្នែកមួយផ្សេងគ្នាក៏ពិត ប៉ុន្តែវា មិនមានន័យផ្សេងគ្នាជាមួយនិងការមនសិការដែលជាប់ទាក់ទងនិងការកំណត់រាប់នូវខ្យល់ ជាដើមនោះឡើយ គឺមានន័យសេចក្ដីដូចគ្នា, លោកអាចារ្យ កាលនឹងសម្ដែងថា ទីកន្លែងដែលខ្យល់ដង្ហើមពាល់ត្រូវហើយៗ វាក៏ជាទីកន្លែងដែលត្រូវកំណត់រាប់នូវខ្យល់ផងដែរ ទើបលោកពោលថា "**ផុសនា ទីកន្លែងដែលពាល់ត្រូវនូវខ្យល់ដង្ហើមចូល ចេញ**" ដូច្នេះ កាលសម្ដែងថា គប្បីធ្វើការកំណត់រាប់នូវខ្យល់ដង្ហើមជាដើម នៅត្រង់កន្លែងដែលខ្យល់ពាល់ត្រូវហើយៗ នុ៎ះឯង ដូច្នេះ ។*

**"ឋបនា"តិ សមាធានំ ។**

*បទថា "**ឋបនា**" បានដល់ ការតាំងមាំរបស់សមាធិហើយដោយល្អ ។*

**តំ ហិ សម្មទេវ អារម្មណេ ចិត្តស្ស អាធានំ ឋបនំ ហោតិ ។**

*មែនពិត ការតាំងមាំរបស់សមាធិដោយប្រពៃនោះ វាជាការតាំងមាំដោយល្អ គឺការតាំងចិត្តទុកក្នុងអារម្មណ៍កម្មដ្ឋាន ដោយល្អនុ៎ះឯង។*

**តថា ហិ សមាធិ "ចិត្តស្ស ឋិតិ សណ្ឋិតី"តិ[៣៧]និទ្ទិដ្ឋោ ។**

*ពិតហើយ ព្រះអង្គទ្រង់សម្ដែងអធិប្បាយពីសមាធិទុកថា "ការតាំងនៅ*

៣៧ (ធ. ស. ១១.១៥) ។

*បាន ការតម្កល់នៅបាន ដោយល្អនៃចិត្ត” ដូច្នេះ ។*

**សមាធិប្បធានា បន អប្បនាតិ អាហ “បឋនាតិ អប្បនា”តិ ។**

*ចំណែកឯ* **អប្បនា** *ដែលមានសមាធិជាប្រធាន ព្រោះហេតុនោះ លោកទើបពោលថា “* **ឋបនា** *បានដល់* **អប្បនា**” *នុ៎ះឯង ដូច្នេះ ។*

**អនិច្ចតាទីនំ សល្លក្ខណតោ សល្លក្ខណា វិបស្សនា ។**

**វិបស្សនា** *ឈ្មោះថា* **សល្លក្ខណា** *ព្រោះជាការកំណត់ដោយល្អនូវសភាវៈជារបស់មិនទៀង ជាដើម ។*

**បវត្តតោ, និមិត្តតោ ច វិនិវដ្ដនតោ វិវដ្ដនា នាម មគ្គោ ។**

**មគ្គ** *ឈ្មោះថា* **វិវដ្ដនា** *ព្រោះជាការវិលត្រឡប់ចាក* **បវត្ត** *(គឺតណ្ហាដែលធ្វើឱ្យប្រព្រឹត្តទៅ) និងចាកអំពីនិមិត្ត (គឺសង្ខារក្នុងកាលទាំង ៣) ។*

**សកលសំកិលេសបដិប្បស្សទ្ធិភាវតោ សព្វសោ សុទ្ធីតិ ចារិសុទ្ធិ ផលំ ។**

**ផល** *ឈ្មោះថា* **ចារិសុទ្ធិ** *ព្រោះអត្ថថា ជាការហ្មត់ចត់តាមប្រការទាំងពួង ជាសភាវៈដែលស្ងប់រម្ងាប់សង្កិលេស ដែលជាគ្រឿងសៅហ្មងដល់ចិត្ត ។*

“**តេស**”ន្តិ វិវដ្ដនាចារិសុទ្ធីនំ ។

*បទថា “***តេសំ***” បានដល់ វិវដ្ដនា និង ចារិសុទ្ធិ ។*

“**បដិបស្សនា**”តិ បដិ បដិ ឧស្សនំ បេក្ខនំ។

*បទថា “***បដិបស្សនា***” បានដល់ ការត្រឡប់មកមើល គឺកំណត់ជាចំណែកៗ ។*

តេនាហ “**បច្ចវេក្ខណា**”តិ ។

*ព្រោះហេតុនោះ លោកទើបពោលថា “បានដល់* **បច្ចវេក្ខណា**” *ដូច្នេះ ។*

"**ខណ្ឌ**"ន្តិ ឯកំ តីណិ បញ្ចាតិ ឯវំ គណនាយ ខណ្ឌនំ ។

*ពាក្យថា "**ខណ្ឌ** ប្រែថា **ការខាតចន្លោះ**" បានដល់ ជាការខាតលំដាប់នៃការកំណត់រាប់នូវខ្យល់ដង្ហើម ដែលមានបែបនេះថា ១ , ៣ , ៥ ជាដើម យ៉ាងនេះ ។*

"**ឱកាសេ**"តិ គណនវិធី សន្ធាយាហ ។

*ពាក្យថា "**ក្នុងឱកាស**" ដែលចង្អៀត លោកពោលសំដៅដល់វិធីការកំណត់រាប់នូវខ្យល់ដង្ហើមនោះ ។*

**គណននិស្សិតោវ** ន កម្មដ្ឋាននិស្សិតោ ។

*ឈ្មោះថា **រមែងអាស្រ័យនៃការកំណត់រាប់ប៉ុណ្ណោះ** គឺមិនអាស្រ័យនៃកម្មដ្ឋាន ។*

"**សិខាប្បត្តំ នុ ខោ**"តិ ឥទំ ចិរតរំ គណនាយ មនសិ ការោន្តស្ស-វសេន វុត្តំ ។

*ពាក្យថា "**នឹងដល់ទីបំផុតឬទេហ្ន៎**" នេះ លោកពោលទុក ដោយជាប់ទាក់ទងជាមួយព្រះយោគាវចរ ដែលបានមនសិការ កំណត់ការរាប់ខ្យល់ដង្ហើមទៅបានយូរៗ ។*

សោ ហិ តថា លទ្ធំ អវិក្ខេបមត្តំ និស្សាយ ឯវំ មញ្ញេយ្យ ។

*ពិតហើយ ព្រះយោគាវចររូបនោះ នឹងគប្បីសម្គាល់យ៉ាងនេះបាន ព្រោះអាស្រ័យត្រឹមតែការមិនរាយមាយ ដែលខ្លួនបានហើយ យ៉ាងនោះ ។*

"**អស្សាសបស្សាសេសុ យោ ឧបដ្ឋាតិ, តំ គហេត្វា**"តិ ឥទំ អស្សា-សបស្សាសេសុ យស្ស ឯកោវ បឋមំ ឧបដ្ឋាតិ, តំ សន្ធាយ វុត្តំ, យស្ស បន ឧភោបិ ឧបដ្ឋហន្តិ, តេន ឧភយម្បិ គហេត្វា គណេតព្វំ ។

*ពាក្យថា "**ក្នុងបណ្តាខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ខ្យល់ប្រភេទ***

*ណាមួយដែលបានប្រាកដច្បាស់, គប្បីចាប់យកនូវខ្យល់ប្រភេទនោះចុះ" នេះ លោកពោលសំដៅយក ព្រះយោគាវចរអ្នកមានខ្យល់ដង្ហើមចូល ឬខ្យល់ដង្ហើមចេញ ណាមួយប៉ុណ្ណោះ ដែលបានប្រាកដច្បាស់មុនគេ (ក្នុងបណ្តាខ្យល់ដង្ហើមទាំង ២ នេះ) ។*

"**យោ ឧបដ្ឋាតី**"តិ ឥមិនា ច ទ្វីសុ ឋានេសុ ផុសនវសេន យោ វាត-ជាតោ ឧបដ្ឋាតិ, សោ គហេតព្វោតិ អយម្បិ អត្ថោ ទីបិតោតិ ទដ្ឋព្វំ ។

*ម្យ៉ាងទៀត ពាក្យថា "**ខ្យល់ប្រភេទណាមួយបានប្រាកដច្បាស់**" នេះ គប្បីយល់ថា លោកបានពោលសម្តែងនូវសេចក្តីនេះថា ក្នុងបណ្តាខ្យល់ដែលមាននៅត្រង់កន្ទែងចុងច្រមុះទាំង២ ឬត្រង់ផ្ទៃបបូរមាត់ខាងលើ ដែលមានខ្យល់ដង្ហើមចូល ឬចេញ ប្រភេទណាមួយដែលបានប្រាកដច្បាស់ជាងគេ, គប្បីកំណត់កាន់យកនូវខ្យល់ដង្ហើមប្រភេទនោះចុះ ដូច្នេះ ។*

"**បវត្តមានំ បវត្តមាន**"ន្តិ អាមេឌិតវចនេន និរន្តរំ អស្សាសបស្សា-សានំ ឧបលក្ខណំ ទស្សេតិ ។

*ពាក្យបានពោលត្រួតគ្នាថា "**កំពុងប្រព្រឹត្តទៅ កំពុងប្រព្រឹត្តទៅ**" លោកសម្តែងដល់ការចូលទៅកំណត់ការរាប់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដោយមិនដាច់ចន្លោះ មិនដាច់លំដាប់ ។*

"**ឯវ**"ន្តិ វុត្តប្បការេន ឧបលក្ខេត្វា វាតិ អត្ថោ ។

*ពាក្យថា (កាលព្រះយោគាវចរនោះកំណត់រាប់ទៅ) "**យ៉ាងនេះ**" មានន័យសេចក្តីថា កាលចូលទៅកំណត់ការរាប់ ទៅតាមប្រការដូចដែលបានពោលមកហើយ ។*

**ចាកដា ហោន្តិ** គណនាវសេន ពហិទ្ធា វិក្ខេចាភាវតោ ។

*ឈ្មោះថា **ជាធម្មជាតិប្រាកដច្បាស់** ព្រោះមិនមានការរាយមាយទៅខាងក្រៅ ដោយអំណាចនៃការកំណត់រាប់នូវខ្យល់ដង្ហើម ។*

## ការរាប់រហ័ស

បលិយស្ស បរិវត្តនំ, តំ យត្ថ និក្ខិបន្តិ, សោ **បលិយត្ថម្ភោ ។**

*សសរដែលមានគេដាក់ជុំស្មៀត ឈ្មោះថា **សសរមានជុំស្មៀត** ។*

"**តិយាមរត្តឹ**"ន្តិ អច្ចន្តសំយោគេ ឧបយោគវចនំ ។

*បទថា "**តិយាមរត្តឹ**" ជាទុតិយាវិភត្តិ ចុះក្នុងអត្ថអច្ចន្តសំយោគ ប្រែថា រហូតអស់យប់ទាំង ៣ យាមនុ៎ះឯង ។*

"**បុរិមនយេនា**"តិ សីឃគណនាយ, គោបាលកគណនាយាតិ អត្ថោ ។

*ពាក្យថា "**តាមន័យដូចខាងដើម**" គឺតាមការកំណត់រាប់រហ័ស, មានន័យថា កំណត់រាប់តាមវិធីអ្នកចិញ្ចឹមគោ ។*

"**ឯកោ ទ្វេ តីណិ ចត្តារិ បញ្ចា**"តិ គណនាវិធិទស្សនំ ។

*ពាក្យថា "**១ , ២ , ៣ , ៤ , ៥**" ជាការសម្ដែងនូវវិធីកំណត់រាប់ ។*

តស្មា "**អដ្ឋា**"តិអាទីសុបិ ឯកតោ បដ្ឋាយេវ បច្ចេកំ អដ្ឋាទីនិ ចាបេតព្វានិ ។

*ព្រោះហេតុនោះ សូម្បីក្នុងពាក្យថា "**៨**" ជាដើម ក៏ត្រូវតែផ្ដើមរាប់តាំងតែទី ១ នុ៎ះឯង ទៅរហូតដល់ ៨ នេះជាចំណែកនៃវិធីរាប់ ។*

**សីឃំ សីឃំ គណេតព្វមេវ** ។

***គប្បីកំណត់រាប់ទៅរហ័សៗ នុ៎ះឯង*** ។

កស្មាតិ តត្ថ ការណំ, និទស្សនញ្ច ទស្សេតិ "**គណនបដិ-ពទ្ធេហី**"តិអាទិនា។

*ព្រោះហេតុអ្វី ? លោកអាចារ្យបានសម្ដែងនូវហេតុ និងរឿងនិទស្សនៈ*

*ដែលជាឧទាហរណ៍ក្នុងការកំណត់រាប់រហ័សនោះ ដោយពាក្យថា "**មែនពិត ក្នុងកម្មដ្ឋានដែលជាប់ទាក់ទងទៅនឹងការកំណត់រាប់**" ជាដើម ។*

តត្ថ អរីយតិ តេន ជាវាតិ អរិត្តំ, ចាជននណ្ណោ ។

*ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា **អរិត្ត** មានវចនត្ថ ថា ទូករមែងរសាត់ទៅបានដោយសារឈើនោះ ហេតុនោះឈើនោះ ឈ្មោះថា **អរិត្ត** បានដល់ ឈើដែលធ្វើឱ្យរសាត់ទៅបាន (ឈើថ្នោលដោលទូក) ។*

អរិត្តេន ឧបត្ថម្ភនំ **អរិត្តុបត្ថម្ភនំ**, តស្ស វសេន ។

*ការច្រត់ទុកដោយថ្នោល ឈ្មោះថា **អរិត្តុបត្ថម្ភនំ**, បានដល់ដោយអំណាចការច្រត់ទប់ទុកដោយឈើថ្នោលនោះ ។*

និប្បរិយាយតោ និរន្តរប្បវត្តិ នាម បបជាយមេវាតិ អាហ "និរន្តរំ បវត្តំ វិយា"តិ ។

*ឈ្មោះថា ការប្រព្រឹត្តទៅមិនដាច់ចន្លោះ រមែងមាន ក្នុង **បបជា** នុ៎ះឯងដោយ **និប្បរិយាយ** (សេចក្ដីអធិប្បាយដោយន័យត្រង់) ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា "**ដូចជា ប្រព្រឹត្តទៅមិនដាច់ចន្លោះ ដូច្នោះ**" ។*

អន្តោ បវិសន្តំ វាតំ មនសិ ករោន្តោ អន្តោ ចិត្តំ បវេសេតិ នាម ។

*កាលធ្វើទុកក្នុងចិត្តត្រង់ខ្យល់ដែលចូលទៅខាងក្នុង ឈ្មោះថា បានបញ្ចូនចិត្តចូលទៅខាងក្នុងរាងកាយ (នេះជាការហាមមិនគួរចម្រើនទេ) ។*

ពហិ ចិត្តនីហរណេបិ ឯសេវ នយោ ។

*សូម្បីក្នុងការនាំចិត្តចេញទៅខាងក្រៅ ក៏មានន័យដូចគ្នា នោះឯង ។*

"**វាតព្ភាហត**"ន្តិ អព្ភន្តរគតំ វាតំ ពហុលំ មនសិ ករោន្តស្ស វាតេន តំ ឋានំ អព្ភាហតំ វិយ, មេទេន បូរិតំ វិយ ច ហោតិ, តថា ឧបដ្ឋាតិ ។

*ពាក្យថា "**ហាក់បីដូចជាត្រូវខ្យល់កំពុងវាយត្រូវ**" មានន័យថា កាលធ្វើទុក*

ក្នុងចិត្តត្រង់ខ្យល់ដែលនៅខាងក្នុងច្រើនៗផង នៅពេលនោះហាក់បីដូចជា ត្រូវបានខ្យល់កំពុងវាយ, និងហាក់បីដូចជា ពោរពេញទៅដោយខ្លាញ់ខាប់, កម្មដ្ឋានរមែងប្រាកដយ៉ាងនេះ ។

**ពហិទ្ធា ចិត្តំ** ... ជីហរតោ ផុដ្ឋោកាសំ មុញ្ចិត្វា, តថា បង ជីហរតោ វាតស្ស គតិសមន្នេសនមុខេន នានារម្មណេសុ ចិត្តំ វិធាវតីតិ អាហ "**ពហិទ្ធា រម្មណេ ចិត្តំ វិក្ខិបតី**"តិ ។

*ឈ្មោះថា "**កាលនាំចិត្តចេញទៅ**" គឺមានន័យថា កាលព្រះយោគាវចរបានរំលងនូវកន្លែងដែលខ្យល់ពាល់ត្រូវ (គឺអត់បានដឹង) ហើយបាននាំចិត្តចេញទៅខាងក្រៅ យ៉ាងនោះ ចិត្ត រមែងត្រាច់ទៅចាប់យកនូវអារម្មណ៍ផ្សេងៗ ដោយខ្យល់ដង្ហើមនោះជាច្រកផ្លូវ ព្រោះហេតុនោះ ទើបលោកពោលថា "**ចិត្តរមែងរាយមាយ ទៅក្នុងអារម្មណ៍ ដែលមានសភាវៈច្រើនប្រការ** ក្នុងចំណែកខាងក្រៅ" ដូច្នេះ ។*

"**ឯត**"ន្តិ ឯតំ អស្សាសបស្សាសជាតំ ។

*ពាក្យថា (និងត្រូវរាប់) ខ្យល់**នេះ** គឺត្រូវចាំបាច់រាប់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលមានមកហើយនេះ ។*

## ការរាប់ដោយមានអនុពន្ធនា

### (វិសុទ្ធិមគ្គ)

[២២៤] **ឯវំ គណនាយ មនសិ ករោន្តស្ស** ... **អនុពន្ធនាយ មនសិកាតព្វំ** ។

*ព្រះយោគាវចរ កាលធ្វើទុកក្នុងចិត្ត ដោយការរាប់យ៉ាងនេះហើយ តទៅទៀតគប្បីធ្វើទុកក្នុងចិត្ត **ដោយសតិនៅជាមួយខ្យល់ដង្ហើម** ផងចុះ ។*

**អនុពន្ធនា នាម គណនំ បដិសំហរិត្វា សតិយា និរន្តរំ អស្សាសបស្សាសានំ អនុគមនំ ។**

*កាលដល់ពេលឈប់រាប់ហើយ ហើយក៏ប្រើសតិ (នៅត្រង់ចុងច្រមុះ) កំណត់ដឹងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដោយមិន (ប្រើការកំណត់រាប់ទៀត) ហើយនៅរក្សាសតិមិនឱ្យដាច់ចន្លោះ ក្នុងការកំណត់ដឹងនូវខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញនោះៗ នេះឈ្មោះថា* **អនុពន្ធនា** ។

**តញ្ច ខោ ន អាទិមជ្ឈបរិយោសានានុគមនវសេន ។**

*ពាក្យថា សតិនៅជាមួយខ្យល់ នុ៎ះឯងមិនមែនជាការតាមដោយអំណាចការតាមខាងដើមខ្យល់(ចុងច្រមុះ) កណ្តាលខ្យល់(បេះដូង) និងទីបំផុតខ្យល់(ត្រង់ផ្ចិត) ដែលលោកបានហាមហើយនោះទេ ។*

**ពហិនិក្ខមនវាតស្ស ហិ នាភិ អាទិ, ហទយំ មជ្ឈំ, នាសិកគ្គំ បរិយោសានំ ។**

*មែនពិត សម្រាប់ខ្យល់ដែលចេញទៅខាងក្រៅ មានផ្ចិតជាខាងដើមខ្យល់, មានបេះដូងជាកណ្តាលខ្យល់, និងមានចុងច្រមុះជាទីបំផុតរបស់ខ្យល់ ។*

**អព្ភន្តរំ បវិសនវាតស្ស នាសិកគ្គំ អាទិ, ហទយំ មជ្ឈំ, នាភិ បរិយោសានំ ។**

*ហើយសម្រាប់ខ្យល់ដែលចូលទៅខាងក្នុងវិញ មានចុងច្រមុះជាខាងដើមខ្យល់, មានបេះដូងជាកណ្តាលខ្យល់, និងមានផ្ចិតជាទីបំផុតរបស់ខ្យល់(ទាំងអស់នេះដែលលោកបានហាម កុំបដិបត្តិបែបនេះឡើយ) ។*

**តញ្ចស្ស អនុគច្ឆតោ វិក្ខេបគតំ ចិត្តំ សារទ្ធាយ ចេវ ហោតិ ឥញ្ជនាយ ច ។**

*កាលព្រះយោគាវចររូបនោះ បានបង្អោនសតិទៅតាមខ្យល់ ដែលមាន*

*ខាងដើមខ្យល់ ជាដើមនោះ ចិត្តរមែងរាយមាយផង រមែងមានភាពរសាប់រសល់ និងមានការញាប់ញ័រផង ។*

យថាហ –

*សមដូចថេរៈដីការបស់ព្រះសារីបុត្តថេរបានពោលទុកមកថាៈ*

**"អស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ អជ្ឈត្តំ វិក្ខេបគតេន ចិត្តេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច ។**

*"កាលយោគីភិក្ខុ ផ្ទង់សតិស្មារតី ទៅតាមខាងដើមខ្យល់ កណ្ដាលខ្យល់ និងទីបំផុតខ្យល់ នៃខ្យល់អស្សាស (ខ្យល់ដង្ហើមចូល) ចិត្តក៏បានរាយមាយទៅខាងក្នុង ធ្វើឱ្យទាំងកាយ ទាំងចិត្ត ជាធម្មជាតិដែលមានសភាពរសាប់រសល់ផង ញាប់ញ័រផង និងមានភាពស្ទុះស្ទាផង ។*

**បស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ ពហិទ្ធា វិក្ខេបគតេន ចិត្តេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ចា"តិ**[៣៨]**។**

*កាលយោគីភិក្ខុ ផ្ទង់សតិស្មារតី ទៅតាមខាងដើមខ្យល់ កណ្ដាលខ្យល់ និងទីបំផុតខ្យល់ នៃខ្យល់បស្សាសៈ (ខ្យល់ដង្ហើមចេញ) ចិត្តក៏បានរាយមាយទៅខាងក្រៅ ធ្វើឱ្យទាំងកាយ ទាំងចិត្ត ជាធម្មជាតិដែលមានសភាពរសាប់រសល់ផង ញាប់ញ័រផង និងមានភាពស្ទុះស្ទាផង" ដូច្នេះ ។*

**តស្មា អនុពន្ធនាយ មនសិការោន្តេន អាទិមជ្ឈបរិយោសានវសេន ន មនសិកាតព្វំ ។**

*ព្រោះហេតុនោះ ព្រះយោគាវចរភិក្ខុកាលនឹងមនសិការ (ការធ្វើទុកក្នុងចិត្ត) ដោយ* **អនុពន្ធនា** *គឺសតិនៅជាមួយខ្យល់ដង្ហើម មិនគួរមនសិការដែល*

*៣៨ (បដិ. ម. ១.១៥៧) ។*

*ជាប់ទាក់ទងជាមួយនឹងខាងដើមខ្យល់(ចុងច្រមុះ), កណ្តាលខ្យល់(បេះដូង), និងទីបំផុតខ្យល់(ត្រង់ផ្ចិត) នោះទេ ។*

**អបិច ខោ ផុសនាវសេន ច ឋបនាវសេន ច មនសិកាតព្វំ ។**

*ក៏ប៉ុន្តែ គប្បីមនសិការ (ការធ្វើទុកក្នុងចិត្ត) ដែលជាប់ទាក់ទងជាមួយនឹង* **ផុសនា** *(កន្លែងដែលពាល់ត្រូវនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ) និងជាមួយ* **ឋបនា** *(គឺភាពតាំងមាំរបស់សមាធិ) នេះឯង ។*

**គណនានុពន្ធនាវសេន វិយ ហិ ផុសនាឋបនាវសេន វិសុំ មនសិការោ នត្ថិ ។**

*មែនពិត វិធីមនសិការដែលជាប់ទាក់ទងជាមួយ* **ផុសនា** *និង* **ឋបនា** *ជាប្រភេទតែមួយមិនផ្សេងគ្នាទេ ដូចគ្នានឹងវិធីមនសិការ ដែលជាប់ទាក់ទងជាមួយនឹងវិធី* **គណនា** *ឬ* **អនុពន្ធនា** *ដែរ ។*

**ផុដ្ឋផុដ្ឋដ្ឋានេយេវ បន គណេន្តោ គណនាយ ច ផុសនាយ ច មនសិករោតិ ។**

*ព្រះយោគាវចរ កាលកំណត់រាប់នូវខ្យល់ដង្ហើម នៅត្រង់កន្លែងដែលខ្យល់ដង្ហើមពាល់ត្រូវហើយៗ នោះប៉ុណ្ណោះ នេះឈ្មោះថា មនសិការដែលមាន* **គណនា** *ផង និងមាន* **ផុសនា** *ផង ។*

**តត្ថេវ គណនំ បដិសំហរិត្វា តេ សតិយា អនុពន្ធន្តោ, អប្បនាវសេន ច ចិត្តំ ឋបេន្តោ អនុពន្ធនាយ ច ផុសនាយ ច ឋបនាយ ច មនសិករោតីតិ វុច្ចតិ ។**

*កាលឈប់រាប់ហើយ (គឺសតិបានតាំងមាំល្អ មិនមានភាពរាយមាយ) ក៏ប្រើសតិនៅជាមួយខ្យល់ដង្ហើមទាំងនោះ (គឺសតិដឹងនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ) នៅត្រង់កន្លែងដែលខ្យល់ពាល់ត្រូវហើយៗ ប៉ុណ្ណោះនុ៎ះឯង, និងតម្កល់ចិត្តទុក ដោយអំណាចនៃ* **អប្បនា** *នេះឈ្មោះថា មនសិការដែលមាន*

*អនុពន្ធនាផង មាន ផុសនាផង និងមាន ឋបនាផង ។*

**ស្វាយមត្ថោ អដ្ឋកថាសុ វុត្តបង្គុឡោវារិកូបមាហិ បដិសម្ភិ-ទាយំ វុត្តកកចូបមាយ ច វេទិតព្វោ ។**

*សេចក្ដីអធិប្បាយនេះ បណ្ឌិតគប្បីជ្រាបទៅតាមរឿង ការឧបមា ជាមួយ មនុស្សខ្វិន និងមនុស្សអ្នកយាមទ្វារព្រះនគរ ដែលបានពោលទុកក្នុង**អដ្ឋកថាទាំងឡាយ** និងតាមរឿងការឧបមា ដោយរណារដែអារឈើ ដែលព្រះសារីបុត្ត-ថេរបានសម្ដែងទុកក្នុង**គម្ពីរបដិសម្ភិទាមគ្គ** (បិដក ៧០) ផងចុះ ។*

## អធិប្បាយពាក្យ អនុពន្ធនា

### (មហាដីកាវិសុទ្ធិមគ្គ)

[២២៤] "**អនុគមន**"ន្តិ បវត្តបវត្តានំ អស្សាសបស្សាសានំ អារម្មណ-ករណវសេន សតិយា អនុ អនុ បវត្តនំ អនុគច្ឆនំ ។

*ពាក្យថា "**សតិនៅជាមួយខ្យល់ដង្ហើមចូល ចេញ**" មានន័យថា ការចម្រើនឱ្យប្រព្រឹត្តទៅរឿយៗ ដោយមានសតិ ដែលដឹងនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ (នៅត្រង់ចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើ ដោយមិនឱ្យដាច់ចន្លោះក្នុងការដឹង) ដែលប្រព្រឹត្តទៅហើយៗ ឱ្យមកជាអារម្មណ៍ នេះឈ្មោះថា សតិនៅជាមួយខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ។*

តេនេវាហ "**តញ្ច ខោ ន អាទិមជ្ឈបរិយោសានានុគមនវ-សេនា**"តិ។

*ព្រោះហេតុនុ៎ះឯង លោកទើបពោលថា "**សតិនៅជាមួយខ្យល់ដង្ហើមនោះនុ៎ះឯង មិនមែនដោយអំណាចទៅតាមដឹង ខាងដើមខ្យល់ ខាងកណ្ដាលខ្យល់ និងទីបំផុតនៃខ្យល់ ដែលលោកបានហាមទុកនោះទេ**"*

**ជាតិ អាទិ** តត្ថ បឋមំ ឧប្បជ្ជនតោ ។

*សម្រាប់ខ្យល់ ដែលចេញទៅខាងក្រៅ ឈ្មោះថា* **មានផ្ចិត ជាខាងដើមរបស់ខ្យល់** *ព្រោះបានកើតឡើងជាលើកដំបូងនៅត្រង់ផ្ចិតនោះ ។*

**បឋមុប្បត្តិវសេន ហិ ឥធ អាទិចិន្តា, ន ឧប្បត្តិមត្តវសេន ។**

*ដែលឈ្មោះថា ខាងដើមខ្យល់ក្នុងទីនេះ ជាការតាំងឈ្មោះ ព្រោះវាបានកើតឡើងមុនដំបូងគេ, មិនមែនគ្រាន់តែការកើតឡើងតែប៉ុណ្ណោះទេ ។*

**តថា ហិ តេ នាភិតោ បដ្ឋាយ យាវ នាសិកគ្គា សព្វត្ថ ឧប្បជ្ជន្តេវ ។**

*មែនពិត ខ្យល់ដែលចេញទៅខាងក្រៅប៉ុណ្ណោះ រមែងកើតឡើង ក្នុងទីទាំងពួង គឺបានផ្ដើមតាំងតែពីផ្ចិត រហូតទៅដល់ចុងច្រមុះ នុ៎ះឯង ។*

**យត្ថ យត្ថ ច ឧប្បជ្ជន្តិ, តត្ថ តត្ថេវ ភិជ្ជន្តិ ធម្មានំ គមនាភាវតោ ។**

*និងកើតឡើងក្នុងទីណាៗ, ក៏រមែងរលត់បាត់ទៅវិញក្នុងទីនោះៗ នុ៎ះឯង ព្រោះធម៌ទាំងឡាយមិនមានការទៅ (ពីទីនេះ ហើយនឹងទៅទីនោះទេ) ។*

**យថាបច្ចយំ បន ទេសន្តរុប្បត្តិយំ គតិសមញ្ញា ។**

*ប៉ុន្តែ* **គតិសមញ្ញា** *(ការកំណត់ដឹងថាទៅ) រមែងមាន ព្រោះមានការកើតឡើងក្នុងទីដទៃ បានទៅតាមសមគួរដល់ហេតុបច្ច័យ ។*

**"ហទយំ មជ្ឈ"ន្តិ ហទយសមីបំ តស្ស ឧបរិភាគោ មជ្ឈំ ។**

*ពាក្យថា "**មានបេះដូងជាកណ្ដាលខ្យល់**" បានដល់ មានបរិវេណជិតបេះដូង គឺចំណែកដែលនៅសាច់បេះដូងនោះ ជាកណ្ដាលរបស់ខ្យល់ដង្ហើម ។*

**"នាសិកគ្គំ បរិយោសាន"ន្តិ នាសិកដ្ឋានំ តស្ស បរិយោសានំ អស្សាសបស្សាសសមញ្ញាយ តទវធិភាវតោ ។**

*ពាក្យថា "**មានចុងច្រមុះ ជាទីបំផុតរបស់ខ្យល់**" គឺទីកន្លែងត្រង់ចុងច្រមុះ ជាទីបំផុតនៃខ្យល់ដង្ហើមដែលចេញទៅខាងក្រៅនោះ ព្រោះកំណត់ដឹងថា ខ្យល់អស្សាស និងខ្យល់បស្សាស គឺមានទីកន្លែងនៅត្រង់ចុងច្រមុះនោះ ជាព្រំដែន ។*

តថា ហោតេ "ចិត្តសមុដ្ឋានា"តិ វុត្តា, ន ច ពហិទ្ធា ចិត្តសមុដ្ឋានានំ សម្ភវោ អត្ថិ ។

*មែនពិត លោកបានពោលដល់ខ្យល់ដង្ហើមទាំងនោះថា "មានចិត្តជាសមុដ្ឋាន", ក៏រូបដែលមានចិត្តជាសមុដ្ឋានទាំងឡាយនេះ គឺមិនមានការកើតឡើងនៅខាងក្រៅនោះទេ ។*

តេនាហ "**អព្ភន្តរំ បវិសនវាតស្ស នាសិកគ្គំ អាទី**"តិ ។

*ព្រោះហេតុនោះ លោកទើបពោលថា* ***"សម្រាប់ខ្យល់ដែលចូលទៅខាងក្នុងមានចុងច្រមុះ ជាខាងដើមរបស់ខ្យល់ដង្ហើម"*** *ដូច្នេះ ។*

**បវិសននិក្ខមនបរិយាយោ បន តំសទិសវសេន វុត្តោតិ វេទិតព្វោ។**

*ពាក្យថា ចូលទៅ ចេញមក គប្បីជ្រាបថា លោកពោលទុកដោយអាស្រ័យខ្យល់ហ្នឹងវាដូចជាចូលទៅ និងចេញមកវិញ យ៉ាងនោះ ។*

**"វិក្ខេបគត"**ន្តិ វិក្ខេបំ ឧបគតំ, វិក្ខិត្តំ អសមាហិតន្តិ អត្ថោ ។

*ពាក្យថា ចិត្ត* ***"ដែលដល់ការរាយមាយ"*** *គឺចិត្តដែលចូលដល់ការរាយមាយ, មានន័យថា រវើរវាយមិនបានតាំងមាំ ។*

"**សារទ្ធាយា**"តិ សទរថភាវាយ ។

*បទថា* ***"សារទ្ធាយ"*** *ប្រែថា ដើម្បីភាពរសាប់រសល់ ។*

"**ឥញ្ជនាយា**"តិ កម្មដ្ឋានមនសិការស្ស ចលនាយ ។

*ពាក្យថា* ***"ដើម្បីភាពញាប់ញ័រ"*** *គឺការមនសិការកម្មដ្ឋានឱ្យញាប់ញ័រ ។*

**"វិក្ខេបគតេន ចិត្តេនា"**តិ ហេតុម្ហិ ករណវចនំ, ឥត្ថម្ភូតលក្ខណេ វា ។

*ត្រង់សេចក្ដីថា "**វិក្ខេបគតេន ចិត្តេន** ប្រែថា **ព្រោះចិត្តដែលដល់ការរាយមាយ**" ជាតតិយាវិភត្តិ ចុះក្នុងអត្ថថា ជាហេតុ ឬក្នុងអត្ថថា ឥត្ថម្ភូតលក្ខណ នឹងប្រែថា មានចិត្តដែលដល់ភាពរាយមាយ ប្រែ បែបនេះក៏បាន ។*

"**សារទ្ធា**"តិ សទរថា ។

*បទថា "**សារទ្ធ**" ប្រែថា មានភាពរសាប់រសល់ ។*

"**ឥញ្ជិតា**"តិ ឥញ្ជនកា ចលនកា ។

*បទថា "**ឥញ្ជិតា**" កែទៅជា **ឥញ្ជនកា** ប្រែថា គឺមានភាពញាប់ញ័រ ។*

**តថា ផន្ទិតា** ។

*បទថា "**ផន្ទិតា** ប្រែថា **មានភាពស្ទុះស្ទា**" ក៏យ៉ាងនោះ គឺបានកែទៅជា **ផន្ទនកា** ប្រែថា មានភាពច្រួច្រា ។*

"**អាទិមជ្ឈបរិយោសានវសេនា**"តិ អាទិមជ្ឈបរិយោសានានុគមនវសេន ន មនសិកាតព្វន្តិ សម្ពន្ធោ ។

*ពាក្យថា កុំគប្បីមនសិការ "**ដោយជាប់ទាក់ទងជាមួយ ខាងដើមខ្យល់ កណ្ដាលខ្យល់ និងទីបំផុតខ្យល់**" សេចក្ដីថា កុំគប្បីមនសិការ ដោយជាប់ទាក់ទងទៅនឹងការជាប់តាមខាងដើមខ្យល់(ចុងច្រមុះ), កណ្ដាលខ្យល់(បេះដូង), និងទីបំផុតរបស់ខ្យល់(ត្រង់ផ្ចិត)ឡើយ ។*

"អនុពន្ធនាយ មនសិ ការោន្តេន ផុសនាវសេន ច ឋបនាវសេន ច មនសិកាតព្វ"ន្តិ យេនាធិប្បាយេន វុត្តំ, តំ វិវរិតុំ "**គណនានុពន្ធនាវសេន វិយា**"តិអាទិមាហ ។

*លោកអាចារ្យបានពោលថា "ព្រះយោគាវចរ កាលនឹងមនសិការ ដោយ **អនុពន្ធនា** (គឺសតិនៅជាមួយខ្យល់ដង្ហើមចូល ចេញ) ហើយក៏គប្បីមនសិការដោយការជាប់ទាក់ទងជាមួយ **ផុសនា** (កន្លែងដែលពាល់ត្រូវនូវខ្យល់*

ដង្ហើមចូល ចេញ) ផងដែរ និងដោយជាប់ទាក់ទងជាមួយ **ឋបនា** (ការតាំងមាំរបស់សមាធិ)" ដូច្នេះ ដែលមានសេចក្តីប្រាថ្នាយ៉ាងណា, គឺដើម្បីនឹងបើកបង្ហាញនូវសេចក្តីប្រាថ្នានោះ ទើបលោកពោលថា "**គណនានុពន្ធនាវសេន វិយ**" ដូច្នេះ ជាដើម ។

តត្ថ "**វិសុំ មនសិការោ នត្ថី**"តិ គណនាយ, អនុពន្ធនាយ ច វិនា យថាក្កមំ កេវលំ ផុសនាវសេន, ឋបនាវសេន ច កម្មដ្ឋានមនសិការោ នត្ថិ ។

បណ្តាពាក្យទាំងនោះ ត្រង់ពាក្យថា "**វិធីមនសិការ ជាប្រភេទមួយ មិនផ្សេងគ្នា**" មានន័យថា វិធីមនសិការកម្មដ្ឋាន ដែលជាប់ទាក់ទងជាមួយ ផុសនា, និងជាប់ទាក់ទងជាមួយ **ឋបនា** ជាការទៅតាមលំដាប់សុទ្ធៗ ដែលវៀរចាកនូវ **គណនា** និង **អនុពន្ធនា** មិនបានឡើយ ។

ននុ ផុសនាយ វិនា ឋបនាយ វិយ, ផុសនាយ វិនា គណនាយបិ មនសិការោ នត្ថិយេវ? យទិបិ នត្ថិ, គណនា បន យថា កម្មដ្ឋានមនសិការស្ស មូលភាវតោ បធានភាវេន គហេតព្វា, ឯវំ អនុពន្ធនា ឋបនាយ, តាយ វិនា ឋបនាយ អសម្ភវតោ ។

សួរថា តើវិធីមនសិការ សូម្បីប្រើនូវ **គណនា** (ការកំណត់រាប់នូវខ្យល់ដង្ហើមចូល ចេញ) រួចហើយវៀរចាកនូវ **ផុសនា** (កន្លែងដែលពាល់ត្រូវនូវខ្យល់ដង្ហើម)នោះ មិនបានទេ, ចុះចំណែក វិធីមនសិការដែលប្រើ **ឋបនា** ការតាំងមាំរបស់សមាធិ ហើយវៀរចាកនូវ **ផុសនា** កន្លែងដែលពាល់ត្រូវនូវខ្យល់ដង្ហើមចូល ចេញនោះ តើបានឬទេ ?

ឆ្លើយថា វិធីមនសិការ ដោយប្រើ **គណនា** ហើយវៀរចាកនូវ **ផុសនា** នោះចេញ គឺមិនបានទេ យ៉ាងណាមិញ, វិធីមនសិការ ដែលប្រើនូវ **ឋបនា** ហើយវៀរចាកនូវ **ផុសនា** នោះ គឺមិនបានដែរ ក៏យ៉ាងនោះដូចគ្នា (គឺត្រូវ

*អាស្រ័យគ្នាទៅវិញទៅមកអត់មិនបានទេ), បើដល់សភាវៈនោះ ព្រះយោគាវចរគប្បីកាន់យកនូវការ* **គណនា** *ដោយប្រើធ្វើជាប្រធាន ព្រោះជាឫសគល់នៃវិធីមនសិការកម្មដ្ឋាន យ៉ាងណាមិញ, នៅពេលបានប្រើដល់* **អនុពន្ធនា** *ក៏គប្បីកាន់យកធ្វើជាប្រធាននៃវិធី ព្រោះជាឫសគល់នៃ* **ឋបនា** *ក៏យ៉ាងនោះដែរ ព្រោះកាលវៀរចាកនូវ* **អនុពន្ធនា** *នោះចេញហើយ* **ឋបនា** *ក៏មិនអាចមានដែរ ។*

**តស្មា សតិបិ ផុសនាយ ឋានន្តរិកភាវេ គណនានុពន្ធនា ឯវ មូលភាវតោ បធានភាវេន គហេត្វា ឥតរាសំ តទភាវំ ទស្សេន្តោ អាហ “គណនានុពន្ធនាវសេន វិយ ហិ ផុសនាឋបនាវសេន វិសុំ មនសិការោ នត្ថី”តិ ។**

*កាលមាន* **ផុសនា** *ជាវិធីមួយម្យ៉ាង ព្រោះហេតុនោះ លោកអាចារ្យកាន់យកចំពោះ* **គណនា** *និង* **អនុពន្ធនា** *តែប៉ុណ្ណោះ ដែលជាវិធីដើរតួជាប្រធាន ព្រោះជាឫសគល់នៃវិធីមនសិការកម្មដ្ឋាន ហើយសម្តែងដល់វិធីមនសិការក្រៅនេះ ដែលមិនមែនជាឫសគល់នោះ ទើបពោលថា “**តាមពិត វិធីមនសិការ ដែលជាប់ទាក់ទងជាមួយ ផុសនា និង ឋបនា ជាប្រភេទតែមួយ មិនផ្សេងគ្នាទេ ដូចគ្នានឹងវិធីមនសិការ ដែលជាប់ទាក់ទងទៅនឹង គណនា និង អនុពន្ធនា ដែរ**” ដូច្នេះ ។*

**យទិ ឯវំ តា កស្មា ឧទ្ទេសេ វិសុំ គហិតាតិ អាហ “ផុដ្ឋផុដ្ឋដ្ឋានេយេវា”តិអាទិ ។**

*សួរថា ប្រសិនជាយ៉ាងនេះ ព្រោះហេតុអ្វីក្នុងឧទ្ទេស លោកទើបកាន់យកនូវវិធីមនសិការទាំងនោះ ហើយបានញែកចេញទៅជាចំណុចមួយៗ ទៀត ? លោកអាចារ្យបានឆ្លើយថា “**ព្រះយោគាវចរ កាលកំណត់រាប់នូវខ្យល់ នៅត្រង់កន្លែងដែលខ្យល់ពាល់ត្រូវហើយៗ នោះប៉ុណ្ណោះ**” ដូច្នេះ ជាដើម ។*

**តត្ថ “ផុដ្ឋផុដ្ឋដ្ឋានេយេវ គណេន្តោ”តិ ឥមិនា គណនាយ ផុសនា**

អគ្គន្តិ ធស្សេតិ ។

*ក្នុងពាក្យទាំងនោះ ដោយពាក្យថា "**កាលកំពុងកំណត់រាប់នូវខ្យល់នៅត្រង់កន្លែងដែលខ្យល់ពាល់ត្រូវហើយៗ**" នេះ លោកសម្ដែងថា* **ផុសនា** *(កន្លែងដែលពាល់ត្រូវនូវខ្យល់ដង្ហើម) វាជាអង្គនៃ* **គណនា** *(គឺការកំណត់រាប់នូវខ្យល់ដង្ហើម) (បានន័យថាការរាប់នូវខ្យល់ នៅត្រង់កន្លែងដែលពាល់ត្រូវនេះជាអង្គមួយ) ។*

**តេនាហ "គណនាយ ច ផុសនាយ ច មនសិ ករោតី"ති ។**

*ព្រោះហេតុនោះ ទើបលោកពោលថា "**មនសិការដោយការប្រើ គណនា ផង ដោយ ផុសនា ផង**" ដូច្នេះ ។*

**តត្ថេវាតិ ផុដ្ឋផុដ្ឋដ្ឋានេយេវ ។**

*បទថា "**តត្ថេវ**" ប្រែថា ត្រង់កន្លែងដែលខ្យល់ពាល់ត្រូវហើយៗ នុ៎ះឯង ។*

**"តេ"តិ អស្សាសបស្សាសេ ។**

*បទថា "**តេ** ប្រែថា **ខ្យល់ទាំងនោះ**" គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ។*

**"សតិយា អនុពន្ធន្តោ"តិ គណនាវសេន អនុគន្ត្វា សតិយា និពន្ធន្តោ, ផុដ្ឋោកាសេយេវ តេ និរន្តរំ ឧបធារេន្តោតិ អត្ថោ ។**

*ពាក្យថា "**ប្រើសតិនៅជាមួយខ្យល់ដង្ហើម**" មានន័យថា (ពេលឈប់កំណត់រាប់នូវខ្យល់ដង្ហើម) ប្រើសតិកំណត់ដឹងនៅជាប់យ៉ាងជិតស្និទ្ធ (នៅត្រង់ចុងច្រមុះ) ដោយបណ្ដោយទៅតាមវិថីចិត្តដែលបានរាប់ខ្យល់នោះ ហើយគ្រាន់តែកំណត់ដឹងនូវខ្យល់ចូល និងខ្យល់ចេញទាំងនោះ មិនឱ្យខាតដាច់ចន្លោះក្នុងពេលដែលខ្យល់បានពាល់ត្រូវហើយៗ នុ៎ះឯង នេះឈ្មោះថា* **មានសតិនៅជាមួយខ្យល់ដង្ហើម** *។*

**"អប្បនាវសេន ចិត្តំ ឋបេន្តោ"តិ** យថា អប្បនា ហោតិ, ឯវំ យថា ឧបដ្ឋិតេ និមិត្តេ ចិត្តំ ឋបេន្តោ សមាទហន្តោ ។

*ពាក្យថា "**តាំងចិត្តទុកដោយអំណាចនៃអប្បនា**" កាលតាំងទុកយ៉ាងមាំទាំនូវចិត្តត្រង់និមិត្ត (គឺចុងច្រមុះ) ដែលចូលទៅតម្កល់ទុកហើយ, ទៅតាមប្រការដែល អប្បនា នឹងកើតឡើង ។*

**"អនុពន្ធនាយ ចា"តិអាទីសុ អនុពន្ធនាយ ច ផុសនាយ ច ឋបនាយ ច មនសិការោតីតិ វុច្ចតីតិ យោជនា ។**

*ក្នុងពាក្យថា "**អនុពន្ធនាយ ច**" ជាដើម មានសេចក្ដីថា ដែលហៅថា មនសិការ គឺមាន* **អនុពន្ធនា** *ផង ដោយ***ផុសនា** *ផង និងដោយ* **ឋបនា** *ផង ។*

**"ស្វាយមត្ថោ"តិ យ្វាយំ "ផុដ្ឋផុដ្ឋដ្ឋានេយេវ គណេន្តោ, តត្ថេវ គណនំ បដិសំហរិត្វា តេ សតិយា អនុពន្ធន្តោ"តិ ច វុត្តោ, សោ អយមត្ថោ ។**

*ពាក្យថា "**អធិប្បាយនេះ នុ៎ះ**" មានន័យថា ការអធិប្បាយ ដែលលោកបានពោលទុកថា "ព្រះយោគាវចរ កាលកំណត់រាប់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលខ្យល់បានពាល់ត្រូវហើយៗ នោះប៉ុណ្ណោះ, ដល់ពេលឈប់រាប់ ក៏ប្រើសតិដឹងនៅជាប់ជាមួយខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះ នៅត្រង់កន្លែងដែលខ្យល់បានពាល់ត្រូវហើយៗ នោះឯង" ដូច្នេះ យ៉ាងណា ការអធិប្បាយក៏យ៉ាងនោះ ។*

**យា អច្ចន្តាយ ន មិនោតិ ន វិនិច្ឆិនាតិ, សា មានស្ស សមីបេតិ ឧបមា យថា "គោណោ វិយ គវយោ"តិ ។**

*វីពាក្យពោលណា ដែលវាស់មិនបាន គឺការកាត់ចេញមិនបាន ព្រោះវាជាពាក្យហួសវិស័យនឹងធ្វើបាន, វីពាក្យពោលនោះ ឈ្មោះថា ការឧបមា ព្រោះអត្ថថា ប្រព្រឹត្តទៅក្នុងទីជិតនៃការវាស់ ដូចជាពាក្យថា "ប្រៀបដូចគោ ទើបឈ្មោះថា លានគោ" ដូច្នេះ ក៏យ៉ាងនោះដែរ ។*

# ប្រៀបដូចជាមនុស្សខ្វិនយោលទោង[៣៩]

## (វិសុទ្ធិមគ្គ)

[២២៤] តត្រាយំ **បង្គុឡោបមា** –

*ក្នុងរឿង ឧបមា ទាំង ៣ យ៉ាងនោះ តទៅនេះ ជាការឧបមា* **មនុស្សខ្វិន**

សេយ្យថាបិ បង្គុឡោ ទោលាយ កីឡតំ មាតាបុត្តានំ ទោលំ ខិបិត្វា តត្ថេវ ទោលាយ ថម្ភមូលេ និសិន្នោ កមេន អាគច្ឆន្តស្ស ច គច្ឆន្តស្ស ច ទោលាផលកស្ស ឧភោ កោដិយោ មជ្ឈញ្ច បស្សតិ, ន ច ឧភោកោដិមជ្ឈានំ ទស្សនត្ថំ ព្យាវដោ ហោតិ, ឯវមេវាយំ ភិក្ខុ សតិវសេន ឧបនិពន្ធនថម្ភមូលេ ឋត្វា អស្សាសបស្សាសទោលំ ខិបិត្វា តត្ថេវ និមិត្តេ សតិយា និសីទន្តោ កមេន អាគច្ឆន្តានញ្ច គច្ឆន្តានញ្ច ផុដ្ឋដ្ឋានេ អស្សាសបស្សាសានំ អាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆន្តោ តត្ថ ច ចិត្តំ ឋបេន្តោ បស្សតិ, ន ច តេសំ ទស្សនត្ថំ ព្យាវដោ ហោតិ, អយំ បង្គុឡោបមា ។

*ប្រៀបដូចជា មានបុរសខ្វិនម្នាក់ បានអង្គុយយោលទោងឱ្យស្ត្រីដែលជាប្រពន្ធ និងកូន ជាអ្នកជិះទោង ហើយក៏អង្គុយនៅត្រង់សសរបង្គោលទោងនោះនុះឯង បុរសខ្វិននោះ រមែងឃើញនូវទីបំផុតទាំង ២ ខាង និងផ្នែកកណ្ដាលរបស់ទោងនោះ ដែលកំពុងយោលទៅ និងកំពុងយោលមក ទៅតាមលំដាប់រឿយៗ, ប៉ុន្តែ បុរសអ្នកយោលទោងនោះ មិនបានខ្វល់ខ្វាយក្នុងការមើលឃើញនូវទីបំផុតទាំង ២ ខាង និងត្រង់កណ្ដាលរបស់ទោងនោះទេ យ៉ាងណាមិញ, ព្រះយោគាវចរភិក្ខុ គឺឈរតាំងនៅទីគល់សសរ ដែលជាទីចូលទៅចងទុក ដោយអំណាចនៃសតិ (គឺកន្លែងខ្យល់ពាល់ត្រូវ)ហើយ ៗ ការយោលទោងគឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ការអង្គុយដោយមានសតិនៅត្រង់និមិត្តនោះ*

---

*៣៩ នេះជាការឧបមាពន្យល់ក្នុងការតម្កល់នូវសតិនៅត្រង់ចុងច្រមុះឱ្យបានត្រឹមត្រូវ ពេលដែលកំណត់ដឹងនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ហាមតាមទៅខាងក្នុងពោះ ។*

*(គឺចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើ)នុ៎ះឯង ការប្រើសតិនៅជាមួយខ្យល់ដង្ហើម និងតម្កល់ចិត្តទុកនៅត្រង់ខ្យល់ដែលបានពាល់ត្រូវហើយៗ នោះ ប៉ុណ្ណោះ រមែងឃើញនូវខាងដើមខ្យល់ កណ្តាលខ្យល់ និងទីបំផុតរបស់ខ្យល់ ដែលខ្យល់ចូលមក និងចេញទៅ ព្រោះបានធ្វងកាត់នៅត្រង់កន្លែងដែលបានពាល់ត្រូវ (នៅត្រង់ចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើនោះ) ទៅតាមលំដាប់, ប៉ុន្តែ ព្រះយោគាវចរមិនបានខ្វល់ខ្វាយ ដើម្បីទៅឃើញនូវខាងដើមខ្យល់(ដែលលោកបានហាម) ជាដើម ទាំងនោះទេ យ៉ាងនេះក៏ដូចគ្នា, នេះជារឿង ឧបមា តាមបែបមនុស្សខ្វិនយោលទោង ។*

## មនុស្សខ្វិនយោលទោង

### (**មហាដីកាវិសុទ្ធិមគ្គ**)

[២២៩] "**បង្គុឡោ**"តិ បីឋសប្បី ។

*បទថា "**បង្គុឡោ**" ប្រែថា មនុស្សខ្វិន ។*

**ទោលា** បេ ខោលោ ។ "**កីឡតំ**"ន្តិ កីឡន្តានំ ។

*មនុស្សខ្វិននោះ **ជាអ្នកយោលទោង** ។ បទថា "**កីឡតំ**" កែទៅជា* **កីឡន្តានំ**។

"**មាតាបុត្តាន**"ន្តិ អត្តនោ ភរិយាយ, បុត្តស្ស ច ។

*ពាក្យថា "**ដល់មាតា និងកូន**" គឺបានដល់ភរិយា និងកូនរបស់ខ្លួន ។*

"**ឧភោ កោដិយោ**"តិ អាគច្ឆន្តស្ស បុរិមកោដី, គច្ឆន្តស្ស បច្ឆិមកោដិន្តិ ទ្វេបិ កោដិយោ ។

*ពាក្យថា "**ទីបំផុតទាំង ២**" គឺទីបំផុតខាងមុខនៃផែនក្តាររបស់ទោងដែលកំពុងមក, និងទីបំផុតខាងក្រោយនៃផែនក្តាររបស់ទោង ដែលកំពុងទៅ ។*

**"មជ្ឈេ"ន្តិ ទោលាផលកាស្សេវ មជ្ឈំ ។**

*ពាក្យថា "**ត្រង់កណ្តាល**" គឺត្រង់កណ្តាលនៃផែនក្តាររបស់ទោង នុ៎ះឯង។*

**ឧបនិពន្ធនថម្ភោ វិយាតិ ឧបនិពន្ធនថម្ភោ**, ជាសិកាគ្គំ, មុខនិមិត្តំ វា, តស្ស **មូលេ** សមីបេ **ឋត្វា** ។

*ពាក្យថា **ឈរតាំងនៅទីគល់សសរ ដែលជាទីចូលទៅចងទុក** មានន័យថា ឈ្មោះថា គល់សសរដែលជាទីចូលទៅចងទុក បានដល់ ខាងចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើ បានដល់ **តាំងនៅ** ជិត **គល់** សសរដែលជាទីចូលទៅចងទុក នោះ ។*

**កថំ ឋត្វា? សតិយា វសេន ។**

*តើតាំងនៅ យ៉ាងដូចម្តេច ? គឺតាំងនៅដោយអំណាចនៃសតិ ។*

**សតិញ្ហិ តត្ថ សូបដ្ឋិតំ ករោន្តោ យោគាវចរោ តត្ថ ឋិតោ នាម ហោតិ, អវយវេនេវ សមុទាយស្ស អបទិសិតព្វតោ ។**

*ព្រះយោគាវចរ កាលចម្រើនសតិ ឱ្យតាំងមាំបានល្អនៅត្រង់ចុងច្រមុះ ជាដើមនោះ ក៏ឈ្មោះថា ជាអ្នកតាំងនៅក្នុងទីនោះ, ព្រោះថា ជាទីប្រជុំនៃធម៌ដែលមករួមគ្នា បណ្ឌិតគប្បីចង្អុលបង្ហាញបានដោយធម៌ដែលជាអង្គប្រកប ។*

**"និមិត្តេ"តិ** ជាសិកគ្គាទិនិមិត្តេ ។

*ពាក្យថា "**នៅត្រង់និមិត្ត**" បានដល់ និមិត្តនៅត្រង់ចុងច្រមុះ ជាដើម ។*

**"សតិយា និសីទន្តោ"តិ** សតិវសេន និសីទន្តោ ។

*ពាក្យថា "**អង្គុយដោយមានសតិ**" គឺការអង្គុយដោយអំណាចនៃសតិ ។*

"សតិញ្ហិ តត្ថា"តិអាទិនា ឋានេ វិយ វត្តព្វំ ។

*ដូចក្នុងឋានៈ ដែលគួរពោលទុកដោយពាក្យថា "ព្រះយោគាវចរ កាល*

*ប្រកបសតិ ឱ្យតាំងមាំបានល្អ នៅត្រង់ចុងច្រមុះ ជាដើមនោះ" ដូច្នេះ ។*

"**តត្ថា**"តិ ផុដ្ឋផុដ្ឋដ្ឋានេ ។

*បទថា "**តត្ថ**" ប្រែថា ត្រង់ទីកន្លែងដែលខ្យល់ពាល់ត្រូវហើយៗ ។*

## ប្រៀបដូចជាមនុស្សយាមទ្វារ[៤០]

**(វិសុទ្ធិមគ្គ)**

[២២៦] អយំ បន **ទោវារិកូបមា** –

*ចំណែកតទៅនេះ ជា **រឿងឧបមាដោយមនុស្សយាមទ្វារក្រុង***

សេយ្យថាបិ ទោវារិកោ នគរស្ស អន្តោ ច ពហិ ច បុរិសេ "កោ ត្វំ, កុតោ វា អាគតោ, កុហឹ វា គច្ឆសិ, កឹ វា តេ ហត្ថេ"តិ ន វីមំសតិ ។

*ឧបមា ប្រៀបដូចជា អ្នកយាមទ្វារក្រុង រមែងមិនសួរដេញដោលនូវមនុស្សទាំងអស់ ទាំងខាងក្នុងក្រុង និងទាំងខាងក្រៅក្រុងទេ ថា "អ្នក គឺជានរណា ?, អ្នកមកអំពីទីណា ?, អ្នកនឹងទៅទីណា ?, ឬថា មានអ្វីនៅក្នុងដៃរបស់អ្នក ?" ។*

ន ហិ តស្ស តេ ភារា, ទ្វារប្បត្តំ ទ្វារប្បត្តំយេវ បន វីមំសតិ, ឯវមេវ ឥមស្ស ភិក្ខុនោ អន្តោ បវិដ្ឋវាតា ច ពហិ និក្ខន្តវាតា ច ន ភារា ហោន្តិ, ទ្វារប្បត្តា ទ្វារប្បត្តាយេវ ភារាតិ អយំ ទោវារិកូបមា ។

*ព្រោះថា មនុស្សទាំងឡាយនោះ មិនមែនជាតួនាទីរបស់អ្នកយាមទ្វារទេ, ប៉ុន្តែ នឹងបានសាកសួរតែមនុស្សគ្រប់ៗរូបណា ដែលមកដល់ត្រង់មាត់ទ្វារចូល*

---

*៤០ នេះជាការឧបមាពន្យល់នូវទីកន្លែងដែលព្រះយោគី គប្បីតម្កល់សតិនៅត្រង់ចុងច្រមុះឱ្យត្រឹមត្រូវពេលដែលកំណត់ដឹងនូវខ្យល់ដង្ហើមចូលនិងខ្យល់ដង្ហើមចេញ ហាមតាមទៅខាងក្នុង។*

*ក្រុង នោះប៉ុណ្ណោះឯង យ៉ាងណាមិញ, ខ្យល់ដង្ហើមដែលចូលទៅខាងក្នុង(មានចុងច្រមុះ បេះដូង និងផ្ចិត) និងខ្យល់ដង្ហើមដែលចេញមកខាងក្រៅវិញ (មានផ្ចិត បេះដូង និងចុងច្រមុះ) ក៏មិនមែនជា តួនាទីរបស់ព្រះយោគាវចរភិក្ខុរូបនេះទេ, គ្រប់ៗ ខណៈខ្យល់ដង្ហើមដែលមកដល់ត្រង់ចុងច្រមុះ នោះប៉ុណ្ណោះ ទើបជាតួនាទីកំណត់ដឹង របស់ព្រះយោគាវចរភិក្ខុអ្នកបដិបត្តិរូបនោះ (សេចក្តីនេះ) ក៏ដូចគ្នា នុ៎ះឯង នេះជារឿង ឧបមាមនុស្សយាមទ្វារក្រុង ។*

## ឧបមា មនុស្សយាមទ្វារក្រុង

**(មហាដីកាវិសុទ្ធិមគ្គ)**

[២២៦] "**តេ**"តិ នគរស្ស អន្តោពហិគតា មនុស្សា, តេសំ សង្គហា ច ហត្ថគតា ។

*ពាក្យថា "**មនុស្សទាំងឡាយនោះ**" បានដល់ ពួកអ្នកដែលនៅខាងក្នុង និងខាងក្រៅក្រុង, ក៏បណ្តាពួកមនុស្សទាំងឡាយនោះ ពួកមនុស្សដែលនៅក្រោមអំណាច ទើបមានការសង្គ្រោះចូល ។*

## ឧបមា ដោយរណារដៃ[៤១]

**(វិសុទ្ធិមគ្គ)**

[២២៧] **កកចូបមា** បន អាទិតោ បដ្ឋាយ ឯវំ វេទិតព្វា។ វុត្តញ្ហេតំ –

*ចំណែក **រឿងឧបមាដោយរណារដៃ** គប្បីជ្រាបតាំងតែខាងដើម នេះ*

---

*៤១ នេះជាការឧបមាពន្យល់នូវទីកន្លែងដែលព្រះយោគី គប្បីតម្កល់សតិនៅត្រង់ចុងច្រមុះឱ្យត្រឹមត្រូវពេលដែលកំណត់ដឹងនូវខ្យល់ដង្ហើមចូលនិងខ្យល់ដង្ហើមចេញ ហាមតាមទៅខាងក្នុង។*

*ទៅ ។ សេចក្ដីនេះ សមដូចពាក្យរបស់ព្រះសារីបុត្តថេរបានសម្ដែងទុកមកថា ៖*

**"និមិត្តំ អស្សាសបស្សាសា, អនារម្មណាមេកចិត្តស្ស;**

**អជានតោ ច តយោ ធម្មេ, ភាវនា នុបលព្ភតិ ។**

*និមិត្ត (គឺចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើ) ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ មិនមែនជាអារម្មណ៍របស់ចិត្តមួយដួងទេ ប៉ុន្តែ កាលព្រះយោគាវចរភិក្ខុ មិនដឹងនូវធម៌ទាំង ៣ យ៉ាងនេះ ការចម្រើនភាវនា ក៏មិនអាចសម្រេចបានឡើយ ។*

**និមិត្តំ អស្សាសបស្សាសា, អនារម្មណាមេកចិត្តស្ស;**

**ជានតោ ច តយោ ធម្មេ, ភាវនា ឧបលព្ភតី"តិ[៤២]។**

*"និមិត្ត(គឺចុងច្រមុះ ឬលើផ្ទៃបបូរមាត់ខាងលើ) ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ មិនមែនជាអារម្មណ៍របស់ចិត្តមួយដួងទេ ប៉ុន្តែ កាលព្រះយោគាវចរភិក្ខុ បានដឹងនូវធម៌ទាំង ៣យ៉ាងនេះ ការចម្រើនភាវនា រមែងបានសម្រេចយ៉ាងពិតប្រាកដ" ដូច្នេះ ។ ហើយព្រះថេរៈ បានសម្ដែងតទៅទៀតថា៖*

**"កថំ ឥមេ តយោ ធម្មា ឯកចិត្តស្ស អារម្មណា ន ហោន្តិ, ន ចិមេ តយោ ធម្មា អវិទិតា ហោន្តិ, ន ច ចិត្តំ វិក្ខេបំ គច្ឆតិ, បធានញ្ច បញ្ញាយតិ, បយោគញ្ច សាធេតិ, វិសេសមធិ គច្ឆតិ?**

*"ធម៌ទាំង ៣ យ៉ាងនេះ មិនមែនជាអារម្មណ៍របស់ចិត្តមួយដួងទេ, ប៉ុន្តែ ធម៌ទាំង ៣ យ៉ាងនេះ មិនមែនព្រះយោគាវចរភិក្ខុមិនដឹងទេ, ចិត្ត មិនដល់នូវសេចក្ដីរាយមាយផង, ទាំងសេចក្ដីព្យាយាម ក៏ប្រាកដផង, ព្រះយោគាវចរភិក្ខុញ៉ាំងសេចក្ដីខិតខំប្រឹងប្រែងឱ្យបានសម្រេចផង, និងបានទម្រុះនូវគុណវិសេស តើដូចម្ដេច?*

---

៤២ បដិ. ម. បិ ៧០. [៩១] ។

## ការឧបមា

សេយ្យថាបិ រុក្ខោ សមេ ភូមិភាគេ និក្ខិត្តោ, តមេនំ បុរិសោ កកចេន ឆិន្ទេយ្យ ។

*ប្រៀបធៀបដូចជា ដើមឈើមួយដើមដែលគេតម្កល់ទុកនៅលើផ្ទៃដ៏រាបស្មើរួចហើយ, មានបុរសម្នាក់បានអារដើមឈើនោះ ដោយរណារដៃ ។*

រុក្ខេ ផុដ្ឋកកចទន្តានំ វសេន បុរិសស្ស សតិ ឧបដ្ឋិតា ហោតិ, ន អាគតេ វា គតេ វា កកចទន្តេ មនសិ ករោតិ, ន អាគតា វា គតា វា កកចទន្តា អវិទិតា ហោន្តិ, បធានញ្ច បញ្ញាយតិ, បយោគញ្ច សាធេតិ, វិសេសមធិគច្ឆតិ ។

*សតិស្មារតីរបស់បុរសនោះ រមែងតម្កល់ទុកចំពោះដើមឈើដោយអំណាចនៃធ្មេញរណារដៃ ដែលបានពាល់ត្រូវហើយ, (បុរសនោះ) មិនធ្វើទុកក្នុងចិត្តត្រង់ធ្មេញរណារដៃដែលមក ឬក៏ ទៅ នោះទេ, ធ្មេញរណារទាំងឡាយដែលទាញមកក្តី និងរុញទៅវិញក្តី មិនមែនបុរសនោះមិនដឹងទេ(គឺដឹង តែមិនចាប់យក), ទាំងសេចក្តីព្យាយាម ក៏រមែងប្រាកដផង, បុរសនោះ រមែងខិតខំប្រឹងប្រែងធ្វើការ (អារឈើ) ឱ្យបានសម្រេច ផង, និងបានទទួលនូវប្រយោជន៍ដ៏វិសេស ។*

## ការឧបមេយ្យ

"យថា រុក្ខោ សមេ ភូមិភាគេ និក្ខិត្តោ, ឯវំ ឧបនិពន្ធនានិមិត្តំ ។

*ចំណែក និមិត្ត (គឺចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើ) ដែលគេចូលទៅចងទុក ប្រៀបដូចជា ដើមឈើដែលគេតម្កល់ទុកនៅលើផ្ទៃ ដ៏រាបស្មើរួចហើយ យ៉ាងណាមិញ ។*

យថា កកចទន្តា, ឯវំ អស្សាសបស្សាសា ។

*ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ប្រៀបដូចជាធ្មេញរណារដែ ក៏យ៉ាងនោះដែរ ។*

**យថា រុក្ខេ ផុដ្ឋកកចទន្តានំ វសេន បុរិសស្ស សតិ ឧបដ្ឋិតា ហោតិ, ន អាគតេ វា គតេ វា កកចទន្តេ មនសិ ករោតិ, ន អាគតា វា គតា វា កកចទន្តា អវិទិតា ហោន្តិ, បធានញ្ច បញ្ញាយតិ, បយោគញ្ច សាធេតិ, វិសេសមធិគច្ឆតិ ។**

*ប្រៀបដូចជា មានបុរសម្នាក់បានតម្កល់សតិទុកត្រង់ធ្មេញរណារដែដែលកំពុងពាល់ត្រូវនូវដើមឈើ ហើយបុរសនោះមិនយកចិត្តទុកដាក់ ទៅនឹងធ្មេញរណារដែដែលកំពុងមកក្តី ឬកំពុងទៅក្តី, ធ្មេញរណារដែដែលកំពុងមក ឬកំពុងទៅ បុរសនោះ រមែងដឹងយ៉ាងច្បាស់ (គឺដឹងនៅត្រង់កន្លែងពាល់ត្រូវនូវដើមឈើ), ទាំងសេចក្តីព្យាយាម ក៏ប្រាកដផង, ទាំងសេចក្តីខិតខំប្រឹងប្រែងធ្វើឱ្យបានសម្រេចផង, និងបានទទួលនូវប្រយោជន៍ដ៏វិសេស យ៉ាងណាមិញ ។*

**ឯវមេវ ភិក្ខុ នាសិកគ្គេ វា មុខនិមិត្តេ វា សតឹ ឧបដ្ឋបេត្វា និសិន្នោ ហោតិ, ន អាគតេ វា គតេ វា អស្សាសបស្សាសេ មនសិករោតិ, ន ច អាគតា វា គតា វា អស្សាសបស្សាសា អវិទិតា ហោន្តិ, បធានញ្ច បញ្ញាយតិ, បយោគញ្ច សាធេតិ, វិសេសមធិគច្ឆតិ ។**

*ព្រះយោគាវចរភិក្ខុ កាលអង្គុយចុះហើយ ក៏តម្កល់សតិទុកនៅត្រង់ចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើ, មិនធ្វើទុកក្នុងចិត្ត នូវខ្យល់ដង្ហើមដែលចូល (គឺពីចុងច្រមុះ ទៅបេះដូង និងទៅផ្ចិត) និងខ្យល់ដង្ហើមដែលចេញ (គឺពីផ្ចិត មកបេះដូង និងមកចុងច្រមុះ ដែលលោកបានហាមនោះ)ទេ, ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលមកក្តី ឬទៅក្តី ជាសភាវៈដែលព្រះយោគាវចរភិក្ខុ រមែងដឹង (គឺដឹងនៅត្រង់ចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើ), ទាំងសេចក្តីព្យាយាម ក៏ប្រាកដផង, ទាំងសេចក្តីខិតខំប្រឹងប្រែងធ្វើឱ្យបានសម្រេចផង, និងបានសម្រេច*

*នូវប្រយោជន៍ គឺគុណដ៏វិសេស ក៏យ៉ាងនោះដែរ ។*

**"បធាន"ន្តិ កាតមំ បធានំ? អារទ្ធវីរិយស្ស កាយោបិ ចិត្តម្បិ កម្មនិយំ ហោតិ, ឥទំ បធានំ ។**

*បទថា "* **បធាន** *" ប្រែថា សេចក្ដីព្យាយាម តើបទថា* **បធាន** *ដូចម្ដេច ?*

*ឆ្លើយថា ទាំងកាយក្ដី ទាំងចិត្តក្ដី របស់ភិក្ខុអ្នកប្រារព្ធនូវសេចក្ដីព្យាយាម ជាធម្មជាតិគួរដល់ការងារ, នេះឈ្មោះថា* **បធាន** *។*

**កាតមោ បយោគោ? អារទ្ធវីរិយស្ស ឧបក្កិលេសា បហីយន្តិ, វិតក្កា វូបសមន្តិ, អយំ បយោគោ ។**

*បទថា* **បយោគ** *ប្រែថា សេចក្ដីខិតខំប្រឹងប្រែង តើបទថា* **បយោគ** *ដូចម្ដេច ?*

*ឆ្លើយថា ឧបក្កិលេសទាំងឡាយរបស់ភិក្ខុអ្នកប្រារព្ធនូវសេចក្ដីព្យាយាម ត្រូវបានលះចេញ, វិតក្កៈទាំងឡាយ រមែងស្ងប់ទៅ, នេះឈ្មោះថា* **បយោគ** *។*

**កាតមោ វិសេសោ? អារទ្ធវីរិយស្ស សំយោជនា បហីយន្តិ, អនុសយា ព្យន្តី ហោន្តិ, អយំ វិសេសោ ។**

*បទថា* **វិសេសោ** *ប្រែថា គុណវិសេស តើបទថា* **វិសេសោ** *ដូចម្ដេច ?*

*ឆ្លើយថា សំយោជនៈទាំងឡាយរបស់ភិក្ខុ អ្នកប្រារព្ធនូវសេចក្ដីព្យាយាម ត្រូវបានលះទៅ, អនុស័យទាំងឡាយក៏ត្រូវបានអស់ទៅ, នេះឈ្មោះថា គុណវិសេស ។*

**ឯវំ ឥមេ តយោ ធម្មា ឯកចិត្តស្ស អារម្មណា ន ហោន្តិ, ន ចិមេ តយោ ធម្មា អវិទិតា ហោន្តិ, ន ច ចិត្តំ វិក្ខេបំ គច្ឆតិ, បធានញ្ច បញ្ញាយតិ, បយោគញ្ច សាធេតិ, វិសេសមធិគច្ឆតិ**[៤៣]**។**

---

៤៣ បដិ. ម. បិ ៧០ . [៩៣]. ទំព័រ ១០៦ ។

*តាមប្រការដូចបានពោលមកហើយនេះ ធម៌ទាំងឡាយ ៣ យ៉ាង មិនមែនជាអារម្មណ៍របស់ចិត្តមួយដួងទេ, ធម៌ទាំងឡាយ ៣ យ៉ាងនេះ មិនមែនព្រះយោគីភិក្ខុមិនដឹងទេ, ទាំងចិត្ត ក៏មិនដល់ភាពរាយមាយ, ព្រះយោគាវចរភិក្ខុ ក៏ធ្វើសេចក្ដីព្យាយាម ក៏ប្រាកដផង, ទាំងសេចក្ដីខិតខំប្រឹងប្រែងធ្វើឱ្យបានសម្រេចផង, និងបានសម្រេចនូវប្រយោជន៍ គឺគុណដ៏វិសេស" ។*

**"អានាបានស្សតិ យស្ស, បរិបុណ្ណា សុភាវិតា;**

**អនុបុព្វំ បរិចិតា, យថា ពុទ្ធេន ទេសិតា;**

**សោ ឥមំ លោកំ បភាសេតិ, អព្ភា មុត្តោវ ចន្ទិមា"តិ[៤៤] ។**

*អានាបានស្សតិ ដែលព្រះយោគាវចរភិក្ខុរូបណា ចម្រើនបានល្អហើយ សន្សំទៅតាមលំដាប់ហើយ (គឺតាមវិធី ដឹងថាវែង និងខ្លី ជាដើម) រហូតបានពេញបរិបូរណ៍ (គ្រប់ទាំង ១៦ ចំណុច) ទៅតាមដែលព្រះពុទ្ធជាម្ចាស់ទ្រង់បានសម្ដែងទុកមកហើយ ព្រះយោគាវចរភិក្ខុរូបនោះ រមែងញុំាងលោកនេះ (គឺខន្ធ ៥ របស់ខ្លួនឯង ជាដើម) ឱ្យភ្លឺស្វាង (ដោយពន្លឺនៃបញ្ញា) ដូចដួងព្រះចន្ទរួចផុតចាកពីពពក ក៏ដូច្នោះដែរ" ដូច្នេះ ។*

**អយំ កកចូបមា ។**

*ចប់ ការឧបមានៃរឿងរណារដៃ តែប៉ុណ្ណេះ ។*

**ឥធ បនស្ស អាគតាគតវសេន អមនសិការមត្តមេវ បយោជនន្តិ វេទិតព្វំ ។**

*ការឧបមា ដោយរណារដៃនេះ គប្បីជ្រាបថា គ្រាន់តែការ មិនយកចិត្តទុកដាក់ជាមួយខ្យល់ដែលមក និងទៅ (ប៉ុន្តែ ត្រូវកំណត់ដឹងនូវខ្យល់ដែលពាល់ត្រូវហើយៗនៅត្រង់ចុងច្រមុះ ឬលើផ្ទៃបបូរមាត់ខាងលើ) នេះជាទិសដៅរបស់ព្រះយោគាវចរភិក្ខុរូបនោះ ។*

៤៤ បដិ. ម. បិ ៧០. [ ៩៤] ទំព័រ ១០៧ ។

# ឧបមា ដោយរណារដៃ

## (មហាដីកាវិសុទ្ធិមគ្គ)

[២២៧] "**អាទិតោ បដ្ឋាយ**"តិ ឧបមេយ្យត្ថទស្សនតោ បដ្ឋាយ ។

*ពាក្យថា"**តាំងតែខាងដើម**"គឺតាំងតែសម្តែងនូវសេចក្តីនៃការឧបមេយ្យ ។*

**កាថាយំ "និមិត្ត"ន្តិ ឧបនិពន្ធនានិមិត្តំ ។**

*ក្នុងគាថា ពាក្យថា "**និមិត្ត**" បានដល់ និមិត្ត ដែលបានចូលទៅចងទុក (ដោយសតិ គឺនៅត្រង់ចុងច្រមុះ ឬនៅត្រង់ផ្ទៃបបូរមាត់ខាងលើ) ។*

**"អនារម្មណមេកចិត្តស្ស"តិ ឯកស្ស ចិត្តស្ស ន អារម្មណំ, អារម្មណំ ន ហោន្តីតិ អត្ថោ ។**

*បទថា "**អនារម្មណមេកចិត្តស្ស** ប្រែថា មិនមែនជាអារម្មណ៍របស់ចិត្តមួយដួងទេ" មានន័យសេចក្តីថា មិនបានជាអារម្មណ៍, គឺ មិនមែនជាអារម្មណ៍ ដែលច្រើនអារម្មណ៍សម្រាប់ចិត្តមួយដួងនោះទេ(ចិត្ត មួយដួង មានអារម្មណ៍តែមួយ) ។*

**"អជានតោ ច តយោ ធម្មេ"តិ និមិត្តំ អស្សាសោ បស្សាសោតិ ឥមេ តយោ ធម្មេ អារម្មណករណវសេន អវិន្ទន្តស្ស ។**

*ពាក្យថា "**ប៉ុន្តែ កាលយោគីភិក្ខុ មិនដឹងនូវធម៌ទាំង ៣ យ៉ាង**" មានន័យថា កាលយោគីភិក្ខុ មិនដឹងនូវធម៌ទាំង ៣ យ៉ាងនេះ គឺនិមិត្ត (នៅត្រង់ចុងច្រមុះ ឬនៅត្រង់ផ្ទៃបបូរមាត់ខាងលើ) ១, ខ្យល់ដង្ហើមចូល ២, និងខ្យល់ដង្ហើមចេញ ៣, ដែលជាប់ទាក់ទងក្នុងការធ្វើឱ្យមកជាអារម្មណ៍ (ក្នុងការបដិបត្តិ) ។*

**ច-សទ្ទោ ព្យតិរេកោ ។ "ភាវនា"តិ អានាបានស្សតិសមាធិភាវនា ។**

*ច សព្ទ ប្រព្រឹត្តិទៅក្នុងអត្ថថា* **ព្យតិរេកោ** *ប្រែថា* **ប៉ុន្តែ** *។ ពាក្យថា "**ភាវនា**" គឺការចម្រើននូវអានាបានស្សតិសមាធិភាវនា ។*

"**នុបលព្ភតី**"តិ ន ឧបលព្ភតិ ន សិជ្ឈតីតិ ។ អយំ ចោទនាគាថាយ អត្ថោ, ទុតិយា បន បរិហារគាថា សុវិញ្ញេយ្យាវ ។

*បទថា "**នុបលព្ភតិ**" កាត់បទទៅជា **ន ឧបលព្ភតិ** ប្រែថា **សម្រេចមិនបាន** ។ នេះជាសេចក្តីនៃការ **ចោទនាគាថា** ជាគាថាដែលចោទសួរ ហើយជាគាថាទី ១, ចំណែក **បរិហារគាថា** គាថាឆ្លើយ គឺជាគាថាទី ២ ដែលមានអត្ថសេចក្តីដឹងបានដោយងាយ ។*

"**កថ**"ន្តិ តាសំ អត្ថំ វិវរិតុំ កថេតុកម្យតាបុច្ឆា ។

*ពាក្យថា "**កថំ** ប្រែថា **តើដូចម្តេច?** នេះជា **កថេតុកម្យតាបុច្ឆា** ជាការប្រាថ្នានឹងបើកបង្ហាញនូវអត្ថសេចក្តីនៃគាថាទាំងនោះ ។*

"**ឥមេ តយោ ធម្មា**"តិអាទីសុ បនយោជនាយ សទ្ធិំ អយមត្ថនិទ្ទេសោ –

*វិនិច្ឆ័យដែលសម្តែងខែអធិប្បាយនូវអត្ថ ព្រមទាំងពាក្យប្រកបបទក្នុងពាក្យថា "**ធម៌ទាំងឡាយ ៣ យ៉ាងនេះ**" ជាដើមនេះ មានន័យសេចក្តីថា*

ឥមេ និមិត្តាទយោ តយោ ធម្មា ឯកចិត្តស្ស កថំ អារម្មណំ ន ហោន្តិ។

*ធម៌ទាំងឡាយ ៣ យ៉ាង ដែលមាននិមិត្ត ជាដើមទាំងនេះ មិនមែនជាអារម្មណ៍របស់ចិត្តមួយដួង តើដូចម្តេច?,*

តថាបិ ន ចិមេ ន ច ឥមេ តយោ ធម្មា អវិទិតា ហោន្តិ។

*ប៉ុន្តែ សូម្បីយ៉ាងនោះ ធម៌ទាំង ៣ យ៉ាងនេះ មិនមែន ព្រះយោគាវចរភិក្ខុ មិនដឹងទេ ។*

កថំ ន ច ហោន្តិ អវិទិតា? តេសញ្ហិ អវិទិតត្តេ ចិត្តញ្ច កថំ វិក្ខេបំ ន គច្ឆតិ ។

*ឈ្មោះថា ព្រះយោគាវចរភិក្ខុដែលមិនដឹង តើមិនដឹងដូចម្ដេច ? ក៏កាលយោគីភិក្ខុមិនដឹងនូវធម៌ទាំងនោះហើយ ទាំងចិត្ត មិនដល់នូវសេចក្ដីពយមាយ តើដូចម្ដេច ?,*

**បធានញ្ច ភាវនាយ និប្ផាទកំ វីរិយញ្ច កថំ បញ្ញាយតិ។**

*ទាំង* **បធាន** *គឺសេចក្ដីព្យាយាមដែលធ្វើការភាវនាឱ្យសម្រេចនិងប្រាកដដូចម្ដេច ?។*

**នីវរណានំ វិក្ខម្ភកំ សម្មទេវ សមាធានាវហំ ភាវនានុយោគសង្ខាតំ បយោគញ្ច យោគី កថំ សាធេតិ។**

*ទាំងបយោគ ពោលគឺការប្រព្រឹត្តិជាប់តគ្នារឿយៗ នូវភាវនាដែលបានគ្រប់គ្រងនីវរណធម៌ហើយនាំមកនូវភាពតាំងមាំ ដោយប្រពៃ ព្រះយោគាវចរភិក្ខុគប្បីធ្វើឱ្យសម្រេច តើដូចម្ដេច ?*

**ឧបរូបរិ លោកិយលោកុត្តរញ្ច វិសេសំ កថមធិគច្ឆតីតិ ។**

*និងបានទម្ងុះនូវគុណវិសេស ដែលជាលោកីយ៍ និងលោកុត្តរ តើដូចម្ដេច ? ដូច្នេះ ។ (នេះជាសំនួរ ហើយព្រះសារីបុត្តថេរបានឆ្លើយទៅតាមលំដាប់ថា )។*

**ឥទានិ តមត្ថំ កកចូបមាយ សាធេតុំ "សេយ្យថាបី"តិអាទិ វុត្តំ ។**

*ឥឡូវនេះ ព្រះសារីបុត្តថេរប្រាថ្នានឹងធ្វើនូវសេចក្ដីនោះឱ្យសម្រេច ដែលមានការឧបមាដោយរណារដៃ ទើបសម្ដែងថា "***សេយ្យថាបិ***" ជាដើម ។*

**ភូមិភាគស្ស វិសមតាយ ចញ្ចលេ រុក្ខេ ឆេទនកិរិយា ន សុករា សិយា, តថា ច សតិ កកចទន្តគតិ ទុព្វិញ្ញេយ្យាតិ អាហ "សមេ ភូមិភាគេ"តិ ។**

*កិរិយាការកាត់នូវដើមឈើដែលប៉ាក់ប៉ើកៗ ព្រោះតែមានទីកន្លែងមិន*

*រាបស្មើ មិនអាចធ្វើការបានស្រួល, កាលបើដូច្នោះ គតិ គឺការទៅ និងការមកវិញរបស់ធ្មេញរណារ នឹងដឹងបានដោយលំបាក ព្រោះហេតុនោះ លោកទើបពោលថា "**លើទឹកន្ទែង ដែលរាបស្មើ**" ដូច្នេះ ។*

**"ककचेना"**តិ ខុទ្ទកេន ខរបត្តេន។ តេនាហ **"បុរិសោ"**តិ ។

*ពាក្យថា "**ប្រើរណារដៃ**" គឺប្រើរណារខ្នាតតូច (គឺរណារអារដោយដៃ) ។ ព្រោះហេតុនោះ លោកទើបពោលថា "**បុរស**" ដូច្នេះ (គឺបុរស អ្នកប្រើរណារដៃ មិនមែនប្រើគ្រឿងយន្តនោះទេ ដូច្នេះទើបជារណារដែលមានខ្នាតតូចក្នុងទីនេះ) ។*

**"ផុដ្ឋកកចទន្តាន"**ន្តិ ផុដ្ឋផុដ្ឋកកចទន្តានំ វសេន ។

*ពាក្យថា "**ត្រង់ធ្មេញរណារដែលពាល់ត្រូវហើយៗ**" គឺដោយអំណាចនៃធ្មេញរណារដៃ ដែលពាល់ត្រូវហើយៗ ។*

តេន ककចទន្តេហិ ផុដ្ឋផុដ្ឋដ្ឋានេយេវ បុរិសស្ស សតិយា ឧបដ្ឋានំ ទស្សេតិ ។

*ដោយពាក្យនោះ លោកសម្តែងដល់ការដែលបុរសមានសតិ ចូលទៅតម្កល់ទុក ត្រង់កន្ទែងដែលធ្មេញរណារដៃពាល់ត្រូវហើយៗ (នូវដើមឈើនោះ) ។*

តេនាហ **"ន អាគតេ វា គតេ វា ककចទន្តេ មនសិ ករោតី"**តិ ។

*ព្រោះហេតុនោះ ទើបលោកពោលថា "**មិនយកចិត្តទុកដាក់នូវធ្មេញរណារដែលមក និងទៅទេ**" ដូច្នេះ ។*

ककចស្ស អាកឌ្ឍនកាលេ បុរិសាភិមុខំ បវត្តា អាគតា ។ បេល្លនកាលេ តតោ វិគតា "គតា"តិ វុត្តា ។

*ធ្មេញរណារដែលប្រព្រឹត្តទៅនៅត្រង់ខាងមុខរបស់បុរសនោះ ក្នុងពេល*

*ដែលទាញរណារមក (ពេលនោះ) ហៅថា មក ។ ដែលផ្លាស់ប្ដូរអំពីត្រង់នោះ ក្នុងពេលរុញច្រានរណារទៅ (ពេលនោះ) ហៅថា ទៅ" ។*

**ន ច អាគតា វា គតា វា ករកចទន្តា អវិទិតា ហោន្តិ សព្វត្ថ សតិយា ឧបដ្ឋិតត្តា ធិដ្ឋិតព្វដ្ឋានំ អផុសិត្វា គច្ឆន្តានំ, អាគច្ឆន្តានញ្ច ករកចទន្តានំ អភាវតោ ។**

*ប៉ុន្តែ ដែលឈ្មោះថា **ធ្មេញរណារដែលមក និងទៅ មិនមែនគេមិនដឹងទេ** ព្រោះការដែលមានសតិចូលទៅតម្កល់ទុក នៅត្រង់ធ្មេញរណារទាំងអស់នោះ (គឺទាំងមក និងទៅ) ព្រោះធ្មេញរណារដែលកំពុងទៅ និងកំពុងមក ដែលថា មិនបានពាល់ត្រូវនូវកន្លែងដែលកាត់ឈើ នោះមិនមានឡើយ ។*

**"បធាន"ន្តិ រុក្ខស្ស ឆេទនវីរិយំ ។**

*ពាក្យថា "**ទាំងសេចក្ដីព្យាយាម**" បានដល់ សេចក្ដីព្យាយាមក្នុងការកាត់ដើមឈើ ។*

**"បយោគ"ន្តិ តស្សេវ ឆេទនកិរិយំ ។**

*ពាក្យថា "**ទាំងសេចក្ដីខិតខំប្រឹងប្រែង**" បានដល់ កិរិយាដែលកាត់ដើមឈើនោះ នុ៎ះឯង ។*

**"វិសេស"ន្តិ អនេកភាវចាតនំ, តេន ច សាធេតព្វំ បយោជនវិសេសំ ។**

*ពាក្យថា "**គុណវិសេស**" បានដល់ ការធ្វើឱ្យបានច្រើនកំណាត់, និងជាប្រយោជន៍ផ្សេងៗ ដែលគប្បីធ្វើឱ្យបានសម្រេច អំពីដើមឈើនោះ ។*

**"យថា រុក្ខោ"តិអាទិ ឧបមាសំសន្ទនំ ។**

*ពាក្យថា "**យថា រុក្ខោ**" ជាដើម ជាពាក្យប្រៀបធៀប ជាមួយ **ឧបមា** ។*

**ឧបនិពន្ធតិ អារម្មណេ ចិត្តំ ឯតាយាតិ សតិ ឧបនិពន្ធនា នាម,**

**តស្សា អស្សាសបស្សាសានំ សល្លក្ខណស្ស និមិត្តន្តិ ឧបនិពន្ធនានិ-មិត្តំ, នាសិកគ្គំ, មុខនិមិត្តំ វា ។**

*សតិ ឈ្មោះថា* **ឧបនិពន្ធនា** *ព្រោះអត្ថថា ជាគ្រឿងចូលទៅចងចិត្តទុកក្នុងអារម្មណ៍, នៅត្រង់ចុងច្រមុះ, ឬនៅត្រង់ផ្ទៃបបូរមាត់ខាងលើ, ហៅថា* **ឧបនិពន្ធនានិមិត្ត** *ព្រោះអត្ថថា ជានិមិត្ត (គឺទីកន្លែងដែលត្រូវកំណត់) សម្រាប់កំណត់ដឹងនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ នៃសតិ ដែលហៅថា* **ឧបនិពន្ធនា** *នោះ ។*

**"ឯវមេវា"តិ យថាបិ សោ បុរិសោ កកចេន រុក្ខំ ឆិន្ទន្តោ អាគតគតេ កកចទន្តេ អមនសិការោន្តោបិ ផុដ្ឋផុដ្ឋដ្ឋានេយេវ សតិយា ឧបដ្ឋបនេន អាគតគតេ កកចទន្តេ ជានាតិ, សុត្តបទញ្ច អវិជ្ជហន្តោ អត្ថកិច្ចំ សាធេតិ, ឯវមេវ ។**

*ពាក្យថា "***ឯវមេវ***" មានន័យថា បុរសនោះ កាលប្រើរណារដៃ អារកាត់នូវដើមឈើ សូម្បីមិនយកចិត្តទុកដាក់ទៅនឹងធ្មេញរណារ ដែលកំពុងមក និងទៅវិញ ក៏ដឹងច្បាស់នូវធ្មេញរណារ ដែលមក និងទៅ ដោយការប្រើសតិចូលទៅតម្កល់ទុកនៅត្រង់កន្លែង ដែលធ្មេញរណារបានពាល់ត្រូវហើយៗ នុ៎ះឯង, ហើយកាលដែលមិនធ្វើនូវគន្លង គឺស្នាមជ្រលងនៃធ្មេញរណារឱ្យខុសទៅទីដទៃ រមែងធ្វើកិច្ចនៃប្រយោជន៍ឱ្យបានសម្រេច យ៉ាងណាមិញ, ព្រះយោគាវចរភិក្ខុរូបនោះក៏យ៉ាងនោះដូចគ្នា ។*

**"នាសិកគ្គេ មុខនិមិត្តេ"**តិ ទីឃនាសិកោ នាសិកគ្គេ ឥតរោ មុខំ ឧសដំ និមីយតិ ឆាទីយតិ ឯតេនាតិ មុខនិមិត្តន្តិ លទ្ធនាមេ ឧត្តរោដ្ឋេ ។

*ពាក្យថា "***នៅត្រង់ចុងច្រមុះ ឬនៅត្រង់ផ្ទៃបបូរមាត់ខាងលើ***" មានន័យថា ព្រះយោគាវចរភិក្ខុ ដែលមានច្រមុះវែងក៏ចូលទៅតម្កល់សតិនៅត្រង់ចុងច្រមុះ ព្រះយោគាវចរភិក្ខុដែលមានច្រមុះខ្លី ក៏ចូលទៅតម្កល់សតិនៅត្រង់លើផ្ទៃ*

*បបូរមាត់ខាងលើ ទើបបានឈ្មោះថា* **មុខនិមិត្ត** *ព្រោះអត្ថថា ជាហេតុនាំឱ្យកំណត់បាន គឺកំណត់បានថា វាជា* **មុខ** *គឺជាច្រកដែលបញ្ចូលនូវរបស់បរិភោគ ។*

**"ឥទំ បធាន"** ន្តិ យេន វីរិយារម្ភេន អារទ្ធវីរិយស្ស យោគិនោ កាយោបិ ចិត្តម្បិ កម្មនិយំ ភាវនាកម្មក្ខមំ ភាវនាកម្មយោគ្គំ ហោតិ, ឥទំ វីរិយំ បធានន្តិ ផលេន ហេតុំ ទស្សេតិ ។

*ពាក្យថា "**នេះឈ្មោះថា បធាន**" មានន័យសេចក្ដីថា លោកបានសម្ដែងនូវហេតុទុក ដោយជាផលថា ទាំងកាយ ទាំងចិត្ត របស់ព្រះយោគាវចរអ្នកប្រារព្ធនូវសេចក្ដីព្យាយាម រមែងជាធម្មជាតិគួរដល់ការងារ គឺគួរដល់ការងាររបស់ភាវនា ដោយអាស្រ័យសេចក្ដីព្យាយាមខាងដើម, សេចក្ដីព្យាយាមនេះហើយឈ្មោះថា បធាន ។*

**"ឧបក្កិលេសា បហីយន្តី"** តិ ចិត្តស្ស ឧបក្កិលេសភូតានិ នីវរណានិ វិក្ខម្ភនវសេន បហីយន្តិ ។

*ពាក្យថា "**ឧបក្កិលេសទាំងឡាយ រមែងត្រូវលះចេញ**" មានន័យថា នីវរណធម៌ទាំងឡាយ ដែលជាគ្រឿងសៅហ្មងរបស់ចិត្ត រមែងត្រូវលះចេញដោយអំណាច វិក្ខម្ភនបហាន ។*

**"វិតក្កា វូបសមន្តី"** តិ តតោ ឯវ កាមវិតក្កាទយោ មិច្ឆាវិតក្កា ឧបសមំ គច្ឆន្តិ, នីវរណប្បហានេន វា បឋមជ្ឈានាធិគមំ ទស្សេត្វា វិតក្កវូបសមាបទេសេន ទុតិយជ្ឈានាធិគមមាហ ។

*ពាក្យថា "**វិតក្កៈទាំងឡាយ រមែងស្ងប់ទៅ**" មានន័យថា ព្រោះហេតុដែលឧបក្កិលេសទាំងឡាយត្រូវបានលះចេញទៅនុ៎ះឯង មិច្ឆាវិតក្កៈទាំងឡាយដែលមានកាមវិតក្កៈ ជាដើម បានដល់ភាពស្ងប់ស្ងាត់, ន័យម្យ៉ាងទៀត លោកសម្ដែងថា កាលបានទម្លុះនូវបឋមជ្ឈាន ចាត់ទុកថាជាការបានលះនូវនីវរណធម៌ ហើយ*

*បានពោលដល់ការទម្លុះនូវ ទុតិយជ្ឈាន ជាដើម ជាការចង្អុលបង្ហាញដល់ភាពស្ងប់ស្ងាត់នៃវិតក្កៈ ។*

**"អយំ បយោគោ"តិ** អយំ ឈានាធិគមស្ស ហេតុភូតោ កម្មដ្ឋានានុយោគោ បយោគោ ។

*ពាក្យថា "**នេះឈ្មោះថា បយោគ**" មានន័យថា ការចម្រើននូវកម្មដ្ឋាន វាជាហេតុនៃការទម្លុះនូវឈាន នេះឈ្មោះថា បយោគ ។*

**"សំយោជនា បហីយន្តី"តិ** ទសបិ សំយោជនានិ មគ្គបដិបាដិយា សមុច្ឆេទវសេន បហីយន្តិ ។

*ពាក្យថា "**សំយោជនៈទាំងឡាយ រមែងត្រូវបានលះ**" មានន័យថា សំយោជនៈទាំង ១០ យ៉ាង រមែងត្រូវលះចេញ ដោយអំណាចនៃសមុច្ឆេទបហាន ។*

**"អនុសយា ព្យន្តី ហោន្តី"តិ** តថា សត្តបិ អនុសយា អនុប្បត្តិធម្មតាបាទ-នេន ភង្គមត្តស្សបិ អនវសេសតោ វិគតន្តា ហោន្តិ ។

*ពាក្យថា "**អនុស័យទាំងឡាយ ក៏ត្រូវអស់ទៅ**" មានន័យថា អនុស័យទាំង ៧ យ៉ាងនោះ ជាធម្មជាតិដែលប្រាសចេញទៅហើយ ដោយមិនមានសេសសល់ សូម្បីត្រឹមតែការរលត់ទៅហើយមិនឱ្យកើតឡើងមកវិញ ជាធម្មតា ។*

ឯត្ថ ច សំយោជនប្បហានំ នាម អនុសយនិរោធេនេវ ហោតិ, បហីនេសុ ច សំយោជនេសុ អនុសយានំ លេសោបិ ន ភវិស្សតីតិ ចទស្សនត្ថំ "**សំយោជនា បហីយន្តិ អនុសយា ព្យន្តី ហោន្តី**"តិ វុត្តំ ។

*ក្នុងសេចក្តីនេះ ព្រះអាចារ្យប្រាថ្នានឹងសម្តែងថា ឈ្មោះថា ការលះនូវសំយោជនៈ រមែងមាន ដោយការរលត់ទៅនៃអនុស័យ ប៉ុណ្ណោះ, និងកាលសំយោជនៈទាំងឡាយ ត្រូវបានលះទៅហើយ សូម្បីអនុស័យដែលនឹងដេកត្រាំនៅ ក៏មិនមាន ដូច្នេះ ទើបលោកពោលថា "**សំយោជនៈទាំងឡាយ រមែងត្រូវលះ***

*ទៅ អនុស័យទាំងឡាយ ក៏ត្រូវអស់ទៅដែរ” ដូច្នេះ ។*

“**អយំ វិសេសោ**”តិ ឥមំ សមាធឹ និស្សាយ អនុក្កមេន លព្ភមានោ អយំ សំយោជនប្បហានាទិកោ ឥមស្ស សមាធិស្ស វិសេសោតិ អត្ថោ។

*ពាក្យថា “**នេះឈ្មោះថា គុណវិសេស**” មានន័យថា គុណវិសេស មានការលះនូវសំយោជនៈ ជាដើមនេះ ដែលព្រះយោគាវចរបានអាស្រ័យនូវសមាធិនេះ ទៅតាមលំដាប់ ឈ្មោះថា គុណវិសេសរបស់សមាធិនេះ ។*

“**យស្សា**”តិ យេន ។ “**អនុបុព្វ**”ន្តិ អនុក្កមេន ។ “**បរិចិតា**”តិ បរិចិណ្ណា ។

*បទថា “**យស្ស**” កែមកជា យេន ។ បទថា “**អនុបុព្វំ**” ប្រែថា **តាមលំដាប់** ។ បទថា “**បរិចិតា**” ប្រែថា **សន្សំហើយ** ។*

អយំ ហេត្ថ សង្ខេបត្ថោ –

*សេចក្តីសង្ខេបនៅក្នុងគាថានេះថា ៖*

**អានាបានស្សតិ យថា ពុទ្ធេន ភគវតា ទេសិតា, តថេវ យេន ធីរស្សបជានជាតិវិធិនា អនុបុព្វំ បរិចិតា សុដ្ឋុ ភាវិតា, តតោ ឯវ បរិបុណ្ណា សោឡសន្នំ វត្ថូនំ ចារិប្ចូរិយា សព្វសោ បុណ្ណា ។**

*អានាបានស្សតិ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សម្តែងទុកហើយយ៉ាងណា, ព្រះយោគាវចរភិក្ខុរូបណាដែលសន្សំហើយ ចម្រើនបានល្អទៅតាមលំដាប់ តាមប្រការនោះ ទុំៈឯង តាមវិធីដែលមានការដឹងច្បាស់នូវខ្យល់ដង្ហើមចូលវែង និងខ្យល់ដង្ហើមចូលខ្លី ជាដើម, ដែលជាហេតុធ្វើឱ្យបរិបូរណ៍ គឺពេញបរិបូរណ៍ ដោយប្រការទាំងពួង ព្រោះសេចក្តីបរិបូរណ៍នៃរឿងទាំង ១៦ ចំណុច ។*

សោ ភិក្ខុ ឥមំ អត្តនោ ខន្ធាទិលោកំ បញ្ញាភាសេន បភាសេតិ ។

*ព្រះយោគាវចរភិក្ខុរូបនោះ រមែងធ្វើលោក គឺមានខន្ធលោក ជាដើមនេះ ឱ្យភ្លឺស្វាង ដោយពន្លឺ គឺបញ្ញា ។*

**យថា កឹ អព្ភា មុត្តោវ ចន្ទិមា អព្ភុបក្កិលេសវិមុត្តោ ចន្ទិមា តារកាភាជា វិយាតិ ។**

*តើដូចអ្វី ? គឺដូចព្រះចន្ទដែលផុតចាកពពក គឺដូច ចន្ទិមា ដែលជារាជា នៃដួងផ្កាយ ដែលផុតហើយចាកគ្រឿងសៅហ្មង គឺពពក ដូច្នោះ ។*

**"ឥធា"តិ កាកចូបមាយំ ។ "អស្សា"តិ យោគិនោ ។**

*បទថា* **"ឥធ"** *ប្រែថា ក្នុងរឿងឧបមាដោយរណារដៃនេះ ។ បទថា* **"អស្ស"** **យោគ យោគិនោ** *បានដល់ ព្រះយោគាវចរ ។*

**"ឥធា"តិ វា ឥមស្មិំ ឋានេ ។ "អស្សា"តិ ឧបមាភូតស្ស កាកចស្ស ។**

*ន័យម្យ៉ាងទៀត បទថា* **"ឥធ** *ប្រែថា ក្នុងទីកន្លែងនេះ" ។ បទថា* **"អស្ស** *បានដល់ រណារដៃ ដែលជាតួឧបមា ។*

**អាគតគតវសេន យថា តស្ស បុរិសស្ស អមនសិការោ, ឯវំ អស្សាសបស្សាសានំ អាគតគតវសេន អមនសិការមត្តមេវ បយោជនំ ។**

*មានសេចក្តីថា កាលដែលមិនយកចិត្តទុកដាក់ ទៅនឹងធ្មេញរណារ ដែលមក និងទៅ ចាត់ជាកិច្ចដែលបុរសនោះគប្បីធ្វើ យ៉ាងណាមិញ, គ្រាន់តែ ការមិនយកចិត្តទុកដាក់ជាមួយខ្យល់* ***អស្សាស*** *ខ្យល់ដង្ហើមចូល និង* ***បស្សាស*** *ខ្យល់ដង្ហើមចេញ ដែលមក និងទៅ (ហើយមកដឹងនៅត្រង់កន្លែងខ្យល់ដែលពាល់ត្រូវហើយៗ)* **ប៉ុណ្ណោះ** *ចាត់ថាជាកិច្ចដែលព្រះយោគាវចររូបនោះ គប្បីធ្វើ ក៏យ៉ាងនោះដែរ ។*

## ការកើតឡើងនៃបរិកម្មនិមិត្ត

(វិសុទ្ធិមគ្គ)

[២២៨] ឥទំ កម្មដ្ឋានំ មនសិករោតោ កស្សចិ ន ចិរេនេវ និមិត្តញ្ច ឧប្បជ្ជតិ, អវសេសឈានង្គបដិមណ្ឌិតា អប្បនាសង្ខាតា ឋបនា ច សម្បជ្ជតិ ។

*សម្រាប់ព្រះយោគាវចរ ដែលបានមនសិការនូវកម្មដ្ឋាននេះ អ្នកខ្លះមាននិមិត្តកើតឡើង (គឺបដិភាគនិមិត្ត), និង* **ឋបនា** *ពោលគឺ* **អប្បនា** *ដែលប្រដាប់ដោយអង្គឈានដ៏សេស ថែមទាំងបានសម្រេចនូវឈាន ដោយមិនយឺតយូរឡើយ ។*

កស្សចិ បន គណនាវសេនេវ មនសិការកាលតោ បភុតិ អនុក្កមតោ ឱឡារិកអស្សាសបស្សាសនិរោធវសេន កាយទរថេ វូបសន្តេ កាយោបិ ចិត្តម្បិ លហុកំ ហោតិ, សរីរំ អាកាសេ លង្ឃនាការប្បត្តំ វិយ ហោតិ ។

*ប៉ុន្តែ សម្រាប់ព្រះយោគាវចររូបខ្លះ កាលបានរម្ងាប់នូវភាពរសាប់រសល់នៃកាយ ដោយអំណាចរលត់បាត់ទៅនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលគ្រោតគ្រាតទៅតាមលំដាប់ ដែលចាប់ផ្តើមតាំងតែពេលមនសិការ ដោយអាស្រ័យនៃការបរិកម្មរាប់ បានធ្វើឱ្យទាំងកាយ ទាំងចិត្ត រមែងជាធម្មជាតិដែលមានសភាពស្រាលទៅៗដល់រាងកាយ, រាងកាយហាក់បីដូចជាអណ្តែតទៅក្នុងអាកាស ។*

យថា សារទ្ធកាយស្ស មញ្ចេ វា បីឋេ វា និសីទតោ មញ្ចបីឋំ ឱនមតិ, វិកូជតិ, បច្ចត្ថរណំ វលី គណ្ហាតិ ។

*ប្រៀបដូចជា កាលបុរសម្នាក់ បានអង្គុយនៅលើគ្រែ ឬក៏តាំង មានកាយរសាប់រសល់ គ្រែ ឬក៏តាំងនោះ រមែងយេកយោក និងលាន់ឮសំឡេង, គ្រឿង*

*កម្រាល ក៏រមែងទក់ខ្ទេចខ្ទី ។*

**អសារទ្ធកាយស្ស បន និសីទតោ នេវ មញ្ចបីឋំ ឱនមតិ, ន វិកូជតិ, ន បច្ចត្ថរណំ វលី គណ្ហាតិ, តូលបិចុបូរិតំ វិយ មញ្ចបីឋំ ហោតិ ។**

*ប៉ុន្តែ កាលបុរសម្នាក់នោះ បានអង្គុយនៅលើគ្រែ ឬក៏តាំង មានកាយមិនរសាប់រសល់ គ្រែ ឬក៏តាំងនោះ រមែងមិនយេកយោក និងមិនលាន់ឮសំឡេងឡើយ, ថែមទាំងគ្រឿងកម្រាល ក៏មិនទក់ខ្ទេចខ្ទី ហើយគ្រែ ឬក៏តាំងនោះហាក់បីដូចជាដុំសំឡី ។*

**កស្មា? យស្មា អសារទ្ធោ កាយោ លហុកោ ហោតិ ។**

*តើព្រោះហេតុអ្វី? គឺព្រោះតែកាយ មិនមានភាពរសាប់រសល់ រមែងជាធម្មជាតិ ដែលស្រាលៗ យ៉ាងណាមិញ ។*

**១. ឯវមេវ គណនាវសេន មនសិការកាលតោ បភុតិ អនុក្កមតោ ឱឡារិកអស្សាសបស្សាសនិរោធវសេន កាយទរថេ វូបសន្តេ កាយោបិ ចិត្តម្បិ លហុកំ ហោតិ, សរីរំ អាកាសេ លង្ឃនាការប្បត្តំ វិយ ហោតិ ។**

*កាលភាពរសាប់រសល់នៃកាយ បានស្ងប់រម្ងាប់ទៅហើយ ដោយអំណាចនៃការរលត់បាត់ទៅនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលមានសភាពគ្រោតគ្រាតទៅតាមលំដាប់ គឺចាប់ផ្ដើមតាំងតែពេលបានមនសិការ ដោយអាស្រ័យនៃការបរិកម្មរាប់ ទាំងកាយ ទាំងចិត្ត រមែងជាធម្មជាតិ ដែលស្រាលៗ, ពេលនោះរាងកាយ ប្រៀបដូចជា បានអណ្ដែតទៅក្នុងអាកាស ដូច្នោះ នុ៎ះឯង ។*

**២. តស្ស ឱឡារិកេ អស្សាសបស្សាសេ និរុទ្ធេ សុខុមស្សាសបស្សាសនិមិត្តារម្មណំ ចិត្តំ បវត្តតិ ។**

*កាលខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលគ្រោតគ្រាតៗ របស់ព្រះយោគាវចរនោះ រលត់បាត់ទៅហើយ ចិត្តដែលមាននិមិត្ត (គឺអាការៈដែល*

*ប្រព្រឹត្តិទៅ) នៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលល្អិតសុខុមនោះ មកជាអារម្មណ៍ ហើយក៏រមែងប្រព្រឹត្តទៅ ។*

**៣. តស្មិម្បិ និរុទ្ធេ អបរាបរំ តតោ សុខុមតរំ សុខុមតរំ និមិត្តារម្មណំ បវត្តតិយេវ ។**

*សូម្បីកាលចិត្ត ដួងណាមួយដែលមាននិមិត្តនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលល្អិតសុខុមមកជាអារម្មណ៍នោះ ហើយបានរលត់បាត់ទៅវិញ ចិត្តដួងតៗ មកទៀត ដែលមាននិមិត្តនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ល្អិតសុខុមក្រៃលែងជាងនោះ មកធ្វើជាអារម្មណ៍ ហើយក៏រមែងប្រព្រឹត្តទៅទៀត (នេះហៅថា លក្ខណៈរបស់បរិកម្មនិមិត្ត) ។*

**កថំ? យថា បុរិសោ មហតិយា លោហសលាកាយ កំសថាលំ អាកោដេយ្យ, ឯកប្បហារេន មហាសទ្ទោ ឧប្បជ្ជេយ្យ, តស្ស ឱឡារិកសទ្ទារម្មណំ ចិត្តំ បវត្តេយ្យ ។**

*តើប្រៀបធៀបដូចនឹងអ្វី? គឺប្រៀបធៀបដូចជា មានបុរសម្នាក់បានគោះដួង ដោយដុំលោហៈមួយ, ពេលនោះសំឡេងបានឮខ្លាំង ក៏កើតឡើង ដោយអាការៈបានគោះដួងនៅលើកទី ១ នោះ, ចិត្តរបស់បុរសនោះ ក៏មានសំឡេងដែលគ្រោតគ្រាតនោះ (គឺសំឡេងឮខ្លាំង) មកជាអារម្មណ៍ គប្បីប្រព្រឹត្តទៅ (គឺបានចាំនូវសំឡេងគ្រោតគ្រាតនោះ) ។*

**និរុទ្ធេ ឱឡារិកេ សទ្ទេ អថ បច្ឆា សុខុមសទ្ទនិមិត្តារម្មណំ, តស្មិម្បិ និរុទ្ធេ អបរាបរំ តតោ សុខុមតរំ សុខុមតរំ សទ្ទនិមិត្តារម្មណំ បវត្តតេវ, ឯវន្តិ វេទិតព្វំ ។**

*កាលសំឡេងគ្រោតគ្រាត បានរលត់បាត់ទៅហើយ តៗមកខាងក្រោយទៀត ចិត្តក៏មាននិមិត្តនៃសំឡេងដែលល្អិតសុខុមនោះ មកធ្វើជាអារម្មណ៍ ហើយក៏រមែងប្រព្រឹត្តទៅ, សូម្បីកាលចិត្តដួងនោះ ដែលមាននិមិត្តនៃសំឡេង*

*ដែលល្អិតសុខុមនោះមកជាអារម្មណ៍ ហើយក៏បានរលត់បាត់ទៅ ចិត្តដួងតៗមកទៀត ក៏មាននិមិត្តនៃសំឡេង ដែលល្អិតសុខុមក្រៃលែងជាងនោះទៀត មកធ្វើជាអារម្មណ៍ ហើយក៏រមែងប្រព្រឹត្តិទៅ, (ការឧបមា) យ៉ាងណា បណ្ឌិត គប្បីជ្រាបនូវសេចក្តីការឧបមេយ្យ ក៏យ៉ាងនោះចុះ ។*

**វុត្តម្បិចេតំ –**

*សេចក្តីនេះ សមដូចដែលលោកបានសម្តែងទុកថា៖*

**"សេយ្យថាបិ កំសេ អាកោដិតេ" តិ[៤៩] វិត្ថារោ ។**

"សេយ្យថាបិ កំសេ អាកោដិតេ" *ដូច្នេះ ជាដើម ចំណែកសេចក្តីពិស្តារ បណ្ឌិតគប្បីជ្រាបទៅតាមន័យ នៃបដិសម្ភិទាមគ្គ បិដក ៧០ [១១៤] ផងចុះ ។*

## ការកើតឡើងនៃបរិកម្មនិមិត្ត

### (មហាដីកាវិសុទ្ធិមគ្គ)

[២២៨] "**និមិត្ត**"ន្តិ បដិភាគនិមិត្តំ ។

*ពាក្យថា "**និមិត្ត**" បានដល់ បដិភាគនិមិត្ត ។*

**"អវសេសឈានង្គបដិមណ្ឌិតា"តិ** អប្បនាវិតក្កាទិអវសេសឈានង្គបដិមណ្ឌិតាតិ វទន្តិ, វិចារាទីតិ បន វត្តព្វំ និប្បរិយាយេន វិតក្កស្ស អប្បនាការតោ ។

*ពាក្យថា "ដែលប្រកបដោយអង្គឈានដ៏សេស" គឺព្រះអាចារ្យលោកបានពោលថា ដែលប្រកបដោយអង្គឈានដ៏សេសមានវិតក្កៈជាដើម ដូច្នេះ, តែលោកពោលពាក្យថា (អង្គឈាន) មានវិចារៈជាដើម ព្រោះវិតក្កៈជាអប្បនាដោយនិប្បរិយាយ (គឺដោយន័យត្រង់) ។*

---

៤៩ (បដិ. ម. បិ. ៧០ .[ ១១៤]) ។

សោ ហិ ចាត្ថិយំ "អប្បនា ព្យប្បនា"តិ[៤៦] និទ្ទិដ្ឋោ, តំសម្បយោគតោ វា យស្មា ឈានំ "អប្បនា"តិ អដ្ឋកថាវោហារោ, ឈានង្គេសុ ច សមាធិ បធានំ, តស្មា តំ "អប្បនា"តិ ឧស្សេត្តោ "**អវសេសឈានង្គបដិមណ្ឌិតា អប្បនាសង្ខាតា ឋបនា ច សម្បជ្ជតី**"តិ អាហ ។

*ពិតមែន វិតក្កៈនោះ ទ្រង់សម្ដែងទុកក្នុងព្រះបាលីថា "(**វិតក្កោ**) ឈ្មោះថា* **អប្បនា** (*ឈ្មោះថា*) **ព្យប្បនា**" *ព្រោះធម៌មានវិចារជាដើម សម្បយុត្តជាមួយវិតក្កៈ (ដែលជាអង្គឈាននោះ) ព្រោះមានពាក្យពោលដល់ឈានទុកក្នុងអដ្ឋកថា ថា "ជា* **អប្បនា**"*, និងក្នុងបណ្ដាអង្គឈានទាំងឡាយ សមាធិជាតួតម្កល់មាំ, ដូច្នោះ លោកអាចារ្យ កាលនឹងសម្ដែងនូវសមាធិនោះថា "ជា* **អប្បនា**" *ទើបពោលថា "**និង ឋបនា ពោលគឺ អប្បនា ដែលប្រកបដោយអង្គឈាន ដ៏សេស រមែងសម្រេច**" ដូច្នេះ ។*

**កស្សចិ បន គណនាវសេនេវ មនសិការកាលតោ បភុតីតិ** ឯត្ថ "**អនុក្កមតោ។...បេ...។ លង្ឃនាការប្បត្តំ វិយ ហោតី**"តិ ឯត្តកោ គន្ថោ បរិហីនោ ។

*ក្នុងពាក្យថា* "**កស្សចិ បន គណនាវសេនេវ មនសិការកាលតោ បភុតិ**" *នេះ មានបាឋៈត្រឹមតែប៉ុណ្ណេះ គឺ* "**អនុក្កមតោ។...បេ...។ លង្ឃនាការប្បត្តំ វិយ ហោតិ**" *បានដាច់បាត់ទៅ (ប៉ុន្តែ បច្ចុប្បន្ននេះ បានបញ្ចូលនូវអ្វីដែលបានបាត់ទៅនោះ ឱ្យបានគ្រប់បរិបូរណ៍មកវិញហើយ) ។*

**សារទ្ធកាយស្ស** កស្សចិ បុគ្គលស្ស ។

*សម្រាប់បុគ្គលរូបខ្លះ មានកាយរសាប់រសល់ ។*

**ឱនមតិ បដ្ដិកាជីនំ បលម្ពនេន** ។ "**វិកូជតី**"តិ សទ្ទំ ករោតិ ។

*គ្រែ ឬ តាំង ឈ្មោះថា រមែងយេកយោក ព្រោះការជ្រីវជ្រួញនៃកម្រាល*

---

៤៦ (*ធ. ស. ៧*) ។

*មានកម្រាលស្បែកជាដើម (ព្រោះកម្រាលស្បែករលោង)។ បទថា* ***"វិក្កូជតិ"*** *ប្រែថា* ***រមែងលាន់ឮសំឡេង*** *។*

**កត្ថាទិសុ ចក្កប្បរាជីនំ សន្ធិដ្ឋានេសុ វលី តណ្ហាតិ តត្ថ តត្ថ វលិតំ ហោតិ ។**

*ក្នុងទីនេះ គ្រឿងកម្រាល ឈ្មោះថា* ***រមែងទក់ខ្ទេចខ្ទី*** *គឺមានសភាពទក់នៅត្រង់ទីអង្គុយនោះៗ ។*

**កស្មា? យស្មា សារទ្ធកាយោ គរុកោ ហោតីតិ កាយទរថវូបសមេន សទ្ធឹ សិជ្ឈមានោ ឱឡារិកអស្សាសបស្សាសនិរោធោ ព្យតិរេកមុខេន តស្ស សាធនំ វិយ វុត្តោ ។**

*តើព្រោះហេតុអ្វី ? គឺព្រោះតែកាយ ដែលមានសភាពរសាប់រសល់ ជាធម្មជាតិមានទម្ងន់ធ្ងន់ ព្រោះហេតុនោះ លោកក៏ពោលដល់ភាពរលត់បាត់ទៅនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលគ្រោតគ្រាត សម្រេចទៅព្រមជាមួយភាពស្ងប់ស្ងាត់នៃសំឡេង ដែលរសាប់រសល់នៃកាយ ប្រៀបហាក់ដូចជាពោលនូវភាពរលត់បាត់ទៅនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនោះ ឱ្យសម្រេចជាពាក្យជំទាស់ដូច្នេះ ។*

**"ឱឡារិកអស្សាសបស្សាសនិរោធវសេនា"តិ អន្វយវសេន តទត្ថសាធនំ ។**

*ពាក្យថា* ***"ដោយអំណាចនៃការរលត់បាត់ទៅនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលគ្រោតគ្រាត"*** *ជាពាក្យដែលធ្វើនូវសេចក្តីកំណត់នោះឱ្យសម្រេច ដោយអាស្រ័យជាព្រះធម៌ប្រព្រឹត្តទៅស្របតាមគ្នា ។*

**តត្ថ "កាយទរថេ វូបសន្តេ"តិ ចិត្តជរូបានំ លហុមុទុកម្មញ្ញភាវេន យោ សេសតិសន្តតិរូបានម្បិ លហុអាទិភាវោ, សោ ឥធ កាយស្សលហុភាវោតិ អធិប្បេតោ ។**

*បណ្ដាពាក្យទាំងនោះ ពាក្យថា "**កាលភាពរសាប់រសល់នៃកាយ រលត់បាត់ទៅហើយ**" មានន័យថា សភាពជាធម្មជាតិដែលស្រាលៗ ជាដើម សូម្បីនៃសន្តតិរូប ដទៃទៀត ក៏រមែងមាន ព្រោះតែចិត្តជរូបទាំងឡាយ ជាធម្មជាតិស្រាលទន់ គួរដល់ការងារ, គឺជាធម្មជាតិដែលស្រាល ជាដើមនោះ លោកមានបំណងពោលថា ជាការស្រាលនៃរាងកាយក្នុងទីនេះ ។*

**ស្វាយំ យស្មា ចិត្តស្ស លហុអាទិភាវេន វិនា នត្ថិ, តស្មា វុត្តំ "កាយោបិ ចិត្តម្បិ លហុកំ ហោតី"តិ ។**

*ភាពជាធម្មជាតិដែលស្រាលជាដើមនៃរាងកាយនោះ ព្រោះហេតុដែលវៀរចាក នូវចិត្តនោះ គឺមិនមានឡើយ, ព្រោះហេតុនោះ ទើបលោកពោលថា "**ទាំងកាយ ទាំងចិត្ត ជាធម្មជាតដែលស្រាល**" ជាដើម ។*

**"ឱឡារិកេ អស្សាសបស្សាសេ និរុទ្ធេ"តិអាទិ ហេដ្ឋា វុត្តនយម្បិ វិចេតព្វាការប្បត្តស្ស កាយសង្ខារស្ស វិចយនវិធឹ ទស្សេតុំ អាដីតំ ។**

*ពាក្យថា "**កាលខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលគ្រោតគ្រាតៗ រលត់បាត់ទៅហើយ**" ជាដើម សូម្បីថា មានន័យដូចបានពោលមកហើយនៅខាងដើម លោកអាចារ្យក៏នាំមកពោល (ម្ដងទៀត) ដើម្បីសម្ដែងនូវវិធីពិនិត្យវិនិច្ឆ័យនូវកាយសង្ខារ ដែលដល់នូវអាការៈគួរនឹងស្វែងយល់ ។*

## មកដល់ខ្យល់ល្អិតសុខុម[៤៧]

### (វិសុទ្ធិមគ្គ)

[២២៩] យថា ហិ អញ្ញានិ កម្មដ្ឋានានិ ឧបរូបរិ វិភូតានិ ហោន្តិ, ន តថា ឥទំ ។

*ដូចជាកម្មដ្ឋានដទៃៗទៀត នឹងប្រាកដច្បាស់ឡើងទៅៗ យ៉ាងណាមិញ, អានាបានស្សតិកម្មដ្ឋាននេះ មិនមែនដូច្នោះឡើយ ។*

ឥទំ បន ឧបរូបរិ ភាវេន្តស្ស សុខុមត្តំ គច្ឆតិ, ឧបដ្ឋានម្បិ ន ឧបគច្ឆតិ, ឯវំ អនុបដ្ឋហន្តេ បន តស្មឹ តេន ភិក្ខុនា ឧដ្ឋាយាសនា ចម្មខណ្ឌំ បប្ផោដេត្វា ន គន្តព្វំ។

*ប៉ុន្តែ កម្មដ្ឋាននេះ កាលព្រះយោគាវចរ បានចម្រើនដោយល្អហើយ ក៏ដល់នូវសភាពល្អិតសុខុមក្រៃលែងនៃខ្យល់, រមែងចូលដល់នូវសភាពមិនប្រាកដច្បាស់, ប៉ុន្តែ កាលបើកម្មដ្ឋាននេះ មិនប្រាកដច្បាស់បែបនេះ ព្រះយោគាវចរភិក្ខុរូបនោះ មិនគួរក្រោកឡើងចាកអាសនៈ ហើយរលាស់នូវកម្រាលរួចដើរចេញទៅទេ ។*

កឹ កាតព្វំ? "អាចរិយំ បុច្ឆិស្សាមី"តិ វា, "នដ្ឋំ ទានិ មេ កម្មដ្ឋាន"ន្តិ វា ន វុដ្ឋាតព្វំ។

*សួរថា តើគួរធ្វើដូចម្តេច?*

*ឆ្លើយថា មិនគួរក្រោកឡើង ដោយគិតថា "យើងនឹងទៅសួរលោក-អាចារ្យ", ឬគិតថា "ពេលឥឡូវនេះ កម្មដ្ឋានរបស់យើង ខូចវិនាសហើយ" ដូច្នេះទេ ។*

ឥរិយាបថំ វិកោបេត្វា គច្ឆតោ ហិ កម្មដ្ឋានំ នវនវមេវ ហោតិ ។

---

*៤៧ សេចក្តីអធិប្បាយនៅក្នុងលំដាប់ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ។*

*ព្រោះថា កាលប្ដូរនូវឥរិយាបថទៅហើយ កម្មដ្ឋានក៏ប្រែក្លាយទៅជាកម្មដ្ឋានសាជាថ្មីមកវិញ ។*

តស្មា យថានិសិន្នេនេវ ទេសតោ អាហរិតព្វំ ។

*ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីអង្គុយនៅបន្តទៀត ទុំះឯង ហើយគប្បីកំណត់ដឹងនូវខ្យល់ដង្ហើមនៅកន្លែងដែលធ្លាប់ដឹង គឺបង្អោនសតិមកដឹងនៅត្រង់កន្លែងដែលខ្យល់ពាល់ត្រូវហើយៗទុំះឯង ។*

## ឧបាយ កំណត់ដឹងខ្យល់ឡើងវិញ

តត្រាយំ អាហរណូបាយោ, តេន ហិ ភិក្ខុនា កម្មដ្ឋានស្ស អនុបដ្ឋានភាវំ ញត្វា ឥតិ បដិសញ្ចិក្ខិតព្វំ, ឥមេ អស្សាសបស្សាសា នាម កត្ថ អត្ថិ, កត្ថ នត្ថិ ។

*ក្នុងការនាំខ្យល់មកវិញនោះ តទៅនេះ ជាការឧបមា ក្នុងការនាំខ្យល់ត្រឡប់មកវិញ, មានន័យថា ព្រះយោគាវចរភិក្ខុរូបនោះ បានជ្រាបនូវសភាវៈដែលកម្មដ្ឋានវាមិនប្រាកដបែបនេះហើយ ក៏គប្បីពិចារណាយ៉ាងនេះថា, ធម្មតាខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនេះ មានក្នុងទីណា, និងមិនមានក្នុងទីណា ។*

កស្ស វា អត្ថិ, កស្ស វា នត្ថីតិ ។

*មានដល់អ្នកណា, ឬថា នឹងមិនមានដល់អ្នកណា ។*

អថេវំ បដិសញ្ចិក្ខតា ឥមេ អន្តោមាតុកុច្ឆិយំ នត្ថិ, ឧទកេ និមុគ្គានំ នត្ថិ, តថា អសញ្ញីភូតានំ, មតានំ, ចតុត្ថជ្ឈានសមាបន្នានំ, រូបារូបភវសមង្គីនំ, និរោធសមាបន្នានន្តិ ញត្វា ឯវំ អត្តនាវ អត្តា បដិចោទេតព្វោ "ននុ ត្វំ, បណ្ឌិត, នេវ មាតុកុច្ឆិគតោ, ន ឧទកេ និមុគ្គោ, ន អសញ្ញីភូតោ, ន មតោ, ន ចតុត្ថជ្ឈានសមាបន្នោ, ន រូបារូបភវសមង្គី,

ន និរោធសមាបន្នោ ។

*លំដាប់នោះ កាលព្រះយោគាវចរពិចារណាយ៉ាងនេះហើយ បានជ្រាបថា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនេះ គឺ ១ មិនមានដល់មនុស្សនៅក្នុងផ្ទៃពោះមាតា, ២ មិនមានដល់មនុស្សមុជក្នុងទឹក, ៣ មិនមានដល់មនុស្សសន្លប់, ៤ មិនមានដល់មនុស្សដែលស្លាប់, ៥ មិនមានដល់មនុស្សកំពុងចូលចតុត្ថជ្ឈាន, ៦ មិនមានដល់មនុស្សប្រកបដោយ រូបភព និងអរូបភព, ៧ មិនមានដល់មនុស្សកំពុងចូលនិរោធសមាបត្តិ (ជាព្រះអរិយបុគ្គល), បានដឹងដូច្នេះហើយ ព្រះយោគាវចរគប្បីដាស់តឿនខ្លួន ដោយខ្លួនឯងដូច្នេះថា "នៃអ្នកបណ្ឌិត! ១ ខ្លួនអ្នកមិនមែន ជាអ្នកនៅក្នុងផ្ទៃពោះមាតា, ២ មិនមែនជាអ្នកមុជក្នុងទឹក, ៣ មិនមែនជាអ្នកសន្លប់, ៤ មិនមែនជាអ្នកដែលស្លាប់, ៥ មិនមែនជាអ្នកកំពុងចូលចតុត្ថជ្ឈាន, ៦ មិនមែនជាអ្នកប្រកបដោយ រូបភព និងអរូបភព, ៧ មិនមែនជាអ្នកកំពុងចូលនិរោធសមាបត្តិ (ជាព្រះអរិយបុគ្គល) តើពិតមែនរឺទេ? ។*

អត្ថិយេវ តេ អស្សាសបស្សាសា, មន្ទបញ្ញតាយ បន បរិគ្គហេតុំ ន សក្កោសី"តិ ។

*ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញរបស់អ្នក ច្បាស់ជាមានយ៉ាងពិតប្រាកដ ន៉ុះឯង, ប៉ុន្តែ ព្រោះហេតុតែ អ្នកជាមនុស្សមានបញ្ញាខ្សោយ ដូច្នោះហើយ ទើបមិនអាចកំណត់ដឹងបាន" ដូច្នេះ ។*

អថានេន បកតិផុដ្ឋវសេន ចិត្តំ ឋបេត្វា មនសិការោ បវត្តេតព្វោ។

*លំដាប់នោះ អ្នកគប្បីតម្កល់ចិត្តទុក នៅត្រង់កន្លែងដែលខ្យល់ពាល់ត្រូវជាប្រក្រតីចុះ ហើយគប្បីមនសិការឱ្យប្រព្រឹត្តិទៅរឿយៗចុះ ។*

ឥមេ ហិ ទីឃនាសិកស្ស នាសាបុដំ ឃដ្ដេន្តា បវត្តន្តិ ។

*តាមពិត ខ្យល់ដង្ហើមទាំងនេះ សម្រាប់បុគ្គលដែលមានច្រមុះវែង រមែង*

*ប្រព្រឹត្តទៅ គឺពាល់ត្រូវនៅត្រង់ប្រហោងចុងច្រមុះ ។*

**វស្សជាសិកស្ស ឧត្តរោដ្ឋំ ។**

*សម្រាប់បុគ្គលអ្នកដែលមានច្រមុះខ្លី រមែងប្រព្រឹត្តទៅ គឺពាល់ត្រូវនៅត្រង់ផ្ទៃបបូរមាត់ខាងលើ ។*

**តស្មា តេន ឥមំ នាម ឋានំ ឃដ្ដេតីតិ និមិត្តំ ឋបេតព្វំ ។**

*ព្រោះហេតុនោះ ព្រះយោគាវចរភិក្ខុរូបនោះ គប្បីតម្កល់និមិត្ត (គឺសតិនៅត្រង់ចុងច្រមុះ ឬនៅត្រង់ផ្ទៃបបូរមាត់ខាងលើ) ហើយកំណត់ទុកថា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ពាល់ត្រូវនៅត្រង់កន្លែងនេះ យ៉ាងពិតប្រាកដដូច្នេះ ។*

**ឥមមេវ ហិ អត្ថវសំ បដិច្ច វុត្តំ ភគវតា –**

*មែនពិត ព្រះដ៏មានព្រះភាគទ្រង់អាស្រ័យអំណាចនៃអត្ថសេចក្ដីនេះនុ៎ះឯង ទើបទ្រង់ត្រាស់សម្ដែងថា ៖*

**"នាហំ, ភិក្ខវេ, មុដ្ឋស្សតិស្ស អសម្បជានស្ស អានាបានស្សតិភាវនំ វទាមី"តិ**(៤៨)**។**

*"ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានសម្ដែងថា ការចម្រើននូវអានាបានស្សតិ មានដល់ព្រះយោគាវចរភិក្ខុ ដែលភ្លេចភ្លាំង**សតិ** និងមិនមាន**សម្បជញ្ញៈ**នោះទេ" ដូច្នេះ ។*

## ខ្យល់ល្អិតសុខុម

### (មហាដីកាវិសុទ្ធិមគ្គ)

[២២៩] **"ឧបរូបរិ វិភូតានី"**តិ ភាវនាពលេន ឧត្តំ ឧត្តំ ចាកដានិ ហោន្តិ ។

*ពាក្យថា* **"និងជាការប្រាកដច្បាស់ឡើងទៅៗ"** *គឺនឹងប្រាកដច្បាស់ៗ*

៤៨ (ម. និ. ៣.១៤៩; សំ. និ. ៥.៩៩២) ។

*ក្រៃលែងឡើងទៅៗ ទៅតាមកម្លាំងរបស់ភាវនា ។*

**"ទេសតោ"តិ បកតិយា ផុសនទេសតោ, បុព្វេ អត្តនា ផុសនវសេន ឧបធារិតដ្ឋានតោ ។**

*ពាក្យថា "**ចាកស្ថានទី**" គឺចាកពីទីកន្លែងដែលពាល់ត្រូវ ជាប្រក្រតី, បានដល់ ការចាកពីដំណែងដែលខ្លួនបានចាំទុកមកហើយ ជាប់ទាក់ទងទៅនឹងខ្យល់ពាល់ត្រូវ នៅខាងដើម ។*

**"កត្ថ នត្ថី"តិ ឋានវសេន, "កស្ស នត្ថី"តិ បុគ្គលវសេន វីមំសិយមានមត្ថំ ឯកជ្ឈំ កត្វា វិភាវេតុំ "អន្តោមាតុកុច្ឆិយ"ន្តិអាទិ វុត្តំ។**

*លោកអាចារ្យ មានសេចក្តីប្រាថ្នា នឹងបើកបង្ហាញទៅព្រមជាមួយនូវសេចក្តីដែលនឹងត្រូវពិនិត្យ ដែលជាប់ទាក់ទងជាមួយស្ថានទី (ដែលមានខ្យល់ឬមិនមាន) ដែលពោលថា "**មិនមានក្នុងទីណា**", ដែលជាប់ទាក់ទងជាមួយបុគ្គលដែលបានពោលថា "**មិនមានដល់អ្នកណា ?**" ទើបពោលទៀតថា "មិនមាន ក្នុងផ្ទៃមាតា" ដូច្នេះជាដើម ។*

**តត្ថ យថា ឧទកេ និមុគ្គស្ស បុគ្គលស្ស និរុទ្ធោកាសតាយ អស្សាសបស្សាសា នប្បវត្តន្តិ, ឯវំ អន្តោមាតុកុច្ឆិយំ ។**

*បណ្តាពាក្យទាំងនោះ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ រមែងមិនប្រព្រឹត្តទៅ ព្រោះភាវៈនៃបុគ្គលអ្នកមុជក្នុងទឹកនោះឯងជាអ្នកមានខ្យល់អាកាសបិទអស់ហើយ (គឺមិនមានខ្យល់ដកដង្ហើម) យ៉ាងណា, ក៏រមែងមិនប្រព្រឹត្តិទៅនៅក្នុងផ្ទៃមាតា ព្រោះភាវៈនៃបុគ្គលនោះឯងជាអ្នកមានខ្យល់អាកាសបិទអស់ហើយ (គឺមិនមានខ្យល់ដកដង្ហើម)បាន ក៏យ៉ាងនោះដូចគ្នា ។*

**យថា មតានំ សមុដ្ឋាបកចិត្តាភាវតោ, ឯវំ អសញ្ញីភូតានំ មុច្ឆាបន្នានំ, អសញ្ញីសុ វា ជាតានំ, តថា និរោធសមាបន្នានំ។**

*រមែងមិនប្រព្រឹត្តិទៅដល់ មនុស្សស្លាប់ ព្រោះមិនមានចិត្ត ដែលជា*

*សមុដ្ឋានយ៉ាងណា, ក៏រមែងមិនប្រព្រឹត្តិទៅដល់មនុស្សអ្នកមិនមានសញ្ញា គឺអ្នកដែលកំពុងសន្ទប់, ឬអ្នកដែលកើតនៅក្នុងអសញ្ញីភព ព្រោះមិនមានចិត្តដែលជាសមុដ្ឋាន យ៉ាងនោះដូចគ្នា, រមែងមិនប្រព្រឹត្តិទៅ ដល់អ្នកកំពុងចូលនិរោធសមាបត្តិ ក៏យ៉ាងនោះដូចគ្នា (ព្រោះមិនមានចិត្តជាសមុដ្ឋាន) ។*

**ចតុត្ថជ្ឈានសមាបន្នានំ បន ឧម្មតារសេនេវ នេសំ អនុប្បវត្តនំ, តថា រូបារូបភវសមង្គីនំ ។**

*ចំណែក កាលដែលខ្យល់ទាំងនោះ មិនប្រព្រឹត្តិទៅដល់អ្នកចូលចតុត្ថជ្ឈាន គឺដោយអំណាចធម្មតានុ៎ះឯង (គឺសំដៅដល់អ្នកបានចូលនូវឈានទី ៤ ដោយសុក្រឹត), ដល់អ្នកដែលព្រមព្រៀងដោយរូបភព និងអរូបភព ក៏យ៉ាងនោះដែរ ។*

**កោចិ បន "អនុបុព្វតោ សុខុមភាវប្បត្តិយា ចតុត្ថជ្ឈានសមាបន្នស្ស, រូបភវេ រូបានំ ភវង្គស្ស ច សុខុមភាវតោ រូបភវសមង្គីនំ នត្ថី"តិ ការណំ វទន្តិ។**

*ចំណែកលោកអាចារ្យពួកខ្លះ បានពោលដល់ហេតុ (នៃភាពមិនប្រព្រឹត្តទៅ) កំណត់ទុកថា "ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ រមែងមិនមានដល់មនុស្សដែលបានចូលចតុត្ថជ្ឈាន ព្រោះបានដល់ភាពល្អិតសុខុមយ៉ាងក្រៃលែងទៅតាមលំដាប់, រមែងមិនមានដល់អ្នកព្រមព្រៀងដោយរូបភព ព្រោះភាវៈនៃរូបភព និងភវង្គនៃរូបភព ជាធម្មជាតិដែលល្អិតសុខុម" ដូច្នោះ ។*

**អត្ថិយេវ តេ អស្សាសបស្សាសា បរិយេសតោតិ អធិប្បាយោ, យថាវុត្តសត្តដ្ឋានវិនិមុត្តស្ស អស្សាសបស្សាសានំ អនុប្បវត្តនដ្ឋានស្ស អភាវតោ។**

*អធិប្បាយថា **ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ របស់អ្នកប្រាកដពិតជាមាននៅ នុ៎ះឯង** ព្រោះនៅមានចំណែកដែលសេសសល់ ដូច្នោះ, ព្រោះវា*

*ជាឋានៈដែលខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលកើតឡើងមិនបាន ត្រូវច្នៃផុតចាកអំពីឋានៈទាំង ៧ យ៉ាង តាមដែលលោកបានពោលមកហើយនោះ មិនមានទេ ។*

**"បកតិផុដ្ឋវសេនា"**តិ បកតិយា ផុសនដ្ឋានវសេន។

*ពាក្យថា "**ត្រង់កន្លែងដែលខ្យល់ពាល់ត្រូវតាមប្រក្រតី**" គឺត្រង់កន្លែងដែលបានពាល់ត្រូវហើយជាប្រក្រតី ។*

**"និមិត្តំ បបេតព្វ"ន្តិ សតិយា តត្ថ តត្ថ សុខប្បវត្តនត្ថំ ថិរតរសញ្ញា-ជនំ បវត្តេតព្វំ ។**

*ពាក្យថា "**គប្បីតាំងនិមិត្តកំណត់**" គឺគប្បីធ្វើសេចក្ដីកំណត់ដឹងឱ្យគង់វង្ស ថែមទៅទៀត ដើម្បីជាប្រយោជន៍ដល់ការចម្រើនសតិឱ្យប្រព្រឹត្តិទៅនៅក្នុងខ្យល់ល្អិតសុខុម នៅត្រង់កន្លែងនោះៗ ។*

**ថិរសញ្ញាបទដ្ឋានា ហិ សតិ ។**

*តាមពិត សតិមានសញ្ញាដែលតាំងមាំជាបទដ្ឋាន ។*

**"ឥមមេវា"តិ ឥមំ ឯវ អនុបដ្ឋហន្តស្ស កាយសង្ខារស្ស កណ្ឌាកា-ដ្ឋាបននយេន ឧបដ្ឋាបនវិធិមេវ ។**

*បទថា "**ឥមមេវ**" បានដល់ វិធីធ្វើកាយសង្ខារ ដែលមិនទាន់ប្រាកដ ឱ្យប្រាកដច្បាស់ តាមន័យ គឺធ្វើឱ្យប្រាកដតាំងតែពីឫសគល់នេះ ន៎ុះឯង ។*

**"អត្ថវសា"ន្តិ ហេតុំ។**

*ពាក្យថា "**ដោយអំណាចនៃអត្ថ**" បានដល់ វាជាហេតុ ។*

**"អត្ថោ"តិ ហិ ផលំ, សោ យស្ស វសេន បវត្តតិ, សោ អត្ថវសោតិ។**

*ពាក្យថា "**អត្ថ**" បានដល់ ផល, អត្ថនោះ រមែងប្រព្រឹត្តទៅ ដោយអំណាច នៃហេតុណា, ហេតុនោះ ឈ្មោះថា អត្ថវសោ ។*

**“មុដ្ឋស្សតិស្សា”តិ វិនដ្ឋស្សតិស្ស។**

*ពាក្យថា “**អ្នកភ្លេចភ្លាំងនូវសតិ**” គឺអ្នកមានសតិបានវិនាសចេញហើយ ។*

**“អសម្បជានស្សា”តិ សម្បជញ្ញរហិតស្ស, ភាវេន្តស្ស អនុក្កមេន អនុបដ្ឋហន្តេ អស្សាសបស្សាសេ វីមំសិត្វា “ឥមេ តេ”តិ ឧបជាវេតុំ, សម្មនេវ បជានិតុញ្ច សមត្ថាហិ សតិបញ្ញាហិ វិរហិតស្សាតិ អធិប្បាយោ។**

*ពាក្យថា “**មិនមានសម្បជញ្ញ**” គឺការប្រាសចាក ដឹងនូវខ្លួន, អធិប្បាយថា ព្រះយោគាវចរ អ្នកចម្រើនកម្មដ្ឋាន ប្រាសចាកសតិ និងបញ្ញា ដែលអាចចូលទៅពិចារណា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលមិនប្រាកដទៅតាមលំដាប់ហើយ ចងចាំទុកនិងដឹងបានដោយប្រពៃនោះឯងថា “ខ្យល់ទាំងនេះ នៅមានពិតប្រាកដដល់យើង” ដូច្នេះ ។*

## ឧបមា ឧបមេយ្យ[៤៩]

### (វិសុទ្ធិមគ្គ)

[២៣០] **កិញ្ចាបិ ហិ យំកិញ្ចិ កម្មដ្ឋានំ សតស្ស សម្បជានស្សេវ សម្បជ្ជតិ។**

*កម្មដ្ឋានប្រភេទណាមួយ នឹងអាចសម្រេចបានដល់បុគ្គលអ្នកមានសតិ និងមាន សម្បជញ្ញៈ តែប៉ុណ្ណោះដោយពិត ។*

**ឥតោ អញ្ញំ បន មនសិករោន្តស្ស ចាកដំ ហោតិ។**

*តែថា កម្មដ្ឋានដទៃក្រៅអំពី អានាបានស្សតិនេះ កាលព្រះយោគាវចរ មនសិការទៅៗ រមែងជាធម្មជាតិប្រាកដច្បាស់ទៅៗ ។*

**ឥទំ បន អានាបានស្សតិកម្មដ្ឋានំ គរុកំ គរុកភាវនំ**

---

*៤៩ ឧបមានិងឧបមេយ្យ ស្ថិតនៅក្នុងខ្យល់ដង្ហើមចូល ចេញ ទំព័រ ២ ។*

ពុទ្ធបច្ចេកពុទ្ធពុទ្ធបុត្តានំ មហាបុរិសានំយេវ មនសិការភូមិភូតំ, ន ចេវ ឥត្តរំ, ន ច ឥត្តរសត្តសមាសេវិតំ ។

*ចំណែក អានាបានស្សតិកម្មដ្ឋាននេះវិញ ជារបស់ដ៏ល្អ ចម្រើនដោយលំបាក ជាភូមិនៃការមនសិការរបស់ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធ និងកូនរបស់ព្រះពុទ្ធទាំងឡាយ ដែលជាមហាបុរស តែប៉ុណ្ណោះ, មិនមែនជាកម្មដ្ឋានដែលតិចតួច ហើយអន់ថយនោះទេ, មិនមែនជាកម្មដ្ឋាន សម្រាប់សត្វដែលមានសតិបញ្ញាតិចតួច ហើយអន់ថយ នឹងអាចប្រព្រឹត្តិទៅបាននោះទេ ។*

យថា យថា មនសិ ការីយតិ, តថា តថា សន្តញ្ចេវ ហោតិ សុខុមញ្ច ។

*កាលមនសិការទៅ ដោយប្រការណាៗ, រមែងជាធម្មជាតិដែលស្ងប់ និងល្អិតសុខុមទៅៗ តាមប្រការនោះៗ ។*

តស្មា ឯត្ថ ពលវតី សតិ ច បញ្ញា ច ឥច្ឆិតព្វា។

*ព្រោះហេតុនោះ ក្នុងទីនេះទើបចាំបាច់ត្រូវប្រាថ្នាឱ្យមានសតិ និងបញ្ញាដែលមានកម្លាំងខ្លាំងក្លា ។*

យថា ហិ មដ្ឋសាដកស្ស តុន្នករណកាលេ សូចិបិ សុខុមា ឥច្ឆិតព្វា។

*ប្រៀបដូចជា ក្នុងវេលាដែលធ្វើការដេរនូវសំពត់ចីវរ ដែលមានសាច់ម៉ដ្ឋល្អិត សូម្បីម្ជុលយកមកដេរ ក៏ត្រូវការប្រើម្ជុលដែលមានខ្នាតតូចបំផុតផងដែរ ។*

សូចិបាសវេធនម្បិ តតោ សុខុមតរំ, ឯវមេវ មដ្ឋសាដកសទិសស្ស ឥមស្ស កម្មដ្ឋានស្ស ភាវនាកាលេ សូចិបដិភាគា សតិបិ, សូចិបាសវេធនបដិភាគា តំសម្បយុត្តា បញ្ញាបិ ពលវតី ឥច្ឆិតព្វា ។

*ថែមទាំងអំបោះដែលសម្រាប់ដេរ ក៏ត្រូវប្រើនូវអំបោះដែលតូចល្អិត*

*ក្រៃលែងជាងម្ដុលនោះទៅទៀត យ៉ាងណា, ក្នុងពេលដែលចម្រើននូវកម្មដ្ឋាន នេះ ក៏ប្រៀបដូចជា ទៅនឹងសំពត់ចីវរដែលមានសាច់ម៉ដ្ឋល្អិត គឺត្រូវចាំបាច់ ប្រាថ្នាទាំងសតិដែលមានកម្លាំងខ្លាំងក្លាផង ដែលប្រៀបទៅនឹងម្ដុលនោះ, ទាំង បញ្ញាដែលសម្បយុត្តជាមួយសតិនោះ ដែលមានកម្លាំង ប្រៀបដូចទៅនឹងអំបោះ ដូច្នោះ ។*

តាហិ ច បន សតិបញ្ញាហិ សមន្នាគតេន ភិក្ខុនា ន តេ អស្សាសបស្សាសា អញ្ញត្រ បកតិផុដ្ឋោកាសា បរិយេសិតព្វា។

*ក៏ចំណែកឯភិក្ខុអ្នកដែលដល់ព្រមដោយសតិ និងបញ្ញាទាំងនោះ កុំគប្បី ស្វែងរកនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនៅក្នុងទីដទៃឡើយ ក្រៅអំពី ទីដែលខ្យល់បានពាល់ត្រូវហើយៗ តាមប្រក្រតីនោះប៉ុណ្ណោះ ។*

## ការឧបមា

យថា បន កស្សកោ កសឹ កសិត្វា ពលីពទ្ទេ មុញ្ចិត្វា គោចរមុខេ កត្វា ឆាយាយ និសិន្នោ វិស្សមេយ្យ, អថស្ស តេ ពលីពទ្ទា វេគេន អដវឹ បវិសេយ្យុំ។

*ប្រៀបដូចជា អ្នកកសិករកាលភ្ជួរស្រែរួចហើយ ក៏បានលែងនូវគោទឹម ដែលខ្លួនបានប្រើរួចហើយ ឱ្យមានមុខឆ្ពោះទៅកាន់ទីកន្ទែង ដែលមានស្មៅ ហើយអ្នកស្រែនោះ ក៏អង្គុយនៅក្រោមម្លប់ដើមឈើ, លំដាប់នុ៎ះឯង គោទឹម ទាំងនោះរបស់កសិករ ក៏ចូលទៅក្នុងព្រៃយ៉ាងរហ័ស ។*

យោ ហោតិ ឆេកោ កស្សកោ, សោ បុន តេ គហេត្វា យោជេតុកាមោ ន តេសំ អនុបទំ គន្ត្វា អដវឹ អាហិណ្ឌាហិ, អថ ខោ រស្មិញ្ច បតោទញ្ច គហេត្វា ឧជុកមេវ តេសំ និបាតនតិត្ថំ គន្ត្វា និសីទតិ វា និបជ្ជតិ វា, អថ តេ គោណេ ទិវសភាគំ ចរិត្វា និបាតនតិត្ថំ ឱតរិត្វា ន្ហត្វា ច បិវិត្វា ច បច្ចុត្តរិត្វា ឋិតេ ទិស្វា រស្មិយា ពន្ធិត្វា បតោទេន វិជ្ឈន្តោ

អានេត្វា យោជេត្វា ធុវេ ថម្ភេ ពន្ធេយ្យ។ ឯវមេវ យោគាវចរោ...

អានេត្វា យោជេត្វា ធុវ ថម្ភេ ពន្ធតិ,

*អ្នកកសិករជាបុគ្គលឆ្លាត កាលនឹងប្រាថ្នាចង់ចាប់យកគោទឹម ដើម្បីទឹមភ្ជួរស្រែម្តងទៀត មិនគួរទៅតាមស្នាមជើងរបស់គោដែលបានចូលទៅក្នុងព្រៃនោះទេ, ប៉ុន្តែ គប្បីកាន់យកនូវខ្សែ និងរំពាត់ រួចហើយដើរតម្រង់ទៅកាន់កំពុងទឹកដែលវានឹងចុះផឹកទឹក រួចហើយអង្គុយ ឬក៏ដេកលេង (ដើម្បីរង់ចាំនូវគោនោះ), បន្ទាប់មកទៀត កាលឃើញគោទឹមទាំងនោះ ដែលវាបានត្រាច់ទៅរកស៊ីស្មៅអស់ពេលមួយថ្ងៃមកហើយ វាក៏បានចុះកំពុងទឹក ត្រាំទឹកផង ផឹកទឹកផង ហើយឡើងមកឈរនៅមាត់ច្រាំង អ្នកកសិករទើបយកខ្សែទៅចងផង និងរំពាត់ទៅដេញផង ដើម្បីដឹកវាយកមកទឹមភ្ជួរស្រែម្តងទៀត មានឧបមាយ៉ាងណា*

## ការឧបមេយ្យ

ឯវមេវ តេន ភិក្ខុនា ន តេ អស្សាសបស្សាសា អញ្ញត្រ បកតិផុដ្ឋោកាសាបរិយេសិតព្វា។

*យោគាវចរភិក្ខុរូបនោះ ក៏មានសេចក្តីដូចគ្នា គឺមិនគួរទៅស្វែងរកខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះ នៅក្នុងទីដទៃឡើយ ក្រៅអំពីទីកន្លែងដែលខ្យល់ធ្លាប់ពាល់ត្រូវហើយៗ ជាប្រក្រតីនុ៎ះឯង ក៏មានឧបមេយ្យយ៉ាងនោះដែរ ។*

សតិរស្មឹ បន បញ្ញាបតោទញ្ច គហេត្វា បកតិផុដ្ឋោកាសេ ចិត្តំ ឋបេត្វា មនសិការោ បវត្តេតព្វោ។

*ប៉ុន្តែ គប្បីកាន់យកខ្សែ គឺសតិ និងកាន់យកនូវរំពាត់ (ជន្លួញ) គឺបញ្ញា ដោយតម្កល់ចិត្តទុកនៅត្រង់កន្លែងដែលខ្យល់បានពាល់ត្រូវហើយៗ តាមប្រក្រតី រួចហើយធ្វើមនសិការឱ្យប្រព្រឹត្តទៅចុះ ។*

ឯវញ្ហិស្ស មនសិករោតោ ន ចិរស្សេវ តេ ឧបដ្ឋហន្តិ និចាតនតិត្ថេ

វិយ គោណា ។

*មែនពិត កាលព្រះយោគាវចរបានមនសិការទៅយ៉ាងនេះរឿយៗ មិនយូរប៉ុន្មានខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះ ក៏បានប្រាកដមកវិញជាមិនខានឡើយ ដូចគ្នានឹងគោទឹមទាំងឡាយ បានមកប្រាកដនៅត្រង់ទីកន្លែងកំពុងទឹក ដូច្នោះដែរ ។*

តតោនេន សតិរស្មិយា ពន្ធិត្វា តស្មឹយេវ ឋានេ យោជេត្វា បញ្ញាបតោទេន វិជ្ឈន្តេន បុនប្បុនំ កម្មដ្ឋានំ អនុយុញ្ជិតព្វំ ។

*តអំពីនោះទៅ ព្រះយោគាវចរគប្បីប្រើខ្សែ គឺសតិ ចងទុកហើយទឹមយកក្នុងទីកន្លែងនោះៗ និងប្រើរំពាត់ (ជន្លួញ) គឺបញ្ញា ដ៏ឆ្លាតឈ្លាសក្នុងការតាមរក្សានូវកម្មដ្ឋានឱ្យគង់វង្សជាប្រក្រតី ទៅរឿយៗ ។*

## ឧបមា ឧបមេយ្យ

### (មហាដីកាវិសុទ្ធិមគ្គ)

[២៣០] **ឥតោ អញ្ញំ** កម្មដ្ឋានំ។ "**គរុកា**"ន្តិ ភារិយំ។

*ពាក្យពេញជា* **ឥតោ អញ្ញំ** កម្មដ្ឋាន ។ *ពាក្យថា* "**គរុកំ** *ប្រែថា* **ជារបស់ធ្ងន់**" ។

សា ចស្ស គរុកតា ភាវនាយ សុទុក្ករភាវេនាតិ អាហ "**គរុក-ភាវន**"ន្តិ។

*អានាបានស្សតិកម្មដ្ឋាននេះ មានសភាពជារបស់ធ្ងន់ ព្រោះការដែលចម្រើន គឺជាការធ្វើបានដោយលំបាក ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា "**ចម្រើនបានដោយលំបាក**" ដូច្នេះ ។*

ឧបរូបរិ សន្តសុខុមភាវប្បត្តិតោ "ពលវតី សុវិសទា សូរា ច សតិបញ្ញា ច ឥច្ឆិតព្វា"តិ វត្វា សុខុមស្ស នាម អត្ថស្ស សាធនេនាបិ សុខុមេនេវ ភវិតព្វន្តិ ឧស្សេតុំ "**យថា ហី**"តិអាទិ វុត្តំ។

*លោកពោលថា "ចាំបាច់ត្រូវប្រាថ្នានូវសតិ និងបញ្ញាដែលមានកម្លាំង គឺមុតស្រួច និងក្លៀវក្លា" ដូច្នេះ ទើបដល់នូវសភាវៈស្ងប់ និងល្អិតសុខុមក្រៃលែងទៅៗ ហើយមានបំណងសម្តែងទៀតថា សូម្បីតែការធ្វើជាប្រយោជន៍ ឈ្មោះថាតិចតួចឱ្យសម្រេចដោយឧបករណ៍ដែលល្អិតប៉ុណ្ណោះ ដូច្នេះ ទើបពោលថា "**ប្រៀបដូចជា**" ដូច្នេះ ជាដើម ។*

**ឥទានិ អនុបជ្ឈាហន្តានំ អស្សាសបស្សាសានំ បរិយេសនុបាយំ ទស្សេន្តោ "តាហិ ច បនា"តិអាទិមាហ។**

*ឥឡូវនេះ លោកអាចារ្យ កាលនឹងសម្តែងនូវឧបាយការស្វែងរកខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលមិនប្រាកដ ទើបលោកពោលថា "**ក៏ចំណែកឯ** យោគាវចរភិក្ខុ អ្នកដល់ព្រមដោយសតិ និងបញ្ញា **ប៉ុណ្ណោះ**" ដូច្នេះ ជាដើម ។*

**តត្ថ "គោចរមុខេ"តិ គោចរភូមិមុខេ។ "អនុបទ"ន្តិ បទានុបទំ។**

*ក្នុងពាក្យទាំងនោះ ត្រង់ពាក្យថា "**គោចរមុខេ** កែទៅជា **គោចរភូមិមុខេ** ប្រែថា ឱ្យមានមុខបែរឆ្ពោះទៅកាន់ទីរកស៊ី គឺទីមានស្មៅ ។ បទថា "**អនុបទំ** ប្រែថា **ស្នាមជើង**" ។*

**"ចរិត្វា"តិ គោចរំ គហេត្វា។ "តស្មឹយេវ ឋានេ"តិ ឧបនិពន្ធនានិមិត្ត-សញ្ញិតដ្ឋានេ ។**

*ពាក្យថា "**ត្រាច់ទៅ**" (អស់ពេលថ្ងៃ) គឺកាន់យកនូវទីដែលត្រាច់ស្វែងរកស៊ីស្មៅ ។ ពាក្យថា "**ក្នុងទីត្រង់នោះ នុ៎ះឯង**" គឺត្រង់ទីកន្លែងដែលបានកំណត់ទុក ជានិមិត្តសម្រាប់ចូលទៅចងទុករបស់សតិ (គឺនៅត្រង់ចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើ) ។*

**"យោជេត្វា"តិ មនសិការេន យោជេត្វា។**

*ពាក្យថា "**ទឹមទុក**" គឺទឹមទុក ដោយការមនសិការ ។*

**"សតិរស្មិយា ពន្ធិត្វា"តិ វា វុត្តមេវត្ថមាហ "តស្មឹយេវ ឋានេ**

**យោជេត្វា**”តិ។

*ន័យម្យ៉ាងទៀត ពាក្យដែលលោកបានពោលទុកថា “**ប្រើខ្សែ គឺសតិចង ហើយទឹមទុក**” លោកពោលសំដៅដល់សេចក្ដី (នោះ) ទុកថា “**បានដល់ ទឹមទុក ក្នុងទីត្រង់នោះ នុ៎ះឯង**” ដូច្នេះ ។*

**ន ហិ ឧបមេយ្យេ ពន្ធនយោជនដ្ឋានានិ វិសុំ លព្ភន្តិ។**

*ព្រោះថា ក្នុងការឧបមេយ្យ នឹងបានទីកន្លែងដែលចងជាមួយស្ថានទីដែលទឹមនោះ មិនផ្សេងពីគ្នាទេ ។*

## ឧគ្គហនិមិត្ត និងបដិភាគនិមិត្ត មាន ១៧[៩០]

### (វិសុទ្ធិមគ្គ)

**[២៣១] តស្សេវមនុយុញ្ជតោ ន ចិរស្សេវ និមិត្តំ ឧបដ្ឋាតិ។**

*កាលព្រះយោគាវចរ តាមរក្សាកម្មដ្ឋានទៅរឿយៗ បែបនេះ និមិត្តនឹងកើតមានឡើង ដោយកាលមិនយូរឡើយ ។*

**តំ បនេតំ ន សព្ពេសំ ឯកសទិសំ ហោតិ។**

*ព្រះអាចារ្យអង្គខ្លះ លោកពោលថា ព្រះយោគាវចរគ្រប់ៗរូប នឹងមាននិមិត្តឱ្យប្រាកដដូចគ្នានោះ គឺវាមិនអាចទៅរួចទេ (គឺនិមិត្តមិនដូចគ្នាទាំងអស់នោះទេ) ។*

**អបិច ខោ កស្សចិ សុខសម្ផស្សំ ឧប្បាទយមានោ តូលបិចុ វិយ កប្បាសបិចុ វិយ វាតធារា វិយ ច ឧបដ្ឋាតីតិ ឯកច្ចេ អាហុ។**

*១. ប៉ុន្តែ អង្គខ្លះ ក៏ប្រាកដដូចជាប៉ុយគរ (ឧគ្គហនិមិត្ត)*

---

*៩០ កើតឡើងតាំងពីការចម្រើន សោ សតោវ អស្សសតិ, សតោ បស្សសតិ ទំព័រទី២ មកម្ល៉េះ។*

*២. អង្គ៍ខ្វះ ក៏ប្រាកដដូចជាប៉ុយកប្បាស (ឧគ្គហនិមិត្ត)*

*៣. អង្គ៍ខ្វះ ក៏ប្រាកដដូចជាខ្សែខ្យល់ បែបនេះក៏មាន ដែលញ៉ាំងសេចក្ដីសុខសម្ផស្សឱ្យកើតឡើងដូច្នេះ (ឧគ្គហនិមិត្ត) ។*

## ការវិនិច្ឆ័យរបស់ព្រះអដ្ឋកថា

**អយំ បន អដ្ឋកថាសុ វិនិច្ឆយោ, ឥទញ្ហិ កស្សចិ តារករូបំ វិយ មណិគុឡិកា វិយ មុត្តាគុឡិកា វិយ ច, កស្សចិ ខរសម្ផស្សំ ហុត្វា កប្បាសដ្ឋិ វិយ ទារុសារសូចិ វិយ ច, កស្សចិ ទីឃបាមង្គសុត្តំ វិយ កុសុមទាមំ វិយ ធូមសិខា វិយ ច, កស្សចិ វិត្ថតំ មក្កដកសុត្តំ វិយ វលាហកបដលំ វិយ បទុមបុប្ផំ វិយ រថចក្កំ វិយ ចន្ទមណ្ឌលំ វិយ សូរិយមណ្ឌលំ វិយ ច ឧបដ្ឋាតិ ។**

*ចំណែកសេចក្ដីតទៅនេះ ជាពាក្យវិនិច្ឆ័យរបស់ព្រះអដ្ឋកថាទាំងឡាយ, ក៏និមិត្តនេះ សម្រាប់ព្រះយោគាវចររូបខ្វះ*

*៤. ក៏ប្រាកដដូចជារូបផ្កាយ (ឧគ្គហនិមិត្ត និងបដិភាគនិមិត្ត)*

*៥. អ្នកខ្វះដូចជាដុំកែវមណី (បដិភាគនិមិត្ត)*

*៦. អ្នកខ្វះដូចជាដុំកែវមុក្តា (បដិភាគនិមិត្ត)*

*៧. សម្រាប់អ្នកខ្វះ ប្រាកដដូចជារបស់ដែលមានសម្ផស្សគ្រោតគ្រាត ដូចគ្រាប់កប្បាស (ឧគ្គហនិមិត្ត និងបដិភាគនិមិត្ត)*

*៨. និងដូចជាវនុកឈើដែលមានខ្លឹម បែបនេះក៏មាន (ឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត)*

*៩. សម្រាប់អង្គ៍ខ្វះ ប្រាកដដូចជាខ្សែសង្វារវែង (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត)*

១០. អ្នកខ្លះដូចជាកម្រងផ្កា (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត)

១១. និងដូចជាកម្សួលផ្សែងឬអណ្តាតផ្សែងហុយឡើង (នេះជាឧគ្គហ-និមិត្ត និងជាបដិភាគនិមិត្ត)

១២. សម្រាប់អង្គខ្លះ ក៏ប្រាកដដូចជាសរសៃពីងពាង ដែលលាតសន្ធឹងរួចហើយ (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត)

១៣. អ្នកខ្លះដូចជាដុំឬផ្ទាំងពពក (នេះជាឧគ្គហនិមិត្ត និងជាបដិភាគ-និមិត្ត)

១៤. ដូចជាផ្កាឈូក (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត)

១៥. ដូចជាកង់នៃរថ (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត)

១៦. ដូចជាមណ្ឌលវង់របស់ព្រះចន្ទ (នេះជាឧគ្គហនិមិត្ត និងជាបដិភាគ-និមិត្ត)

១៧. និងដូចជាមណ្ឌលវង់ របស់ព្រះអាទិត្យបែបនេះក៏មាន (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត) ។

**តញ្ច បនេតំ យថា សម្ពហុលេសុ ភិក្ខូសុ សុត្តន្តំ សជ្ឈាយិត្វា និសិន្នេសុ ឯកេន ភិក្ខុនា "តុម្ហាកំ កីទិសំ ហុត្វា ឥទំ សុត្តំ ឧបដ្ឋាតី"តិ វុត្តេ ឯកោ "មយ្ហំ មហតី បព្វតេយ្យា នទី វិយ ហុត្វា ឧបដ្ឋាតី"តិ អាហ ។**

ចំណែកឯកម្មដ្ឋាននេះតែមួយប៉ុណ្ណោះឯង រមែងប្រាកដផ្សេងពីគ្នា ក៏ព្រោះភាពផ្សេងគ្នារបស់សញ្ញា ប្រៀបដូចជា កាលព្រះភិក្ខុទាំងឡាយមានចំនួនច្រើន បានគង់អង្គុយស្វាធ្យាយព្រះសូត្ររួមគ្នា កាលភិក្ខុមួយអង្គបានសួរថា "ព្រះសូត្រនេះ បានប្រាកដដល់លោកម្ចាស់ទាំងឡាយ តើមានសេចក្តីដូចម្តេចដែរ ?" ដូច្នេះ ភិក្ខុមួយអង្គបានឆ្លើយថា "សម្រាប់រូបខ្ញុំម្ចាស់ បានប្រាកដ ប្រៀប

*ដូច នឹងខ្សែទឹកធំ ដែលហូរចុះពីលើភ្នំ" ។*

**អបរោ "មយ្ហំ ឯកោ វនរាជិ វិយ"។**

*ព្រះភិក្ខុមួយអង្គទៀត បានឆ្លើយថា "សម្រាប់រូបខ្ញុំម្ចាស់ បានប្រាកដ ប្រៀបដូចទៅនឹងដងព្រៃមួយ" ។*

**អញ្ញោ "មយ្ហំ ឯកោ សីតច្ឆាយោ សាខាសម្បន្នោ ផលភារភរិត-រុក្ខោ វិយា"តិ ។**

*ព្រះភិក្ខុមួយអង្គដទៃទៀត ក៏បានឆ្លើយថា "សម្រាប់រូបខ្ញុំម្ចាស់ បាន ប្រាកដ ប្រៀបដូច ទៅនឹងដើមឈើមួយដើម ដែលពោរពេញទៅដោយផ្លែ និង ផ្កា ដល់ព្រមដោយមែកធាង ហើយមានម្លប់សែនត្រជាក់" ដូច្នេះ ។*

**តេសំ ហិ តំ ឯកមេវ សុត្តំ សញ្ញានានតាយ នានតោ ឧបដ្ឋាតិ។**

*ក៏ព្រះសូត្រនេះ ព្រះសូត្រតែមួយប៉ុណ្ណោះឯង បានប្រាកដដល់ភិក្ខុ ទាំងឡាយនោះ មានសេចក្តីផ្សេងៗ គ្នា ព្រោះភាពផ្សេងៗ គ្នា របស់សញ្ញា យ៉ាងណាមិញ ។*

**ឯវំ ឯកមេវ កម្មដ្ឋានំ សញ្ញានានតាយ នានតោ ឧបដ្ឋាតិ។**

*កម្មដ្ឋាននេះ តែមួយប៉ុណ្ណោះ រមែងប្រាកដដល់ភិក្ខុទាំងឡាយនោះ មាន សេចក្តីផ្សេងៗគ្នា ព្រោះសេចក្តីផ្សេងៗ គ្នា នៃសញ្ញា ក៏យ៉ាងនោះដែរ ។*

**សញ្ញជញ្ហិ ឯតំ សញ្ញានិទានំ សញ្ញាបភវំ។**

*មែនពិត កម្មដ្ឋាននេះ កើតអំពីសញ្ញា មានសញ្ញាជាហេតុ មានសញ្ញាជា ដែនកើត ។*

**តស្មា សញ្ញានានតាយ នានតោ ឧបដ្ឋាតីតិ វេទិតព្វំ។**

*ព្រោះហេតុនោះ គប្បីជ្រាបថា ការប្រាកដផ្សេងៗគ្នា ក៏ព្រោះភាពផ្សេងៗ គ្នានៃសញ្ញា ។*

**ឯត្ថ ច អញ្ញមេវ អស្សាសារម្មណំ ចិត្តំ, អញ្ញំ បស្សាសារម្មណំ, អញ្ញំ និមិត្តារម្មណំ ។**

*ម្យ៉ាងទៀត ក្នុងអានាបានស្សតិកម្មដ្ឋាននេះ ចិត្តដែលមានខ្យល់ដង្ហើមចូល មកជាអារម្មណ៍ មានតែមួយដួងប៉ុណ្ណោះឯង, ចិត្តដែលមានខ្យល់ដង្ហើមចេញ មកជាអារម្មណ៍ ក៏មានតែមួយដួងដែរ, ចិត្តដែលមាននិមិត្ត (គឺកន្ទ្រង់ចុងច្រមុះ រឺផ្ទៃបបូរមាត់ខាងលើ) មកជាអារម្មណ៍ ក៏មានតែមួយដួងដូចគ្នា ។*

**យស្ស ហិ ឥមេ តយោ ធម្មា នត្ថិ, តស្ស កម្មដ្ឋានំ នេវ អប្បនំ, ន ឧបចារំ ចាបុណាតិ ។**

*ព្រះយោគាវចររូបណា មិនមានធម៌ ៣ យ៉ាងនេះ, កម្មដ្ឋានរបស់ព្រះយោគាវចររូបនោះ រមែងមិនចាក់ដុះនូវអប្បនា, និងមិនបានសម្រេចនូវឧបចារៈឡើយ ។*

**យស្ស បន ឥមេ តយោ ធម្មា អត្ថិ, តស្សេវ កម្មដ្ឋានំ ឧបចារញ្ច អប្បនញ្ច ចាបុណាតិ ។ វុត្តញ្ហេតំ –**

*ចំណែកព្រះយោគាវចររូបណាមានធម៌ ៣ យ៉ាងនេះ, កម្មដ្ឋានរបស់ព្រះយោគាវចររូបនោះប៉ុណ្ណោះ ទើបបានសម្រេចនូវឧបចារៈផង និងអប្បនាផង ។ សេចក្តីនេះ ស្របទៅតាម ដែលព្រះសារីបុត្តថេរបានសម្តែងទុកមកថា ៖*

**"និមិត្តំ អស្សាសបស្សាសា, អនារម្មណមេកចិត្តស្ស;**
**អជានតោ តយោ ធម្មេ, ភាវនា នុបលព្ភតិ។**

*"១ និមិត្ត(គឺកន្ទ្រង់ចុងច្រមុះ ឬ ផ្ទៃបបូរមាត់ខាងលើ), ២ ខ្យល់ដង្ហើមចូល, ៣ និងខ្យល់ដង្ហើមចេញ មិនមែនជាអារម្មណ៍របស់ចិត្តតែមួយដួងទេ, ប៉ុន្តែកាលព្រះយោគីភិក្ខុ មិនដឹងនូវធម៌ទាំង ៣ យ៉ាងនេះទេ ការចម្រើនភាវនារបស់ព្រះយោគីភិក្ខុរូបនោះ មិនបានសម្រេចឡើយ ។*

"និមិត្តំ អស្សាសបស្សាសា, អនារម្មណមេកចិត្តស្ស;
អជានតោ ច តយោ ធម្មេ, ភាវនា នុបលព្ភតី"តិ(៩១)។

"១ និមិត្ត (គឺកន្លែងចុងច្រមុះ ឬ ផ្ទៃបបូរមាត់ខាងលើ), ២ ខ្យល់ដង្ហើមចូល, ៣ និងខ្យល់ដង្ហើមចេញ, មិនមែនជាអារម្មណ៍របស់ចិត្តតែមួយដួងទេ, ប៉ុន្តែកាលព្រះយោគីភិក្ខុបានដឹងនូវធម៌ទាំង ៣ យ៉ាងនេះហើយ ការចម្រើនភាវនារបស់ព្រះយោគីភិក្ខុរូបនោះ រមែងបានសម្រេចយ៉ាងពិតប្រាកដ ។

## ឧគ្គហនិមិត្ត និង បដិភាគនិមិត្ត

**(មហាដីកាវិសុទ្ធិមគ្គ)**

[២៣១] "**និមិត្ត**"ន្តិ ឧគ្គហនិមិត្តំ, បដិភាគនិមិត្តំ វា។ ឧភយម្បិ ហិ ឥធ ឯកជ្ឈំ វុត្តំ។

*ពាក្យថា "និមិត្ត" បានដល់ ឧគ្គហនិមិត្ត, ឬបដិភាគនិមិត្ត ។ ព្រោះថាក្នុងទីនេះ លោកបានពោលរួមនិមិត្តទាំង ២ យ៉ាង គឺឧគ្គហនិមិត្តផង និបដិភាគ-និមិត្តផង ចូលរួមគ្នាតែមួយ ។*

តថា ហិ តូលបិចុអាទិឧបមត្តយំ ឧគ្គហេ យុជ្ជតិ, សេសំ ឧភយត្ថ។

*មែនពិត ជាយ៉ាងនោះហើយ ការឧបមាមាន ៣ យ៉ាង ដែលមានលក្ខណៈដូចជាប៉ុយគ (ដុំសំឡីគ) ដូចជាប៉ុយសំឡី (ដុំសំឡី) ដូចជាខ្សែខ្យល់ រមែងប្រើបាននៅក្នុងឧគ្គហនិមិត្ត, ការឧបមាដ៏សេសទៀត រមែងប្រើបាននៅក្នុងនិមិត្តទាំង ២ យ៉ាង (គឺឧគ្គហនិមិត្ត និងបដិភាគនិមិត្ត) ។*

"**ឯកច្ចេ**"តិ ឯកេ អាចរិយា។

*ពាក្យថា លោកអាចារ្យ "**ពួកខ្លះ**" បានដល់ លោកអាចារ្យមួយពួក ។*

---

៩១ (បារា. អដ្ឋ. ២.១៦៥) ។

"**តារការរូបំ វិយា**"តិ តារកាយ បការូបំ វិយ។

*ពាក្យថា "**ដូចជារូបផ្កាយ**" គឺប្រៀបដូចជារូបរស្មីនៃដួងផ្កាយ ។*

មណិគុឡិកាទិឧបមា បដិភាគេ វដ្ដន្តិ។

*ឧបមា ដូចជាមានដុំកែវមណី ជាដើម រមែងប្រើបានក្នុងបដិភាគនិមិត្ត ។*

កថំ បនេតំ ឯកំយេវ កម្មដ្ឋានំ អនេកាការតោ ឧបដ្ឋាតីតិ អាហ "តញ្ច បនេត"ន្តិអាទិ ។

*លោកអាចារ្យធ្វើពាក្យបានចោទសួរទុកក្នុងចិត្តថា ក៏កម្មដ្ឋានតែមួយប៉ុណ្ណោះ នឹងប្រាកដដោយអាការៈច្រើនប្រការយ៉ាងដូចម្ដេច ? ដូច្នេះហើយទើបពោលថា "**ក៏ឯ** កម្មដ្ឋានតែមួយ **នេះ នុ៎ះឯង**" ដូច្នេះជាដើម ។*

"**សុត្តន្ត**"ន្តិ ឯកំ សុត្តំ។ បគុណប្បវត្តិភាវេន អវិច្ឆេទំ, មហាវិសយតញ្ច សន្ធាយាហ "**មហាតី បព្វតេយ្យា នទី វិយា**"តិ។

*ពាក្យថា "**ព្រះសូត្រ**" បានដល់ ព្រះសូត្រតែមួយ ។ ភិក្ខុមួយរូប សំដៅយកសេចក្ដីដែលមិនដាច់ខ្សែ (មិនដាច់ចន្លោះ) ដោយភាវៈដែលប្រព្រឹត្តិទៅយ៉ាងស្ទាត់ជំនាញ, និងការមានវិស័យធំ ទើបពោលថា "**ប្រៀបដូចជា ទន្លេធំដែលហូរចុះមកអំពីភ្នំ**" ដូច្នោះ ។*

អត្ថព្យញ្ជនសម្បត្តិយា សមន្តភទ្ទកំ សុត្តំ សព្វភាគមនោហរា សព្វចាលិផុល្លា វនឃដា វិយាតិ អាហ "**ឯកា វនរាជិ វិយា**"តិ ។

*ព្រះសូត្រមានលម្អគ្រប់អន្លើ ព្រោះការដល់ព្រមនៃអត្ថ និងព្យញ្ជនៈ ប្រៀបដូចជាដងព្រៃដែលចេញផ្ការីកស្គុសស្គាយគ្រប់មែកធាង គួរឱ្យចាប់ចិត្តគ្រប់ចំណែក ព្រោះហេតុនោះ ភិក្ខុមួយអង្គទៀត ទើបពោលថា "**ប្រៀបដូចជាដងព្រៃមួយជួរ**" ដូច្នេះ ។*

**តេនាហ ភគវា – "វនប្បគុម្ពេ យថ ផុស្សិតគ្គេ"តិ(៤២) ។**

*ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់សម្ដែងទុកថា "ដូចជាគុម្ពឈើ ក្នុងព្រៃដែលចេញផ្ការីកស្គុសស្គាយគ្រប់មែកជាង" ដូច្នេះ ។*

**នានានុសន្ធិកំ នានាបេយ្យាលំ វិវិធនយនិបុណំ ពហុវិធកម្មដ្ឋានមុខសុត្តន្តំ អត្ថិកេហិ សក្កច្ចំ សមុបធីរិតព្វន្តិ អាហ "សីតច្ឆាយោ។ ...បេ...។ រុក្ខោ វិយា"តិ ។**

*ព្រះសូត្រដែលមានអនុសន្ធិច្រើន មានភាពល្អិតសុខុមច្រើនៗ (ពាក្យថា) បេយ្យាល មានន័យផ្សេងៗ ជាមុខនៃកម្មដ្ឋានច្រើនយ៉ាង ជារឿងដែលអ្នកត្រូវការប្រយោជន៍ គប្បីតម្កល់ទុកដោយសេចក្ដីគោរព ព្រោះហេតុនោះ ភិក្ខុមួយអង្គ ទើបពោលថា "**ប្រៀបដូចជា ដើមឈើ** ដែលមានផ្លៃស្អែកស្កុះ ។...ល...។ **មានម្លប់ត្រជាក់**" ដូច្នេះ ។*

**"សញ្ញានានតាយា"តិ និមិត្តុបដ្ឋានតោ បុព្វេ បវត្តសញ្ញានំ នានាវិធការតោ។**

*ពាក្យថា "**ព្រោះភាពផ្សេងគ្នានៃសញ្ញា**" គឺព្រោះភាពដែលសញ្ញាប្រព្រឹត្តទៅក្នុងកាលមុន តែការប្រាកដនៃនិមិត្ត មានបែបផ្សេងៗគ្នា ។*

**"ឥមេ តយោ ធម្មា"តិ អស្សាសោ, បស្សាសោ, និមិត្តន្តិ ឥមេ តយោ ធម្មា។**

*ពាក្យថា "**ធម៌ទាំងឡាយ ៣ យ៉ាងនេះ**" បានដល់ ធម៌ ៣ យ៉ាងទាំងនេះ គឺខ្យល់ដង្ហើមចូល ១, ខ្យល់ដង្ហើមចេញ ១, និងនិមិត្ត ១ (គឺកន្លែងចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើ)។*

**"នត្ថី"តិ កម្មដ្ឋានវសេន មនសិកាតព្វភាវេន នត្ថិ ន ឧបលព្ភន្តិ។**

*បទថា "**នត្ថិ**" បានដល់ ការមិនមាន គឺការមិនបាន ដោយភាពជាវត្ថុគួរ*

៤២ (ខុ. បា. ៦.១៣; សុ. និ. ២៣៦)។

*មនសិការ ដោយអំណាចជាកម្មដ្ឋាន ។*

**"ន ច ឧបចារ"ន្តិ ឧបចារម្បិ ន ចាបុណាតិ, បគេវ អប្បនន្តិ អធិប្បាយោ។**

*ត្រង់សេចក្ដីថា* **"ន ច ឧបចារំ"** *អធិប្បាយថា សូម្បីតែ* **ឧបចារ** *ក៏មិនបាន សម្រេចទៅហើយ នឹងពោលទៅថ្វីដល់* **អប្បនា** *ទៀតនោះ ។*

**"យស្ស បនា"តិ វិជ្ជមានបក្ខោ វុត្តនយានុសារេន វេទិតព្វោ។**

*ពាក្យថា* **"ចំណែក ព្រះយោគាវចររូបណា"** *គប្បីជ្រាបថា សង្រួមចិត្តមើល ដល់ធម្ម ដែលកំពុងមាន ទៅតាមទំនងនៃន័យសេចក្ដីដែលបានពោលមក ហើយ ។*

**ឥទានិ វុត្តស្សេវ អត្ថស្ស សមត្ថនត្ថំ កកចូបមាយំ អាគតា "និមិត្ត"ន្តិអាទិកា គាថា បច្ចានីតា។**

*ឥឡូវនេះ ដើម្បីនឹងធ្វើអត្ថ ដែលបានពោលមកហើយនោះឱ្យកាន់តែ រឹងមាំសេចក្ដី លោកអាចារ្យ ទើបនាំយកនូវគាថាដែលមានមកថា "និមិត្តំ" នេះ ជាដើម ដែលមានមកហើយនៅក្នុងការឧបមា ដោយរណារដៃ ត្រឡប់មកម្ដង ទៀត គឺលើកយកមកសម្ដែងម្ដងទៀត។*

# ការទូន្មានរបស់លោកអាចារ្យ

(វិសុទ្ធិមគ្គ)

**[២៣២] ឯវំ ឧបដ្ឋិតេ បន និមិត្តេ តេន ភិក្ខុនា អាចរិយស្ស សន្តិកំ គន្ត្វា អារោចេតព្វំ "មយ្ហំ, ភន្តេ, ឯវរូបំ នាម ឧបដ្ឋាតី"តិ ។**

*១. កាលមុន* ***លោកអាចារ្យជាអ្នកពោល (គឺអ្នកសម្តែងនូវ) ទីឃនិកាយ*** *បានពោលទុកយ៉ាងនេះថា កាលនិមិត្ត បានប្រាកដហើយ យ៉ាងនេះ ព្រះយោគាវចរភិក្ខុអង្គនោះ គប្បីទៅកាន់សំណាក់របស់លោកអាចារ្យ ហើយប្រាប់ឱ្យលោកបានជ្រាបនូវសេចក្តីនោះថា "លោកអាចារ្យដ៏ចម្រើន អារម្មណ៍លក្ខណៈយ៉ាងនេះ បានប្រាកដមកដល់រូបខ្ញុំ" ដូច្នេះ ។*

**អាចរិយេន បន ឯតំ និមិត្តន្តិ វា ន វា និមិត្តន្តិ ន វត្តព្វំ។**

*ចំណែក ខាងលោកអាចារ្យ មិនគួរនឹងពោលប្រាប់ថា នេះជានិមិត្ត ឬថា នេះមិនមែនជានិមិត្តទេ ។*

**"ឯវំ ហោតិ, អាវុសោ"តិ វត្វា បុនប្បុនំ មនសិ ករោហីតិ វត្តព្វំ។**

*តែគួរពោលនឹងកូនសិស្សថា "វា ក៏យ៉ាងនេះឯងណាគុណម្ចាស់" ហើយពោលបន្តទៅទៀតថា គុណម្ចាស់ចូរមនសិការទៅរឿយៗ យ៉ាងនេះចុះ ។*

**និមិត្តន្តិ ហិ វុត្តេ វោសានំ អាបជ្ជេយ្យ។ ន និមិត្តន្តិ វុត្តេ និរាសោ វិសីទេយ្យ។**

*ព្រោះថា កាលប្រាប់ថា វាជានិមិត្ត កូនសិស្សនោះនឹងឈប់ ហើយលែងបដិបត្តិតទៅទៀត ។ កាលប្រាប់ថា វាមិនមែនជានិមិត្តទេ កូនសិស្សនោះនឹងរាថយឈប់បដិបត្តិ ។*

**តស្មា តទុភយម្បិ អវត្វា មនសិការេយេវ និយោជេតព្វោតិ ។ ឯវំ តាវ ទីឃភាណកា ។**

*ព្រោះហេតុនោះ មិនត្រូវពោលទាំង ២ យ៉ាងនោះទេ គប្បីបបួលកូនសិស្ស ឱ្យប្រកបក្នុងការមនសិការតែប៉ុណ្ណោះ ដូច្នេះ ។ លោកអាចារ្យជាអ្នកពោលនូវ* ***ទីឃនិកាយ*** *ពោលយ៉ាងនេះ ។*

**មជ្ឈិមភាណកា** បនាហុ "និមិត្តមិទំ, អាវុសោ, កម្មដ្ឋានំ បុនប្បុនំ មនសិករោហិ សប្បុរិសាតិ វត្តព្វោ"តិ ។

*២. ចំណែក* ***លោកអាចារ្យជាអ្នកសម្ដែងនូវមជ្ឈិមនិកាយ*** *បានពោលទុកថា "លោកអាចារ្យ គួរពោលប្រាប់នឹងកូនសិស្សវិញថា គុណម្ចាស់នេះជានិមិត្តណាគុណម្ចាស់, ហើយលោកចូរមនសិការ គឺការធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាននេះ យ៉ាងនេះតទៅរឿយៗណា គុណម្ចាស់ជាសប្បុរស" ដូច្នេះ ។*

**អថានេន និមិត្តេយេវ ចិត្តំ ឋបេតព្វំ ។**

*លំដាប់នោះ ព្រះយោគាវចរ គប្បីតម្កល់ចិត្តទុកក្នុងនិមិត្ត តែម្យ៉ាងចុះ (នេះសំដៅយកនិមិត្តបានតាំងមាំល្អហើយ) ។*

**ឯវមស្សាយំ ឥតោ បភុតិ ឋបនាវសេន ភាវនា ហោតិ ។**

*តាំងតែពីពេលនេះទៅ ការភាវនានេះនឹងមានដល់អ្នក ដោយអំណាចនៃឋបនា ទៅតាមសេចក្ដីដែលបានពោលមកហើយនោះ ។*

**វុត្តញ្ហេតំ ពោរាណេហិ –**

*ត្រង់សេចក្ដីនេះ ស្របទៅតាមដែលលោកបោរាណាចារ្យទាំងឡាយ បានពោលទុកមកថា ៖*

**"និមិត្តេ ឋបយំ ចិត្តំ, នានាការំ វិភាវយំ;**
**ធីរោ អស្សាសបស្សាសេ, សកំ ចិត្តំ និពន្ធតី"តិ**[៩៣]**។**

*"ព្រះយោគាវចរ ជាអ្នកប្រាជ្ញ កាលតម្កល់ចិត្តទុកក្នុងនិមិត្ត (និមិត្តក្នុង*

*៩៣ (បារា. អដ្ឋ. ២.១៦៥); (សមន្តបាសាទិកា ១ ,៥២៣) ។*

*ទីនេះសំដៅយកបដិភាគនិមិត្ត) ធ្វើអាការៈផ្សេងៗ ក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឱ្យវិនាសទៅ ក៏រមែងចងចិត្តរបស់ខ្លួនទុកបានដែរ" ដូច្នេះ ។*

**តស្សេវំ និមិត្តុបដ្ឋានតោ បភុតិ នីវរណានិ វិក្ខម្ភិតានេវ ហោន្តិ, កិលេសា សន្និសិន្នាវ ។**

*ចាប់ផ្ដើមតាំងតែនិមិត្តបានប្រាកដយ៉ាងនេះហើយនីវរណធម៌ទាំងឡាយត្រូវបានអ្នកគ្របសង្កត់ទុកដោយល្អហើយ, កិលេសទាំងឡាយ ក៏ស្ងប់រម្ងាប់ទៅជាមួយគ្នាផងដែរ ។*

**សតិ ឧបដ្ឋិតាយេវ ។**

*សតិ ក៏ចូលទៅតម្កល់ទុកបានហើយនុ៎ះឯង ។*

**ចិត្តំ ឧបចារសមាធិនា សមាហិតមេវ ។**

*ចិត្ត ក៏បានតាំងមាំ ដោយឧបចារសមាធិនុ៎ះឯង ។*

**អថានេន តំ និមិត្តំ នេវ វណ្ណតោ មនសិ កាតព្វំ, ន លក្ខណតោ បច្ចវេក្ខិតព្វំ ។**

*លំដាប់នោះ យោគាវចរមិនគួរយកចិត្តទុកដាក់ជាមួយនិមិត្តនោះ ដោយការពិចារណាជាពណ៌, និងមិនគួរពិចារណាជាលក្ខណៈឡើយ ។*

**អបិច ខោ ខត្តិយមហេសិយា ចក្កវត្តិគព្ភោ វិយ កស្សកេន សាលិយវគព្ភោ វិយ ច អាវាសាទីនិ សត្ត អសប្បាយានិ វជ្ជេត្វា តានេវ សត្ត សប្បាយានិ សេវន្តេន សាធុកំ រក្ខិតព្វំ។**

*ប៉ុន្តែ គប្បីវៀរចាកនូវរឿង ៧ យ៉ាង ដែលមានអាវាស ជាដើម វាជាហេតុមិនសប្បាយដល់ចិត្ត ហើយគួរសេពនូវរឿង ៧ យ៉ាង ដែលមានអាវាស ជាដើម នុ៎ះឯងដែលជាទីសប្បាយដល់ចិត្ត ហើយរក្សានូវនិមិត្តនោះទុកឱ្យល្អ ប្រៀបដូចជា អគ្គមហេសីរបស់ព្រះរាជា ដែលពពោះរក្សាគភ៌ ហើយព្រះឱរសនោះនឹង*

*ក្លាយទៅជាព្រះចៅចក្រពត្តិ និងដូចជាអ្នករក្សាគភ៌របស់ស្រូវសាលី (ស្រូវផើម) ឬ ដូចជាអ្នករក្សាគភ៌ស្រូវដំណើប (ស្រូវដំណើបផើម) ដូច្នោះដែរ ។*

**អថ នំ ឯវំ រក្ខិត្វា បុនប្បុនំ មនសិការវសេន វុឌ្ឍឹ វិរូឡ្ហឹ គមយិត្វា ទសវិធំ អប្បនាកោសល្លំ សម្បាទេតព្វំ, វីរិយសមតា យោជេតព្វា ។**

*លំដាប់នោះ ព្រះយោគាវចរ កាលបានរក្សានូវនិមិត្តនោះបែបនេះហើយ ធ្វើឱ្យដល់សេចក្តីចម្រើនរុងរឿងឡើងៗទៅ ដោយអំណាចនៃការយកចិត្តទុកដាក់ជាមួយនិមិត្តនោះទៅរឿយៗ ហើយគប្បីធ្វើអប្បនាកោសល្លទាំង ១០ យ៉ាង ឱ្យដល់ព្រម, គប្បីប្រកបភាពស្មើគ្នានៃសេចក្តីព្យាយាមក្នុងកម្មដ្ឋានរបស់ខ្លួន ។*

**តស្សេវំ ឃដេន្តស្ស បថវីកសិណេ វុត្តានុក្កមេនេវ តស្មឹ និមិត្តេ ចតុក្កបញ្ចកជ្ឈានានិ និព្វត្តន្តិ។**

*កាលអ្នកបានព្យាយាមយ៉ាងនេះហើយ ឈានទាំង ៤ យ៉ាង ឬ ទាំង ៥ យ៉ាង ក៏កើតឡើងក្នុងនិមិត្តនោះ ទៅតាមលំដាប់ ដូចបានពោលសម្តែងមកហើយនៅក្នុងបឋវីកសិណ នុ៎ះឯង ។*

## ការទូន្មានរបស់លោកអាចារ្យ

### (មហាដីកាវិសុទ្ធិមគ្គ)

[២៣២] “**និមិត្តេ**”តិ យថាវុត្តេ បដិភាគនិមិត្តេ។ “**ឯវំ ហោតី**”តិ ភាវនមនុយុត្តស្ស ឯវ ហោតិ ។

*ពាក្យថា “**កាលនិមិត្តប្រាកដហើយ**” គឺកាលពន្ធ័នៃបដិភាគនិមិត្ត ដូចតាមដែលពោលមកហើយ (បានកើតឡើងប្រាកដច្បាស់ហើយ) ។ ពាក្យថា “**ក៏ជាយ៉ាងនេះឯង**” គឺសម្រាប់ព្រះយោគាវចរជាអ្នកបំពេញភាវនា ក៏ជាយ៉ាងនេះហើយ ។*

តស្មា "បុនប្បុនំ ឯវំ មនសិ ករោហី"តិ វត្តព្វោ។

*ព្រោះហេតុនោះ លោកអាចារ្យ គប្បីពោលជាមួយកូនសិស្សថា "គុណម្ចាស់ ចូរមនសិការទៅរឿយៗ យ៉ាងនេះចុះ" ដូច្នេះ ។*

"**វោសានំ អាបជ្ជេយ្យា**"តិ "និមិត្តំ នាម ទុក្ខរំ ឧប្បាទេតុំ, តយិទំ លទ្ធំ, ហន្ទាហំ ទានិ យថា វា តថា វា វិសេសំ និព្វត្តេស្សាមី"តិ សង្កោចំ អាបជ្ជេយ្យ ។

*ពាក្យថា "**កូនសិស្សនោះនឹងឈប់ ហើយលែងបដិបត្តិតទៅទៀត**" គឺនឹងគិតថា "ដែលឈ្មោះថានិមិត្ត ធ្វើឱ្យកើតឡើងដោយលំបាក, វិនិមិត្តនេះ យើងក៏បានវាហើយ, យកតែប៉ុណ្ណេះ យើងនឹងធ្វើនូវគុណវិសេសឱ្យកើតឡើងតែម្តងដល់ពេលណាក៏ដល់ពេលនោះទៅ" ។*

"**វិសីទេយ្យា**"តិ "ឯត្តកំ កាលំ ភាវនមនុយុត្តស្ស និមិត្តម្បិ ន ឧប្បន្នំ, អភព្វោ មញ្ញេ វិសេសស្សា"តិ វិសាទំ អាបជ្ជេយ្យ។

*ពាក្យថា "**កូនសិស្សនោះនឹងរាថយឈប់បដិបត្តិ**" គឺនឹងគិតថា "យើងបានចម្រើនភាវនាមកអស់កាលជាយូរមកហើយ សូម្បីតែនិមិត្តក៏មិនកើតឡើងដែរ, ឃើញថា យើងជាមនុស្សដែលមិនមាននូវគុណវិសេសទេមើលទៅ" ដូច្នេះហើយក៏នឹងរាថយឈប់បដិបត្តិទៅ ។*

"ឥមាយ បដិបទាយ ជរាមរណតោ មុច្ចិស្សាមីតិ បដិបន្នស្ស និមិត្ត"ន្តិ វុត្តេ កាចំ សង្កោចាបត្តិ, កិំ យ្យោសោ មត្តាយ ឧស្សាហមេវ ករេយ្យាតិ "**និមិត្ត- មិទំ។..បេ...។ វត្តព្វោ**"តិ **មជ្ឈិមភាណកា** អាហុ។

*ព្រះអាចារ្យជា**អ្នកពោលនូវមជ្ឈិមនិកាយ** បានធ្វើទុកក្នុងចិត្តថា កាលប្រាប់ថា "វាជានិមិត្តមានដល់ព្រះយោគាវចរ អ្នកបដិបត្តិគិតថា យើងនឹងរួចផុតចាកអំពីជរា និង មរណៈបាន ដោយអំណាចនៃផ្លូវបដិបទានេះ ដូច្នេះហើយក៏ព្យាយាមបន្ថែមទៀត" ទោះបីជាមានភាពយឺតយូរបន្តិចក៏ដោយ, ក៏គប្បីធ្វើនូវ*

*សេចក្ដីព្យាយាមឱ្យលើសជាប្រមាណបន្ថែមទៀត ដូច្នេះហើយទើបលោកពោលថា "លោកអាចារ្យគួរពោលជាមួយនឹងកូនសិស្សថា នេះវាជានិមិត្តណាគុណម្ចាស់ ។...ល...។ ណាលោកសប្បុរស" ដូច្នេះ ។*

**"ឯវ"ន្តិ វុត្តប្បការេន បដិភាគនិមិត្តេយេវ ការនាចិត្តស្ស ឋបនេន។**

*បទថា "**ឯវំ** ប្រែថា តាមប្រការដូចបានពោលមកហើយ" គឺតាមដែលតាំងការនាទុកក្នុងចិត្ត នៅក្នុងបដិភាគនិមិត្តតែម្យ៉ាង ។*

**"តតោ បភុតី"តិ តតោ បដិភាគនិមិត្តុប្បត្តិតោ បដ្ឋាយ។**

*ពាក្យថា " **តាំងតែពីពេលនេះទៅ**" គឺចាប់ផ្ដើមតាំងតែពន្ទឹបដិភាគនិមិត្តបានកើតឡើងហើយ ។*

**បុព្វេ យំ វុត្តំ "អនុពន្ធនាយ ច ផុសនាយ ច ឋបនាយ ច មនសិការោតី"តិ[៥៤], តត្ថ អនុពន្ធនំ, ផុសនញ្ច វិស្សជ្ជេត្វា "ឋបនាវសេន ភាវនា ហោតី"តិ ឋបនាវសេនេវ ភាវេតព្វន្តិ អត្ថោ ។**

*មានអធិប្បាយថា ពាក្យដែលលោកពោលទុកនៅខាងដើមថា "(ការដែលហៅថា) មនសិការដោយ**អនុពន្ធនា**ផង ដោយ**ផុសនា**ផង និងដោយ **ឋបនា**ផង" ដូច្នេះណា, ក្នុងពាក្យនោះ កាលវៀរចាកនូវ **អនុពន្ធនា** និង**ផុសនា**ហើយ **ការភាវនាក៏នឹងមានដោយអំណាចនៃ ឋបនា** ព្រោះហេតុនោះ ព្រះយោគាវចរគប្បីចម្រើននូវកម្មដ្ឋាននេះ ដោយអំណាចនៃ **ឋបនា** តែម្យ៉ាងចុះ (នេះសំដៅយកពន្ទឹបដិភាគនិមិត្តបានតាំងមាំល្អហើយ) ។*

**ចោរាណេហិ វុត្តោវាយមត្ថោតិ "និមិត្តេ"តិ គាថមាហ។**

*ការអធិប្បាយនេះ **លោកបោរាណាចារ្យទាំងឡាយ** ក៏បានពោលទុកមកហើយដូចគ្នា ព្រោះហេតុនោះ ព្រះអាចារ្យទើបពោលពាក្យជាគាថា ថា "**និមិត្តេ**" ជាដើម ។*

---

៥៤ (វិសុទ្ធិ. ១.២២៤) ។

តត្ថ **"និមិត្តេ"**តិ បដិភាគនិមិត្តេ។ **"ឋបយំ ចិត្តំ"**ន្តិ ភាវេន្តោ ចិត្តំ ឋបេន្តោ, ឋបនាវសេន មនសិករោន្តោតិ អត្ថោ។

*ក្នុងគាថានោះ ពាក្យថា **"ក្នុងនិមិត្ត"** បានដល់ ក្នុងបដិភាគនិមិត្ត ។ ពាក្យថា **"កាលតម្កល់ចិត្តទុក"** គឺកាលតាំងចិត្តភាវនា, សេចក្ដីថា កាលមនសិការដោយអំណាចនៃ ឋបនា ។*

**"នានាការ"**ន្តិ "ចត្តារោ វណ្ណា"តិ[៥៩]ឯវំ វុត្តំ នានាការំ ។

*បទថា **"នានាការំ ប្រែថា បានដល់អាការៈផ្សេងៗ"** ដែលលោកបានពោលទុកមកយ៉ាងនេះហើយថា **"ចត្តារោ វណ្ណា** ប្រែថា អាការៈ ៤ យ៉ាង" ដូច្នេះ ។*

អាការសាមញ្ញវសេន ហេតំ ឯកវចនំ ។ **"វិភាវយ"**ន្តិ វិភាវេន្តោ អន្តរធាបេន្តោ ។

*ក៏ពាក្យថា **នានាការំ** នេះ ជាឯកវចនៈ ដោយអំណាចជាអាការៈស្មើៗគ្នា ។ បទថា **"វិភាវយំ** ប្រែថា **ធ្វើឱ្យវិនាសទៅ"** គឺឱ្យអន្តរធានទៅ ។*

និមិត្តុប្បត្តិតោ បដ្ឋាយ ហិ តេ អាការា អមនសិករោតោ អន្តរហិតា វិយ ហោន្តិ ។

*មែនពិត ចាប់ផ្ដើមតាំងតែនិមិត្តបានកើតឡើងហើយ អាការៈទាំងនោះរមែងហាក់បីដូចជាអន្តរធានបាត់ទៅដល់ព្រះយោគាវចរ ដែលមិនយកចិត្តទុកដាក់ ។*

**"អស្សាសបស្សាសេ"**តិ អស្សាសបស្សាសេ យោ នានាការោ, តំ វិភាវយំ, អស្សាសបស្សាសសម្ភូតេ វា និមិត្តេ។

*ពាក្យថា **"ក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ"** សេចក្ដីថា អាការៈ*

---

៥៩ (វិសុទ្ធិ. ១.២១៩; បារា. អដ្ឋ. ២.១៦៥; បដិ. ម. អដ្ឋ. ២.១.១៦៣) ។

*ផ្សេងៗណានៅក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ, ឬ ក្នុងនិមិត្តដែលបានកើតអំពីខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ធ្វើអាការៈផ្សេងៗ នោះ ឱ្យវិនាសទៅ ។*

**"សកំ ចិត្តំ និពន្ធតី"**តិ តាយ ឯវ បបញាយ អត្តនោ ចិត្តំ ឧបនិពន្ធតិ, អប្បេតីតិ អត្ថោ ។

*ពាក្យថា "**ក៏រមែងចងចិត្តរបស់ខ្លួនទុកបានដែរ**" គឺចូលទៅចងចិត្តរបស់ខ្លួនទុកបាន ដោយវិធីបបញានោះឯង, សេចក្តីថា ធ្វើឱ្យបានដល់នូវ **អប្បនា** ។*

យេ បន "វិភាវយន្តិ វិភាវេន្តោ វិទិតំ ចាកដំ ករោន្តោ"តិ អត្ថំ វទន្តិ, តំ បុព្វភាគវសេន យុជ្ជេយ្យ។

*ចំណែកអាចារ្យអង្គខ្លះ បានពោលនូវសេចក្តីនេះទុកថា "បទថា **វិភាវយំ** គឺធ្វើឱ្យបើកបង្ហាញ ដែលធ្វើឱ្យជាក់ច្បាស់ ធ្វើឱ្យច្បាស់ប្រាកដ" ដូច្នេះ ពាក្យនោះគប្បីប្រើបានដោយអំណាចនៃភាវនាក្នុងចំណែកខាងដើម ។*

អយញ្ចេត្ថ អត្ថោ –

*ក៏ក្នុងពាក្យរបស់អាចារ្យទាំងនោះ មានសេចក្តីអធិប្បាយដូចតទៅនេះ ៖*

**និតិសម្បន្នត្តា ធីរោ យោគី អស្សាសបស្សាសេ នានាការំ វិភាវេន្តោ នានាការតោ តេ បជានន្តោ វិទិតេ ចាកដេ ករោន្តោ, នានាការំ វា ឧឡារិកោឡារិកេ បស្សម្ភេន្តោ វូបសមេន្តោ តត្ថ យំ លទ្ធំ និមិត្តំ, តស្មឹ ចិត្តំ បបេន្តោ អនុក្កមេន សកំ ចិត្តំ និពន្ធតិ អប្បេតីតិ ។**

*ព្រះយោគាវចរដែល**ជាអ្នកប្រាជ្ញ** ព្រោះការដល់ព្រមដោយបញ្ញា កាលធ្វើនូវអាការៈផ្សេងៗ ក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឱ្យបើកបង្ហាញ គឺកាលដឹងច្បាស់នូវខ្យល់ដង្ហើមចូលទាំងនោះ ដោយអាការៈផ្សេងៗ បានដល់ការធ្វើឱ្យជាក់ច្បាស់ ឬថា កាលធ្វើនូវអាការៈផ្សេងៗ គឺខ្យល់ដង្ហើមចូលគ្រោតគ្រាតៗ ឱ្យរលត់បាត់ ឱ្យស្ងប់រម្ងាប់ កាលតម្កល់ចិត្តទុកក្នុងនិមិត្ត ដែលមាននៅ*

*ក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះ ក៏រមែងចងចិត្តរបស់ខ្លួនទុកដែរ, គឺបានធ្វើចិត្តឱ្យដល់អប្បនា ទៅតាមលំដាប់ ដូច្នេះ ។*

"**វណ្ណតោ**"តិ បិចុបិណ្ឌតារការូចាទីសុ វិយ ឧបដ្ឋិតវណ្ណតោ ។

*ពាក្យថា "**ដោយពណ៌**" គឺដោយពណ៌ដែលបានប្រាកដ ដូចជា ដែលបានប្រាកដនូវដុំសំឡីគ ឬ រូបដួងផ្កាយ ជាដើម ។*

"**លក្ខណតោ**"តិ ខរភាវាទិសភាវតោ, អនិច្ចាទិលក្ខណតោ វា ។

*ពាក្យថា "**ដោយលក្ខណ**" គឺដោយសភាវៈ មានភាវៈដែលគ្រោតគ្រាតជាដើម, ឬ ដោយលក្ខណៈ មានអនិច្ចលក្ខណជាដើម ។*

**រក្ខិតព្វំ តំ និមិត្តន្តិ សម្ពន្ធោ។**

*ភ្ជាប់សេចក្តីថា "គប្បីរក្សានូវនិមិត្តនោះ" ។*

និមិត្តស្ស រក្ខណំ នាម តត្ថ បដិលទ្ធស្ស ឧបចារឈានស្ស រក្ខណេនេវ ហោតីតិ អាហ "**បុនប្បុនំ មនសិការវសេន វុឌ្ឍឹ វិរុឡ្ហឹ គមយិត្វា**"តិ។

*ឈ្មោះថា ការរក្សានូវនិមិត្ត រមែងមាន ដោយការកំណត់នូវឧបចារឈានដែលមានមកហើយ ក្នុងនិមិត្តនោះ នុ៎ះឯង ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា"**ធ្វើ (នូវនិមិត្តនោះ) ឱ្យដល់សេចក្តីចម្រើនរុងរឿងឡើងៗដោយអំណាចនៃការយកចិត្តទុកដាក់ជាមួយនិមិត្តនោះទៅរឿយៗ**" ។*

## ការកំណត់នាម និងរូប[៩៦]

**(វិសុទ្ធិមគ្គ)**

[២៣៣] ឯវំ និព្ពត្តចតុក្កបញ្ចកជ្ឈានោ បនេត្ថ ភិក្ខុ **សល្លក្ខណា-វិវដ្ដនា**វសេន កម្មដ្ឋានំ វឌ្ឍេត្វា **ចារិសុទ្ធឹ** បត្តុកាមោ តទេវ ឈានំ បញ្ចហាការេហិ វសិប្បត្តំ បគុណំ កត្វា នាមរូបំ វវត្ថបេត្វា វិបស្សនំ បដ្ឋបេតិ ។

*ព្រះយោគាវចរភិក្ខុជាអ្នកមានឈានទាំង ៤ ឬ ឈានទាំង ៥ បានកើតឡើងហើយយ៉ាងនេះ ជាអ្នកប្រាថ្នាដើម្បីនឹងចម្រើនកម្មដ្ឋានដោយអំណាចនៃ* ***សល្លក្ខណា*** *និង* ***វិវដ្ដនា*** *រហូតបានសម្រេចដល់* ***ចារិសុទ្ធិ*** *ក្នុងអានាបាន-ស្សតិភាវនានេះ រមែងធ្វើឈាននោះ ទុំះឯង ឱ្យសម្រេចដល់វសី គឺឱ្យស្ទាត់ជំនាញក្នុងអាការៈវសីទាំង ៥ យ៉ាង (រួចចម្រើននូវធាតុទាំង ៤ )ហើយទើបចាប់ផ្ដើមចម្រើនវិបស្សនាដោយការកំណត់នាម និងរូប (គឺ****នាមរូបបរិច្ឆេទ-ញាណ*** *ជាញាណទី ១) ។*

កថំ? សោ ហិ សមាបត្តិតោ វុដ្ឋាយ អស្សាសបស្សាសានំ សមុទយោ ករជកាយោ ច ចិត្តញ្ចាតិ បស្សតិ។

*សួរថា តើចាប់ផ្ដើមយ៉ាងដូចម្ដេច ? ។ ឆ្លើយថា ដ្បិតថា ព្រះយោគាវចរភិក្ខុនោះ ចេញចាកអំពីសមាបត្តិហើយ រមែងពិចារណាឃើញថា ករជកាយ និងចិត្ត វាជាហេតុកើតឡើងនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងឡាយ ។*

យថា ហិ កម្មារគគ្គរិយា ធម្មមានាយ ភស្តញ្ច បុរិសស្ស ច តជ្ជំ វាយាមំ បដិច្ចវាតោ សញ្ចរតិ, ឯវមេវ កាយញ្ច ចិត្តញ្ច បដិច្ច អស្សាសប-ស្សាសាតិ ។

*ប្រៀបដូចជា កាលចង្ក្រានស្នប់របស់ជាងមាស គឺបុគ្គលសប់ ខ្យល់រមែង*

[៩៦] *ការកំណត់នាម និងរូបដោយការចម្រើនវិបស្សនា ។* *ទំព័រទី ២២៤ ដល់ ២៣១*

*ចូល និងចេញបាន ព្រោះអាស្រ័យនូវស្នប់ផង នូវសេចក្ដីព្យាយាមដែលសមគួរ ដល់ការងារនោះរបស់បុរសផង រមែងសញ្ចរទៅ យ៉ាងណាមិញ, ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងឡាយ រមែងចូល និងចេញបាន ព្រោះអាស្រ័យនូវកាយ និងចិត្ត ក៏យ៉ាងនោះដែរ ។*

**តតោ អស្សាសបស្សាសេ ច កាយញ្ច រូបន្តិ ចិត្តញ្ច តំសម្បយុត្ត-ធម្មេ ច អរូបន្តិ ววត្ថបេតិ ។**

*តអំពីនោះមក ព្រះយោគាវចរ ទើបកំណត់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងឡាយ នូវកាយផងថា ជារូប, នូវចិត្តផង នូវធម៌ដែលសម្បយុត្តជាមួយចិត្តនោះផងថា ជានាម (**ក្នុងនាមរូបបរិច្ឆេទញាណ ជាញាណទី ១**)។*

**អយមេត្ថ សង្ខេបោ ។ វិត្ថារតោ បន នាមរូបววត្ថានំ បរតោ អាវិភវិស្សតិ ។**

*នេះជាសេចក្ដីសង្ខេប ក្នុងការកំណត់នូវនាម និងរូបនោះ ។ ចំណែកឯការកំណត់នូវនាម និងរូប ដោយសេចក្ដីពិស្ដារ នឹងមានប្រាកដច្បាស់នៅខាងមុខ ។*

**ឯវំ នាមរូបំ ววត្ថបេត្វា តស្ស បច្ចយំ បរិយេសតិ។**

*ព្រះយោគាចរ កាលកំណត់នូវនាម និងរូបយ៉ាងនេះហើយ ក៏រមែងស្វែងរកនូវហេតុបច្ច័យរបស់នាម និងរូបនោះ (**បច្ចយបរិគ្គហញាណទី២**)។*

**បរិយេសន្តោ ច នំ ទិស្វា តីសុបិ អទ្ធាសុ នាមរូបស្ស បវត្តឹ អារព្ភ កង្ខំ វិតរតិ។**

*ក៏ព្រះយោគាវចរ កាលស្វែងរក បានឃើញនូវហេតុបច្ច័យនោះហើយ ក៏រមែងឆ្លងផុតនូវសេចក្ដីសង្ស័យ ប្រារព្ធនូវសេចក្ដីព្យាយាមឱ្យប្រព្រឹត្តទៅ របស់នាម និងរូបក្នុងកាលសូម្បីទាំង ៣ កាល ។*

វិតិណ្ណកង្ខោ កលាបសម្មសនវសេន តិលក្ខណំ អារោបេត្វា ឧទយព្វយានុបស្សនាយ បុព្វភាគេ ឧប្បន្នេ ឱភាសាទយោ ទស វិបស្សនុបក្កិលេសេ បហាយ ឧបក្កិលេសវិមុត្តំ បដិបទាញាណំ មគ្គោតិ វវត្ថបេត្វា ឧទយំ បហាយ ភង្គានុបស្សនំ បត្វា និរន្តរំ ភង្គានុបស្សនេន វយតោ ឧបដ្ឋិតេសុ សព្វសង្ខារេសុ និព្វិន្ទន្តោ វិរជ្ជន្តោ វិមុច្ចន្តោ យថាក្កមេន ចត្តារោ អរិយមគ្គេ ចាបុណិត្វា អរហត្តផលេ បតិដ្ឋាយ ឯកូនវីសតិភេទស្ស បច្ចវេក្ខណាញាណស្ស បរិយន្តំ បត្តោ សទេវកស្ស លោកស្ស អគ្គទក្ខិណេយ្យោ ហោតិ ។

*ព្រះយោគាវចរ ជាអ្នកមានសេចក្តីសង្ស័យបានឆ្លងផុតហើយ លើកឡើង (នូវនាម និងរូប) កាន់ត្រៃលក្ខណ៍ ដោយអំណាចនៃការពិចារណាជារូបកលាប ហើយលះបង់រូបកលាបនោះ និងបានជួបនូវវិបស្សនូបក្កិលេសទាំង ១០ យ៉ាង មាន***ឱភាស*** *ជាដើម ដែលកើតឡើង ក្នុង***បុព្វភាគ** *(នៅក្នុងចំណែកខាងដើម) នៃ***ឧទយព្វយានុបស្សនាញាណ** *(ឬហៅថា* **សម្មសនញាណ** ***ជាញាណទី ៣*** *គឺកិរិយាពិចារណាឃើញនូវការកើតឡើង តាំងនៅ និងការរលត់បាត់ទៅវិញ ជា***ឧទយព្វយញាណ** *នៅទន់ខ្ចី), ហើយក៏កំណត់នូវ* **បដិបទា-ញាណ***( ឬហៅថា* **ឧទយព្វយញាណ** ***ជាញាណទី ៤*** **មានកម្លាំងខ្លាំង)** *ដែលផុតចាកពីឧបក្កិលេសទាំង១០នោះ, ថាជាមគ្គ(ជាដំណើរផ្លូវ) ហើយលះបង់នូវការកើតឡើង សម្រេចដល់* **ភង្គានុបស្សនា*(ជាញាណទី ៥*)** *កិរិយាពិចារណាឃើញនូវការបែកធ្លាយ ហើយក៏នឿយណាយ ធុញទ្រាន់ក្នុងសង្ខារទាំងពួង,* **ភយញាណ*(ជាញាណទី៦)*** *ដែលប្រាកដឡើងដោយភាពគួរភ័យខ្លាច) ,ដោយអំណាចនៃ* **ភង្គានុបស្សនាញាណ** *មិនមានចន្លោះ រួចផុតស្រឡះដល់នូវអរិយមគ្គទាំង ៤ ទៅតាមលំដាប់យ៉ាងណា តាំងនៅស៊ប់ក្នុងព្រះអរហត្តផល ដល់ហើយនូវទីបំផុតនៃ* **បច្ចវេក្ខណាញ្ញាណ*(ជាញាណទី១៦)*** *ដែលមាន ១៩ ប្រភេទ ជាអគ្គទក្ខិណេយ្យបុគ្គលនៃលោក ព្រមទាំងទេវលោក ។*

ឯត្តាវតា ចស្ស គណនំ អាទឹ កត្វា វិបស្សនាបរិយោសានា អានាបានស្សតិសមាធិភាវនា សមត្តា ហោតីតិ អយំ សព្វាការតោ បឋមចតុក្កវណ្ណនា។

*ការចម្រើននូវអានាបានស្សតិសមាធិភាវនា របស់ព្រះយោគាវចរភិក្ខុរូបនេះ ដែលចាប់ផ្តើមតាំងតែធ្វើការកំណត់រាប់ជាខាងដើមមក ទៅរហូតដល់* **បដិបស្សនាញាណ** *ដែលជាទីបំផុត ក៏ជាធម្មជាតិដែលបានចប់ស្រេចហើយដោយហេតុមានប្រមាណប៉ុណ្ណោះឯង នេះជាពាក្យពណ៌នានៅក្នុងចតុក្កទី ១ តាមអាការៈទាំងពួង ។*

## ការកំណត់នាម និងរូប

### (មហាដីកាវិសុទ្ធិមគ្គ)

[២៣៣] "**ឯត្ថា**"តិ ឯតិស្សំ កាយានុបស្សនាយំ។

*បទថា* "**ឯត្ថ** *ប្រែថា ក្នុងកាយានុបស្សនានេះ*" ។

"**ចារិសុទ្ធឹ បត្តុកាមោ**"តិ អធិគន្តុកាមោ, សមាបជ្ជិតុកាមោ ច, តត្ថ សល្លក្ខណាវិវដ្ដនាវសេន អធិគន្តុកាមោ, សល្លក្ខណាវសេន សមាបជ្ជិតុកាមោតិ យោជេតព្វំ ។

*ពាក្យថា* " **អ្នកណានឹងបានសម្រេចដល់បារិសុទ្ធិ**" *អ្នកណានឹងចាក់ធ្លុះ* **ចារិសុទ្ធិ** *និងអ្នកណាចូលកាន់***ចារិសុទ្ធិ** *(គឺអ្នកដែលចូលផលសមាបត្តិនោះឯង), ក្នុងពាក្យនោះ គប្បីប្រកបសេចក្តីថា អ្នកណានឹងបានសម្រេចនូវ* **ចារិសុទ្ធិ** *ដោយអំណាចនៃ* **សល្លក្ខណា** *និង* **វិវដ្ដនា**, *អ្នកណានឹងចូលកាន់* **ចារិសុទ្ធិ** *ដោយអំណាចនៃ* **សល្លក្ខណា** *។*

"**នាមរូបំ វវត្ថបេត្វា វិបស្សនំ បដ្ឋបេតី**"តិ សង្ខេបតោ វុត្តមត្ថំ វិត្ថារតោ ទស្សេតុំ "**កាយ**"ន្តិអាទិ វុត្តំ។

*លោកអាចារ្យ មានសេចក្តីប្រាថ្នានឹងសម្តែងថា កាលសេចក្តីដែលលោកពោលទុកដោយសង្ខេបថា "**ចាប់ផ្តើមចម្រើនវិបស្សនាទៅកំណត់នាម និងរូប**" ដូច្នេះ ដោយសេចក្តីពិស្តារ ទើបពោលថា "**តើយ៉ាងដូចម្តេច ?**" ដូច្នេះ ជាដើម ។*

**តត្ថ "យថា ហី"តិអាទិ កាយស្ស, ចិត្តស្ស ច អស្សាសបស្សាសានំ សមុទយការណស្សនំ ។**

*ក្នុងពាក្យទាំងនោះ ពាក្យថា "**ប្រៀបដូចជា**" ជាដើម ជាពាក្យដែលសម្តែងដល់ភារៈដែលកាយ និងចិត្ត ជាហេតុកើតឡើង នៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ។*

**"កម្មារគគ្គរិយា"តិ កម្មារានំ ឧក្កាយំ អគ្គិធមនភស្តា។**

*ពាក្យថា "**ចង្រ្កានស្នប់របស់ជាងមាស**" គឺចង្រ្កានស្នប់របស់ជាងមាស ដែលមានដងសម្រាប់សប់ផ្លុំខ្យល់ ។*

**"ធម្មានាយា"តិ ធមយន្តិយា, វាតំ គាហាបេន្តិយាតិ អត្ថោ។**

*បទថា "**ធម្មានាយ** ប្រែថា កាលស្រូប", សេចក្តីថា ធ្វើឱ្យចាប់យកនូវខ្យល់ ។*

**"តជ្ជំ"ន្តិ តទនុរូបំ។ "ឯវមេវា"តិ ឯត្ថ កម្មារគគ្គរីវិយ ករជកាយោ, វាយាមោ វិយ ចិត្តំ ឧជ្ជំ។**

*បទថា "**តជ្ជំ**" ប្រែថា **ដែលសមគួរដល់ការផាវនោះ** ។ ក្នុងពាក្យថា "**ក៏យ៉ាងនោះដូចគ្នា**" នេះ គប្បីជ្រាបថា **ករជកាយ** ប្រៀបដូចជា ចង្រ្កានស្នប់របស់ជាងមាស, **ចិត្ត** ប្រៀបដូចជា សេចក្តីព្យាយាម ។*

**កិញ្ចាបិ អស្សាសបស្សាសា ចិត្តសមុដ្ឋានា, ករជកាយំ បន វិនា តេសំ អប្បវត្តនតោ "កាយញ្ច ចិត្តញ្ច បដិច្ច អស្សាសបស្សាសា"តិ វុត្តំ។**

*ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ មានចិត្តជាសមុដ្ឋាន យ៉ាង*

*ពិតប្រាកដ, តែថាវៀរចាកនូវ ករជកាយហើយ ខ្យល់ដង្ហើមទាំងនោះក៏ប្រព្រឹត្តទៅមិនបានឡើយ លោកអាចារ្យទើបពោលថា "**ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ** រមែងចូល និងចេញបាន **ព្រោះអាស្រ័យនូវកាយ និងចិត្ត**" ដូច្នេះ ។*

**"តស្សា"តិ នាមរូបស្ស។ "បច្ចយំ បរិយេសតី"តិ "អវិជ្ជាសមុទយា រូបសមុទយោ"តិអាទិនា[៩៧]អវិជ្ជាទិកំ បច្ចយំ វីមំសតិ បរិគ្គណ្ហាតិ ។**

*បទថា "**តស្ស** ប្រែថា **របស់នាម និងរូបនោះ**" ។ ពាក្យថា "**រមែងស្វែងរកនូវបច្ច័យ**" បានដល់ រមែងសួរ និងឆ្លើយ គឺការកំណត់នូវហេតុបច្ច័យដែលមានអវិជ្ជាជាដើម ដោយន័យថា "ព្រោះអវិជ្ជាកើតឡើង ទើបរូបកើតឡើង" ដូច្នេះជាដើម ។*

**"កង្ខំ វិតរតី"តិ "អហោសិ នុ ខោ អហំ អតីតមទ្ធាន"ន្តិ[៩៨]អាទិនយប្បវត្តំ សោឡសវត្ថុកំ វិចិកិច្ឆំ អតិក្កមតិ បជហាតិ។**

*ពាក្យថា "**រមែងឆ្លងនូវសេចក្ដីសង្ស័យ**" បានដល់ រមែងឈានកន្លង គឺរមែងលះនូវសេចក្ដីសង្ស័យ ដែលមានវត្ថុ ១៦ ដែលប្រព្រឹត្តទៅដោយន័យថា "ក្នុងអតីតកាល យើងបានមានហើយឬហ្ន៎?" ដូច្នេះជាដើម ។*

**"យំ កិញ្ចិ រូបំ អតីតានាគតបច្ចុប្បន្ន"ន្តិ[៩៩]អាទិនយប្បវត្តំ កលាបសម្មសនំ ។**

*ការពិចារណាដែលប្រព្រឹត្តទៅដោយន័យថា "រូបយ៉ាងណានីមួយ ដែលជាអតីត អនាគត និងបច្ចុប្បន្ន (រូបនោះទាំងអស់មិនទៀង)" ដូច្នេះជាដើម ឈ្មោះថា **ជាការពិចារណានូវរូបកលាប** ។*

**"បុព្វភាគេ"តិ បដិបទាញាណទស្សនវិសុទ្ធិបរិយាបន្នាយ**

---

*៩៧ (បដិ. ម. ១.៥០) ។*

*៩៨ (ម. និ. ១.១៨; សំ. និ. ២.២០) ។*

*៩៩ (ម. និ. ១.៣៤៧; ៣៦១; ៣.៨៦; អ. និ. ៤.១៨១) ។*

ឧទយព្វយានុបស្សនាយ បុព្វភាគេ ។

*ពាក្យថា "**ក្នុងចំណែកខាងដើម**" គឺក្នុងចំណែកខាងដើម នៃឧទយព្វ-យានុបស្សនាញាណ ដែលរាប់នៅក្នុង បដិបទាញាណទស្សនវិសុទ្ធិ ។*

"**ឧប្បន្នេ ឱភាសាទយោ**"តិ ឱភាសោ ញាណំ បីតិ បស្សទ្ធិ សុខំ អធិមោក្ខោ បគ្គហោ ឧបេក្ខា ឧបដ្ឋានំ និកន្តីតិ ឥមេ ឱភាសាទយោ ទស ។

*ពាក្យថា "**វិបស្សនូបក្កិលេស ១០ យ៉ាង មានឱភាសជាដើមដែលកើតឡើង**" បានដល់វិបស្សនូបក្កិលេសទាំង ១០ យ៉ាងនេះ គឺ ១ ឱភាស, ២ ញាណ, ៣ បីតិ, ៤ បស្សទ្ធិ, ៥ សុខៈ, ៦ អធិមោក្ខៈ, ៧ បគ្គហៈ, ៨ ឧបេក្ខា, ៩ ឧបដ្ឋានៈ, ១០និកន្តិ ដូច្នេះ ។*

"**ឧទយំ បហាយា**"តិ ឧទយព្វយានុបស្សនាយ គហិតំ សង្ខារានំ ឧទយំ វិស្សជ្ជេត្វា ។

*ពាក្យថា "**លះទាំងការកើត**" គឺលះការកើតឡើងនៃសង្ខារដែលកាន់យកដោយ ឧទយព្វយានុបស្សនាញាណ ចេញ ។*

តេសំ ភង្គស្សេវ អនុបស្សនតោ ភង្គានុបស្សនំ ញាណំ **បត្វា** អាទីនវានុបស្សនាបុព្វង្គមាយ និព្វិទានុបស្សនាយ **និព្វិន្ទន្តោ** ។

*ឈ្មោះថា ចាក់ធ្លុះនូវ* **ភង្គានុបស្សនាញាណ**(*ជាញាណទី៥*) *ដោយការតាមពិចារណាឃើញចំពោះភាពបែកធ្លាយនិងកើតឡើងរបស់សង្ខារទាំងនោះតែម្យ៉ាង , ដែលមាន* **អាទីនវានុបស្សនាញាណ**(*ជាញាណទី៧*) *ព្រោះបានឃើញទុក្ខទោសគ្រប់ទាំងពួង ដែលមានការប្រែប្រួលទៅរហូតរកទីពឹងមិនបាន, ឈ្មោះថា* ***កាលនឿយណាយ*** *ដោយ* **និព្វិទានុបស្សនាញាណ** (***ជាញាណទី៨***) *បានឃើញដោយភាពនឿយណាយ ។*

មុញ្ចិតុកម្យតាបដិសង្ខានុបស្សនាសង្ខារុបេក្ខានុលោមញា-

ញាណំ ចិណ្ណាបរិយន្តេ ឧប្បន្នគោត្រភុញាណានន្តរំ ឧប្បន្នេន មគ្គញាណេន សព្វសង្ខារេសុ **វិរជ្ជន្តោ វិមុច្ចន្តោ ។**

**មុញ្ចិតុកម្យតាញាណ** *បានដឹងនូវអ្វីដែលនឹងរួចផុតទៅបាន(ញាណទី៩),* **បដិសង្ខារញាណ** *ដែលពិចារណារលើកឡើងវិញ ដើម្បីនឹងរកផ្លូវចៀសចេញទៅ(ញាណទី១០),* **សង្ខារុបេក្ខាញាណ** *ដែលប្រព្រឹត្តទៅដោយសភាពជាកណ្តាលៗ តម្កល់ជាធម្មតាៗចំពោះសង្ខារ(ញាណទី១១),* **អនុលោមញាណ** *ដែលប្រព្រឹត្តទៅតាមសមគួរដល់ការដឹងនូវអរិយសច្ចៈ ដែលអាចឃើញជាត្រៃលក្ខណ៍ផង(ញាណទី១២),* **គោត្រភូញាណ** *គ្របគ្រង់នូវគោត្របានដល់ការដឹងដ៏មានកម្លាំងបំផុត(ញាណទី១៣),* **មគ្គញាណ** *ញាណក្នុងអរិយមគ្គ(ញាណទី ១៤), ដែលបានសន្សំមកហើយ ក៏ឈ្មោះថា* **រួចផុតស្រឡះ** *។*

**មគ្គក្ខណេ ហិ អរិយោ វិរជ្ជតិ វិមុច្ចតីតិ ច វុច្ចតិ ។**

*មែនពិត ព្រះអរិយបុគ្គលបានពោលថា នឿយណាយ រួចផុតស្រឡះ ក៏ក្នុងខណៈនៃមគ្គ ។*

**តេនាហ "យថាក្កមេន ចត្តារោ អរិយមគ្គេ ចាបុណិត្វា"តិ ។**

*ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា* ***"បានសម្រេចនូវព្រះអរិយមគ្គ ៤ ទៅតាមលំដាប់"*** *ដូច្នេះ ។*

**មគ្គផលនិព្វានបហីនាវសិដ្ឋកិលេសសង្ខាតស្ស បច្ចវេក្ខិតព្វស្ស បភេទេន ឯកូនវីសតិភេទស្ស ។**

*ឈ្មោះថា* ***បច្ចវេក្ខណញាណ ដែលមាន ១៩ប្រភេទ*** *តាមប្រភេទនៃធម៌ដែលគប្បីពិចារណា ពោលគឺមគ្គ ផល ព្រះនិព្វាន កិលេសដែលលះហើយ និងកិលេសដែលនៅសេសសល់ ។*

**អរហតោ ហិ អវសិដ្ឋកិលេសាភាវេន ឯកូនវីសតិតា ។**

*មែនពិត ធម៌ដែលគប្បីពិចារណាមានសេចក្តី ១៩ យ៉ាង ព្រោះព្រះអរហត្ត មិនមានកិលេសដែលនៅសេសសល់ឡើយ ។*

**"អស្ស"**តិ អាណាចានកម្មដ្ឋានិកស្ស ។

*ពាក្យថា "របស់ភិក្ខុ**នោះ**" គឺរបស់ភិក្ខុអ្នកមានខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ មកជាកម្មដ្ឋាន ។*

# វេទនានុបស្សនា ចតុក្កៈទី ២[៦០]

## (វិសុទ្ធិមគ្គ)

[២៣៤] ឥតរេសុ បន តីសុ ចតុក្កេសុ យស្មា វិសុំ កម្មដ្ឋានភាវនានយោ នាម នត្ថិ។

*ចំណែកក្នុង ៣ ចតុក្កៈ ដទៃទៀត ព្រោះមិនមានភាវនាន័យនៃកម្មដ្ឋានជាផ្នែកផ្សេងគ្នា ។*

តស្មា អនុបទវណ្ណនានយេនេវ តេសំ ឯវំ អត្ថោ វេទិតព្វោ។

*ព្រោះហេតុនោះ ការអធិប្បាយនៃចតុក្កៈទាំងនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះ ទៅតាមន័យនៃពាក្យពណ៌នាទៅតាមលំដាប់បទតែប៉ុណ្ណោះ ។*

**"បីតិប្បដិសំវេទី"**តិ បីតឹ បដិសំវិទិតំ ករោន្តោ បាកដំ ករោន្តោ អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតិ។

*បទថា **"បីតិប្បដិសំវេទី"** ជាដើម បានសេចក្តីថា រមែងសិក្សាថាអាត្មាអញជាអ្នកធ្វើបីតិឱ្យដឹងច្បាស់ គឺធ្វើឱ្យប្រាកដ ដកដង្ហើមចូល ដកដង្ហើម*

*៦០ វេទនានុបស្សនាចតុក្កៈទី២នេះ មានទាំងសមថៈកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន*

*ចេញ ដូច្នេះ ។*

**តត្ថ ទ្វីហាការេហិ បីតិ បដិសំវិទិតា ហោតិ អារម្មណតោ ច អសម្មោហតោ ច ។**

*ក្នុងសេចក្តីនេះ មានការអធិប្បាយថា បីតិ រមែងជាធម្មជាតិ ដែលព្រះយោគាវចរដឹងច្បាស់ ដោយអាការៈ ២ យ៉ាង គឺ ១ដោយអារម្មណ៍ និង ២ដោយអសម្មោហ ។*

**កថំ អារម្មណតោ បីតិ បដិសំវិទិតា ហោតិ? សប្បីតិកេ ទ្វេ ឈានេ សមាបជ្ជតិ ។**

*សួរថា បីតិ រមែងជាធម្មជាតិ ដែលព្រះយោគាវចរដឹងច្បាស់* ***ដោយអារម្មណ៍*** *តើដូចម្តេច? ឆ្លើយថា ព្រះយោគាវចរ រមែងចូលកាន់ឈានក្នុងឈានទី ២ ដែលមានបីតិ ទើបដឹង ។*

**តស្ស សមាបត្តិក្ខណេ ឈានបដិលាភេន អារម្មណតោ បីតិ បដិសំវិទិតា ហោតិ, អារម្មណស្ស បដិសំវិទិតត្តា ។**

*ក្នុងខណៈដែលចូលកាន់ឈាន បីតិ នោះ ព្រះយោគាវចរ រមែងដឹងច្បាស់ ដោយអារម្មណ៍ គឺដោយការចូលឈាននោះឯង, ព្រោះជាអារម្មណ៍ដែលអ្នកត្រូវដឹងច្បាស់ហើយ ។*

**កថំ អសម្មោហតោ? សប្បីតិកេ ទ្វេ ឈានេ សមាបជ្ជិត្វា វុដ្ឋាយ ឈានសម្បយុត្តំ បីតឹ ខយតោ វយតោ សម្មសតិ ។**

*សួរថា តើបីតិ ជាធម្មជាតិ ដែលព្រះយោគាវចរដឹងច្បាស់* ***ដោយអសម្មោហោ*** *យ៉ាងដូចម្តេច? ឆ្លើយថា ព្រះយោគាវចរចូលឈានទី ២ ដែលមានបីតិ កាលចាកចេញហើយ ក៏ពិចារណានូវបីតិដែលសម្បយុត្តជាមួយឈានថា អស់ទៅ សូន្យទៅ ។*

**តស្ស វិបស្សនាក្ខណេ លក្ខណបដិវេធេន អសម្មោហតោ បីតិ បដិសំវិទិតា ហោតិ ។**

*បីតិ ក៏ព្រះយោគាវចរនោះ ជាអ្នកដឹងច្បាស់ហើយ ដោយអសម្មោហ ដោយការចាក់ធ្លុះនូវលក្ខណៈក្នុងខណៈនៃវិបស្សនា ។*

**វុត្តញ្ហេតំ បដិសម្ភិទាយំ**(៦១)–

*ក្នុងសេចក្តីនេះ សមតាមដែលព្រះសារីបុត្តថេរបានសម្តែងទុកក្នុងគម្ពីរបដិសម្ភិទាមគ្គថា ៖*

**"ទីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ ។**

*"កាលព្រះយោគាវចរភិក្ខុ ដឹងច្បាស់នូវឯកគ្គតានៃចិត្ត គឺភាពមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូលវែង សតិ ជាធម្មជាតិដែលចូលទៅតម្កល់ទុក (នៅត្រង់អារម្មណ៍) បានហើយ ។*

**តាយ សតិយា តេន ញាណេន សា បីតិ បដិសំវិទិតា ហោតិ។**

*បីតិនោះ ក៏ជាសភាវៈដែលអ្នកដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ។*

**ទីឃំ បស្សាសវសេន... រស្សំ អស្សាសវសេន... រស្សំ បស្សាសវសេន... សព្វកាយបដិសំវេទី អស្សាសបស្សាសវសេន... បស្សម្ភយំ កាយសង្ខារំ អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ ។**

*កាលព្រះយោគាវចរភិក្ខុ ដឹងច្បាស់នូវឯកគ្គតានៃចិត្ត គឺសភាពមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចេញវែង..., ដោយអំណាចនៃខ្យល់ដង្ហើមចូលខ្លី... ដោយអំណាចនៃខ្យល់ដង្ហើមចេញខ្លី..., ដោយអំណាចនៃ*

៦១ (បដិ. ម. ១.១៧២) ។

*ការកំណត់ដឹងឱ្យជាក់ច្បាស់នូវកាយ គឺខ្យល់ដង្ហើមចូលទាំងអស់ ជាចំណែកៗ ដោយល្អ ក្នុងខណៈដកដង្ហើមចូល និងក្នុងខណៈដកដង្ហើមចេញ..., កាលព្រះយោគាវចរភិក្ខុ ដឹងច្បាស់នូវឯកគ្គតានៃចិត្ត គឺសភាពមិនរាយមាយ ដោយអំណាចនៃការធ្វើកាយសង្ខារ គឺខ្យល់ដង្ហើមឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចូល និងក្នុងខណៈដកដង្ហើមចេញ សតិ ជាធម្មជាតិដែលចូលទៅតម្កល់ទុក (នៅត្រង់អារម្មណ៍) បានហើយ ។*

**តាយ សតិយា តេន ញាណេន សា បីតិ បដិសំវិទិតា ហោតិ។**

*បីតិនោះ ជាសភាវៈដែលអ្នកដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ ។*

**អាវជ្ជតោ សា បីតិ បដិសំវិទិតា ហោតិ។**

*កាលព្រះយោគាវចរភិក្ខុ នឹកដល់ បីតិនោះជាសភាវៈដែលអ្នកដឹងច្បាស់ហើយ ។*

**ជានតោ បស្សតោ បច្ចវេក្ខតោ ចិត្តំ អធិដ្ឋហតោ សទ្ធាយ អធិមុច្ចតោ វីរិយំ បគ្គណ្ហតោ សតឹ ឧបដ្ឋាបយតោ ចិត្តំ សមាទហតោ បញ្ញាយ បជានតោ អភិញ្ញេយ្យំ បរិញ្ញេយ្យំ បហាតព្វំ ភាវេតព្វំ សច្ឆិកាតព្វំ សច្ឆិករោតោ សា បីតិ បដិសំវិទិតា ហោតិ ។**

*កាលព្រះយោគាវចរភិក្ខុដឹងហើយ... កាលព្រះយោគាវចរភិក្ខុឃើញហើយ... កាលព្រះយោគាវចរភិក្ខុពិចារណាហើយ... កាលព្រះយោគាវចរភិក្ខុអធិដ្ឋានចិត្តហើយ... កាលព្រះយោគាវចរភិក្ខុបង្អោនចិត្តជឿដោយសទ្ធាហើយ... កាលព្រះយោគាវចរភិក្ខុផ្គងឡើងនូវសេចក្តីព្យាយាមហើយ... កាលព្រះយោគាវចរភិក្ខុធ្វើសតិឱ្យចូលទៅតម្កល់ទុកហើយ... កាលព្រះយោគាវចរភិក្ខុធ្វើចិត្តឱ្យតាំងមាំហើយ... កាលព្រះយោគាវចរភិក្ខុដឹងច្បាស់ដោយបញ្ញាហើយ... កាលព្រះយោគីភិក្ខុដឹងច្បាស់យ៉ាងក្រៃលែងនូវអភិញ្ញេយ្យធម៌ (គឺធម៌*

*ដែលគួរដឹងដោយបញ្ញាដ៏ពិសេសយ៉ាងក្រៃលែង)ហើយ ... កាលព្រះយោគាវចរភិក្ខុកំណត់ដឹង នូវបរិញ្ញេយ្យធម៌... កាលព្រះយោគាវចរភិក្ខុលះបហាតព្វធម៌... កាលព្រះយោគាវចរភិក្ខុចម្រើននូវភាវេតព្វធម៌... កាលព្រះយោគាវចរភិក្ខុធ្វើឱ្យជាក់ច្បាស់នូវសច្ឆិកាតព្វធម៌ បីតិនោះជាសភាវៈដែលអ្នកដឹងច្បាស់ហើយ ។*

**ឯវំ សា បីតិ បដិសំវិទិតា ហោតី"តិ។**

*បីតិនោះ ជាសភាវៈដែលព្រះយោគាវចរភិក្ខុដឹងច្បាស់ហើយ យ៉ាងនេះ" ដូច្នេះ ។*

**ឯតេនេវ នយេន អវសេសបទានិបិ អត្ថតោ វេទិតព្វានិ។**

*សូម្បីបទដទៃទៀត គប្បីជ្រាបនូវសេចក្តីទៅតាមន័យនេះឯង ។*

**ឥទម្បនេត្ថ វិសេសមត្តំ, តិណ្ណំ ឈានានំ វសេន សុខប្បដិសំវេទិតា, ចតុន្នម្បិ វសេន ចិត្តសង្ខារប្បដិសំវេទិតា វេទិតព្វា។**

*ក្នុងបទទាំងនេះ មានសេចក្តីផ្សេងៗគ្នា ដូចតទៅនេះ, គឺភាពជា* ***សុខប្បដិសំវេទី*** *ប្រែថា អ្នកដឹងនូវសេចក្តីសុខយ៉ាងជាក់ច្បាស់ គប្បីជ្រាបបានដោយអំណាចនៃឈានទី ៣, ភាពជា* ***ចិត្តសង្ខារប្បដិសំវេទី*** *ប្រែថា អ្នកដឹងនូវចិត្តសង្ខារយ៉ាងជាក់ច្បាស់ គប្បីជ្រាបបានដោយអំណាចនៃឈានទី ៤ ។*

**"ចិត្តសង្ខារោ"តិ វេទនាទយោ ទ្វេ ខន្ធា។**

*ពាក្យថា* **"ចិត្តសង្ខារ"** *បានដល់ ខន្ធ ២ ដែលមានវេទនាខន្ធជាដើម ។*

**សុខប្បដិសំវេទីបទេ ចេត្ថ វិបស្សនាភូមិទស្សនត្ថំ "សុខន្តិ ទ្វេ សុខានិ កាយិកញ្ច សុខំ ចេតសិកញ្ចា"តិ បដិសម្ភិទាយំ(៦២) វុត្តំ។**

*ក្នុងបទថា* **សុខប្បដិសំវេទី** *នោះ មានពាក្យពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គថា "ពាក្យថា* **សុខ** *បានដល់ សុខ ២ យ៉ាង គឺ***កាយិកសុខ** *ប្រែថា សុខតាមផ្លូវកាយ និង***ចេតសិកសុខ** *ប្រែថា សុខតាមផ្លូវចិត្ត" ដូច្នេះ*

៦២ (បដិ. ម. ១.១៧៣) ។

*នេះដើម្បីសម្ដែងនូវភូមិរបស់វិបស្សនា ។*

**"បស្សម្ភយំ ចិត្តសង្ខារ"ន្តិ ឱឡារិកំ ឱឡារិកំ ចិត្តសង្ខារំ បស្សម្ភេន្តោ, និរោធេន្តោតិ អត្ថោ។**

*រីឯសេចក្ដីថា* "**បស្សម្ភយំ ចិត្តសង្ខារំ**" *ជាដើម មានសេចក្ដីអធិប្បាយថា អាត្មាអញធ្វើចិត្តសង្ខារដែលគ្រោតគ្រាតៗ ឱ្យស្ងប់រម្ងាប់, គឺឱ្យរលត់បាត់ទៅ ដូច្នេះ ។*

**សោ វិត្ថារតោ កាយសង្ខារេ វុត្តនយេនេវ វេទិតព្វោ។**

*សេចក្ដីរលត់បាត់នោះ បណ្ឌិតគប្បីជ្រាបដោយពិស្ដារ ទៅតាមន័យដែលបានពោលមកហើយនៅក្នុងកាយសង្ខារ នុ៎ះឯង ។*

**អបិចេត្ថ បីតិបទេ បីតិសីសេន វេទនា វុត្តា។**

*មួយទៀត ក្នុងបទទាំងនោះ ក្នុងបទថា* **បីតិ** *ព្រះអង្គទ្រង់ត្រាស់សម្ដែងសំដៅដល់វេទនាដោយ* **បីតិ***ជាសំខាន់ ។*

**សុខបទេ សរូបេនេវ វេទនា។**

*ក្នុងបទថា* **សុខ** *ព្រះអង្គទ្រង់ត្រាស់សម្ដែងសំដៅដល់វេទនា ដោយសភាវៈរបស់ខ្លួនតែម្យ៉ាង ។*

**ទ្វីសុ ចិត្តសង្ខារបទេសុ "សញ្ញា ច វេទនា ច ចេតសិកា ឯតេ ធម្មា ចិត្តបដិពទ្ធា ចិត្តសង្ខារា"តិ(៦៣)វចនតោ សញ្ញាសម្បយុត្តា វេទនាតិ ។**

*ក្នុងបទថា ចិត្តសង្ខារទាំង ២ បទ ព្រះអង្គទ្រង់ត្រាស់សម្ដែងសំដៅដល់វេទនាដែលសម្បយុត្តជាមួយសញ្ញា ព្រោះមានព្រះបាលីសម្ដែងថា* "**សញ្ញា ច វេទនា ច ចេតសិកា ឯតេ ធម្មា ចិត្តបដិពទ្ធា ចិត្តសង្ខារា"តិ** *ប្រែថា "សញ្ញា និងវេទនាមាននៅក្នុងចិត្ត ធម៌ទាំងនេះជាប់អាស្រ័យជាមួយចិត្ត ទើបឈ្មោះថា*

---

៦៣ (បដិ. ម. ១.១៧៤; ម. និ. ១.៤៦៣) ។

*ចិត្តសង្ខារ" ដូច្នេះ នុ៎ះឯង ។*

**ឯវំ វេទនានុបស្សនានយេន ឥទំ ចតុក្កំ ភាសិតន្តិ វេទិតព្វំ។**

*តាមសេចក្តីដែលបានពោលមកហើយនេះ គប្បីជ្រាបថាក្នុងចតុក្កៈទី ២ នេះ ទ្រង់ភាសិតទុក* ***ដោយន័យនៃវេទនានុបស្សនា*** *យ៉ាងនេះឯង ។*

## វេទនានុបស្សនា ចតុក្កៈទី ២

### (មហាដីកាវិសុទ្ធិមគ្គ)

[២៣៤] **វិសុំ កម្មដ្ឋានភាវនានយោ នាម នត្ថិ** បឋមចតុក្កវសេន អធិគតឈានស្ស វេទនាចិត្តធម្មានុបស្សនាវសេន ទេសិតត្តា។ "**តេស**"ន្តិ តិណ្ណំ ចតុក្កានំ។

*ឈ្មោះថា មិនមានភាវនាន័យនៃកម្មដ្ឋានជាផ្នែកផ្សេងគ្នា ព្រោះទ្រង់សម្តែងទុក ដោយអំណាចជាវេទនានុបស្សនា ចិត្តានុបស្សនា និងធម្មានុបស្សនា របស់ព្រះយោគាវចរ ជាអ្នកបានសម្រេចនូវឈាន ដោយអំណាចនៃចតុក្កៈខាងដើម (ចតុក្កៈទី ១) ។ ពាក្យថា អធិប្បាយ នៃចតុក្កៈ* ***ទាំងនោះ*** *គឺនៃចតុក្កៈទាំង ៣ ទៀត ។*

"**បីតិប្បដិសំវេទី**"តិ បីតិយា បដិ បដិ សម្មទេវ វេទនាសីលោ, តស្សា វា បដិ បដិ សម្មទេវ វេទោ ឯតស្ស អត្ថិ, តំ វា បដិ បដិ សម្មទេវ វេទយមានោ។

*បទថា* "**បីតិប្បដិសំវេទី** *ប្រែថា អ្នកមានប្រក្រតីដឹងដោយល្អ ជាចំណែកៗ នូវបីតិ, ឬប្រែថា អ្នកមានការដឹងដោយល្អ ជាចំណែកៗ នូវបីតិនោះ, ឬ ប្រែថា ដឹងដោយល្អ ជាចំណែកៗ នូវបីតិនោះ ។*

តត្ថ កាមំ សំវេទនគ្គហណេនេវ បីតិយា សក្កច្ចំ វិទិតភាវោ ពោធិតោ ហោតិ, យេហិ បន បការេហិ តស្សា សំវេទនំ ឥច្ឆិតំ, តំ

ឧស្សេត្វាំ **បដិសទ្ធត្ថហាណំ** "បដិ បដិ សំវេទីតិ បដិសំវេទី"តិ ។

*ក្នុងពាក្យថា* **បីតិប្បដិសំវេទី** *នោះ សភាវៈបីតិដែលព្រះយោគាវចរដឹង ដោយគោរព ទ្រង់ធ្វើឱ្យយើងបានជ្រាបដោយសទ្ទាថា* **សំវេទន** *នោះឯង, ក៏ការដឹងនូវបីតិនោះ ទ្រង់ប្រាថ្នាហើយដោយបការៈណា, ដើម្បីសម្តែងនូវបការៈនោះ ទើបទ្រង់ប្រើសព្ទថា* បដិ *សេចក្តីថា ឈ្មោះថា* "បដិសំវេទី *ព្រោះអត្ថថា ជាអ្នកដឹងដោយល្អជាចំណែកៗ" ។*

តេនាហ "**ទ្វីហាការេហី**"តិអាទិ ។

*ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា "**ដោយអាការៈ ២ យ៉ាង**" ដូច្នេះជាដើម ។*

តត្ថ "**កថំ អារម្មណតោ បីតិ បដិសំវិទិតា ហោតី**"តិ បុច្ឆាវចនំ ។

*ក្នុងពាក្យទាំងនោះ ពាក្យថា "**បីតិជាធម្មជាតិដែលព្រះយោគាវចរដឹងច្បាស់ ដោយអារម្មណ៍ តើដូចម្តេច?**" នេះជាពាក្យសួរ ។*

"**សប្បីតិកេ ទ្វេ ឈានេ សមាបជ្ជតី**"តិ បីតិសហគតានិ ទ្វេ បឋមទុតិយឈានានិ បដិបាដិយា សមាបជ្ជតិ ។

*ពាក្យថា "**ព្រះយោគាវចរ រមែងចូលឈានទី ២ ដែលមានបីតិ**" គឺព្រះយោគាវចរ រមែងចូលឈានទី ២ គឺឈានទី ១ និងឈានទី ២ ដែលសហគតដោយបីតិទៅតាមលំដាប់ ។*

"**តស្សា**"តិ តេន។ "បដិសំវិទិតា"តិ ហិ បទំ អបេក្ខិត្វា កត្តុអត្ថេ ឯតំ សាមិវចនំ ។

*បទថា "**តស្ស**" កែទៅជា តេន ។ ព្រោះថា សម្ទឹងដល់បទថា "បដិសំវិ-ទិតា" ហើយ បទថា* តស្ស *នេះ ក៏ត្រូវការជាឆដ្ឋីវិភត្តិ ក្នុងអត្ថថា ជា* **កត្តុ** (អ្នកធ្វើ) ។

**"សមាបត្តិក្ខណេ"តិ សមាបន្នក្ខណេ។ ឈានបដិលាភេនាតិ ឈានេន សមង្គិភាវេន ។**

*បទថា "**សមាបត្តិក្ខណេ**" ប្រែថា ក្នុងខណៈដែលចូលឈាន ។ ពាក្យថា "**ដោយការបាននូវឈាន**" គឺដោយសភាវៈជាអ្នកដល់ព្រមដោយឈាន ។*

**"អារម្មណតោ"តិ អារម្មណមុខេន, តទារម្មណឈានបរិយាបន្នា បីតិ បដិសំវិទិតា ហោតិ អារម្មណស្ស បដិសំវិទិតត្តា ។**

*ពាក្យថា "**ដោយអារម្មណ៍**" គឺ ដោយអារម្មណ៍ជាច្រកផ្លូវ, សេចក្ដីថា បីតិដែលរាប់បញ្ចូលក្នុងអង្គឈាន ដែលមាននិមិត្តនោះជាអារម្មណ៍ រមែងជាសភាវៈដែលព្រះយោគាវចរបានដឹងច្បាស់ហើយ **ព្រោះជាអារម្មណ៍ ដែលអ្នកត្រូវដឹងច្បាស់ហើយ** ។*

**កថំ វុត្តំ ហោតិ? យថា នាម សប្បបរិយេសនំ ចរន្តេន តស្ស អាសយេ បដិសំវិទិតេ សោបិ បដិសំវិទិតោ គហិតោ ឯវ ហោតិ មន្តាគទពលេន តស្ស គហណស្ស សុករត្តា, ឯវំ បីតិយា អាសយភូតេ អារម្មណេ បដិសំវិទិតេ សា បីតិ បដិសំវិទិតា ឯវ ហោតិ សលក្ខណតោ, សាមញ្ញតោ ច តស្សា គហណស្ស សុករត្តាតិ ។**

*តើមានសេចក្ដីអធិប្បាយ ដូចម្ដេច ? មានសេចក្ដីអធិប្បាយយ៉ាងនេះថា ប្រៀបធៀបដូចជា កាលបុរសម្នាក់ ជាអ្នកដើរស្វែងរកសត្វពស់ ហើយបានដឹងច្បាស់នូវទីអាស្រ័យរបស់សត្វពស់នោះ ជាអ្នកដឹងច្បាស់ហើយក៏ចាប់នូវសត្វពស់នុ៎ះឯង ព្រោះការចាប់សត្វពស់ដោយកម្លាំងនៃការរាយមន្តអាគមនោះ វាជារឿងដែលធ្វើបានដោយងាយ យ៉ាងណា, កាលព្រះយោគាវចរ បានដឹងច្បាស់នូវអារម្មណ៍ ដែលជាទីអាស្រ័យនៃបីតិហើយ ក៏ជាការដឹងច្បាស់នូវបីតិនោះហើយដូចគ្នា ព្រោះថា ការកាន់យកនូវបីតិនោះ ដោយលក្ខណៈរបស់ខ្លួន និងដោយសាមញ្ញលក្ខណៈ វាជារឿងដែលធ្វើបានដោយងាយហើយក៏យ៉ាងនោះ*

*ដែរ បែបនេះឯង ។*

**កថំ អសម្មោហតោ បីតិ បដិសំវិទិតា ហោតីតិ អាទេត្វា សម្ពន្ធិតព្វំ។**

*សួរថា បីតិ ជាធម្មជាតិ ដែលព្រះយោគាវចរដឹងច្បាស់ដោយ* **អសម្មោហ** *តើដូចម្ដេច ? ។*

**"វិបស្សនាក្ខណេ"តិ វិបស្សនាបញ្ញាយ តិក្ខវិសទប្បត្តាយ វិសយតោ ទស្សនក្ខណេ ។**

*ពាក្យថា* ***"ក្នុងខណៈនៃវិបស្សនា"*** *គឺក្នុងខណៈដែលឃើញ (បីតិ) ដោយអារម្មណ៍ជាវិបស្សនាបញ្ញា ដែលដល់ភាពបរិសុទ្ធស្អាតមុតស្រួច ។*

**"លក្ខណបដិវេធេនា"តិ បីតិយា សលក្ខណស្ស, សាមញ្ញលក្ខណស្ស ច បដិវិជ្ឈនេន។**

*ពាក្យថា "ដោយការចាក់ធ្លុះនូវលក្ខណៈ" គឺដោយការចាក់ធ្លុះនូវលក្ខណៈរបស់ខ្លួន និងសាមញ្ញលក្ខណៈនៃបីតិ ។*

**យំ ហិ យស្ស វិសេសតោ, សាមញ្ញតោ ច លក្ខណំ, តស្មិំ វិទិតេ សោ យាថាវតោ វិទិតោ ឯវ ហោតិ ។**

*មែនពិត កាលព្រះយោគាវចរ ដឹងច្បាស់នូវលក្ខណៈដោយពិសេស និងដោយសាមញ្ញរបស់ខ្លួនក្នុងធម៌ណាបានហើយ ជាការដឹងនូវធម៌នោះ តាមសេចក្ដីពិតហើយនោះឯង ។*

**តេនាហ "អសម្មោហតោ បីតិ បដិសំវិទិតា ហោតី"តិ។**

*ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា "បីតិ ក៏ព្រះយោគាវចរនោះ ជាអ្នកកំណត់ដឹងច្បាស់ជាចំណែកៗ ដោយល្អនូវបីតិ* **អសម្មោហ**" *ដូច្នេះ ។*

ឥទានិ តមត្ថំ ចាជ្ឈិយា ឯវ វិភាវេតុំ "វុត្តញ្ហេត"ន្តិអាទិមាហ។

*ឥឡូវនេះ ព្រះអាចារ្យលោកប្រាថ្នាបើកបង្ហាញនូវសេចក្តីនោះ ជាព្រះបាលីនុ៎ះឯង ទើបពោលថា* ***"ក្នុងសេចក្តីនេះ សមតាមដែលព្រះសារីបុត្តថេរបានសម្តែងទុកមកថា"*** *ដូច្នេះជាដើម ។*

តត្ថ **"ទីឃំ អស្សាសវសេនា"**តិអាទីសុ យំ វត្តព្វំ, តំ ហេដ្ឋា វុត្តមេវ។

*ក្នុងពាក្យថា* ***"ដោយអំណាចនៃខ្យល់ដង្ហើមចូលវែង"*** *ជាដើម ក្នុងគម្ពីរព្រះត្រៃបិដកបដិសម្ភិទាមគ្គនោះ ខ្ញុំម្ចាស់គួរពោលអធិប្បាយនូវពាក្យនោះទុកយ៉ាងណា, រីពាក្យនោះ ខ្ញុំម្ចាស់បានពោលអធិប្បាយទុកមកហើយ នូវន័យខាងដើមនុ៎ះឯង ។*

តត្ថ បន សតោការិនោឧស្សនវសេន ចាជ្ឈិ អាគតា, ឥធ បីតិបដិសំវេទិតាវសេន, បីតិបដិសំវេទិតា ច អត្ថតោ វិភត្តា ឯវ។

*តែថា នៅក្នុងទីនោះ ព្រះបាលីមានសេចក្តីជាប់ទាក់ទងជាមួយការសម្តែងនូវ* **សតោការី** *(អ្នកមានប្រក្រតីចម្រើននូវសតិ), ហើយនៅក្នុងទីនេះមានសេចក្តីជាប់ទាក់ទងជាមួយសភាវៈរបស់បីតិ ដែលព្រះយោគាវចរបានដឹងច្បាស់ហើយ និងភាពជាអ្នកធ្វើបីតិឱ្យជាក់ច្បាស់ លោកក៏បានចែកទុកដោយអត្ថសេចក្តីរួចមកហើយនុ៎ះឯង ។*

អបិច អយមេត្ថ សង្ខេបត្ថោ –

*តទៅទៀតនេះ ជាសេចក្តីសង្ខេបនៅក្នុងសេចក្តីនេះ ៖*

**"ទីឃំ អស្សាសវសេនា"**តិ ទីឃស្ស អស្សាសស្ស អារម្មណភូតស្ស វសេន បជានតោ សា បីតិ បដិសំវិទិតា ហោតីតិ សម្ពន្ធោ។

*ពាក្យថា* ***"ដោយអំណាចនៃខ្យល់ដង្ហើមចូលវែង"*** *បានដល់ ដោយអំណាចនៃខ្យល់ដង្ហើមចូលវែង ដែលជាអារម្មណ៍ ភ្ជាប់សេចក្តីថា កាលព្រះយោគាវចរ*

*ភិក្ខុនោះដឹងច្បាស់នូវបីតិនោះ វាជាការដែលអ្នកដឹងច្បាស់ហើយ ។*

**"ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ"**តិ ឈានបរិយាបន្នំ "អវិក្ខេ-បោ"តិ លទ្ធនាមំ ចិត្តស្សេកគ្គតំ តំសម្បយុត្តាយ បញ្ញាយ បជានតោ។

*ពាក្យថា* ***"កាលព្រះយោគាវចរភិក្ខុ ដឹងច្បាស់នូវឯកគ្គតានៃចិត្ត គឺភាពមិនរាយមាយ"*** *គឺកាលព្រះយោគាវចរភិក្ខុ ដឹងច្បាស់នូវឯកគ្គតានៃចិត្ត ដែលរាប់បញ្ចូលក្នុងឈាន បានឈ្មោះថា "មិនមានភាពរាយមាយ" ដោយបញ្ញាដែលសម្បយុត្តជាមួយឯកគ្គតានោះ ។*

យថេវ ហិ អារម្មណមុខេន បីតិ បដិសំវិទិតា ហោតិ, ឯវំ តំសម្បយុត្តធម្មាបិ អារម្មណមុខេន បដិសំវិទិតា ឯវ ហោន្តីតិ។

*មែនពិត បីតិ ជាធម្មជាតិ ដែលព្រះយោគាវចរភិក្ខុដឹងច្បាស់ ដោយអារម្មណ៍ជាច្រកផ្លូវយ៉ាងណា, សូម្បីធម៌ទាំងឡាយដែលសម្បយុត្តជាមួយបីតិនោះ ក៏ជាធម្មជាតិដែលភិក្ខុដឹងច្បាស់បានតាមអារម្មណ៍ វាជាច្រកផ្លូវ ក៏យ៉ាងនោះដូចគ្នាដែរ ។*

**"សតិ ឧបដ្ឋិតា ហោតី"**តិ ឥមិនា អស្សាសវសេន ឈានសម្បយុត្តា សតិ តស្ស អារម្មណេ ឧបដ្ឋិតា អារម្មណមុខេន ឈានេបិ ឧបដ្ឋិតា នាម ហោតិ ។

*ពាក្យថា* ***"សតិ រមែងជាធម្មជាតិ ដែលចូលទៅតម្កល់ទុកហើយ"*** *បានសេចក្តីថា សតិ ដែលសម្បយុត្តជាមួយឈាន ព្រះយោគាវចរភិក្ខុនោះចូលទៅតម្កល់ទុក នៅត្រង់អារម្មណ៍នោះបានហើយ ដោយអំណាចនៃខ្យល់ដង្ហើមចូលវែង ឈ្មោះថា ជាការដែលចូលទៅតម្កល់ទុកសូម្បីក្នុងឈាន ដោយអារម្មណ៍ជាច្រកផ្លូវ ។*

**"តាយ សតិយា"**តិ ឯវំ ឧបដ្ឋិតាយ តាយ សតិយា យថាវុត្តេន តេន ញាណេន សុប្បដិវិទិតត្តា អារម្មណស្ស តស្ស វសេន តទារម្មណា សា

**បីតិ បដិសំវិទិតា ហោតិ ។**

*ពាក្យថា "**ដោយសតិនោះ**" ជាដើម បានសេចក្តីថា បីតិនោះ ដែលមាននិមិត្តនោះមកជាអារម្មណ៍ **រមែងជាការដែលភិក្ខុដឹងច្បាស់ហើយ** ដោយអំណាចនៃអារម្មណ៍នោះ ព្រោះអារម្មណ៍ ជាការដែលភិក្ខុដឹងច្បាស់ហើយបានយ៉ាងល្អ ដោយសតិដែលបានតម្កល់ទុកយ៉ាងនេះ **ដោយញាណ**តាមដែលបានពោលមកហើយនោះ ។*

**"ឥមំ បសាសវសេន"**តិអាទីសុបិ ឥមិនាវ នយេន អត្ថោ វេទិតព្វោ។

*សូម្បីក្នុងពាក្យថា "**ដោយអំណាចនៃខ្យល់ដង្ហើមចេញវែង**" ជាដើម ក៏បណ្ឌិតគប្បីជ្រាបនូវសេចក្តីនោះ តាមន័យនេះឯង ។*

**ឯវំ បឋមចតុក្កវសេន ឧទ្ទិដ្ឋំ បីតិបដិសំវេទនំ អារម្មណតោ, អសម្មោហតោ ច វិភាគសោ ឧទ្ទេសេតុំ "អាវជ្ជតោ"តិអាទិ វុត្តំ។**

*លោកអាចារ្យ ប្រាថ្នានឹងសម្តែងការដឹងច្បាស់បីតិដែលបានសម្តែងទុកដោយជាប់ទាក់ទងជាមួយចតុក្កៈខាងដើម ហើយយ៉ាងនេះ ដោយការចែកទៅតាមអារម្មណ៍ និងអសម្មោហៈ ទើបពោលថា "កាលភិក្ខុនឹកដល់" ដូច្នេះជាដើម ។*

**តត្ថ "អាវជ្ជតោ"តិ ឈានំ អាវជ្ជន្តស្ស។ "សា បីតី"តិ សា ឈានបរិយាបន្នា បីតិ ។**

*ក្នុងពាក្យទាំងនោះ ពាក្យថា "**កាលយោគីភិក្ខុនឹកដល់**" គឺកាលភិក្ខុនឹកដល់ឈាន (គឺនឹកដល់ពន្លឺបដិភាគនិមិត្ត) ។ ពាក្យថា "**បីតិនោះ**" បានដល់បីតិដែលរាប់បញ្ចូលទៅក្នុងអង្គឈាន ។*

**"ជានតោ"តិ សមាបន្នក្ខណេ អារម្មណមុខេន ជានតោ ។**

*ពាក្យថា "**កាលភិក្ខុដឹង**" គឺកាលភិក្ខុដឹង ដោយអារម្មណ៍ជាប្រក្រតី ក្នុងខណៈដែលចូលឈាន ។*

**តស្ស សា បីតិ បដិសំវិទិតា ហោតីតិ សម្ពន្ធោ ។**

*សេចក្ដីថា បីតិនោះ ជាសភាវៈដែលអ្នកដឹងច្បាស់ប្រាកដហើយ ។*

**"បស្សតោ"តិ ឧស្សនកូតេន ញាណេន ឈានតោ វុដ្ឋាយ បស្សន្តស្ស។**

*ពាក្យថា "**កាលព្រះយោគីភិក្ខុឃើញ**" គឺកាលយោគីភិក្ខុចាកចេញអំពីឈានហើយ បានឃើញដោយញាណ ដែលជាគ្រឿងឃើញ ។*

**"បច្ចវេក្ខតោ"តិ ឈានំ បច្ចវេក្ខន្តស្ស។**

*ពាក្យថា "**កាលព្រះយោគីភិក្ខុបច្ចវេក្ខណ**" គឺកាលយោគីភិក្ខុពិចារណានូវឈាន (គឺពិចារណាអង្គឈានថា វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា មានគ្រប់បរិបូរណ៍ហើយ) ។*

**"ចិត្តំ អធិដ្ឋហតោ"តិ "ឯត្តកំ វេលំ ឈានសមង្គី ភវិស្សាមី"តិ ឈានចិត្តំ អធិដ្ឋហន្តស្ស។**

*ពាក្យថា "**កាលយោគីភិក្ខុអធិដ្ឋានចិត្ត**" គឺកាលយោគីភិក្ខុអធិដ្ឋាននូវឈានថា "យើងជាអ្នកនៅជាមួយឈាននេះ (ចូលឈាន) តែម្យ៉ាង នៅរហូតអស់កាលប៉ុណ្ណោះ" (ឬថា ខ្ញុំសូមនៅជាមួយបឋមជ្ឈាននេះរយៈពេល ១ម៉ោង រួចហើយក៏បង្អោនចិត្តចូលក្នុងឈានទៅ) ដូច្នេះ ។*

**ឯវំ បញ្ចន្នំ វសីភាវានំ វសេន ឈានស្ស បជាននមុខេន អារម្មណតោ បីតិយា បដិសំវេទនា ទស្សិតា។**

*ដោយបការៈដែលបានពោលមកហើយនេះ ជាការដែលព្រះអាចារ្យបានសម្ដែងឱ្យដឹងច្បាស់នូវបីតិតាមអារម្មណ៍ ជាការដឹងច្បាស់នូវឈានជាប្រក្រតី*

*ដោយអំណាចនៃវសីភាវៈ ៩ យ៉ាង (គឺការហ្វឹកហាត់ឱ្យស្ទាត់ជំនាញក្នុងចំណុច ៩ យ៉ាង) ។*

ឥធានិ យេហិ ធម្មេហិ ឈានំ, វិបស្សនា ច សិជ្ឈន្តិ; តេសំ ឈានបរិយាបន្នានំ, វិបស្សនាមគ្គបរិយាបន្នានញ្ច សទ្ធាទីនំ វសេន បីតិបដិសំវេទនំ ទស្សេតុំ "**សទ្ធាយ អធិមុច្ចតោ**"តិអាទិ វុត្តំ ។

*ឈាន និងវិបស្សនា នឹងសម្រេចបានដោយធម៌ទាំងឡាយណា, ឥឡូវនេះ អាចារ្យ លោកប្រាប់ថានឹងសម្ដែងឱ្យដឹងច្បាស់នូវបីតិ ដោយជាប់ទាក់ទងជាមួយ ធម៌ មានសទ្ធាជាដើម ដែលរាប់បញ្ចូលទៅក្នុងឈាន, និងរាប់បញ្ចូលទៅក្នុង វិបស្សនា និងមគ្គទាំងនោះ ទើបលោកពោលថា "**កាលព្រះយោគីភិក្ខុ បង្អោន ចិត្តជឿដោយសទ្ធា**" ដូច្នេះ ជាដើម ។*

តត្ថ "**អធិមុច្ចតោ**"តិ សទ្ទហន្តស្ស, សមថវិបស្សនាវសេនាតិ អធិប្បាយោ។

*ក្នុងពាក្យទាំងនោះ ពាក្យថា "**កាលព្រះយោគីភិក្ខុ បង្អោនចិត្តជឿ**" គឺកាល យោគីភិក្ខុ បង្អោនចិត្តជឿ អធិប្បាយថា ដោយជាប់ទាក់ទងជាមួយសមថៈ និង វិបស្សនា ។*

"**វីរិយំ បគ្គណ្ហតោ**"តិអាទីសុបិ ឯសេវ នយោ។

*សូម្បីក្នុងពាក្យថា "**កាលព្រះយោគីភិក្ខុ ផ្គងនូវសេចក្ដីព្យាយាម**" ជាដើម ក៏មានន័យដូចគ្នា នុ៎ះឯង ។*

"**អភិញ្ញេយ្យ**"ន្តិ អភិវិសិដ្ឋាយ បញ្ញាយ ជានិតព្វំ។

*ពាក្យថា "**កាលអភិញ្ញេយ្យធម៌**" គឺធម៌ដែលគួរដឹងដោយបញ្ញាដ៏ពិសេស យ៉ាងក្រៃលែង ។*

"**អភិជានតោ**"តិ វិបស្សនាបញ្ញាបុព្វង្គមាយ មគ្គបញ្ញាយ

ជានតោ។

*ពាក្យថា "**កាលព្រះយោគីភិក្ខុដឹងច្បាស់យ៉ាងក្រៃលែង**" គឺកាលយោគីភិក្ខុដឹងច្បាស់ ដោយមគ្គបញ្ញា ដែលមានវិបស្សនាបញ្ញាជាខាងដើម ។*

**"បរិញ្ញេយ្យ"ន្តិ ទុក្ខសច្ចំ តីរណបរិញ្ញាយ, មគ្គបញ្ញាយ ច បរិជានតោ។**

*ពាក្យថា "**កាលយោគីភិក្ខុកំណត់ដឹងនូវបរិញ្ញេយ្យធម៌**" គឺកាលយោគីភិក្ខុកំណត់ដឹងនូវទុក្ខសច្ចៈ ដោយ* **តីរណបរិញ្ញា**, *និងដោយ* **មគ្គបញ្ញា** ។

**"បហាតព្វ"ន្តិ សមុទយសច្ចំ បហានបរិញ្ញាយ, មគ្គបញ្ញាយ ច បជហតោ។**

*ពាក្យថា "**កាលយោគីភិក្ខុលះ បហាតព្វធម៌**" គឺកាលយោគីភិក្ខុលះនូវ* សមុទយសច្ច *ដោយ* បហានបរិញ្ញា, *និង* មគ្គបញ្ញា ។

**ភាវយតោ សច្ឆិករោតោ ភាវេតព្វំ មគ្គសច្ចំ, សច្ឆិកាតព្វំ និរោធសច្ចំ។**

*ឈ្មោះថា **កាលយោគីភិក្ខុចម្រើនភាវេតព្វធម៌** គឺចម្រើននូវមគ្គសច្ច, **ធ្វើឱ្យជាក់ច្បាស់នូវសច្ឆិកាតព្វធម៌** គឺធ្វើឱ្យជាក់ច្បាស់នូវនិរោធសច្ច ។*

**កេចិ បនេត្ថ បីតិយា ឯវ វសេន អភិញ្ញេយ្យានីតិ វទន្តិ, តំ អយុត្តំ ឈានាទិសមុទាយំ ឧទ្ធរិត្វា តតោ បីតិយា និទ្ធារណស្ស អធិប្បេតត្តា។**

*ក្នុងរឿងនេះព្រះអាចារ្យ ពួកខ្លះ លើកបទបាលីថា* **អភិញ្ញេយ្យំ** *ប្រែថា នូវធម៌ដែលគួរដឹងយ៉ាងក្រៃលែង ជាដើមទុក ដោយជាប់ទាក់ទងជាមួយបីតិតែប៉ុណ្ណោះ, ពាក្យនោះពិតជាមិនត្រឹមត្រូវឡើយ ព្រោះលោកមានក្តីប្រាថ្នានឹងលើកប្រជុំធម៌ដែលមានឈាន ជាដើម ហើយដកយកនូវបីតិចេញពីប្រជុំធម៌នោះ* (មកពោល) ។

ឯត្ថ ច "ទីឃំ អស្សាសវសេនា"តិអាទិនា បឋមចតុក្កវសេន អារម្មណតោ បីតិប្បដិសំវេទនំ វុត្តំ, តថា "អាវជ្ជតោ"តិអាទីហិ បញ្ចហិ បទេហិ។

*មួយទៀត នៅក្នុងសេចក្ដីនេះ គប្បីជ្រាបថា ដោយបទថា "ដោយអំណាចនៃខ្យល់ដង្ហើមចូលវែង" ជាដើម វាជាការដែលលោកបានពោលដល់ការដឹងច្បាស់នូវបីតិ ដោយអារម្មណ៍ ដោយជាប់ទាក់ទងជាមួយចតុក្កៈខាងដើម, ដោយមាន ៥ បទ ថា "កាលព្រះយោគីភិក្ខុ នឹកដល់" ជាដើម ក៏យ៉ាងនោះដូចគ្នា ។*

"អភិញ្ញេយ្យំ អភិជានតោ"តិអាទីហិ បន អសម្មោហតោ។

*ចំណែកបទថា "កាលព្រះយោគីភិក្ខុ ដឹងច្បាស់នូវធម៌អភិញ្ញេយ្យ" ជាដើម ជាការដែលលោកពោលដល់ ការដឹងច្បាស់នូវបីតិ ដោយ អសម្មោហ ។*

"សទ្ធាយ អធិមុច្ចតោ"តិអាទីហិ ឧភយថាបីតិ សង្ខេបតោ សមថវសេន អារម្មណតោ, វិបស្សនាវសេន អសម្មោហតោ បីតិបដិសំវេទនំ វុត្តន្តិ ឧជ្ឈព្វំ។

*ដោយបទថា "កាលយោគីភិក្ខុ បង្អោនចិត្តជឿដោយសទ្ធា" ជាដើម ជាការដែលលោកពោលសំដៅដល់ ការដឹងច្បាស់នូវបីតិ សូម្បីតាមប្រការទាំង ២ យ៉ាង ព្រោះហេតុនោះ ដោយសង្ខេបគប្បីឃើញថា លោកពោលការដឹងច្បាស់នូវបីតិ ដោយអារម្មណ៍ ដោយអំណាចសមថៈ, ជាអសម្មោហៈដោយអំណាចវិបស្សនា ។*

កស្មា បនេត្ថ វេទនានុបស្សនាយំ បីតិសីសេន វេទនា គហិតា, ន សរូបតោ ឯវាតិ? ភូមិវិភាគាទិវសេន វេទនំ ភិន្ទិត្វា ចតុធា វេទនានុបស្សនំ ទស្សេតុំ ។

*សួរថា ក្នុងវេទនានុបស្សនានេះ ព្រោះហេតុអ្វី ទើបលោកកាន់យកវេទនា*

*ដោយបីតិជាសំខាន់, ហើយមិនកាន់យកដោយសភាវៈ ដែលមាន(ដោយត្រង់ខ្លួន) តែម្តងទៅ? ឆ្លើយថា លោកកាន់យកវេទនា ដោយបីតិជាសំខាន់ មិនកាន់យកដោយសភាវៈដែលមាន ក៏ដើម្បីនឹងញែកនូវវេទនា ដោយអំណាចការចែកនូវភូមិជាដើម ហើយសម្តែងនូវវេទនានុបស្សនាទុកជា ៤ ប្រការ ។*

**អបិច វេទនាកម្មដ្ឋានំ ទស្សេន្តោ ភគវា បីតិយា ឱឡារិកត្តា តំសម្បយុត្តសុខំ សុខគ្គហណត្ថំ បីតិសីសេន ទស្សេតិ។**

*ន័យម្យ៉ាងទៀត ព្រោះសភាវៈបីតិ ជាធម្មជាតិដែលគ្រោតគ្រាត ព្រះដ៏មានព្រះភាគជាម្ចាស់ ជាអ្នកសម្តែងនូវវេទនាកម្មដ្ឋាន ទើបទ្រង់សម្តែងនូវសុខដែលសម្បយុត្តជាមួយបីតិជាសំខាន់ ក៏ដើម្បីកាន់យក (នូវការយល់ចូលចិត្ត) បានងាយស្រួល ។*

**"ឯតេនេវ នយេន អវសេសបទានី"តិ "សុខបដិសំវេទី ចិត្តសង្ខារបដិសំវេទី"តិ បទានិ បីតិបដិសំវេទិបទេ អាគតនយេនេវ អត្ថតោ វេទិតព្វានិ ។**

*ពាក្យថា "**សូម្បីបទដទៃទៀត គប្បីជ្រាបនូវសេចក្តីទៅតាមន័យនេះឯង**" សេចក្តីថា បទថា "**សុខបដិសំវេទី ចិត្តសង្ខារបដិសំវេទី**" គប្បីជ្រាបដោយអត្ថ ទៅតាមន័យដែលមានមកហើយក្នុងបទថា **បីតិប្បដិសំវេទី** នុ៎ះឯង។*

**សច្ចំ ហិ "ទ្វីហាការេហិ សុខប្បដិសំវេទិតា ហោតិ, ចិត្តសង្ខារប្បដិសំវេទិតា ហោតិ អារម្មណតោ"តិអាទិនា បីតិដ្ឋានេ សុខាទិបទានិ បក្ខិបិត្វា "សុខសហគតានិ តីណិ ឈានានិ, ចត្តារិ វា ឈានានិ សមាបជ្ជតី"តិអាទិនា អត្ថំ វិញ្ញាតុំ ។**

*មែនពិត បណ្ឌិតអាចនឹងបញ្ចូលបទថា **សុខ** ជាដើម មកជំនួសបទ **បីតិ** បាន ដោយន័យថា "សេចក្តីជា **សុខប្បដិសំវេទី** រមែងមាន ដោយអាការៈ ២ យ៉ាងគឺ រមែងមានជា **ចិត្តសង្ខារប្បដិសំវេទី** និង រមែងមានដោយអារម្មណ៍"*

*ដូច្នេះជាដើម ហើយយល់ចូលចិត្តដោយន័យថា "ភិក្ខុ រមែងចូលឈាន ទី ៣ ឬ ទី ៤ ដែល* ***សហគត*** *ដោយសុខ" ដូច្នេះជាដើម ។*

តេនាហ "**តិណ្ណំ ឈានានំ វសេនា**"តិអាទិ។

*ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា "**ដោយអំណាចនៃឈាន ទី ៣**" ដូច្នេះជាដើម ។*

**វេទនាទយោតិ អាទិ**-សទ្ទេន សញ្ញា គហិតា។ តេនាហ "**ទ្វេ ខន្ធា**"តិ។

*ដោយ* **អាទិ**-*សព្ទ ក្នុងបទថា វេទនាទយោ ប្រែថា មានវេទនាជាដើម លោកកាន់យកសញ្ញា ។ ព្រោះហេតុនោះ ទើបលោកពោលថា "**ខន្ធ ២**" ដូច្នេះ ។*

"**វិបស្សនាភូមិទស្សនត្ថ**"ន្តិ បកិណ្ណកសង្ខារសម្មសនវសេន វិបស្សនាយ ភូមិទស្សនត្ថំ "**សុខន្តិ ទ្វេ សុខានី**"តិអាទិ វុត្តំ សមថេ កាយិកសុខាភាវតោ។

*ពាក្យថា "**ដើម្បីសម្ដែងនូវភូមិរបស់វិបស្សនា**" គឺដើម្បីសម្ដែងនូវភូមិរបស់ វិបស្សនា ដោយអំណាច ការពិចារណាជា បកិណ្ណកសង្ខារ លោកពោលថា "**បទថា សុខ បានដល់ សុខ ២ យ៉ាង**" ជាដើម ព្រោះនៅក្នុងសមថៈមិនមាន សុខ តាមផ្លូវកាយទេ ។*

"**សោ**"តិ សោ បស្សម្ភនបរិយាយេន វុត្តោ និរោធោ។

*បទថា "សោ" បានដល់* ***សេចក្ដីរលត់នោះ*** *ដែលលោកពោលទុកដោយ សេចក្ដីបរិយាយថា រម្ងាប់ ។*

"ឥមស្ស ហិ ភិក្ខុនោ បុព្វេ អបរិគ្គហិតកាលេ"តិអាទិនា[៦៤] វិត្ថារតោ កាយសង្ខារេ វុត្តោ, តស្មា វុត្តនយេនេវ វេទិតព្វោ។

៦៤ (វិសុទ្ធិ. ១.២២០) ។

*ដែលបានពោលទុកនៅក្នុងសេចក្តីកាយសង្ខារយ៉ាងពិស្តារហើយ ដោយន័យថា "គឺថា កាយ និងចិត្ត របស់ភិក្ខុនេះ ក្នុងកាលមុនដែលមិនទាន់បានកំណត់កាន់យក" ដូច្នេះជាដើម, ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបទៅតាមន័យដែលបានពោលមកហើយ នោះឯង ។*

**តត្ថ កាយសង្ខារវសេន អាគតោ, ឥធ ចិត្តសង្ខារវសេនាតិ អយមេវ វិសេសោ ។**

*មានសេចក្តីផ្សេងគ្នានៅត្រង់នេះប៉ុណ្ណោះ គឺនៅក្នុងចតុក្កៈទី ១ នោះ មានមកហើយ ដោយអំណាចនៃកាយសង្ខារ, នៅក្នុងចតុក្កៈទី ២ នេះ មានមកហើយ ដោយអំណាចនៃចិត្តសង្ខារ ដូច្នេះ ។*

**ឯវំ ចិត្តសង្ខារស្ស បស្សម្ភនំ អតិទេសេន ទស្សេត្វា យទញ្ញំ ឥមស្មឹ ចតុក្កេ វត្តព្វំ, តំ ទស្សេតុំ "អបិចា"តិអាទិ វុត្តំ ។**

*លោកអាចារ្យ កាលសម្តែងដោយការចង្អុលបង្ហាញដល់ការធ្វើចិត្តសង្ខារឱ្យ រលត់បាត់ យ៉ាងនេះហើយ ក៏មានសេចក្តីប្រាថ្នាសម្តែងនូវពាក្យដែលគួរពោលនៅក្នុងចតុក្កៈនេះទៀត ទើបពោលថា "**មួយទៀត**" ដូច្នេះជាដើម ។*

**តត្ថ "បីតិបទេ"តិ "បីតិបដិសំវេទី"តិអាទិនា ទេសិតកោដ្ឋាសេ ។**

*ក្នុងពាក្យទាំងនោះ ពាក្យថា "**ក្នុងបទថាបីតិ**" គឺក្នុងចំណែករបស់ពាក្យពោលដែលសម្តែងទុកដោយពាក្យថា "បីតិប្បដិសំវេទី" ជាដើម ។*

**"បីតិសីសេន វេទនា វុត្តា"តិ បីតិអបទេសេន តំសម្បយុត្តា វេទនា វុត្តា, ន បីតីតិ អធិប្បាយោ ។ តត្ថ ការណំ ហេដ្ឋា វុត្តមេវ ។**

*ពាក្យថា "**ព្រះអង្គត្រាស់សម្តែងសំដៅដល់វេទនា ដោយ បីតិជាសំខាន់**" គឺព្រះអង្គត្រាស់សម្តែងសំដៅដល់វេទនា ដែលសម្បយុត្តជាមួយបីតិនោះ ដោយការអាងដល់បីតិ, អធិប្បាយថា មិនបានត្រាស់សម្តែងដល់តួបីតិទេ ។ ហេតុដែលត្រាស់សម្តែងដល់វេទនាហើយមិនបានត្រាស់សម្តែងដល់បីតិនោះ ខ្ញុំម្ចាស់បាន*

*ពោលមកហើយក្នុងន័យនៅខាងដើម ។*

**"ទ្វីសុ ចិត្តសង្ខារបទេសូ"**តិ "ចិត្តសង្ខារបដិសំវេទី បស្សម្ភយំ ចិត្តសង្ខារ"ន្តិ ចិត្តសង្ខារបដិសំយុត្តេសុ ទ្វីសុ បទេសុ។

*ពាក្យថា **"ក្នុងបទថា ចិត្តសង្ខារទាំង ២ បទ"** បានដល់ ក្នុង ២ បទ ដែលជាប់ជាមួយចិត្តសង្ខារ គឺបទថា* "ចិត្តសង្ខារបដិសំវេទី បស្សម្ភយំ ចិត្តសង្ខារ" ។

"វិញ្ញាណបច្ចយា នាមរូប"ន្តិ[៦៩] វចនតោ ចិត្តេន បដិពទ្ធាតិ **ចិត្តបដិពទ្ធា**។

*ឈ្មោះថា **"ជាប់ជាមួយចិត្ត"** ព្រោះអត្ថថា ជាប់ជាមួយចិត្ត តាមព្រះពុទ្ធដីកាសម្ដែងថា "ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាម និងរូប" ។*

តតោ ឯវ កាមំ ចិត្តេន សង្ខរីយន្តីតិ **ចិត្តសង្ខារា**, សញ្ញាវេទនាទយោ, ឥធ បន ឧបលក្ខណមត្តំ សញ្ញា វេទនាវ អធិប្បេតាតិ អាហ **"សញ្ញាសម្បយុត្តា វេទនា"**តិ ។

*ព្រោះហេតុនុ៎ះឯងធម៌ទាំងឡាយមានសញ្ញា និងវេទនាជាដើម **ឈ្មោះថាចិត្តសង្ខារ** ព្រោះអត្ថថា ដែលចិត្តតាក់តែងដោយពិត, តែថា ក្នុងទីនេះ មកកំណត់ (ថាជាចិត្តសង្ខារដូចម្ដេច ?) ទើបលោកប្រាថ្នាយកសញ្ញា និងវេទនាតែប៉ុណ្ណោះ ព្រោះហេតុនោះ ទើបពោលថា **"ត្រាស់សំដៅដល់វេទនា ដែលសម្បយុត្តជាមួយសញ្ញា"** ដូច្នេះ ។*

---

៦៩ (មហាវ. ១; ម. និ. ៣.១២៦; ឧទា. ១) ។

# ចិត្តានុបស្សនា ចតុក្កៈទី ៣[៦៦]

## (វិសុទ្ធិមគ្គ)

[២៣៤] តតិយចតុក្កេបិ ចតុន្នំ ឈានានំ វសេន **ចិត្តប្បដិសំវេទិតា វេទិតព្វា។**

*សូម្បីនៅក្នុងចតុក្កៈទី ៣ បណ្ឌិតគប្បីជ្រាបនូវសេចក្តី* ***ចិត្តប្បដិសំវេទី*** *ប្រែថា* ***ជាអ្នកធ្វើចិត្តឱ្យដឹងច្បាស់*** *ដោយអំណាចនៃឈាន ទី ៤ ។*

**"អភិប្បមោទយំ ចិត្ត"ន្តិ** ចិត្តំ មោទេន្តោ បមោទេន្តោ ហាសេន្តោ បហាសេន្តោ អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតិ។

*សេចក្តីថា "អភិប្បមោទយំ ចិត្តំ" ជាដើម មានន័យថា រមែងសិក្សាថា "អាត្មាអញនឹងធ្វើចិត្តឱ្យរីករាយ គឺឱ្យបាមោជ្ជៈ ឱ្យសប្បាយចិត្ត ឱ្យត្រេកអរចិត្ត ក្នុងខណៈដកដង្ហើមចូល ដកដង្ហើមចេញ ។*

តត្ថ ទ្វីហាការេហិ អភិប្បមោទោ ហោតិ សមាធិវសេន ច វិបស្សនាវសេន ច។

*ក្នុងសេចក្តីនេះ ការធ្វើឱ្យសប្បាយចិត្ត រមែងមាន ដោយអាការៈ ២ យ៉ាង គឺដោយអំណាចនៃសមាធិ និងវិបស្សនា ។*

កថំ **សមាធិវសេន**? សប្បីតិកេ ទ្វេ ឈានេ សមាបជ្ជតិ។

*តើដោយអំណាចនៃសមាធិ ដូចម្តេច? ឆ្លើយថាព្រះយោគាវចរភិក្ខុ រមែងចូលឈានទី ២ ដែលមានបីតិ ។*

សោ សមាបត្តិក្ខណេ សម្បយុត្តបីតិយា ចិត្តំ អាមោទេតិ បមោទេតិ។

*ក្នុងខណៈដែលចូលឈានព្រះយោគាវចរភិក្ខុនោះឈ្មោះថា រមែងធ្វើចិត្ត*

---

៦៦ ចិត្តានុបស្សនាចតុក្កៈទី៣នេះ មានទាំងសមថៈកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន

*ឱ្យរីករាយ ឱ្យបាមោជ្ជៈ ដោយបីតិដែលសម្បយុត្ត (ជាមួយចិត្តនោះ) ។*

**កថំ វិបស្សនាវសេន?** សប្បីតិកេ ទ្វេ ឈានេ សមាបជ្ជិត្វា វុដ្ឋាយ ឈានសម្បយុត្តបីតឹ ខយតោ វយតោ សម្មសតិ។

***តើដោយអំណាចនៃវិបស្សនា ដូចម្ដេច ?*** *ឆ្លើយថាព្រះយោគាវចរភិក្ខុរមែងចូលឈានទី ២ ដែលមានបីតិ បានចាកចេញហើយ ក៏ពិចារណានូវបីតិដែលសម្បយុត្តជាមួយឈាន ដោយសភាវៈអស់ទៅ សូន្យទៅ ។*

**ឯវំ វិបស្សនាក្ខណេ ឈានសម្បយុត្តំ បីតឹ អារម្មណំ កត្វា ចិត្តំ អាមោទេតិ បមោទេតិ។**

*យោគីភិក្ខុ កាលធ្វើបីតិដែលសម្បយុត្តជាមួយឈាន ឱ្យមកជាអារម្មណ៍ ក្នុងខណៈនៃវិបស្សនាយ៉ាងនេះ ទើបឈ្មោះថា ធ្វើចិត្តឱ្យសប្បាយរីករាយ ឱ្យបាមោជ្ជៈ ។*

**ឯវំ បដិបន្នោ "អភិប្បមោទយំ ចិត្តំ អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតី"តិ វុច្ចតិ ។**

*ព្រះយោគីភិក្ខុបដិបត្តិបានយ៉ាងនេះ ពោលបានថា "ឈ្មោះថា រមែងសិក្សាថា អាត្មាអញធ្វើចិត្តឱ្យរីករាយ ខណៈដកដង្ហើមចូល ដកដង្ហើមចេញ" ដូច្នេះ ។*

**"សមាទហំ ចិត្ត"ន្តិ បឋមជ្ឈានាទិវសេន អារម្មណេ ចិត្តំ សមំ អាទហន្តោ សមំ ឋបេន្តោ ។**

*ក្នុងសេចក្ដីថា "**សមាទហំ ចិត្តំ** ប្រែថា **ធ្វើចិត្តឱ្យតាំងមាំ**" ដាដើម សេចក្ដីថា ធ្វើចិត្តឱ្យតាំងមាំ គឺការរក្សាឱ្យស្មើៗនៅក្នុងអារម្មណ៍ ដោយអំណាចនៃបឋមជ្ឈាន ជាដើម ។*

តានិ វា បន ឈានានិ សមាបជ្ជិត្វា វុដ្ឋាយ ឈានសម្បយុត្តំ ចិត្តំ

ខយតោ វយតោ សម្បស្សតោ វិបស្សនាក្ខណេ លក្ខណបដិវេធេន ឧប្បជ្ជតិ ខណិកាចិត្តេកគ្គតា ។

*ឬថា កាលព្រះយោគាវចរភិក្ខុចូលឈានទាំងនោះ រួចបានចាកចេញហើយ ក៏ពិចារណានូវចិត្ត ដែលសម្បយុត្តជាមួយឈាន ដោយសភាវៈអស់ទៅ សូន្យទៅ* **ខណិកាចិត្តេកគ្គតា** *រមែងកើតឡើង ដោយការចាក់ធ្លុះនូវលក្ខណៈក្នុងខណៈនៃវិបស្សនា ។*

ឯវំ ឧប្បន្នាយ ខណិកាចិត្តេកគ្គតាយ វសេនបិ អារម្មណេ ចិត្តំ សមំ អាធហន្តោ សមំ ឋបេន្តោ "សមាទហំ ចិត្តំ អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតី"តិ វុច្ចតិ ។

*កាលធ្វើចិត្តឱ្យតាំងមាំដោយស្មើៗ គឺកាលតម្កល់ទុក ស្មើៗនៅក្នុងអារម្មណ៍ សូម្បីដោយអំណាចនៃខណិកចិត្តេកគ្គតា ដែលកើតឡើងយ៉ាងនេះ ក៏ពោលបានថា "ឈ្មោះថា រមែងសិក្សាថា អាត្មាអញនឹងធ្វើចិត្តឱ្យតាំងមាំ ខណៈដកដង្ហើមចូល ដកដង្ហើមចេញ" ដូច្នេះ ។*

**"វិមោចយំ ចិត្ត"ន្តិ** បឋមជ្ឈានេន នីវរណេហិ ចិត្តំ មោចេន្តោ វិមោចេន្តោ, ទុតិយេន វិតក្កវិចារេហិ, តតិយេន បីតិយា, ចតុត្ថេន សុខទុក្ខេហិ ចិត្តំ មោចេន្តោ វិមោចេន្តោ ។

*ក្នុងសេចក្តីថា "***វិមោចយំ ចិត្តំ** *ប្រែថា អាត្មាអញនឹងធ្វើចិត្តឱ្យរួចផុតចាកពីនីវរណធម៌" ជាដើម សេចក្តីថា ព្រះយោគាវចរដកចិត្ត គឺធ្វើឱ្យរួចផុតពីនីវរណធម៌ទាំងឡាយ ដោយបឋមជ្ឈាន, ដកចិត្ត គឺធ្វើឱ្យរួចផុតពីវិតក្កៈ និងវិចារៈ ដោយ ទុតិយជ្ឈាន, រួចផុតពីបីតិ ដោយតតិយជ្ឈាន, រួចផុតពីសុខ និងទុក្ខ ដោយចតុត្ថជ្ឈាន ។*

តានិ វា បន ឈានានិ សមាបជ្ជិត្វា វុដ្ឋាយ ឈានសម្បយុត្តំ ចិត្តំ ខយតោ វយតោ សម្មសតិ។

*ឬថា ព្រះយោគាវចរភិក្ខុ ចូលឈានទាំងនោះ រួចហើយចាកចេញក៏ពិចារណាចិត្តដែលសម្បយុត្តជាមួយឈាន ដោយសភាវៈអស់ទៅ សូន្យទៅ ។*

**សោ វិបស្សនាក្ខណេ អនិច្ចានុបស្សនាយ និច្ចសញ្ញាតោ ចិត្តំ មោចេន្តោ, ទុក្ខានុបស្សនាយ សុខសញ្ញាតោ, អនត្តានុបស្សនាយ អត្តសញ្ញាតោ, និព្វិទានុបស្សនាយ នន្ទិតោ, វិរាគានុបស្សនាយ រាគតោ, និរោធានុបស្សនាយ សមុទយតោ, បដិនិស្សគ្គានុបស្សនាយ អាទានតោ ចិត្តំ មោចេន្តោ អស្សសតិ ចេវ បស្សសតិ ច ។**

*ក្នុងខណៈនៃវិបស្សនា ព្រះយោគាវចរភិក្ខុអង្គនោះបិត្តរួចផុត គឺធ្វើឱ្យរួចផុតពី* **និច្ចសញ្ញា** *ដោយ* **អនិច្ចានុបស្សនា**, *បិត្តរួចផុត គឺធ្វើឱ្យរួចផុតពី* **សុខសញ្ញា** *ដោយ* **ទុក្ខានុបស្សនា**, *ចេញពី* **អត្តសញ្ញា** *ដោយ* **អនត្តានុបស្សនា**, *ចេញពី* **នន្ទិ** *(សេចក្តីត្រេកអរ) ដោយ* **និព្វិទានុបស្សនា**, *ចេញពី* **រាគ** *ដោយ* **វិរាគានុបស្សនា**, *ចេញពី* **សមុទយ** *ដោយ* **និរោធានុបស្សនា**, *ចេញពី* **អាទាន** *ដោយ* **បដិនិស្សគ្គានុបស្សនា** *ខណៈដកដង្ហើមចូល និង ខណៈដកដង្ហើមចេញ ។*

**តេន វុច្ចតិ "វិមោចយំ ចិត្តំ អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតី"តិ ។**

*ព្រោះហេតុនោះ ទើបពោលបានថា "ឈ្មោះថា រមែងសិក្សាថា អាត្មាអញនឹងធ្វើចិត្តឱ្យរួចផុតអំពីនីវរណធម៌ ដកដង្ហើមចូល និងដកដង្ហើមចេញ" ដូច្នេះ ។*

**ឯវំ ចិត្តានុបស្សនាវសេន ឥទំ ចតុក្កំ ភាសិតន្តិ វេទិតព្វំ ។**

*គប្បីជ្រាបថា ក្នុងចតុក្កៈនេះ ទ្រង់ភាសិតទុក* **ដោយអំណាចជាចិត្តានុបស្សនា** *តាមប្រការដែលពោលមកហើយនេះ ។*

## ចិត្តានុបស្សនា ចតុក្កៈទី ៣

### (មហាដីកាវិសុទ្ធិមគ្គ)

[២៣៤] "ចិត្តប្បដិសំវេទី"តិ ឯត្ថ ទ្វីហាការេហិ ចិត្តបដិសំវេទិតា ហោតិ អារម្មណតោ, អសម្មោហតោ ច ។

*ក្នុងបទថា* **ចិត្តប្បដិសំវេទី** *នេះ មានសេចក្ដីថា ជាអ្នកធ្វើចិត្តឱ្យដឹងច្បាស់ រមែងមាន ដោយអាការៈ ២ យ៉ាង គឺដោយអារម្មណ៍ និងដោយអសម្មោហ ។*

កថំ អារម្មណតោ? ចត្តារិ ឈានានិ សមាបជ្ជតិ, តស្ស សមាបត្តិក្ខណេ ឈានបដិលាភេនាតិអាទិនា វុត្តនយានុសារេន សព្វំ សុវិញ្ញេយ្យន្តិ អាហ "**ចតុន្នំ ឈានានំ វសេន ចិត្តបដិសំវេទិតា វេទិតព្វា**"តិ។

*ដោយអារម្មណ៍ តើដូចម្ដេច? ពាក្យឆ្លើយទាំងអស់ បណ្ឌិតគប្បីជ្រាបបាន ដោយងាយតាមទំនងនៃន័យដែលបានពោលមកហើយ ដោយពាក្យថា ព្រះយោគាវចរ រមែងចូលឈានទី ៤, ក្នុងខណៈដែលព្រះយោគាវចរនោះចូលឈាន ចិត្ត ដែលព្រះយោគាវចរនោះដឹងច្បាស់ដោយអារម្មណ៍ ដោយការបានមកនូវឈាន ដូច្នេះជាដើម ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា* ***"បណ្ឌិតគប្បីជ្រាបនូវចិត្តប្បដិសំវេទី ដោយអំណាចនៃឈានទី ៤"*** *ដូច្នេះ ។*

**"ចិត្តំ មោទេន្តោ"**តិ ឈានសម្បយុត្តំ ចិត្តំ សម្បយុត្តាយ បីតិយា មោទយមានោ, តំ វា បីតឹ អារម្មណំ កត្វា បវត្តំ វិបស្សនាចិត្តំ តាយ ឯវ អារម្មណភូតាយ បីតិយា មោទយមានោ។

*ពាក្យថា* ***"ធ្វើចិត្តឱ្យសប្បាយរីករាយ"*** *គឺធ្វើចិត្តដែលសម្បយុត្តជាមួយឈានឱ្យសប្បាយរីករាយ ដោយបីតិដែលប្រកបរួមគ្នា, ឬធ្វើវិបស្សនាចិត្តឱ្យប្រព្រឹត្តទៅ ធ្វើបីតិនោះឱ្យមកជាអារម្មណ៍ ឱ្យសប្បាយរីករាយ ដោយបីតិដែល*

*ជាអារម្មណ៍នោះ ទុំះឯង ។*

"**បមោទេន្តោ**"តិអាទីនិ បទានិ តស្សេវ វេវចនានិ បីតិបរិយាយ-ការតោ ។

*បទថា "**បមោទេន្តោ** ប្រែថា **ឱ្យបាមោជ្ជៈ** ជាដើម ក៏ជាពាក្យវេវចនៈរបស់ពាក្យថា* មោទេន្តោ *ប្រែថា ឱ្យសប្បាយរីករាយ នោះ ទុំះឯង ព្រោះជាពាក្យអធិប្បាយបីតិ ។*

"**សម្បយុត្តាយ បីតិយា ចិត្តំ អាមោទេតី**"តិ ឈានចិត្តសម្ប-យុត្តាយ បីតិសម្ពោជ្ឈង្គភូតាយ ឱឧត្យលក្ខណាយ ឈានបីតិយា តមេវ ឈានចិត្តំ សហជាតាធិបច្ចយវសេនចេវ ឈានបច្ចយវសេន ច បរិព្រូហេន្តោ ហដ្ឋបហដ្ឋាការំ ចាបេន្តោ អាមោទេតិ បមោទេតិ ច ។

*ពាក្យថា "**ឈ្មោះថា រមែងធ្វើចិត្តឱ្យសប្បាយរីករាយផង បីតិដែលសម្បយុត្ត**" សេចក្ដីថា កាលបង្កើនឡើង គឺកាលធ្វើឈានចិត្តនោះ ទុំះឯង ឱ្យដល់អាការៈសប្បាយរីករាយ ដោយបីតិក្នុងឈាន ដែលសម្បយុត្តជាមួយឈានចិត្ត ដែលបីតិសម្ពោជ្ឈង្គ ដែលមានសភាវៈត្រេកអរជាលក្ខណៈ ដោយអំណាចនៃបច្ច័យមានសហជាតបច្ច័យជាដើម និងដោយអំណាចនៃឈានបច្ច័យ ពោលបានថា ឈ្មោះថា ធ្វើឱ្យសប្បាយរីករាយ និងធ្វើឱ្យបាមោជ្ជៈ ។*

"**អារម្មណំ កត្វា**"តិ ឧឡារំ ឈានសម្បយុត្តំ បីតឹ អារម្មណំ កត្វា បវត្តមានំ វិបស្សនាចិត្តំ តាយ ឯវ អារម្មណភូតាយ បីតិយា យោគាវចរោ ហដ្ឋបហដ្ឋាការំ ចាបេន្តោ "អាមោទេតិ បមោទេតី"តិ វុច្ចតិ។

*បទថា "**អារម្មណំ កត្វា**" សេចក្ដីថា ព្រះយោគាវចរ កាលធ្វើវិបស្សនាចិត្ត ដែលប្រព្រឹត្តិទៅ ធ្វើបីតិដែលសម្បយុត្តជាមួយឈាន ដែលឧឡារ (ដ៏ប្រសើរ) ឱ្យមកជាអារម្មណ៍ ឱ្យដល់នូវអាការៈសប្បាយរីករាយត្រេកអរ ដោយ*

*បីតិដែលជាអារម្មណ៍នោះ នុ៎ះឯង ពោលបានថា "ឈ្មោះថា ធ្វើចិត្តឱ្យរីករាយ ឱ្យបាមោជ្ជៈ" ។*

"**សមំ ឋបេន្តោ**"តិ យថា ឡីសកម្បិ លីនបក្ខំ, ឧទ្ធច្ចបក្ខញ្ច អនុបគម្មអនោនតំ អនុន្នតំ យថា ឥន្ទ្រិយានំ សមត្តបដិបត្តិយា អវិសមំ, សមាធិស្ស វា ឧក្កំសតមនេន អានេញ្ជប្បត្តិយា សម្មទេវ ឋិតំ ហោតិ, ឯវំ អប្បនាវសេន ឋបេន្តោ ។

*ពាក្យថា "**តម្កល់ទុកស្មើៗ**" គឺការតម្កល់ទុកដោយអំណាចនៃអប្បនា តាមប្រការដែលចិត្តមិនធ្លាក់ចុះឡើងៗ ព្រោះមិនចូលដល់ធម៌ដែលជាផ្នែកនៃការរាថយ និងធម៌ដែលជាផ្នែកនៃការរាយមាយ សូម្បីត្រឹមតែបន្តិចបន្តួច តាមប្រការដែលចិត្តមិនបានប្រាសចាក ភាពស្ងប់ ព្រោះតែឥន្ទ្រីយ៍ទាំងឡាយបានដំណើរការទៅដោយសភាពស្មើៗគ្នា, ឬតាមប្រការដែលចិត្តបានតម្កល់ដោយល្អ ព្រោះតែសភាពមិនញាប់ញ័រ ព្រោះហេតុតែសមាធិបានទៅដល់សភាពថ្នាក់ខ្ពស់នុ៎ះឯង។*

"**លក្ខណបដិវេធោ**"តិ អនិច្ចាទិកស្ស លក្ខណស្ស បដិ បដិ វិជ្ឈនេន ខណោ ខណោ អវពោធេន ។

*ពាក្យថា "**តាមការចាក់ធ្លុះនូវលក្ខណៈ**" គឺតាមការចាក់ធ្លុះ បានដល់ តាមការដឹងក្នុងខណៈៗ នូវលក្ខណៈ មានអនិច្ចលក្ខណៈ ជាដើម ។*

"**ខណិកចិត្តេកគ្គតា**"តិ ខណមត្តដ្ឋិតិកោ សមាធិ។

*ពាក្យថា "**ខណិកចិត្តេកគ្គតា**" បានដល់ សមាធិដែលមានការតាំងនៅបានជាជួរ ខណៈៗ ។*

សោបិ ហិ អារម្មណេ និរន្តរំ ឯកាកាវេន បវត្តមានោ បដិបក្ខេន អនភិភូតោ អប្បិតោ វិយ ចិត្តំ និច្ចលំ ឋបេតិ។

*មែនពិត សូម្បីសមាធិនោះ កាលប្រព្រឹត្តទៅមិនដាច់ចន្លោះក្នុងអារម្មណ៍*

*ដោយអាការៈតែមួយ ហើយមិនត្រូវបានធម៌ ដែលជាបដិបក្ខគ្របសង្កត់ ក៏ដូចជាដល់អប្បនា រមែងតាំងចិត្តទុកឱ្យរួចផុតអំពីភាពញាប់ញ័រ ។*

តេន វុត្តំ "**ឯវំ ឧប្បជ្ជាយា**"តិអាទិ។

*ព្រោះហេតុនោះ លោកទើបពោលថា "**កាលធ្វើចិត្តឱ្យតាំងមាំស្មើៗ ដែលកើតឡើងយ៉ាងនេះ**" ដូច្នេះជាដើម ។*

"**មោចេន្តោ**"តិ វិក្ខម្ភនវិមុត្តិវសេន វិវេចេន្តោ វិសុំ ករោន្តោ, នីវរណានិ បជហន្តោតិ អត្ថោ ។

*ពាក្យថា "**ចិត្តរួចផុត**" គឺធ្វើឱ្យស្ងាត់ទៅ ដោយអំណាចនៃ **វិក្ខម្ភនវិមុត្តិ**, បានសេចក្ដីថា ការលះនូវនីវរណធម៌ទាំងឡាយតែម្យ៉ាង ។*

"**វិបស្សនាក្ខណេ**"តិ ភង្គានុបស្សនាក្ខណេ។

*ពាក្យថា "**ក្នុងខណៈនៃវិបស្សនា**" គឺក្នុងខណៈនៃភង្គានុបស្សនាញាណ ។*

ភង្គោ ហិ នាម អនិច្ចតាយ បរមា កោដិ, តស្មា តាយ ភង្គានុបស្សកោ យោគាវចរោ ចិត្តមុខេន សព្វសង្ខារគតំ អនិច្ចតោ បស្សតិ, នោ និច្ចតោ ។

*មែនពិត ខាងចុងបំផុត ដោយសភាវៈជារបស់មិនទៀង ឈ្មោះថា ភង្គ ប្រែថា សភាវៈបែកធ្លាយ, ព្រោះហេតុនោះ ព្រះយោគាវចរអ្នកតាមពិចារណាឃើញភង្គៈ ដោយភង្គានុបស្សនាញាណនោះ រមែងឃើញសង្ខារទាំងពួងថាមិនទៀង ដោយមានចិត្តជាប្រធាន, មិនមែនឃើញថាទៀងទេ ។*

អនិច្ចស្ស ទុក្ខត្តា, ទុក្ខស្ស ច អនត្តកត្តា តទេវ ទុក្ខតោ អនុបស្សតិ, នោ សុខតោ ។

*ព្រោះសភាវៈដែលមិនទៀងជាទុក្ខ, និងព្រោះសភាវៈដែលជាទុក្ខ ជាអនត្តា ទើបតាមឃើញសង្ខារនោះ នុ៎ះឯងថា ជាទុក្ខ, មិនមែនតាមឃើញថាជា*

*សុខទេ ។*

អនត្តតោ អនុបស្សតិ, នោ អត្តតោ។

*រមែងតាមឃើញថា ជាអនត្តា, មិនមែនតាមឃើញថា ជាអត្តាទេ ។*

យស្មា បន យំ អនិច្ចំ ទុក្ខំ អនត្តា, ន តំ អភិនន្ទិតព្វំ។

*ព្រោះតែ សភាវៈណាមិនទៀង ជាទុក្ខ ជាអនត្តា, សភាវៈនោះ មិនមែនសភាវៈដែលគួរឱ្យត្រេកត្រអាលឡើយ ។*

យញ្ច ន អភិនន្ទិតព្វំ, ន តំ រញ្ជិតព្វំ។

*និងសភាវៈណាមិនមែនជាសភាវៈដែលគួរត្រេកត្រអាល, សភាវៈនោះក៏មិនមែនជាសភាវៈដែលគួរត្រេកអរឡើយ ។*

តស្មា ភង្គានុបស្សនានុសារេន "អនិច្ចំ ទុក្ខំ អនត្តា"តិ សង្ខារគតេ ទិដ្ឋេ តស្មឹ និព្វិន្ទតិ, នោ នន្ទតិ។ វិរជ្ជតិ, នោ រជ្ជតិ។

*ព្រោះហេតុនោះ កាលព្រះយោគាវចរបានឃើញនូវសង្ខារថា "មិនទៀង ជាទុក្ខ ជាអនត្តា" ហើយ តាមន័យនៃការឃើញភង្គៈ ព្រះយោគាវចរ ក៏រមែងនឿយណាយនៅក្នុងសង្ខារនោះ, មិនមែនជាការត្រេកត្រអាលទេ ។ រមែងមិនកំណាត់ត្រេកអរ, មិនមែនការកំណាត់សប្បាយរីករាយឡើយ ។*

សោ ឯវំ និព្វិន្ទន្តោ វិរជ្ជន្តោ លោកិយេនេវ តាវ ញាណេន រាគំ និរោធេតិ, នោ សមុទេតិ, នាស្ស សមុទយំ ករោតីតិ អត្ថោ។

*ព្រះយោគាវចរនោះ កាលនឿយណាយ បន្ធូរបន្ថយនូវការត្រេកអរយ៉ាងនេះហើយ ក៏រមែងធ្វើរាគៈឱ្យរលត់បាត់ទៅ មិនមែនធ្វើឱ្យកើតឡើងទេ ដោយលោកិយញាណនោះនុ៎ះឯង, សេចក្តីថា មិនសាងហេតុដែលឱ្យកើតឡើងនៃសង្ខារនេះ ។*

អថ វា សោ ឯវំ វិរត្តោ យថា ទិដ្ឋំ សង្ខារគតំ, តថា អទិដ្ឋំ អត្តនោ

ញាណេន និរោធេតិ, នោ សមុទេតិ។

*ន័យម្យ៉ាងទៀត មានសេចក្ដីថា ព្រះយោគាវចរ អ្នកនឿយណាយក្នុងការត្រេកអរយ៉ាងនេះហើយនោះ រមែងធ្វើសង្ខារ ដែលមិនទាន់ឃើញឱ្យរលត់បាត់ទៅដោយញាណរបស់ខ្លួន ដូចជាសង្ខារដែលបានឃើញហើយនោះ, មិនមែនធ្វើឱ្យកើតឡើងនោះទេ ។*

និរោធមេវស្ស មនសិករោតិ, នោ សមុទយន្តិ អត្ថោ។

*គឺរមែងធ្វើទុកក្នុងចិត្ត ចំពោះសភាវៈរលត់បាត់ របស់សង្ខារនេះប៉ុណ្ណោះ, មិនមែនធ្វើទុកក្នុងចិត្តនូវសភាវៈកើតឡើងនោះទេ ។*

សោ ឯវំ បដិបន្នោ បដិនិស្សជ្ជតិ, នោ អាទិយតិ។

*ព្រះយោគាវចរ អ្នកបដិបត្តិបានយ៉ាងនេះនោះ ឈ្មោះថា រមែងលះចេញមិនមែនប្រកាន់ទុកទេ ។*

កឹ វុត្តំ ហោតិ? អយញ្ហិ អនិច្ចាទិអនុបស្សនា សទ្ធឹ ខន្ធាភិសង្ខារេហិ កិលេសានំ បរិច្ចជនតោ, សង្ខតទោសទស្សនេន តព្វិបរីតេ និព្វានេ តន្និន្នតាយ បក្ខន្ទនតោ បរិច្ចាគបដិនិស្សគ្គោ បក្ខន្ទនបដិនិស្សគ្គោ ចាតិ វុច្ចតិ ។

*តើមានការអធិប្បាយយ៉ាងដូចម្ដេច ? អធិប្បាយថា បញ្ញាដែលតាមពិចារណាឃើញថា មិនទៀងជាដើមនេះ លោកហៅថា* បរិច្ចាគបដិនិស្សគ្គ *និង* បក្ខន្ទនបដិនិស្សគ្គ *ព្រោះលះកិលេសទាំងឡាយព្រមទាំងខន្ធ និងអភិសង្ខារទាំងឡាយ ព្រោះដោយការឃើញទោសរបស់សង្ខតធម៌ ក៏ស្ទុះទៅដោយសភាវៈដែលបង្អោនចិត្តទៅក្នុងព្រះនិព្វាន ដែលផ្ទុយគ្នាជាមួយសង្ខតធម៌នោះ ។*

តស្មា តាយ សមន្នាគតោ យោគាវចរោ វុត្តនយេន កិលេសេ ច បរិច្ចជតិ, និព្វានេ ច បក្ខន្ទតិ ។

*ព្រោះហេតុនោះ ព្រះយោគាវចរអ្នកប្រកបព្រមដោយបញ្ញា (ដែលតាមពិចារណាឃើញថា មិនទៀងជាដើម)នោះ ទើបឈ្មោះថា រមែងលះបង់នូវកិលេសទាំងឡាយ និងស្ទុះទៅកាន់ព្រះនិព្វាន តាមន័យដែលបានពោលមកហើយ ។*

**តេន វុត្តំ "សោ វិបស្សនាក្ខណេ អនិច្ចានុបស្សនាយ និច្ចសញ្ញាតោ ចិត្តំ មោចេន្តោ វិមោចេន្តោ ។...បេ...។ បដិនិស្សគ្គានុបស្សនាយ អាទានតោ ចិត្តំ មោចេន្តោ វិមោចេន្តោ អស្សសតិ ចេវ បស្សសតិ ចា"តិ ។**

*ព្រោះហេតុនោះ លោកអាចារ្យទើបពោលបានថា "ក្នុងខណៈនៃវិបស្សនា ព្រះយោគាវចរនោះដកចិត្ត គឺធ្វើឱ្យរួចផុតពីនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា ។...ល...។ ដកចិត្ត គឺធ្វើឱ្យរួចផុតពីអាទាន ដោយបដិនិស្សគ្គានុបស្សនា ខណៈដកដង្ហើមចូល និងខណៈដកដង្ហើមចេញ" ដូច្នេះ ។*

តត្ថ អនិច្ចស្ស, អនិច្ចន្តិ វា អនុបស្សនា **អនិច្ចានុបស្សនា**។

*ក្នុងពាក្យទាំងនោះ បញ្ញាដែលតាមពិចារណាឃើញនូវសភាវៈដែលមិនទៀង ឬតាមពិចារណាឃើញថា មិនទៀង ឈ្មោះថា* **អនិច្ចានុបស្សនា** *។*

**តេភូមិកានំ ធម្មានំ អនិច្ចតំ គហេត្វា បវត្តាយ វិបស្សនាយ ឯតំ នាមំ។**

*ពាក្យថា អនិច្ចានុបស្សនានេះ ជាឈ្មោះរបស់វិបស្សនាបញ្ញា ដែលប្រព្រឹត្តទៅ កាន់យកសភាវៈដែលធម៌ទាំងឡាយប្រព្រឹត្តទៅក្នុងភូមិ ៣ ជារបស់មិនទៀង ។*

**"និច្ចសញ្ញាតោ"**តិ សង្ខតធម្មេ "និច្ចា សស្សតា"តិ បវត្តាយ មិច្ឆាសញ្ញាយ។

*ពាក្យថា "**ចេញពីនិច្ចសញ្ញា**" គឺចេញពីមិច្ឆាសញ្ញាដែលប្រព្រឹត្តទៅក្នុងសង្ខតធម៌ថា "ទៀង គឺទៀងទាត់" ។*

សញ្ញាសីសេន ចិត្តទិដ្ឋីនម្បិ គហណំ ទដ្ឋព្វំ។ ឯស នយោ សុខសញ្ញាទីសុបិ ។

*គប្បីឃើញថា លោកកាន់យកទាំងចិត្ត និងទិដ្ឋិ ដោយសញ្ញាដែលជាប្រធាន ។ សូម្បីក្នុងសុខសញ្ញាជាដើម ក៏មានន័យយ៉ាងនេះឯង ។*

"**និព្វិទានុបស្សនាយា**"តិ សង្ខារេសុ និព្វិន្ទនាការេន បវត្តាយ អនុបស្សនាយ ។

*ពាក្យថា "ដោយ* **និព្វិទានុបស្សនា**" *គឺដោយអនុបស្សនា ដែលប្រព្រឹត្តទៅដោយអាការៈនឿយណាយនៅក្នុងសង្ខារទាំងឡាយ ។*

"**នន្ទិតោ**"តិ សប្បីតិកតណ្ហាតោ។ "**វិរាគានុបស្សនាយា**"តិ តថា វិរជ្ជនាការេន បវត្តាយ អនុបស្សនាយ ។

*ពាក្យថា "ចេញពី* **នន្ទិ**" *ប្រែថា សេចក្ដីត្រេកត្រអាល គឺចាកពីតណ្ហាដែលមានបីតិ ។ ពាក្យថា "ដោយ* **វិរាគានុបស្សនា**" *គឺដោយ អនុបស្សនា ដែលប្រព្រឹត្តទៅយ៉ាងនោះ គឺដោយអាការៈនឿយណាយ ។*

តេន វុត្តំ "**រាគតោ មោចេន្តោ**"តិ។

*ព្រោះហេតុនោះ លោកទើបពោលថា "**ដកចិត្តពីរាគៈ**" ដូច្នេះ ។*

"**និរោធានុបស្សនាយា**"តិ សង្ខារានំ និរោធស្ស អនុបស្សនាយ។

*ពាក្យថា "**ដោយនិរោធានុបស្សនា**" គឺដោយបញ្ញាដែលតាមពិចារណាឃើញសភាវៈរលត់បាត់ទៅនៃសង្ខារទាំងឡាយ ។*

យថា សង្ខារា និរុជ្ឈន្តិយេវ, អាយតឹ បុនព្ភវវសេន ន ឧប្បជ្ជន្តិ, ឯវំ វា អនុបស្សនា និរោធានុបស្សនា។

*ន័យម្យ៉ាងទៀត បញ្ញាដែលតាមពិចារណាឃើញតាមប្រការដែលសង្ខារទាំងឡាយ នឹងរលត់បាត់ទៅ មិនកើតឡើងមកវិញ ដោយអំណាចនៃភពថ្មី*

*តទៅទៀត ឈ្មោះថា និព្វេទានុបស្សនា ។*

**មុញ្ចិតុកម្យតា ហិ អយំ ពលប្បត្តា។**

**និព្វេទានុបស្សនា***នេះ បានដល់* **មុញ្ចិតុកម្យតាញាណ***ដែលមានកម្លាំង (ជាញាណទី ៩ ក្នុងវិបស្សនាញាណទាំង ១៦) ។*

**តេនាហ "សមុទយតោ មោចេន្តោ"តិ។**

*ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា "**ដកចិត្តចេញពីសមុទ័យ**" ដូច្នេះ ។*

**បដិនិស្សជ្ជនាការេន បវត្តា អនុបស្សនា បដិនិស្សគ្គានុបស្សនា។**

*អនុបស្សនាដែលប្រព្រឹត្តិទៅតាមអាការៈលះបង់ ឈ្មោះថា* **បដិនិស្សគ្គា-នុបស្សនា** *។*

**"អាទានតោ"តិ និច្ចាទិវសេន គហណតោ, បដិសន្ធិគ្គហណតោ វាតិ ឯវមេត្ថ អត្ថោ ទដ្ឋព្វោ។**

*ពាក្យថា "**ចេញពីអាទាន**" គឺចេញពីការប្រកាន់ខ្ជាប់ ដោយអំណាចជារបស់ទៀង ជាដើម, ឬចេញពីការកាន់យកបដិសន្ធិ ។ បណ្ឌិតគប្បីជ្រាបនូវសេចក្ដីអធិប្បាយនៅក្នុងពាក្យទាំងនេះទៅតាមប្រការដូចបានពោលមកហើយនេះផងចុះ ។*

# ធម្មានុបស្សនា ចតុក្កៈទី ៤[៦៧]

## (វិសុទ្ធិមគ្គ)

[២៣៦] ចតុត្ថចតុក្កេ បន "**អនិច្ចានុបស្សី**"តិ ឯត្ថ តាវ អនិច្ចំ វេទិតព្វំ។

*ចំណែកនៅក្នុងចតុក្កៈទី ៤ នេះ មុននឹងសម្តែងក្នុងបទថា "**អនិច្ចានុបស្សី**" នេះ គប្បីជ្រាបនូវបទថា អនិច្ចំ ប្រែថា សភាវៈមិនទៀង ។*

អនិច្ចតា វេទិតព្វា។ អនិច្ចានុបស្សនា វេទិតព្វា។ អនិច្ចានុបស្សី វេទិតព្វោ។

*គប្បីជ្រាបនូវ **អនិច្ចតា** ប្រែថា សភាវៈមិនទៀង ។ គប្បីជ្រាបនូវ **អនិច្ចានុបស្សនា** ប្រែថា ការពិចារណាឃើញរឿយៗ ថាមិនទៀង ។ គប្បីជ្រាបនូវ **អនិច្ចានុបស្សី** ប្រែថា បុគ្គលអ្នកពិចារណាឃើញរឿយៗ ថាមិនទៀង ។*

តត្ថ "**អនិច្ច**"ន្តិ បញ្ចក្ខន្ធា។ កស្មា? ឧប្បាទវយញ្ញថត្តភាវា។

*ក្នុងបណ្តាបទទាំងនោះ បទថា "អនិច្ចំ" ប្រែថា សភាវៈដែលមិនទៀង បានដល់ខន្ធ៥ ។ តើព្រោះហេតុអ្វី ? ព្រោះមានការកើតឡើងនិងវិនាសទៅវិញដោយសភាវៈផ្សេងៗ ។*

"**អនិច្ចតា**"តិ តេសំយេវ ឧប្បាទវយញ្ញថត្តំ, ហុត្វា អភាវោ វា, និព្វត្តានំ តេនេវាការេន អដ្ឋត្វា ខណភង្គេន ភេទោតិ អត្ថោ ។

*បទថា "**អនិច្ចតា** ប្រែថា **សភាវៈដែលមិនទៀង**" បានដល់ សភាវៈដែលកើតឡើងហើយ និងវិនាសទៅវិញ នឹងជាបការៈដទៃនៃខន្ធទាំងនោះ នុ៎ះឯង, ឬបានដល់ សភាវៈដែលមានហើយ ត្រឡប់ទៅជាមិនមានវិញ, សេចក្តីថា បានដល់ ការតាំងនៅមិនបានដោយអាការៈនោះ នុ៎ះឯង ហើយបែកធ្លាយទៅ ដោយការបែកធ្លាយទៅក្នុងខណៈនៃខន្ធទាំងឡាយដែលបង្កើតហើយ ។*

---

*៦៧ ធម្មានុបស្សនា ចតុក្កៈទី៤ នេះ ជាការចម្រើនវិបស្សនាតែម្យ៉ាង ។*

**"អនិច្ចានុបស្សនា"តិ តស្សា អនិច្ចតាយ វសេន រូបាទីសុ អនិច្ចន្តិ អនុបស្សនា ។**

*បទថា "**អនិច្ចានុបស្សនា**" បានដល់ ការពិចារណាឃើញរឿយៗថា មិនទៀង ក្នុងខន្ធទាំងឡាយ មានរូបខន្ធជាដើម ដោយអំណាចនៃ **អនិច្ចតា** នោះ ។*

**"អនិច្ចានុបស្សី"តិ តាយ អនុបស្សនាយ សមន្នាគតោ ។**

*បទថា "**អនិច្ចានុបស្សី**" បានដល់ បុគ្គលអ្នកដល់ព្រមដោយអនុបស្សនា នោះ ។*

**តស្មា ឯវំភូតោ អស្សសន្តោ បស្សសន្តោ ច ឥធ "អនិច្ចានុបស្សី អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតី"តិ វេទិតព្វោ ។**

*ព្រោះហេតុនោះ បុគ្គលជាអ្នកយ៉ាងនេះ ដកដង្ហើមចូល និងដកដង្ហើមចេញ គប្បីជ្រាបថា ឈ្មោះថា រមែងសិក្សាថា "អាត្មាអញឃើញរឿយៗ នូវបញ្ច-ខន្ធនេះថា មិនទៀង ខណៈដកដង្ហើមចូល និងខណៈដកដង្ហើមចេញ ។*

**"វិរាគានុបស្សី"តិ ឯត្ថ បន ទ្វេ វិរាគា ខយវិរាគោ ច អច្ចន្តវិរាគោ ច ។**

*ចំណែកក្នុងបទថា "**វិរាគានុបស្សី** ប្រែថា រមែងសិក្សាថា "អាត្មាអញឃើញរឿយៗ នូវធម៌ជាគ្រឿងធ្វើចិត្តឱ្យប្រាសចាកនូវតម្រេក" នេះ មានសេចក្តីថា ដែលឈ្មោះថា **វិរាគ** ប្រែថា តម្រេកមាន ២ យ៉ាង គឺ**ខយវិរាគ** ប្រែថា សភាវៈអស់ទៅ គឺសូន្យទៅ និង **អច្ចន្តវិរាគ** ប្រែថា ការអស់ទៅយ៉ាងពិតប្រាកដ ។*

**តត្ថ "ខយវិរាគោ"តិ សង្ខារានំ ខណភង្គោ។**

*ក្នុងវិរាគៈទាំង ២ យ៉ាងនោះ សភាវៈបែកធ្លាយរលត់បាត់ទៅក្នុងខណៈនៃសង្ខារទាំងឡាយ ឈ្មោះថា **ខយវិរាគ** ។*

**"អច្ចន្តវិរាគោ"តិ និព្វានំ។**

*ព្រះនិព្វាន ឈ្មោះថា "**អច្ចន្តវិរាគ**" ។*

**"វិរាគានុបស្សនា"**តិ តទុភយេនស្សនវសេន បវត្តា វិបស្សនា ច មគ្គោ ច ។

*វិបស្សនា និងមគ្គ ដែលប្រព្រឹត្តទៅ ដោយអំណាចនៃវិរាគៈទាំង ២ នោះ ឈ្មោះថា* **វិរាគានុបស្សនា** ។

តាយ ទុវិធាយបិ អនុបស្សនាយ សមន្នាគតោ ហុត្វា អស្សសន្តោ បស្សសន្តោ ច "វិរាគានុបស្សី អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតី"តិ វេទិតព្វោ។

*ព្រះយោគីភិក្ខុ ជាអ្នកដល់ព្រមដោយ អនុបស្សនា ទាំង ២ យ៉ាងនោះ ខណៈដកដង្ហើមចូល និងខណៈដកដង្ហើមចេញ គប្បីជ្រាបថា ឈ្មោះថា រមែងសិក្សាថា "អាត្មាអញជាអ្នកពិចារណាឃើញរឿយៗ នូវសភាវៈរលត់បាត់ទៅ ខណៈដកដង្ហើមចូល និងខណៈដកដង្ហើមចេញ" ដូច្នេះ ។*

**និរោធានុបស្សីបទេបិ** ឯសេវ នយោ ។

*សូម្បីនៅក្នុងបទថា "***និរោធានុបស្សី** *ប្រែថា* ***ព្រះយោគាវចរភិក្ខុជាអ្នកពិចារណាឃើញរឿយៗ នូវសភាវៈរលត់បាត់ទៅ****" ក៏មានន័យសេចក្ដីដូចគ្នា ។*

**"បដិនិស្សគ្គានុបស្សី"**តិ ឯត្ថាបិ ទ្វេ បដិនិស្សគ្គា បរិច្ចាគបដិនិស្សគ្គោ ច បក្ខន្ទនបដិនិស្សគ្គោ ច។

*សូម្បីនៅក្នុងបទថា "***បដិនិស្សគ្គានុបស្សី** *ប្រែថាព្រះយោគាវចរភិក្ខុពិចារណាឃើញ រឿយៗ នូវធម៌ជាគ្រឿងរលាស់ចិត្តចេញពីកិលេស" នេះ ក៏មានសេចក្ដីថា ឈ្មោះថា* **បដិនិស្សគ្គ** *មាន ២ យ៉ាង គឺ* **បរិច្ចាគបដិនិស្សគ្គ** *ប្រែថា សេចក្ដីចេញទៅ គឺ* **បរិច្ចាគ** *និង* **បក្ខន្ទនបដិនិស្សគ្គ** *ប្រែថា សេចក្ដីចេញទៅ គឺស្ទុះទៅ ។*

បដិនិស្សគ្គោយេវ អនុបស្សនា បដិនិស្សគ្គានុបស្សនា។

*អនុបស្សនា គឺបដិនិស្សគ្គ ទើបឈ្មោះថា* **បដិនិស្សគ្គានុបស្សនា។**

**វិបស្សនាមគ្គានំ ឯតមធិវចនំ។**

*ពាក្យថា "***បដិនិស្សគ្គានុបស្សនា** *នេះ ជាឈ្មោះ របស់វិបស្សនា និង មគ្គ ។*

**វិបស្សនា** ហិ តទង្គវសេន សទ្ធឹ ខន្ធាភិសង្ខារេហិ កិលេសេ បរិច្ចជតិ, សង្ខតទោសទស្សនេន ច តព្វិបរីតេ និព្វានេ តន្និន្នតាយ បក្ខន្ទតីតិ **បរិច្ចាគបដិនិស្សគ្គោ** ចេវ "**បក្ខន្ទនបដិនិស្សគ្គោ**"តិ ច វុច្ចតិ ។

*មែនពិត វិបស្សនា រមែងលះបង់នូវកិលេសទាំងឡាយ ព្រមទាំងខន្ធ និង អភិសង្ខារ ដោយអំណាចតទង្គបហានៈ, និងព្រោះការឃើញនូវទោសនៅក្នុង សង្ខត ទើបស្ទុះទៅកាន់ព្រះនិព្វាន ដែលមានសភាវៈផ្ទុយពីគ្នាជាមួយសង្ខត នោះ ដោយសភាវៈដែលមានចិត្តបង្អោនទៅក្នុងព្រះនិព្វាននោះ ព្រោះហេតុនោះ ទើបហៅថា* **បរិច្ចាគបដិនិស្សគ្គ** *និង* **បក្ខន្ទនបដិនិស្សគ្គ** *។*

**មគ្គោ** សមុច្ឆេទវសេន សទ្ធឹ ខន្ធាភិសង្ខារេហិ កិលេសេ បរិច្ចជតិ, អារម្មណករណេន ច និព្វានេ បក្ខន្ទតីតិ **បរិច្ចាគបដិនិស្សគ្គោ** ចេវ បក្ខន្ទនបដិនិស្សគ្គោតិ ច វុច្ចតិ។

*ចំណែក* **មគ្គ** *រមែងលះកិលេសទាំងឡាយ ព្រមទាំងខន្ធ និងអភិសង្ខារ ដោយអំណាចសមុច្ឆេទបហាន, និងស្ទុះទៅក្នុងព្រះនិព្វាន ដោយការធ្វើឱ្យមក ជាអារម្មណ៍ ព្រោះហេតុនោះ ទើបហៅថា* **បរិច្ចាគបដិនិស្សគ្គ** *និង* **បក្ខន្ទនប-ដិនិស្សគ្គ** *។*

ឧភយម្បិ បន បុរិមបុរិមញ្ញាណានំ អនុបស្សនតោ "**អនុបស្សនា**"តិ វុច្ចតិ។

*ធម្មជាតិទាំង ២ យ៉ាងហៅថា "***អនុបស្សនា***" ក៏ព្រោះការពិចារណា ឃើញតាមញាណខាងដើមៗ នោះ ។*

**តាយ ទុវិធាយបិ បដិនិស្សគ្គានុបស្សនាយ សមន្នាគតោ ហុត្វា អស្សសន្តោ បស្សសន្តោ ច "បដិនិស្សគ្គានុបស្សី អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតី"តិ វេទិតព្វោ ។**

*យោគីភិក្ខុ ជាអ្នកដល់ព្រមដោយ* **បដិនិស្សគ្គានុបស្សនា** *ទាំង ២ យ៉ាងនោះ ដកដង្ហើមចូល និងដកដង្ហើមចេញ គប្បីជ្រាបថា "ឈ្មោះថា រមែងសិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញរឿយៗ នូវធម៌ជាគ្រឿងរលាស់ចិត្តចេញពីកិលេស ដកដង្ហើមចូល និងដកដង្ហើមចេញ" ដូច្នេះ ។*

**ឥទំ ចតុត្ថចតុក្កំ សុទ្ធវិបស្សនាវសេនេវ វុត្តំ ។**

*ក្នុងចតុក្កៈទី ៤ នេះ ព្រះអង្គត្រាស់សម្ដែងទុក ដោយអំណាចជាវិបស្សនាសុទ្ធសាធ ។*

**បុរិមានិ បន តីណិ សមថវិបស្សនាវសេន។**

*ចំណែកចតុក្កៈទាំង ៣ ខាងដើមនោះ ព្រះអង្គត្រាស់សម្ដែងទុក ដោយអំណាចជាសមថៈផង និងជាវិបស្សនាផង ។*

**ឯវំ ចតុន្នំ ចតុក្កានំ វសេន សោឡសវត្ថុកាយ អានាបានស្សតិយា ភាវនា វេទិតព្វា ។**

*គប្បីជ្រាបនូវការចម្រើនអានាបានស្សតិ ដែលមានវត្ថុ (គឺរឿង) ទាំង ១៦ ប្រភេទដោយអំណាចនៃចតុក្កៈទាំង ៤ យ៉ាង ទៅតាមប្រការដែលបានពោលមកហើយនេះឯងផងចុះ ។*

**ឯវំ សោឡសវត្ថុវសេន ច បន អយំ អានាបានស្សតិ មហប្ផលា ហោតិ មហានិសំសា ។**

*ម្យ៉ាងទៀត អានាបានស្សតិ ដោយជាប់ទាក់ទងជាមួយវត្ថុទាំង ១៦ យ៉ាង តាមដែលបានពោលមកហើយនេះ រមែងមានផលច្រើន និងមានអានិសង្សច្រើន ។*

## ធម្មានុបស្សនា ចតុក្កៈទី ៤

### (មហាដីកាវិសុទ្ធិមគ្គ)

[២៣៦] អនិច្ចន្តិ អនុបស្សី, អនិច្ចស្ស វា អនុបស្សនសីលោ **អនិច្ចា-នុបស្សីតិ** ឯត្ថ កឹ បនេតំ អនិច្ចំ, កថំ វា អនិច្ចំ, កា វា អនិច្ចានុបស្សនា, កស្ស វា អនិច្ចានុបស្សនាតិ ចតុក្កំ វិភាវេតព្វន្តិ តំ ទស្សេន្តោ "**អនិច្ចំ វេទិតព្វ**"ន្តិអាទិមាហ ។

*ព្រះយោគីភិក្ខុអ្នកពិចារណាឃើញរឿយៗថា មិនទៀង, ឬយោគីភិក្ខុជាអ្នកមានការពិចារណាឃើញរឿយៗ នូវសភាវៈ ដែលមិនទៀងជាប្រក្រតី ឈ្មោះថា* **អនិច្ចានុបស្សី** *ក៏ក្នុងសេចក្តីនេះ លោកអាចារ្យ កាលនឹងសម្តែងនូវសេចក្តីដែលថា បណ្ឌិតគប្បីជ្រាបនូវចតុក្កៈថា សភាវៈដែលជា* **អនិច្ចំ** *នេះ គឺជាអ្វី?, ជា* **អនិច្ចំ** *ដូចម្តេច?, តើអ្វីដែលឈ្មោះថា* **អនិច្ចានុបស្សនា**, *និង* **អនិច្ចានុបស្សនា** *មានដល់អ្នកណា ដូច្នេះនោះ ទើបពោលថា "គប្បីជ្រាប* **អនិច្ចំ**" *ដូច្នេះជាដើម ។*

តត្ថ និច្ចំ នាម ធុវំ សស្សតំ យថា តំ និព្វានំ, ន និច្ចន្តិ **អនិច្ចំ**, ឧទយ-ព្វយវន្តំ, អត្ថតោ សង្ខតា ធម្មាតិ អាហ "**អនិច្ចន្តិ បញ្ចក្ខន្ធា** ។

*ក្នុងពាក្យទាំងនោះ សភាវៈដែលនៅគង់វង្ស នៅយូរបាន ដូចនឹងព្រះនិព្វាន ឈ្មោះថា* **និច្ចំ**, *ឈ្មោះថា* **អនិច្ចំ** *ព្រោះអត្ថថាមិនមែន* **និច្ចំ**, *បានដល់ធម្មជាតិដែលមានការកើតឡើង ហើយរលត់បាត់ទៅវិញ, ដោយសភាវៈ បានដល់សង្ខតធម៌ទាំងឡាយ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា "***បទថា អនិច្ចំ** *បានដល់ខន្ធ ៥" ។*

**កស្មា? ឧប្បាទវយញ្ញថត្តភាវា**"តិ, ឧប្បាទវយញ្ញថត្តសព្ភាវាតិ អត្ថោ ។

*ព្រោះហេតុអ្វី? ព្រោះមានការកើត និងរលត់ និងមានបការៈដទៃៗទៀត"*

*ដូច្នេះ, សេចក្តីថា ព្រោះសភាវៈដែលមានការកើតឡើង ហើយរលត់បាត់ទៅវិញ និងសភាវៈជាប្រការដទៃទៀត ។*

**តត្ថ សង្ខតធម្មានំ ហេតុបច្ចយេហិ ឧប្បជ្ជនំ អហុត្វា សម្ភវោ អត្តលាភោ ឧប្បាទោ ។**

*ក្នុងពាក្យថា ព្រោះមានការកើតឡើងនោះ ការកើតឡើង ព្រោះហេតុបច្ច័យទាំងឡាយ គឺសភាវៈដែលមិនមាន ហើយត្រឡប់មកមានវិញ ជាការបានតួសភាវៈនៃសង្ខតធម៌ទាំងឡាយ ឈ្មោះថា* ***ឧប្បាទ*** *ប្រែថា* ***ការកើតឡើង*** *។*

**ឧប្បន្នានំ តេសំ ខណនិរោធោ វិនាសោ វយោ ។**

*សភាវៈរលត់បាត់ទៅក្នុងខណៈ គឺការវិនាសទៅនៃសង្ខតធម៌ ដែលកើតឡើងហើយទាំងនោះ ឈ្មោះថា* ***វយ*** *ប្រែថា* ***ការសូន្យទៅ, រលត់បាត់ទៅ*** *។*

**ជរាយ អញ្ញថាភាវោ អញ្ញថត្តំ។**

*សភាវៈជាប្រការដទៃនៃជរា ឈ្មោះថា* ***អញ្ញថត្ត*** *សភាវៈជាប្រការដទៃ ។*

**យថា ហិ ឧប្បាទាវត្ថាយ ភិន្នាយ ភង្គាវត្ថាយំ វត្ថុភេទោ នត្ថិ, ឯវំ ឋិតិសង្ខាតាយ ភង្គាភិមុខាវត្ថាយម្បិ វត្ថុភេទោ នត្ថិ, យត្ថ ជរាវោហារោ ។**

*ប្រៀបដូចជា កាលឧប្បាទខណៈបែកធ្លាយទៅហើយ (គឺឧប្បាទខណៈរលត់បាត់ទៅហើយ) ត្រង់ភង្គខណៈក៏នៅមិនទាន់បែកធ្លាយនៃតួវត្ថុ (គឺតួវត្ថុនៅមានដដែល ត្រឹមតែថា មានជាខណៈចុងក្រោយ) យ៉ាងណាមិញ, សូម្បីត្រង់ខណៈដែលមានមុខឆ្ពោះទៅកាន់សភាវៈរលត់ ដែលហៅថា ឋិតិ ក៏មិនមានការបែកធ្លាយនៃវត្ថុ ក៏យ៉ាងនោះដែរ, ដែលជា ខណៈត្រង់ដែលមានវោហារថា ជរា ។*

**តស្មា ឯកស្សាបិ ធម្មស្ស ជរា យុជ្ជតិ, យា ខណិកជរាតិ វុច្ចតិ ។**

*ព្រោះហេតុនោះ ជរា ក៏រមែងសមគួរសូម្បីដល់ធម៌តែមួយ, ដែលជាជរា គឺលោកហៅថា ខណិកជរា ។*

**ឯកាំសេន ច ឧប្បាទកង្គាវត្ថាសុ វត្ថុនោ អភេទោ ឥច្ឆិតព្វោ, អញ្ញថា "អញ្ញោ ឧប្បជ្ជតិ, អញ្ញោ ភិជ្ជតី"តិ អាបជ្ជេយ្យ។**

*ត្រង់ឧប្បាទខណៈ និងភង្គខណៈ បណ្ឌិតគប្បីត្រូវការដល់សភាវៈដែលតួវត្ថុនៅមិនទាន់បែកធ្លាយយ៉ាងពិតប្រាកដ, ប្រសិននឹងកាន់យកនូវសភាវៈដោយប្រការដទៃ ក៏នឹងក្លាយទៅជាថា "ធម៌ម្យ៉ាងទៀតកើត, ធម៌ម្យ៉ាងទៀតរលត់បាត់" ដូច្នេះ ។*

**តយិមំ ខណិកាជរំ សន្ធាយាហ "អញ្ញថត្ត"ន្តិ។**

*លោកអាចារ្យសំដៅយក ខណិកជរានេះ ទើបពោលថា* "**អញ្ញថត្តំ** *ប្រែថា សភាវៈជាប្រការដទៃ" ដូច្នេះ ។*

**យំ បនេត្ថ វត្តព្វំ, តំ បរតោ កថយិស្សាម។**

*ក្នុងពាក្យនេះ នឹងមានពាក្យគួរពោលអធិប្បាយយ៉ាងណា, ខ្ញុំម្ចាស់នឹងពោលនូវពាក្យដែលគួរពោលអធិប្បាយនោះនៅខាងមុខ ។*

**យស្ស លក្ខណត្តយស្ស ភាវា ខន្ធេសុ អនិច្ចសមញ្ញា, តស្មឹ លក្ខណត្តយេ អនិច្ចតាសមញ្ញាតិ "អនិច្ចតាតិ តេសំយេវ ឧប្បាទវយញ្ញថត្ត"ន្តិ វត្វា វិសេសតោ ជម្មានំ ខណិកានិរោធេ អនិច្ចតាវោហារោតិ ទស្សេន្តោ "ហុត្វា អភាវោ វា"តិអាទិមាហ ។**

*ឈ្មោះថា* **អនិច្ចំ** *រមែងមានក្នុងខន្ធទាំងឡាយ ព្រោះមានលក្ខណៈ ៣ យ៉ាងណា, ឈ្មោះថា* **អនិច្ចតា** *ក៏រមែងមានក្នុងលក្ខណៈ ៣ យ៉ាងនោះ ព្រោះហេតុនោះ លោកអាចារ្យ កាលពោលថា "បទថា* **អនិច្ចំ** *បានដល់ សភាវៈដែលកើតឡើង ហើយរលត់បាត់ទៅវិញ និងជាបការៈដទៃនៃខន្ធទាំងនោះនុ៎ះឯង" ដូច្នេះ ហើយកាលសម្ដែងថា ជាពិសេសធម៌ទាំងឡាយមានវោហារថា*

*អនិច្ចតា ព្រោះសភាវៈរលត់ទៅក្នុងខណៈ ដូច្នេះ ទើបពោលថា "ឬ បានដល់សភាវៈដែលមានហើយ ត្រឡប់ទៅជាមិនមានវិញ" ដូច្នេះ ជាដើម ។*

**តត្ថ ឧប្បាទបុព្វកត្តា អភាវស្ស ហុត្វាតិ ហាណំ។**

*ក្នុងពាក្យនោះ លោកប្រើសព្ទថា* **ហុត្វា** *មានហើយ ព្រោះធម៌ដែលនឹងត្រឡប់ទៅជាមិនមាន នឹងត្រូវមានការកើតឡើងជាមុនសិន ។*

**តេន ចាកភាវបុព្វកត្តំ វិនាសភាវស្ស ឧស្សេតិ។**

*ដោយពាក្យនោះ លោកសម្ដែងថា ធម៌ដែលមានសេចក្ដីវិនាសទៅនោះ ត្រូវមានសភាពចាស់ទ្រុឌទ្រោមជាមុនសិន ។*

"**តេនេវាការេនា**"តិ និព្វត្តនាការេនេវ ។

*ពាក្យថា "**ដោយអាការៈនោះ នុ៎ះឯង**" គឺដោយអាការៈដែលបង្កើតនុ៎ះឯង ។*

"**ខណភង្គេនា**"តិ ខណិកនិរោធេន។

*ពាក្យថា "**ដោយការបែកធ្លាយរលត់បាត់ទៅក្នុងខណៈ**" គឺដោយការរលត់បាត់ទៅដែលមាននៅក្នុងខណៈ ។*

"**តស្សា អនិច្ចតាយា**"តិ ខណិកភង្គសង្ខាតាយ អនិច្ចតាយ។

*ពាក្យថា (ដោយអំណាច) "**នៃ អនិច្ចតា នោះ**" គឺ (ដោយអំណាច) នៃអនិច្ចតា ដែលហៅថា សភាពបែកធ្លាយរលត់បាត់ក្នុងខណៈ ។*

"**តាយ អនុបស្សនាយា**"តិ យថាវុត្តាយ អនិច្ចានុបស្សនាយ។

*ពាក្យថា "**ដោយអនុបស្សនានោះ**" គឺដោយអនិច្ចានុបស្សនា តាមដែលបានពោលមកហើយ ។*

"**សមន្នាគតោ**"តិ សមង្គីភូតោ យោគាវចរោ។

*ពាក្យថា "**បុគ្គលជាអ្នកដល់ព្រម**" បានដល់ ព្រះយោគាវចរ ជាអ្នកដល់ព្រមហើយ ។*

**ខយោ** សង្ខារានំ វិនាសោ, វិរជ្ជនំ តេសំយេវ វិលុជ្ជនំ **វិរាគោ**, ខយោ ឯវ វិរាគោ **ខយវិរាគោ**, ខណិកនិរោធោ។

*ឈ្មោះថា **ខយ** ប្រែថា សភាវៈអស់ទៅ បានដល់ ការវិនាសទៅ, គឺសភាវៈថយទៅៗ នៃសង្ខារទាំងឡាយ សេចក្តីវិនាសទៅនៃសង្ខារទាំងនោះ នុ៎ះឯង ឈ្មោះថា **វិរាគ** ប្រែថា សេចក្តីថយទៅៗ, **ខយ** នោះឯងជា **វិរាគ** ទើបឈ្មោះថា **ខយវិរាគ**, បានដល់ ការរលត់បាត់ទៅដែលមានក្នុងខណៈ ។*

អច្ចន្តមេត្ថ ឯតស្មិំ អធិគតេ សង្ខារា វិរជ្ជន្តិ និរុជ្ឈន្តីតិ **អច្ចន្តវិរាគោ**, និព្វានំ។

*ព្រះនិព្វាន ឈ្មោះថា **អច្ចន្តវិរាគ** ព្រោះអត្ថថា ជាធម្មមួយយ៉ាង កាលដែលបុគ្គលបានចាក់ធ្លុះហើយ សង្ខារទាំងឡាយ ក៏រមែងថយទៅៗ គឺរលត់បាត់ទៅ យ៉ាងពិតប្រាកដ ។*

តេនាហ "**ខយវិរាគោ សង្ខារានំ ខណភង្គោ, អច្ចន្តវិរាគោ-និព្វាន**"ន្តិ។

*ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា "សភាវៈបែកធ្លាយទៅក្នុងខណៈ នៃសង្ខារទាំងឡាយ ឈ្មោះថា **ខយវិរាគ**, ព្រះនិព្វាន ឈ្មោះថា **អច្ចន្តវិរាគ**" ដូច្នេះ ។*

"**តទុភយវសេន បវត្តា**"តិ ខយវិរាគានុបស្សនាវសេន វិបស្សនាយ, អច្ចន្តវិរាគានុបស្សនាវសេន មគ្គស្ស បវត្តិ យោជេតព្វា។

*ពាក្យថា "**ដែលប្រព្រឹត្តិទៅ ដោយអំណាចនៃវិរាគទាំង ២**" បានសេចក្តីថា សម្រាប់វិបស្សនា គប្បីប្រកបការប្រព្រឹត្តទៅ ដោយអំណាចនៃការតាមពិចារណាឃើញខយវិរាគ, សម្រាប់មគ្គ គប្បីប្រកបការប្រព្រឹត្តិទៅ ដោយអំណាចនៃការ*

*តាមពិចារណាឃើញ អច្ចន្តវិរាគ ។*

អារម្មណតោ វា វិបស្សនាយ ខយវិរាគានុបស្សនាវសេន បវត្តិ, តន្និន្នភាវតោ អច្ចន្តវិរាគានុបស្សនាវសេន, មគ្គស្ស បន អសម្មោហតោ ខយវិរាគានុបស្សនាវសេន, អារម្មណតោ អច្ចន្តវិរាគានុបស្សនាវសេន បវត្តិ វេទិតព្វា។

*ន័យម្យ៉ាងទៀត គប្បីជ្រាបថា* **វិបស្សនា** *មានការប្រព្រឹត្តិទៅ ដោយអំណាចការតាមពិចារណាឃើញ* **ខយវិរាគ** *ដោយអារម្មណ៍ (ការធ្វើ* **ខយវិរាគ** *ឱ្យមកជាអារម្មណ៍), មានការប្រព្រឹត្តទៅ ដោយអំណាចនៃការតាមពិចារណាឃើញ* **អច្ចន្តវិរាគ** *តាមសភាវៈដែលបង្អោនទៅក្នុង* **អច្ចន្តវិរាគ***នោះ, ចំណែក* **មគ្គ** *មានការប្រព្រឹត្តទៅ ដោយអំណាចការតាមពិចារណាឃើញ* **ខយវិរាគ** *ដោយអសម្មោហ, មានការប្រព្រឹត្តទៅ ដោយអំណាចការតាមពិចារណាឃើញ* **អច្ចន្តវិរាគ** *ដោយអារម្មណ៍ ។*

"**ឯសេវ នយោ**"តិ ឥមិនា យស្មា វិរាគានុបស្សីបទេ វុត្តនយានុសារេន "ទ្វេ និរោធា ខយនិរោធោ ច អច្ចន្តនិរោធោ ចា"តិ ឯវមាទិអត្ថវណ្ណនំ អតិទិសតិ, តស្មា វិរាគដ្ឋានេ និរោធបទំ បក្ខិបិត្វា "ខយោ សង្ខារានំ វិនាសោ"តិអាទិនា ឥធ វុត្តនយេន តស្ស អត្ថវណ្ណនា វេទិតព្វា ។

*ដោយពាក្យថា "***ក៏មានន័យនេះឯង***" នេះ ព្រោះហេតុដែលសំដៅដល់ការអធិប្បាយមានយ៉ាងនេះថា "ឈ្មោះថា* **និរោធ** *មាន ២ យ៉ាង គឺ***ខយនិរោធ** *និង* **អច្ចន្តនិរោធ***" ដូច្នេះជាដើម តាមទំនងនៃន័យដែលបានពោលទុកក្នុងបទថា* **វិរាគានុបស្សនា***, ដូច្នេះ បណ្ឌិតគប្បីបញ្ចូលបទថា* **និរោធ** *មកជំនួសបទថា* **វិរាគ** *ហើយគប្បីជ្រាប សេចក្តីអធិប្បាយនៃបទថា* **និរោធានុបស្សី** *នោះ ទៅតាមន័យសេចក្តីដែលខ្ញុំម្ចាស់បានពោលមកហើយក្នុងទីនេះ ដោយពាក្យថា*

*"ឈ្មោះថា ខយ ប្រែថា សភាវៈអស់ទៅ គឺការវិនាសទៅនៃសង្ខារទាំងឡាយ" ដូច្នេះ ជាដើមផងចុះ ។*

**បដិនិស្សជ្ជនំ បហាតព្វស្ស តទង្គវសេន វា សមុច្ឆេទវសេន វា បរិច្ចជនំ បរិច្ចាគបដិនិស្សគ្គោ។**

*ការលះទៅ គឺការបរិច្ចាគនូវវត្ថុដែលគួរលះ ដោយអំណាចការ បរិច្ចាគ-ជាតទង្គ ឬដោយអំណាចការ បរិច្ចាគជាសមុច្ឆេទ ឈ្មោះថា* ***បរិច្ចាគបដិនិ-ស្សគ្គ*** *។*

**តថា សព្វបជីនំ បដិនិស្សគ្គភូតេ វិសង្ខារេ អត្តនោ និស្សជ្ជនំ, តន្និន្នតាយ វា តទារម្មណតាយ វា តត្ថ បក្ខន្ទនំ បក្ខន្ទនបដិនិស្សគ្គោ។**

*ដូចគ្នាផងដែរ ការលះខ្លួនទៅក្នុងវិសង្ខារ (គឺព្រះនិព្វាន) ជាការលះនូវឧបធិទាំងពួង, គឺការស្ទុះទៅក្នុងព្រះនិព្វាននោះ ដោយសភាវៈដែលមានចិត្តបង្អោនទៅក្នុងព្រះនិព្វាននោះក្តី ដោយសភាវៈដែលមានព្រះនិព្វាននោះមកជាអារម្មណ៍ក្តី ឈ្មោះថា* ***បក្ខន្ទនបដិនិស្សគ្គ*** *។*

**"តទង្គវសេនា"តិ ឯត្ថ អនិច្ចានុបស្សនា តាវ តទង្គប្បហានវសេន និច្ចសញ្ញំ បរិច្ចជតិ, បរិច្ចជន្តី ច តថា អប្បវត្តិយំ យេ "និច្ច"ន្តិ គហណវសេន កិលេសា, តម្មូលកា អភិសង្ខារា, តទុភយមូលកា ច វិបាកក្ខន្ធា អនាគតេ ឧប្បជ្ជេយ្យុំ, តេ សព្វេបិ អប្បវត្តិករណវសេន បរិច្ចជតិ, តថា ទុក្ខសញ្ញាទយោ ។**

*ក្នុងពាក្យថា "**ដោយអំណាចការលះជាតទង្គ**" នេះ មានសេចក្តីអធិប្បាយមុនដំបូង អនិច្ចានុបស្សនា រមែងបរិច្ចាគនិច្ចសញ្ញា ដោយអំណាចការលះជា-តទង្គ, មួយទៀត ធម៌ណា គឺកិលេសទាំងឡាយ អភិសង្ខារ ដែលមានកិលេសទាំងនោះជាឫសគល់ និងវិបាកខន្ធទាំងឡាយ ដែលមានកិលេសជាមួយអភិសង្ខារទាំងពីរយ៉ាងនោះជាឫសគល់ គប្បីកើតឡើងបាន ក្នុងអនាគត ដោយអំណាចនៃការប្រកាន់ខ្ជាប់ថា "ទៀង" ក្នុងកាលនោះ វាមិនប្រព្រឹត្តទៅ*

*យ៉ាងនោះ, អនិច្ចានុបស្សនា កាលនឹងបរិច្ចាគ រមែងបរិច្ចាគធម៌ទាំងនោះសូម្បីតែទាំងអស់ ដោយអំណាចការធ្វើមិនឱ្យប្រព្រឹត្តទៅ, ទុក្ខានុបស្សនាជាដើម រមែងលះសុខសញ្ញាជាដើម យ៉ាងនោះដូចគ្នា ។*

**តេនាហ "វិបស្សនា ហិ តទង្គវសេន សទ្ធឹ ខន្ធាភិសង្ខារេហិ កិលេសេ បរិច្ចជតី"**តិ ។

*ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា "មែនពិត វិបស្សនា រមែងបរិច្ចាគកិលេសទាំងឡាយព្រមទាំងខន្ធ និងអភិសង្ខារ ដោយអំណាចការលះជាតទង្គ" ដូច្នេះ ។*

"**សង្ខតទោសទស្សនេនា**"តិ សង្ខតេ តេភូមកេ សង្ខារគតេ អនិច្ចាទិទោសទស្សនេន ។

*ពាក្យថា "**ព្រោះឃើញទោសក្នុងសង្ខត**" គឺព្រោះឃើញទោស គឺសភាវៈជារបស់មិនទៀងជាដើម ក្នុងសង្ខត គឺក្នុងសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។*

និច្ចាទិភាវេន **តព្វិបរីតេ។ "តន្និន្នតាយា"**តិ តទធិមុត្តតាយ។

*(ព្រះនិព្វាន) ឈ្មោះថា "**មានសភាវៈផ្ទុយគ្នាជាមួយសង្ខតនោះ**" ដោយសភាវៈដែលជារបស់ទៀងជាដើម ។ បទថា "**តន្និន្នតាយ**" ប្រែថា ដោយសភាវៈដែលមានចិត្តបង្អោនទៅក្នុងព្រះនិព្វាននោះ ។*

"**បក្ខន្ទតី**"តិ អនុបវិសតិ អនុបវិសន្តំ វិយ ហោតិ ។

*ពាក្យថា "**ស្ទុះទៅ**" បានដល់ តាមចូលទៅ គឺដូចជាតាមចូលទៅ ។*

"**សទ្ធឹ ខន្ធាភិសង្ខារេហិ កិលេសេ បរិច្ចជតី**"តិ មគ្គេន កិលេសេសុ បរិច្ចត្តេសុ អវិបាកធម្មតាបាទនេន អភិសង្ខារា, តម្មូលកា ច ខន្ធា អនុប្បត្តិរហភាវេន បរិច្ចត្តា នាម ហោន្តីតិ សព្វេបិ តេ មគ្គោ បរិច្ចជតីតិ វុត្តំ ។

*ពាក្យថា "(មគ្គ) រមែងលះកិលេសទាំងឡាយព្រមទាំងខន្ធ និងអភិ-*

*សង្ខារ" សេចក្តីថា កាលកិលេសទាំងឡាយ ត្រូវបានមគ្គលះទៅហើយ អភិសង្ខារទាំងឡាយ ក៏ឈ្មោះថា ត្រូវបានបរិច្ចាគទៅហើយដែរ ដោយការធ្វើឱ្យដល់ជាធម៌ដែលគ្មានវិបាក, ខន្ធទាំងឡាយ ដែលមានកិលេស និងអភិសង្ខារទាំងនោះជាឫសគល់ ក៏ឈ្មោះថា ត្រូវបានលះចោលទៅហើយ ដោយសភាវៈជារបស់គួរដល់ការមិនកើតឡើង ព្រោះហេតុនោះ ទើបពោលបានថា មគ្គ រមែងបរិច្ចាគនូវធម៌ទាំងនោះ សូម្បីទាំងអស់ ។*

**"ឧភយ"ន្តិ វិបស្សនាញាណំ, មគ្គញាណញ្ច ។**

*ពាក្យថា "**ធម្មជាតិសូម្បីទាំង ២**" បានដល់ វិបស្សនាញាណ, និងមគ្គញាណ ។*

**មគ្គញាណម្បិ ហិ គោត្រភុញាណស្ស អនុ បច្ឆា និព្វានទស្សនតោ "អនុបស្សនា"តិ វុច្ចតិ។**

*មែនពិត សូម្បី មគ្គញាណ ក៏ហៅថា "**អនុបស្សនា**" បាន ព្រោះឃើញព្រះនិព្វាន តាម គឺខាងក្រោយ គោត្រភូញាណ ។*

**"សោឡសវត្ថុវសេន ចា"តិ សោឡសន្នំ វត្ថូនំ វសេនាបិ វុច្ចមានសន្តភាវាធិវសេនាបីតិ ។ សមុច្ចយត្ថោ ច-សទ្ទោ។**

*ពាក្យថា "**សោឡសវត្ថុវសេន ច**" បានសេចក្តីថា សូម្បីដោយអំណាចនៃសភាវៈដែលស្ងប់ជាដើម ដែលពោលទុក សូម្បីដោយជាប់ទាក់ទងជាមួយវត្ថុទាំង ១៦ ។ ច សព្ទ មានអត្ថថា រួបរួម ។*

**"អានាបានស្សតិ ភាវិតា"តិ បទំ អានេត្វា សម្ពន្ធិតព្វំ។**

*គប្បីនាំបទចូលមកភ្ជាប់ជាមួយថា "អានាបានស្សតិ ភាវិតា" អានាបានស្សតិ ដែលយោគីភិក្ខុ ចម្រើនបានហើយ ។*

# អានិសង្សរបស់អានាបានស្សតិ

**(វិសុទ្ធិមគ្គ)**

[២៣៧] តត្រស្ស "អយម្បិ ខោ, ភិក្ខវេ, អានាបានស្សតិសមាធិ ភាវិតោ ពហុលីកតោ សន្តោ ចេវ បណីតោ ចា"តិអាទិវចនតោ សន្តភាវាទិវសេនាបិ មហានិសំសតា វេទិតព្វា, វិតក្កុបច្ឆេទសមត្ថតាយបិ ។

*ក្នុងបណ្តានៃអានិសង្សទាំងនោះ គប្បីជ្រាបនូវសេចក្តីដែលអានាបានស្សតិនេះ មានអានិសង្សច្រើន ដោយជាប់ទាក់ទងជាមួយសភាវៈជាធម៌ មានការស្ងប់ជាដើម ទៅតាមពុទ្ធដីកាដែលព្រះអង្គត្រាស់សម្តែងទុកមកថា "ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិនេះឯង ដែលយោគីភិក្ខុចម្រើនហើយ ធ្វើឱ្យច្រើនហើយ រមែងជាធម៌ដែលស្ងប់ពិតផង ប្រណីតផង" ដូច្នេះជាដើម, ព្រោះជាសភាវៈធម៌ដែលអាចកាត់នូវវិតក្កៈបាន ។*

អយញ្ហិ សន្តបណីតអសេចនកសុខវិហារត្តា សមាធិអន្តរាយការានំ វិតក្កានំ វសេន ឥតោ ចិតោ ច ចិត្តស្ស វិធាវនំ វិច្ឆិន្ទិត្វា អានាបានារម្មណាភិមុខមេវ ចិត្តំ ករោតិ ។

*មែនពិត សមាធិនេះ ព្រោះជាសភាវៈធម៌ដែលស្ងប់ ប្រណីត សុខស្ងប់ប្រណីត និងជាសុខវិហារធម៌ ទើបកាត់ភាពឆ្វេឆ្វាទៅខាងនេះខាងនោះនៃចិត្ត ដោយអំណាចនៃវិតក្កៈ ដែលធ្វើអន្តរាយដល់សមាធិ ហើយធ្វើចិត្តឱ្យមានមុខឆ្ពោះទៅកាន់អារម្មណ៍កម្មដ្ឋាន គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញតែប៉ុណ្ណោះ ។*

១. តេនេវ វុត្តំ "អានាបានស្សតិ ភាវេតព្វា វិតក្កុបច្ឆេទាយា"តិ[៦៨]។

*ព្រោះហេតុនោះ ទើបព្រះអង្គត្រាស់សម្តែងទុកថា "គប្បីចម្រើនអានាបានស្សតិ ដើម្បីកាត់នូវវិតក្កៈ" ដូច្នេះ ។*

៦៨ (អ. និ. ៩.១) ។

**២. វិជ្ជាវិមុត្តិចារិបូរិយា មូលការវេជាបិ ចស្សា មហានិសំសតា វេទិតព្វា ។**

*មួយទៀត គប្បីជ្រាបនូវសភាវៈដែលអានាបានស្សតិនេះ មានអានិសង្ស យ៉ាងច្រើនក្រៃលែងសូម្បីតែសភាវៈដែលជាឫសគល់នៃវិបស្សនាធ្វើវិជ្ជា (មគ្គ) និងវិមុត្តិ (ផល) ឱ្យពេញបរិបូរណ៍ ។*

**វុត្តញ្ហេតំ ភគវតា –**

*សេចក្ដីនេះ សមតាមដែលព្រះដ៏មានព្រះភាគត្រាស់សម្ដែងទុកមកថា៖*

**៣. "អានាបានស្សតិ, ភិក្ខវេ, ភាវិតា ពហុលីកតា ចត្តារោ សតិបដ្ឋានេ បរិបូរេតិ, ចត្តារោ សតិប្បដ្ឋានា ភាវិតា ពហុលីកតា សត្ត សម្ពោជ្ឈង្គេ បរិបូរេន្តិ, សត្ត សម្ពោជ្ឈង្គា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តី"តិ** (៦៩) ។

*"ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលយោគីភិក្ខុធ្វើឱ្យកើតហើយ ធ្វើឱ្យច្រើនហើយ រមែងធ្វើសតិប្បដ្ឋានទាំង ៤ ឱ្យបរិបូរណ៍, សតិប្បដ្ឋានទាំង ៤ ដែលយោគីភិក្ខុធ្វើឱ្យកើតហើយ ធ្វើឱ្យច្រើនហើយ រមែងធ្វើសម្ពោជ្ឈង្គទាំង ៧ ឱ្យបរិបូរណ៍បាន, សម្ពោជ្ឈង្គទាំង ៧ ដែលយោគីភិក្ខុធ្វើឱ្យកើតហើយ ធ្វើឱ្យច្រើនហើយ រមែងធ្វើវិជ្ជា និងវិមុត្តិឱ្យពេញបរិបូរណ៍" ដូច្នេះ ។*

**អបិច ចរិមកានំ អស្សាសបស្សាសានំ វិទិតភាវករណតោបិស្សា មហានិសំសតា វេទិតព្វា ។**

*ន័យមួយទៀត គប្បីជ្រាបដែលអានាបានស្សតិនោះ មានអានិសង្សច្រើន សូម្បីការចម្រើនឱ្យដឹងច្បាស់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលជា* **ចរិមក** *ប្រែថា* **មានទីបំផុត** ។

**វុត្តញ្ហេតំ ភគវតា –**

---

៦៩ (ម. និ. ៣.១៤៧) ។

*សេចក្តីនេះ សមតាមដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងទុកមកថា៖*

"ឯវំ ភាវិតាយ ខោ, រាហុល, អានាបានស្សតិយា ឯវំ ពហុលីកតាយ យេបិ តេ ចរិមកា អស្សាសបស្សាសា, តេបិ វិទិតាវ និរុជ្ឈន្តិ, នោ អវិទិតា"តិ (៧០)។

*"ម្នាលរាហុល កាលអានាបានស្សតិ អ្នកធ្វើឱ្យកើតបានយ៉ាងនេះហើយ កាលអានាបានស្សតិ អ្នកធ្វើឱ្យច្រើនបានយ៉ាងនេះហើយ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលមានទីបំផុត សូម្បីបែបនោះបានយ៉ាងណា, ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលមានទីបំផុត សូម្បីទាំងនោះ ដែលអ្នកបានកំណត់ដឹងហើយទុំះឯង ក៏រលត់បាត់ទៅ, នៅមិនទាន់បានដឹង ក៏រលត់បាត់ទៅ" ដូច្នេះ ។*

## អានិសង្សរបស់អានាបានស្សតិ

### (មហាដីកាវិសុទ្ធិមគ្គ)

[២៣៧] "**អស្សា**"តិ អានាបានស្សតិសមាធិស្ស ។

*ពាក្យថា នៃអានាបានស្សតិ "នេះ" គឺនៃអានាបានស្សតិសមាធិ ។*

**កាមវិតក្កាទិវិតក្កុបច្ឆេទសមត្ថតាយបិ មហានិសំសតា វេទិតព្វាតិ សម្ពន្ធោ ។**

*ភ្ជាប់សេចក្តីថា គប្បីជ្រាបនូវសេចក្តីដែលមានអានិសង្សច្រើន សូម្បីតាមសភាវៈដែលអាចកាត់វិតក្កៈបាន មានកាមវិតក្កៈជាដើម ។*

"**អយ**"ន្តិ អានាបានស្សតិសមាធិ ។

*ពាក្យថា សមាធិ "**នេះ**" គឺអានាបានស្សតិសមាធិ ។*

---

៧០ (ម. និ. ២.១២១) ។

ឧច្ចាវចេសុ អារម្មណេសុ បវត្តិយេវ **ឥតោ ចិតោ ច ចិត្តស្ស វិធាវនំ** ។

*សភាវៈធម៌ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំងឡាយ ទាំងសភាវៈខ្ពស់និងទាំងសភាវៈទាបនោះប៉ុណ្ណោះ ឈ្មោះថា* ***សភាវៈដែលស្ទុះទៅខាងនេះខ្វះទៅខាងនោះខ្វះនៃចិត្ត*** *។*

**វិជ្ជា** ឯាម មគ្គោ។ **វិមុត្តិ** ផលំ។ **មូលភាវោ** វិបស្សនាយ ចាតកភាវោ។

**មគ្គ** *ឈ្មោះថា វិជ្ជា ។* **ផល** *ឈ្មោះថា វិមុត្តិ ។ សភាវៈជាបាទនៃវិបស្សនាឈ្មោះថា* ***សភាវៈជាមូល*** *(ជាឫសគល់) ។*

**"ចត្តារោ សតិបដ្ឋានេ បរិបូរេតិ"** កាយានុបស្សនាទីនំ ចតុន្នំ អនុបស្សនានំ វសេន តស្សា ភាវនាយ បវត្តនតោ។

*ឈ្មោះថា* ***"រមែងធ្វើសតិប្បដ្ឋានទាំង ៤ ឱ្យពេញបរិបូរណ៍"*** *ព្រោះការចម្រើនអានាបានស្សតិនោះ ប្រព្រឹត្តទៅដោយអំណាចនៃ អនុបស្សនា ៤ យ៉ាងមានកាយានុបស្សនាជាដើម។*

**"សត្ត សម្ពោជ្ឈង្គេ បរិបូរេន្តិ"** ពោជ្ឈង្គភាវនាយ វិនា សតិប្បដ្ឋានភាវនាចារិបូរិយា អភាវតោ ។

*ឈ្មោះថា* ***"រមែងធ្វើពោជ្ឈង្គទាំង ៧ ឱ្យបរិបូរណ៍"*** *ព្រោះវៀរការចម្រើនពោជ្ឈង្គចេញហើយក៏មិនមានការបរិបូរណ៍នៃការចម្រើនសតិប្បដ្ឋានឡើយ ។*

**"វិជ្ជាវិមុត្តី បរិបូរេន្តិ"** ពោជ្ឈង្គភាវនាយ តាសំ សិទ្ធាប្បត្តិភាវតោ។

*ឈ្មោះថា* ***"រមែងធ្វើវិជ្ជា និងវិមុត្តិឱ្យពេញបរិបូរណ៍"*** *ព្រោះវិជ្ជា (មគ្គ) និងវិមុត្តិ (ផល) ទាំងនោះ ជាសភាវៈធម៌ ដែលមានការដល់នូវកំពូល ក៏ដោយអាស្រ័យចម្រើនពោជ្ឈង្គ ។*

"**ចរិមកាន**"ន្តិ អន្តិមកានំ។

*ពាក្យថា "**ចរិមកា**" បានដល់ មានទីបំផុត ។*

## ចរិមក( មានទីបំផុត ) ៣ យ៉ាង

### ( វិសុទ្ធិមគ្គ )

[២៣៨] តត្ថ និរោធវសេន តយោ ចរិមកា ភវចរិមកា, ឈានចរិមកា, ចុតិចរិមកាតិ ។

*ក្នុងបណ្តាខ្យល់ដង្ហើមទាំងនោះ ដោយជាប់ទាក់ទងជាមួយសេចក្តីរលត់បាត់ ក៏ចាត់ជា* **ចរិមក**(*មានទីបំផុត*) *៣ យ៉ាង គឺ ១.* **ភវចរិមក**, *២.* **ឈានចរិមក** , *៣. និង* **ចុតិចរិមក** *។*

១. ភវេសុ ហិ កាមភវេ អស្សាសបស្សាសា បវត្តន្តិ, រូបារូបភវេសុ នប្បវត្តន្តិ, តស្មា តេ **ភវចរិមកា**។

*មែនពិត ក្នុងបណ្តាភពទាំងឡាយ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ រមែងប្រព្រឹត្តទៅក្នុងកាមភព, មិនប្រព្រឹត្តទៅក្នុងរូបភព និងអរូបភពទេ, ព្រោះហេតុនោះ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះ ទើបឈ្មោះថា* **ភវចរិមក** (*មានភពជាទីបំផុត*)*។*

២. ឈានេសុ បុរិមេ ឈានត្តយេ បវត្តន្តិ, ចតុត្ថេ នប្បវត្តន្តិ, តស្មា តេ **ឈានចរិមកា** ។

*ក្នុងបណ្តាឈានទាំងឡាយ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ រមែងប្រព្រឹត្តទៅក្នុងឈានទាំង ៣ នៅខាងដើម, មិនប្រព្រឹត្តទៅក្នុងឈានទី ៤ នោះ*

*ទេ (សម្រាប់ឈានដែលសុក្រឹត), ព្រោះហេតុនោះ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះ ទើបឈ្មោះថា* **ឈានចរិមកា** *(គឺមានឈានជាទីបំផុត)។*

**៣. យេ បន ចុតិចិត្តស្ស បុរតោ សោឡសមេន ចិត្តេន សទ្ធឹ ឧប្បជ្ជិត្វា ចុតិចិត្តេន សហ និរុជ្ឈន្តិ, ឥមេ ចុតិចរិមកា នាម។**

*ចំណែកខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញឯណា កើតឡើងព្រមជាមួយចិត្តដួងទី ១៦ នៅខាងមុខចុតិចិត្ត ហើយរលត់បាត់ទៅព្រមជាមួយចុតិ-ចិត្តនោះ,ខ្យល់ដង្ហើមចូលនិងខ្យល់ដង្ហើមចេញនេះឯង ឈ្មោះថា***ចុតិចរិមកា** ។

**ឥមេ ឥធ "ចរិមកា"តិ អធិប្បេតា។**

*ខ្យល់ដង្ហើមដែលឈ្មោះថា* **ចុតិចរិមកា** *(គឺមានចុតិជាទីបំផុត) នេះឯងជាខ្យល់ដង្ហើមដែលព្រះអង្គប្រាប្ថាសម្ដែងថា "ជា* **ចរិមកា**" *ក្នុងព្រះសូត្រនេះ ។*

**ឥមំ កិរ កម្មដ្ឋានំ អនុយុត្តស្ស ភិក្ខុនោ អានាបានារម្មណស្ស-សុដ្ឋុ បរិគ្គហិតត្តា ចុតិចិត្តស្ស បុរតោ សោឡសមស្ស ចិត្តស្ស ឧប្បាទ-ក្ខណេ ឧប្បាទំ អាវជ្ជតោ ឧប្បាទោបិ នេសំ បាកដោ ហោតិ។**

*បានស្ដាប់មកថា សម្រាប់យោគីភិក្ខុជាអ្នកតាមប្រកបកម្មដ្ឋាននេះ ព្រោះការដែលអារម្មណ៍ គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ អ្នកកំណត់កាន់យកបានយ៉ាងល្អហើយ កាលនឹកដល់ការកើតឡើងនៅត្រង់ឧបចារៈខណៈនៃចិត្តដួងទី ១៦ ខាងមុខនៃចុតិចិត្ត(ដែលជា១៧ខណៈ) សូម្បីការកើតឡើងរបស់ខ្យល់ទាំងនោះ ក៏ប្រាកដច្បាស់ ។*

**ឋិតឹ អាវជ្ជតោ ឋិតិបិ នេសំ បាកដា ហោតិ។ ភង្គំ អាវជ្ជតោ ច ភង្គោ នេសំ បាកដោ ហោតិ ។**

*កាលនឹកដល់ក៏តាំងនៅ សូម្បីការតាំងនៅរបស់ខ្យល់ទាំងនោះ ក៏ប្រាកដច្បាស់ ។ កាលនឹកដល់ ហើយក៏រលត់បាត់ទៅ សូម្បីការរលត់បាត់ទៅរបស់ខ្យល់ទាំងនោះ ក៏ប្រាកដច្បាស់ ។*

ឥតោ អញ្ញតរំ កម្មដ្ឋានំ ភាវេត្វា អរហត្តំ បត្តស្ស ភិក្ខុនោ ហិ អាយុអន្តរំ បរិច្ឆិន្នំ វា ហោតិ អបរិច្ឆិន្នំ វា ។

*មែនពិតព្រះយោគាវចរភិក្ខុអ្នកចម្រើនកម្មដ្ឋានដទៃក្រៅអំពីអានាបា-នស្សតិកម្មដ្ឋាននេះ ហើយ សម្រេចនូវព្រះអរហត្ត រមែងកំណត់ចន្លោះកាលនៃអាយុបានខ្លះ និងកំណត់មិនបានខ្លះ ។*

ឥមំ បន សោឡសវត្ថុកំ អានាបានស្សតឹ ភាវេត្វា អរហត្តំ បត្តស្ស អាយុអន្តរំ បរិច្ឆិន្នមេវ ហោតិ ។

*ប៉ុន្តែព្រះយោគាវចរភិក្ខុជាអ្នកចម្រើននូវអានាបានស្សតិ ដែលមានវត្ថុទាំង ១៦ យ៉ាងនេះ ហើយបានសម្រេចនូវព្រះអរហត្ត រមែងកំណត់ចន្លោះកាលនៃអាយុបានទាំងអស់យ៉ាងពិតប្រាកដ ។*

សោ "ឯត្តកំ ទានិ មេ អាយុសង្ខារា បវត្តិស្សន្តិ, ន ឥតោ បរ"ន្តិ ញត្វា អត្តនោ ធម្មតាយ ឯវ សរីរបដិជគ្គននិវាសនចារុបនាទីនិ សព្វកិច្ចានិ កត្វា អក្ខីនិ និមីលេតិ កោដបព្វតវិហារវាសីតិស្សត្ថេរោ វិយ មហាករញ្ជិយវិហារវាសីមហាតិស្សត្ថេរោ វិយ ទេវបុត្តមហារដ្ឋេ បិណ្ឌបាតិកតិស្សត្ថេរោ វិយ ចិត្តលបព្វតវិហារវាសិនោ ទ្វេ ភាតិយ-ត្ថេរា វិយ ច ។

*ព្រះយោគីភិក្ខុជាអ្នកចម្រើនអានាបានស្សតិ ហើយបានសម្រេចនូវព្រះអរហត្តនោះបានជ្រាបសេចក្ដីថា "ក្នុងកាលឥឡូវនេះ អាយុសង្ខាររបស់អាត្មាអញ នឹងប្រព្រឹត្តទៅអស់កាលមានប្រមាណត្រឹមតែប៉ុណ្ណេះ, នឹងមិនប្រព្រឹត្តទៅលើសជាងនេះឡើយ" ដូច្នេះហើយ ក៏ធ្វើកិច្ចទាំងឡាយ មានការជម្រះនូវរាងកាយ និងគ្រងដណ្ដប់ចីវរជាដើម ទៅតាមធម្មតារបស់ខ្លួនហ្នឹងឯង ហើយក៏បិទភ្នែក (ចូលកាន់ព្រះនិព្វានទៅ) ដូចជា ព្រះតិស្សត្ថេរ ជាអ្នកអាស្រ័យគង់នៅក្នុងកោដបព្វតវិហារ, ដូចជា ព្រះមហាតិស្សត្ថេរ ជាអ្នកគង់អាស្រ័យ*

*នៅក្នុងមហាករញ្ជិយវិហារ, ដូចជា ព្រះបិណ្ឌបាតិកតិស្សត្ថេរ ក្នុងទេវបុត្ររដ្ឋ និងដូចជា ព្រះថេរៈ ២អង្គ ត្រូវជាបងប្អូននឹងគ្នា ជាអ្នកមានប្រក្រតីគង់អាស្រ័យនៅក្នុងចិត្តលបព្វតវិហារ យ៉ាងដូច្នោះឯង។*

**តត្រិទំ ឯកវត្ថុបរិទីបនំ។**

*តទៅនេះ ជាការសម្ដែងរឿងរបស់ព្រះថេរៈមួយអង្គ ក្នុងចំណោមព្រះថេរៈទាំងពីរអង្គដែលជាបងប្អូននឹងគ្នានោះ ។*

**ទ្វេភាតិយត្ថេរានំ កិរេកោ បុណ្ណមុបោសថទិវសេ បាតិមោក្ខំ ឱសារេត្វា ភិក្ខុសង្ឃបរិវុតោ អត្តនោ វសនដ្ឋានំ គន្ត្វា ចង្កមេ ឋិតោ ចន្ទាលោកំ ឱលោកេត្វា អត្តនោ អាយុសង្ខារេ ឧបបរេត្វា ភិក្ខុសង្ឃ-មាហ –**

*មានរឿងថា ក្នុងចំណោមព្រះថេរៈបងប្អូនទាំងពីរព្រះអង្គនោះ មានព្រះថេរៈមួយអង្គ បន្ទាប់ពីធ្វើបាតិមោក្ខក្នុងថ្ងៃឧបោសថសីលព្រះចន្ទពេញវង់ចប់ហើយ មានភិក្ខុសង្ឃហែហមអមដំណើរ និមន្តទៅកាន់ទីជាទីនៅរបស់ខ្លួនរួចហើយបានឋិតនៅត្រង់ទីចង្រ្កម ក៏រមិលមើលនូវពន្លឺព្រះចន្ទ រួចហើយពិចារណានូវអាយុសង្ខាររបស់ខ្លួន ហើយប្រាប់ភិក្ខុសង្ឃថា ៖*

**"តុម្ហេហិ កថំ បរិនិព្វាយន្តា ភិក្ខូ ទិដ្ឋបុព្វា"តិ។**

*"តើគុណម្ចាស់ទាំងឡាយ បានធ្លាប់ឃើញព្រះភិក្ខុទាំងឡាយចូលកាន់ព្រះនិព្វាន ដោយអាការៈដូចម្ដេចខ្លះ ?" ។*

**តត្រ កេចិ អាហំសុ "អម្ហេហិ អាសនេ និសិន្នកាវ បរិនិព្វាយន្តា ទិដ្ឋបុព្វា"តិ ។**

*បណ្ដាព្រះភិក្ខុទាំងនោះ ភិក្ខុពួកខ្លះ បានពោលថា "ពួកខ្ញុំករុណាធ្លាប់បានឃើញភិក្ខុទាំងឡាយ ដែលអង្គុយលើអាសនៈហ្នឹងឯង ចូលកាន់ព្រះនិព្វាន" ។*

**កេចិ "អម្ហេហិ អាកាសេ បល្លង្កមាភុជិត្វា និសិន្នកា" តិ ។**

*ភិក្ខុពួកខ្លះ បានពោលថា "ពួកខ្ញុំករុណាធ្លាប់បានឃើញភិក្ខុទាំងឡាយ ដែលអង្គុយពែនភ្នែន នៅលើអាកាស ចូលកាន់ព្រះនិព្វាន" ។*

**ថេរោ អាហ – "អហំ ឍានិ វោ ចង្កមន្តមេវ បរិនិព្វាយមានំ ឧស្សេស្សាមី" តិ ។**

*ព្រះថេរៈ ពោលថា "ក្នុងកាលឥឡូវនេះ ខ្ញុំករុណានឹងសំដែងនូវភិក្ខុដែលកំពុងតែចង្ក្រមហ្នឹងឯង ចូលកាន់ព្រះនិព្វាន ដល់អ្នកទាំងឡាយ" ។*

**តតោ ចង្កមេ លេខំ កត្វា "អហំ ឥតោ ចង្កមកោដិតោ បរកោដឹ គន្ត្វា និវត្តមានោ ឥមំ លេខំ បត្វាវ បរិនិព្វាយិស្សាមី" តិ វត្វា ចង្កមំ ឱរុយ្ហ បរភាគំ គន្ត្វា និវត្តមានោ ឯកេន បាទេន លេខំ អក្កន្តក្ខណេយេវ បរិនិព្វាយិ ។**

*ក្នុងលំដាប់នោះ ព្រះថេរៈធ្វើនូវគំនូសត្រង់ទីចង្ក្រម ហើយពោលថា "ខ្ញុំករុណា នឹងដើរទៅកាន់ទីបំផុតនៅខាងមុខ អំពីទីបំផុតនៃទីចង្ក្រមនេះ រួចហើយកាលត្រឡប់មកវិញ គ្រាន់តែដល់នូវគំនូសនេះភ្លាម ខ្ញុំករុណានឹងចូលកាន់ព្រះនិព្វានភ្លាម" ធ្វើយ៉ាងនេះហើយ ក៏ចុះកាន់ទីចង្ក្រម ដើរទៅកាន់ចំណែកខាងនាយ កាលត្រឡប់មកវិញ ក៏ចូលកាន់ព្រះនិព្វានក្នុងខណៈដែលលោកជាន់នូវគំនូស ដោយជើងម្ខាងភ្លាមហ្នឹងឯង ។*

**តស្មា ហវេ អប្បមត្តោ, អនុយុញ្ជេថ បណ្ឌិតោ;**
**ឯវំ អនេកានិសំសំ, អានាបានស្សតឹ សទាតិ។**

*ព្រោះហេតុនុ៎ះឯង បណ្ឌិតគប្បីជាអ្នកមិនប្រមាទ ប្រកបរឿយៗ នូវអានាបានស្សតិ ដែលមានអានិសង្សច្រើនយ៉ាងនេះ សព្វៗកាល យ៉ាងនេះចុះ ។*

**ឥទំ អានាបានស្សតិយំ វិត្ថារកថាមុខំ ។**

*នេះជាកថាមុខ ពោលដោយពិស្តារ ក្នុងអានាបានស្សតិ ។*

## ចរិមក

### (មហាដីកាវិសុទ្ធិមគ្គ)

[២៣៨] "**និរោធវសេនា**"តិ និរុជ្ឈនវសេន។ "**ភវចរិមកា**"តិ ភវវសេន ចរិមកា និហីនភវបវត្តិនោ ។

*បទថា "និរោធវសេន" ប្រែថា ដោយជាប់ទាក់ទងជាមួយការរលត់បាត់ ។ ពាក្យថា "ភវចរិមក" បានដល់ មានទីបំផុត ដោយជាប់ទាក់ទងជាមួយភព គឺមានការប្រព្រឹត្តទៅក្នុងភពជាន់ទាប ។*

តថា **ឈានចរិមកា** វេទិតព្វា។ "**ចុតិចរិមកា**"តិ ចុតិយា ចរិមកា ចុតិក្ខណាបវត្តិនោ សព្វបរិយោសានកា ។

*គប្បីជ្រាប* **ឈានចរិមក** *ដោយន័យសេចក្តី ដូចគ្នានោះ ។ ពាក្យថា* "**ចុតិចរិមក**" *បានដល់ មានទីបំផុតដោយការចុតិ គឺខ្យល់ដង្ហើមដែលមានការប្រព្រឹត្តិទៅជិតខណៈចុតិ ជាខ្យល់ដង្ហើមគ្រាចុងក្រោយរបស់ខ្យល់ទាំងអស់ ។*

"**តស្មា**"តិ តីសុ ភវេសុ និហីនេ កាមភវេ បវត្តនតោ។ "**តេ**"តិ អស្សាសបស្សាសា ។

*ពាក្យថា* "**ព្រោះហេតុនោះ**" *គឺព្រោះក្នុងបណ្តាភពទាំង ៣ មានការប្រព្រឹត្តទៅក្នុងភពជាន់ទាប គឺកាមភព (ទើបឈ្មោះថា* **ភវចរិមក**) *។ បទថា* "**តេ**" *យោគ អស្សាសបស្សាសា ប្រែថា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ។*

"**បុរតោ**"តិ ហេដ្ឋា។

*ពាក្យថា "**ខាងមុខ (ចុតិចិត្ត)**" បានដល់ មុនខាងមុខ ។*

**យស្មា វិភង្គដ្ឋកថាយំ**(៧១) រូបជម្មានំ សោឡសចិត្តក្ខណាយុកតា វិភាវិតា, តស្មា "**សោឡសមេន ចិត្តេន សទ្ធឹ ឧប្បជ្ជិត្វា**"តិ វុត្តំ ។

*ព្រោះហេតុដែលលោកបានចែងទុក **ក្នុងអដ្ឋកថាព្រះវិភង្គ**ហើយថា រូបធម៌ទាំងឡាយមានអាយុស្មើ ១៦ ខណៈចិត្ត, ដូច្នោះ លោកទើបហៅថា "**កើតឡើងព្រមជាមួយចិត្តដួងទី ១៦**" ដូច្នេះ ។*

"**ចុតិចិត្តស្ស បុរតោ**"តិ វា ចុតិចិត្តំ អវធិភាវេន គហេត្វា តតោ ឱរំ សោឡសមេន ចិត្តេន សទ្ធឹ ឧប្បជ្ជិត្វាតិ ឯវំ បន អត្ថេ គយ្ហមានេ សត្តរសចិត្តក្ខណាយុកតាវ អស្សាសបស្សាសានំ វុត្តា ហោតិ ។

*ន័យមួយទៀត ពាក្យថា "**ខាងមុខចុតិចិត្ត**" បានសេចក្តីថា លោកកាន់យកចុតិចិត្តជាខេត្តដែន ពោលថា កើតឡើងព្រមជាមួយចិត្តដួងទី ១៦ រាប់ថយក្រោយមកអំពីចុតិចិត្តនោះ ដូច្នេះ កាលកាន់យកសេចក្តីយ៉ាងនេះ ក៏ពោលបានថា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ មានអាយុស្មើជាមួយ ១៧ ខណៈចិត្ត ។*

ឥមេ កិរ ឥមំ កម្មដ្ឋានំ អនុយុត្តស្ស ភិក្ខុនោ ចាកដា ហោន្តីតិ អានេត្វា សម្ពន្ធោ ។

*គប្បីនាំបទចូលមកភ្ជាប់សេចក្តីជាមួយថា* **ឥមេ កិរ ឥមំ កម្មដ្ឋានំ អនុយុត្តស្ស ភិក្ខុនោ ចាកដា ហោន្តិ** *ដូច្នេះផងចុះ ។*

តត្ថ ការណមាហ "**អាជាចាជារម្មណស្ស សុដ្ឋុ បរិគ្គហិតត្តា**"តិ។

*ក្នុងបណ្តាបទទាំងនោះ លោកពោលដល់ហេតុទុកថា "**ព្រោះការដែលអារម្មណ៍ គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ អ្នកកំណត់កាន់យកបានយ៉ាងល្អហើយ**" ដូច្នេះ ។*

*៧១ (វិភ. អដ្ឋ. ២៦ បកិណ្ណកកថា) ។*

តមេវត្ថំ វិភាវេតុំ "**ចុតិចិត្តស្ស**"តិអាទិ វុត្តំ។

*ប្រាថ្នានឹងបើកបង្ហាញនូវសេចក្ដីនោះ នុ៎ះឯង ទើបលោកពោលថា "**ចុតិចិត្តស្ស**" ដូច្នេះជាដើម ។*

តត្ថ **អាយុអន្តរំ** នាម ជីវិតន្តរំ ជីវនក្ខណាវធិ។ "**ធម្មតាយ ឯវ**"តិ សភាវេនេវ, រុចិវសេនេវាតិ អត្ថោ ។

*ក្នុងបណ្ដាបទទាំងនោះ ឈ្មោះថា **ចន្លោះកាលនៃអាយុ** បានដល់ ចន្លោះនៃជីវិត គឺព្រំដែននៃខណៈចិត្តកំពុងមានជីវិតរស់នៅ ។ ពាក្យថា "តាមធម្មតានោះឯង" គឺតាមប្រក្រតីនោះឯង, សេចក្ដីថា តាមការពេញចិត្តនុ៎ះឯង។*

"**ចន្ទាលោកំ ឱលោកេត្វា**"តិ ជុណ្ហបក្ខេ បទោសវេលាយំ សមន្តតោ អាសិញ្ចមានខីរធារំ វិយ គគនតលំ, រជតបត្តសទិសវាលិកា-សន្ថតញ្ច ភូមិភាគំ ទិស្វា "រមណីយោ វតាយំ កាលោ, ទេសោ ច មម អជ្ឈាសយសទិសោ, កីវ ចិរំ នុ ខោ អយំ ទុក្ខភារោ វហិតព្វោ"តិ អត្តនោ អាយុសង្ខារេ ឧបធារេត្វា បរិក្ខីណោតិ អធិប្បាយោ ។

*ពាក្យថា "**រមិលមើលនូវពន្លឺនៃព្រះចន្ទ**" អធិប្បាយថា ក្នុងវេលាពេលព្រលប់នាខាងខ្នើត ឃើញផ្ទៃមេឃដូចជាមានធារទឹកដោះ ស្រោចស្រពនៅជុំវិញទិស, និងឃើញភូមិភាគ ដែលដេរដាសដោយវាលខ្សាច់ស ដូចជាក្រាលដោយផែនប្រាក់ ក៏គិតថា "វេលា និងស្ថានទីនេះគួរមនោរម្យហ្ន៎! ត្រូវអធ្យាស្រ័យរបស់យើង, យើងនឹងត្រូវទទួលភារៈ គឺសេចក្ដីទុក្ខនេះនៅយូរប៉ុនណាទៀតហ្ន៎" ដូច្នេះ រឭកមើលអាយុសង្ខាររបស់ខ្លួនឯង លោកជ្រាបសេចក្ដីថា អស់រលីងហើយ ។*

"**លេខំ កត្វា**"តិ ចង្កមេ តិរិយំ លេខំ កត្វា។

*ពាក្យថា "**ធ្វើស្នាមគំនូសទុក**" គឺធ្វើស្នាមគំនូសទុកលើទីចង្ក្រម គឺកាត់ផ្លូវចង្ក្រម ។*

**"អនុយុញ្ជថា"**តិ អនុយុញ្ជេយ្យ, ភាវេយ្យាតិ អត្ថោ។

*បទថា "**អនុយុញ្ជថ**" ប្រែថា គប្បីប្រកបរឿយៗ, មានសេចក្តីថា គប្បីចម្រើន ។*

**អានាបានស្សតិនិទ្ទេសវណ្ណនា និដ្ឋិតា ។**

*ការពណ៌នា អានាបានស្សតិនិទ្ទេស ចប់ហើយដោយបការៈដូច្នេះ ។*

*ចប់ មហាដីកា ដោយបរិបូរណ៍ ។*

*ថ្ងៃសៅរ៍ ៨រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨*

*ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤*

*ភិក្ខុ ឋានវរោ សួស ប៊ុនថន*

## ធម៌បដិបក្ខគ្នា

| អង្គឈាន៥ | នីវរណធម៌៥ |
|---|---|
| វិតក្កៈ | ថីនមិទ្ធៈ |
| វិចារៈ | វិចិកិច្ឆា |
| បីតិ | ព្យាបាទៈ |
| សុខៈ | ឧទ្ធច្ចកុក្កុច្ចៈ |
| ឯកគ្គតា | កាមច្ឆន្ទៈ |

## ពាក្យថានិមិត្ត មាន ៤ ប្រភេទ

១. ពាក្យថា **និមិត្ត** គឺសតិនៅត្រង់ចុងច្រមុះ ។

២. ពាក្យថា **បរិកម្មនិមិត្ត** គឺការកំណត់ដឹងខ្យល់ចូល ចេញពី១ ដល់១០ ឬ ៨, និងការកំណត់ដឹងខ្យល់ចូលចេញ តែម្យ៉ាង ។

៣. ពាក្យថា **ឧគ្គហនិមិត្ត** គឺពន្លឺដែលកើតចេញ បន្ទាប់ពីសតិបានកំណត់ដឹងខ្យល់ចូលចេញបានល្អហើយ តែពន្លឺនោះនៅមិនទាន់បានតាំងមាំល្អទេ ។

៤. ពាក្យថា **បដិភាគនិមិត្ត** គឺពន្លឺដែលកើតចេញ បន្ទាប់ពីសតិបានកំណត់ដឹងខ្យល់ចូលចេញបានល្អហើយ ហើយពន្លឺនោះឯងបានតាំងមាំល្អណាស់ ។

## ពាក្យថា និមិត្ត

**និមិត្តំ អស្សាសបស្សាសា អនារម្មណមេកចិត្តស្ស ជានតោ ច តយោធម្មេ ភាវនា ឧបលព្ភតីតិ។**

កាលយោគីភិក្ខុបានស្គាល់នូវធម៌៣ប្រការ គឺនិមិត្ត (គឺសតិនៅត្រង់ចុងច្រមុះឬផ្ទៃបបូរមាត់ខាងលើ)១, ខ្យល់ដង្ហើមចូល១, និងខ្យល់ដង្ហើមចេញ១

ដែលមិនមែនជាអារម្មណ៍របស់ចិត្តមួយដួងទេ ការដឹងបែបនេះភាវនារមែង ចម្រើន ។

ពាក្យថានិមិត្តនៅទីនេះសំដៅយកត្រង់ចុងច្រមុះឬផ្ទៃបបូរមាត់ខាងលើ ដែលបាលីថា **ឆាសិកគ្គេ វា មុខនិមិត្តេ វា**។

## បរិកម្មនិមិត្តមាន ៤ លំដាប់

### លំដាប់ទី ១

- កំណត់ដឹងខ្យល់ចូល ចេញ រាប់ថា ១
- កំណត់ដឹងខ្យល់ចូល ចេញ រាប់ថា ២
- កំណត់ដឹងខ្យល់ចូល ចេញ រាប់ថា ៣
- កំណត់ដឹងខ្យល់ចូល ចេញ រាប់ថា ៤
- កំណត់ដឹងខ្យល់ចូល ចេញ រាប់ថា ៥
- កំណត់ដឹងខ្យល់ចូល ចេញ រាប់ថា ៦
- កំណត់ដឹងខ្យល់ចូល ចេញ រាប់ថា ៧
- កំណត់ដឹងខ្យល់ចូល ចេញ រាប់ថា ៨

រួចហើយចាប់ផ្តើមរាប់តាំងពីលេខ ១ ដល់លេខ ៨ ឡើងវិញ បើសិន នៅពេលណាមួយបានកំណត់ដឹងនូវខ្យល់ទាន់បានល្អហើយ បើអាចមកកំណត់ ដឹងនូវលំដាប់ទីពីរបាន ពេលនោះគប្បីមកកំណត់ចុះ ។

### លំដាប់ទី ២

- កំណត់ដឹងខ្យល់ចូល រាប់ថា ១
- កំណត់ដឹងខ្យល់ចេញ រាប់ថា ២
- កំណត់ដឹងខ្យល់ចូល រាប់ថា ៣
- កំណត់ដឹងខ្យល់ចេញ រាប់ថា ៤

- កំណត់ដឹងខ្យល់ចូល រាប់ថា ៥
- កំណត់ដឹងខ្យល់ចេញ រាប់ថា ៦
- កំណត់ដឹងខ្យល់ចូល រាប់ថា ៧
- កំណត់ដឹងខ្យល់ចេញ រាប់ថា ៨

រួចហើយចាប់ផ្ដើមរាប់តាំងពីលេខ ១ ដល់លេខ ៨ ម្ដងទៀត ធ្វើបែបនេះរឿយៗ រហូតសតិអាចកំណត់ដឹងនូវខ្យល់ចូល ចេញបានទាន់ខ្យល់ដែលមិនអាចរាយមាយ ឬក៏មានការរាយមាយតិចបំផុត ពេលនោះគប្បីមកកំណត់នូវចំណុចទីបីចុះ ។

## លំដាប់ទី ៣

កំណត់ដឹងខ្យល់ចូល. ចេញ តែម្យ៉ាង ដោយតាំងសតិនៅត្រង់ចុងច្រមុះតែមួយ បើមានពួកឧគ្គហនិមិត្ត ឬក៏បដិភាគនិមិត្តកើតឡើង ក៏គប្បីរក្សាសតិនៅត្រង់ចុងច្រមុះដដែល ហើយកំណត់ដឹងខ្យល់ចូល ចេញ ធ្វើបែបនេះដើម្បីទុកឱ្យពួកនិមិត្តទាំងនោះមានកម្លាំងកាន់តែខ្លាំង នៅពេលបដិភាគនិមិត្តមានកម្លាំងល្អហើយ ពេលនោះគប្បីមកនៅត្រង់ចំណុចទីបួនចុះ ប៉ុន្តែបើសិននិមិត្តទាំងនោះមិនទាន់មានទេ ហើយការកំណត់ដឹងនូវខ្យល់ដង្ហើមក៏មិនទាន់បានល្អ ពេលនោះគប្បីទៅនៅត្រង់ចំណុចទីពីរ ពេលណាអាចកំណត់ទាន់ហើយមកត្រង់ទីបី ចម្រើនបែបនេះដើម្បីរក្សាសតិឱ្យនៅជាមួយខ្យល់ល្អិតឱ្យបាន ហើយកុំឱ្យមានភាពរាយមាយឡើយ ។

## លំដាប់ទី ៤

នៅត្រង់ចំណុចទីបួននេះ គឺដឹងខ្យល់ចូល ចេញ រួចហើយបណ្ដោយវិថីចិត្តដឹងខ្យល់ចូល ចេញតែម្យ៉ាងនៅជាមួយពន្លឺបដិភាគនិមិត្តនោះចុះ ពេលណាពន្លឺបានធ្លាក់ចុះ ពេលនោះគប្បីទៅនៅជាមួយចំណុចទីបីវិញ ដើម្បីឱ្យពន្លឺ

មានកម្លាំងភ្លឺមកវិញ រួចហើយមកនៅជាមួយចំណុចទីបួនវិញ ធ្វើបែបនេះទៅរឿយៗតាមជាក់ស្តែងរបស់កម្មដ្ឋាន ។

## ឧគ្គហនិមិត្ត និងបដិភាគនិមិត្តមាន១៧ ប្រភេទ

១. ប៉ុន្តែ អង្គខ្លះ ក៏ប្រាកដដូចជាប៉ុយគរ (នេះជាឧគ្គហនិមិត្ត) ។

២. អង្គខ្លះ ក៏ប្រាកដដូចជាប៉ុយកប្បាស (នេះជាឧគ្គហនិមិត្ត) ។

៣. អង្គខ្លះ ក៏ប្រាកដដូចជាខ្សែខ្យល់ បែបនេះក៏មាន ដែលញុំាងសេចក្តីសុខសម្ផស្សឱ្យកើតឡើងដូច្នេះ (នេះជាឧគ្គហនិមិត្ត) ។

៤. ក៏ប្រាកដដូចជារូបផ្កាយ (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត) ។

៥. អ្នកខ្លះដូចជាដុំកែវមណី (នេះជាបដិភាគនិមិត្ត) ។

៦. អ្នកខ្លះដូចជាដុំកែវមុក្តា (នេះជាបដិភាគនិមិត្ត) ។

៧. សម្រាប់អ្នកខ្លះ ប្រាកដដូចជារបស់ដែលមានសម្ផស្សគ្រោតគ្រាត ដូចគ្រាប់កប្បាស (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត) ។

៨. និងដូចជាទេុកឈើដែលមានខ្លឹម បែបនេះក៏មាន (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត) ។

៩. សម្រាប់អង្គខ្លះ ប្រាកដដូចជាខ្សែសង្វារវែង (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត)។

១០. អ្នកខ្លះដូចជាកម្រងផ្កា (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត)។

១១. និងដូចជាកម្សួលផ្សែងឬអណ្តាតផ្សែងហុយឡើង (នេះជាឧគ្គហ-និមិត្ត និងជាបដិភាគនិមិត្ត)។

១២. សម្រាប់អង្គខ្លះ ក៏ប្រាកដដូចជាសរសៃពីងពាង ដែលលាតសន្ធឹងរួចហើយ (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត)។

១៣. អ្នកខ្លះដូចជាដុំឬផ្ទាំងពពក (នេះជាឧគ្គហនិមិត្ត និងជាបដិភាគ-និមិត្ត)។

១៤. ដូចជាផ្កាឈូក (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត)។

១៥. ដូចជាកង់នៃរថ (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត)។

១៦. ដូចជាមណ្ឌលវង់របស់ព្រះចន្ទ (នេះជាឧគ្គហនិមិត្ត និងជាបដិភាគ-និមិត្ត)។

១៧. និងដូចជាមណ្ឌលវង់ របស់ព្រះអាទិត្យបែបនេះក៏មាន (នេះជាឧគ្គហនិមិត្ត និងជាបដិភាគនិមិត្ត) ។

## សមាធិមាន ៣ ប្រភេទ

១. បរិកម្មសមាធិ

២. ឧបចារសមាធិ

៣.អប្បនាសមាធិ ឬហៅថា ឈានសមាធិ

(ខណិកសមាធិនេះ លោកហៅសម្រាប់នៅក្នុងវិបស្សនា ព្រោះវិបស្សនាអត់មានឧបចារសមាធិ និងអប្បនាសមាធិទេ ប៉ុន្តែនៅក្នុងសមថៈ គឺមានឧបចារសមាធិ និងអប្បនាសមាធិ ខុសគ្នាបែបនេះឯង) ។

អារម្មណ៍របស់បរិកម្មសមាធិ អាចជាបរិកម្មនិមិត្ត ឬឧគ្គហនិមិត្ត និងបដិភាគនិមិត្តម្តងកាល ។

## សង្ខេបមាន ៤ ចំណុច

## ទី ១

**សោ សតោវ អស្សសតិ, សតោ បស្សសតិ ។**

*ព្រះយោគាវចរភិក្ខុនោះ ជាអ្នកមានសតិស្មារតីតម្កល់ (នៅត្រង់ចុងច្រមុះ ឬក៏ផ្ទៃបបូរមាត់ខាងលើ) ខណៈដកដង្ហើមចូល កំណត់ដឹងថាចូល, ជាអ្នកមានសតិស្មារតីតម្កល់ (នៅត្រង់ចុងច្រមុះ ឬក៏ផ្ទៃបបូរមាត់ខាងលើ) ខណៈដកដង្ហើមចេញ កំណត់ដឹងថាចេញ ។*

## ទី ២

**១. ទីឃំ វា អស្សសន្តោ "ទីឃំ អស្សសាមី"តិ បជានាតិ ។**

*ព្រះយោគាវចរភិក្ខុនោះ កាលដកដង្ហើមចូលវែង ក៏កំណត់ដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចូលវែង" ។*

**ទីឃំ វា បស្សសន្តោ "ទីឃំ បស្សសាមី"តិ បជានា"តិ ។**

*កាលដកដង្ហើមចេញវែង ក៏កំណត់ដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចេញវែង" ។*

**២. រស្សំ វា អស្សសន្តោ "រស្សំ អស្សសាមី"តិ បជានាតិ។**

*កាលដកដង្ហើមចូលខ្លី ក៏កំណត់ដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចូលខ្លី" ។*

**រស្សំ វា បស្សសន្តោ "រស្សំ បស្សសាមី"តិ បជានាតិ។**

*កាលដកដង្ហើមចេញខ្លី ក៏កំណត់ដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចេញខ្លី" ។*

## ទី ៣

**៣. "សព្វកាយប្បដិសំវេទី អស្សសិស្សាមី"តិ សិក្ខតិ។**

*ភិក្ខុរមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងឱ្យជាក់ច្បាស់នូវកាយ គឺខ្យល់ដង្ហើមចូលទាំងអស់ ជាចំណែកៗដោយល្អ (គឺខាងដើម កណ្តាល*

*និងខាងចុងរបស់ខ្យល់) ក្នុងខណៈដកដង្ហើមចូល" ។*

**"សព្វកាយប្បដិសំវេទី បស្សសិស្សាមី"តិ សិក្ខតិ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងឱ្យជាក់ច្បាស់នូវកាយ គឺខ្យល់ដង្ហើមចេញទាំងអស់ ជាចំណែកៗដោយល្អ (គឺខាងដើម កណ្ដាល និងខាងចុងរបស់ខ្យល់) ក្នុងខណៈដកដង្ហើមចេញ" ។*

## ទី ៤

**៤. "បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមី"តិ សិក្ខតិ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកធ្វើកាយសង្ខារគឺខ្យល់ដង្ហើមដែលគ្រោតគ្រាតៗ ឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចូល ។*

**"បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមី"តិ សិក្ខតិ។**

*រមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកធ្វើកាយសង្ខារគឺខ្យល់ដង្ហើមដែលគ្រោតគ្រាតៗ ឱ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចេញ" ។*

## ចំណុចសំខាន់របស់សមាធិមាន ៣ យ៉ាង

១. *ស្គាល់ទីតាំងរបស់សមាធិ ។*

២. *ស្គាល់អារម្មណ៍របស់សមាធិ ។*

៣. *ប្រើបញ្ញាក្នុងការរក្សាកម្មដ្ឋាន ។*

# ឯកសារយោង

១. បាលីឆដ្ឋសង្គាយនា លើកទី ៦ ។

២. ព្រះត្រៃបិដកបាលី និងប្រែជាភាសាខ្មែរ ភាគទី ១៧,២៦, ៧០ ។

៣. អដ្ឋកថា សទ្ធម្មបកាសិនី បាលី ប្រែ ។

៤. គម្ពីរវិសុទ្ធិមគ្គ បាលី ប្រែ ។

៥. គម្ពីរបរមត្ថមញ្ជុសា វិសុទ្ធិមគ្គមហាដីកា បាលី ប្រែ ។

៦. បទានុក្រមបាលី ប្រែភាសាខ្មែរ ។

៧. វចនានុក្រមខ្មែរ សម្តេច ជោតញ្ញាណោ ជួន ណាត ។

**សមាធឹ ភិក្ខវេ ភាវេថ, សមាហិតោ**

**ភិក្ខវេ ភិក្ខុ យថាភូតំ បជានាតិ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចម្រើនសមាធិ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុដែលមានចិត្តតម្កល់មាំមួនហើយ រមែងឃើញតាមសភាវៈពិត ។

( បិដក ៣៩/២២៦ )

**ន សមាធិ បរោ អត្ថិ　　អស្មឹ លោកេ បរម្ហិ ច**

**ន បរំ នាបិ អត្តានំ　　វិហឹសតិ សមាហិតោ ។**

ក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី មិនមានធម៌ដទៃ ប្រសើរជាងសមាធិឡើយ

( ព្រោះ ) បុគ្គលអ្នកតាំងនៅក្នុងសមាធិហើយ រមែងមិនបៀតបៀន

បុគ្គលដទៃផង មិនបៀតបៀនខ្លួនឯងផង ។

( បិដក ៥៨/២១៨ )

**នត្ថិ ឈានំ អបញ្ញស្ស　　បញ្ញា នត្ថិ អឈាយតោ**

**យម្ហិ ឈានញ្ច បញ្ញា ច　　ស វេ និព្វានសន្តិកេ ។**

ឈាន រមែងមិនមានដល់អ្នកមិនមានបញ្ញា

បញ្ញា រមែងមិនមានដល់អ្នកមិនមានឈាន

ឈានផង និង បញ្ញាផង មានក្នុងបុគ្គលណា

បុគ្គលនោះឯងនៅជិតនៃព្រះនិព្វាន ។ ( បិដក ៥២/១០០ )

**ឈាយថានន្ទ មា បមាទត្ថ  មា បច្ឆា វិប្បដិសារិនោ**

**អហុវត្ថ អយំ វោ  អម្ហាកំ អនុសាសនី ។**

ម្នាលអានន្ទ អ្នកទាំងឡាយ ចូរចម្រើនឈាន ចូរកុំប្រមាទ ចូរកុំមានសេចក្តី

ស្តាយក្រោយ ក្នុងកាលជាខាងក្រោយឡើយ នេះជាពាក្យប្រៀនប្រដៅ

របស់តថាគតចំពោះអ្នកទាំងឡាយ  ។ ( បិដក ២៦/១៥២ )